# អដ្ឋកថា បបញ្ចសូទនី

## នៃព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មូលបណ្ណាសក

## លេខ ២០ ភាគ ២

ពុទ្ធសករាជ ២៥៤៧

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មូលបណ្ណាសក

## ទុតិយភាគ

## ភាគ ២០

ឈ្មោះ

# បបញ្ចសូទនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

សម្មាទិដ្ឋិ.សតិបដ្ឋាន.ចូឡសីហនាទ.មហាសីហនាទ.មហាទុក្ខក្ខន្ធ.ចូឡទុក្ខក្ខន្ធ.អនុមាន.ចេតោខិល.វនបត្ថបរិយាយ.មធុបិណ្ឌិក.ទ្វេធាវិតក្ក.វិតក្កសណ្ឋាន

# ស្រៈនិសូ៉យ

# *Signes et accents:*



# ស្រះពេញតួ
# *Voyelles:*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឡូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

## Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| ឡាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| Krman | ꨆ | ꨇ | ꨈ | ꨉ | ꨋ |

D

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| រ៉ូម Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| លង្កា Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត | ថ | ទ | ធ | ន |
| រូម [illegible] | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| ឡាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| សឹង្ហ Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

# G

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រ៉ូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຟ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| CAMBODGIEN | យ | រ | ល | វ | ស | ហ | ឡ | ំ | ។ |
| Romain | y | r | l | v | s | h | ḷ | ṃ | ·/. |
| Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

*ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី*

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣ អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

**៤ អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ  ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ  សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌  ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិចត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណី បាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្អក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវយ៉ាងណា

ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ងាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ កទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធ-សាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសព្ទត់រហូតសកលជម្ពូទីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទី ពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេច បដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាង ត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍ នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍ នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរ ត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយ អធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុង ព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនា បករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថា ឈ្មោះ អដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត (ឈ្មោះដូចអគ្គសាវក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធ-ទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុដៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញវេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយនមស្ការព្រះពុទ្ធឃោសៈនិមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ:ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សន្ដាយនា

ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរិយ: ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

*ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។*

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសះ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបោរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

| | |
|---|---|
| ឧបាសក ភ្លាត ហ៊ិន | ឧបាសក នាក់ ម៉ៅ |
| ឧបាសក ឆុំ ឆួន | ឧបាសក ហុក សឹងហួត |
| ឧបាសក ជឹម ជំនិត | ឧបាសក កើត ឆិត្យ |
| ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន |
| ឧបាសក អ៊ឹម អ៊ែយ៉ា | ឧបាសក សុក្រ ហ៊ិត |
| ឧបាសក សំ ឆាយ | ឧបាសិកា ថាប់ លៀម |
| ឧបាសិកា ហាយ សារ៉ាត់ | ឧបាសិកា ប៊ុត សុម៉ាលី |
| ឧបាសិកា យស សម្បត្តិ | ឧបាសិកា ពូ ហ៊ាង |

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអត្ថទិន្នោ នូវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុធម្មប្បញ្ញោ ឆុំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

ព្រះភិក្ខុយន្តទិន្នោ ផល សុភ័ណ សមណសិស្ស សាលាសតិប្បដ្ឋាន

ព្រះភិក្ខុបវរធម្មោ អ៊ុល សុធា សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ អគ្គកាមោ អ៊ឹម សុជាន សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ចាន់ បូណា សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

ឧបាសក ក្លាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទូន ឧបាសក ហុក សឹងហួត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| **អដ្ឋកថា សម្មាទិដ្ឋិសូត្រ ទី៩** | ១ |
| អធិប្បាយ សម្មាទិដ្ឋិ | ១ |
| អធិប្បាយ បាណាតិបាត | ៦ |
| អធិប្បាយ អទិន្នាទាន | ៨ |
| អធិប្បាយ កាមេសុមិច្ឆាចារ | ៩ |
| អធិប្បាយ មុសាវាទ | ១១ |
| អធិប្បាយ បិសុណាវាទ | ១៣ |
| អធិប្បាយ ផរុសវាទ | ១៤ |
| អធិប្បាយ សម្ផប្បលាប | ១៥ |
| អធិប្បាយ អភិជ្ឈា-ព្យាបាទ | ១៦ |
| អធិប្បាយ មិច្ឆាទិដ្ឋិ | ១៧ |
| វិនិច្ឆ័យដោយអាការ ៥ យ៉ាង | ១៨ |
| អធិប្បាយ អកុសលមូល | ១៩ |
| អធិប្បាយ អកុសលកម្មបថ-វិរតិ ៣ | ២១ |
| និទានដោយសម្បត្តវិរតិ | ២២ |
| និទានដោយសមាទានវិរតិ-សមុច្ឆេទវិរតិ-កុសលកម្មបថ | ២៣ |
| វិនិច្ឆ័យដោយអាការ ៥ យ៉ាង | ២៤ |
| អរិយសច្ចក្នុងកម្មបថ | ២៦ |
| ភិក្ខុទាំងឡាយអនុមោទនាភាសិតរបស់ព្រះសារីបុត្ត | ២៩ |
| កថាពណ៌នា អាហារវារៈ | ៣០ |
| កវឡិង្ការាហារ | ៣២ |
| ផស្សាហារ , មនោសញ្ចេតនាហារ , វិញ្ញាណាហារ | ៣៤ |

ភ័យក្នុងអាហារ ៤ ៣៨
ការប្រៀបធៀប ស្វាមីភរិយាស៊ីសាច់កូន ៤១
ការប្រៀបធៀប មេគោត្រូវពន្លះស្បែក ៤៣
ការប្រៀបធៀប រណ្ដៅរងើកភ្លើង , ចាក់ដោយលំពែង ៤៤
តណ្ហាកើត អាហារទើបកើត ៤៧
តណ្ហារលត់ អាហារទើបរលត់ ៤៨
កថាពណ៌នា សច្ចវារៈ ៥០
កថាពណ៌នា ជរាមរណវារៈ ៥១
កថាពណ៌នា ជរា ២ យ៉ាង ៥៣
កថាពណ៌នា ជាតិវារៈ ៥៨
កថាពណ៌នា ភវវារៈ ៦០
កថាពណ៌នា តណ្ហាវារៈ ៦៤
កថាពណ៌នា វេទនាវារៈ ៦៧
កថាពណ៌នា ផស្សវារៈ ៦៩
កថាពណ៌នា សឡាយតនវារៈ ៧០
កថាពណ៌នា នាមរូបវារៈ ៧១
កថាពណ៌នា វិញ្ញាណវារៈ ៧៣
កថាពណ៌នា សង្ខារវារៈ ៧៤
កថាពណ៌នា អវិជ្ជាវារៈ ៧៥
កថាពណ៌នា អាសវវារៈ ៧៨

**អដ្ឋកថា សតិប្បដ្ឋានសូត្រ ទី ១០** ៨១
ហេតុដូចម្ដេច ទើបព្រះអង្គត្រាស់សម្ដែងសតិប្បដ្ឋាន ៨៧
សត្វសេកចម្រើនសតិប្បដ្ឋាន ៨៩

| | |
|---|---|
| អត្ថនៃពាក្យថា ឯកាយនៈ | ៩០ |
| សិស្ស និង អាចារ្យសន្ទនាគ្នា | ៩៣ |
| អធិប្បាយមគ្គ | ៩៥ |
| ព្រះថេរៈគប់បំបាក់ជើង | ៩៨ |
| ភិក្ខុសម្រេចព្រះអរហន្តក្នុងមាត់ខ្លា | ៩៩ |
| ព្រះថេរៈត្រូវចាក់ដោយលំពែង | ១០១ |
| សក្កទេវរាជចុតិ , ទេវតាធ្លាក់នរក | ១០៣ |
| អធិប្បាយស័ព្ទថា យទិទំ , សតិប្បដ្ឋាន | ១០៣ |
| ហេតុដែលត្រាស់សតិប្បដ្ឋាន ៤ យ៉ាង | ១១២ |
| មតិរបស់អដ្ឋកថា | ១១៥ |
| អត្ថនៃពាក្យថា ភិក្ខុ | ១១៧ |
| អធិប្បាយពាក្យថា កាយ | ១១៨ |
| ពិចារណាកាយ | ១២០ |
| អធិប្បាយបទ អាតាបី សតិមា សម្បជានោ | ១២៤ |
| អធិប្បាយបទ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ | ១២៥ |
| អធិប្បាយបទ អនុបស្សី | ១២៩ |
| អធិប្បាយ វេទនានុបស្សនា | ១៣១ |
| សមាធិ ៤ | ១៣៥ |
| ឧបមា ចិត្តដូចជាកូនគោ | ១៣៦ |
| ទ្រង់ប្រៀបភិក្ខុ ដូចជាខ្លាដំបង | ១៣៩ |
| ចម្រើនអានាបានស្សតិ | ១៤០ |
| អរិយសច្ច ៤ ក្នុងអានាបានៈ | ១៤៤ |
| ពិចារណាកាយដោយឥរិយាបថ ៤ | ១៤៦ |
| វាយោធាតុកើតអំពីចិត្ត | ១៤៧ |

អរិយសច្ចក្នុងឥរិយាបថ ១៥០
ពិចារណាកាយដោយសម្បជញ្ញៈ ៤ ១៥២
សាត្ថកសម្បជញ្ញៈ ១៥៣
សប្បាយសម្បជញ្ញៈ ១៥៤
រឿងភិក្ខុកំលោះ ១៥៥
គោចរសម្បជញ្ញៈ ១៥៦
ភិក្ខុនាំទៅ មិននាំទ្រឡប់ ១៥៧
ភិក្ខុមិននាំទៅ មិននាំត្រឡប់ ១៦០
ភិក្ខុនាំទៅ នាំត្រឡប់ ១៦១
រឿងមហាបុស្សទេវត្ថេរ ១៦៣
រឿងព្រះមហានាគត្ថេរ ១៦៤
រឿងភិក្ខុ ៥០ រូប ១៦៥
អសម្មោហសម្បជញ្ញៈ ១៦៨
នាទីរបស់ចិត្តមួយខណៈ ៗ ១៧៣
រឿងព្រះមហាថេរៈ ១៧៩
បដិកូល ១០ ១៨៧
អរិយសច្ចក្នុងសម្បជញ្ញៈ ១៩២
បដិកូលមនសិការបព្វៈ ១៩៤
ធាតុមនសិការបព្វៈ ១៩៦
នវសីវថិកាបព្វៈ ១៩៩
ព្រៃខ្មោច ៩ ២០៣
វេទនានុបស្សនា ២០៦
ការដឹងមិនមែនសតិប្បដ្ឋាន ២០៦
រឿងព្រះថេរៈមួយរូប ២០៧

| | |
|---|---|
| រូបកម្មដ្ឋាន អរូបកម្មដ្ឋាន | ២០៩ |
| វេទនា គឺ អរូបកម្មដ្ឋាន | ២១២ |
| សុខវេទនាប្រែប្រួល | ២១៥ |
| អរិយសច្ចក្នុងវេទនា | ២១៨ |
| អធិប្បាយចិត្តានុបស្សនា | ២១៩ |
| អរិយសច្ចក្នុងចិត្តានុបស្សនា | ២២១ |
| អធិប្បាយធម្មានុបស្សនា , នីវរណបព្វៈ | ២២៣ |
| អធិប្បាយ សុភនិមិត្ត | ២២៤ |
| អធិប្បាយ អសុភនិមិត្ត | ២២៥ |
| លះកាមច្ឆន្ទៈដោយធម៌ ៦ ប្រការ | ២២៦ |
| អធិប្បាយ បដិឃនិមិត្ត | ២២៧ |
| លះព្យាបាទដោយធម៌ ៦ ប្រការ | ២២៨ |
| អធិប្បាយ អរតិជាដើម | ២៣០ |
| អធិប្បាយ អារព្ភធាតុជាដើម | ២៣០ |
| លះថីនមិទ្ធៈដោយធម៌ ៦ ប្រការ | ២៣២ |
| អធិប្បាយ ឧទ្ធច្ចកុក្កុច្ចៈ | ២៣៤ |
| លះឧទ្ធច្ចកុក្កុច្ចៈដោយធម៌ ៦ ប្រការ | ២៣៥ |
| អធិប្បាយ វិចិកិច្ឆា | ២៣៦ |
| អរិយសច្ចក្នុងនីវរណៈ | ២៣៩ |
| ខន្ធបព្វៈ | ២៤០ |
| អរិយសច្ចក្នុងបញ្ចក្ខន្ធ | ២៤១ |
| អាយតនបព្វៈ | ២៤២ |
| ការកើតឡើងនៃសំយោជនៈ | ២៤៣ |
| អរិយសច្ចក្នុងអាយតនៈ | ២៤៦ |

ពោជ្ឈង្គបព្វៈ ២៤៧
អត្ថនៃពាក្យថា សម្ពោជ្ឈង្គៈ ២៤៧
ការកើតឡើងនៃសតិសម្ពោជ្ឈង្គៈ ២៤៨
ការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ ២៤៩
ការកើតឡើងនៃវីរិយសម្ពោជ្ឈង្គៈ ២៥៤
រឿងព្រះមហាមិត្តត្ថេរៈ ២៥៧
ការកើតឡើងនៃបីតិសម្ពោជ្ឈង្គៈ ២៦២
ការកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គៈ ២៦៤
ការកើតឡើងនៃសមាធិសម្ពោជ្ឈង្គៈ ២៦៦
ការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គៈ ២៧០
អរិយសច្ចក្នុងពោជ្ឈង្គៈ ២៧៣
សច្ចបព្វៈ ២៧៥
អរិយសច្ច ក្នុងអរិយសច្ច ២៧៦
អានិសង្សនៃការចម្រើនសតិប្បដ្ឋាន ២៧៨

**អដ្ឋកថា ចុល្លសីហនាទសូត្រ ទី១** ១៨០
ប្រមាណ ៤ យ៉ាង ២៨០
ប្រៀបធៀបពន្លឺអំពិលអំពែក និងព្រះអាទិត្យ ២៨៤
ទិដ្ឋិ ៦២ ២៨៨
បបញ្ចធម៌ ២៩៩
រឿងទន្សាយ និងផែនដី ៣០៥
រឿងឆ្កែចចកស៊ីមេស្រា ៣០៩
កិរិយាសត្វទីទុយ ៣១២

## អដ្ឋកថា មហាសីហនាទសូត្រ ទី ២ ៣១៧

ហេតុកើតឡើងនៃស្តេចលិច្ឆវី ៣១៧

ឧត្តរិមនុស្សធម៌ ៣២២

សេចក្តីករុណារបស់ព្រះសារីបុត្រ ៣២៦

កម្លាំងពីរយ៉ាងរបស់ព្រះតថាគត ៣៣១

កម្លាំងព្រះតថាគតប្រៀបនឹងកម្លាំងដំរី ១០ ត្រកូល ៣៣១

សព្ទថា ចក្រ ៣៣៥

ទសពលញ្ញាណ ៣៤១

សព្វញ្ញុតញ្ញាណ ៣៤២

វេសារជ្ជញ្ញាណ ៣៤៥

ព្រះតថាគតយាងកាន់ចក្រវាឡដទៃ ៣៤៨

ពាក្យថា យោនិ ៣៥០

ពាក្យថា គតិ ៣៥២

វិនិច្ឆ័យ អាសវក្ខយវារៈ ៣៥៨

ពោលអំពី ព្រហ្មចរិយៈ ៣៦១

ការសម្តែងព្រះធម៌លឿនជាងអ្នកជំនាញបាញ់ធ្នូ ៣៨២

## អដ្ឋកថា មហាទុក្ខក្ខន្ធសូត្រ ទី ៣ ៣៨៧

វិនិយបរិយាយថា សង្ឃ ៣៨៧

ពាក្យថា គុណ ៣៩០

ពាក្យថា កាម ៣៩២

កម្មករណ៍ច្រើនយ៉ាង ៣៩៤

ការកម្ចាត់បង់ឆន្ទរាគៈ ឈ្មោះថា និព្វាន ៣៩៧

| | |
|---|---|
| **អដ្ឋកថា ចុល្លទុក្ខក្ខន្ធសូត្រ ទី ៤** | ៤០០ |
| *ញាតិរបស់ព្រះតថាគត* | ៤០១ |
| *ការសង្ស័យរបស់ព្រះរាជាមហានាម* | ៤០២ |
| **អដ្ឋកថា អនុមានសូត្រ ទី ៥** | ៤១០ |
| *ការសិក្សាទាំងយប់-ថ្ងៃ* | ៤១៣ |
| *ការព្យាយាមលះកិលេស* | ៤១៤ |
| **អដ្ឋកថា ចេតោខិលសូត្រ ទី ៦** | ៤១៥ |
| *បទថា ធម្មេ* | ៤១៦ |
| *បុគ្គលប្រកបដោយអង្គ ១៥ ប្រការ* | ៤១៨ |
| *ឧបមាដូចមេមាន់ក្រាបពង* | ៤១៩ |
| **អដ្ឋកថា វនបត្ថបរិយាយសូត្រ ទី ៧** | ៤២៤ |
| **អដ្ឋកថា មធុបិណ្ឌិកសូត្រ ទី ៨** | ៤២៥ |
| *រឿង ភិក្ខុទេវទត្ត* | ៤២៦ |
| *ពាក្យថា ទណ្ឌទានំ* | ៤៣០ |
| *ការកើតចក្ខុវិញ្ញាណជាដើម* | ៤៣៣ |
| *ភាពជាបណ្ឌិត ដោយធម៌ ៤ យ៉ាង* | ៤៣៥ |
| *មហាបញ្ញា* | ៤៣៦ |
| **អដ្ឋកថា ទ្វេធាវិតក្កសូត្រ ទី ៩** | ៤៣៧ |
| *វិតក្ក ៣ យ៉ាង* | ៤៣៧ |
| *អត្តភាពរបស់ព្រះពោធិសត្វ....* | ៤៤០ |

ការត្រិះរិះរបស់ព្រះពោធិសត្វ ៤៤២

សមាធិខ្វះ វិបស្សនាខ្វះ របស់ព្រះពោធិសត្វ ៤៤៦

ឧបមាដូចព្រានម្រឹគដែលឆ្លាត ៤៤៩

ផ្លូវប្រកបដោយអង្គ ៨ ៤៥២

**អដ្ឋកថា វិតក្កសណ្ឋានសូត្រ ទី ១០** ៤៥៤

អធិចិត្ត ៤៥៤

វិតក្ក ៣ យ៉ាង ៤៥៥

គប្បីមនសិការនិមិត្តដទៃ ៤៥៦

ទឹកជាសត្រូវដោយត្រង់ចំពោះភ្លើង ៤៦០

ការដកកន្ទុះឈើចាស់ ៤៦១

រឿង តិស្សសាមណេរ ៤៦៤

ពាក្យថា សណ្ឋាន ៤៦៦

ទន្សាយផ្អើលផ្លែត្នោត ៤៦៧

# អដ្ឋកថា សម្មាទិដ្ឋិសូត្រ ទី ៩

## ឈ្មោះ បបញ្ចសូទនី

## អដ្ឋកថា មជ្ឈិមនិកាយ បឋមភាគ

## លេខ ២០ " ភាគ ២ "

[១១០] *សម្មាទិដ្ឋិសូត្រមានពាក្យផ្ដើមថា ខ្ញុំម្ចាស់ បានស្ដាប់មកហើយយ៉ាងនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាទិដ្ឋិសូត្រនោះ ដូចតទៅនេះ ៖*

*ពាក្យសួរដែលព្រះថេរៈ ( សារីបុត្រ ) ពោលទុកយ៉ាងនេះថា ម្នាលអាវុសោ ដែលហៅថា សម្មាទិដ្ឋិ ដោយហេតុមានប៉ុន្មានយ៉ាងហ្ន៎ ? ដូច្នេះ ឬថា អកុសល តើដូចម្ដេច ? ម្នាលអាវុសោ ដូច្នេះគ្រប់ប្រការ ជាកថេតុកម្យតាបុច្ឆា ( សួរដើម្បីឆ្លើយខ្លួនឯង ) ប៉ុណ្ណោះឯង ។*

*ព្រោះថា ក្នុងពាក្យសួរទាំងនោះ បុគ្គលទាំងឡាយយល់ក្នុងសម្មាទិដ្ឋិនោះក៏មាន មិនយល់ក៏មាន ជាបុគ្គលក្រៅសាសនាក៏មាន ក្នុងសាសនាក៏មាន ពោលថា សម្មាទិដ្ឋិដោយអំណាចដែលបានស្ដាប់តាមគ្នាមកក៏មាន ដោយបានប្រចក្សដោយខ្លួនឯងមកក៏មាន ដូច្នេះ ទើបព្រះសារីបុត្របានពោលសំដៅយកពាក្យសួររបស់បុគ្គលចំណែកច្រើននោះបញ្ចាក់ដល់ ២ ជន ថា ម្នាលអាវុសោ ដែលហៅថា សម្មាទិដ្ឋិដែលពិតក្នុងរឿងនេះមានអធិប្បាយដូចតទៅនេះ សូម្បីអាចារ្យពួកដទៃក៏ហៅថា សម្មាទិដ្ឋិ ។*

*ព្រះសារីបុត្រនេះនោះ កាលពោលយ៉ាងនេះ បានពោលថាដោយហេតុប៉ុន្មានយ៉ាងហ្ន៎ ? ម្នាលអាវុសោ អរិយសាវកទើបឈ្មោះថា មានការឃើញត្រូវដូច្នេះ សំដៅដល់អត្ថៈ និង លក្ខណៈ ( របស់សម្មាទិដ្ឋិ ) ។*

# អធិប្បាយពាក្យថា សម្មាទិដ្ឋិ

បណ្ដាបទទាំងនោះ បទថា **សម្មាទិដ្ឋិ** សេចក្ដីថា ដែលឈ្មោះថា ជាអ្នកប្រកបដោយការឃើញទាំងល្អទាំងប្រសើរ ។

ក៏កាលណា សព្ទថា សម្មាទិដ្ឋិនេះប្រើក្នុងធម្មៈប៉ុណ្ណោះ កាលនោះគប្បីជ្រាបអត្ថនៃសព្ទនោះយ៉ាងនេះថា ទិដ្ឋិទាំងល្អទាំងប្រសើរ ឈ្មោះថា សម្មាទិដ្ឋិ ។ ហើយសម្មាទិដ្ឋិនេះនោះ មាន ២ យ៉ាង គឺ លោកិយសម្មាទិដ្ឋិ ១ លោកុត្តរសម្មាទិដ្ឋិ ១ ។

ក្នុងចំនួនសម្មាទិដ្ឋិទាំង ២ យ៉ាងនោះ កម្មស្សកតាបញ្ញា ( ប្រាជ្ញាដឹងច្បាស់ថា សត្វមានកម្មជារបស់ខ្លួន ) និង **សច្ចានុលោមិកញ្ញាណ** ( ប្រាជ្ញាប្រព្រឹត្តទៅដោយសមគួរដល់ការកំណត់ដឹងអរិយសច្ចៈ ) ឈ្មោះថា លោកិយសម្មាទិដ្ឋិ ។ ចំណែកបញ្ញាដែលសម្បយុត្តដោយអរិយមគ្គ អរិយផល ឈ្មោះថា លោកុត្តរសម្មាទិដ្ឋិ ។ តែបុគ្គលដែលមានសម្មាទិដ្ឋិ មាន ៣ ប្រភេទ គឺ បុថុជ្ជន ១ **សេក្ខបុគ្គល** ( អ្នកនៅសិក្សា ) ១ **អសេក្ខបុគ្គល** ( អ្នកចប់កិច្ចសិក្សា ) ១ ។

ក្នុងចំនួនបុគ្គល ៣ ប្រភេទនោះ បុថុជ្ជនមាន ២ ប្រភេទ គឺ **ពាហិរកជន** ( បុគ្គលក្រៅសាសនា ) ១ , **សាសនិកជន** ( បុគ្គលក្នុងសាសនា ) ១ ។ ក្នុងចំនួន ២ ប្រភេទនោះ ពាហិរកបុថុជ្ជនអ្នកជាកម្មវាទី ( ជឿកម្ម ) ឈ្មោះថា ជាអ្នកមានការឃើញត្រូវ ( ជាសម្មាទិដ្ឋិកបុគ្គល ) ដោយការឃើញថាសត្វមានកម្មជារបស់ខ្លួន មិនមែនដោយការឃើញថ្នាក់សច្ចានុលោមញាណ ចំណែកសាសនិកបុថុជ្ជន ឈ្មោះថា មានការឃើញត្រូវ ( ជាសម្មាទិដ្ឋិកបុគ្គល ) ដោយ

ការឃើញទាំង ២ យ៉ាង ( កម្មស្សកតា និង អនុលោមញាណ ព្រោះនៅស្អាប អន្ធែលការឃើញរឿងអត្តា និងលះសក្កាយទិដ្ឋិមិនទាន់បាន ) ។

សេក្ខបុគ្គល ឈ្មោះថា មានការឃើញប្រពៃ ព្រោះមានការឃើញប្រពៃពិតប្រាកដ ។ ចំណែកអសេក្ខបុគ្គលឈ្មោះថា មានការឃើញប្រពៃ ព្រោះអស់កិច្ចសិក្សា ។ តែក្នុងទីនេះប្រាថ្នាយកអ្នកប្រកបដោយសម្មាទិដ្ឋិដែលជាលោកុត្តរកុសលដ៏ទៀងទាត់ គឺ ជាគ្រឿងនាំសត្វចេញចាកទុក្ខថា អ្នកមានការឃើញប្រពៃ

ព្រោះហេតុនោះឯង ទើបព្រះសារីបុត្របានពោលទុកថា ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងធម៌ បានមកកាន់ព្រះសទ្ធម្មនេះហើយ ។ អធិប្បាយថា សម្មាទិដ្ឋិដែលជាលោកុត្តរកុសលប៉ុណ្ណោះ ជាការឃើញដ៏ត្រង់ ព្រោះទៅតាមផ្លូវត្រង់ មិនជាប់នៅនឹងទីបំផុតទាំង ២ យ៉ាង ឬកាត់ផ្តាច់ភាពកោងគ្រប់យ៉ាង មានការកោងផ្លូវកាយជាដើម ហើយទៅត្រង់ ហើយអ្នកប្រកបដោយទិដ្ឋិនោះឯង ឈ្មោះថា ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងធម៌ គឺ ដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងលោកុត្តរធម៌ ៩ ប្រការ អរិយសាវក កាលលះបង់ការប្រកាន់មាំដោយទិដ្ឋិគ្រប់យ៉ាង លះបង់កិលេសទាំងអស់ហើយ ចេញចាកសង្សារវដ្ត គឺ ជាតិ សម្រេចដល់ការបដិបត្តិ លោកហៅថា អ្នកបាន មកកាន់ព្រះសទ្ធម្ម ពោលគឺ ព្រះនិព្វានដែលញុំាងចុះកាន់អមតធម៌ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រកាសហើយដោយអរិយមគ្គ ។

[១១១] ពាក្យថា យតោ ខោ នេះ ជាពាក្យកំណត់កាលវេលា មានអធិប្បាយថា ក្នុងកាលណា ។

សេចក្ដីថា អកុសលញ្ច បជានាតិ សេចក្ដីថា ដឹងច្បាស់នូវអកុសល ពោលគឺ អកុសលកម្មបថ ១០ ប្រការ គឺ កាលចាក់ធ្លុះថា វត្ថុនេះជាទុក្ខដោយអំណាចនៃកិច្ចញាណ ឈ្មោះថា ដឹងច្បាស់នូវអកុសល ព្រោះការដឹងច្បាស់ដែលមាននិរោធជាអារម្មណ៍ ។

សេចក្ដីថា អកុសលមូលញ្ច បជានាតិ សេចក្ដីថា ដឹងច្បាល់នូវឫសគល់របស់អកុសលថាជាឫសគល់ ជាបច្ច័យនៃអកុសលនោះ គឺ ការចាក់ធ្លុះថា នេះជាហេតុឲ្យកើតទុក្ខដោយប្រការដូច្នោះឯង ( ឈ្មោះថា ដឹងច្បាស់នូវឫសគល់របស់អកុសល) ។

សូម្បីក្នុងពាក្យនេះថា កុសល និងឫសគល់របស់កុសលនេះ ក៏មានន័យនេះ ។

ក្នុងគ្រប់វារៈតអំពីវារៈនេះទៅ ក៏ដូចវារៈនេះ គួរជ្រាបការដឹងច្បាស់នូវវត្ថុ ដោយអំណាចនៃកិច្ចញាណនោះឯង ។

បទថា ឯត្តាវតាបិ សេចក្ដីថា ដោយហេតុត្រឹមប៉ុណ្ណេះ គឺ សូម្បីការ ដឹងច្បាស់នូវអកុសលជាដើមនេះ ។

បទថា សម្មាទិដ្ឋិ ហោតិ សេចក្ដីថា ជាអ្នកប្រកបដោយលោកុត្តរសម្មា-ទិដ្ឋិ មានប្រការដូចពោលមកហើយ ។

ដោយពាក្យត្រឹមប៉ុណ្ណេះថា អរិយសាវកនោះមានទិដ្ឋិត្រង់ ។ល។ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ជាការដែលព្រះសារីបុត្របញ្ចប់ការសម្ដែងដោយសង្ខេបហើយ ។ ការសម្ដែង ( របស់លោក ) នេះ សូម្បីនឹងសង្ខេប តែក៏គួរ

ជ្រាបដោយការចាក់ចុះ ដោយមនសិការដ៏ប្រពៃ ដោយអំណាចនៃសេចក្តីពិស្តារនោះឯង សម្រាប់ភិក្ខុទាំងនោះ ។

ចំណែកក្នុងទុតិយវារៈសូម្បីការសម្តែង ( និងបង្រួញ ) ក៏គួរជ្រាបដល់ការចាក់ចុះដោយមនសិការដ៏ប្រពៃយ៉ាងពិស្តារថា បានប្រព្រឹត្តទៅហើយដោយពិស្តារនោះឯង ។

ភិក្ខុទាំងឡាយបានពោលថា បណ្តាការសម្តែងទាំង ២ យ៉ាងនោះ ដោយការសម្តែងយ៉ាងសង្ខេប ព្រះសារីបុត្របានពោលដល់មគ្គខាងក្រោមទាំង ២ យ៉ាង ដោយការសម្តែងយ៉ាងពិស្តារ ព្រះសារីបុត្របានពោលដល់មគ្គខាងលើ ២ យ៉ាង

ក្នុងទីបំផុតនៃការសម្តែងយ៉ាងពិស្តារ ភិក្ខុទាំងឡាយពិចារណាឃើញ-ពាក្យមានជាអាទិ៍ថា ព្រោះលះរាគានុស័យបាន ដោយប្រការទាំងពួង ។ តែព្រះថេរៈ បានពោលថា មគ្គទាំង ៤ បានពោលទុកហើយ ដោយជាពួក ដោយការ សម្តែងយ៉ាងសង្ខេបក៏មាន ដោយការសម្តែងយ៉ាងពិស្តារក៏មាន ។

ម្យ៉ាងទៀត ការសម្តែងទាំងដោយសង្ខេបទាំងដោយពិស្តារនេះ ជាការសម្តែង ដែលខ្ញុំម្ចាស់បានធ្វើការពិចារណាទុកដោយល្អិតល្អន់ជាក់ច្បាស់ហើយ ក្នុងទីនេះការសម្តែងនោះ គប្បីជ្រាបតាមន័យដែលពោលទុកហើយ ក្នុងទីនេះ គ្រប់ ៗ វារៈចុះ ។ ព្រោះថា តអំពីនេះទៅ ខ្ញុំម្ចាស់នឹងធ្វើត្រឹមតែការបរិយាយសេចក្តីចំពោះបទដែលលំបាក ដែលនៅមិនទាន់បាន ( អធិប្បាយ ) ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងការសម្តែងដោយពិស្តារនូវបឋមវារៈក្នុងចំនួនវារៈទាំងនោះមុន ។

ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា ម្នាលអាវុសោ បាណាតិបាតនោះឯង ជាអកុសល ។ អកុសល ព្រោះអត្ថថា ប្រព្រឹត្តទៅដោយការមិនឆ្លាត ( គឺ កើតអំពីការមិនឆ្លាត ) អកុសលនោះ គប្បីជ្រាបដោយ ( ជាធម៌ ) ផ្ទុយគ្នានឹងកុសលដែលនឹងត្រូវពោលខាងមុខ ឬដោយលក្ខណៈ គប្បីជ្រាប ( ថាជា ) វត្ថុដែលមានទោស និងមានវិបាកជាទុក្ខ ជាវត្ថុដែលសៅហ្មង ។ នេះជាការបរិយាយបទទូទៅក្នុងអកុសលវារៈប៉ុណ្ណេះសិន ។

## អធិប្បាយ បាណាបាតិបាត

ចំណែកក្នុងបទចំពោះ ( មិនទូទៅ ) គប្បីជ្រាបវិនិច្ឆ័យថា ការញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងទៅ ឈ្មោះថា **បាណាតិបាត** បានដល់ ការសម្លាប់សត្វដែលមានជីវិត អធិប្បាយថា ការទំលាយសត្វដែលមានជីវិត ។ ក៏ពាក្យថា **បាណៈ** ក្នុងពាក្យថា **បាណាតិបាតោ** នេះ ពោលដោយវោហារ បានដល់ សត្វ តែបើពោលដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ៍ ។

ចំណែកចេតនា ដែលសម្លាប់ របស់អ្នកមានការសម្គាល់ក្នុងសត្វមានជីវិតនោះថា ជាសត្វមានជីវិត ដែលជាសមុដ្ឋាននៃការព្យាយាមដែលនឹងចូលទៅកាត់ផ្តាច់ជីវិតិន្ទ្រិយ៍ ដែលប្រព្រឹត្តទៅតាមកាយទ្វារ ឬវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **បាណាតិបាត** ។

បាណាតិបាតនោះ គប្បីជ្រាបថា មានទោសតិច ព្រោះសត្វមានជីវិតនោះមានខ្លួនតូច ក្នុងចំនួនសត្វមានជីវិតទាំងឡាយ មានតិរច្ឆានជាដើម ដែលប្រាសចាកគុណ តែគប្បីជ្រាបថា មានទោសច្រើន ព្រោះសត្វដែលមានជីវិត

មានខ្លួនធំ ។

ព្រោះហេតុអ្វី ?

ព្រោះមានប្រយោគធំ ( មានវិធីការច្រើន ) ។

សូម្បីកាលមានប្រយោគស្មើគ្នា បាណាតិបាត គប្បីជ្រាបថា មានទោសច្រើន ព្រោះវត្ថុធំ ( សត្វធំ ) ។

ក្នុងជំពូកសត្វមានគុណ មានមនុស្សជាដើម ព្រោះសត្វមានគុណតិច បាណាតិបាតគប្បីជ្រាបថា មានទោសតិច , ព្រោះសត្វមានគុណច្រើន គប្បីជ្រាបថាមានទោសច្រើន ។ តែកាលសរីរៈ និងគុណមានការស្មើគ្នា បាណាតិបាតគប្បីជ្រាបថា មានទោសតិច ព្រោះកិលេស និងការព្យាយាមទន់ខ្សោយ គប្បីជ្រាបថា មានទោសច្រើន ព្រោះកិលេស និងការព្យាយាមខ្លាំងក្លា ។

បាណាតិបាតនោះមានអង្គ ៥ ឲ្យគឺ សត្វមានជីវិត ១ សេចក្តីដឹងថាសត្វមានជីវិត ១ គិតនឹងសម្លាប់ ១ ការព្យាយាមនឹងសម្លាប់ ១ សត្វស្លាប់ដោយសេចក្តីព្យាយាមនោះ ១ ។

ប្រយោគនៃការសម្លាប់មាន ៦ គឺ សាហត្ថិកប្រយោគ ( សម្លាប់ដោយដៃខ្លួនឯង ) ១ អាណត្តិកបយោគ ( ប្រើឲ្យអ្នកដទៃសម្លាប់ ) ១ និស្សគ្គិយ-បយោគ ( សម្លាប់ដោយសស្ត្រាវុធដែលពួយ ឬបោលចេញទៅ ) ១ ថាវរប-យោគ ( សម្លាប់ដោយគ្រឿងឧបករណ៍ មានអន្ទាក់ក៏ដាក់នៅនឹងកន្លែង ) ១ វិជ្ជា-មយបយោគ (សម្លាប់ដោយអំណាចវិជ្ជា) ១ ឥទ្ធិមយបយោគ (សម្លាប់ដោយឫទ្ធិ) ១ ។

តែកាលនឹងអធិប្បាយបយោគនេះឲ្យពិស្តារក្នុងបឋមវារៈនេះ ក៏នឹងយឺតយ៉ាវពេក ព្រោះហេតុដូច្នេះ នឹងសូមមិនអធិប្បាយបយោគនោះ និងយ៉ាងដទៃបែបនេះឲ្យពិស្តារ ចំណែកអ្នកមានសេចក្ដីត្រូវការ គប្បីសិក្សាមើលក្នុងសមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យចុះ ។

## អធិប្បាយពាក្យថា អទិន្នាទាន

ការកាន់យកព្រទ្យដែលគេមិនបានឲ្យ ឈ្មោះថា **អទិន្នាទាន** ការលួចព្រទ្យរបស់អ្នកដទៃ ឈ្មោះថា **ថេយ្យ** អធិប្បាយថា ជាកិរិយារបស់ចោរ ។

បទថា **អទិន្នំ** បានដល់ ទ្រព្យដែលអ្នកដទៃហួងហែង ដែលអ្នកដទៃ ( ម្ចាស់ទ្រព្យ ) កាលប្រើប្រាស់តាមដែលត្រូវការ ក៏មិនគួរបានទទួលទណ្ឌៈ និងមិនត្រូវតិះដៀល ។

ចំណែកចេតនាដែលនឹងលួច របស់អ្នកមានការសម្គាល់ក្នុងទ្រព្យ ដែលអ្នកដទៃហួងហែងនោះថា ជាទ្រព្យដែលគេហួងហែង ដែលជាសមុដ្ឋាននៃការព្យាយាម និងកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យនោះ ឈ្មោះថា **អទិន្នាទាន** ។

អទិន្នាទាននោះ មានទោសតិច ព្រោះទ្រព្យរបស់អ្នកដទៃថោកថយ ឈ្មោះថា មានទោសច្រើន ព្រោះទ្រព្យរបស់អ្នកដទៃប្រណីត ។

ព្រោះហេតុអ្វី ?

ព្រោះថា ជារបស់ប្រណីត ។

កាលមានការស្មើគ្នានៃទ្រព្យ ឈ្មោះថា មានទោសច្រើន ព្រោះទ្រព្យដែលមាននោះ ជារបស់អ្នកមានគុណក្រៃលែង ។

អទិន្នាទាននោះ ឈ្មោះថា មានទោសតិច ព្រោះទ្រព្យដែលមាន ជារបស់អ្នកមានគុណធម៌ទាបជាងនោះ ព្រោះប្រៀបធៀបនឹងអ្នកមានគុណធម៌ខ្ពស់នោះ ។

អទិន្នាទាននោះ មានអង្គប្រកប ៥ ប្រការ គឺ ទ្រព្យដែលអ្នកដទៃហួងហែង ១ សេចក្តីដឹងថាជាទ្រព្យដែលអ្នកដទៃហួងហែង ១ ចិត្តគិតនឹងលួច ១ សេចក្តីព្យាយាម ( នឹងលួច ) ១ លួចទ្រព្យបានមកដោយសេចក្តីព្យាយាមនោះ ១ ។

ក៏ប្រយោគការ ( ប្រកបអទិន្នាទាន ) មាន ៦ យ៉ាង មានសាហត្ថិកបយោគជាដើម ក៏បយោគទាំងនោះឯង ប្រព្រឹត្តទៅហើយ ដោយអំណាចនៃ **អាវហា** ( ការលួច ) ទាំងនេះ គឺ **ថេយ្យាវហារ** ( លួចដោយការលួច ) ១ **បសយ្ហាវហារ** ( លួចដោយការធ្មេចក ) ១ **បដិច្ឆិន្នាវហារ** ( លួចដោយការគ្របបិទទ្រព្យទុក ) ១ **បរិកប្បាវហារ** ( លួចដោយការកំណត់ទ្រព្យ ឬពេលវេលា ) ១ **កុសាវហារ** ( លួចដោយប្តូរស្លាក ) ១ សេចក្តីដូចដែលបានពោលមកហើយនេះ ជាសេចក្តីសង្ខេបក្នុងអវហារនេះ ។ ចំណែកសេចក្តីពិស្តារបានពោលទុកហើយក្នុងអដ្ឋកថាឈ្មោះ សមន្តបាសាទិកា ។

## អធិប្បាយពាក្យថា កាមេសុមិច្ឆាចារ

ក៏បទថា កាមេសុ ក្នុងសេចក្តីថា កាមេសុមិច្ឆាចារោ នេះ បានដល់ **មេថុនសមាចារ** ។ ការប្រព្រឹត្តដ៏លាមក ដែលបណ្ឌិតតិះដៀលដោយចំណែកមួយ ឈ្មោះថា **មិច្ឆាចារ** ។ តែដោយលក្ខណៈ ចេតនាដែលប្រព្រឹត្តកន្លងអគមនីយដ្ឋាន

(ស្ត្រីដែលត្រូវហាម) ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយសេចក្តីប្រាថ្នាចំពោះអសទ្ធម្ម ឈ្មោះថា **កាមេសុមិច្ឆាចារ** ។

ស្ត្រីដែលឈ្មោះថា អគមនីយដ្ឋាន ( ស្ត្រីដែលត្រូវហាម ) សម្រាប់បុរសក្នុងកាមេសុមិច្ឆាចារនេះ បានដល់ ស្ត្រី ២០ ចំពូក គឺ ស្ត្រីដែលមានមាតារក្សាជាដើម ។

ស្ត្រី ១០ ចំពួក គឺ ស្ត្រីដែលមានមាតារក្សា ១ ស្ត្រីដែលបិតារក្សា ១ ស្ត្រីដែលមានមាតានិងបិតារក្សា ១ ស្ត្រីដែលមានបងប្អូនប្រុសរក្សា ១ ស្ត្រីដែលមានបងប្អូនស្រីរក្សា ១ ដែលញាតិរក្សា ១ ស្ត្រីដែលគោត្ររក្សា ១ ស្ត្រីដែលធម៌រក្សា ១ ស្ត្រីដែលមានការអារក្ខា ១ ស្ត្រីដែលមានច្បាប់រក្សា ( នៅក្នុងច្បាប់រដ្ឋបាល ) ១ ។

និងស្ត្រី ១០ ចំពូកទៀត មានស្ត្រីដែលលោះមកដោយទ្រព្យជាដីម ទាំងនេះ គឺ កិរិយាដែលលោះមកដោយទ្រព្យ ( កិរិយាលោះដោយទ្រព្យ ) ១ កិរិយាដែលនៅជាមួយគ្នាព្រោះការពេញចិត្ត ១ ដែលនៅជាមួយគ្នាព្រោះភោគៈ ១ ដែលនៅជាមួយគ្នាព្រោះគ្រឿងស្លៀកដណ្តប់ ១ ដែលអ្នកគ្រប់គ្រងពេញចិត្តលើកឲ្យ ១ ដែលបុរសដាក់ទំនូលចុះពីលើសីសៈ ១ ដែលទាំងជាកិរិយាទាំងជាទាសៈ ១ ដែលទាំងជាកិរិយាទាំងជាកូនឈ្នួល ១ ដែលជាឈ្លើយសឹក ១ ដែលនៅជាមួយគ្នាត្រឹមតែមួយគ្រា ១ ។

ចំណែកបុរសដទៃក្រៅអំពីស្វាមីរបស់ខ្លួន ឈ្មោះថា ជាអគមនីយដ្ឋាន ( បុរសត្រូវហាម ) សម្រាប់ស្ត្រី ១២ ចំពូក គឺ ២ ចំពូកសម្រាប់ស្ត្រីមានអារក្ខា

និងស្ត្រីមានអាជ្ញាគ្រប់គ្រង និង ១០ ចំពូក សម្រាប់កិរិយាដែលលោះមកដោយទ្រព្យជាដើម ។ ក្នុងចំនួនស្ត្រីទាំងឡាយ ( ១០ ចំពូក ) សម្រាប់កិរិយា ។

ម្យ៉ាងទៀត មិច្ឆាចារនេះ ឈ្មោះថា មានទោសតិច ព្រោះអគមនីយដ្ឋាន ( អ្នកត្រូវហាម ) ប្រាសចាកគុណធម៌ មានសីលជាដើម ឈ្មោះថា មានទោសច្រើន ព្រោះដល់ព្រមដោយគុណធម៌ មានសីលធម៌ជាដើម ។

កាមេសុមិច្ឆាចារនោះ មានអង្គ ៤ យ៉ាង គឺ ជាបុគ្គលត្រូវហាម ១ ចិត្តគិតនឹងសេពក្នុងបុគ្គលត្រូវហាមនោះ ១ ការប្រកបការសេព ១ ការញ៉ាំងមគ្គឲ្យដំណើរទៅក្នុងមគ្គ ឬឈប់នៅ ១ ប្រយោគមានតែមួយ គឺ សាហត្ថិកប្រយោគប៉ុណ្ណោះ ។

## អធិប្បាយពាក្យថា មុសាវាទ

កាយប្រយោគ ឬវចីប្រយោគ ដែលធ្វើឲ្យវិនាសប្រយោជន៍ ( អ្នកដទៃ ) របស់អ្នកប្រាថ្នានឹងនិយាយឲ្យខុស ឈ្មោះថា **មុសា** ។ ចេតនារបស់អ្នកនិយាយឲ្យខុសចំពោះអ្នកដទៃដោយប្រាថ្នានឹងឲ្យគេយល់ខុស មានកាយប្រយោគ និងវចីប្រយោគជាសមុដ្ឋាន ឈ្មោះថា **មុសាវាទ** ។

ម្យ៉ាងទៀត រឿងមិនពិត មិនមែនឈ្មោះថា **មុសា** ( រឿងកុហក ) ។ ការឲ្យ ( អ្នកដទៃ ) ដឹងរឿងកុហកនោះ ថាជារឿងពិត រឿងមែន ឈ្មោះថា វាទៈ ( ការនិយាយ ) តែពោលដោយលក្ខណៈ ចេតនារបស់អ្នកប្រាថ្នានឹងឲ្យអ្នកដទៃដឹងរឿងដែលមិនពិតថា ជារឿងពិត ដែលជាសមុដ្ឋាននៃវិញ្ញត្តិ ( ការកម្រើក ) យ៉ាងនោះ ឈ្មោះថា **មុសាវាទ** ( ការនិយាយកុហក ) ។

មុសាវាទនោះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ដែលខ្លួនធ្វើឲ្យវិនាសមានចំនួនតិច , ឈ្មោះថា មានទោសច្រើន ព្រោះប្រយោជន៍ដែលខ្លួនធ្វើឲ្យវិនាសមានចំនួនច្រើន ។

ម្យ៉ាងទៀត សម្រាប់គ្រហស្ថ មុសាវាទដែលប្រព្រឹត្តទៅហើយដោយន័យមានជាអាទិ៍ថា មិនមាន ព្រោះមិនបំណងឲ្យរបស់ខ្លួន (ដល់អ្នកដទៃ) មានទោសតិច ដែលពោលបំពានធ្វើជាសាក្សីដើម្បីធ្វើឲ្យវិនាសប្រយោជន៍ ( របស់គូភាគី ) មានទោសច្រើន , សម្រាប់បព្វជិត មុសាវាទដែលប្រព្រឹត្តទៅហើយ ដោយន័យនៃបូរណាកថា ( និយាយឲ្យពេញសេចក្តី ឬលេងសើច ) ថាថ្ងៃនេះ ប្រេងក្នុងស្រុកប្រហែលនឹងហូរទៅជាស្ទឹងហើយមើលទៅ ដោយសេចក្តីប្រាថ្នានឹងឲ្យសើច ព្រោះបានប្រេង ឬទឹកដោះថ្លាតិចពេក មានទោសតិច តែរបស់អ្នកនិយាយដោយន័យមានជាអាទិ៍ថា វត្ថុដែលមិនបានឃើញ ថាបានឃើញ មានទោសច្រើន ។

មុសាវាទនោះ មានអង្គប្រកប ៤ យ៉ាង គឺ រឿងមិនពិត ១ តាំងចិត្តនិយាយឲ្យខុស ១ ព្យាយាមនិយាយ ១ អ្នកដទៃដឹងច្បាស់សេចក្តីនោះ ១ ។ ប្រយោគមាន ១ គឺ សាហត្ថិកប្បយោគប៉ុណ្ណោះ ។ ប្រយោគនោះ គប្បីឃើញថាបានដល់ ការសម្តែងកិរិយារបស់អ្នកនិយាយឲ្យខុសចំពោះអ្នកដទៃ ដោយកាយ ដោយរបស់ជាប់នឹងកាយ ឬដោយវាចា ។

ប្រសិនបើអ្នកដទៃដឹងសេចក្តីនោះ ដោយកិរិយានោះ កិរិយានេះ ឈ្មោះថា ជាប់ដោយមុសាវាទកម្ម ក្នុងខណៈនៃចេតនា ដែលមានកិរិយាជាសមុដ្ឋាននោះឯង ។

# អធិប្បាយពាក្យថា បិសុណាវាចា

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បិសុណាវាចា** ជាដើម ។ វាចាដែលជាហេតុឲ្យបេះដូងរបស់បុគ្គលអ្នកដែលខ្លួននិយាយជាមួយ កើតសេចក្តីស្រឡាញ់ខ្លួន និងស្អប់ខ្ពើមអ្នកដទៃ ឈ្មោះថា **បិសុណាវាចា** ។

ចំណែកវាចាដែលជាហេតុធ្វើឲ្យខ្លួនឯងខ្លះ អ្នកដទៃខ្លះ គ្រោតគ្រាត និងវាចាដែលគ្រោតគ្រាតខ្លួនឯង គឺ មិនពីរោះត្រចៀក ឬមិនសប្បាយចិត្ត ( អ្នកស្តាប់ ) នេះឈ្មោះថា **ផរុសវាចា** ។

វាទៈដែលជាហេតុនៃការនិយាយរោយរាយ គឺ ឥតប្រយោជន៍ ឈ្មោះថា **សម្ផប្បលាប** សូម្បីចេតនាដែលជាសមុដ្ឋាននៃការពោលពាក្យទ្រគោះ និងពាក្យរោយរាយទាំងនោះ ក៏បាននាមថា **បិសុណាវាចា** ជាដើមនោះឯង ។ ក្នុងទីនេះ ក៏ប្រាថ្នាយកចេតនានោះឯង ។

ចេតនារបស់អ្នកមានចិត្តសៅហ្មង ដែលជាសមុដ្ឋាននៃកាយបយោគ និងវចីបយោគ ដើម្បីបំបែកបំបាក់ពួកជនដទៃ ឬដើម្បីប្រាថ្នានឹងធ្វើខ្លួនឲ្យជាទីស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា **បិសុណាវាចា** ក្នុងវចីកម្មនោះ ។

បិសុណាវាចានោះ ឈ្មោះថា មានទោសតិច ព្រោះអ្នកដែលត្រូវធ្វើឲ្យបែកបាក់នោះ មានគុណធម៌តិច ឈ្មោះថា មានទោសច្រើន ព្រោះមានគុណ-ធម៌ច្រើន ។

បិសុណាវាចានោះមាន អង្គប្រកប ៤ ប្រការ គឺ មានអ្នកដទៃដែលខ្លួនប្រាថ្នាបំបែក ១ ប្រាថ្នាឲ្យគេបែកបាក់គ្នា ឬប្រាថ្នាឲ្យខ្លួនជាទីស្រឡាញ់របស់គេ ១

មានសេចក្ដីព្យាយាមដែលកើតចិត្តនោះ ១ អ្នកដទៃជឿពាក្យញុះញង់នោះ ១ ។

## អធិប្បាយ ផរុសវាចា

ចេតនាដ៏គ្រោតគ្រាតដោយចំណែកមួយ ដែលជាសមុដ្ឋាននៃកាយបយោគ និងវចីបយោគ ដែលជាហេតុកាត់ផ្ដាច់សេចក្ដីស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា **ផរុសវាចា** ដើម្បីការជាក់ច្បាស់នៃផរុសវាចានោះ ត្រូវសាធកៈរឿងនេះ ។

បានឮមកថា ក្មេងម្នាក់មិនជឿពាក្យរបស់មាតា ( ចចេស ) ចូលព្រៃទៅ ។ មាតាកាលមិនអាចនឹងឲ្យគេត្រឡប់បាន ទើបជេរថា សូមឲ្យមេក្របីកាចចូរដេញជល់ ។ ខាងក្រោយមក មេក្របីបានប្រាកដជល់គេ ដូចដែលម្ដាយជេរនោះឯង ។

ក្មេងទើបធ្វើសច្ចកិរិយាថា ម៉ែរបស់ខ្ញុំ ពោលយ៉ាងណាដោយមាត់ សូមកុំជាយ៉ាងនោះ តែគិតយ៉ាងណាដោយចិត្ត សូមឲ្យជាយ៉ាងនោះចុះ ។ មេក្របីបានឈប់ស្ងៀមនៅក្នុងទីនោះឯង ដូចត្រូវគេចង ។

វចីបយោគ សូម្បីជាហេតុកាត់ផ្ដាច់នូវពាក្យស្រឡាញ់ ( ពាក្យដែលអាស្រ័យដល់វត្ថុដែលជាទីស្រឡាញ់ ) ដូចដែលពណ៌នាកមនេះ ក៏មិនជាផរុសវាទ ព្រោះអ្នកនិយាយមានចិត្តទន់ភ្លន់ ។ ពិតណាស់ គ្រាខ្លះមាតាបិតាជេរស្ដីកូនៗយ៉ាងនេះថា សូមឲ្យពួកចោរកាត់ពួកឯងឲ្យដាច់ជាកំណាត់ៗ ទៅចុះ សូម្បីយ៉ាងនោះ តែសេចក្ដីពិតសូម្បីត្រឹមតែគ្របកផ្កាឧប្បល ក៏មិនប្រាថ្នានឹងឲ្យធ្លាក់លើខ្លួនរបស់ពួកគេឡើយ ។ គ្រាខ្លះអាចារ្យ និងឧបជ្ឈាយ៍ ស្ដីបន្ទោសអន្តេវាសិក និង

សទ្ធិវិហារិកអ្នកនៅអាស្រ័យទាំងឡាយថា ពួកនេះនឹងនិយាយអ្វី ក៏មិនមានការអៀនខ្មាស មិនមានការខ្លាចក្រែងអ្វីទាំងអស់ អ្នកទាំងឡាយ ចូរបណ្តេញវាទៅ ។ សូម្បីតែដូច្នេះ អាចារ្យ និងឧបជ្ឈាយ៍ទាំងនោះ ក៏នៅប្រាថ្នាសម្បត្តិ គឺ អាគម ( បរិយត្តិ ) និងអធិគម ( បដិវេធ ) ដល់អន្តេវាសិក និងសទ្ធិវិហារិក ទាំងនោះ ។

ម្យ៉ាងទៀត វចីបយោគដែលមិនមែនជាផរុសវាចា ព្រោះអ្នកនិយាយមានចិត្តទន់ភ្លន់យ៉ាងណា និងមិនជាផរុសវាចា ព្រោះអ្នកនិយាយមានពាក្យនិយាយផ្អែមល្ហែមដូច្នេះក៏ទេ ព្រោះថា ពាក្យនិយាយរបស់អ្នកប្រាថ្នានឹងឲ្យគេស្លាប់ថា ឯងចូរឲ្យមនុស្សម្នាក់នេះដេកឲ្យសប្បាយចុះ ដូច្នោះ មិនមែនមិនជាផរុសវាចា តែវាចានេះជាផរុសវាចាពិត ព្រោះអ្នកនិយាយមានចិត្តគ្រោតគ្រាត ។

ផរុសវាចានេះ ឈ្មោះថា មានទោសតិច ព្រោះអ្នកដែលជាផរុសវាទីបុគ្គលនិយាយសំដៅដល់អ្នកមានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះមានគុណច្រើន ។

ផរុសវាចានោះ មានអង្គប្រកប ៣ ប្រការ គឺ អ្នកដែលនឹងត្រូវជេរ ជាអ្នកដទៃ ១ ចិត្តខឹងក្រោធ ១ ការជេរ ១ ។

## អធិប្បាយពាក្យថា សម្ផប្បលាប

ចេតនាដែលជាអកុសល ដែលជាសមុដ្ឋាននៃកាយបយោគ និងវចីបយោគ ដែលញ៉ាំងអ្នកដទៃឲ្យដឹងពាក្យនិយាយដែលឥតប្រយោជន៍ ឈ្មោះថា

សម្ផប្បលាប សម្ផប្បលាបនោះ មានទោសតិច ព្រោះអ្នកនិយាយមានអាសេវនៈខ្សោយ ( សេពតិច ) ឈ្មោះថា មានទោសច្រើន ព្រោះអ្នកនិយាយមានអាសេវនៈច្រើន ( សេពច្រើន ) ។

សម្ផប្បលាបៈនោះ មានអង្គប្រកប ២ ប្រការ គឺ ការប្រាថ្នាដែលនឹងនិយាយពាក្យឥតប្រយោជន៍ មានរឿងសង្គ្រាមភារតៈ និងរឿងការលួចនាំនាងសីតា ( រឿងរាមកេរ្តិ៍ ) ជាដើម ១ ការពោលពាក្យប្រភេទនោះ ១ ។

## អធិប្បាយ អភិជ្ឈា

ចេតនាដែលឈ្មោះថា **អភិជ្ឈា** ព្រោះសម្លឹងរំពៃ អធិប្បាយថា រមែងប្រព្រឹត្តទៅដើម្បីភាពជាអ្នកឆ្ពោះមុខសម្លឹងរំពៃចំពោះភណ្ឌៈរបស់អ្នកដទៃ ហើយបង្អោនភណ្ឌៈនោះមក ។ អភិជ្ឈានោះ មានលក្ខណៈសម្លឹងរំពៃភណ្ឌៈរបស់អ្នកដទៃយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ របស់នេះនឹងគប្បីជារបស់យើង ។ អភិជ្ឈានោះឈ្មោះថា មានទោសតិច និងមានទោសច្រើន ដូចអទិន្នាទាន ។

អភិជ្ឈានោះ មានអង្គប្រកប ២ ប្រការ គឺ ទ្រព្យរបស់អ្នកដទៃ ១ បង្អោនវត្ថុនោះមកដើម្បីខ្លួន ១ ។

អធិប្បាយថា សូម្បីនឹងកើតការលោភ ដែលមានភណ្ឌៈរបស់អ្នកដទៃជាទីតាំងឡើង កម្មបថក៏នៅមិនទាន់ដាច់ ដរាបណាដែលនៅមិនទាន់បានបង្អោនមកដើម្បីខ្លួនថា ធ្វើដូចម្តេចហ្ន៎ របស់នេះនឹងគប្បីជារបស់យើង ។

## អធិប្បាយពាក្យថា ព្យាបាទ

បាបធម៌ដែលឈ្មោះថា **ព្យាបាទ** ព្រោះញុំាំងប្រយោជន៍ និងសេចក្តីសុខ

ឲ្យដល់សេចក្តីវិនាស ។

ព្យាបាទនោះ មានលក្ខណៈប្រទូសរ៉ាយ ដើម្បីសេចក្តីវិនាសរបស់អ្នកដទៃ ។ ព្យាបាទនោះ ឈ្មោះថា មានទោសតិច និងមានទោសច្រើន ដូចផរុសវាចា ។

ព្យាបាទនោះមានអង្គប្រកប ២ ប្រការ គឺ សត្វដទៃ ១ ការគិតនឹងឲ្យសត្វនោះវិនាស ១ ។

អធិប្បាយថា សូម្បីនឹងកើតសេចក្តីក្រោធដែលមានសត្វដទៃជាអារម្មណ៍ក៏ដោយ កម្មបថក៏នៅមិនទាន់ដាច់ ដរាបណាដែលអ្នកក្រោធ នៅមិនទាន់បានគិតឲ្យសត្វនោះវិនាសថា ដូចម្តេចហ្ន៎ សត្វនោះនឹងគប្បីដាច់សូន្យវិនាសទៅ ។

## អធិប្បាយពាក្យថា មិច្ឆាទិដ្ឋិ

ចេតនាដែលឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះឃើញខុស ដោយមិនមានការកាន់យកតាមសេចក្តីពិត ។ មិច្ឆាទិដ្ឋិនោះ មានលក្ខណៈឃើញខុស ដោយន័យមានជាអាទិ៍ថា ទានដែលឲ្យហើយមិនមានផល ។ មិច្ឆាទិដ្ឋិនោះ ឈ្មោះថា មានទោសតិច និងមានទោសច្រើន ដូចសម្ផប្បលាប ។ម្យ៉ាងទៀត **អនិយតមិច្ឆាទិដ្ឋិ** ( មិនទៀង ) ឈ្មោះថា មានទោសតិច ជា **និយត** ( ទៀង ) ឈ្មោះថា មានទោសច្រើន ។

មិច្ឆាទិដ្ឋិនោះមានអង្គប្រកប ២ ប្រការ គឺ ការដែលរឿងខុសអំពីអាការដែលប្រកាន់ ១ ការប្រាកដឡើងនៃរឿងនោះ ដោយមិនមានដូចដែលមិច្ឆាទិដ្ឋិកបុគ្គលប្រកាន់ ១ ។

## វិនិច្ឆ័យដោយអាការ ៥ យ៉ាង

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យអកុសលកម្មបថទាំង ១០ យ៉ាងនេះ ដោយអាការ ៥ យ៉ាង គឺ ដោយធម៌ ( **ធម្មតោ** ) ១ ដោយកោដ្ឋាសៈ ( **កោដ្ឋាសតោ** ) ១ ដោយអារម្មណ៍ ( **អារម្មណតោ** ) ១ ដោយវេទនា ( **វេទនតោ** ) ១ ដោយមូល ( **មូលតោ** ) ១ ។

បណ្ដាបទទាំងនោះ បទថា **ធម្មតោ** មានសេចក្ដីថា សេចក្ដីពិត ក្នុងចំនួនកម្មបថ ១០ យ៉ាងនេះ កម្មបថ ៧ យ៉ាង តាមលំដាប់ ( កាយកម្ម ៣ វចីកម្ម ៤ ) ជាចេតនាធម៌ ចំណែកកម្មបថ ៣ យ៉ាង មានអភិជ្ឈាជាដើម ជាធម៌ប្រកបនឹងចេតនា ។

បទថា **កោដ្ឋាសតោ** សេចក្ដីថា កម្មបថ ៧ ប្រការ តាមលំដាប់ និងមិច្ឆាទិដ្ឋិ ១ ទៀត រួមជា ៨ ប្រការនេះ ជាកម្មបថតែម្យ៉ាង មិនជាមូល ( ឫសគល់នៃអកុសល ) ចំណែកអភិជ្ឈា និងព្យាបាទ ( ២ ប្រការនេះ ) ទាំងជាកម្មបថ ទាំងជាមូល ( ឫសគល់របស់អកុសល ) ។ អធិប្បាយថា ព្រោះជាឫសគល់ អភិជ្ឈាទើបជាលោភអកុសលមូល ព្យាបាទជាទោសអកុសលមូល ។

បទថា **អារម្មណតោ** សេចក្ដីថា បាណាតិបាត មានសង្ខារជាអារម្មណ៍ ព្រោះមានជីវិតិន្ទ្រិយ៍ជាអារម្មណ៍ អទិន្នាទាន មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ មិច្ឆាចារមានសង្ខារជាអារម្មណ៍ដោយអំណាចនៃផោដ្ឋព្វៈ អាចារ្យពួកមួយពោលថា មានសត្វជាអារម្មណ៍ក៏មាន ។ មុសាវាទ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ បិសុណាវាចា ក៏ដូចគ្នានឹងផរុសវាចា មានសត្វជា

អារម្មណ៍តែម្យ៉ាង សម្ផប្បលាបៈមានសត្វជាអារម្មណ៍ខ្លះ ដោយអំណាចនៃរូបដែលបានឃើញហើយ សម្លេងដែលបានឮហើយ ក្លិន រស និងផោដ្ឋព្វៈដែលបានជ្រាបហើយ និងធម្មារម្មណ៍ ដែលបានដឹងហើយ ។

អភិជ្ឈា ក៏ដូចគ្នា (តែ) ព្យាបាទៈ មានសត្វជាអារម្មណ៍តែម្យ៉ាង (ចំណែក) មិច្ឆាទិដ្ឋិ មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

បទថា **វេទនតោ** សេចក្ដីថា បាណាតិបាត មានវេទនាជាទុក្ខ ។ ព្រោះថា ព្រះរាជាទាំងឡាយទ្រង់ឃើញចោរហើយ សូម្បីទឹងទ្រង់ញញឹមបណ្ដើរ ត្រាស់បញ្ជាបណ្ដើរថា យកវាទៅសម្លាប់ ដូច្នេះក៏ពិត តែចេតនាដែលជាអ្នកប្រើឲ្យសម្លាប់ជីវិតសត្វ ក្នុងព្រះហឫទ័យរបស់ព្រះរាជាទាំងនោះ ជាចេតនាដែលប្រកបដោយទុក្ខវេទនា ។

អទិន្នាទាន មានវេទនា ៣ មិច្ឆាចារ មានវេទនា ២ ដោយអំណាចនៃសុខវេទនា និងឧបេក្ខាវេទនា ។ តែមិនមែនមានវេទនាជាឧបេក្ខា ព្រោះចិត្តជាអ្នកឲ្យសម្រេច ។ មុសាវាទ មានវេទនា ៣ ។ បិសុណាវាចាក៏ដូចគ្នា ។ ផរុសវាចា មានវេទនាជាទុក្ខតែម្យ៉ាង ។ សម្ផប្បលាបៈ មានវេទនា ៣ ។ អភិជ្ឈា មានវេទនា ២ ដោយអំណាចនៃសុខវេទនា និងឧបេក្ខាវេទនា ។ មិច្ឆាទិដ្ឋិក៏ដូចគ្នា ។ ( តែ ) ព្យាបាទមានវេទនាជាទុក្ខ ។

## អធិប្បាយ អកុសលមូល

បទថា **មូលតោ** សេចក្ដីថា បាណាតិបាត មានអកុសល ២ យ៉ាង ជា

មូលដោយអំណាចនៃទោសៈ និងមោហៈ ។

អទិន្នាទាន ( មានអកុសល ២ យ៉ាងជាមូល ) ដោយអំណាចនៃទោសៈ និងមោហៈ ឬដោយអំណាចនៃលោភៈ និងមោហៈ មិច្ឆាចារ ( មានអកុសល ២ យ៉ាងជាមូល ) ដោយអំណាចនៃលោភៈ និងមោហៈ ។ មុសាវាទ ដោយអំណាចនៃទោសៈ និងមោហៈ ឬលោភៈ និងមោហៈ ។

បិសុណាវាចា និងសម្ផប្បលាបៈ ក៏ដូចគ្នា ( នឹងមុសាវាទ ) ។ ផរុសវាចា ដោយអំណាចនៃទោសៈ និងមោហៈ ។ អភិជ្ឈា មានអកុសលតែមួយជាមូល ដោយអំណាចនៃមោហៈ ។

ព្យាបាទក៏ដូចគ្នា ( នឹងអភិជ្ឈា ) ។ ( តែ ) មិច្ឆាទិដ្ឋិ មានអកុសល ២ យ៉ាងជាមូល ដោយអំណាចនៃលោភៈ និងមោហៈ ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា លោភោ អកុសលមូលំ ជាដើម ( ដូចតទៅនេះ) ។

អកុសលធម៌ ដែលឈ្មោះថា លោភៈ ព្រោះចង់បាន ។ ដែលឈ្មោះថា ទោសៈ ព្រោះប្រទូសរ៉ាយ ។ ដែលឈ្មោះថា មោហៈ ព្រោះវង្វេង ។

ក្នុងចំនួនអកុសលធម៌ទាំង ៣ យ៉ាងនោះ លោភៈឈ្មោះថា ជាអកុសលមូល ព្រោះខ្លួនជាអកុសល ព្រោះអត្ថថា មានទោស និងមានទុក្ខជាវិបាក ទាំងជាឫសគល់របស់អកុសលធម៌ទាំងនេះ មានបាណាតិបាតជាដើម ព្រោះអត្ថថា ជាសភាពនៃសម្បយុត្តធម៌របស់អកុសលពួកខ្លះ ហើយព្រោះអត្ថថា ជាឧបនិស្សយប្បច្ច័យរបស់អកុសលពួកខ្លះ ។ សមពិតដូចពាក្យដែលព្រះសារីបុត្ត

បានពោលទុកថា បុគ្គលអ្នកត្រេកអរខ្លាំងហើយ ត្រូវរាគៈគ្របសង្កត់ហើយ មានចិត្តត្រូវរាគៈរួបរឹតហើយ រមែងសម្លាប់សត្វមានជីវិតបាន ដូច្នេះជាដើម សូម្បីក្នុងការដែលទោសៈ និងមោហៈជាអកុសលមូល ក៏មានន័យនេះដូចគ្នា ។

## អធិប្បាយ កុសលកម្មបថ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បាណាតិបាតា វេរមណី កុសលំ** ( ចេតនាវៀរចាកបាណាតិបាតជាកុសល ) ជាដើម ដូចតទៅនេះ អកុសល-កម្មបថទាំងឡាយ មានបាណាតិបាតជាដើម មានអធិប្បាយដូចដែលខ្ញុំបានពោលមកហើយនោះឯង ។

ចេតនាដែលឈ្មោះថា **វេរមណី** ព្រោះញាំញីពៀរ អធិប្បាយថា លះបង់ពៀរបាន ។ម្យ៉ាងទៀត បុគ្គលវៀរចាកពៀរបាន ព្រោះចេតនានេះជាហេតុ ព្រោះហេតុនោះ ចេតនានោះទើបឈ្មោះថា **វេរមណី** ដោយផ្លាស់ **វិ** អក្សរ ឲ្យជា **វេ** អក្សរ ។ នេះជាការបរិយាយសេចក្ដីក្នុងពាក្យថា **វេរមណី** នេះ ដោយព្យញ្ជនៈមុន ។ ចំណែកការបរិយាយសេចក្ដីក្នុងអត្ថ ( សេចក្ដី ) គប្បីជ្រាបថា **វិរតិ** ដែលសម្បយុត្តជាមួយនឹងកុសលចិត្ត ឈ្មោះថា **វេរមណី** ។ វិរតិរបស់អ្នកវៀរចាកបាណាតិបាត ដែលត្រាស់ទុកយ៉ាងនេះថា ការវៀរចាកបាណាតិបាតក្នុងសម័យនោះ ដូច្នេះ ឈ្មោះថា វិរតិដែលសម្បយុត្តជាមួយនឹងកុសលចិត្ត ។

## អធិប្បាយ វិរតិ ៣

វិរតិនោះ ចែកជាប្រភេទមាន ៣ យ៉ាង គឺ សម្បត្តវិរតិ ១ សមាទាន-វិរតិ ១ សមុច្ឆេទវិរតិ ១ ។

ក្នុងចំនួនវិរតិទាំង ៣ នោះ វិរតិ ដែលកើតឡើងដល់អ្នកមិនបានសមាទានសិក្ខាបទទាំងឡាយ ( មកពីមុន ) តែបានពិចារណាដល់ជាតិ វ័យ និងភាពជាពហុស្សូតជាដើម របស់ខ្លួនហើយ ឃើញថា មិនសមគួរដល់យើងមានការធ្វើយ៉ាងនេះ ហើយមិនកន្លងនូវវត្ថុដែលប្រាកដនៅចំពោះមុខ គប្បីជ្រាបថា ជាសម្បត្តវិរតិ ដូចវិរតិរបស់ចក្កនៈឧបាសក ក្នុងសីហឡទ្វីប ។

## និទាន ដោយសម្បត្តវិរតិ

បានឮថា ក្នុងពេលគេនៅកម្មោះនោះឯង មាតារបស់គេកើតរោគ ហើយពេទ្យប្រាប់គេថា គួរនឹងបានសាច់ទន្សាយស្រស់ ៗ ។ ( មកផ្សំថ្នាំ ) ។ លំដាប់នោះ បងប្រុសរបស់ចក្កនៈបញ្ជាថា ឯងចូលទៅស្រែនោះ ។ គេក៏បានទៅកាន់ស្រែនោះ ។ ហើយពេលនោះ មានទន្សាយមួយមកស៊ីស្មៅខ្ចី ។ ទន្សាយឃើញហើយប្រញាប់រត់គេចចេញទៅ តែរត់ទៅជាប់វល្លិ ទើបបញ្ចេញសម្លេងស្រែកក្រែក ៗ (ក្រិ ក្រិ) ឡើង ។ ចក្កនៈទៅតាមសម្លេងនោះ ចាប់ទន្សាយបានតាំងចិត្តថា នឹងយកវាមកធ្វើជាថ្នាំឲ្យម៉ែ តែក៏គិតឡើងមកថា មិនជាការសមគួរសម្រាប់យើងដែលនឹងសម្លាប់ជីវិតសត្វដទៃ ឬយកជីវិតម៉ែរបស់យើង ។ ទើបនិយាយថា ទៅចុះ ឯងចូរទៅបរិភោគស្មៅ និងទឹករួមជាមួយនឹងទន្សាយទាំងឡាយក្នុងព្រៃចុះ ហើយក៏ប្រលែងវាទៅ កាលត្រឡប់មកដល់ផ្ទះ គេត្រូវបងប្រុសសួរថា យ៉ាងណាហើយប្អូន បានទន្សាយទេ ? ទើបបានប្រាប់ការប្រព្រឹត្តទៅនោះឲ្យជ្រាប ។ ពេលនោះ បងប្រុសក៏បានស្តីបន្ទោសគេ ។ គេចូលទៅរកម៉ែហើយ បានឈរតាំងសច្ចាធិដ្ឋានថា ខ្ញុំតាំងពីកើតមក ចាំបានថា មិនធ្លាប់

មានចិត្តសម្លាប់ជីវិតសត្វឡើយ ។ រំពេចនោះឯង មាតារបស់គេ ក៏បានជាសះស្បើយអំពីរោគ ។

តែវិរតិ ដែលកើតឡើងដល់អ្នកបានសមាទានសិក្ខាបទមកហើយ សូម្បីនឹងលះជីវិតរបស់ខ្លួនក្នុងពេលសមាទានសិក្ខាបទ និងពេលបន្ទាប់អំពីនេះទៅ ក៏មិនកន្លងវត្ថុ គប្បីជ្រាបថា ជាសមាទានវិរតិ ដូចវិរតិរបស់ឧបាសកអ្នកភ្នំឧត្តរ-វឌ្ឍមានៈ ។

## និទាន ដោយសមាទានវិរតិ

បានឮមកថា ឧបាសកនោះ ទទួលសិក្ខាបទក្នុងសម្នាក់របស់ព្រះបិង្គល-ពុទ្ធរក្ខិតត្ថេរ អ្នកស្រុកអម្ពរយវិហារ ហើយទៅភ្ជួរស្រែ ។ តមក គោរបស់គាត់បាត់ទៅ ។ គាត់កាលតាមរកវា បានឡើងលើភ្នំឧត្តរវឌ្ឍមានៈ ។ ពស់ធំបានរុំព័ទ្ធគាត់នៅភ្នំនោះ ។ គាត់គិតថា នឹងយកកាំបិតដ៏មុតនេះ កាត់ក្បាលវាចោល តែក៏បានគិតទៀតថា ការដែលសមាទានសិក្ខាបទក្នុងសំណាក់របស់គ្រូ អ្នកគួរឲ្យរាប់អានហើយ ទម្លាយចោលមិនសមគួរឡើយ ។ លុះគិតយ៉ាងនេះ ដល់ ៣ ដង ហើយក៏កាត់ចិត្តថា យើងនឹងលះបង់ជីវិត មិនព្រមលះបង់សិក្ខាបទ ( សីល ) ហើយបានក្រវែងកាំបិតដ៏មុតដែលលីនៅលើស្មា ចូលព្រៃទៅ ។ ភ្លាមនោះឯងពស់ដ៏ធំ ក៏បានស្រាយខ្លួនចេញ ហើយលូនទៅ ។

## អធិប្បាយ សមុច្ឆេទវិរតិ និងកុសលកម្មបថ

ចំណែកវិរតិ ដែលសម្បយុត្តដោយអរិយមគ្គគួរជ្រាបថា ជាសមុច្ឆេទវិរតិ ដែលចាប់ផ្តើមពីកើតហើយ ព្រះអរិយៈទាំងឡាយ មិនធ្លាប់សូម្បីតែនឹងកើតការ

គិតថា យើងនឹងសម្លាប់សត្វមានជីវិត ដូច្នេះ ។

តែវិរតិនេះ លោកហៅថា កុសល ព្រោះប្រព្រឹត្តទៅជាមួយនឹងការឆ្ងាត ឈ្លាស ម្យ៉ាងទៀត លោកហៅថា កុសល ព្រោះកាត់ផ្តាច់នូវភាពជាអ្នកទ្រុស្ត-សីល ដែលបានរៀបរាប់ថា **កុសះ** ព្រោះជាទីកាត់ផ្តាច់នូវបាបអកុសល ដ៏លាមក ។ តែមិនបានហៅថា កុសល ព្រោះមិនសមនឹងបញ្ហានេះថា ម្នាលអាវុសោ កុសល តើដូចម្តេច ?

## វិនិច្ឆ័យដោយអាការ ៥ យ៉ាង

ម្យ៉ាងទៀត កុសលកម្មបថទាំងនេះ ក៏គួរជ្រាបវិនិច្ឆ័យដោយអាការ ៥ យ៉ាង គឺ ដោយធម៌ ( **ធម្មតោ** ) ១ ដោយកោដ្ឋាសៈ ( **កោដ្ឋាសតោ** ) ១ ដោយអារម្មណ៍ ( **អារម្មណតោ** ) ១ ដោយវេទនា ( **វេទនតោ** ) ១ ដោយមូល ( **មូលតោ** ) ១ ដូចអកុសលកម្មបថទាំងឡាយដែរ ។

បណ្តាបទទាំងនោះ បទថា ធម្មតោ សេចក្តីថា ក្នុងចំនួនកុសលកម្មបថសូម្បីទាំងនេះ កម្មបថ ៧ ប្រការ តាមលំដាប់ជាតួចេតនា វិរតិទាំង ៣ ប្រការចុងក្រោយ ( មនោកម្ម ៣ ) ជាធម៌សម្បយុត្តជាមួយនឹងចេតនា ។

បទថា កោដ្ឋាសតោ សេចក្តីថា កុសលធម៌ ៧ ប្រការតាមលំដាប់ជាកម្មបថតែម្យ៉ាង មិនជាមូល ។ ( តែ ) កុសលធម៌ ៣ ប្រការខាងចុងទាំងជាកម្មបថទាំងជាមូល ។ អធិប្បាយថា អនភិជ្ឈា ដែលដល់កម្មបថហើយ ទើបឈ្មោះថាជា អលោភកុសលមូល ។ តែអព្យាបាទ ឈ្មោះថា ជាអទោស-កុសលមូល ។ ចំពោះសម្មាទិដ្ឋិ ឈ្មោះថា ជាអមោហកុសលមូល ។

បទថា អារម្មណតោ សេចក្ដីថា អារម្មណ៍ទាំងឡាយ មានបាណាតិបាតជាដើមនោះឯង ជាអារម្មណ៍របស់វេរមណី ( ចេតនាវៀរចាកបាណាតិបាតជាដើម ) ទាំងនោះព្រោះថា វេរមណីនឹងមានបាន ក៏ដោយបានប្រសព្វនឹងវត្ថុដែលនឹងត្រូវឈានកន្លងប៉ុណ្ណោះ ឧបមាដូចអរិយមគ្គ ( ត្រូវ ) មាននិព្វានជាអារម្មណ៍ ទើបនឹងលះបង់កិលេសបាន យ៉ាងណា កម្មបថទាំងនេះក៏គប្បីជ្រាបថា ដូច្នោះដូចគ្នា ( ត្រូវ ) មានជីវិតិន្ទ្រិយ៍ជាដើម ជាអារម្មណ៍ ទើបនឹងលះការទ្រុស្តសីល មានបាណាតិបាតជាដើមបាន ។

បទថា វេទនាតោ សេចក្ដីថា កុសលកម្មបថទាំងអស់ប្រកបនឹងសុខវេទនាខ្លះ ប្រកបនឹងឧបេក្ខាវេទនាខ្លះ ព្រោះពោលដល់កុសលហើយ នឹងមិនមានទុក្ខវេទនា ( កម្មបថចំណែកកុសល មិនមានឲ្យផលជាទុក្ខ ) ។

បទថា មូលតោ សេចក្ដីថា កម្មបថ ៧ មានមូល ៣ ដោយអំណាចនៃអលោភៈ អទោសៈ និងអមោហៈ ចំពោះអ្នកវៀរចាកដោយចិត្តសម្បយុត្តដោយញាណ តែមានមូល ២ ចំពោះអ្នកវៀរចាកដោយចិត្តប្រាសចាកញាណ ។ អនភិជ្ឈា មានមូល ២ សម្រាប់អ្នកវៀរចាកដោយចិត្តសម្បយុត្តដោយញាណ មានមូល ១ សម្រាប់អ្នកវៀរចាកដោយចិត្តដែលប្រាសចាកញាណ តែអលោភៈខ្លួនឯង ជាមូលរបស់ខ្លួនឯងមិនបាន ។ សូម្បីក្នុងអព្យាបាទ ក៏ទំនងដូចគ្នានេះឯង ។ សម្មាទិដ្ឋិ មានមូល ២ ដូចគ្នា ដោយអំណាចនៃអលោភៈ និងអទោសៈដូច្នោះ ។

កុសលធម៌ឈ្មោះថា អលោភៈ ក្នុងពាក្យថា អលោភោ កុសលមូលំ

ជាដើម ព្រោះមិនលោភ ។ ពាក្យថា **អលោភ** នេះ ជាឈ្មោះរបស់ធម៌ដែលជាបដិបក្ខនឹងលោភៈ ។ សូម្បីអទោសៈ និងអមោហៈ ក៏មានទំនងដូចគ្នានេះឯង ។

ក្នុងចំនួនកុសលមូលទាំង ៣ យ៉ាងនោះ អលោភៈ ដែលឈ្មោះថា ជាកុសលមូល ព្រោះខ្លួនឯងក៏ជាកុសល និងឈ្មោះថា ជាមូលរបស់កុសលធម៌ទាំងឡាយ មានការវៀរចាកបាណាតិបាតជាដើម ទាំងនេះផង ព្រោះអត្ថថា ជាបច្ច័យនៃសម្បយុត្តធម៌របស់កុសលពួកខ្លះ និងព្រោះអត្ថថា ជាឧបនិស្សយប្បច្ច័យរបស់កុសលធម៌ពួកខ្លះ ។

ក្នុងការដែលអទោសៈ និងអមោហៈ ជាកុសលមូល ក៏ន័យនេះឯង ។

## អរិយសច្ចក្នុងកម្មបថ

ឥឡូវនេះ ព្រះសារីបុត្តកាលនឹងបញ្ចប់សេចក្តីនោះទាំងអស់ដែលលោកបានសម្តែងទុកហើយ ទាំងដោយសង្ខេប និងដោយពិស្តារម្តងទៀត ទើបបានពោលអប្បនាវារៈទុក មានជាអាទិ៍ថា **យតោ ខោ អាវុសោ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯវំ អកុសលំ បជានាតិ** សេចក្តីថា ដឹងច្បាស់អកុសល ដោយអំណាចនៃអកុសលកម្មបថ ១០ តាមដែលសម្តែងទុកហើយយ៉ាងនេះ សូម្បីក្នុងបទមានជាអាទិ៍ថា **ឯវំ អកុសលមូលំ** ក៏ន័យនេះឯង ។

ដោយហេតុត្រឹមតែប៉ុណ្ណោះ គឺ ដោយន័យដូចគ្នា ជាការដែលព្រះសារីបុត្ត បានពោលដល់កម្មដ្ឋាន ដែលជាហេតុនាំសត្វចេញ ( ចាកភព ) រហូតដល់ព្រះអរហត្ត សម្រាប់អ្នកបំពេញកម្មដ្ឋាន មានចតុរារិយសច្ចជាអារម្មណ៍ ។

ពោលទុកដូចម្តេច ?

ពោលទុកថា ការពិត អកុសលកម្មបថ ១០ និងកុសលកម្មបថ ១០ វៀរអភិជ្ឈា ( លោកពោលថា ) ជាទុក្ខសច្ច ក្នុងកម្មបថវារៈនេះ ចំណែកធម៌ទាំង ២ យ៉ាងនេះ គឺ អភិជ្ឈា ១ លោភៈដែលជាអកុសលមូល ១ ( លោកពោលថា ) ជាសមុទយសច្ចដោយត្រង់ ។ តែកម្មបថទាំងអស់ ( លោកពោលថា ) ជាទុក្ខសច្ចដោយអម ។ កុសលមូល និងអកុសលទាំងអស់ ( លោកពោលថា ) ជាសមុទយសច្ច ។ ការមិនប្រព្រឹត្តទៅនៃកុសល និងអកុសលមូលទាំង ២ ( លោកពោលថា ) ជានិរោធសច្ច ។ កាលកំណត់ដឹងទុក្ខ ការលះបង់សមុទ័យ ការដឹងច្បាស់និរោធ អរិយមគ្គ ( លោកពោលថា ) ជាមគ្គសច្ច សច្ចៈទាំង ២ លោកបានពោលទុកហើយដោយសរុប ដូចដែលពណ៌នាមកនេះ ។ ចំណែកសច្ចៈ ២ យ៉ាង ( និរោធ , មគ្គ ) គប្បីជ្រាបដោយអំណាចនៃការមិនវិលត្រឡប់ ។

បទថា **សោ សព្វសោ រាគានុសយំ បហាយ** ( លោកលះបង់រាគានុស័យបានដោយប្រការទាំងពួង ) សេចក្ដីថា លោកដឹងច្បាស់អកុសលជាដើមយ៉ាងនេះ នឹងលះបង់រាគានុស័យបានដោយអាការគ្រប់យ៉ាង ។

បទថា **បដិឃានុសយំ បដិវិនោទេត្វា** ( បន្ទោបង់បដិឃានុស័យ ) មានពាក្យដែលលោកពោលទុកថា នាំបដិឃានុស័យចេញបានដោយប្រការទាំងពួង ដោយពាក្យត្រឹមតែប៉ុណ្ណោះ ព្រះថេរៈបានពោលដល់អនាគាមិមគ្គ ។

បទថា **អស្មីតិ ទិដ្ឋិមានានុសយា សមោហនិត្វា** ( ដកទិដ្ឋិមានានុស័យថាយើងមានចេញ ) សេចក្ដីថា ដកទិដ្ឋិមានានុស័យ ដែលប្រព្រឹត្តទៅដោយអាការ

ប្រកាន់រួមគ្នានេះថា យើងមាន ដោយធ្វើធម៌ប្រការខ្វះក្នុងខន្ធ ៥ មិនឲ្យធ្លាក់ចុះ ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋិមានានុសយំ** លោកអធិប្បាយទុកថា បានដល់ មានានុស័យដែលប្រហែលនឹងទិដ្ឋិ ។ ព្រោះថា មានានុស័យនេះ ប្រហែលគ្នានឹងទិដ្ឋិ ព្រោះមានលក្ខណៈប្រព្រឹត្តទៅថា យើងមាន ព្រោះហេតុដូច្នេះ ទើបលោកបានពោលទុកយ៉ាងនេះ ។ម្យ៉ាងទៀត អ្នកប្រាថ្នានឹងយល់ **អស្មិមានះ** នេះ ដោយពិស្តារសូមមើល ខេមកសូត្រ ក្នុងខន្ធកវគ្គចុះ ។

បទថា **អវិជ្ជំ បហាយ** សេចក្តីថា លះអវិជ្ជាដែលជាឫសគល់របស់វដ្តៈ ។

បទថា **វិជ្ជំ ឧប្បាទេត្វា** សេចក្តីថា ញ៉ាំងវិជ្ជា គឺ ព្រះអរហត្តមគ្គដែលបំផ្លាញអវិជ្ជានោះឲ្យកើតឡើង ។ ដោយពាក្យត្រឹមប៉ុណ្ណេះព្រះសារីបុត្តបានពោលដល់អរហត្តមគ្គ ។

សេចក្តីថា **ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ** ( ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះ ) សេចក្តីថា ជាអ្នកធ្វើការកាត់ផ្តាច់វដ្តទុក្ខក្នុងអត្តភាពនេះឯង ។

ព្រះសារីបុត្តញ៉ាំងទេសនាឲ្យចប់ទៅ ដោយពាក្យថា **ឯត្តាវតាបិ ខោ អាវុសោ** អធិប្បាយថា សូម្បីដោយអំណាចនៃការចាក់ធ្លុះដោយមនសិការ ដូចដែលពោលហើយក្នុងការសំដែងកម្មបថនេះ ។ ពាក្យដ៏សេសមានន័យដូចដែលបានពោលមកហើយនោះឯង ។

ព្រះសារីបុត្រថេរៈបានបញ្ចប់ទេសនាដោយអនាគាមិមគ្គ និងអរហត្តមគ្គដូចដែលបានពណ៌នានេះឯង ។

( ចប់កថា ពោលដោយកម្មបថ )

## ភិក្ខុទាំងឡាយអនុមោទនាភាសិតរបស់ព្រះសារីបុត្រ

[១១២] ក្នុងពាក្យថា *សាធាវុសោ ខោ ។បេ។ អាគតោ ឥមំ សទ្ធម្មំ* មានពាក្យអធិប្បាយទុកថា ភិក្ខុទាំងនោះ លុះបានស្តាប់ធម្មទេសនា ពោលអំពីសច្ចៈទាំង ៤ របស់ព្រះសារីបុត្រ ដោយប្រធាន គឺ កុសល និងអកុសលយ៉ាងនេះហើយ ទើបត្រេកអរអនុមោទនាចំពោះភាសិតរបស់ព្រះសារីបុត្រ ដោយពាក្យនេះថា ម្នាលអាវុសោ ប្រពៃហើយ ហើយអនុមោទនាដោយចិត្តដែលជាសមុដ្ឋាននៃពាក្យនោះឯង ទទួលយកដោយវាចា រីករាយដោយចិត្ត ។

ឥឡូវ ព្រោះហេតុដែលព្រះថេរៈ ជាអ្នកអាចដែលនឹងសម្តែងធម៌ទេសនាពោលដោយចតុរិយសច្ចបាន ដូចដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រអាចនឹងប្រាប់ នឹងសម្តែងអរិយសច្ច ៤ បានដោយពិស្តារ ។ ឬព្រោះហេតុដែលព្រះសារីបុត្រត្រូវការនឹងសម្តែងធម៌ឲ្យខ្ពស់ឡើងទៅ ទើបបានពោលថា **ឯត្តាវតាបិ ខោ អាវុសោ** ( ដោយហេតុត្រឹមតែប៉ុណ្ណោះឯង ម្នាលអាវុសោទាំងឡាយ ) ព្រោះហេតុនោះ ភិក្ខុទាំងនោះ អ្នកប្រាថ្នានឹងស្តាប់សច្ចទេសនា ដោយន័យសូម្បីយ៉ាងដទៃ ទើបបានសួរបញ្ហាខ្ពស់ឡើងទៅនឹងព្រះសារីបុត្រ ។ ភិក្ខុទាំងនោះ ទើបបានសួរបញ្ហាដទៃដែលខ្ពស់ឡើងទៅ ដោយន័យនេះថា លោកម្ចាស់នៅមានទៀត ឬបរិយាយសូម្បីយ៉ាងដទៃ គឺ ហេតុសូម្បីយ៉ាងដទៃដែលល្អជាងបញ្ហា ដែលលោកម្ចាស់បានសួរខ្លួនឯង ឆ្លើយខ្លួនឯងមកហើយ ។

ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ភិក្ខុទាំងនោះបាននាំគ្នាសួរបញ្ហាក្នុង

ចំណែកដែលល្អជាងបញ្ហាមុនឡើងទៅ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ភិក្ខុទាំងឡាយ បានសួរបញ្ហាដំបូងឲ្យខ្ពង់ខ្ពស់ឡើងទៅទៀត ។

បន្ទាប់ពីនោះ ព្រះថេរៈ កាលនឹងព្យាករណ៍បញ្ហាឲ្យភិក្ខុទាំងនោះស្តាប់ ទើបបានពោលពាក្យមានជាអាទិ៍ថា **សិយា អាវុសោ** ម្នាលអាវុសោទាំងឡាយ ( នៅមានទៀត ) ដូច្នេះ ។

## កថាពណ៌នា អាហារវារៈ ( ភូត សម្ភវេសី )

[១១៣] ក្នុងបណ្តាបទទាំងនោះ ពាក្យអធិប្បាយតទៅនេះ នឹងជាពាក្យអធិប្បាយចំពោះបទដែលលំបាក ។

ពាក្យថា **អាហារ** បានដល់ បច្ច័យ ។ ព្រោះបច្ច័យនាំផលមកឲ្យខ្លួន ដូច្នោះ បច្ច័យ ទើបហៅថា អាហារ ។

ពួកសត្វដែលកើតហើយ ឈ្មោះថា **ភូត** ក្នុងពាក្យទាំងឡាយ មានជាអាទិ៍ថា **ភូតានំ វា សត្តានំ** ។ ពួកសត្វដែលស្វែងរក គឺ ស្វែងរកការសម្ភព គឺ ការកើត បានដល់ ការកើតឡើង ឈ្មោះថា **សម្ភវេសី** ។

បណ្តាកំណើតទាំង ៤ យ៉ាងនោះ ពួកសត្វដែលកើតក្នុងពង និងដែលកើតក្នុងពពុះទឹក ដរាបណាដែលនៅមិនទាន់ទម្លាយក្រសោមពង និងស្រោមសម្រាល ( ចេញមក ) ដរាបនោះ ក៏នៅឈ្មោះថា **សម្ភវេសី** កាលទម្លាយក្រ-សោមពង និងស្រោមសម្រាលចេញមកខាងក្រៅហើយ ទើបឈ្មោះថា **ភូត** ។

ចំណែកសត្វដែលជាសំសេទជកំណើត និងឧបបាតិកកំណើតក្នុងខណៈនៃចិត្តដួងដំបូង ឈ្មោះថា **សម្ភវេសី** តាំងពីខណៈនៃចិត្តដួងទី ២ ទៅ ឈ្មោះថា

ភូត ។

ម្យ៉ាងទៀត សត្វទាំងឡាយនឹងកើតដោយឥរិយាបថណាក៏ដោយ ដរាបណានៅមិនទាន់ផ្លាស់ប្តូរឥរិយាបថមួយទៅឥរិយាបថមួយនោះ ដរាបនោះឈ្មោះថា **សម្ភវេសី** ផ្លាស់ប្តូរឥរិយាបថនោះទៅ ទើបឈ្មោះថា **ភូត** ។ ម្យ៉ាងទៀត ពួកសត្វដែលកើតហើយ គឺ កើតឡើងហើយ ( សម្រេចហើយ ) ឈ្មោះថា **ភូត** ព្រះខីណាស្រពពួកណា ដែលជាព្រះអរិយជាម្ចាស់ហើយនោះឯង រាប់ថានឹងមិនកើតទៀត ពាក្យថា **ភូត** នេះ ជាឈ្មោះរបស់ព្រះខីណាស្រពទាំងនោះ ។

សត្វពួកណាកំពុងស្វែងរកទីកើត សត្វពួកនោះ ឈ្មោះថា **សម្ភវេសី** ពាក្យថា **សម្ភវេសី** នេះ ជាឈ្មោះរបស់ព្រះសេក្ខៈ និងបុថុជ្ជនអ្នកកំពុងស្វែងរកការកើតតទៅ ព្រោះលះបង់សំយោជនៈក្នុងភពមិនទាន់បាន ។

កាលបើដូច្នេះ ដោយ ២ បទនេះ សូម្បីក្នុងទីគ្រប់កន្លែង ( សេចក្តី ) ទើបសំដៅដល់សត្វគ្រប់ប្រភេទ ។ ហើយ **វា** សព្ទ ក្នុងពាក្យថា **ភូតានំ វា សត្តានំ** នេះជាសម្បិណ្ឌនត្ថ ( មានសេចក្តីរួម មិនមែនជាវិកប្បត្ថ ) ។ ព្រោះហេតុដូច្នោះ អ្នកសិក្សាគប្បីជ្រាប ( ថាស្មើនឹង ) សេចក្តីនេះថា **ភូតានំ ច សម្ភវេសីនញ្ច** ( ទាំងភូត ទាំងសម្ភវេសី ) ។

បទថា **ឋិតិយា** បានដល់ ដើម្បីឋិតនៅ ។

បទថា **អនុគ្គហាយ** បានដល់ ដើម្បីអនុគ្រោះ គឺ ដើម្បីឧបការៈ ។

ទាំងពីរបទគឺ **ភូតានំ វា សម្ភវេសីនំ** នោះ មានការផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ តែសេចក្តីនៃបទទាំងពីរនោះ ដូចគ្នា ។

បទថា **ឋិតិយា** (ដើម្បីតាំងនៅ) គឺ ដើម្បីមិនឲ្យធម៌ទាំងឡាយដែលកើតឡើងហើយដល់សត្វនុ៎ះៗ ដាច់ជាចំណែកទៅ ដោយមិនអាចជាប់តគ្នាបាន ។

បទថា **អនុគ្គហាយ** ដើម្បីអនុគ្រោះ បានដល់ដើម្បីឲ្យធម៌ដែលនៅមិនទាន់កើត បានកើតឡើង ។

ហើយទាំង ២ បទនេះ គួរប្រើក្នុងសេចក្ដីទាំងពីរយ៉ាងនេះថា ដើម្បីការតាំងនៅ និងដើម្បីអនុគ្រោះភូតទាំងឡាយផង ដើម្បីការតាំងនៅ និងដើម្បីអនុគ្រោះសម្ភវេសីទាំងឡាយផង ។

## កវឡិង្ការាហារ

អាហារដែលនឹងត្រូវធ្វើឲ្យជាពំនូតៗទៅហើយទំពាស៊ី ឈ្មោះថា **កវ-លិង្ការាហារ** ។ ពាក្យថា កវឡិង្ការាហារនេះ ជាឈ្មោះរបស់ឱជៈ ដែលមានបាយ និង នំស្រស់ ( កុម្មាស ) ជាដើមជាទីតាំង ។

ពីរបទថា **ឱឡារិកោ វា សុខុមោ វា** សេចក្ដីថា ( អាហារ ) ឈ្មោះថា ឱឡារៈ ព្រោះជារបស់ដែលគ្រោតគ្រាតដោយវត្ថុ ឈ្មោះថា **សុខុម** ព្រោះជារបស់ដែលល្អិតដោយវត្ថុ ។

តែដោយសភាវៈ **កវឡិង្ការាហារ** ឈ្មោះថា ជារបស់ល្អិតពិត ព្រោះជាសុខុមរូប ។ សូម្បីថា ការដែលអាហារនោះនឹងជារបស់គ្រោតគ្រាត និងជារបស់ល្អិតដោយវត្ថុ ក៏ត្រូវដឹងបាន ព្រោះឧបាទាយរូប ។ ពិតណាស់ អាហាររបស់សត្វក្ងោក ក៏ឈ្មោះថា ជារបស់ល្អិត ព្រោះប្រៀបធៀបនឹងអាហារសត្វក្រពើ ។ បានឮថា ពួកសត្វក្រពើលេបដុំថ្មចូលទៅ ហើយដុំថ្មទាំងនោះធ្លាក់ដល់

ពោះរបស់ក្រពើប៉ុណ្ណោះ ក៏រលាយអស់ ( រលាយទៅ ) ។ ពួកសត្វក្ងោកចឹក ស៊ីសត្វមានជីវិតដូចជាពស់ និងខ្យងជាដើម ។ តែអាហាររបស់សត្វក្អែក ឈ្មោះ ថាជារបស់ល្អិត ព្រោះប្រៀបធៀបនឹងអាហាររបស់សត្វក្ងោក ។

បានឮថា ក្អែកទាំងនោះកកេរឆ្អឹង ( សត្វ ) ដែលបោះចោលអស់ ៣ ឆ្នាំ បាន ក៏ស្អែង និងឆ្អឹងសត្វទាំងនោះ លុះតែត្រូវទឹកមាត់របស់វាប៉ុណ្ណោះ ក៏ផុយ រលួយ ដូចមើមដំឡូង ។

អាហាររបស់ពួកសត្វដំរី ឈ្មោះថា ជារបស់ល្អិត ព្រោះប្រៀបធៀបនឹង អាហាររបស់ក្អែក ពួកវាបរិភោគមែកឈើផ្សេងៗ ។ អាហាររបស់សត្វទាំងឡាយ ដូចជាគោព្រៃ រមាស និងម្រឹគជាដើម ឈ្មោះថា ជារបស់ល្អិតជាងអាហារដំរី ។ បានជ្រាបថា ពួកវានាំគ្នាស៊ីស្លឹកឈើផ្សេង ៗ ជាដើមដែលមិនរឹង ( មិនមាន ខ្លឹម ) ។ អាហាររបស់ពួកគោ ឈ្មោះថា ជាអាហារល្អិតជាងអាហាររបស់សត្វ រមាសជាដើមទាំងនោះ ។ ពួកវាស៊ីស្មៅស្រស់ និងស្មៅស្ងួត ។ អាហាររបស់ សត្វទន្សាយ ជាអាហារល្អិតជាងអាហាររបស់ពួកសត្វគោ ។ អាហាររបស់ ពួកបក្សីល្អិតជាងអាហាររបស់ទន្សាយ ។ អាហាររបស់អ្នកជាយដែន ល្អិតជាង អាហាររបស់បក្សី ។ អាហាររបស់អ្នកក្រុងល្អិតជាងអាហាររបស់អ្នកជាយដែន ។ អាហាររបស់ព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ល្អិតជាងអាហាររបស់អ្នក ក្រុង ។ ព្រះក្រយាហាររបស់ព្រះចៅចក្រពត្តិល្អិតជាងអាហាររបស់មនុស្សស្រួប្បី ទាំងនោះ ។ អាហាររបស់ពួកទេវតាជាន់ចាតុម្មហារាជិកា ល្អិតជាងអាហាររបស់ ពួកភុម្មទេវតា ។ អាហារ ( របស់ពួកទេវតាជាន់ផ្សេង ៗ ) ក៏គួរពង្រីកឲ្យពិស្តារ

យ៉ាងនេះទៅ រហូតដល់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។ អាហាររបស់ពួកទេវតាជាន់ទាំងនោះត្រូវយល់ថា ជាអាហារល្អិតទាំងអស់ ។ ម្យ៉ាងទៀត ក្នុងវត្ថុគ្រោតគ្រាតនេះ ឱជាក៏តិច មានកម្លាំងតិច ។ ក្នុងវត្ថុល្អិត ឱជាមានកម្លាំងខ្លាំង ។ ពិតយ៉ាងនោះ អ្នកហុតយាគូពេញទាំងបាត្រ មួយភ្លែតប៉ុណ្ណោះក៏ហៅ ចង់ទីងទំពាស៊ីរបស់ណាមួយនោះឯង ។ ចំណែកអ្នកផឹកទឹកដោះថ្លា សូម្បីត្រឹមតែមួយទូកដៃក៏មិនចង់ស៊ី ( មិនហៅ ) រហូតមួយថ្ងៃ ។ ក្នុងចំនួនវត្ថុ និងឱជា ២ យ៉ាងនោះ វត្ថុបន្ទោបង់ភាពក្រវល់ក្រវាយ ( ហៅ ) បាន តែមិនអាចរក្សា ( ជីវិត ) ទុកបាន ។ ( ចំណែក ) ឱជារក្សាជីវិតទុកបាន តែមិនអាចបន្ទោបង់ភាពក្រវល់-ក្រវាយ ( ហៅ ) បាន ។ តែទាំង ២ យ៉ាងនោះ រួមចូលគ្នាហើយបន្ទោបង់ភាពក្រវល់ក្រវាយ ( ហៅ ) បានផង រក្សា ( ជីវិត ) បានផង ដូច្នេះឯង ។

## ផស្សាហារ មនោសញ្ចេតនាហារ វិញ្ញាណាហារ

បទថា **ផស្សោ ទុតិយោ** សេចក្តីថា ផស្សៈទាំង ៦ យ៉ាង មានចក្ខុសម្ផស្សៈជាដើម គប្បីជ្រាបថា ជាអាហារប្រភេទទី ២ ក្នុងចំនួនអាហារ ៤ យ៉ាងនោះ ។ ក៏ន័យនេះ ជាន័យនៃទេសនាប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ទើបមិនគួរស្វែងរកពាក្យនេះថា អាហារទី ២ និងទី ៣ ក្នុងអាហារវារៈនេះ ។

ចេតនានោះឯង លោកហៅថា **មនោសញ្ចេតនាហារ** ។

ចិត្តដូចណាមួយ ឈ្មោះថា **វិញ្ញាណ** ។

ក្នុងរឿងនេះ ព្រះសារីបុត្របានពោលទុកថា បើមានពាក្យសួរថា សត្វតាំងនៅបានព្រោះបច្ច័យ តាំងនៅបានព្រោះអាហារ កាលបើដូច្នោះ ហេតុអ្វី កាល

បច្ច័យរបស់សត្វទាំងឡាយសូម្បីយ៉ាងដទៃមាន ទើបព្រះអង្គត្រាស់អាហារ ទុក ៤ យ៉ាងនេះ ប៉ុណ្ណោះ ។

ខ្ញុំនឹងពោលឆ្លើយថា ព្រះអង្គត្រាស់ទុក ព្រោះជាបច្ច័យពិសេសនៃសន្តតិដែលប្រព្រឹត្តទៅខាងក្នុង ។ អធិប្បាយថា **កវឡិង្ការាហារ** ជាបច្ច័យពិសេសរបស់របកាយរបស់សត្វទាំងឡាយ អ្នកមានកវឡិង្ការាហារជាអាហារ ផស្សាហារជាបច្ច័យពិសេសរបស់វេទនាក្នុងពួកនាម មនោសញ្ចេតនាហារជាបច្ច័យពិសេសរបស់វិញ្ញាណ វិញ្ញាណជាបច្ច័យពិសេសរបស់នាមរូប ដូចដែលព្រះមានព្រះភាគបានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ រាងកាយនេះ អាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបាន យ៉ាងណា ។ ដូចជាវេទនាកើតមានព្រោះផស្សៈជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ ។

សួរថា ក៏ក្នុងអាហារវារៈនេះ អាហារអ្វី នាំអ្វីមកឲ្យ ?

ឆ្លើយថា កវឡិង្ការាហារ នាំរូបមានឱជា ជាទី ៨ មកឲ្យ ( អវិនិព្ភោគរូប ៨ ) ផស្សាហារនាំវេទនា ៣ មកឲ្យ មនោសញ្ចេតនាហារ នាំភពទាំង ៣ មកឲ្យ វិញ្ញាណនាំនាមរូបក្នុងបដិសន្ធិមកឲ្យ ។

នាំមកឲ្យ ដូចម្តេច ?

( នាំឲ្យកើតយ៉ាងនេះ ) គឺ កវឡិង្ការាហារ ត្រឹមតែដាក់ក្នុងមាត់ប៉ុណ្ណោះ ក៏ជាសមុដ្ឋាននៃរូបទាំង ៨ ( សាងរូបទាំង ៨ ឡើង ) ចំណែកដុំបាយមួយដុំ ៗ ដែលធ្មេញទំពាឲ្យល្អិតលេបចូលទៅ នឹងជាសមុដ្ឋាននាំឲ្យកើតរូបឡើងមួយដុំ ៗ

៨ រូបប៉ុណ្ណោះ ។ កវឡិង្ការាហារ នាំរូបមានឱជាជាទី ៨ មកឲ្យយ៉ាងនេះ ។ ចំណែកផស្សាហារ គឺ ផស្សៈដែលនឹងឲ្យកើតសុខវេទនា កាលកើតឡើងនឹងនាំសុខវេទនាមកឲ្យ ។ ផស្សៈដែលនឹងឲ្យកើតទុក្ខវេទនាក៏ដូច្នោះ គឺ នឹងនាំទុក្ខ-វេទនាមកឲ្យ ។ ដែលនឹងឲ្យកើតអទុក្ខមសុខវេទនាក៏នឹងនាំអទុក្ខមសុខមកឲ្យ ។ ផស្សាហារនឹងនាំវេទនាទាំង ៣ មកឲ្យ ដោយប្រការទាំងពួង ដូចដែលពណ៌នាមកនេះ ។

មនោសញ្ចេតនាហារ គឺ កម្ម ដែលនឹងឲ្យចូលដល់កាមភព និងនាំកាមភពមកឲ្យ ។ ដែលនឹងឲ្យចូលដល់រូបភព និងអរូបភព ក៏នឹងនាំរូបភព និងអរូបភពមកឲ្យ ។ មនោសញ្ចេតនាហារ នឹងនាំភពទាំង ៣ មកឲ្យយ៉ាងនេះ សូម្បីដោយប្រការទាំងពួង ។

តែវិញ្ញាណាហារ លោកពោលថា នឹងនាំខន្ធទាំង ៣ ដែលសម្បយុត្តដោយវិញ្ញាណនោះ និងរូប ៣០ យ៉ាង ដែលកើតឡើងដោយអំណាចនៃសន្តតិ ៣ មកឲ្យ ដោយន័យនៃបច្ច័យ មានសហជាតប្បច្ច័យជាដើម ក្នុងបដិសន្ធិខណៈ ។ វិញ្ញាណាហារ នាំនាមរូបក្នុងបដិសន្ធិខណៈមកឲ្យ យ៉ាងនេះដូច្នេះ ។

មួយ៉ាងទៀត ក្នុងអាហារវារៈនេះ កុសលចេតនា និងអកុសលចេតនាដែលនៅមានអាសវៈនោះឯង លោកពោលទុកថា មនោសញ្ចេតនាហារនឹងនាំភពទាំង ៣ មកឲ្យ បដិសន្ធិវិញ្ញាណនោះឯង លោកពោលទុកថា វិញ្ញាណនឹងនាំនាមរូប ក្នុងបដិសន្ធិខណៈមកឲ្យ ។ តែអាហារ ៣ យ៉ាងនេះ គប្បីជ្រាបថាជាអាហារដោយមិនប្លែកគ្នា ។

ព្រោះនាំមកនូវធម៌ដែលសម្បយុត្តជាមួយនឹងវិញ្ញាណនោះ និងធម៌ដែលជាសមុដ្ឋាននៃវិញ្ញាណនោះ ។

ក្នុងចំនួនអាហារ ៤ យ៉ាងនោះ កវឡិង្ការាហារកាលឧបត្ថម្ភគាំទ្រ ( ជីវិត ) រមែងឲ្យសម្រេចកិច្ច គឺ ការនាំ ( រូប ) មក ។ ផស្សៈ កាលពាល់ត្រូវនោះឯង ( រមែងឲ្យសម្រេចកិច្ច គឺ ការនាំវេទនាមក ) ។ មនោសញ្ចេតនា ការប្រមូលមកនោះឯង ( រមែងឲ្យសម្រេចកិច្ច គឺ ការនាំភពមក ) ។ វិញ្ញាណ ការដឹងច្បាស់នោះឯង ( រមែងឲ្យសម្រេចកិច្ច គឺ ការនាំនាមរូបក្នុងបដិសន្ធិខណៈមក ) ។

យ៉ាងណា ?

( យ៉ាងនេះគឺ ) ពិតណាស់ កវឡិង្ការាហារ កាលឧបត្ថម្ភគាំទ្រ ( ជីវិត ) នោះឯង នឹងមានការធ្វើឲ្យសត្វទាំងឡាយតាំងនៅបាន ដោយការឧបត្ថម្ភរាងកាយឲ្យប្រព្រឹត្តទៅ ព្រោះថា រាងកាយនេះ សូម្បីកម្មតាក់តែងឲ្យកើត កវឡិង្ការាហារ ក៏ឧបត្ថម្ភគាំទ្រទុក ទើបតាំងនៅបានរហូតដល់កំណត់អាយុ ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ដូចទារកដែលមាតាឱ្យកើតហើយ មេដោះឲ្យផឹកទឹកដោះជាដើម ចិញ្ចឹមថែរក្សា ទើបតាំងនៅបានយូរ ។ ដូចផ្ទះដែលប្រើឈើទ្រុល ទ្រុលទុក ។

សមពិតតាមព្រះពុទ្ធវចនៈថា សូមថ្វាយព្រះពរមហាបពិត្រ កាលផ្ទះនឹងរលំ មនុស្សទាំងឡាយនឹងយកឈើដទៃមកទល់ ផ្ទះនោះ ដែលត្រូវឈើដទៃទល់ទប់ធ្វើឲ្យតាំងនៅបាន កាលបើដូច្នោះ ផ្ទះនោះនឹងមិនរលំដួល យ៉ាងណា សូមថ្វាយព្រះពរមហាបពិត្រ ព្រះរាជសម្ភារ រាងកាយនេះ ក៏ដូច្នោះដូចគ្នានោះឯង តាំងនៅបានព្រោះអាហារ អាស្រ័យអាហារ ទើបតាំងនៅបាន ។ កវឡិង្ការាហារ

កាលឧបត្ថម្ភគាំទ្រកាយយ៉ាងនេះ រមែងឈ្មោះថា ឲ្យសម្រេចនាទីរបស់អាហារ ( ការនាំរូបមក ) សូម្បីកាលឲ្យសម្រេចអាហារកិច្ចយ៉ាងនេះ កវឡិង្ការាហារ ក៏ឈ្មោះថា ជាបច្ច័យរបស់រូបសន្តតិ ២ យ៉ាង គឺ ជាបច្ច័យរបស់រូប ដែលមានអាហារជាសមុដ្ឋានផង រូបដែលតណ្ហា និងទិដ្ឋិកាន់យកហើយផង ។ កវឡិង្កា-រាហារ ជាអ្នកតាមរក្សាកម្មជរូប ( រូបកើតអំពីកម្ម ) ហើយជាអ្នកឲ្យកំណើតដល់រូប ដែលមានអាហារជាសមុដ្ឋាន ។

ចំណែកផស្សៈ កាលពាល់ត្រូវអារម្មណ៍ដែលជាទីតាំងនៃសេចក្តីសុខជាដើមនោះឯង ឈ្មោះថា មានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការវិលវល់ទៅនៃសុខវេទនាជាដើម ។

មនោសញ្ចេតនា ការប្រមូលមក ដោយអំណាចនៃកុសលកម្ម និងអកុសលកម្មនោះនោះឯង ឈ្មោះថា មានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការញ៉ាំងឫសគល់របស់ភពឲ្យសម្រេច ។

វិញ្ញាណ ការដឹងច្បាស់នោះឯង ឈ្មោះថា មានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការប្រព្រឹត្តទៅនៃនាមរូប ។

## ភ័យក្នុងអាហារ ៤

ក្នុងអាហារ ៤ យ៉ាងនេះ ដែលឲ្យសម្រេចអាហារកិច្ច ដោយអំណាចនៃការឧបត្ថម្ភជាដើម គួរឃើញភ័យ ៤ ប្រការយ៉ាងនេះ គឺ ក្នុងកវឡិង្ការាហារ បានដល់ភ័យ គឺ ការប្រាថ្នា ( ចំណង់ ) ក្នុងផស្សាហារ បានដល់ ភ័យ គឺ ការ

ជាប់ជំពាក់ ( ជាប់ ) នោះឯង ក្នុងមនោសញ្ចេតនាហារ បានដល់ ភ័យ គឺ ការប្រមូលមក ( សន្សំ ) នោះឯង ក្នុងវិញ្ញាណាហារ បានដល់ ភ័យ គឺ ការធ្លាក់ចុះចំពោះ ( ការកាន់យកកំណើត ) ។

ព្រោះហេតុអ្វី ?

ព្រោះថាសត្វទាំងឡាយសាងភ័យ គឺ សេចក្តីប្រាថ្នាក្នុងកវឡិង្ការាហារ ត្រូវប្រឈមមុខចំពោះភាពរងាជាដើម ធ្វើការងារ មានការរាប់ដោយម្រាមដៃជាដើម ដើម្បីត្រូវការអាហារ រមែងចូលដល់ទុក្ខមិនមែនតិច ។ ហើយបុគ្គលចំពូកខ្លះ សូម្បីនឹងបួសក្នុងព្រះសាសនានេះក៏ស្វែងរកអាហារ ដោយការស្វែងរកដែលមិនសមគួរ មានវេជ្ជកម្មជាដើម និងជាអ្នកត្រូវរិះគន់តិះដៀលក្នុងបច្ចុប្បន្ននេះ ។

សូម្បីក្នុងសម្បរាយិកភព ក៏នឹងជាសមណប្រេត ដោយន័យដែលបានពោលទុកហើយក្នុងលក្ខណសំយុត្តមានជាអាទិ៍ថា សូម្បីសង្ឃាដិរបស់លោកត្រូវភ្លើងឆេះសន្ធោសន្ធៅហើយ ហើយការប្រាថ្នាក្នុងកវឡិង្ការាហារនោះឯង គប្បីជ្រាបថា ជាភ័យ ព្រោះហេតុនោះសិនចុះ ។

ជនទាំងឡាយអ្នកមានអស្សាទៈក្នុងផស្សៈ សូម្បីកាលបានជួបប្រទះនឹងផស្សៈ ក៏នឹងបៀតបៀនរបស់ទាំងឡាយ មានប្រពន្ធជាដើម របស់អ្នកដទៃដែលគេរក្សា ។ អ្នកម្ចាស់ទ្រព្យនឹងចាប់គេ ព្រមដោយរបស់កាប់ឲ្យដាច់ជាកំណាត់ ៗ បោលត្រង់គំនរសម្រាម ឬប្រគល់ខ្លួនដល់ព្រះរាជា ។ តពីនោះ ព្រះរាជាក៏នឹងត្រាស់បញ្ជាឲ្យពួកគេធ្វើការងារផ្សេង ៗ ( ដាក់ទោស ) ។ និងព្រោះកាយបែកធ្លាយទៅ ពួកគេបានទទួលភ័យ គឺ ទុគ្គតិ ។ កម្ម ដែលមានអស្សាទៈក្នុងផស្សៈ

ជាមូលដ្ឋាន ជាហេតុឲ្យប្រសព្វភ័យទាំងក្នុងបច្ចុប្បន្ន និងសម្បរាយិកភពដោយពិត ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ការប្រាថ្នាក្នុងផស្សាហារនោះឯង គប្បីជ្រាបថាជាភ័យ ។ តែភ័យក្នុងទាំងភព ៣ ដែលមានកុសល និងអកុសល-កម្មនោះ ជាមូលដ្ឋាន នឹងមានមកទាំងអស់ ព្រោះការប្រមូលមកនូវកុសលកម្ម និងអកុសលកម្មនោះឯង ។ ព្រោះហេតុនេះ ការប្រមូលមកក្នុងមនោសញ្ចេតនា-ហារនោះឯង គប្បីជ្រាបថាជាភ័យ ។

ចំណែកបដិសន្ធិវិញ្ញាណ ក៏នឹងទទួលយកបដិសន្ធិនាមរូបនោះឯង កើតឡើងក្នុងទីដែលកាន់យកកំណើត កាលបដិសន្ធិវិញ្ញាណនោះកើតឡើងហើយ ភ័យគ្រប់យ៉ាង ក៏ជាការកើតឡើងដូចគ្នា ព្រោះមានបដិសន្ធិនោះជាមូលដ្ឋាន ព្រោះហេតុដូចដែលបានពណ៌នាមកហើយនោះឯង ការកាន់យកកំណើត ( ធ្លាក់ចុះចំពោះ ) គប្បីជ្រាបថា ជាភ័យក្នុងវិញ្ញាណាហារ ដូច្នេះឯង ។

តែក្នុងចំនួនអាហារទាំង ៤ យ៉ាងនេះ ដែលជាភ័យយ៉ាងនេះ ដើម្បីនឹងឲ្យគ្រប់សង្កត់សេចក្តីប្រាថ្នាក្នុងកវឡិង្ការាហារ ព្រះសម្មាសម្ពុទ្ធ ទ្រង់ទើបសម្តែងការប្រៀបធៀបដោយសាច់របស់បុត្រ ដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ប្តីប្រពន្ធទាំងពីរសូម្បី យ៉ាងណា ។

ដើម្បីឲ្យគ្រប់សង្កត់ចំណង់ក្នុងផស្សាហារ ទើបទ្រង់សម្តែងការប្រៀប-ធៀបដោយមេគោដែលត្រូវពន្លះស្បែក ដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ មេគោដែលត្រូវគេពន្លះស្បែកចេញហើយ សូម្បីយ៉ាងណា ។

ដើម្បីឲ្យគ្រប់សង្កត់សេចក្តីប្រាថ្នា ក្នុងមនោសញ្ចេតនាហារ ទើបទ្រង់

សម្តែងការប្រៀបធៀបដោយរណ្តៅរងើកភ្លើង ដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ រណ្តៅរងើកភ្លើង សូម្បីយ៉ាងណា ។

ដើម្បីឲ្យគ្របសង្កត់សេចក្តីប្រាថ្នាក្នុងវិញ្ញាណាហារ ទើបទ្រង់សម្តែងការប្រៀបធៀបដោយការចាក់ដោយលំពែង ៣០០ លំពែង ដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ដែលចោរអ្នកប្រព្រឹត្តអាក្រក់ សូម្បីយ៉ាងណា ។

នេះជាការប្រកបសេចក្តីដោយសង្ខេប ដោយអធិប្បាយសេចក្តីឲ្យជាក់ច្បាស់ក្នុងអាហារវារៈនោះ ។

## ប្រៀបធៀប ស្វាមីភរិយាស៊ីសាច់បុត្ត

បានឮមកថា ពីរនាក់ប្តីប្រពន្ធពបុត្រដើរផ្លូវកន្តារ ១០០ យោជន៍ ដោយស្បៀងបន្តិចបន្តួច ។ កាលគេដើរទៅបាន ៥០ យោជន៍ ស្បៀងក៏អស់ទៅ ។

គេទាំងពីរសោប់សោល់ ព្រោះការហេវហត់ នាំគ្នាអង្គុយក្រោមម្លប់នៃដើមឈើដែលមានស្លឹករើង ៗ បន្ទាប់អំពីនោះ ខាងបុរសបាននិយាយនឹងភរិយាថា នាងអើយរយៈផ្លូវ ៥០ យោជន៍ជុំវិញៗ នេះ មិនមានស្រុក ឬនិគមឡើយ ព្រោះហេតុដូច្នោះ ឥឡូវនេះ បងមិនអាចនឹងធ្វើការងារដ៏ច្រើន ដែលបុរសនឹងគប្បីធ្វើបាន មានការធ្វើស្រែ និងចិញ្ចឹមគោជាដើមបាន ណ្ហើយនាង ចូរសម្លាប់បង ហើយបរិភោគសាច់មួយចំណែក មួយចំណែកទៀតយកធ្វើជាស្បៀងដើរឆ្លងផ្លូវកន្តារ ទៅជាមួយនឹងកូនចុះ ។

ចំណែកនាង បាននិយាយជាមួយនឹងស្វាមីថា បងអើយបង ឥឡូវនេះ

អូនមិនអាចនឹងធ្វើការងារ ដែលស្ត្រីនឹងធ្វើ មានការរវៃអំបោះជាដើមដ៏ច្រើនបាន ណ្ហើយបង ចូរសម្លាប់អូន ហើយបរិភោគសាច់មួយចំណែក មួយចំណែកទៀត យកទៅធ្វើជាស្បៀង ធ្វើដំណើរឆ្លងផ្លូវកន្តារទៅជាមួយនឹងកូនចុះ ។

ចំណែកបុរសដែលជាប្តី បាននិយាយនឹងភរិយាទៀតថា អូនអើយ ព្រោះមេផ្ទះស្លាប់ ការស្លាប់នឹងប្រាកដដល់យើងទាំងពីរនាក់ឪពុកកូន ព្រោះកូនក្មេងតូចវៀរមាតាហើយ នឹងមិនអាចមានជីវិតនៅបាន តែបើយើងទាំងពីរនាក់នៅមានជីវិតក៏នឹងបានកូនទៀត ណ្ហើយចុះ ឥឡូវនេះ យើងនឹងសម្លាប់កូនយកសាច់បរិភោគឆ្លងផ្លូវកន្តារ ។

លំដាប់នោះ ម្តាយបាននិយាយជាមួយនឹងកូនថា កូនអើយចូរកូនទៅរកឪពុកចុះ ។ កូនក៏ទៅ ( រកឪពុក ) ។ បន្ទាប់ពីនោះ ឪពុករបស់កូននិយាយថា បងបានសោយទុក្ខមកមិនមែនតិច ព្រោះការធ្វើស្រែចំការចិញ្ចឹមគោដោយសង្ឃឹមថានឹងចិញ្ចឹមកូន ទើបបងមិនអាចនឹងសម្លាប់កូនបានទេ នាងនោះឯង ចូរសម្លាប់កូននាងចុះ ដូច្នេះ ហើយបានប្រាប់កូនថា កូនអើយ ចូរកូនទៅរកម៉ែឯងចុះ ។ កូនក៏បានទៅ ( រកម៉ែ) សូម្បីម៉ែរបស់កូននោះ ក៏បាននិយាយថា ខ្ញុំកាលចង់បានកូន បានសោយទុក្ខមិនតិច ដោយការប្រព្រឹត្តខ្លួនដូចជាគោ ប្រព្រឹត្តខ្លួនដូចជាសុនខ ហើយអង្វរសូមចំពោះទេវតាជាដើម មិនចាំបាច់និយាយថ្វី ដល់ការបីបាច់រក្សាគភ៌ ទើបខ្ញុំមិនអាចនឹងសម្លាប់កូនបាន ហើយបានប្រាប់កូនថា កូនអើយ កូនឯងចូរទៅរកឪពុកចុះ ។ កូននោះ កាលដើរទៅដើរមកក្នុងរវាងឪពុកម្តាយទាំងពីរយ៉ាងនេះ ក៏បានស្លាប់ទៅ ។

ពីរនាក់ប្ដីប្រពន្ធនោះ ឃើញកូនស្លាប់ នាំគ្នាទួញយំ យកសាច់កូនមកបរិភោគ ហើយចៀសចេញទៅតាមន័យដែលបានពោលទុកហើយតាំងពីដើម ។

គេទាំង ២ នាក់នោះ មិនបានយកសាច់បុត្របរិភោគជាអាហារដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់តុបតែង មិនមែនដើម្បីតាក់-តែង តែដើម្បីត្រូវការឆ្លងឲ្យផុតផ្លូវកន្តារតែម្យ៉ាង ប៉ុណ្ណោះឯង ព្រោះជារបស់បដិកូលដោយហេតុ ៩ ប្រការ ។

ប្រសិនបើនឹងសួរថា បដិកូលដោយហេតុ ៩ ប្រការនោះ តើអ្វីខ្លះ ?

ឆ្លើយថា គឺ ព្រោះជាសាច់ដែលកើតអំពីខ្លួន ១ ព្រោះជាសាច់របស់ញាតិ ១ ព្រោះជាសាច់របស់កូន ១ ព្រោះជាសាច់របស់កូនជាទីស្រឡាញ់ ១ ព្រោះជាសាច់របស់ក្មេងខ្ចី ១ ព្រោះជាសាច់ឆៅ ១ ព្រោះជាសាច់ដែលមិនមែនសម្រាប់បរិភោគ ១ ព្រោះមិនបានដាក់អំបិល ១ ព្រោះមិនបានចម្អិន ១ ។

ព្រោះហេតុដូច្នោះ ភិក្ខុណា ឃើញកវឡិង្ការាហារដូចជាសាច់កូនយ៉ាងនេះ លោកនឹងគ្របសង្កត់ ( បន្ទោបង់ ) ការជាប់ជំពាក់ក្នុងកវឡិង្ការាហារនោះបាន ។ នេះជាការប្រកបសេចក្ដី ក្នុងសេចក្ដីឧបមាដោយសាច់បុត្ត ដូច្នេះឯង ។

## ការប្រៀបធៀប មេគោដែលត្រូវពន្លះស្បែក

ចំណែកក្នុងសេចក្ដីប្រៀបធៀបដោយមេគោដែលពន្លះស្បែក គប្បីជ្រាបអធិប្បាយដូចតទៅនេះ មេគោនោះ គេពន្លះស្បែកតាំងពីករហូតដល់ក្រចកចេញទៅ ហើយប្រលែងចោល វានឹងត្រូវសត្វមានជីវិតខាំនៅក្នុងទីដែលវាអាស្រ័យ ។

នឹងមានតែរឿងទុក្ខប៉ុណ្ណោះ យ៉ាងណា ។ សូម្បីផស្សៈ ក៏ដូច្នេះដូចគ្នា អាស្រ័យវត្ថុ ឬអារម្មណ៍ណាៗ បិតនៅ នឹងមានតែរឿងទុក្ខ ដែលបានសោយហើយប៉ុណ្ណោះ ដែលកើតអំពីវត្ថុ និងអារម្មណ៍នោះ ៗ ។

ព្រោះដូច្នោះ ភិក្ខុណា ឃើញនូវផស្សាហារថា ដូចជាមេគោដែលគេពន្លះស្បែកយ៉ាងនេះ ភិក្ខុនោះនឹងគ្របសង្កត់ការជាប់ជំពាក់ក្នុងផស្សាហារនោះបាន ។ នេះជាការប្រកបសេចក្តី ក្នុងការប្រៀបធៀបដោយមេគោដែលគេពន្លះស្បែក ។

## ប្រៀបធៀប រណ្តៅរងើកភ្លើង

តែក្នុងការប្រៀបធៀបដោយរណ្តៅរងើកភ្លើង គប្បីជ្រាបអត្ថាធិប្បាយដូចតទៅនេះ ភពទាំង ៣ ដូចរណ្តៅរងើកភ្លើង ព្រោះអត្ថថា ក្តៅគគុក មនោសញ្ចេតនាដូចជាបុរស ២ នាក់ ម្នាក់ៗ នាំគ្នាចាប់ដៃទាញទម្លាក់ក្នុងរណ្តៅរងើកភ្លើងនោះ ព្រោះអត្ថថា អូសកន្ទ្រាក់ចូលទៅកាន់ភពទាំងឡាយ ។

ព្រោះដូច្នោះ ភិក្ខុណាពិចារណាឃើញមនោសញ្ចេតនាហារថា ដូចជារណ្តៅរងើកភ្លើងយ៉ាងនេះ ភិក្ខុនោះ នឹងគ្របសង្កត់ការជាប់ជំពាក់ក្នុងមនោសញ្ចេតនាហារបាន ។ នេះជាការប្រកបសេចក្តីក្នុងការប្រៀបធៀប ដោយរណ្តៅរងើកភ្លើង ។

## ប្រៀបធៀប ការចាក់ដោយលំពែង

ចំណែកក្នុងការប្រៀបធៀប ការត្រូវចាក់ដោយលំពែង ៣០០ លំពែង

គប្បីជ្រាបអត្ថាធិប្បាយដូចតទៅនេះ ក្នុងវេលាព្រឹក បុរសម្នាក់ក្តៅក្រហាយ ព្រោះលំពែង ១០០ ទាំងឡាយណា ។ លំពែងទាំងឡាយនោះ ចាក់រាងកាយរបស់គេឲ្យមានមុខដំបៅដល់ទៅ ១០០ កន្លែង ធ្លុះទៅមិនមានសល់ចន្លោះ ក្នុងកាលតមកក៏ជ្រុះចេញទៅ ។ លំពែង ១០០ លំពែងផ្សេង ៗ ទៀត ក៏យ៉ាងនោះកាលបើដូច្នេះ ទើបធ្លុះធ្លាយពេញរាងកាយ ព្រោះលំពែងច្រើន ដែលបាញ់ចេញទៅ មិនត្រូវកន្លែងដែលលំពែង ១០០ ( គ្រាមុន ) នោះ មុតហើយក៏ទេ ។

ទុក្ខរបស់បុរសនោះ ដែលកើតឡើង ព្រោះមុខរបួស សូម្បីមុខរបួសតែមួយ ក៏រកប្រមាណមិនបានទៅហើយ ។ នឹងចាំបាច់ពោលទៅថ្វីដល់ទុក្ខដែលកើតឡើង ព្រោះមុខរបួស ៣០០ កន្លែង ។

បណ្តាហេតុការណ៍ទាំងនោះ បដិសន្ធិដូចពេលដែលលំពែងធ្លាក់ត្រូវ ។ ការកើតឡើងនៃខន្ធ ដូចជាការកើតមុខរបួស ការកើតឡើងនៃទុក្ខនានាដែលមានវដ្តៈជាមូលមានបាន ព្រោះខន្ធទាំងឡាយដែលកើតហើយ ដូចជាការកើតឡើងនៃទុក្ខវេទនា ព្រោះមុខរបួសទាំងឡាយ ។

ម្យ៉ាងទៀត បដិសន្ធិវិញ្ញាណ ដូចបុរសអ្នកប្រព្រឹត្តអាក្រក់ ។ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដូចមុខរបួសដែលកើតឡើងដល់បុរសនោះព្រោះត្រូវលំពែងទាំងឡាយមុតហើយ ។ គប្បីឃើញការកើតឡើង នៃទុក្ខមានប្រការផ្សេងៗ សម្រាប់វិញ្ញាណ ព្រោះមាននាមរូបជាបច្ច័យ ដោយអំណាចនៃកម្មករណ៍ ៣២ ប្រការ និងរោគ ៩៨ ប្រភេទជាដើម ដូចការកើតឡើងនៃទុក្ខធ្ងន់ ដល់បុរសនោះ ព្រោះមានមុខរបួសជាបច្ច័យ ។

ព្រោះហេតុនោះ ភិក្ខុណាពិចារណាឃើញវិញ្ញាណាហារថា ដូចជាត្រូវចាក់ដោយលំពែង ៣០០ យ៉ាងនេះ ភិក្ខុនោះ គួរបសង្កត់ការជាប់ជំពាក់ក្នុងវិញ្ញាណាហារបាន ។ នេះជាការប្រកបសេចក្តីក្នុងការប្រៀបធៀប ដោយការត្រូវចាក់ដោយលំពែង ៣០០ ។

លោកកាលគួរបសង្កត់ការជាប់ជំពាក់ក្នុងអាហារទាំងនេះ យ៉ាងនេះថា ឈ្មោះថា រមែងកំណត់ដឹងអាហារទាំង ៤ យ៉ាង ។ ក៏ការកំណត់ដឹងអាហារទាំងនោះហើយ វត្ថុដែលកំណត់ដឹងសូម្បីទាំងអស់ ក៏ជាការដែលកំណត់ដឹងហើយដូចគ្នា ។

សមពិតតាមដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយកំណត់ដឹងកវឡិង្ការាហារហើយ រាគៈដែលអាស្រ័យបញ្ចកាមគុណ ក៏ជាការដែលកំណត់ដឹងហើយដែរ ការកំណត់ដឹងរាគៈ ដែលអាស្រ័យបញ្ចកាមគុណហើយ នឹងមិនមានសំយោជនៈ ( កាមរាគសំយោជនៈ ) ដែលជាហេតុឲ្យអរិយសាវកអ្នកប្រកបហើយ មកកាន់លោកនេះទៀត ។

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកកំណត់ដឹងផស្សាហារហើយ វេទនាទាំង ៣ ក៏ជាការដែលអ្នកទាំងឡាយកំណត់ដឹងហើយដែរ ។ កាលអ្នកទាំងឡាយកំណត់ដឹងវេទនាទាំង ៣ ហើយ តថាគតពោលថា អរិយសាវកនឹងមិនមានកិច្ចអ្វីដែលនឹងត្រូវធ្វើឲ្យក្រៃលែងតទៅឡើយ ។

ម្នាលភិក្ខុទាំងឡាយ កាលកំណត់ដឹងមនោសញ្ចេតនាហារហើយ តណ្ហា ៣ ក៏ជាការដែលកំណត់ដឹងហើយដែរ ។ កាលកំណត់ដឹងតណ្ហា ៣ ហើយ តថា-

គតពោលថា អរិយសាវកនឹងមិនមានកិច្ចអ្វីដែលនឹងត្រូវធ្វើឲ្យក្រៃលែងជាងនោះទៀតឡើយ ។

ម្នាលភិក្ខុទាំងឡាយ កាលកំណត់ដឹងវិញ្ញាណាហារហើយ នាមរូបក៏ជាការដែលកំណត់ដឹងហើយ កាលកំណត់ដឹងនាមរូបហើយ តថាគតក៏ពោលថា អរិយសាវកនឹងមិនមានកិច្ចអ្វីដែលត្រូវធ្វើឲ្យក្រៃលែងជាងនេះទៀតឡើយ ។

## តណ្ហាកើត អាហារទើបកើត

បទថា **តណ្ហាសមុទយា អាហារសមុទយោ** មានសេចក្តីថា ព្រោះតណ្ហាពីអតីតៈកើតឡើង សមុទយៈ ( ហេតុឲ្យកើត ) គឺ ការកើតឡើងនៃអាហារទាំងឡាយ ដែលមានមកអំពីបដិសន្ធិ រមែងមានឡើង ។

មានដូចម្តេច ?

( មានយ៉ាងនេះគឺ ) ព្រោះក្នុងខណៈនៃបដិសន្ធិ នឹងមានឱជាដែលកើតឡើងហើយ ក្នុងខាងក្នុងរូបចំនួន ៣០ ដែលកើតឡើងដោយអំណាចនៃសន្តតិ ៣ នេះ គឺ កវឡិង្ការាហារដែលជាឧបាទិន្នកៈ ( មានចិត្តគ្រប់គ្រង ) កើតឡើងហើយព្រោះតណ្ហាជាបច្ច័យ ។ ចំណែកផស្សាហារ មានមនោសញ្ចេតនាហារ និងវិញ្ញាណាហារ ដែលជាឧបាទិន្នកៈទាំងនេះ គឺ ផស្សៈ និងចេតនាដែលសម្បយុត្តជាមួយនឹងបដិសន្ធិចិត្ត និងវិញ្ញាណ គឺ តួចិត្តនោះឯង កើតឡើងហើយ ព្រោះមានតណ្ហាជាបច្ច័យ ដូច្នេះឯង ។

គប្បីជ្រាបការកើតឡើងនៃអាហារទាំងឡាយដែលមានមកតាំងពីបដិសន្ធិ

ព្រោះតណ្ហាកាលមុនកើតឡើង ដូចដែលពណ៌នាមកដូច្នេះឯង ។

តែព្រោះហេតុដែលក្នុងអាហារវារៈនេះ ព្រះសារីបុត្តពោលដល់អាហារលាយគ្នា ទាំងអាហារដែលជាឧបាទិន្នកៈ ( ដែលមានចិត្តគ្រប់គ្រង ) និងដែលជាអនុបាទិន្នកៈ ( ដែលមិនមានចិត្តគ្រប់គ្រង ) ដូច្នោះ ទើបគួរជ្រាបការកើតឡើងនៃអាហារ ព្រោះតណ្ហាកើតឡើងយ៉ាងនេះ ចំណែកអាហារទាំងឡាយដែលជាអនុបាទិន្នកៈគប្បីដឹង ( ដូចតទៅនេះ ) ៖

ពិតណាស់ ឱជាមាននៅក្នុងរូបទាំងឡាយ ដែលកើតឡើងអំពីចិត្តសហគតដោយលោភៈ ៨ ដួងនេះ គឺ កវឡិង្ការាហារដែលជាអនុបាទិន្នកៈដែលកើតឡើងហើយ ព្រោះតណ្ហាដែលកើតឡើងព្រមគ្នាជាបច្ច័យ ចំណែកផស្សៈ ១ចេតនាដែលសម្បយុត្តជាមួយនឹងចិត្ត ដែលសហគតដោយលោភៈ ១ វិញ្ញាណ គឺ តួចិត្ត ១ រួមទាំង (៣ យ៉ាង) នេះ បានដល់ ផស្សាហារ មនោសញ្ចេតនាហារ និងវិញ្ញាណាហារ ដែលជាអនុបាទិន្នកៈកើតឡើងហើយ ព្រោះមានតណ្ហាជាបច្ច័យ ដូច្នេះឯង ។

## តណ្ហារលត់ អាហារទើបរលត់

ពីរបទថា **តណ្ហានិរោធា អាហារនិរោធោ** សេចក្តីថា ការរលត់ទៅនៃអាហាររមែងប្រាកដ ព្រោះការរលត់ទៅនៃតណ្ហា ដែលជាបច្ច័យរបស់អាហារទាំងឡាយ ទាំងដែលជាឧបាទិន្នកៈ ទាំងដែលជាអនុបាទិន្នកៈនេះ ។

ពាក្យដ៏សេស ( ក្រៅអំពីពាក្យដែលបានអធិប្បាយនេះ ) មានន័យដូច

ដែលបានពោលទុកហើយនោះឯង ។

ក្នុងអាហារវារៈនេះ ព្រះសារីបុត្តបានពោលដល់សច្ចៈទាំង ៤ ទុកដោយសរុបហើយ ។ ហើយក្នុងគ្រប់វារៈក្រៅអំពីនេះ លោកក៏បានពោលទុកដូចក្នុងអាហារវារៈនេះដែរ ព្រោះហេតុនោះឯង អ្នកសិក្សាដែលមិនវង្វេងគួរលើកសច្ចៈទាំងឡាយឡើងគ្រប់វារៈ ។ ហើយការប្រមូលទេសនាគ្រប់វារៈ ។ **ឯត្តាវតាបិ ខោ អាវុសោ** នេះ គួរប្រកបដោយអំណាចនៃធម៌ដែលសម្តែងហើយក្នុងវារៈនោះ ៗ ។ នេះជាការប្រកបសេចក្តីនោះក្នុងវារៈនេះ ដូច្នេះ ។

បទថា **ឯត្តាវតាបិ** នេះ សេចក្តីថា ការសម្តែងអំពីអាហារនេះ មានអធិប្បាយថា សូម្បីដោយអំណាចនៃការចាក់ធ្លុះដោយមនសិការៈ ដែលពោលមកហើយ ។ សូម្បីក្នុងគ្រប់បទក៏ទំនង ( ន័យ ) នេះ ។

" ចប់ កថាពណ៌នាអាហារវារៈ "

# កថាពណ៌នា សច្ចវារៈ

[១១៤] ឥឡូវនេះ ភិក្ខុទាំងនោះ លុះត្រេកអរអនុមោទនាភាសិតរបស់ព្រះថេរៈនោះ ដោយន័យដែលបានពោលទុកហើយក្នុងកាលមុនថា **សាធាវុសោ** ហើយ បានសួរបញ្ហាខ្ពស់ៗ តទៅទៀត ហើយព្រះថេរៈក៏បានឆ្លើយបញ្ហាដោយទំនងសូម្បីយ៉ាងដទៃដល់ភិក្ខុទាំងនោះ ។ ក្នុងគ្រប់វារៈ សូម្បីក្រៅអំពីវារៈនេះ ក៏មានន័យនេះ ។

[១១៥-២១៦] ព្រោះដូច្នោះ តអំពីនេះទៅខ្ញុំនឹងពន្រឹកសេចក្ដីនៃចម្លើយដែលព្រះថេរៈបានឆ្លើយទុកហើយ មិនទាក់ទងដល់ពាក្យបែបនេះ ។ តែដោយការសម្ដែងដោយសង្ខេបនូវវារៈនេះ ព្រះថេរៈបានសម្ដែងទុក្ខសច្ចទុកថា ពាក្យថា **ទុក្ខញ្ច បជានាតិ** ។ ចំណែកក្នុងការសម្ដែងដោយពិស្ដារ ពាក្យដែលនឹងត្រូវពោលទាំងអស់ បានពោលទុកហើយក្នុងសច្ចនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

" ចប់ កថាពណ៌នាសច្ចវារៈ "

## កថាពណ៌នា ជរាមរណវារៈ

[១១៧] តអំពីនេះទៅ ជាទេសនាពោលដោយបដិច្ចសមុប្បាទ ។

ក្នុងចំនួនវារៈទាំងនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងជរាមរណវារៈថា

បទថា **តេសំ តេសំ** នេះ ជាការសម្តែងទូទៅដល់សត្វចំនួនច្រើនទុកដោយសង្ខេប ។ ព្រោះថា ការសម្តែងអស់មួយថ្ងៃយ៉ាងនេះថា ការចាស់របស់ព្រះទេវទត្ត ការចាស់របស់សោមទត្ត ដូច្នេះ សត្វទាំងឡាយនឹងមិនត្រូវជរា-មរណៈ គ្របសង្កត់ ( ជរាមរណៈនឹងមិនគ្របសង្កត់ដល់សត្វទាំងអស់ មិនមាន ) ។ តែដោយបទទាំងពីរនេះ ( **តេសំ តេសំ** ) សត្វណាមួយ នឹងមិនត្រូវជរាមរណៈគ្របសង្កត់មិនមាន ( ជរាមរណៈគ្របសង្កាត់សត្វគ្រប់ប្រភេទ ) ។ ព្រោះដូច្នោះ ខ្ញុំម្ចាស់ទើបពោលទុកថា បទនេះ ជាការសម្តែងទូទៅដល់សត្វចំនួនច្រើនទុក ដោយសង្ខេប ។

បទទាំង ២ ថា **តម្ហិ តម្ហិ** នេះ ជាការសម្តែងទូទៅដល់ពួកសត្វចំនួនច្រើនដោយអំណាចនៃការកើតក្នុងគតិ ។

បទថា **សត្តនិកាយេ** ជាការសម្តែងសរុបដល់សត្វ ដែលបានសម្តែងទុកហើយដោយសាធារណនិទ្ទេស ។

ក៏បទថា **ជរា** ក្នុងពាក្យទាំងឡាយមានអាទិ៍ថា **ជរា ជីរណតា** ជាការសម្តែងដល់សភាវធម៌ ។

បទថា **ជីរណតា** ជាការសម្តែងដល់អាការ ។

បទទាំងឡាយមាន **ខណ្ឌិច្ចំ** ជាដើម ជាការសម្តែងដល់នាទី ( របស់

ជរា ) ព្រោះកន្លងកាលវេលាទៅ ។

ពីរបទក្រោយ ជាការសម្តែងដល់ ( នាទី ) តាមប្រក្រតី ព្រោះថា ជរានេះ ព្រះសារីបុត្តសម្តែងទុកដោយសភាវៈ ដោយបទថា **ជរា** ព្រោះដូច្នោះ បទនេះ ទើបជាបទសម្តែងដល់សភាវៈរបស់ជរានោះ ។

ដោយបទថា **ជីរណតា** នេះ ព្រះថេរបានសម្តែងទុកដោយអាការ ។ ព្រោះដូច្នោះ បទនេះ ទើបជាបទសម្តែងដល់អាការរបស់ជរានោះ ។

ដោយបទថា **ខណ្ឌិច្ចំ** នេះ ព្រះថេរបានសម្តែងដោយកិច្ច គឺ ការធ្វើភាវៈនៃធ្មេញ និងក្រចក ឲ្យបាក់ជាកំណាត់ ៗ ព្រោះកន្លងកាលវេលាទៅ ។

ដោយបទថា **បាលិច្ចំ** នេះ ព្រះថេរៈបានសម្តែងដោយកិច្ច គឺ ការធ្វើភាវៈនៃសក់ និងរោម ឲ្យស្កូវ ។ ដោយបទថា **វលិតតចតា** នេះ ព្រះថេរៈបានសម្តែងសូម្បីដោយកិច្ច គឺ ការធ្វើឲ្យសាច់ស្បែកយុរយារ ។ ដោយហេតុនោះ ស័ព្ទទាំង ៣ មាន **ខណ្ឌិច្ចំ** ជាដើមនេះ ទើបជាស័ព្ទសម្តែងដល់កិច្ចរបស់ជរានោះ ព្រោះកន្លងកាលវេលាទៅ ដោយស័ព្ទទាំង ៣ នោះ ព្រះថេរៈបានសម្តែងដល់ជរាដែលប្រាកដ គឺ ជាវត្ថុដែលប្រាកដដោយអំណាចឃើញភាពពិការទាំងនេះបាន ។

ឧបមាដូចថា ផ្លូវដើរនៃទឹកប្រាកដ ( ឲ្យឃើញបាន ) ព្រោះស្មៅកម្រើក និងដើមឈើជាដើមឲ្យដួលរលំ ឬផ្លូវដើររបស់ភ្លើងប្រាកដ ( ឲ្យឃើញបាន ) ព្រោះស្មៅ និងដើមឈើជាដើមឆេះ ។ ហើយផ្លូវដើរ ( របស់ទឹកជាដើម ) ក៏មិនមែនទឹកជាដើមទាំងនោះឡើយ ( ជាគន្លងមួយយ៉ាង ) យ៉ាងណា ។ ផ្លូវដើររបស់ជរា ក៏ដូច្នោះដូចគ្នា ជាធម្មជាតិប្រាកដ ( ឲ្យឃើញ ) ក្នុងអវយវៈទាំងឡាយមាន

ផ្ចេញជាដើម ដោយអំណាចនៃភាពពិការទាំងឡាយ មានការបាក់ជាដើម បុគ្គលសូម្បីបើកភ្នែកមើលហើយ ក៏ចាប់ពាល់បាន ។ និងផ្លូវដើររបស់ជរានោះ ដោយអំណាចនៃភាពពិការទាំងឡាយ មានសភាពបាក់ជាដើម ក៏មិនមែនជរា ។ ព្រោះជរា ជាធម្មជាតិមិនអាចដឹងបានដោយចក្ខុឡើយ ។ ( ត្រូវដឹងបានដោយបញ្ញា ) ។

តែដោយបទទាំងនេះថា **អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** ព្រះថេរៈបានសម្តែងជរាតាមប្រក្រតី ព្រោះការអស់ទៅនៃអាយុ ជារបស់ដែលដឹងបាន ព្រោះការចាស់នៃឥន្ទ្រិយ៍ មានចក្ខុជាដើម ព្រោះការឈានកន្លងកាលវេលាប៉ុណ្ណោះ ព្រោះហេតុដែលលោកជាអ្នកច្បាស់ក្រៃលែង ។

ព្រោះដូច្នោះ អាការ ២ ខាងក្រោយនេះ គប្បីជ្រាបថា ជាការសម្តែង ( អាការ ) តាមប្រក្រតីរបស់ជរានោះ ។

បណ្តាអាយុ និងឥន្ទ្រិយ៍ទាំង ២ យ៉ាងនោះ ព្រោះហេតុដែលអាយុរបស់អ្នកដល់ការចាស់ រមែងអស់ទៅ ( ច្រើនឡើង ) ដូច្នេះ ទើបលោកបានពោលជរាទុកដោយជិតចំពោះផល ( ជិតចំពោះសេចក្តីស្លាប់ ) ថា បានដល់ ការអស់ទៅនៃអាយុ អាយុច្រើន ។

តែព្រោះហេតុដែលកាលនៅកម្លោះ ឥន្ទ្រិយ៍ទាំងឡាយ មានភ្នែកជាដើម នៅស្រស់ថ្លាអាចទទួលយកអារម្មណ៍ ( មានរូបជាដើម ) របស់ខ្លួនសូម្បីដ៏ល្អិតបានដោយងាយ កាលចូលដល់ជរាហើយ និងចាស់ ស្រពាំង ស្រអាប់ មិនស្រស់ថ្លា អារម្មណ៍របស់ខ្លួនសូម្បីជារបស់គ្រោតគ្រាត ក៏មិនអាចនឹងទទួលបាន ដូច្នោះ ជរា ព្រះថេរៈទើបពោលទុកដោយសភាពជិតចំពោះផលថា ការចាស់នៃ

ឥន្ទ្រិយ៍ទាំងឡាយខ្វះ ។

## ជរា ២ យ៉ាង

ម្យ៉ាងទៀត ជរានោះ គឺ ជរាទាំងអស់ដែលសម្តែងមកហើយ យ៉ាងនេះ មាន ២ យ៉ាងគឺ **បាកដជរា** ( ការចាស់ដែលប្រាកដ ) ១ ។ **បដិច្ឆន្នជរា** ( ការចាស់ដែលមិនប្រាកដ ) ១ ។ ក្នុងចំនួនជរាទាំង ២ យ៉ាងនោះ ការដែលរូបធម៌ទាំងឡាយចាស់ ឈ្មោះថា **បាកដជរា** ព្រោះសម្តែងភាពវិការ មានការបាក់ជាដើមក្នុងអវយវៈទាំងឡាយ មានធ្មេញជាដើមឲ្យឃើញ ចំណែកក្នុងអរូបធម៌ ឈ្មោះថា **បដិច្ឆន្នជរា** ព្រោះមិនសម្តែងអាការវិការដូច្នោះ ឲ្យឃើញ ។

មានជរា ២ យ៉ាងដទៃទៀត យ៉ាងនេះគឺ **អវីចិជរា** ( ជរាមិនមានស្នាមឲ្យឃើញ ) ១ **សវីចិជរា** ( មានស្នាមឲ្យឃើញ ) ១ ក្នុងចំនួនជរា ២ យ៉ាងនោះ ជរារបស់កែវមណី មាស ប្រាក់ កែវប្រវាឡ ព្រះច័ន្ទ និងព្រះអាទិត្យជាដើម គប្បីជ្រាបថា ឈ្មោះថា **អវីចិជរា** អធិប្បាយថា ឈ្មោះថា ជរាមិនមានស្នាមចន្លោះ ( មិនមានស្នាមប្រាកដឲ្យឃើញ ) ព្រោះការបែកធ្លាយរបស់ពណ៌ជាដើម ក្នុងចន្លោះៗ ដឹងបានដោយលំបាក ដូចការបែកធ្លាយនៃពណ៌ជាដើម ក្នុងចន្លោះៗ របស់សត្វមានអាយុក្នុងវ័យមន្ទទសកៈ ( វ័យ ១០ ឆ្នាំ ) ជាដើម និងដូចការបែកធ្លាយនៃពណ៌ជាដើម ក្នុងចន្លោះៗ នៃវត្ថុដែលមិនមានវិញ្ញាណក្នុងដើមឈើ ផ្លែឈើ និងស្លឹកឈើជាដើម ។ តែជរាក្នុងវត្ថុដទៃក្រៅអំពីនោះតាមដែលពោលមកហើយ ឈ្មោះថា **សវីចិជរា** ព្រោះការបែកធ្លាយនៃ

ពណ៌ជាដើម ក្នុងចន្លោះ ៗ ជាវត្ថុដែលគប្បីដឹងបានងាយ ។

តអំពីនេះទៅ បទថា **តេសំ តេសំ** ជាដើម គប្បីជ្រាបដោយន័យ ដែលបានពោលមកហើយនោះឯង ។

ក៏បទថា **ចុតិ** ក្នុងពាក្យទាំងឡាយមានជាអាទិថា **ចុតិ ចវនតា** ជាដើម ព្រះថេរៈពោលទុកដោយអំណាចនៃសត្វអ្នកឃ្លាតទៅ ។

ពាក្យថា **ចុតិ** នេះ ជាពាក្យទូទៅសម្រាប់ខន្ធ ១ ខន្ធ ៤ និង ខន្ធ ៥ ។

ពាក្យថា **ចវនតា** ជាពាក្យសម្ដែងដល់លក្ខណៈ ( របស់ខន្ធ ) ដោយការឃ្លាតចាកការៈ ។

ពាក្យថា **ភេទោ** ជាពាក្យសម្ដែងដល់ការបែកធ្លាយ និងការកើតឡើងនៃខន្ធទាំងឡាយដែលចុតិ ។

ពាក្យថា **អន្តរធានំ** ជាពាក្យសម្ដែងដល់ភាវៈនៃការឃ្លាតចាកអំពីទីឋានដោយបរិយាយណាមួយ នៃចុតិខន្ធទាំងឡាយដែលបែកធ្លាយទៅ ដូចក្អមដែលបែកហើយដូច្នោះ ។ ការស្លាប់ ពោលគឺ មច្ចុ ឈ្មោះថា **មច្ចុមរណៈ** ។

ដោយស័ព្ទថា **មច្ចុមរណំ** នោះ ព្រះថេរៈបដិសេធសមុច្ឆេទមរណៈ ជាដើម ( ការស្លាប់ដោយការកាត់ផ្ដាច់នូវជាតិជាដើម ) ។ មច្ចុរាជ អ្នកធ្វើនូវទីបំផុត ( ទីបញ្ចប់ ) ឈ្មោះថា កាលៈ ការធ្វើកាលៈនោះ ឈ្មោះថា **កាលកិរិយា** ( ភាពដល់ការចាស់កម្ម ) ។ ដោយស័ព្ទថា **កាលកិរិយា** ដោយពាក្យថា កាល-កិរិយានេះ ព្រះថេរៈសម្ដែងដល់ការស្លាប់តាមសម្មតិរបស់សត្វលោក ។ តទៅនេះ ដើម្បីនឹងសម្ដែងដល់សេចក្ដីស្លាប់ដោយបរមត្ថ ព្រះអង្គទើបបានពោលពាក្យមាន

ជាអាទិ៍ថា **ខន្ធានំ ភេទោ** ។

ពិតណាស់ ដោយបរមត្ថ ខន្ធទាំងឡាយប៉ុណ្ណោះបែកធ្លាយ មិនមែនសត្វណាៗ ស្លាប់ឡើយ កាលខន្ធទាំងឡាយកំពុងបែកធ្លាយ សត្វក៏ឈ្មោះថា កំពុងស្លាប់ កាលបែកធ្លាយហើយ ក៏មានវោហារថា សត្វស្លាប់ហើយ ។

ក្នុងជរាមរណវារៈនេះ ការបែកធ្លាយនៃខន្ធទាំងឡាយ មានបានដោយចតុវោការភព ( នាមខន្ធ ៤ ) , ការដាក់ចុះសាកសព មានបានដោយឯកវោ-ការភព ( រូបខន្ធ ១ ) ឬការបែកធ្លាយនៃខន្ធទាំងឡាយ គប្បីជ្រាបដោយចតុ-វោការភព , ( ចំណែក ) ការដាក់ចុះនូវសាកសព គប្បីជ្រាបដោយអំណាចនៃភពទាំង ២ ដ៏សេស ( ឯកវោការភព និងបញ្ចវោការភព ) ។

ព្រោះហេតុអ្វី ?

ព្រោះសាកសព ពោលគឺ រូបកាយកើតឡើងចំពោះក្នុងភព ២ ប៉ុណ្ណោះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលខន្ធទាំងឡាយក្នុងទេវលោក និងព្រហ្មលោកមានចាតុម្មហារាជិកាជាដើម បែកធ្លាយទៅតែម្យ៉ាង មិនមានបោះបង់អ្វីទុកដូច្នេះ ការបែកធ្លាយនៃខន្ធទាំងឡាយ គប្បីជ្រាបដោយអំណាចនៃខន្ធទាំងឡាយ ក្នុងទេវលោក និងព្រហ្មលោក មានចាតុម្មហារាជិកាជាដើមទាំងនោះ ។ ( ចំណែក ) ការដាក់ចុះនូវសាកសព មាននៅក្នុងសត្វទាំងឡាយ មានមនុស្សជាដើម ។ ការស្លាប់ដោយការដាក់ចុះនូវសាកសព ព្រះថេរៈពោលថា ការដាក់ចុះនូវសាកសព ។ គប្បីជ្រាបអត្ថាធិប្បាយយ៉ាងនេះថា ទាំងជរា ទាំងមរណៈនេះ គប្បីជ្រាបដូចដែលពណ៌នាមកនេះ ។ ប្រការថា **ឥទំ វុច្ចតាវុសោ** សេចក្តីថា ជរា និងមរណៈ ទាំង

២ យ៉ាងនេះ ព្រះថេរៈពោលរួមគ្នាថា **ជរាមរណៈ** ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ដូច្នេះឯង ។

" ចប់ កថាពណ៌នាជរាមរណវារៈ "

## កថាពណ៌នា ជាតិវារៈ

[១១៨] គប្បីជ្រាបវិន័យ ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា ជាតិ សញ្ជាតិ ក្នុងជាតិវារៈ ( ដូចតទៅនេះ ) ៖

ឈ្មោះថា **ជាតិ** ព្រោះអត្ថថា ( ផ្ដើម ) កើត ។ ជាតិនោះ ប្រកបហើយ ដោយអំណាចនៃអាយតនៈមិនទាន់បរិបូរណ៍ ។

ឈ្មោះថា **សញ្ជាតិ** ព្រោះអត្ថថា កើតគ្រប់ហើយ ។ សញ្ជាតិនោះ ប្រកបគ្រប់ហើយ ដោយអំណាចនៃអាយតនៈបរិបូរណ៍ហើយ ។

ឈ្មោះថា **ឱក្កន្តិ** ព្រោះអត្ថថា ឈានចុះ ( កាន់គភ៌ ) ។ ឱក្កន្តិនោះ ប្រកបដោយអណ្ឌជកំណើត ( កើតក្នុងស៊ុត ) និងជលាពុជកំណើត ( កើតជាគភ៌ ) ។ អធិប្បាយថា សត្វទាំងនោះឈានចុះ គឺ ចាប់បដិសន្ធិ ដូចការឈានចូលទៅកាន់កន្ទ្រោមពង និងស្បូន ។

ឈ្មោះថា **អភិនិព្វត្តិ** ព្រោះអត្ថថា ផុសឡើង ។ អភិនិព្វត្តិនោះ ប្រកបដោយសំសេទជកំណើត ( កើតពីញើសក្អែល ) និងឱបបាតិកកំណើត ( ផុសឡើង ) អធិប្បាយថា សត្វទាំងនោះកើតប្រាកដឡើងតែម្ដង ។ នេះជាទេសនាដោយវោហារ ។ តទៅនេះ ទើបជាទេសនាដោយបរមត្ថ អធិប្បាយថា ដោយបរមត្ថ ខន្ធទាំងឡាយប៉ុណ្ណោះឯង ប្រាកដឡើង មិនមែនសត្វប្រាកដ ។

បណ្ដាបទទាំងនោះ បទថា **ខន្ធានំ** គប្បីជ្រាបថា សំដៅយកខន្ធ ១ ក្នុងឯកវោការភព ខន្ធ ៤ ក្នុងចតុវោការភព និង ខន្ធ ៥ ខ្វះ ក្នុងបញ្ចវោការភព ។

ការឧប្បត្តិ ឈ្មោះថា **បាតុភាវោ** ។ គប្បីជ្រាបការសង្គ្រោះដោយអាយតនៈ ដែលកំពុងកើតឡើងក្នុងភពនោះៗ ចូលក្នុងពាក្យថា **អាយតនានំ** នេះ ។

ការប្រាកដឡើងក្នុងសន្តតិនោះឯង ឈ្មោះថា **បដិលាភោ** អធិប្បាយថា អាយតនៈទាំងនោះ ដែលប្រាកដនោះឯង រមែងឈ្មោះថា ជាការដែលសត្វទាំងឡាយត្រឡប់បានហើយ ។

ដោយបទនេះថា **អយំ វុច្ចតាវុសោ ជាតិ** ព្រះថេរៈពោលបញ្ចប់ដល់ជាតិដែលបានសម្តែងមកហើយ ទាំងដោយវោហារ ទាំងដោយបរមត្ថ ដូច្នេះឯង ។

ក៏អ្នកសិក្សាគប្បីជ្រាប **កម្មភព** ដែលជាបច្ច័យនៃជាតិ ក្នុងពាក្យថា **ភវសមុទយា** នេះ ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ។

" ចប់ កថាពណ៌នាជាតិវារៈ "

# កថាពណ៌នា ភវវារៈ

[១១៩] គប្បីជ្រាបវិនិច្ឆ័យ ក្នុងភវវារៈ ដូចតទៅនេះ ៖

**កម្មភព** និង **ឧបបត្តិភព** ឈ្មោះថា **កាមភព** ។ បណ្តាភពទាំង ២ យ៉ាងនោះ កម្មដែលជាហេតុឲ្យចូលដល់កាមភពនោះឯង ឈ្មោះថា កម្មភព ។

អធិប្បាយថា កម្មនោះឯង លោកពោលថា **ភព** ដោយការពោលដល់ផល ដូចពាក្យទាំងឡាយមានជាអាទិ៍ថា ការឧប្បត្តិឡើងនៃព្រះពុទ្ធជាម្ចាស់ ជាហេតុនាំមកនូវសេចក្តីសុខ ការសន្សំបាបជាហេតុមកនូវទុក្ខ ដូច្នេះ ព្រោះកម្មភពនោះជាហេតុ នៃឧបបត្តិភព ។ ខន្ធបញ្ចកៈ ដែលតណ្ហា និងទិដ្ឋិចាប់យកហើយកើតឡើងដោយកម្មនោះ ឈ្មោះថា **ឧបបត្តិភព** ។ ព្រោះថា ខន្ធបញ្ចកៈនោះលោកពោលថា ភព ព្រោះមានវិគ្រោះថា ជាទីកើត ( នៃបដិសន្ធិចិត្ត ) ។

កាលបើយ៉ាងនេះ ទាំង ២ យ៉ាងនេះ គឺ កម្មភពនេះ ១ ឧបបត្តិភព ១ លោកពោលថា ជាកាមភព សូម្បីដោយប្រការទាំងពួង ។ ក្នុងរូបភព និងអរូបភព ក៏ទំនងនេះ ។ តែឧបាទានក្នុងពាក្យនេះថា **ឧបាទានសមុទយា** នេះ ជាបច្ច័យនៃកម្មភពដែលជាកុសល ។ ដោយឧបនិស្សយប្បច្ច័យនោះឯង ។ ឧបាទាន ជាបច្ច័យនៃកម្មភពដែលជាអកុសល ដោយឧបនិស្សយប្បច្ច័យខ្លះ ដោយសហជាតប្បច្ច័យជាដើមខ្លះ តែជាបច្ច័យរបស់ឧបបត្តិភព របស់កម្មភពទាំងដែលជាកុសល និងអកុសលទាំងអស់ ដោយឧបនិស្សយប្បច្ច័យ ។ ពាក្យដ៏សេស មានន័យដូចដែលមកហើយនោះឯង ដូច្នេះ ។

" ចប់ កថាពណ៌នាភវវារ "

## កថាពណ៌នា ឧបាទានវារៈ

[១២០] គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា **កាមុបា-ទានំ** ក្នុងឧបាទានវារៈ ។

កិលេសជាតិ ឈ្មោះថា **កាមុបាទាន** ព្រោះវិគ្រោះថា ជាហេតុប្រកាន់មាំក្នុងវត្ថុកាម ឬព្រោះប្រកាន់វត្ថុកាមនោះឯង ។ ម្យ៉ាងទៀត កាមនោះផង ជាឧបាទានផង ព្រោះដូច្នោះ ទើបឈ្មោះថា **កាមុបាទាន** ។

ការប្រកាន់មាំនូវលោកហៅថា **ឧបាទាន** ។ ព្រោះថា **ឧប** ស័ព្ទ ក្នុងពាក្យថា **ឧបាទានំ** នេះ មានសេចក្ដីថា **មាំ** ដូច **ឧប** ស័ព្ទ ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា **ឧបាយាស** និង **ឧបកដ្ឋ** ។

ពាក្យថា **កាមុបាទាន** នេះ ជាឈ្មោះរបស់រាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ។ នេះជាសេចក្ដីសង្ខេបក្នុងកាមុបាទាននេះ ។

តែពោលដោយពិស្ដារ កាមុបាទាននេះ គប្បីជ្រាបដោយន័យដែលបានត្រាស់ទុកហើយថា បណ្ដាឧបាទានទាំងនោះ **កាមុបាទាន** តើដូចម្ដេច ? បានដល់សេចក្ដីពេញចិត្ត ដោយអំណាចការជាប់ជំពាក់ក្នុងកាមទាំងឡាយ ។

**ទិដ្ឋុបាទាន** ក៏យ៉ាងនោះ គឺ ទិដ្ឋិនោះផង ជាឧបាទានផង ព្រោះដូច្នោះ ទើបឈ្មោះថា ទិដ្ឋុបាទាន ។ ម្យ៉ាងទៀត កិលេសជាតិ ឈ្មោះថា **ទិដ្ឋុបាទាន** ។ ព្រោះប្រកាន់មាំនូវទិដ្ឋិ ។ ឬឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះមានវិគ្រោះថា ជាហេតុឲ្យប្រកាន់មាំនូវទិដ្ឋិ ។ អធិប្បាយថា កិលេសជាតិណា រមែងប្រកាន់មាំនូវទិដ្ឋិខាងដើម ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា ទាំងអត្តា ( អាត្មន ) ទាំងលោកជា

របស់ទៀត ព្រោះដូច្នោះ កិលេសជាតិនោះ ទើបឈ្មោះថាយ៉ាងនោះ ( ទិដ្ឋុបា-ទាន ) ។ ដូចត្រាស់ទុកមានជាអាទិ៍ថា ទាំងអត្តា ( អាត្មន ) ទាំងលោកជារបស់ទៀត វត្ថុនេះប៉ុណ្ណោះជាសត្យ ( របស់ពិត ) ដទៃជាមោឃៈ ( ឥតប្រយោជន៍ ) ។ ពាក្យថា ទិដ្ឋុបាទាននេះ ជាឈ្មោះរបស់ទិដ្ឋិទាំងអស់ វៀរតែសីលព្វតុបាទាន និងអត្តវាទុបាទាន ។ នេះជាសេចក្ដីសង្ខេបក្នុងទិដ្ឋុបាទាននេះ ។ តែដោយពិស្តារ ទិដ្ឋុបាទាននេះ គប្បីជ្រាបដោយន័យដែលបានត្រាស់ទុកហើយនោះឯងថា បណ្ដាឧបាទានទាំងនោះ ទិដ្ឋុបាទាន តើដូចម្ដេច ? ( ទិដ្ឋុបាទានគឺ ) ទានដែលបុគ្គលឲ្យហើយ មិនមានផល ។

បណ្ដាឧបាទានទាំងនោះ ឈ្មោះថា សីលព្វតុបាទាន ព្រោះជាហេតុប្រកាន់មាំនូវសីល និងវត្តខ្លះ ព្រោះសីល និងវត្តនោះ ប្រកាន់មាំដោយខ្លួនឯងខ្លះ ព្រោះសីល និងវត្តនោះផង ជាឧបាទានខ្លះ ។

អធិប្បាយថា ការប្រកាន់មាំដោយខ្លួនឯងនោះឯង ដោយការជឿមាំថា សីល និងវត្តទាំងឡាយ មានសីលរបស់គោ និងវត្តរបស់គោជាដើម ជារបស់បរិសុទ្ធដោយអាការយ៉ាងនេះ ព្រោះដូចោះ ទើបឈ្មោះថាយ៉ាងនោះ ( សីលព្វ-តុបាទាន ) ។ នេះជាសេចក្ដីសង្ខេបក្នុងសីលព្វតុបាទាននេះ ។

តែដោយពិស្តារសីលព្វតុបាទាននេះ គប្បីជ្រាបដោយន័យដែលត្រាស់ទុកហើយថា បណ្ដាឧបាទានទាំងនោះ សីលព្វតុបាទានតើដូចម្ដេច ? គឺ សេចក្ដីបរិសុទ្ធដោយសីលរបស់សមណព្រាហ្មណ៍ទាំងឡាយ ខាងក្រៅសាសនានេះ ។ ឈ្មោះថា **វាទៈ** ព្រោះជាហេតុពោលក្នុងឥឡូវនេះ ។ ដែលឈ្មោះថា **ឧបាទាន**

ព្រោះជាហេតុឲ្យប្រកាន់មាំ ។

សួរថា ពោល ឬប្រកាន់មាំនូវអ្វី ?

ឆ្លើយថា ពោល ឬប្រកានមាំនូវអត្តា ( អាត្ម័ន ) ។

ការប្រកាន់មាំនូវវាទៈរបស់ខ្លួន ឈ្មោះថា **អត្តវាទុបាទាន** ។ មួ៉ាងទៀត ឈ្មោះថា អត្តវាទុបាទ ព្រោះជាហេតុប្រកាន់មាំត្រឹមតែវាទៈរបស់ខ្លួនប៉ុណ្ណោះថាជាអាត្មា ( អាត្ម័ន ) ។ ពាក្យថា អត្តវាទុបាទាននេះ ជាឈ្មោះរបស់សក្កាយទិដ្ឋិ ដែលមានវត្ថុ ២០ ។ នេះជាសេចក្ដីសង្ខេបក្នុងអត្តវាទុបាទាននេះ ។

ចំណែកដោយពិស្ដារ អត្តវាទុបាទាននេះ គប្បីជ្រាបដោយន័យដែលត្រាស់ទុកហើយថា បណ្ដាឧបាទានទាំងនេះ អត្តវាទុបាទាន តើដូចម្ដេច ? អត្តវាទុបាទាន គឺ បុថុជ្ជនក្នុងព្រះសាសនានេះ មិនបានស្ដាប់ មិនបានឃើញព្រះអរិយៈជាម្ចាស់ទាំងឡាយ ដូច្នេះ ។

តណ្ហាក្នុងពាក្យថា **តណ្ហាសមុទយា** នេះ ជាបច្ច័យរបស់កាមុទបាទានដោយឧបនិស្សយប្បច្ច័យ ឬដោយអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ នត្ថិប្បច្ច័យ និងអាសេវនប្បច្ច័យ តែជាបច្ច័យរបស់ឧបាទានដ៏សេស គឺ សូម្បីដោយសហជាតប្បច្ច័យជាដើមខ្លះ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ដូច្នេះ ។

" ចប់ កថាពណ៌នាឧបាទានវារៈ "

## កថាពណ៌នា តណ្ហាវារៈ

### តណ្ហា ១០៨

[១២១] គប្បីជ្រាបវិនិច្ឆ័យក្នុងតណ្ហាវារៈ ( តទៅ ) ៖

តណ្ហាដែលប្រព្រឹត្តទៅហើយដោយជវនវិថី មានឈ្មោះតាមអារម្មណ៍ដែលស្រដៀងនឹងបិតា ( អ្នកឲ្យកំណើត ) ថា រូបតណ្ហា ។ល។ ធម្មតណ្ហា ដូច ( មនុស្ស ) មានឈ្មោះតាមបិតាក្នុងពាក្យទាំងឡាយ មានជាអាទិ៍ថា សេដ្ឋីបុត្រ ព្រាហ្មណបុត្រ ជាដើម ។

ក៏ក្នុងតណ្ហាវារៈនេះ តណ្ហា មាន ៣ ប្រការ យ៉ាងនេះ គឺ តណ្ហាដែលមានរូបជាអារម្មណ៍ គឺ តណ្ហាក្នុងរូប ព្រោះដូច្នោះ ទើបឈ្មោះថា រូបតណ្ហា រូបតណ្ហានោះ កាលត្រេកអរប្រព្រឹត្តទៅដោយភាពជាកាមរាគៈ ឈ្មោះថា កាម-តណ្ហា ។

កាលត្រេកអរនឹង ( រូប ) ប្រព្រឹត្តទៅយ៉ាងនេះថា រូបទៀង គឺ ឋិតថេរបានដល់ ជាប់តគ្នាមិនដាច់ ដោយភាពជារាគៈដែលកើតរួមជាមួយសស្សតទិដ្ឋិ ឈ្មោះថា ភវតណ្ហា ។

កាលត្រេកអរនឹង (រូប) ប្រព្រឹត្តទៅយ៉ាងនេះថា រូបដាច់សូន្យ គឺ វិនាសទៅ បានដល់ លះលោកនេះទៅហើយ នឹងមិនមាន ដោយភាពជារាគៈកើតរួមនឹងឧច្ឆេទទិដ្ឋិ ឈ្មោះថា វិភវតណ្ហា ។

យ៉ាងទៀត សទ្ទតណ្ហាជាដើម ក៏ដូចរូបតណ្ហា ដូច្នោះ ទើបរួមជាតណ្ហា-វិចរិត ១៨ ប្រការ ។ តណ្ហាវិចរិតទាំងនោះ បែកចេញជា ១៨ ក្នុងអាយតនៈ

ទាំងឡាយ មានរូបខាងក្នុងជាដើម ( នឹង ) ចែកចេញជា ១៨ ក្នុងអាយតៈទាំងឡាយ មានរូបខាងក្រៅជាដើម ទើបរួមជា ៣៦ ប្រការ ចែកជាអតីតៈ ៣៦ ជាអនាគត ៣៦ បច្ចុប្បន្ន ៣៦ ដោយប្រការយ៉ាងនេះ ទើបជាតណ្ហាវិចរិត ១០៨ ប្រការ ។

ម្យ៉ាងទៀត តណ្ហាវិចរិត ១៨ ប្រការ អាស្រ័យរូបដែលប្រព្រឹត្តទៅខាងក្នុងជាដើម មានជាអាទិ៍យ៉ាងនេះថា ព្រោះអាស្រ័យរូបខាងក្នុង មានតណ្ហាថា យើងមានព្រោះរូបនេះ ( និង ) ថា កាលយើងមាន យើងក៏ជាទីប្រាថ្នា ដូច្នោះ ទើបរួមជាតណ្ហា ៣៦ ចែកជាអតីតៈ ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ ដោយប្រការយ៉ាងនេះ រួមជាតណ្ហាវិចរិត ១០៨ ដូចដែលពណ៌នាមកនេះឯង ។

កាលធ្វើការសង្គ្រោះចូលគ្នាទៀត តណ្ហា ក៏មាន ៦ ពួកប៉ុណ្ណោះ ក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ដោយអត្ថដែលលោកសម្តែងទុកយ៉ាងនេះថា តណ្ហាមាន ៣ យ៉ាង ប៉ុណ្ណោះ មានកាមតណ្ហាជាដើម អ្នកប្រាជ្ញគប្បីជ្រាបតណ្ហា ដោយការសង្គ្រោះសេចក្តីដែលពិស្តារចូលជាមួយគ្នាទៀត អំពីសេចក្តីពិស្តារ ដែលសម្តែងទុកហើយ ដូច្នេះ ។

ក៏វេទនាដែលជាវិបាក ព្រះថេរៈប្រាថ្នាយកហើយថា វេទនា ក្នុងពាក្យថា **វេទនាសមុទយា** នេះ ។ បើនឹងមានពាក្យសួរថា វេទនានោះ ជាបច្ច័យនៃតណ្ហាក្នុងទ្វារ ៦ ដូចម្តេច ?

ឆ្លើយថា ជាបច្ច័យ ព្រោះវេទនាជាវត្ថុដែលគួរត្រេកអរ ។ អធិប្បាយថា កាលសត្វទាំងឡាយប្រកាន់វេទនាថា ជារបស់យើង ។ ដោយសេចក្តីពេញចិត្ត

សុខវេទនា គេនឹងជាអ្នកញ៉ាំងសេចក្តីប្រាថ្នាក្នុងវេទនាឲ្យកើតឡើង ហើយត្រេកអរដោយការត្រេកអរចំពោះវេទនា ប្រាថ្នារូបដែលបានឃើញហើយនោះឯង និងកាលបានរូបនោះហើយ ក៏ពេញចិត្ត ទាំងធ្វើសក្ការៈដល់ជាងគំនូរជាដើម អ្នកឲ្យអារម្មណ៍ ។

ក្នុងសោតទ្វារជាដើម ក៏ដូចគ្នា សត្វទាំងឡាយរមែងប្រាថ្នាសម្លេងជាដើម ដែលជាទីគួរប្រាថ្នា លុះបានហើយ ក៏ពេញចិត្តនឹងសម្លេងជាដើមទាំងនោះ ទាំងធ្វើការសក្ការៈ អ្នកដេញពិណ ជាងផ្សំទឹកក្រអូប ជាងត្បាញ និងអ្នកសម្តែងសិល្បៈនានា ជាដើម ។

ដូចអ្វី ?

ដូចម្តាយដែលស្រឡាញ់កូន ធ្វើសក្ការៈដល់មេដោះ គឺ ឲ្យគេផឹក និងបរិភោគទឹកដោះថ្លា និងទឹករដោះដ៏ឆ្ងាញ់ជាដើម ព្រោះសេចក្តីស្នេហាចំពោះកូន , ពាក្យដ៏សេស មានន័យដូចដែលពោលហើយនោះឯង ។

( ចប់កថាពណ៌នាតណ្ហាវារៈ )

# កថាពណ៌នា វេទនាការៈ

[១២២] គប្បីជ្រាបវិនិច្ឆ័យក្នុងវេទនាការៈ ( តទៅ ) ៖

ពួកវេទនា ឈ្មោះថា **វេទនាកាយៈ** ។

ពាក្យថា **ចក្ខុសម្ផស្សជាវេទនា ។បេ។ មនោសម្ផស្សជាវេទនា** នេះ ជាឈ្មោះរបស់វេទនាទាំងដែលជាកុសល ទាំងជាអកុសល និងអព្យាកតៈ ដែលប្រព្រឹត្តទៅហើយក្នុងចក្ខុទ្វារជាដើម តាមវត្ថុ ( ទីតាំង ) ដែលស្រដៀងមាតា ដូចជាឈ្មោះ ( របស់កូន ) តាមមាតា ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា សារីបុត្រ ( កូននាងសារី ) មន្តានីបុត្រ ( កូននាងមន្តានី ) ព្រោះមកហើយក្នុងគម្ពីរវិភង្គ យ៉ាងនេះថា វេទនាកើតអំពីចក្ខុសម្ផស្ស ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រិតក៏មាន ក្នុងពាក្យមានជាអាទិ៍ថា ចក្ខុសម្ផស្សជាវេទនានេះ មានអត្ថថា វេទនាដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាហេតុ ឈ្មោះថា ចក្ខុសម្ផស្សជាវេទនា ក្នុងគ្រប់ទ្វារ មានសោតៈជាដើមក៏ទំនងនេះ ។ នេះជាកថាដែលពោលដោយការសង្គ្រោះចូលគ្នាគ្រប់យ៉ាងក្នុងវេទនាការៈនេះ ដូច្នេះ ។

តែថា វេទនា គប្បីជ្រាបដោយវេទនា ដែលសម្បយុត្តដោយធម៌ទាំងនេះ គឺ ក្នុងចក្ខុទ្វារជាវិបាកវិញ្ញាណ ២ ដួង មនោធាតុ ២ ដួង មនោវិញ្ញាណធាតុ ៣ ដួង ។ ក្នុងសោតទ្វារជាដើម ក៏ទំនងនេះ ។ ចំណែកមនោទ្វារ គប្បីយល់ថាជាវេទនា ដែលសម្បយុត្តជាមួយនឹងមនោវិញ្ញាណធាតុ ។

ក៏ក្នុងពាក្យថា **ផស្សសមុទយា** នេះ គប្បីជ្រាបវិនិច្ឆ័យក្នុងទ្វារទាំង ៥ វេទនាអាស្រ័យវត្ថុទាំង ៥ មានការកើតឡើងព្រោះចក្ខុសម្ផស្ស ដែលកើតឡើង

រួមគ្នាជាដើមកើតឡើង ។ ចក្ខុសម្ផស្សជាដើម ទើបជាបច្ច័យរបស់វេទនាដ៏សេស ទាំងឡាយដោយភាពជាឧបនិស្សយប្បច្ច័យជាដើម វេទនាក្នុងតទាលម្ពណខណៈ ក្នុងមនោទ្វារ និងវេទនាក្នុងបដិសន្ធិខណៈ ភវង្គខណៈ និងចុតិខណៈដែល ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ មានការកើតឡើង ព្រោះការកើតឡើងនៃមនោសម្ផស្ស ដែលកើតឡើងរួមគ្នា ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះ ឯង ។

( ចប់ កថាពណ៌នាវេទនាហារៈ )

# កថាពណ៌នា ផស្សាហារៈ

[១២៣] គប្បីជ្រាបវិនិច្ឆ័យក្នុងផស្សាហារៈ ( តទៅ ) ៖

ផស្សៈក្នុងចក្ខុ ឈ្មោះថា **ចក្ខុសម្ផស្ស** ។ ក្នុងគ្រប់ទ្វារ ក៏ទំនងនេះ ។ ហើយដោយពាក្យត្រឹមតែប៉ុណ្ណោះថា **ចក្ខុសម្ផស្សោ** ។បេ។ **កាយសម្ផស្សោ** ជាការដែលព្រះថេរៈ បានពោលដល់សម្ផស្សៈទាំង ១០ មានវត្ថុ ៥ ទាំងដែលជាកុសលវិបាក និងអកុសលវិបាក ។

ដោយពាក្យថា **មនោសម្ផស្សោ** នេះ ជាការដែលព្រះថេរៈបានពោលដល់ផស្សៈ ដែលសម្បយុត្តជាមួយនឹងលោកិយវិបាកដ៏សេស ២២ យ៉ាង ។

បទថា **សឡាយតន សមុទយា** សេចក្តីថា ព្រោះអាយតៈ ៦ យ៉ាងមានចក្ខុជាដើម កើតឡើង ផស្សៈសូម្បីទាំង ៦ យ៉ាងនេះ ក៏មានការកើតឡើងដែរ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

( ចប់ កថាពណ៌នាផស្សាហារៈ )

# កថាពណ៌នា សឡាយតនវារៈ

[១២៤] គប្បីជ្រាបវិនិច្ឆ័យក្នុងសឡាយតនៈវារៈ ( តទៅ ) ថា អាយតនៈទាំងអស់ដែលគួរនឹងពោលក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា **ចក្ខាយតនំ** មានន័យដូចដែលបានពោលទុកហើយក្នុងខន្ធនិទ្ទេស និងអាយតននិទ្ទេសក្នុងគម្ពីរវិសុទ្ធិ-មគ្គនោះឯង ។

តែថា ក្នុងពាក្យថា **នាមរូបសមុទយា** នេះ អ្នកសិក្សាគប្បីជ្រាប ការកើតឡើងនៃសឡាយតនៈ ព្រោះនាមរូបកើត ដោយន័យដែលបានពោលទុកហើយក្នុងនិទ្ទេសនៃបដិច្ចសមុប្បាទក្នុងគម្ពីរវិសុទ្ធិមគ្គ ដោយអំណាចនៃអាយតនៈដែលមានរូប ( តែម្យ៉ាង ) និងនាម ( តែម្យ៉ាង ) និងទាំងនាម ទាំងរូបជាបច្ច័យ ។ ពាក្យដ៏សេស មានប្រការដូចដែលពោលមកហើយនោះឯង ។

( ចប់ កថាពណ៌នាសឡាយតនៈ )

## កថាពណ៌នា នាមរូបវារៈ

[១២៥] គប្បីជ្រាបវិនិច្ឆ័យក្នុងនាមរូបវារៈ ( តទៅ ) ៖

**នាម** មានការបង្អោនទៅជាលក្ខណៈ ។ **រូប** មានការបែកធ្លាយទៅជាលក្ខណៈ ។ តែថា ក្នុងវារៈនៃវិត្ថារន័យរបស់នាមរូបនោះ គប្បីជ្រាបថា វេទនា បានដល់ វេទនាខន្ធ សញ្ញា បានដល់ សញ្ញាខន្ធ ចេតនា ផស្សៈ មនសិការៈ បានដល់ សង្ខារក្ខន្ធ ។ សូម្បីមានពួកធម៌យ៉ាងដទៃ ដែលសង្គ្រោះចូលក្នុងសង្ខារក្ខន្ធក៏ពិត តែធម៌ ៣ យ៉ាងនេះ មាននៅក្នុងចិត្តដែលមានកម្លាំងខ្សោយគ្រប់ដួង ព្រោះដូច្នោះ ក្នុងនាមរូបវារៈនេះ ព្រះថេរៈក៏បានសម្តែងសង្ខារក្ខន្ធទុកដោយអំណាចនៃធម៌ ៣ យ៉ាងនេះ នោះឯង ។

ពាក្យថា **ចត្តារិ** ក្នុងពាក្យថា **ចត្តារិ មហាភូតានិ** នេះ ជាការកំណត់ការរាប់ ( ជាចំនួនរាប់ ) ។

ពាក្យថា **មហាភូតានិ** ជាឈ្មោះរបស់ដី ទឹក ភ្លើង ខ្យល់ តែហេតុដែលនាំឲ្យហៅវត្ថុទាំង ៤ នោះថា មហាភូត និងន័យនៃការវិនិច្ឆ័យយ៉ាងដទៃ ក្នុងនាមរូបនេះទាំងអស់ បានពោលទុកហើយក្នុងនិទ្ទេសនៃរូបក្ខន្ធ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

ចំណែកពាក្យថា **ចតុន្នំ** ក្នុងពាក្យថា **ចតុន្នញ្ច មហាភូតានំ ឧបាទាយ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ មានអធិប្បាយថា អាស្រ័យនូវមហាភូតរូបទាំង ៤ ។

បទថា **ឧបាទាយ** សេចក្តីថា ចូលទៅតោង គឺ ចាប់ទុក ។ អាចារ្យពួកខ្លះពោលថា **និស្សាយ** ( អាស្រ័យ ) ក៏មាន ។

ក៏សព្ទថា **វត្តមានំ** នេះ ជាបាឋៈដែលលើស ។ ម្យ៉ាងទៀត ពាក្យថា **វត្តមានំ** នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថថា **ជំនុំ** ព្រោះហេតុនោះ គប្បីជ្រាបអត្ថាធិប្បាយនេះថា រូបដែលអាស្រ័យការជំនុំមហាភូតរូបទាំង ៤ ប្រព្រឹត្តទៅ ។

កាលបើយ៉ាងនេះ សូម្បីក្នុងទីគ្រប់កន្លែង មហាភូតរូប ៤ មានបឋវីជាដើម និង រូប ២៣ យ៉ាង ដែលអាស្រ័យមហាភូតរូប ៤ ប្រព្រឹត្តទៅ ដែលត្រាស់ទុកក្នុងព្រះបាលីនោះឯង ក្នុងគម្ពីរអភិធម្ម ដោយចែកប្រភេទជា **ចក្ខាយ-តនំ** ជាដើម សូម្បីទាំងអស់គប្បីជ្រាបថា ឈ្មោះថា រូប ។

ក៏ក្នុងពាក្យថា **វិញ្ញាណសមុទយា** នេះ វិញ្ញាណណាជាបច្ច័យរបស់នាម ( តែម្យ៉ាង ) ផង របស់រូបសុទ្ធ ( តែម្យ៉ាង ) ផង ទាំងជាបច្ច័យដល់នាម និងរូបផង ព្រោះដូច្នោះ ដោយអំណាចនៃនាម នៃរូប និងទាំងនាម ទាំងរូបដែលមានវិញ្ញាណជាបច្ច័យនោះ អ្នកសិក្សាគប្បីជ្រាបការកើតឡើងនៃនាមរូប ព្រោះវិញ្ញាណកើតឡើង តាមន័យដែលបានពោលទុកហើយក្នុងនិទ្ទេសនៃបដិច្ចសមុ-ប្បាទ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះចុះ ក្នុងពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ដូច្នេះឯង ។

( ចប់ កថាពណ៌នានាមរូបវារៈ )

# កថាពណ៌នា វិញ្ញាណវារៈ

[១២៦] គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិញ្ញាណវារៈ ( តទៅ ) ៖

វិញ្ញាណក្នុងចក្ខុ ឈ្មោះថា **ចក្ខុវិញ្ញាណ** ម្យ៉ាងទៀត វិញ្ញាណដែលកើតឡើងហើយអំពីចក្ខុ ព្រោះដូច្នោះ ទើបឈ្មោះថា ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ក៏យ៉ាងនេះដូចគ្នា ។ តែវិញ្ញាណនេះ បានដល់ មនោ នោះឯង ព្រោះដូច្នោះ ទើបឈ្មោះថា មនោវិញ្ញាណ ។ ពាក្យថា មនោវិញ្ញាណនេះ ជាឈ្មោះរបស់វិបាកចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ វៀរទ្វិបញ្ចវិញ្ញាណ ។

តែក្នុងពាក្យថា **សង្ខារសមុទយា** នេះ អ្នកសិក្សាគប្បីជ្រាបការកើតឡើងនៃវិញ្ញាណ ព្រោះសង្ខារកើត តាមន័យដែលបានពោលទុកហើយក្នុងគម្ពីរវិសុទ្ធិ-មគ្គនោះឯង ដោយវិញ្ញាណដែលមានសង្ខារជាបច្ច័យ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ដូច្នេះឯង ។

( ចប់ កថាពណ៌នាវិញ្ញាណវារៈ )

## កថាពណ៌នា សង្ខារវារៈ

[១២៧] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសង្ខារវារៈ ( តទៅ ) ៖

សង្ខារ មានការតាក់តែងជាលក្ខណៈ ។ តែថាក្នុងវារៈនៃវិត្ថារន័យរបស់សង្ខារនោះ សង្ខារដែលប្រព្រឹត្តហើយតាមកាយទ្វារ ឈ្មោះថា កាយសង្ខារ ។

ពាក្យថា **កាយសង្ខារ** នេះ ជាឈ្មោះរបស់កាយសញ្ចេតនា ២០ ដួង គឺដែលនៅក្នុងមហាកុសល ៨ ដួង និងអកុសល ១២ ដួង ដែលប្រព្រឹត្តទៅដោយការកម្រើកកាយទ្វារ ។

ពាក្យថា **វចីសង្ខារ** នេះ ជាឈ្មោះរបស់វចីសញ្ចេតនា ២០ ដួង ដូចគ្នាដែលប្រព្រឹត្តទៅហើយដោយការកម្រើកវាចាក្នុងវចីទ្វារ ។

សង្ខារ ដែលប្រព្រឹត្តហើយតាមមនោទ្វារ ឈ្មោះថា **ចិត្តសង្ខារ** ពាក្យថា ចិត្តសង្ខារ នេះ ជាឈ្មោះរបស់មនោសញ្ចេតនា ២៩ ដួង ដោយលោកិយកុសល និង លោកិយអកុសលដែលប្រព្រឹត្តទៅហើយ ( កើតឡើង ) ដល់អ្នកអង្គុយគិតនៅក្នុងទីកំបាំង ដោយមិនបានធ្វើការកម្រើកកាយ និងវាចា ។ ក៏ក្នុងពាក្យថា **អវិជ្ជាសមុទយា** នេះ គប្បីជ្រាបវិនិច្ឆ័យថា អវិជ្ជា នៃសង្ខារដែលជាកុសលដោយឧបនិស្សយប្បច្ច័យខ្លះ នៃសង្ខារដែលជាអកុសល ដោយសហជាតប្បច្ច័យជាដើមខ្លះ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង ។

( ចប់ កថាពណ៌នាសង្ខារវារៈ )

# កថាពណ៌នា អវិជ្ជាវារៈ

[១២៨-១២៩] គប្បីជ្រាបវិនិច្ឆ័យក្នុងអវិជ្ជាវារៈ ( តទៅ ) ៖

ការមិនដឹងទុក្ខសច្ច ឈ្មោះថា ការមិនដឹងទុក្ខ ។ ពាក្យថា ទុក្ខេអញ្ញាណំ នេះ ជាឈ្មោះរបស់មោហៈ ។ ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា សមុទយេ អញ្ញាណំ ក៏មានន័យដូច្នេះដែរ ។

ក្នុងចំនួនសច្ចៈទាំង ៤ នោះ ការមិនដឹងទុក្ខ គប្បីជ្រាបបានដោយហេតុ ៤ ប្រការ គឺ ៖-

-ដោយការញុំាងចុះកាន់ខាងក្នុង ១

-ដោយឋានៈ ( ទីតាំង ) ១

-ដោយអារម្មណ៍ ១

-ដោយការបិទបាំងទុក ១

ពិតណាស់ ការមិនដឹងទុក្ខនោះ ឈ្មោះថា ញុំាងចុះកាន់ក្នុងខាងក្នុងទុក្ខ ព្រោះសង្គ្រោះចូលក្នុងទុក្ខសច្ចៈ , ទុក្ខសច្ចៈ ឈ្មោះថា ជាឋានៈ ( ទីតាំង ) ព្រោះជានិស្សយប្បច្ច័យនៃការមិនដឹងទុក្ខនោះ , ឈ្មោះថា ជាអារម្មណ៍ ព្រោះជាអារម្មណប្បច្ច័យ ( នៃការមិនដឹងទុក្ខនោះ ) និងទុក្ខសច្ចៈ រមែងបិទបាំងការមិនដឹងទុក្ខនោះទុក ។

ក្នុងអធិការនៃអវិជ្ជាវារៈ ការមិនដឹងសមុទយៈ គប្បីដឹងបានដោយហេតុ ៣ ប្រការ គឺ ៖-

-ដោយឋានៈ ១

-ដោយអារម្មណ៍ ១

-ដោយការបិទបាំង ១

ព្រោះសមុទយនោះ រារាំងការចាក់ធ្លុះលក្ខណៈតាមសេចក្តីពិត និងព្រោះមិនប្រគល់ឲ្យនូវការប្រព្រឹត្តទៅនៃញាណ ។ ការមិនដឹងនិរោធ និងបដិបទា គប្បីជ្រាបបានដោយហេតុតែមួយប៉ុណ្ណោះ គឺ ដោយការបិទបាំងទុក ។ ក៏ការមិនដឹងដែលបិទបាំងទុក ។ ក៏ការមិនដឹងដែលបិទបាំងនិរោធ និងបដិបទាទុកនោះឯង គប្បីជ្រាបបាន ព្រោះហាមឃាត់នូវការចាក់ធ្លុះលក្ខណៈ តាមសេចក្តីពិតនៃនិរោធ-សច្ចៈ និងបដិបទាទាំងនោះ និងព្រោះមិនប្រគល់ឲ្យនូវការប្រព្រឹត្តទៅនៃញាណក្នុងសច្ចៈទាំងពីរនោះ ។ តែការមិនដឹងសច្ចៈទាំងពីរនោះ មិនជាការញ៉ាំងចុះកាន់ក្នុងខាងក្នុងសច្ចៈទាំង ២ នោះទេ ។ ព្រោះមិនសង្រ្គោះចូលក្នុងសច្ចៈទាំងពីរនោះ សច្ចៈទាំងពីរនោះ ក៏មិនជាទីតាំងនៃការមិនដឹងសច្ចៈទាំងពីរនោះ ព្រោះមិនមែនជាធម៌កើតរួមគ្នា ( និង ) មិនមែនជារម្មណ៍ ព្រោះមិនប្រារព្ធសច្ចៈទាំងពីរប្រព្រឹត្តទៅ ។

អធិប្បាយថា សច្ចៈ ២ ខាងក្រោយ ឃើញបានលំបាក ព្រោះជ្រាលជ្រៅ តែក្នុងរឿងនេះ ការមិនដឹង មិនមែនដោយការខ្វាក់ ទើបប្រព្រឹត្តទៅ ។ ចំណែកសច្ចៈពីរខាងដើម ជ្រាលជ្រៅ ព្រោះលក្ខណៈរបស់សភាវៈ ឃើញបានលំបាក ដោយសេចក្តីថា ជាសត្រូវនឹងគ្នា ទើបប្រព្រឹត្តទៅដោយការដល់វិបល្លាសក្នុងសច្ចៈទាំងពីរនោះ ។

ម្យ៉ាងទៀត ដោយពាក្យត្រឹមតែប៉ុណ្ណោះថា ទុក្ខេ ព្រះថេរៈ បានសម្តែង

អវិជ្ជាទុក ដោយការសង្គ្រោះចូលជាមួយគ្នា ទាំងដោយឋានៈ ( ទីតាំង ) ដោយអារម្មណ៍ និងដោយកិច្ច ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះថា **ទុក្ខសមុទយេ** លោកសម្តែងទុកដោយឋានៈ ( ទីតាំង ) ដោយរម្មណៈ និងដោយកិច្ច ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះថា **ទុក្ខនិរោធេ ទុក្ខនិរោធគាមិនិយា បដិបទាយ** លោកសម្តែងទុក ដោយកិច្ច ។ តែបើពោលដោយសរុបហើយ អវិជ្ជាគប្បីជ្រាបថា លោកសម្តែងទុកដោយសភាវៈ ដោយពាក្យថា **អញ្ញាណំ** នេះ ក៏កាមាសវៈ កវាសវៈ ក្នុងពាក្យថា **អាសវសមុទយា** នេះ ជាបច្ច័យនៃអវិជ្ជាដោយអំណាចនៃសហជាតប្បច្ច័យជាដើម ។ អវិជ្ជាសវៈ គប្បីជ្រាបថា ក៏អវិជ្ជាដែលកើតឡើងមុន ជាបច្ច័យនៃអវិជ្ជាដែលកើតក្រោយៗ ដោយឧបនិស្សយប្បច្ច័យនោះឯងឈ្មោះថា **អវិជ្ជាសវៈ** ក្នុងពាក្យថា **អាសវសមុទយា** នេះ ។ អវិជ្ជាសវៈនោះនឹងជាឧបនិស្សយប្បច្ច័យនៃអវិជ្ជា ដែលកើតឡើងក្នុងកាលតមក ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង ដូច្នេះ ។

( ចប់ កថាពណ៌នាអវិជ្ជាវារៈ )

## កថាពណ៌នា អាសវវារៈ

[១៣០] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាសវៈ ( តទៅ ) ៖

អវិជ្ជាក្នុងពាក្យថា **អវិជ្ជាសមុទយា** នេះ ជាបច្ច័យដោយសហជាតប្បច្ច័យជាដើម នៃកាមាសវៈ និងភវាសវៈ ហើយជាបច្ច័យនៃអវិជ្ជាសវៈ ដោយឧបនិស្សយប្បច្ច័យនោះឯង តែក្នុងពាក្យថា **អវិជ្ជាសមុទយា** នេះ អវិជ្ជាដែលកើតឡើងក្នុងកាលតៗ មក គប្បីជ្រាបថា ជាអវិជ្ជាសវៈ ។ អវិជ្ជានោះឯងដែលកើតឡើងក្នុងកាលមុន និងជាឧបនិស្សយបច្ច័យនៃអវិជ្ជាដែលកើតឡើងក្នុងកាលតៗ មក ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯងដូច្នេះ ។

វារៈនេះ លោកពោលទុកហើយ ដោយការសម្តែងបច្ច័យរបស់អវិជ្ជានេះដែលជាប្រធាន ក្នុងបទបដិច្ចសមុប្បាទទាំងឡាយ ។ ដោយវារៈដែលលោកពោលទុកយ៉ាងនេះ ដែលសម្រេចដល់សង្សារវដ្តមិនមានទីបំផុតខាងដើម ដែលគ្មាននរណា អាចដឹងបាន ។

សួរថា មិនដឹងយ៉ាងណា ? ឆ្លើយថា ( មិនដឹងយ៉ាងនេះគឺ ) ព្រោះថាការកើតឡើងនៃអវិជ្ជា ព្រោះការកើតឡើងនៃអាសវៈ ការកើតឡើងនៃអាសវៈសូម្បីព្រោះការកើតឡើងនៃអវិជ្ជា អាសវៈក៏ជាបច្ច័យនៃអវិជ្ជា សូម្បីអវិជ្ជាក៏ជាបច្ច័យនៃអាសវៈ ព្រោះអធិប្បាយដូចដែលពោលមកហើយនេះ ទីបំផុតខាងដើមទើបមិនប្រាកដ ការៈដែលសង្សារមានទីបំផុតខាងដើម ដែលគ្មាននរណាអាចដឹងបាន ជាការដែលសម្រេច ព្រោះខាងដើមរបស់អវិជ្ជានោះ មិនប្រាកដ ។

វារៈទាំងនេះ គឺ ៖

| | |
|---|---|
| កម្មបថវារៈ ១ | អាហារវារៈ ១ |
| ទុក្ខវារៈ ១ | ជរាមរណវារៈ ១ |
| ជាតិវារៈ ១ | ភវវារៈ ១ |
| ឧបាទានវារៈ ១ | តណ្ហាវារៈ ១ |
| វេទនាវារៈ ១ | ផស្សវារៈ ១ |
| សឡាយតនវារៈ ១ | នាមរូបវារៈ ១ |
| វិញ្ញាណវារៈ ១ | សង្ខារវារៈ ១ |
| អវិជ្ជាវារៈ ១ | អាសវវារៈ ១ |

រួម ១៦ វារៈ ព្រះថេរៈបានពោលទុកហើយក្នុងព្រះសូត្រនេះ ដូចដែលពណ៌នាមកនេះ ។

ព្រោះក្នុងចំនួនវារៈទាំង ១៦ វារៈនោះ មួយវារៈ ៗ លោកសម្តែងទុក ២ យ៉ាង ដោយសង្ខេប និងពិស្តារ ទើបជា ៣២ ស្ថាន ។ ដោយហេតុដូច្នេះ ក្នុងព្រះសូត្រនេះ ទើបជាការដែលព្រះថេរៈបានពោលសច្ចៈ ទុក ៤ យ៉ាង ក្នុង ២២ ស្ថាននេះ ។

ព្រះថេរៈបានពោលអរហត្តទុក ក្នុងទី ១៦ ស្ថាន ដែលពោលទុកហើយដោយពិស្តារ ក្នុងបណ្តាយ៉ាងសង្ខេប និងយ៉ាងពិស្តារនោះឯង ។ តែតាមមតិរបស់ព្រះថេរៈ លោកបានពោលដល់សច្ចៈទាំង ៤ និង មគ្គ ទាំង ៤ ទុកក្នុង ៣២ ស្ថានប៉ុណ្ណោះ ព្រោះហេតុដូចដែលពោលមកហើយនេះឯង ក្នុងព្រះពុទ្ធវចនៈ

ដែលព្រះធម្មសង្គាហកាចារ្យបានរួបរួមទុកក្នុងនិកាយធំទាំង ៥ និកាយ ទាំងអស់ ទើបមិនមានសូត្រដែលប្រកាសសច្ចៈ ៤ យ៉ាង ទុកដល់ ៣២ ដង និងប្រកាស អរហត្តទុកដល់ ៣២ ដង ក្រៅអំពីសម្មាទិដ្ឋិសូត្រនេះឯង ។

ពាក្យថា *ឥទមវោចាយស្មា សារិបុត្តោ* មានសេចក្តីថា ព្រះសារីបុត្ត បានពោលសម្មាទិដ្ឋិសូត្រនេះ ពោរពេញទៅដោយហេតុ ៦៤ យ៉ាង គឺ ដោយ ការបរិយាយអរិយសច្ចៈ ៤ ទុក ៣២ យ៉ាង និងបរិយាយព្រះអរហត្តទុក ៣២ យ៉ាង ។

ភិក្ខុទាំងនោះ រីករាយត្រេកអរ អនុមោទនាភាសិតរបស់ព្រះសារីបុត្ត ដូច្នេះឯង ។

( ចប់ អដ្ឋកថាសម្មាទិដ្ឋិសូត្រ ទី ៩ )

# អដ្ឋកថា
# សតិប្បដ្ឋានសូត្រទី ១០

[១៣១] សតិប្បដ្ឋានសូត្រ មានពាក្យអធិប្បាយថា ខ្ញុំម្ចាស់បានស្ដាប់មកហើយយ៉ាងនេះ ។

## ពាក្យថា កុរុ

បណ្ដាបទទាំងនោះ បទថា កុរូសុ វិហរតិ សេចក្ដីថា សូម្បីជនបទមួយជាទីនៅនៃរាជកុមារអ្នកនៅក្នុងជនបទឈ្មោះថា កុរុ គេហៅថា កុរូ ដោយ រុឡ្ហិ ស័ព្ទ ( ពាក្យដែលបែកចេញអំពីពាក្យដើម ) ( ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចទ្រង់គង់នៅ ) ក្នុងកុរុជនបទនោះ ។

តែព្រះអដ្ឋកថាចារ្យទាំងឡាយពោលទុកថា ក្នុងរជ្ជសម័យរបស់ព្រះបាទមន្ធាតុរាជ មនុស្សក្នុងទ្វីបទាំង ៣ បានឮ ( ពាក្យនិយាយត ៗ គ្នា ) ថា ដែលឈ្មោះថា ជម្ពូទ្វីប ជាដែនដែលឧប្បត្តិឡើងនៃកំពូលមនុស្ស ( ឧត្តម-បុរស ) ចាប់ផ្ដើមអំពីព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងស្ដេចចក្រពត្តិទាំងឡាយ ជាតំបន់អភិរម្យឧត្តមទ្វីប ទើបបាននាំគ្នាមក ព្រមជាមួយនឹងព្រះបាទចក្រពត្តិមន្ធាតុរាជ ដែលទ្រង់បង្វិលចក្ររតន៍ចេញទៅខាងមុខហើយ ស្ដេចជាប់តាម មកកាន់ទ្វីបទាំង ៤ ។

តអំពីនោះមក ព្រះរាជាបានត្រាស់សួរបរិនាយកកែវថា តើនៅមានស្ថានដែលជារមណិយដ្ឋានដ៏ក្រៃលែងជាងមនុស្សលោកនេះ ដែរឬទេ ?

បរិនាយកកែវបានក្រាបទូលថា បពិត្រព្រះមហារាជ ទេវលោកគួរមនោរម្យជាង មហាបពិត្រ ។

ព្រះរាជា ទើបទ្រង់បង្វិលចក្ររតន៍ទៅមុនហើយ ស្ដេចក៏បានយាងទៅទីនោះ ។ ស្ដេចចាតុម្មហារាជ បានជ្រាបថា ព្រះបាទមន្ធាតុរាជស្ដេចមកហើយ ទ្រង់ត្រិះរិះថា ព្រះរាជាអ្នកសម្បូរឫទ្ធិច្រើន ( ស្ដេចមកហើយ ) យើងមិនអាចនឹងតទល់បានដោយការច្បាំង ទើបបានប្រគល់រាជសម្បត្តិរបស់ខ្លួនថ្វាយ ។

ព្រះអង្គទ្រង់ទទួលរាជសម្បត្តិនោះហើយ បានត្រាស់សួរទៀតថា នៅមានស្ថាន ដែលជាទីមនោរម្យដ៏ក្រៃលែងជាងនេះ ដែរឬទេ ?

ស្ដេចចាតុម្មហារាជ បានក្រាបទូលដល់តាវត្តិង្សពិភពចំពោះព្រះអង្គថា ( ព្រះករុណាថ្លៃវិសេស ) តាវត្តិង្សពិភព ជារមណីយដ្ឋានក្រៃលែងជាង ( នេះ ) ។ នៅតាវត្តិង្សពិភពនោះ មហារាជទាំង ៤ នេះ ជាអ្នកបម្រើ ( បរិចារិកា ) របស់សក្កទេវរាជនោះ នឹងប្រថាប់ឈរត្រង់ទ្វារ សក្កទេវរាជទ្រង់មានឫទ្ធិច្រើន ទ្រង់មានអានុភាពច្រើន និងព្រះអង្គមានទេវស្ថាន សម្រាប់ប្រើប្រាស់ទាំងនេះ គឺ វេជយន្តប្រាសាទកម្ពស់ ១០០០ យោជន៍ សុធម្មាទេវសភាកម្ពស់ ៥០០ យោជន៍ វេជយន្តរថកម្ពស់ ១៥០ យោជន៍ ដំរីឰរាវណ ក៏ខ្ពស់ប៉ុណ្ណោះដែរ ឧទ្យាននន្ទវ័ន ឧទ្យានចិត្តលតាវ័ន ឧទ្យានបារុសកវ័ន ឧទ្យានមិសកវ័ន ប្រដាប់ដោយទិព្វព្រឹក្សា ចំនួន ១ ពាន់ដើម ដើមឈើសួគ៌ ឈ្មោះបារិច្ឆត្តកៈកម្ពស់ ១០០ យោជន៍ ខាងក្រោមដើមបារិច្ឆត្តកៈនោះ មានព្រះទីនាំងបណ្ឌុកម្ពលសិលាសនៈ មានពណ៌ដូចផ្កាសិរ-

មាន់ បណ្តោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្ពស់ ១៥ យោជន៍ ដ៏ទន់ល្មើយ កាលសក្កទេវរាជទ្រង់ប្រថាប់គង់ ព្រះវរកាយនឹងលិចចុះពាក់កណ្តាលព្រះអង្គ ។ លុះទ្រង់ស្តាប់ពាក្យក្រាបបង្គំទូលនោះហើយ ព្រះរាជាមានព្រះរាជបំណងនឹងស្តេចយាងទៅកាន់តាវត្តិង្សពិភពនោះ ទើបទ្រង់បោះចក្រកែវឡើងទៅ ។ ចក្រកែវនោះ ប្រតិស្ឋានទៅលើអាកាស ព្រមដោយចតុរង្គសេនា ។ តមក ចក្រកែវក៏រមៀលចុះអំពីពាក់កណ្តាលទេវលោកទាំង ២ ប្រតិស្ឋានទៅត្រង់ផែនដី ព្រមដោយចតុរង្គសេនា មានបរិនាយកកែវជាប្រមុខ ។ ព្រះរាជា ស្តេចបានទៅកាន់តាវត្តិង្សពិភពតែមួយព្រះអង្គឯងប៉ុណ្ណោះ ។

សក្កទេវរាជ លុះបានទ្រង់ជ្រាបថា ព្រះបាទមន្ធាតុស្តេចយាងមកប៉ុណ្ណោះ ក៏ស្តេចយាងក្រោកទទួលរាក់ទាក់ ព្រះអង្គក្រាបទូលថា សូមតេជបារមី ក្រោមល្អងធូលីព្រះបាទដោយត្បូង ព្រះមហាករុណាទិគុណដ៏ប្រសើរអស្ចារ្យក្រៃលែង នៅក្រោមល្អងធូលីព្រះបាទ ស្តេចយាងមក ( នេះជា ) រាជ-សម្បត្តិរបស់ល្អងធូលីព្រះបាទនោះឯង សូមទ្រង់យាងគ្រប់គ្រងចុះ ព្រះអង្គដោយសិរសា ដោយក្រោមនៃតេជៈ ហើយបានទ្រង់ចែកទេវរាជសម្បត្តិជា ២ ចំណែក ព្រមដោយទេពធីតារបាំ បានបង្អោនថ្វាយ ១ ចំណែកដល់ព្រះរាជាមន្ធាតុ ត្រឹមតែស្តេចប្រថាប់នៅនឹងតាវត្តិង្សពិភពប៉ុណ្ណោះ ភាពជាមនុស្សក៏បាត់ទៅ ភាពជាទេវតាក៏ប្រាកដឡើងជំនួស ។

បានជ្រាបថា ព្រះអង្គប្រថាប់លើព្រះទីនាំងបណ្ឌុកម្ពលសិលាសនៈរួមជាមួយនឹងសក្កទេវរាជ ដោយហេតុត្រឹមតែបើកព្រះនេត្រឡើង ទើបនឹងប្រាកដភាពផ្សេងគ្នា ។ ពួកទេវតា កាលទៅសង្កេតព្រះអង្គ ក៏នឹងប្រឡំក្នុង

ភាពផ្សេងគ្នារវាងសក្កទេវរាជ និងព្រះអង្គ ។ ព្រះអង្គ កាលទ្រង់សោយទិព្វសម្បត្តិក្នុងតាវត្តិង្សពិភពនោះ ទ្រង់គ្រប់គ្រងទេវរាជសម្បត្តិ រហូតសក្កទេវរាជស្ដេចឧប្បត្តិ និងចុតិដល់ទៅ ៣៦ ព្រះអង្គ ក៏មិនទ្រង់ឆ្អែតដោយកាមគុណឡើយ លុះទ្រង់ធ្លាក់ចាកទេវលោកនោះហើយ ក៏ទ្រង់ស្ថិតនៅក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ មានព្រះវរកាយត្រូវខ្យល់ និងកម្ដៅថ្ងៃប៉ះខ្ទប់ ទើបបានសោយទិវង្គត ។ ក៏កាលចក្រកែវប្រតិស្ឋានលើផែនដី បរិនាយកកែវ ក៏ប្រថាប់ស្នាមព្រះបាទរបស់ព្រះបាទមន្ធាតុនៅនឹងផែនមាស ហើយបង្អោនថ្វាយរាជសម្បត្តិថា នេះជារាជសម្បត្តិរបស់ព្រះបាទមន្ធាតុ ។ មនុស្សដែលមកអំពីទ្វីបទាំង ៣ នោះ មិនអាចនឹងត្រឡប់វិញបាន បាននាំគ្នាចូលទៅរកបរិនាយកកែវ ហើយប្រាប់ថា ក្រោមល្អងធូលីព្រះបាទ ពួកខ្ញុំព្រះអង្គមកដោយព្រះបរមរាជានុភាព ឥឡូវនេះ មិនអាចនឹងទៅបាន សូមក្រោមល្អងធូលីព្រះបាទ ករុណាផ្ដល់ទីលំនៅដល់ពួកខ្ញុំព្រះអង្គផងចុះ ។ បរិនាយកកែវបានប្រគល់ជនបទ ឲ្យដល់គេទាំងនោះ ដើម្បីប្រយោជន៍ដល់ការនៅ ម្នាក់ ៗ មួយកន្លែង ។

ក្នុងចំនួនជនបទទាំងនោះ តំបន់ដែលមានមនុស្សមកអំពីបុព្វវិទេហទ្វីបអាស្រ័យនៅ បាននាមថា **វិទេហរដ្ឋ** តាមឈ្មោះចាស់នោះឯង ។ តំបន់ដែលមានមនុស្សមកអំពីអមរគោយានទ្វីបអាស្រ័យនៅ បាននាមថា **អបរន្តជនបទ** ។ តំបន់ដែលមានមនុស្សមកអំពីឧត្តរកុរុទ្វីបអាស្រ័យនៅ បាននាមថា **កុរុរដ្ឋ** ។ តែមនុស្សទាំងឡាយហៅដោយពហុវចនៈ ដោយសំដៅដល់ស្រុក និងនិគមចំនួនច្រើន ព្រោះហេតុដូចដែលពោលមកហើយនេះ ទើប

ព្រះអានន្ទ ពោលថា ទ្រង់គង់នៅក្នុងដែនកុរុទាំងឡាយ ( ជាពហុវចនៈ ) ដូច្នេះ ។

## ទីមកនៃពាក្យថា កម្មាសធម្ម

ក្នុងបទថា **កម្មាសធម្មំ** ក្នុងបណ្ដាពាក្យថា **កម្មាសធម្មំ នាមកុរូនំ និគមោ** នេះ អាចារ្យពួកខ្លះ ពោលអត្ថាធិប្បាយសេចក្ដីដោយ ( ផ្លាស់ ) ធ ជា ទ ។ ស្ថានទីដែលឈ្មោះថា **កម្មាសធម្ម** ព្រោះជាកន្លែងត្រូវទូន្មានមនុស្សមានជើងពពាល ។ ព្រះបាទបោរិសាទ ដែលមានព្រះបាទពពាល គេហៅថា **កម្មាស** ( ព្រះអង្គម្ចាស់ពពាល ) ។

តំណាលមកថា ដំបៅកើតត្រង់ព្រះបាទក្នុងទីដែលត្រូវគល់ឈើចាក់ដុះឡើងស្រដៀងឈើមានធ្នូត ព្រោះដូច្នោះ ទើបប្រាកដថា មានព្រះបាទពពាល ។ ហើយក្នុងឱកាសនោះ ព្រះអង្គត្រូវទូន្មាន ហើយត្រូវហាមចាកភាពជាមនុស្សស៊ីមនុស្ស ។

នរណា ទូន្មាន ?

ព្រះបរមពោធិសត្វ ។

សួរថា ក្នុងជាតកអ្វី ?

ឆ្លើយថា ព្រះថេរៈមួយពួក ( អាងថាមានមក ) ក្នុង **សុតសោមជាតក** ។ ប៉ុន្តែព្រះថេរៈទាំងនេះប្រាប់ថា មានមកក្នុង **ជយទិសជាតក** ។ ពិតណាស់ ព្រះបរមពោធិសត្វ ទ្រង់បានទូន្មានព្រះបាទបោរិសាទដែលមានព្រះបាទពពាល ។ ដូចដែលលោកពោលទុកថា ៖

កាលយើងជាព្រះបរមឱរសាធិរាជនៃព្រះបាទជយទិស ដែល ជារាជាធិបតីនៃបញ្ចាលរដ្ឋ បានលះបង់ជីវិត ប្តូរយកព្រះ រាជបិតាហើយ ម្យ៉ាងទៀត យើងបានធ្វើឲ្យព្រះបាទបោរិ- សាទ ដែលមានព្រះបាទពពាល ជ្រះថ្លាហើយ ដូច្នោះ ។

តែអាចារ្យខ្លះ អត្ថាធិប្បាយដោយ ធ អក្សរ តែម្យ៉ាង ។ ដូចដែល តំណាលមកថាអ្នក កុរុរដ្ឋ មានទំនៀមទម្លាប់ប្រចាំកុរុរដ្ឋ តែកើតការពព្រុះ ពពាលឡើងក្នុងធម្មទំនៀមនោះ ព្រោះដូច្នោះ ទីដែលពព្រុះពពាលនោះ ទើប ត្រូវហៅថា **កម្មាសធម្ម** ព្រោះមានធម៌ គឺ ការពព្រុះពពាលកើតឡើង ។

សួរថា ហេតុដូចម្តេច ទើបលោកមិនពោលឈ្មោះនិគមដែលនៅ អាស្រ័យគ្នានេះប៉ុណ្ណោះ ទុកដោយសត្តមីវិភត្តិក្នុងពាក្យថា **កម្មាសធម្ម** នោះ ?

ឆ្លើយថា ព្រោះ ( ព្រះមានព្រះភាគ ) មិនមានឱកាសដែលនឹងគង់ ប្រថាប់ ។ បានជ្រាបថា មិនមានវិហារអ្វីដែលជាឱកាសឲ្យព្រះមានព្រះភាគ ទ្រង់ប្រថាប់ក្នុងនិគមនោះឡើយ ។ តែឆ្ងាយពីនិគមទៅ មានព្រៃសណ្ឋ:ធំ ក្នុងភូមិភាគមួយកន្លែង សម្បូណ៌ដោយទឹក ជារមណិយដ្ឋាន ។ ព្រះមាន- ព្រះភាគ ស្តេចប្រថាប់ត្រង់មហាព្រៃសណ្ឋ:នោះ ទ្រង់យកនិគមនោះ ជា **គោចរគ្រាម** ( ស្រុកទទួលបិណ្ឌបាត ) ។ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តី ក្នុងរឿងនេះថា ព្រះមានព្រះភាគស្តេចប្រថាប់នៅដែនកុរុ ទ្រង់យកនិគមរបស់ អ្នកកុរុ ដែលឈ្មោះ **កម្មាសធម្ម** ជាគោចរគ្រាម ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ** ដូចតទៅនេះ ៖

## ហេតុដូចម្ដេច ទើបត្រាស់សតិប្បដ្ឋានសូត្រនៅក្នុងកុរុរដ្ឋ

[១៣២] សួរថាហេតុ ដូចម្ដេចព្រះមានព្រះភាគ ទើបបានត្រាស់ព្រះសូត្រនេះ នៅក្នុងដែនកុរុរដ្ឋនោះ ?

ឆ្លើយថា ព្រោះអ្នកកុរុអាចនឹងទទួលយកព្រះធម្មទេសនាដ៏ជ្រាលជ្រៅបាន ។ បានជ្រាបថា ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាទាំងឡាយ អ្នកដែនកុរុរដ្ឋ ជាអ្នកមានរាងកាយ និងចិត្តសប្បាយជានិច្ច ដោយអំណាចនៃបច្ច័យ គឺ រដូវជាទីសប្បាយ ព្រោះរដ្ឋនោះសម្បូរដោយបច្ច័យ គឺ រដូវ ។ មនុស្សទាំងនោះមាន កម្លាំងបញ្ញាដែលអាស្រ័យការសប្បាយចិត្ត និងរាង-កាយអនុគ្រោះហើយ និងជាអ្នកអាចទទួល ( ស្ដាប់ ) ពាក្យដ៏ជ្រាលជ្រៅបាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគកាល ទ្រង់ពិចារណាឃើញថា មនុស្សទាំងនោះអាចនឹងទទួល ( ស្ដាប់ ) ព្រះធម្មទេសនាដ៏ជ្រាលជ្រៅនេះបាន ទើបបានត្រាស់ **សតិប្បដ្ឋានសូត្រ** ដែលមានអត្ថដ៏ជ្រាលជ្រៅនេះ ដោយបំពេញព្រះកម្មដ្ឋានចូលក្នុងព្រះអរហត្ត ក្នុងឋានៈ ១៩ យ៉ាង ។

ឧបមាដូចបុរសបានប្រអប់មាសហើយ បញ្ចុះផ្កាឈើប្រភេទផ្សេង ៗ ទុកក្នុងប្រអប់មាសនោះ ឬបានហិបមាសហើយ ទុកដាក់រតនៈទាំង ៧ ( ក្នុងនោះ ) យ៉ាងណា ។ ព្រះមានព្រះភាគ ក៏ដូច្នោះ លុះទ្រង់បានអ្នកកុរុរដ្ឋបរិស័ទ ទើបបានទ្រង់សម្ដែង ព្រះធម្មទេសនាដ៏ជ្រាលជ្រៅ ។ ដោយហេតុនោះទុំឯងក្នុងមជ្ឈិមនិកាយមូលបណ្ណាសកនេះ ទ្រង់ទើបបានសម្ដែងព្រះសូត្រ ដែលមានខ្លឹមសារជ្រាលជ្រៅទុកតែម្យ៉ាងក្នុងទីឃនិកាយ ទ្រង់បានសម្ដែងទុកម្យ៉ាងទៀត គឺ **មហានិទានសូត្រ ១ មហាសតិប្បដ្ឋានសូត្រ ១** ( និង ) ក្នុងមជ្ឈិម-

និកាយនេះ ទ្រង់បានសម្តែងទុកម្យ៉ាងទៀត គឺ សារោបមសូត្រ ១ រុក្ខូបមសូត្រ ១ រដ្ឋបាលសូត្រ ១ មាគន្ទិយសូត្រ ១ អានញ្ជសប្បាយសូត្រ ១ ។

ម្យ៉ាងទៀត ក្នុងជនបទនោះ តាមសភាពប្រក្រតីបរិស័ទទាំង ៤ នាំគ្នាប្រកបសេចក្តីព្យាយាមរឿយ ៗ នៅក្នុងសតិប្បដ្ឋានភាវនា ដោយទីបំផុតសូម្បីពួកទាសៈ កម្មករ និងបរិវារជន ក៏និយាយចរចាគ្នាទាក់ទងសតិប្បដ្ឋាននោះ ។ សូម្បីតែត្រង់កំពង់ទឹក និងស្ថានទីរវៃអំបោះជុំគ្នាជាដើម ដែលឈ្មោះថា ការនិយាយគ្នាក្នុងរឿងឥតប្រយោជន៍នឹងប្រព្រឹត្តទៅ មិនមានឡើយ ។ បើស្ត្រីណាមួយត្រូវសួរថា អ្នកម៉ែម្ចាស់ អ្នកម៉ែមនសិការសតិប្បដ្ឋានភាវនាប្រការណា ? ហើយឆ្លើយថា មិនបានមនសិការប្រការណាឡើយ ។ មនុស្សទាំងឡាយនឹងតិះដៀលថា ជីវិតរបស់នាងឥតប្រយោជន៍ នាងមានជីវិតរស់នៅដូចជាមនុស្សស្លាប់ហើយ ។ ទើបបានឲ្យឱវាទនាងថា ចាប់តាំងពីពេលនេះទៅ កុំធ្វើយ៉ាងនេះឡើយ ហើយឲ្យរៀនយកសតិប្បដ្ឋានប្រការណាមួយ ។ តែ ( បើ ) ស្ត្រីណានិយាយថា ខ្ញុំមនសិការសតិប្បដ្ឋានឈ្មោះឯណោះ ។ មនុស្សទាំងឡាយ នឹងនាំគ្នាឲ្យសាធុការថា សាធុ សាធុ ហើយសរសើរដោយពាក្យទាំងឡាយមានជាអាទិ៍ថា ជីវិតរបស់នាង ជាជីវិតដ៏ល្អហើយ នាងឈ្មោះថា ជាមនុស្សប្រសើរហើយ ព្រះសម្មាសម្ពុទ្ធស្តេចឧប្បត្តិឡើងមកដើម្បីប្រយោជន៍ដល់នាង ។ ក៏ក្នុងរឿងនេះ មិនមែនចំពោះតែមនុស្សជាតិតែម្យ៉ាងប៉ុណ្ណោះទេ ដែលនាំគ្នាប្រកបមនសិការសតិប្បដ្ឋាន សូម្បីតែពួកសត្វតិរច្ឆានដែលនៅអាស្រ័យគេ ក៏មនសិការសតិប្បដ្ឋាន ក្នុងការមនសិការសតិប្បដ្ឋានរបស់សត្វនោះ មានរឿងតំណាលដូចតទៅនេះ ៖

# សត្វសេកចម្រើនសតិប្បដ្ឋាន

តំណាលមកថា អ្នករបាំម្នាក់ដើរចាប់កូនសេកមកហ្វឹកហាត់ ។ នាងនៅអាស្រ័យភិក្ខុនី វេលាទៅ ក៏ទៅ (តែខ្លួន) ភ្លេចកូនសេក ពួកសាមណេរីក៏ចាប់វាមកចិញ្ចឹមទុក ។ ដាក់ឈ្មោះឲ្យវាថា **ពុទ្ធរក្ខិតៈ** ( ពុទ្ធរក្សា ) ។ ថ្ងៃមួយព្រះថេរីឃើញវាទំនៅខាងមុខ ទើបហៅថា ពុទ្ធរក្ខិតៈ ។

វាឆ្លើយថា អ្វីចា៎ ម៉ែម្ចាស់ ព្រះថេរីសួរមានមនសិការភាវនាអ្វីខ្លះទេ ? បក្សីឆ្លើយថា មិនមានទេម៉ែម្ចាស់ ។ ព្រះថេរីនិយាយថា ឯងអើយ ធម្មតាអ្នកនៅក្នុងសម្នាក់បព្វជិត មិនគួរនឹងរស់នៅ ដោយបណ្តោយអត្តភាពចោល ( បណ្តោយខ្លួន ) គួរប្រារព្ធមនសិការឯណាមួយ ហើយបានប្រាប់ថា តែយ៉ាងដទៃ ឯងមិនអាច ( ធ្វើបាន ) ចូរស្វាធ្យាយ ( បរិកម្ម ) ថា **អដ្ឋិ អដ្ឋិ** ឆ្អឹង ឆ្អឹង ។ វាតាំងនៅក្នុងឱវាទរបស់ព្រះថេរី ត្រាច់ស្វាធ្យាយថា **អដ្ឋិ អដ្ឋិ** ឆ្អឹង ឆ្អឹង ។ ថ្ងៃមួយពេលព្រឹក វាទំនៅលើចុងសសរហាលកម្តៅថ្ងៃ បក្សីមួយ បានយកក្រញាំក្រចកឆាបយកទៅ ។ វាស្រែកឮសំឡេង ចេច ចេច ។ សាមណេរីទាំងឡាយបានឮសំឡេងស្រែក ទើបនិយាយថា ព្រះម៉ែម្ចាស់ ពុទ្ធរក្ខិតៈ ត្រូវខ្លែងឆាបយកទៅហើយ នាងទៅជួយឲ្យវាព្រលែង ហើយនាំគ្នាកាន់យកដុំដីជាដើម ដេញតាមទៅ ឲ្យវាព្រលែងទាល់តែបាន ។ ព្រះថេរីសួរវា ដែលគេជួយនាំមក ទំនៅខាងមុខថា ពុទ្ធរក្ខិតៈ វេលាបក្សីឆាបយកទៅឯងគិតដូចម្តេច ?

វាឆ្លើយថា អ្នកម៉ែម្ចាស់ នាងខ្ញុំមិនបានគិតយ៉ាងដទៃទេ នាងខ្ញុំគិតដល់គំនរឆ្អឹងប៉ុណ្ណោះ យ៉ាងនេះថា គ្រោងឆ្អឹងនេះឯង ឆាបយកគ្រោងឆ្អឹងទៅ

គ្រោងឆ្អឹងនឹងបែកជ្រាយខ្ចាត់ខ្ចាយទៅ ។ មិនថាសូម្បីក្នុងទីណា ។

ល្អហើយ ល្អហើយ ពុទ្ធវក្ខិត: ( ការមនសិការយ៉ាងនោះ ) នឹងជាបច្ច័យដល់ការអស់ទៅនៃភព របស់អ្នកក្នុងអនាគត ។ សូម្បីសត្វតិរច្ឆានក្នុងជនបទនោះ ក៏ប្រកបមនសិការក្នុងសតិប្បដ្ឋាន ដូចដែលពោលមកហើយនេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ញ៉ាំងការបម្រើនក្នុងសតិប្បដ្ឋាននោះឯង ឲ្យកើតដល់គេទាំងនោះ ទើបបានត្រាស់ព្រះសូត្រនេះទុក ។

## អត្ថនៃពាក្យថា ឯកាយន

បណ្ដាបទទាំងនោះ បទថា **ឯកាយនោ** ប្រែថា ផ្លូវឯក ។ ព្រោះថាផ្លូវមានឈ្មោះច្រើនយ៉ាង គឺ **មគ្គោ** , **បន្ថ:** , **បថ:** , **បជ្ជ:** , **អញ្ជស:** , **វដុម:** , **អាយតន:** , **នាវា** , **ឧត្តរសេតូ** , **កុល្ល:** , **ភិសិ** និង **សង្កម:** ។

ក្នុង **សតិប្បដ្ឋានសូត្រ** នេះ ព្រះអង្គត្រាស់ផ្លូវនេះទុក ដោយឈ្មោះថា **អយន:** ។ ព្រោះដូច្នោះ ក្នុងពាក្យថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ** ( ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះ ជាផ្លូវមូលតែមួយ ) នេះ គួរយល់សេចក្ដីយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវមួយខ្សែ មិនមែនជាផ្លូវ ២ ខ្សែឡើយ ។

មយ៉ាងទៀត ផ្លូវដែលឈ្មោះថា **ឯកាយន:** ព្រោះមនុស្សម្នាក់ប៉ុណ្ណោះគប្បីទៅ ។ ពាក្យថា ម្នាក់ឯង គឺ គួរលះបង់ការនៅច្រឡូកច្រឡំដោយពួកគណ: ចៀសចេញទៅកាន់ទីស្ងាត់ ដំណើរទៅ គឺ បដិបត្តិ ( ម្នាក់ឯង )

ឬដែលឈ្មោះថា **អយនៈ** ព្រោះជាហេតុនៃដំណើរទៅ គឺ ទៅអំពីវដ្តសង្សារ ដល់ព្រះនិព្វាន ។

ផ្លូវដើររបស់បុគ្គលឯក ឈ្មោះថា **ឯកាយនៈ** ពាក្យថា បុគ្គលឯក បានដល់ បុគ្គលប្រសើរជាទីបំផុត ។ បុគ្គលដែលប្រសើរជាទីបំផុតជាង សព្វសត្វ គឺ ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបមានអធិប្បាយថា បានដល់ ( ផ្លូវយាន ) របស់ព្រះមានព្រះភាគ ។

ពិតណាស់ សូម្បីអ្នកដទៃ ក៏ដើរទៅតាមផ្លូវនោះបាន តែសូម្បីយ៉ាង នោះក៏ដោយ ផ្លូវនោះ ក៏ឈ្មោះថា ជាផ្លូវដំណើររបស់ព្រះមានព្រះភាគ ព្រោះ ព្រះអង្គទ្រង់សាងឡើង ។ ដូចដែលលោកបានពោលទុកថា ម្នាលព្រាហ្មណ៍ ពិតណាស់ ព្រះមានព្រះភាគអង្គនោះ ទ្រង់ញុំាងផ្លូវ ដែលមិនទាន់កើត ឲ្យ កើតឡើងហើយ ដូច្នេះជាដើម ។

ម្យ៉ាងទៀត ដែលឈ្មោះថា **អយនៈ** ព្រោះទៅ គឺ ដំណើរទៅ អធិប្បាយថា ប្រព្រឹត្តទៅ ។ មានអធិប្បាយថា ទៅក្នុងទីតែមួយ គឺ ប្រព្រឹត្ត ទៅក្នុងធម្មវិន័យ ( សាសនា ) នេះប៉ុណ្ណោះ មិនមែនទៅទីដទៃ ។ ដូចដែល ត្រាស់ទុកថា ម្នាលសុភទ្ទៈ **អរិយមគ្គមានអង្គ ៨** ស្វែងរកបានតែក្នុង ព្រះធម្មវិន័យ ( សាសនា ) នេះឯង ។ សេចក្តីពិត ខ្លឹមសារទាំង ២ នេះ ផ្សេងគ្នាត្រឹមតែទេសនា ( វោហារ ) ប៉ុណ្ណោះ ប៉ុន្តែក៏មានសេចក្តីដូចគ្នា ។

ម្យ៉ាងទៀត ដែលឈ្មោះថា **ឯកាយនៈ** ព្រោះទៅកាន់ទិសដៅតែមួយ មានអធិប្បាយថា ក្នុងខាងដើម សូម្បីនឹងប្រព្រឹត្តទៅដោយន័យនៃការនាដែល ជាគោលផ្សេងគ្នា ប៉ុន្តែខាងក្រោយ ក៏នឹងទៅកាន់ព្រះនិព្វានតែម្យ៉ាងនោះឯង

ដូចដែលសហម្បតីព្រហ្ម បានពោលទុកថា ៖

ព្រះមានព្រះភាគ ព្រះអង្គទ្រង់ឃើញទីបំផុតនៃការអស់ទៅនៃជាតិ ទ្រង់អនុគ្រោះ ( ទ្រង់មានព្រះករុណាទិគុណ ) ទ្រង់ជ្រាបផ្លូវទៅកាន់ទីកន្លែងមួយ ( ព្រះនិព្វាន ) ដោយផ្លូវនេះ ដែលមនុស្សទាំងឡាយបានធ្លាប់ឆ្លងឱឃៈ អន្លង់ទឹកមកហើយ កំពុងឆ្លង និងឆ្លងតទៅ ។

ប៉ុន្តែអាចារ្យពួកខ្លះពោលថា ដែលឈ្មោះថា **ឯកាយនៈ** ព្រោះទៅដល់និព្វានមួយដង តាមន័យនៃសេចក្ដីថា មិនទៅដល់ត្រើយ ( គឺ ព្រះនិព្វាន ) ដល់ ២ ដង ។ ពាក្យនោះមិនត្រឹមត្រូវ ។ ព្រោះថា **អត្ថ** ( សេចក្ដី ) យ៉ាងនេះ ព្យញ្ជនៈគួរនឹងជាយ៉ាងនេះថា **សកឹ អយនោ** ( មិនមែន **ឯកាយនោ** ) ។ តែបើនឹងពោលប្រកបសេចក្ដីយ៉ាងនេះថា ផ្លូវនោះ មានផ្លូវទៅតែម្យ៉ាង គឺមានគតិ បានដល់ មានការប្រព្រឹត្តទៅតែម្យ៉ាង ដូច្នេះព្យញ្ជនៈក៏ប្រើបាន ។ តែអត្ថ ប្រើមិនបានទាំង ២ យ៉ាង ។

ព្រោះហេតុអ្វី ?

ព្រោះក្នុងទីនេះ ទ្រង់បំណងយកមគ្គដែលជាបុព្វភាគ ។

អធិប្បាយថា ក្នុងទីនេះ ព្រះអង្គទ្រង់បំណងយកមគ្គជាទីតាំងនៃសតិ ( សតិប្បដ្ឋាន ) ដែលជាចំណែកខាងដើម ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៤ មានកាយជាដើម ។ មិនមែនមគ្គដែលជាលោកុត្តរៈ ។ ហើយមគ្គដែលជាចំណែកខាងដើមនោះ ក៏ទៅបានមិនមែនមួយដង ទាំងមានការទៅមិនមែនតែមួយដង ។

## សិស្ស និងអាចារ្យសន្ទនាគ្នា

ម្យ៉ាងទៀត សូម្បីកាលមុនក្នុងបទនេះ ព្រះមហាថេរៈទាំងឡាយក៏មានការសន្ទនាមកហើយ ដូចគ្នា ។ ( គឺ ) ព្រះត្រៃបិដកចុល្លនាគត្ថេរ បានពោលទុកថា ជាផ្លូវ គឺ សតិប្បដ្ឋានដែលជាបុព្វភាគ ។ ប៉ុន្តែអាចារ្យរបស់លោក គឺ ព្រះត្រៃបិដកចុល្លសុមនត្ថេរ បានពោលទុកថា ជាមិស្សកមគ្គ ( ទាំងលោកិយៈ និងលោកុត្តរៈ ) ។

ព្រះត្រៃបិដកចុល្លនាគត្ថេរពោលថា ជាបុព្វភាគ លោកម្ចាស់ !

ព្រះត្រៃបិដកចុល្លសុមនត្ថេរ ប្រកែកថា ជាមិស្សកមគ្គ អាវុសោ ! កាលអាចារ្យពោលដដែលហើយដដែលទៀត សិស្សក៏នៅស្ងៀម មិនជំទាស់ ។ ( ទាំង ២ នាក់ ) ក៏ក្រោកឡើងដោយមិនវិនិច្ឆ័យឲ្យ ( ដាច់ស្រេច ) បញ្ហាឡើយ ។ ក្រោយមក ព្រះថេរៈ ជាអាចារ្យទៅកាន់បន្ទប់ផ្លូតទឹក គិតថា យើងនិយាយថា ជាមិស្សកមគ្គ ( ទាំងជាលោកិយមគ្គ និងទាំងជាលោកុត្តរមគ្គ ) ប៉ុន្តែអាវុសោ ចុល្លនាគសម្តែងថា ជាផ្លូវខាងដើម ក្នុងបញ្ហានេះនឹងមានវិនិច្ឆ័យយ៉ាងណាហ្ន៎ ទើបស្វាធ្យាយព្រះសូត្រតាំងអំពីដើមទៅ កំណត់ ( បញ្ឈប់ ) ត្រង់នេះថា **យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេយ្យ សត្ត វស្សានិ** ( ម្នាលភិក្ខុទាំងឡាយ អ្នកណាមួយក៏ដោយ ចម្រើនសតិប្បដ្ឋានទាំង ៤ យ៉ាងនេះ រហូត ៧ ឆ្នាំ ) ដូច្នេះ លោកក៏ដឹងថា ធម្មតាលោកុត្តរមគ្គ កាលកើតឡើងហើយនឹងជំអក់នៅរហូត ៧ ឆ្នាំ មិនមានមគ្គដែលជាមិស្សកៈ ដែលយើងពោលហើយនោះ មិនត្រឹមត្រូវឡើយ ចំណែកមគ្គដែលជាបុព្វភាគ ដែលអាវុសោចុល្លនាគសម្តែងហើយនោះ ទើបត្រឹមត្រូវ

ទើបបានទៅក្នុងទីដែលសម្រាប់ប្រកាសក្នុងថ្ងៃធម្មស្សវនៈ ៨ កេច ។

បានជ្រាបថា ព្រះថេរៈក្នុងកាលមុនពេញចិត្តស្តាប់ធម៌ ។ លុះបានឮសំឡេងប៉ុណ្ណោះ ក៏គិតថា យើង (នឹងស្តាប់) មុន (នឹងស្តាប់) មុន ហើយដាក់ចិត្តស្តាប់ដោយសេចក្តីគោរពយ៉ាងខ្លាំងក្លា ។ ថ្ងៃនោះ ក៏ជាវារៈរបស់ព្រះចុល្លនាគត្ថេរ កាលលោកអង្គុយលើធម្មាសនៈ ចាប់ផ្ដិតហើយពោល **អារម្ភបទ** ( បុព្វកថា ) ព្រះថេរៈដែលឈរនៅក្រោយអាសនៈ បានមានការគិតថា យើងអង្គុយក្នុងទីកំបាំង មិននិយាយ ( អ្វី ) ។ ព្រោះថា ព្រះថេរៈក្នុងកាលមុនជាអ្នកស្តាប់ ។ នឹងមិនលើកដាក់ការពេញចិត្តរបស់ខ្លួនឡើង ជាធំតែម្យ៉ាង ប្រៀបដូចមនុស្សលើបាច់អំពៅ ដូច្នោះ ប្រកាន់ហេតុផលម្យ៉ាង ។ លះបង់វត្ថុដែលមិនមានហេតុផលចោល ព្រោះដូច្នោះ ទើបព្រះថេរៈនិយាយថា អាវុសោ ចុល្លនាគ ។

ព្រះ ( ចុល្លនាគ ) សង្ស័យថា សំឡេងនេះ ដូចជាសំឡេងរបស់លោកអាចារ្យ ក៏បានបញ្ឈប់ការសម្តែងធម៌ ហើយសួរថា មានការអ្វីលោកម្ចាស់ ?

ព្រះថេរៈឆ្លើយថា អាវុសោ ចុល្លនាគ មគ្គផ្លូវដែលខ្ញុំពោលមកនោះ មិនត្រឹមត្រូវទេ ប៉ុន្តែមគ្គ គឺ សតិប្បដ្ឋានដែលជាបុព្វភាគ ដែលអាវុសោពោលនោះ ត្រឹមត្រូវហើយ ។

ព្រះថេរៈ ( ចុល្លនាគ ) គិតថា អាចារ្យរបស់យើងរៀនបរិយត្តិទូទៅរហូតចាំព្រះត្រៃបិដកទុកបាន ជាសុតពុទ្ធ បញ្ហានេះនៅជាអាថ៌កំបាំងសម្រាប់ភិក្ខុប្រភេទនេះ ( ឋានៈជាអាចារ្យ ) ភិក្ខុនៅកំលោះក្នុងអនាគតនឹងសង្ស័យ

បញ្ហានេះជាពិតប្រាកដ យើងនឹងលើកយកព្រះសូត្រមកអធិប្បាយបញ្ហានេះឲ្យបានច្បាស់លាស់ ។ ចាកគម្ពីរ បដិសម្ភិទាមគ្គ បុព្វភាគសតិប្បដ្ឋានមគ្គ លោកហៅថា ឯកាយនមគ្គ ។ ព្រះថេរៈបាននាំយកព្រះសូត្រមកសម្តែងថា ៖

បណ្តាផ្លូវទាំងឡាយ ផ្លូវមានអង្គ ៨ ប្រសើរជាទីបំផុត បណ្តាសច្ចៈទាំងឡាយ បទ គឺ (សច្ចៈ) ទាំង ៤ ប្រសើរជាទីបំផុត បណ្តាធម៌ទាំងឡាយ វិរាគធម៌ប្រសើរជាទីបំផុត បណ្តាសត្វជើង ២ ទាំងឡាយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់មានបញ្ញាចក្ខុ ប្រសើរជាទីបំផុត ផ្លូវនេះប៉ុណ្ណោះ មិនមានផ្លូវដទៃ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធិនៃញាណទស្សនៈ ។ អ្នកទាំងឡាយ ចូរដើរផ្លូវនោះចុះ ដែលជាទីញ៉ាំងមារ និងសេនាមារឲ្យវង្វេង ។ ព្រោះថា អ្នកទាំងឡាយដើរទៅតាមផ្លូវនោះហើយ នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

## អធិប្បាយ មគ្គ

ផ្លូវ ដែលឈ្មោះថា មគ្គ ព្រោះអត្ថដូចម្តេច ?

ព្រោះអត្ថថា ជាហេតុឲ្យដល់ព្រះនិព្វាន និងព្រោះអត្ថថា អ្នកមានសេចក្តីត្រូវការព្រះនិព្វាន នឹងដើរទៅ ។

បទថា **សត្តានំ វិសុទ្ធិយា** (ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ) សេចក្តីថា ដើម្បីប្រយោជន៍ដល់សេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ អ្នកមានចិត្តសៅហ្មងហើយ ព្រោះមន្ទិលទាំងឡាយ មានរាគៈជាដើម និងព្រោះឧបក្កិ-

លេសទាំងឡាយ មានអភិជ្ឈាវិសមលោភៈជាដើម ។

ពិតណាស់ ក៏សត្វទាំងនេះ គឺ **ព្រះសម្មាសម្ពុទ្ធជាម្ចាស់** ចំនួនច្រើន ព្រះអង្គ ចាប់ផ្តើមអំពីព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា **តណ្ហង្ករ មេធង្ករ សរណង្ករ ទីបង្ករ** ដែលស្តេចបានឧប្បត្តិហើយក្នុងកប្បមួយជាមួយគ្នានោះឯង ។ មុនអំពីកប្បនេះទៅ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប រហូតដល់ **ព្រះសក្យមុនី** ជាទីបំផុតក្តី **ព្រះបច្ចេកសម្ពុទ្ធជាម្ចាស់** ច្រើនរយព្រះអង្គក្តី **ព្រះអរិយសាវក** ដែលរាប់មិនបានប្រមាណមិនត្រូវក្តី ទ្រង់បានបណ្តេត និងបន្សាត់មន្ទិលរបស់ចិត្តទាំងមូលហើយ ទ្រង់សម្រេច និងសម្រេចភាពបរិសុទ្ធិដ៏កំពូល ក៏ដោយផ្លូវនេះ ។ ប៉ុន្តែដោយអំណាចនៃមន្ទិលរបស់រូប នឹងមិនមានការបញ្ញត្តិការសៅហ្មង និងភាពផូរផង់ឡើយ ។

ពិតណាស់ ព្រះមហាឫសី ( ព្រះពុទ្ធជាម្ចាស់ ) មិនបានត្រាស់ទុកថា មាណព ( បុគ្គល ) ទាំងឡាយសៅហ្មង ព្រោះរូបសៅហ្មង បរិសុទ្ធព្រោះរូបបរិសុទ្ធ ប៉ុន្តែព្រះមហាឫសីបានត្រាស់ទុកយ៉ាងនេះថា មាណព ( បុគ្គល ) ទាំងឡាយស្មៅហ្មង ព្រោះចិត្តសៅហ្មង បរិសុទ្ធ ព្រោះចិត្តបរិសុទ្ធ ។

ដូចដែលព្រះអង្គបានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយសៅហ្មង ព្រោះចិត្តសៅហ្មង , ផូរផង់ ព្រោះចិត្តផូរផង់ ។ ហើយភាពផូរផង់របស់ចិត្តនោះ មានបានព្រោះផ្លូវ គឺ សតិប្បដ្ឋាននេះឯង ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ទុកថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ។

បទថា **សោកបរិទេវានំ សមតិក្កមាយ** ( ដើម្បីលះបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលទាំងឡាយ ) សេចក្តីថា ដើម្បីរំងាប់ អធិប្បាយ

ថា ដើម្បីលះបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួលទាំងឡាយ ។

ព្រោះថា មគ្គនេះ បុគ្គលអប់រំហើយ ប្រព្រឹត្តទៅដើម្បីលះបង់នូវសេចក្តីសោកសៅ ( របស់សត្វទាំងឡាយបាន ) ដូចសន្តតិមហាមាត្យជាដើម នឹងលះបង់នូវសេចក្តីខ្សឹកខ្សួល ( របស់សត្វទាំងឡាយ ) បាន ដូចបដាចារ-ថេរីជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ទុកថា **សោកបរិទេវានំ សមតិក្កមាយ** ( ដើម្បីឈានកន្លងនូវសេចក្តីសោក និងបរិទេវៈទាំងឡាយ ) ។

សេចក្តីពិត សន្តតិមហាមាត្យ សូម្បីនឹងបានស្តាប់ព្រះគាថានេះថា ៖

**អ្នកចូរធ្វើសេចក្តីសោកក្នុងកាលមុន ( សោកមានអារម្មណ៍ជាអតីត ) ឲ្យរីងស្ងួតទៅ អ្នកកុំមានសេចក្តីកង្វល់ចិត្តក្នុងកាលជាខាងក្រោយឡើយ ( មិនកង្វល់ចំពោះអារម្មណ៍ជាអនាគត ) បើអ្នកមិនប្រកាន់ចំពោះធម៌ជាកណ្តាល គឺបច្ចុប្បន្ន អ្នកនឹងជាបុគ្គលស្ងប់ត្រាច់ទៅ ដូច្នេះ ។**

សន្តតិមហាមាត្យ បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។

ព្រះនាងបដាចារាថេរី បានស្តាប់ព្រះគាថានេះថា ៖

**មានបុត្តទុកដើម្បីជួយក៏មិនបាន បិតាក៏មិនបាន ពួកញាតិក៏មិនបាន កាលសេចក្តីស្លាប់គ្របសង្កត់ហើយ ញាតិទាំងឡាយក៏ជួយមិនបាន ។**

ហើយបានតាំងនៅក្នុងសោតាបត្តិផល ផងដែរ ។ ប៉ុន្តែថា ព្រោះដែលឈ្មោះថា **ភាវនា** ហើយ នឹងមិនទាក់ទងជាមួយធម៌ឯណានីមួយក្នុង **កាយ** ,

វេទនា , ចិត្ត , ធម៌ មិនមាន ព្រោះដូច្នោះ សូម្បីអ្នកទាំង ២ នោះ ក៏ត្រូវជ្រាបផងថា ការឈានកន្លង **សោកៈ បរិទេវៈ** ទៅបាននោះ ព្រោះមគ្គនេះដូចគ្នា ។

បទថា **ទុក្ខទោមនស្សានំ អត្ថង្គមាយ** ( ដើម្បីរំងាប់នូវទុក្ខទាំងឡាយ ) សេចក្តីថា ដើម្បីរំងាប់ អធិប្បាយថា ដើម្បីរំលត់នូវទុក្ខទាំង ២ យ៉ាងនេះ គឺ **ទុក្ខផ្លូវកាយ ១ ទោមនស្សផ្លូវចិត្ត ១** ។ ដោយថា មគ្គនេះ បុគ្គលអប់រំហើយ នឹងប្រព្រឹត្តទៅដើម្បីរំលត់នូវទុក្ខនៃសត្វទាំងឡាយ ដូចសេចក្តីទុក្ខរបស់ **ព្រះតិស្សត្ថេរ** ជាដើម និងដើម្បីរំលត់ទោមនស្សនៃសត្វទាំងឡាយ ដូចទោមនស្សរបស់សក្កទេវរាជជាដើម ។ ក្នុងរឿងនោះ មានការសម្តែងសេចក្តីដូចតទៅនេះ ៖

## ព្រះថេរៈគប់បំបាក់ជើង

តំណាលមកថា ក្នុងក្រុងសាវត្ថី បុត្ររបស់កុដុម្ពីឈ្មោះ **តិស្សៈ** លះបង់នូវទ្រព្យសម្បត្តិ ៤០ កោដិ ចេញបួស នៅតែម្នាក់ឯងក្នុងព្រៃ មិនមានផ្ទះ ។ ភរិយារបស់ប្អូនប្រុសលោកបានបញ្ជូនចោរ ៥០០ នាក់ ទៅសម្លាប់លោកចោល ពួកចោរបានឡោមព័ទ្ធព្រះថេរៈ ព្រះថេរៈសួរថា ឧបាសកនាំគ្នាមកធ្វើអ្វី ? ចោរ ប្រាប់ថា ពួកខ្ញុំនឹងសម្លាប់លោកឯងហ្នឹងណា៎ ។ ព្រះថេរៈសុំអង្វរថា ឧបាសកទាំងឡាយ ចូរកាន់យកខ្លួនអាត្មាភាពទុកជាគ្រឿងធានា ហើយឲ្យជីវិតដល់អាត្មាមួយយប់នេះចុះ ។

ពួកចោរសួរថា សមណៈ នរណានឹងជាអ្នកប្រាកដប្រជាឲ្យលោកនៅ

ក្នុងទីនេះ ?

ព្រះថេរៈ ក៏ចាប់ដុំថ្មមួយដុំធំ គប់ឆ្អឹងស្មងជើងទាំងពីរឲ្យបាក់ រួចពោលថា ឧបាសកអើយ មនុស្សដែលត្រូវគេចាប់យកទុកជាថ្នូរ ( ម្នាក់នេះ ) សមគួរ ( ឬទេ ) ? ពួកចោរក៏នាំគ្នាចៀសចេញទៅ បង្កាត់ភ្លើង ដេកនៅត្រង់ខាងដើមផ្លូវចង្ក្រម ( របស់លោក ) ។

កាលព្រះថេរៈគ្របសង្កត់វេទនាទុកហើយ ពិចារណាសីល ព្រោះអាស្រ័យសីលដ៏បរិសុទ្ធិ បីតិ និងបាមោជ្ជៈ ទើបកើតឡើង លំដាប់តអំពីនោះ លោកក៏ចម្រើនវិបស្សនា បំពេញសមណធម៌រហូតពេញមួយយប់ គ្រប់យាមទាំងបី លុះអរុណរះឡើង ក៏បានសម្រេចអរហត្ត បានបន្លឺឧទានថា ៖

យើងគប់ជើងទាំងពីរ ជាការទប់ស្កាត់ចំពោះចោរទាំងឡាយ
យើងអៀនខ្មាសចំពោះសេចក្ដីស្លាប់ ទាំងដែលនៅមានរាគៈ
យើងគិតយ៉ាងនេះហើយ ក៏ឃើញច្បាស់តាមសេចក្ដីពិត
ដល់ពេលអរុណរះ យើងក៏បើកទ្វារនាំង ដល់នូវការអស់
កិលេសពុំមានសេសសល់ ។

## ភិក្ខុបានសម្រេចព្រះអរហត្តក្នុងមាត់ខ្លា

ភិក្ខុ ៣០ អង្គ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះមានព្រះភាគជាម្ចាស់ បានចាំវស្សាក្នុងអរញ្ញវិហារ និងសន្យាគ្នាថា យើងគួរធ្វើសមណធម៌ពេញមួយយប់ ក្នុងយាមទាំងបី យើងមិនគួរមកកាន់សម្នាក់របស់គ្នា និងគ្នា រួចហើយភិក្ខុទាំង ៣០ អង្គ ក៏នៅកន្លែងផ្សេង ៗ គ្នា ។ កាលភិក្ខុទាំងនោះធ្វើសមណ-

ធម៌ ពេលជិតភ្លឺក៏ងោកងក់លក់មិនដឹងខ្លួន ខ្លាធំមួយ ក៏មកចាប់ភិក្ខុទៅស៊ីជាអាហារ មួងមួយអង្គ ៗ ភិក្ខុណា ៗ ក៏មិនបានស្រែក សូម្បីគ្រាន់តែវាចាថា ខ្លាចាប់ខ្ញុំហើយ ក៏អត់ដែរ ។

ភិក្ខុត្រូវខ្លាចាប់ស៊ីអស់ ១៥ អង្គ ដោយអាការយ៉ាងនេះ ដល់ថ្ងៃឧបោសថ ភិក្ខុដ៏សេស បាននិមន្តមកជួបជុំគ្នា លុះដឹងរឿងហើយ ក៏បានប្រាប់គ្នាថា អង្គណាត្រូវខ្លាចាប់ គួរប្រាប់គ្នា ហើយក៏នៅផ្សេងគ្នាដូចមុនទៀត ។

ក្រោយមក ខ្លាក៏ចាប់ភិក្ខុកំលោះមួយអង្គរបៀបដូចមុន លោកក៏ស្រែកថា ខ្លាចាប់ខ្ញុំករុណាហើយទាន ភិក្ខុទាំងឡាយក៏កាន់ឈើច្រត់ និងគប់ភ្លើងដេញតាម ដោយគិតថា ឲ្យខ្លាវាព្រលែងលោកមកវិញ ប៉ុន្តែខ្លាវាបានលោតឡើងទៅកាន់ទីដាច់មួយនៃភ្នំ ដែលភិក្ខុទាំងឡាយមិនអាចតាមទៅបាន ហើយវាក៏ចាប់ផ្តើមស៊ីភិក្ខុនោះ ចាប់ពីម្រាមជើងឡើងទៅ ។

ភិក្ខុទាំងឡាយដែលតាមខ្លាទៅនោះ ក៏បានត្រឹមតែពោលថា សប្បុរសឥឡូវនេះ កិច្ចដែលពួកយើងនឹងត្រូវធ្វើមិនមានឡើយ ដែលឈ្មោះថា សេចក្តីពិសេសរបស់ភិក្ខុទាំងឡាយ រមែងប្រាកដក្នុងឋានៈ ដូច្នេះ ។

ភិក្ខុកំលោះដែលត្រូវខ្លាខាំស៊ីនោះ នៅក្នុងមាត់ខ្លា ខំប្រឹងអត់ទ្រាំចំពោះទុក្ខវេទនា ហើយចម្រើនវិបស្សនា ពេលខ្លាស៊ីដល់កជើង បានជាព្រះសោ-តាបន្ន ពេលស៊ីដល់ក្បាលជង្គង់ បានជាព្រះសកទាគាមី ពេលខ្លាស៊ីដល់ពោះរបស់លោក ក៏បានជាព្រះអនាគាមី ពេលខ្លាស៊ីជិតដល់បេះដូង លោកក៏បានសម្រេចនូវព្រះអរហត្តព្រមដោយបដិសម្ភិទា ទើបបន្លឺឧទានដូច្នេះថា ៖

យើងមានសីល ដល់ព្រមដោយវត្ត មានបញ្ញា មានចិត្ត

តម្កល់ស្មើល្អហើយ អាស្រ័យសេចក្តីប្រមាទមួយភ្លែត ទាំងដែលមានចិត្តមិនគិតប្រទូស្តចំពោះខ្លា វាក៏ចាប់ទុកក្នុងក្រញាំក្រចក ហើយនាំទៅកាន់លើផែនថ្ម ខ្លាស៊ីយើងដល់ឆ្អឹង និងសរសៃ ទៅតាមសេចក្តីប្រាថ្នារបស់វា យ៉ាងណា ក៏ដោយយើងនឹងធ្វើកិលេសឲ្យអស់ទៅ នឹងបានពាល់ត្រូវនូវវិមុត្តិ គឺ ការរួចចាកទុក្ខ ។

## រឿងព្រះថេរៈដែលត្រូវចាក់ដោយលំពែង បានសម្រេចព្រះអរហត្ត

ភិក្ខុមួយអង្គទៀត ព្រះនាម **បីតិមល្លត្ថេរ** កាលដែលនៅជាគ្រហស្ថនោះ លោកបានទង់មកកាន់កោះលង្កា លោករមែងចូលទៅគាល់ព្រះរាជារហូតបីរជ្ជកាលមកហើយ ទទួលបាននូវព្រះរាជានុគ្រោះ ។

ថ្ងៃមួយលោកបានធ្វើដំណើរទៅកាន់ទ្វារសាលា ដែលមានកន្ទែងអង្គុយក្រាលដោយកន្ទេល បានស្តាប់ **នតុម្ហាកវគ្គ** ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ( **នតុម្ហាកំ** ថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់អ្នកទាំងឡាយ អ្នកទាំងឡាយចូរលះបង់នូវរូបនោះចេញ រូបនោះ ដែលអ្នកទាំងឡាយលះបង់បានហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលជាអង្វែង ។

លោកបានគិតថា មិនមែនចំពោះតែរូបប៉ុណ្ណោះទេ វេទនាក៏មិនមែនជារបស់ខ្លួនដែរ លោកធ្វើបាលីនោះឲ្យជាគោលហើយ ចេញទៅកាន់មហា

វិហារ សូមបព្វជ្ជាឧបសម្បទា លោកធ្វើមាតិកាទាំងពីរឲ្យជាទីតាំងយ៉ាងស្ទាត់ជំនាញ " រូបំ នត្ថុម្ហាកំ វេទនា នត្ថុម្ហាកំ " ហើយបាននាំភិក្ខុ ៣០ អង្គទៅកាន់ទីតំបន់ គវបរបាលី ធ្វើសមណធម៌ ។

លុះព្រះថេរៈនិមន្តដោយបាទជើងមិនបាន លោកក៏លុតជង្គង់ដើរចង្ក្រមក្នុងយាមនោះ មានព្រានម្រឹគម្នាក់សម្គាល់លោកថា ជាម្រឹគ ក៏ពួយលំពែងសំដៅទៅរកលោក លំពែងបានទម្លុះកាយលោកធ្លាយចុងទៅម្ខាង ។

ព្រះថេរៈឲ្យគេជួយដកលំពែង យកស្មៅញាត់មុខរបួស រួចហើយឲ្យគេជួយគ្រាហ៍លោកក្រោកអង្គុយស្រួលបួលនៅលើផែនថ្ម ឲ្យគេបើកឱកាសចម្រើនវិបស្សនា បានសម្រេចនូវព្រះអរហត្តព្រមដោយបដិសម្ភិទា រួចហើយបានព្យាករណ៍ដល់ភិក្ខុទាំងឡាយដែលនាំគ្នានិមន្តមកក្នុងទីនោះ ដោយឧទានថា ៖

ព្រះពុទ្ធជាម្ចាស់ ទ្រង់ជាបុគ្គលប្រសើរបំផុត ដែលអ្នកប្រាជ្ញទាំងឡាយនាំគ្នាសរសើរថា ទ្រង់ជាកំពូលលើលោកទាំងពួងព្រះអង្គបានត្រាស់នូវភាសិតថា ម្នាលភិក្ខុទាំងឡាយ រូបនេះមិនមែនជារបស់អ្នកទាំងឡាយឡើយ អ្នកទាំងឡាយគប្បីលះបង់នូវរូបនោះចេញ ។ សង្ខារទាំងឡាយ មិនទៀងហ្ន៎មានការកើតឡើង និងវិនាសទៅវិញជាធម្មតា លុះកើតឡើងហើយ ក៏រលត់ទៅវិញ ការស្ងប់រំងាប់នូវសង្ខារទាំងនោះ គឺ ព្រះនិព្វាន ទើបជាសុខ ។

គ្រានោះ ភិក្ខុទាំងឡាយបាននិយាយនឹងលោកថា បើព្រះសម្មាសម្ពុទ្ធ

ជាម្ចាស់ទ្រង់មិនប្រឈួនទេនោះ ព្រះអង្គទ្រង់នឹងលាតព្រះហស្ត ( ធ្វើសមុទ្រ ) មកស្ទាបសិរសាលោកយ៉ាងពិតប្រាកដ ។

ដោយហេតុត្រឹមតែប៉ុណ្ណោះ មគ្គនេះ រមែងប្រព្រឹត្តទៅដើម្បីរំលត់ទុក្ខរបស់សត្វទាំងឡាយ ដូចជាទុក្ខរបស់ព្រះតិស្សត្ថេរជាដើម ។

## សក្កទេវរាជចុតិហើយ ឧប្បត្តិភ្លាម

ក៏សក្កទេវរាជ លុះទ្រង់ឃើញបុព្វនិមិត្ត ៥ យ៉ាង របស់ព្រះអង្គហើយ ទ្រង់ត្រូវមរណភ័យគ្របសង្កត់ កើតទោមនស្ស ទើបចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សួរបញ្ហា ។ ក្នុងអវសាននៃការវិសជ្ជនាបញ្ហា ព្រះអង្គបានសម្រេចសោតាបត្តិផល ព្រមដោយទេវតា ៨ ម៉ឺនអង្គ ស្តេចទ្រង់ ( ចុតិហើយ ) ស្តេចឧប្បត្តិឡើងជាថ្មី ប្រក្រតីដូចដើមទៀត ។

## ទេវតាធ្លាក់នរក

សូម្បី សុព្រហ្មទេវបុត្រ មានទេពអប្សរមួយពាន់ជាបរិវារ សោយសួគ៌សម្បត្តិ បណ្តាទាំងទេពអប្សរមួយពាន់នោះ ទេពអប្សរ ៥០០ អង្គកំពុងបេះផ្កាអំពីដើម ក៏ចុតិហើយកើតក្នុងនរក ។ សុព្រហ្មទេវបុត្រ រំពឹងគិតថា ដូចម្តេចហ្ន៎ ទេពអប្សរបេះផ្កាទាំងនេះ ទើបមានការយឺតយូរម្ល៉េះ ទ្រង់បានដឹងថា ពួកនាងចុតិកើតក្នុងនរក ហើយទ្រង់ពិចារណាឃើញថា អាយុរបស់យើងតើប៉ុន្មានហើយហ្ន៎ ! ស្រាប់តែទ្រង់ជ្រាប ព្រះជន្មាយុរបស់ព្រះអង្គក៏នឹងត្រូវអស់ទៅដូចគ្នា ក៏ទ្រង់ឃើញថា ព្រះអង្គនឹងទ្រង់កើតក្នុងនរកនោះឯង

ទើបរន្ធត់ព្រះទ័យ ទ្រង់ទោមនស្សយ៉ាងខ្លាំងក្លា ទ្រង់ត្រិះរិះថា ព្រះសាស្តានឹងទ្រង់បន្ទោបង់ទោមនស្សរបស់យើងនេះបាន អ្នកដទៃកម្ចាត់មិនបាន ហើយបានទ្រង់នាំទេពអប្សរ ៥០០ ដ៏សេសទៅគាល់ព្រះមានព្រះភាគជាម្ចាស់ ទូលសួរបញ្ហាថា ៖

ចិត្តនេះតក់ស្លុតជានិច្ច ចិត្តនេះរន្ធត់ជានិច្ច ទាំងក្នុងកិច្ចដែលមិនទាន់កើត ទាំងក្នុងកិច្ចដែលកើតឡើងហើយ បើសេចក្តីមិនរន្ធត់តក់ស្លុតមាន ខ្ញុំព្រះអង្គសូមទូលសួរ សូមព្រះអង្គសម្តែងប្រាប់នូវការមិនរន្ធត់តក់ស្លុតនោះ ដល់ខ្ញុំព្រះអង្គ ។

លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់ប្រាប់ដល់សុព្រហ្មទេវបុត្រថា ៖

ក្រៅអំពីអង្គធម៌ជាគ្រឿងត្រាស់ដឹង តបៈជាគ្រឿងដុតនូវបាប ក្រៅអំពីការសង្រួមឥន្ទ្រិយ៍ ក្រៅអំពីលះបង់នូវសង្ខតធម៌ទាំងពួង បានដល់ ព្រះនិព្វាន តថាគតរកមើលមិនឃើញនូវសួស្តីរបស់សត្វទាំងឡាយឡើយ ។

ក្នុងវេលាចប់ព្រះធម៌ទេសនា សុព្រហ្មទេវបុត្រតាំងនៅក្នុងសោតាបត្តិផលព្រមទាំងទេពអប្សរ ទ្រង់ធ្វើទិព្វសម្បត្តិនោះ ឲ្យមានស្ថេរភាពហើយស្តេចទៅកាន់ទេវលោកដូចដើម ។

មគ្គនេះ បុគ្គលចម្រើនហើយ គប្បីយល់ថា ប្រព្រឹត្តទៅដើម្បីរំលត់ទោមនស្សរបស់សត្វទាំងឡាយ ដូចទោមនស្សរបស់សក្កទេវរាជជាដើម ដូចដែលពណ៌នាមកនេះ ។

អរិយមគ្គមានអង្គ ៨ នោះ លោកហៅថា **ញាយ** ក្នុងពាក្យថា **ញាយស្ស អធិគមាយ** ដើម្បីចាក់ធ្លុះ អធិប្បាយថា ដើម្បីដល់អរិយមគ្គនោះ ។ ព្រោះថា **មគ្គសតិប្បដ្ឋាន** ដែលជាលោកិយៈក្នុងខាងដើមនេះ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីបាន **លោកុត្តរមគ្គ** ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ញាយស្ស អធិគមាយ** ។

បទថា **និព្វានស្ស សច្ឆិកិរិយាយ** ( ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ) សេចក្តីថា ដើម្បីធ្វើឲ្យជាក់ច្បាស់ លោកពោលអធិប្បាយទុកថា ដើម្បីប្រចក្សដោយខ្លួនឯងនូវ **អមតធម៌** ដែលបាននាមថា **ព្រះនិព្វាន** ព្រោះវៀរចាកតណ្ហាជាគ្រឿងរួបរឹត ។ ព្រោះថា **មគ្គនេះ** ដែលបុគ្គលអប់រំហើយ ឲ្យសម្រេចការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានតាមលំដាប់ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **និព្វានស្ស សច្ឆិកិរិយាយ** ។

បណ្តាពាក្យទាំងនោះ កាលព្រះអង្គត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ពាក្យថា ឈានកន្លងនូវសេចក្តីសោកជាដើម ក៏ជាការដែលសម្រេចសេចក្តីហើយក៏ពិតមែន ប៉ុន្តែក៏នៅមិនទាន់ប្រាកដដល់អ្នកដទៃក្រៅអំពីអ្នកឆ្លាតក្នុងសេចក្តីបញ្ចប់នៃសាសនា ។ ហើយព្រះមានព្រះភាគទ្រង់មិនបានធ្វើឲ្យបុគ្គលជាអ្នកឆ្លាតក្នុងសេចក្តីបញ្ចប់នៃសាសនាមុន ហើយទើបទ្រង់សម្តែងធម៌ខាងក្រោយ ។ តែទ្រង់ឲ្យយល់ផលដែលត្រូវការនោះ ៗ ដោយសូត្រនោះ ៗ ប៉ុណ្ណោះ ព្រោះដូច្នោះ ក្នុងសតិប្បដ្ឋានសូត្រនេះ កាលព្រះអង្គទ្រង់នឹងសម្តែងផលដែលត្រូវការនូវ **ឯកាយនមគ្គ** នឹងឲ្យសម្រេចបានប្រាកដ ទើបបានត្រាស់ទុកថា **សោកបរិទេវានំ សមតិក្កមាយ** ដើម្បី

កម្ចាត់បង់នូវសេចក្ដីសោក និងបរិទេវៈទាំងឡាយ ដូច្នេះជាដើម ។

ម្យ៉ាងទៀត ព្រោះសេចក្ដីបរិសុទ្ធិនៃសត្វទាំងឡាយនឹងប្រព្រឹត្តទៅព្រម ក៏ដោយ **ឯកាយនមគ្គ** សេចក្ដីបរិសុទ្ធិនឹងមានបាន ព្រោះឈានកន្លងនូវ **សោកៈ បរិទេវៈ** ការឈានកន្លង **សោកៈ បរិទេវៈ** នឹងមានបាន ព្រោះ **ទុក្ខទោមនស្ស** រលត់ទៅ ការរំលត់ **ទុក្ខទោមនស្ស** នឹងមានបាន ព្រោះបាន សម្រេចញាយធម៌ ការសម្រេច **ញាយធម៌** នឹងមានបាន ព្រោះការធ្វើឲ្យ ជាក់ច្បាស់នូវព្រះនិព្វាន ដូច្នោះ ព្រះអង្គកាលទ្រង់សម្ដែងលំដាប់នេះ ហើយ ទើបត្រាស់ថា **សត្តានំ វិសុទ្ធិយា** ដើម្បីសេចក្ដីបរិសុទ្ធិនៃសត្វទាំងឡាយ ហើយបានត្រាស់ពាក្យមានជាអាទិ៍នេះទុកថា **សោកបរិទេវានំ សមតិក្កមាយ** ដើម្បីរំលត់បង់នូវសេចក្ដីសោក និងបរិទេវៈ ។

ម្យ៉ាងទៀត ពាក្យថា **សត្តានំ វិសុទ្ធិយា** ជាដើមនេះ ជាពាក្យពោល សរសើរ **ឯកាយនមគ្គ** ដូចសេចក្ដីថា ព្រះមានព្រះភាគជាម្ចាស់ បានត្រាស់ សរសើរទេសនា ៦ ពួក មួយពួក ៗ ៦ ប្រការ ដោយបទ ៨ បទថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងធម៌មានលម្អបទដើម លម្អបទកណ្ដាល លម្អបទចុង និងប្រកាសព្រហ្មចារ្យ ( សាសនា ) ដ៏បរិសុទ្ធ បរិបូរសព្វ គ្រប់ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ គឺ ព្រហ្មចារ្យ ៦ ពួក មួយ ៗ ៦ ប្រការ ដល់អ្នកទាំងឡាយ ហើយបានត្រាស់សរសើរ **អរិយវង្សទេសនា** ទុក ដោយបទ ៩ បទ ថា ម្នាលភិក្ខុទាំងឡាយ អរិយវង្ស ៤ យ៉ាងនេះ ជា របស់ដែលអ្នកប្រាជ្ញស្គាល់ថា ដ៏ប្រសើរ ស្គាល់មកជាយូរ ដឹងថាជាវង្ស (នៃព្រះអរិយៈជាម្ចាស់) ជារបស់ចាស់ មិនឃ្លៀងឃ្លាត មិនធ្លាប់ឃ្លៀងឃ្លាត

មិនត្រូវសង្ស័យ មិនត្រូវសមណព្រាហ្មណ៍ដែលជាបណ្ឌិតជំទាស់ យ៉ាងណា ព្រះអង្គ ក៏បានត្រាស់សរសើរ **ឯកាយនមគ្គ** នេះទុក ដោយបទ ៧ បទ មានបទថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយជាដើម ដូច្នោះ ។

ប្រសិនបើនឹងសួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ដើម្បីនឹងឲ្យកើតឧស្សាហៈដល់ភិក្ខុទាំងនោះ ។

សេចក្តីថា ភិក្ខុទាំងនោះ លុះបានស្តាប់ការត្រាស់សរសើរហើយ នឹងកើតឧស្សាហៈឡើងថា **មគ្គនេះ** នឹងនាំឧបទ្រវៈទាំង ៤ ចេញទៅ គឺ

សេចក្តីសោក ដែលជាវត្ថុដុតកេលចិត្ត ១ សេចក្តីសោកខ្សឹកខ្សួលរំជួលចិត្ត ដែលជាការពណ៌នាផ្លូវវាចា ១ សេចក្តីទុក្ខដែលជាការមិនសប្បាយផ្លូវកាយ ១ ទោមនស្សដែលជាការមិនស្រស់ស្រាយផ្លូវចិត្ត ១ ។ ( និង ) នាំគុណវិសេស ៣ យ៉ាងមកឲ្យ គឺ វិសុទ្ធិ សេចក្តីបរិសុទ្ធិ ១ ញាយធម៌ដែលគួរដឹង ១ និព្វាន ការរំលត់ ( កិលេស ) ១ ។

ដូច្នេះហើយ នឹងសម្គាល់ព្រះធម៌ទេសនានេះថា ត្រូវរៀន ត្រូវទន្ទេញ ត្រូវទ្រទ្រង់ចាំ ត្រូវបង្ហាត់បង្រៀន ហើយសម្គាល់ **មគ្គនេះថា** ត្រូវចម្រើន ( ដំណើរ ) ព្រះមានព្រះភាគបានត្រាស់សរសើរ ( **ឯកាយនមគ្គ** ) ដើម្បីឲ្យភិក្ខុទាំងនោះកើតឧស្សាហៈ ដោយប្រការដូចដែលពណ៌នាមកនេះ ដូចអ្នកជំនួញសំពត់ ពោលសរសើរគុណភាពសំពត់កម្ពលជាដើម ដូច្នោះ ។

សេចក្តីពិស្តារថា កាលអ្នកជំនួញសំពត់រោមសត្វពណ៌លឿង ( បណ្ឌុកម្ពល ) តម្លៃមួយសែន ឃោសនាថា សូមអញ្ជើញទិញសំពត់រោមសត្វទាន

មនុស្សទាំងឡាយនៅមិនទាន់ជ្រាបថា ជាសំពត់កម្ពលប្រភេទឯណោះ ។ ព្រោះថា សូម្បីសំពត់ **កេសកម្ពល** និងសំពត់ **ផាលកម្ពល** ជាដើម ដែលមានក្លិនស្អុយ សាច់គ្រោតគ្រាត (សម្រាប់រុំសាកសព) គេក៏ហៅថា សំពត់កម្ពលដូចគ្នា ។ ប៉ុន្តែកាលណាគេឃោសនាថា សំពត់ **កម្ពលក្រហម** មកអំពី **គន្ធារវដ្ឋ** សាច់ល្អិត ត្រជាក់ ស្មៀកដណ្តប់ទន់ល្អ ។ កាលនោះ មនុស្សដែលមានទ្រព្យសមល្មម ក៏នឹងទទួល (ទិញ) ចំណែកមនុស្សដែលមានទ្រព្យមិនល្មម ក៏ចង់មើលដែរ ។ សូម្បីកាលព្រះអង្គត្រាស់ថា **មគ្គនេះ** ជាមគ្គឯកក៏នៅមិនទាន់ជាក់ច្បាស់ថា ជាមគ្គនុ៎ះដូច្នោះ ដូចគ្នា ។ ព្រោះថា ផ្លូវដែលមិននាំចេញចាកទុក្ខប្រការផ្សេង ៗ គេក៏ហៅថា ផ្លូវដូចគ្នា ។ តែកាលត្រាស់ពាក្យមានជាអាទិ៍ថា **សត្តានំ វិសុទ្ធិយា** ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ភិក្ខុទាំងឡាយក៏នឹងកើតឧស្សាហៈថា បានជ្រាបថា មគ្គនេះនាំឧបទ្រវៈទាំង ៤ ចេញទៅ នាំគុណវិសេស ៣ ប្រការមកឲ្យ និងសម្គាល់ព្រះធម៌-ទេសនានេះថា គួររៀន គួរទន្ទេញ គួរទ្រទ្រង់ គួរបង្ហាត់បង្រៀន និងសម្គាល់មគ្គ នេះថា គួរចម្រើន ( ប្រព្រឹត្តតាម ) ដូច្នោះ ព្រះមានព្រះ-ភាគជាម្ចាស់ កាលនឹងត្រាស់សរសើរ ( **ឯកាយនមគ្គ** ) ទើបបានត្រាស់ទុកថា **សត្តានំ វិសុទ្ធិយា** ។

ហើយក្នុងរឿងនេះ គួរនាំសេចក្តីប្រៀបធៀបនឹងឈ្មួញមាសជម្ពូនុទពណ៌ក្រហម ឈ្មួញកែវមណីទឹកថ្លាស្អាត ឈ្មួញកែវមុក្តាហារថ្លាស្អាត និងឈ្មួញកែវប្រវាឡដែលច្នៃហើយ ជាដើមមក ដូចសេចក្តីប្រៀបធៀបនឹងឈ្មួញបណ្ឌុកម្ពលតម្លៃមួយសែន ដូច្នោះ ។

## អធិប្បាយសព្ទថា យទិទំ

សព្ទថា **យទិទំ** ជានិបាត មានន័យស្មើនឹង **យេ ឥមេ** ។ សព្ទថា **ចត្តារោ** ជាការកំណត់រាប់ ( ចំនួនរាប់ ) ។ ដោយសព្ទនោះ ព្រះអង្គទ្រង់សម្តែងដល់ការកំណត់ ( ចំនួន ) **សតិប្បដ្ឋាន** ថា មានមិនតិច មិនច្រើនជាងចំនួននោះ ។

## អធិប្បាយ សតិប្បដ្ឋាន

បទថា **សតិប្បដ្ឋាន** បានដល់ សតិប្បដ្ឋាន ៣ យ៉ាង គឺ អារម្មណ៍របស់សតិ ១ ការដែលព្រះសាស្តា ទ្រង់មិនសោមនស្ស និងទោមនស្សក្នុងកាលសាវកទាំងឡាយបដិបត្តិក្នុងសតិប្បដ្ឋាន ៣ យ៉ាង ១ , សតិ ១ ។

អធិប្បាយថា អារម្មណ៍របស់សតិលោកហៅថា **សតិប្បដ្ឋាន** ( ដូច ) ក្នុងព្រះពុទ្ធវចនៈទាំងឡាយមានជាអាទិ៍ថា

> ម្នាលភិក្ខុទាំងឡាយ តថាគតនឹង សម្តែងការកើត និងការរលត់ទៅនៃសតិប្បដ្ឋាន ៤ យ៉ាង អ្នកទាំងឡាយចូរស្តាប់ទេសនានោះ ។ល។ ម្នាលភិក្ខុទាំងឡាយ ក៏ការកើតឡើងនៃកាយ តើដូចម្តេច ? ការកើតនៃអាហារ គឺ ការកើតឡើងនៃកាយ ។

ម្យ៉ាងទៀត អារម្មណ៍របស់សតិ លោកហៅថា **សតិប្បដ្ឋាន** ( ដូច ) ក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា **កាយ** ជាទីចូលទៅតាំង ( នៃសតិ ) មិនមែនតួសតិ សតិជាទីតាំងផង ជាតួសតិផង ( ឈ្មោះថា សតិប្បដ្ឋាន ) ដូច្នេះ

ខ្ញុំ ។

សតិប្បដ្ឋាននោះ មានអត្ថថា ឈ្មោះថា **បដ្ឋាន** ព្រោះជាទីតាំង ។ អ្វីតាំង ? សតិតាំង ។ ទីតាំងរបស់សតិ ឈ្មោះថា **សតិប្បដ្ឋាន** ។ម្យ៉ាងទៀត ស្ថានទីជាទីចត ( ប្រធាន ) ដូច្នេះ ទើបឈ្មោះថា **បដ្ឋាន** ។ ស្ថានទីជាទីចតនៃសតិនោះ ឈ្មោះថា **សតិប្បដ្ឋាន** ដូចគ្នានឹងស្ថានទីឈរនៃដំរី និងស្ថានទីឈរនៃសេះជាដើម ដូច្នោះ ។

**សតិប្បដ្ឋាន ៣ យ៉ាង** គឺ ការដែលព្រះសាស្តាទ្រង់មិនសោមនស្ស និងទោមនស្ស ព្រោះសាវកទាំងឡាយអ្នកបដិបត្តិក្នុងសតិប្បដ្ឋាន ៣ យ៉ាង លោកហៅថា **សតិប្បដ្ឋាន** ( ដូច) ក្នុងព្រះពុទ្ធវចនៈនេះថា ព្រះសាស្តាទ្រង់ជាព្រះអរិយៈជាម្ចាស់ កាលទ្រង់សេពវត្ថុដែលព្រះអរិយៈជាម្ចាស់សេព គួរតាមបង្រៀនពួកគណៈ ដូច្នេះ ។ សេចក្តីនោះមានន័យថា ឈ្មោះថា **បដ្ឋាន** ព្រោះគួរឲ្យផ្តើមតាំងទុក អធិប្បាយថា ព្រោះគួរឲ្យប្រព្រឹត្តទៅ ( ប្រព្រឹត្ត ) ។

ព្រោះគួរឲ្យអ្វីតាំង ?

គួរឲ្យសតិតាំង ការតាំងសតិ ឈ្មោះថា **សតិប្បដ្ឋាន** ដូច្នេះ ។

ក៏សតិនោះឯង លោកហៅថា **សតិប្បដ្ឋាន** ក្នុងពាក្យទាំងឡាយ មានជាអាទិ៍ថា សតិប្បដ្ឋានដែលអប់រំហើយ ធ្វើឲ្យច្រើនហើយ នាំឲ្យពោជ្ឈង្គៈ ៧ ប្រការ បរិបូណ៌បាន ។ ក្នុងសេចក្តីនោះ មានន័យថា ឈ្មោះថា **បដ្ឋាន** ព្រោះតាំងទុក អធិប្បាយថា ចូលទៅតាំងទុក គឺ ឈានចុះ ស្ទុះទៅ ប្រព្រឹត្តទៅ ។ **បដ្ឋាន** គឺ សតិនោះឯង ទើបឈ្មោះថា **សតិប្បដ្ឋាន** ។

ម្យ៉ាងទៀត ឈ្មោះថា **សតិ** ព្រោះអត្ថថា រឭក ឈ្មោះថា **បដ្ឋាន**

ព្រោះអត្ថថា ចូលទៅតាំងទុក សតិនោះផង ការតាំងទុកផង ដូច្នោះ ទើបឈ្មោះថា **សតិប្បដ្ឋាន** ដោយប្រការដូច្នេះខ្លះ ។ ក្នុង **សតិប្បដ្ឋានសូត្រ** នេះ លោកសំដៅយក **សតិប្បដ្ឋាន** ប្រការនេះឯង ។

សួរថា បើយ៉ាងនោះ ហេតុដូចម្ដេច ពាក្យថា **សតិប្បដ្ឋាន** ទើបជាពហុវចនៈ ?

ព្រោះសតិមានច្រើន ។

ពិតណាស់ ពោលដោយប្រភេទនៃអារម្មណ៍ សតិនោះមានច្រើន ។

កាលបើដូច្នោះ ហេតុអ្វីពាក្យថា **មគ្គ** ( ដែលមានច្រើនដូចគ្នា ) ទើបជាឯកវចនៈ ។

ព្រោះមានតែមួយ៉ាង ដោយអត្ថថា នឹងត្រូវធ្វើដំណើរទៅ ។

ពិតណាស់ សតិទាំងនោះ សូម្បីនឹងមាន ៤ យ៉ាង ប៉ុន្តែដល់ភាពតែមួយ៉ាង ដោយអត្ថថា ត្រូវធ្វើដំណើរទៅ ។ សមពិតដូចដែលលោកពោលទុកថា **ផ្លូវ** ដែលឈ្មោះថា **មគ្គ** ព្រោះអត្ថដូចម្ដេច ?

ព្រោះអត្ថថា ជាគ្រឿងទៅកាន់និព្វាន និងព្រោះអត្ថថា អ្នកមានសេចក្ដីត្រូវការនិព្វាន និងត្រូវធ្វើដំណើរទៅ ។

ក៏សតិសូម្បីទាំង ៤ យ៉ាងនោះ កាលញ៉ាំងកិច្ចឲ្យសម្រេចក្នុងអារម្មណ៍ទាំងឡាយ មានកាយជាដើម ( រហូត ) ដល់និព្វានក្នុងកាលខាងក្រោយ និងអ្នកប្រាថ្នានិព្វាន ក៏ធ្វើដំណើរទៅតាំងអំពីនោះ ព្រោះហេតុដូចដែលពោលមកហើយនោះ លោកទើបពោលទុកថា សតិសូម្បីទាំង ៤ យ៉ាង ជាផ្លូវមួយតែមួយ ។

កាលបើដូច្នោះ ទើបមានទេសនាដែលមានការបន្តគ្នាមកតាមលំដាប់ដោយការបន្តពាក្យគ្នាមក ដូចក្នុងព្រះពុទ្ធវចនៈទាំងឡាយមានជាអាទិ៍ថា ៖

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងផ្លូវសម្រាប់ ញាំញីមារ ព្រមទាំងសេនាមារ អ្នកទាំងឡាយចូរស្តាប់ ។ល។ ម្នាលភិក្ខុទាំងឡាយ ក៏ផ្លូវសម្រាប់ញាំញីមារ និងសេនាមារ គឺអ្វី ? គឺ ពោជ្ឈង្គៈ ៧ ( អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ) ទាំងផ្លូវសម្រាប់ញាំញីមារ និងពោជ្ឈង្គៈ ៧ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ យ៉ាងណា ឯកាយនមគ្គ និង សតិប្បដ្ឋាន ៤ ក៏ដូច្នោះ ។

មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។ ព្រោះដូច្នោះ គប្បីយល់ថា ( មគ្គ ) ជាឯកវចនៈ ព្រោះអត្ថថា នឹងត្រូវដំណើរទៅ (ហើយ) គប្បីយល់ ( សតិប្បដ្ឋាន ) ថា ជាពហុវចនៈ ព្រោះសតិមានច្រើនដោយប្រភេទ នៃអារម្មណ៍ ។

## ហេតុដែលត្រាស់សតិប្បដ្ឋានទុក ៤ យ៉ាង

ប៉ុន្តែហេតុដូចម្តេច បានជាព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សតិប្បដ្ឋាន ទុក ៤ យ៉ាងប៉ុណ្ណោះ មិនលើសមិនខ្វះ ( ជាងនោះ ) ?

ព្រោះព្រះអង្គទ្រង់អនុគ្រោះដល់វេនេយ្យសត្វ ។

អធិប្បាយថា បណ្តាវេនេយ្យសត្វទាំងឡាយ ពួកតណ្ហាចរិត ពួកទិដ្ឋិចរិត ពួកសមថយានិក និងពួកវិបស្សនាយានិក ដែលប្រព្រឹត្តទៅដោយ

ចំណែកទាំង ២ គឺ បញ្ញាទន់ខ្សោយ និងបញ្ញាចាស់ក្លា អ្នកមានតណ្ហាចរិត បញ្ញាទន់ខ្សោយ មាន **កាយានុបស្សនាសតិប្បដ្ឋាន** ដែលមានអារម្មណ៍គ្រោតគ្រាត ជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ ប៉ុន្តែអ្នកមានតណ្ហាចរិត មានបញ្ញាចាស់ក្លា មាន **វេទនានុបស្សនាសតិប្បដ្ឋាន** ដ៏ល្អិតជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ សូម្បីអ្នកមានទិដ្ឋិចរិត មានបញ្ញាទន់ខ្សោយ មាន **ចិត្តានុបស្សនាសតិប្បដ្ឋាន** ដែលមានអារម្មណ៍ចែកចេញមិនច្រើនពេក ជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ តែអ្នកមាន **ទិដ្ឋិចរិត** បញ្ញាចាស់ក្លា មាន **ធម្មានុបស្សនាសតិប្បដ្ឋាន** ដែលមានអារម្មណ៍ចែកចេញជាច្រើនប្រភេទ ជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ ហើយ **សតិប្បដ្ឋាន** ប្រការដំបូង ដែលមាននិមិត្ត នឹងដែលគប្បីប្រសព្វបានមិនលំបាក ជាផ្លូវនៃសេចក្តីបរិសុទ្ធិនៃ **សមថយានិកបុគ្គល** ប្រភេទបញ្ញាទន់ខ្សោយ ។ ប្រការទី ២ ជាផ្លូវបរិសុទ្ធិនៃ **សមថយានិកបុគ្គល** ប្រភេទបញ្ញាចាស់ក្លា ។ ព្រោះលោកតាំងនៅបានមិនមាំទាំក្នុងអារម្មណ៍ដែលគ្រោតគ្រាត ។ ប្រការទី ៣ ដែលមានអារម្មណ៍ចែកចេញទៅមិនច្រើនប្រភេទពេក ជាផ្លូវនៃសេចក្តីបរិសុទ្ធិរបស់ **វិបស្សនាយានិកបុគ្គល** ប្រភេទបញ្ញាទន់ខ្សោយ ។ ប្រការទី ៤ ដែលមានអារម្មណ៍ចែកចេញច្រើនប្រភេទ ជាផ្លូវនៃសេចក្តីបរិសុទ្ធិរបស់ **វិបស្សនាយានិកបុគ្គល** ប្រភេទបញ្ញាចាស់ក្លា ។ **សតិប្បដ្ឋាន** ទើបត្រាស់ទុក ៤ យ៉ាងប៉ុណ្ណោះ មិនលើសមិនខ្វះ ដោយប្រការដូចដែលពោលមកនេះ ដូច្នេះ ។

ម្យ៉ាងទៀត ( ដែលទ្រង់សម្តែងទុក ៤ យ៉ាងប៉ុណ្ណោះ ) ដើម្បីលះ

**វិបល្លាស** គឺ សភាពស្អាត សេចក្តីសុខ សភាពទៀង និងសភាពជាខ្លួនជាដើម សេចក្តីពិត **កាយ** ជារបស់មិនស្អាត ប៉ុន្តែសត្វទាំងឡាយតាំងនៅយ៉ាងវិបរិត សម្គាល់ខុសក្នុងកាយនោះថា ស្អាត ។ **សតិប្បដ្ឋាន** ប្រការទី ១ ត្រាស់ទុកសម្រាប់សត្វទាំងនោះ ដើម្បីឲ្យលះបង់សុភវិបល្លាសនោះ ដោយការឃើញថា មិនស្អាត ក្នុងកាយនោះ ។ ហើយក្នុងវេទនាជាដើម សូម្បីសត្វទាំងឡាយប្រកាន់មាំថា ជា **សុខ ទៀង** ជា **អត្តា** ( ក៏មានន័យនេះ គឺ ) **វេទនាជាទុក្ខ ចិត្តមិនទៀង ធម៌ទាំងឡាយជាអនត្តា** ប៉ុន្តែសត្វទាំងឡាយ តាំងនៅយ៉ាងវិបរិត សម្គាល់ខុសក្នុងវេទនា ចិត្ត និងធម៌ទាំងនោះថា **ជា សុខ ទៀង** និង **ជាអត្តា** ។ ត្រាស់ ៣ យ៉ាង ដ៏សេសទុកសម្រាប់សត្វ ទាំងនោះ ដើម្បីឲ្យលះវិបល្លាសដ៏សេសទាំងនោះ ដោយការឃើញវេទនាជាដើមទាំងនោះថា ជាទុក្ខ ជាដើម ដូច្នេះ ។

កាលបើដូច្នោះ **សតិប្បដ្ឋាន** ក៏គួរយល់ថា ព្រះអង្គត្រាស់ទុក ៤ យ៉ាងប៉ុណ្ណោះ មិនលើសមិនខ្វះ ក៏ដើម្បីឲ្យលះ **សុភវិបល្លាស សុខ-វិបល្លាស និច្ចវិបល្លាស** និង **អត្តវិបល្លាស** ។ ហើយមិនត្រឹមតែត្រាស់ទុកដើម្បីឲ្យលះវិបល្លាសតែម្យ៉ាងប៉ុណ្ណោះទេ ប៉ុន្តែគួរយល់ថា ត្រាស់ទុក ៤ យ៉ាងប៉ុណ្ណោះ ក៏ដើម្បីឲ្យលះឱឃៈ ៤ យោគៈ ៤ អាសវៈ ៤ គន្ថៈ ៤ និងឧបាទាន ទាំង ៤ និងអគតិ ៤ ផង ដើម្បីឲ្យកំណត់ដឹងអាហារទាំង ៤ ផង ។ នេះជាន័យតាមបករណ៍ ដូច្នេះ ។

## មតិរបស់អដ្ឋកថា

ចំណែកក្នុងអដ្ឋកថា លោកពោលទុកប៉ុណ្ណោះឯងថា បើពោលដោយការរឭក និងដោយការប្រមូលចុះកាន់ទីតែមួយជាមួយគ្នាហើយ សតិប្បដ្ឋាន ក៏មានតែមួយប៉ុណ្ណោះ ប៉ុន្តែពោលតាមអារម្មណ៍មាន ៤ យ៉ាង ។ ឧបមាថា ក្នុងព្រះនគរដែលមានទ្វារ ៤ អ្នកដែលមកអំពីទិសខាងកើត កាន់យកវត្ថុ ដែលមាននៅក្នុងទិសខាងកើតហើយ ចូលកាន់ព្រះនគរនោះឯង តាមខ្លោងទ្វារទិសខាងកើត , អ្នកដែលមកអំពីទិសខាងត្បូង , ទិសខាងលិច , ទិសខាងជើង កាន់យករបស់ដែលមាននៅក្នុងទិសឧត្តរ ហើយចូលទៅកាន់ព្រះនគរនោះឯង តាមទ្វារទិសឧត្តរ យ៉ាងណា សេចក្តីឧបមេយ្យដែលឲ្យឧបមាដល់ព្រមនេះ ក៏គួរជ្រាបដូច្នេះ ។

## សេចក្តីប្រៀបធៀប

ពិតណាស់ **ព្រះនិព្វាន** ប្រៀបដូចព្រះនគរ ។

**លោកុត្តរមគ្គប្រកបដោយអង្គ ៨** ប្រៀបដូចទ្វារព្រះនគរ ។ **កាយជាដើម** ប្រៀបដូចទិសខាងកើតជាដើម ។

ព្រះយោគាវចរទាំងឡាយ កាលមកដោយអំណាច **កាយានុបស្សនា** ចម្រើន **កាយានុបស្សនាសតិប្បដ្ឋាន** ដោយវិធី ១៤ យ៉ាង ហើយនឹងទៅរួមចុះកាន់ទីតែមួយជាមួយគ្នា គឺ **ព្រះនិព្វាន** នោះឯង ។ ដោយអរិយមគ្គ ដែលកើតឡើងដោយអានុភាពនៃកាយានុបស្សនា ដូចមនុស្ស

ទាំងឡាយដែល មកអំពីទិសខាងកើត គឺ នាំយករបស់ដែលមាននៅក្នុង ទិសខាងកើតហើយ ក៏ចូលកាន់ព្រះនគរបានដូចគ្នា តាមទ្វារព្រះនគរទិស ខាងកើតបាន ដូច្នោះ ។

ព្រះយោគាវចរ កាលដំណើរតាមផ្លូវ **វេទនានុបស្សនា** ចម្រើន **វេទនានុបស្សនាសតិប្បដ្ឋាន** ដោយវិធី ៩ យ៉ាង ក៏ទៅរួមចុះកាន់ទីតែមួយ ជាមួយគ្នា គឺ **ព្រះនិព្វាន** នោះឯង ដោយអរិយមគ្គ ដែលកើតឡើងដោយ អានុភាពនៃវេទនានុបស្សនាសតិប្បដ្ឋាន ដូចអ្នកមកអំពីទិសខាងត្បូង កាន់ យករបស់ដែលមាននៅក្នុងទិសខាងត្បូង ក៏ចូលដល់ព្រះនគរដូចគ្នា តាម ទ្វារព្រះនគរទិសខាងត្បូង ដូច្នេះ ។

ព្រះយោគាវចរទាំងឡាយ កាលធ្វើដំណើរមកតាមផ្លូវ **ចិត្តានុប-ស្សនា** ចម្រើន **ចិត្តានុបស្សនាសតិប្បដ្ឋាន** ដោយវិធី ១៦ យ៉ាង នឹង ទៅរួមត្រង់កន្លែងមួយជាមួយគ្នា គឺ **ព្រះនិព្វាន** នោះឯង ដោយអរិយមគ្គ ដែលកើតឡើងដោយអានុភាព នៃចិត្តានុបស្សនាសតិប្បដ្ឋាន ដូចអ្នកមក អំពីទិសខាងលិច កាន់យករបស់ដែលមាននៅក្នុងទិសខាងលិច ក៏ចូល ដល់ព្រះនគរដូចគ្នា តាមខ្លោងទ្វារព្រះនគរទិសខាងលិច ដូច្នេះ ។

ព្រះយោគាវចរទាំងឡាយ កាលធ្វើដំណើរមកតាមទ្វារ **ធម្មានុ-បស្សនា** ចម្រើន **ធម្មានុបស្សនាសតិប្បដ្ឋាន** ដោយវិធី ៥ យ៉ាងហើយ នឹងទៅរួមត្រង់កន្លែងជាមួយគ្នា គឺ **ព្រះនិព្វាន** នោះឯង ដោយអរិយមគ្គ ដែលកើតឡើង ដោយអានុភាពនៃធម្មានុបស្សនាសតិប្បដ្ឋាន ដូចអ្នកដែល

មកអំពីទិសខាងជើង កាន់យករបស់ដែលមាននៅក្នុងទិសខាងជើង ក៏ចូលទៅដល់ព្រះនគរដូចគ្នា តាមទ្វារព្រះនគរទិសខាងជើងបាន ដូច្នេះ ។

**សតិប្បដ្ឋាន** គប្បីជ្រាបថា ត្រាស់ទុកតែម្យ៉ាងប៉ុណ្ណោះ ដោយការរឭក និងដោយការរួមចុះកាន់ទីតែមួយជាមួយគ្នា គប្បីជ្រាបថា ត្រាស់ទុក ៤ យ៉ាងនោះឯង តាមអារម្មណ៍ ដោយប្រការដូច្នេះ ។

## អត្ថនៃពាក្យថា ភិក្ខុ

បទថា **កតមេ ចត្តារោ** ( ៤ យ៉ាង គឺអ្វីខ្លះ ) ជា **កថេតុកម្យតាបុច្ឆា** ( ពាក្យសួរ ដើម្បីនឹងឆ្លើយខ្លួនឯង ) ។

បទថា **ឥធ** បានដល់ **ឥមស្មឹ** ផ្លាស់ជា **សាសនេ** ប្រែថា ក្នុងសាសនានេះ ពាក្យថា **ភិក្ខវេ** នេះ ជាពាក្យហៅបុគ្គលអ្នកទទួលធម្មៈ ។

ពាក្យថា **ភិក្ខុ** ជាពាក្យសម្ដែងដល់បុគ្គលអ្នកនឹងញុំាងវត្តបដិបត្តិឲ្យដល់ព្រម ម្យ៉ាងទៀត ទេវតា និងមនុស្សស្រួម្បីពួកដទៃ ក៏ញុំាងវត្តបដិបត្តិឲ្យដល់ព្រមបានដូចគ្នា ។ ប៉ុន្តែព្រះអង្គត្រាស់ហៅថា **ភិក្ខុ** ព្រោះជាអ្នកប្រសើរ និងព្រោះទ្រង់សម្ដែងដល់ **ភិក្ខុភាវ** ដោយវត្តបដិបត្តិ ។

ព្រោះថា កាលភិក្ខុទាំងឡាយ បដិបត្តិតាមអនុសាសនីរបស់ព្រះមានព្រះភាគជាម្ចាស់ហើយ ភិក្ខុទាំងឡាយ ក៏នឹងជាអ្នកប្រសើរជាទីបំផុត ព្រោះ ( ដូចជា ) ភាជនៈ ( សម្រាប់ទទួល ) អនុសាសនីគ្រប់ប្រការ ។ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា **ភិក្ខុ** ព្រោះជាអ្នកប្រសើរជាទីបំផុត ។

ក៏ទ្រង់បញ្ជាក់ដល់ភិក្ខុទាំងនោះហើយ ទេវតា និងមនុស្សដ៏សេស ក៏ជាការដែលទ្រង់បញ្ជាក់ដល់ផងដែរ ដូចគ្នា ដូចបរិស័ទដ៏សេសត្រូវបញ្ជាក់ដល់ ដោយរាជស័ព្ទក្នុងកិច្ចទាំងឡាយ មានការដែលស្តេចព្រះរាជដំណើរជាដើម ។

ហើយអ្នកណាបដិបត្តិ វត្តបដិបត្តិនេះ អ្នកនោះក៏ឈ្មោះថា ភិក្ខុ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា ភិក្ខុ ព្រោះទ្រង់សម្តែងដល់ ភិក្ខុភាវ ដោយវត្តបដិបត្តិខ្លះ ។ អ្នកបដិបត្តិនឹងជាទេវតា ឬមនុស្សក៏ដោយ ចូលដល់ ការរាប់ថា ភិក្ខុ ទាំងអស់ ។ សមដូចដែលត្រាស់ទុកថា ៖

សូម្បីអ្នកដែលតាក់តែងហើយ ប្រសិនបើប្រព្រឹត្តធម៌ស្មើ
ស្ងប់ហើយ ទូន្មានហើយ មានគតិដ៏ទៀងទាត់ ប្រព្រឹត្ត
ព្រហ្មចារ្យ គេដាក់ចុះនូវអាជ្ញាចំពោះសត្វទាំងពួងអស់ហើយ
រមែងឈ្មោះថា ជាព្រាហ្មណ៍ ជាសមណៈ ជាភិក្ខុ ។

## អធិប្បាយពាក្យថា កាយ

បទថា កាយេ បានដល់ ក្នុងរូបកាយ ។ ពិតណាស់ រូបកាយព្រះអង្គទ្រង់សម្តែងថា កាយ ក្នុងព្រះសូត្រនេះ ដូចកាយដំរី និងកាយសេះ ជាដើម ។ ព្រោះអត្ថថា ជាទីប្រជុំនៃអវយវៈតូចធំ និងជាទីប្រជុំនៃរូបធម៌ទាំងឡាយ មានសក់ជាដើម ។

ក៏ (រូបកាយ) ឈ្មោះថា កាយ ព្រោះអត្ថថា ជាទីប្រជុំ (នៃអវយវៈ

តូចធំទាំងឡាយ ) យ៉ាងណា ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីមកនៃរបស់ដែលគួរខ្ពើមទាំងឡាយ គឺ របស់ដែលគួរឲ្យខ្ពើមរអើមយ៉ាងក្រៃលែងដូច្នេះ ។

ព្រោះថា រូបកាយនោះ ជាទីមកដល់នៃរបស់ដែលគួរខ្ពើមទាំងឡាយ គឺ របស់ដែលគួរខ្ពើមយ៉ាងក្រៃលែង ព្រោះដូច្នោះ ទើបឈ្មោះថា **កាយ** ។

បទថា **អាយោ** បានដល់ ដែនកើត ( របស់គួរខ្ពើម ) ក្នុងបទថា **កាយោ** នោះ មានវចនត្ថៈដូចតទៅនេះ ៖

ឈ្មោះថា **អាយ** ព្រោះជាដែនកើត ។

អ្វីកើត ?

អវយវៈទាំងឡាយ មានសក់ជាដើម ដែលគួរខ្ពើមកើត ឈ្មោះថា **កាយ** ព្រោះជាដែនកើតនៃរបស់ដែលគួរខ្ពើមទាំងឡាយ ដោយប្រការយ៉ាងនេះ ។

បទថា **កាយានុបស្សី** បានដល់ អ្នកពិចារណាឃើញកាយរឿយ ៗ ជាប្រក្រតី ឬអ្នកពិចារណាឃើញរឿយ ៗ នូវកាយ ។

គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ សូម្បីត្រាស់ហើយថា **កាយេ** តែក៏ទ្រង់ធ្វើ ( ត្រាស់ ) **កាយ** ស័ព្ទ ទុកជាលើកទី ២ ទៀតថា **កាយានុបស្សី** ដើម្បីនឹងទ្រង់សម្តែងដល់ការបំបែកដុំ ( **ឃនសញ្ញា** ) ចេញទៅ ដោយការកំណត់ដោយ **ចតុធាតុវវដ្ឋានកម្មដ្ឋាន** ដោយមិនឲ្យប្រឡូកប្រឡល់គ្នា ព្រះយោគាវចរ មិនមែនជាអ្នកពិចារណាឃើញវេទនា ក្នុងកាយ ឬពិចារណា

ឃើញចិត្ត និងធម៌ ក្នុងកាយ ។ ដែលពិត ជាអ្នកពិចារណាឃើញកាយ ( ក្នុងកាយ ) នោះឯង ។ ព្រោះដូច្នេះ ដោយបទថា **កាយានុបស្សី** នោះ ទើបជាការដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងដល់ការកំណត់ ដោយមិនឲ្យលាយឡំគ្នា ដោយទ្រង់សម្ដែងចំពោះអាការ គឺ ការពិចារណាឃើញកាយក្នុងវត្ថុ ពោលគឺ កាយនោះឯង ។

មួយវិញទៀត មិនមែនជាអ្នកពិចារណាឃើញធម៌យ៉ាងដទៃ សូម្បីតែមួយ៉ាង ក្រៅអំពីអវយវៈតូច-ធំក្នុងកាយ ទាំងមិនមែនជាអ្នកពិចារណាឃើញស្ត្រី ឬបុរស ក្រៅអំពីសក់ រោមជាដើម ក្នុងកាយ ។

## ពិចារណាកាយ

ក្នុងពាក្យថា **កាយេ កាយានុបស្សី** នេះ មិនមែនពិចារណាឃើញធម៌យ៉ាងដទៃ សូម្បីតែមួយ៉ាងក្រៅអំពី ( **មហា** ) **ភូតរូប** និង **ឧបាទាយរូប** សូម្បីក្នុងកាយ ពោលគឺ ប្រជុំនៃ ( **មហា** ) **ភូតរូប** និង **ឧបាទាយរូប** មានសក់ រោមជាដើម ។ ដោយពិត ក៏ជាអ្នកពិចារណាឃើញការប្រជុំនៃចំណែកផ្សេង ៗ ដូចអ្នកសម្លឹងមើលឃើញគ្រឿងប្រកបនៃរថ ដូច្នោះ ជាអ្នកពិចារណាឃើញការប្រជុំនៃសក់ រោមជាដើម ដូចអ្នកឃើញចំណែកផ្សេង ៗ នៃទីក្រុង ដូច្នោះ ហើយជាអ្នកពិចារណា ឃើញការប្រជុំនៃ ( **មហា** ) **ភូតរូប** និង **ឧបាទាយរូប** នោះឯង ដូចអ្នក បកស្រទបចេក ចេញអំពីដើមចេកដូច្នោះ និងដូចអ្នកលាដៃក្ដាប់ទទេ ចេញយ៉ាងនោះឯង

ព្រោះដូច្នោះ ដោយទ្រង់សម្ដែងវត្ថុ ពោលគឺ **កាយ** ដោយអំណាចនៃការប្រជុំដោយប្រការផ្សេង ៗ នោះឯង ជាការដែលព្រះអង្គទ្រង់សម្ដែងកាយបំបែកឃនសញ្ញាចេញហើយ ។ ព្រោះថា ក្នុងពាក្យថា **កាយេ កាយានុបស្សី** នេះ នឹងមិនឃើញជាស្ត្រី ជាបុរស ឬជាធម៌អ្វី ដទៃក្រៅអំពីការប្រជុំនៃធម៌តាមដែលពោលហើយ ។ តែសត្វទាំងឡាយធ្វើការប្រកាន់ខុសយ៉ាងនេះ យ៉ាងនោះ ក្នុងសភាវៈត្រឹមតែការប្រជុំនៃធម៌ តាមដែលពោលហើយប៉ុណ្ណោះ ។ ព្រោះដូច្នោះ ព្រះបុរាណាចារ្យ ទើបបានពោលទុកថា ៖

> របស់ណាដែលបុគ្គលកំពុងឃើញ របស់នោះមិនមែនរបស់ដែលគេបានឃើញហើយទេ របស់ណាដែលបុគ្គលបានឃើញហើយ របស់នោះ មិនមែនរបស់ដែលគេកំពុងឃើញ កាលមិនឃើញ ( តាមសេចក្ដីពិត ) ទើបវង្វេងជាប់នៅ កាល ( វង្វេង ) ជាប់នៅ រមែងមិនរួចផុត ។

មានអធិប្បាយថា ដើម្បីសម្ដែងដល់ការបំបែកភាពជាដុំ ( ឃនសញ្ញា ) ចេញ ជាដើម ។

ដោយអាទិសព្ទ ក្នុងពាក្យថា **ឃនវិនិព្ភោគាទិទស្សនត្ថំ** នេះ ក៏គួរជ្រាបអត្ថាធិប្បាយដូចតទៅនេះ ៖

សេចក្ដីពិត ព្រះយោគាវចរនេះ ពិចារណាឃើញកាយតែម្យ៉ាងប៉ុណ្ណោះ មិនមែនពិចារណាឃើញធម៌យ៉ាងដទៃ ។

មានអត្ថាធិប្បាយទុកយ៉ាងណា ?

មានអត្ថាធិប្បាយទុកថា មនុស្ស ( ទូទៅ ) មើលឃើញថ្ងៃបណ្តើរកូន ដែលមិនមែនទឹកសោះ ថាជាទឹកយ៉ាងណា ព្រះយោគាវចរ មិនមែនដូចយ៉ាងនោះ គឺ មិនឃើញកាយនេះ ដែលជារបស់មិនទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាតសោះ ថាជារបស់ទៀង ជាសុខ ជាអត្តា និងជារបស់ស្អាតទៅវិញទេ សេចក្តីពិត ពិចារណាឃើញ ( ត្រឹមតែ ) កាយ គឺ ពិចារណាឃើញថា ជាទីប្រជុំនៃកាយដែលមិនទៀង ជាទុក្ខ ជាអនត្តា និងជារបស់មិនស្អាត ប៉ុណ្ណោះ ។

ម្យ៉ាងទៀត គួរជ្រាបសេចក្តីសូម្បីយ៉ាងនេះថា កាយនេះណា មានខ្យល់ចេញចូលជាខាងដើម មានឆ្អឹង ដែលក្លាយទៅជាម្សៅម៉ដ្ឋផូរផង់ជាទីបំផុត ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកមុនហើយដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃ ឬ ។ល។ ភិក្ខុនោះ មានសតិដកដង្ហើមចេញ និងកាយណាដែលព្រះសារីបុត្រពោលទុកក្នុង បដិសម្ភិទាមគ្គ ថា ព្រះយោគាវចររូបខ្លះក្នុងសាសនានេះ ពិចារណាឃើញកាយ គឺ ដី , កាយ គឺ ទឹក , កាយ គឺ ភ្លើង , កាយ គឺ ខ្យល់ , កាយ គឺ សក់ , កាយ គឺ រោម , កាយ គឺ សម្បុរ , កាយ គឺ ស្បែក , កាយ គឺ សាច់ , កាយ គឺ ឈាម , កាយ គឺ សរសៃ , កាយ គឺ ឆ្អឹង , និងកាយ គឺ ខួរក្នុងឆ្អឹង ដោយជារបស់មិនទៀង ព្រោះពិចារណាឃើញកាយនោះទាំងអស់ ក្នុងកាយនេះ ទុំះឯង ព្រះយោគាវចរ ទើបឈ្មោះថា

ពិចារណាឃើញកាយក្នុងកាយ ។

មា៉ងទៀត គួរជ្រាបអត្ថយ៉ាងនេះថា ពិចារណាឃើញកាយ ពោល គឺ ទីប្រជុំរូបធម៌ មានសក់ជាដើម ក្នុងកាយផ្សេង ៗ ព្រោះមិនឃើញ របស់ណាមួយក្នុងកាយ ដែលនឹងត្រូវប្រកាន់មាំយ៉ាងនេះថា យើង ឬរបស់ យើង តែព្រោះពិចារណាឃើញការប្រជុំនៃរូបធម៌ផ្សេង ៗ នោះ ៗ ឯង មានសក់ និងរោម ជាដើម ។

មា៉ងទៀត គួរយល់អត្ថយ៉ាងនេះថា ជាអ្នកពិចារណាឃើញកាយ ក្នុងកាយ ព្រោះពិចារណាឃើញកាយ ពោលគឺ ការប្រជុំនៃអាការមាន **អនិច្ចលក្ខណៈ** ជាដើម ទូទៅគ្រប់យ៉ាងក្នុងកាយនេះ មានន័យដូចដែល មានមកហើយក្នុង **បដិសម្ភិទាមគ្គ** ដោយន័យមានជាអាទិ៍ថា ពិចារណា ឃើញដោយភាពជារបស់មិនទៀង មិនមែនឃើញដោយភាពជារបស់ទៀង ។

ពិតណាស់ ភិក្ខុអ្នកបដិបត្តិ **កាយេ កាយានុបស្សនាបដិបទា** ( ប្រការ បដិបត្តិ ពោលដោយការពិចារណាកាយក្នុងកាយ) នេះ គប្បីជ្រាបថា នឹង ពិចារណាឃើញកាយនេះ ដោយអំណាចនៃអនុបស្សនា ៧ ប្រការ មាន **អនិច្ចានុបស្សនា** ជាដើម គឺ នឹងពិចារណាឃើញដោយភាពជារបស់មិន ទៀង មិនមែនពិចារណាឃើញដោយភាពជារបស់ទៀង និងពិចារណាឃើញ ដោយភាពជាទុក្ខ មិនមែនពិចារណាឃើញដោយភាពជាសុខ និងពិចារណា ឃើញដោយភាពជាអនត្តា មិនមែនពិចារណាឃើញដោយភាពជាអត្តា នឹង នឿយណាយ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្ដីត្រេកអរ នឹងប្រាសចាក

តម្រេក មិនមែនត្រេកអរ រីករាយ នឹងរលត់ ( តណ្ហា ) មិនមែននឹងឲ្យកើត (តណ្ហា) នឹងរលាស់ចេញ មិនមែនប្រកាន់មាំ លោកកាលពិចារណាឃើញកាយនោះ ដោយសភាពមិនទៀង ក៏នឹងលះ **និច្ចសញ្ញា** បាន កាលពិចារណាឃើញដោយសភាពជាទុក្ខ ក៏នឹងលះ **សុខសញ្ញា** បាន កាលពិចារណាឃើញដោយភាពជាអនត្តា ក៏នឹងលះ **អត្តសញ្ញា** បាន កាលនឿយណាយ ក៏នឹងលះ **នន្ទិធម៌** សេចក្ដីក្រេីតក្រេីនបាន កាលប្រាសចាកតម្រេក ក៏នឹងលះ **រាគ** បាន កាលរំលត់ ( តណ្ហា ) ក៏នឹងលះ **សមុទយ** បាន កាលរលាស់ចេញបាន ក៏នឹងលះការប្រកាន់មាំបាន ។

## អធិប្បាយបទ អាតាបី សតិមា សម្បជានោ

បទថា **វិហរតិ** បានដល់ ដំណើរទៅ ។

ក្នុងបទថា **អាតាបី** គប្បីជ្រាបវិគ្រោះដូច្នេះ ដែលឈ្មោះថា **អាតាប** ព្រោះអត្ថថា រមែងដុតកម្ទេចកិលេសក្នុងភព ៣ ។ ពាក្យថា **អាតាប** នេះ ជាឈ្មោះនៃវិរិយៈ ។ **អាតាប** នៃភិក្ខុនោះមាន ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា **អាតាបី** ។

បទថា **សម្បជានោ** បានដល់ ប្រកបដោយញាណ ពោលគឺសម្បជញ្ញ ។

បទថា **សតិមា** គឺ ប្រកបដោយសតិ ដែលប្រើកំណត់កាយ ។

ក៏ធម្មតាថា **អនុបស្សនា** នេះ នឹងមិនមានដល់អ្នកប្រាសចាកសតិ

ឡើយ ព្រោះព្រះយោគាវចរ មានសតិជាគ្រឿងកំណត់អារម្មណ៍ហើយ ទើបពិចារណាឃើញ ( កាយជាដើម ) ដោយបញ្ញា ព្រោះហេតុនោះឯង ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលដល់សតិថា មានប្រយោជន៍ដល់ធម៌ទាំងពួង ព្រោះដូច្នេះ ក្នុងព្រះសូត្រនេះ ទើបព្រះអង្គត្រាស់ទុកថា **កាយេ កាយានុបស្សី វិហរតិ** ( ពិចារណាឃើញកាយក្នុងកាយ ) ។ ដោយពាក្យត្រឹមតែប៉ុណ្ណោះ ជាការដែលព្រះអង្គត្រាស់ **កាយានុបស្សនាសតិប្បដ្ឋានកម្មដ្ឋាន** ។

ម្យ៉ាងទៀត ព្រោះហេតុដែលអ្នកមិនមានសេចក្តីព្យាយាម ការរួញរាចិត្តខាងក្នុង រមែងធ្វើអន្តរាយឲ្យបាន អ្នកដែលមិនមានសម្បជញ្ញៈ រមែងជាអ្នកវង្វេងភ្លេចសតិ ក្នុងការកំណត់ឧបាយ និងក្នុងការវៀរចាកវត្ថុដែលមិនមែនឧបាយ គឺ ជាអ្នកមិនអាចក្នុងការកំណត់ឧបាយ និងក្នុងការលោះបោលនូវវត្ថុដែលមិនមែនឧបាយ ( ហើយ ) កម្មដ្ឋាននោះ នឹងមិនសម្រេចដល់លោកដោយវិធីនោះ ដូច្នោះ គប្បីជ្រាបថា ដើម្បីទ្រង់នឹងសម្តែងធម៌ទាំងឡាយ ដែលមានអានុភាពជាហេតុឲ្យ សម្រេចនូវកម្មដ្ឋាននោះ ទើបព្រះអង្គត្រាស់ពាក្យនេះទុកថា **អាតាបី** មានសេចក្តីព្យាយាម **សម្បជានោ** មានសម្បជញ្ញៈ **សតិមា** មានសតិ ។

## អធិប្បាយបទ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងកាយានុបស្សនាសតិប្បដ្ឋាន

និងវិធីប្រកបការយានុបស្សនាសតិប្បដ្ឋាននោះ ដោយប្រការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងអង្គនៃការលះកិលេស ទើបត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** គប្បីកម្ចាត់បង់នូវ **អភិជ្ឈា** និង **ទោមនស្ស** ក្នុងលោកចេញ ។

បណ្តាបទទាំងនោះ បទថា **វិនេយ្យ** បានដល់ កម្ចាត់បង់ដោយការគ្របសង្កត់ទុក ។

បទថា **លោកេ** បានដល់ ក្នុងកាយនោះ ៗ ឯង ។

ពិតណាស់ **កាយ** ព្រះអង្គទ្រង់ប្រាថ្នាយកថា **លោក** ក្នុងទីនេះ ព្រោះអត្ថថា បែកធ្លាយ ។ ប៉ុន្តែព្រោះហេតុដែលលោកមិនមែននឹងលះបង់ **អភិជ្ឈា** និង **ទោមនស្ស** បាន ចំពោះតែក្នុងកាយប៉ុណ្ណោះទេ សូម្បីក្នុងវេទនាជាដើម ក៏លះបានដូចគ្នា ដូច្នោះ ទើបលោកពោលទុកក្នុងគម្ពីរវិភង្គថា **លោក** គឺ ឧបាទានក្ខន្ធទាំង ៥ ។

មួយវិញទៀត ព្រោះធម៌ទាំងនោះត្រូវរាប់ថាជា **លោក** ពាក្យថា លោកនុ៎ះ ទើបលោកពោលទុកដោយ **អត្ថុទ្ធារន័យ** ( ដោយការពន្រើកសេចក្តី ) ថែកពាក្យណាដែលលោកពោលទុកថា ក្នុងធម៌ទាំងនោះណាជា **លោក** កាយនុ៎ះឯង ជា **លោក** ។ នេះជាសេចក្តីអត្ថាធិប្បាយក្នុងពាក្យនេះ ។ គប្បីឃើញការសម្ព័ន្ធសេចក្តីយ៉ាងនេះថា **កម្ចាត់អភិជ្ឈា** និង **ទោមនស្ស** ក្នុងលោកនោះចេញបាន ។

ក៏ព្រោះហេតុដែលក្នុងសូត្រនេះ **កាមច្ឆន្ទ** សង្គ្រោះចូលក្នុងសព្ទថា

**អភិជ្ឈា ព្យាបាទ** សង្គ្រោះចូលក្នុងស័ព្ទថា **ទោមនស្ស** ដូច្នោះ គប្បីជ្រាបថា ការលះបង់ **នីវរណ** ជាការដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកហើយ ដោយការសម្តែងធម៌ពីរយ៉ាង ដែលមានកម្លាំង ទាក់ទង (នឹងការលះ) **នីវរណ** ប៉ុន្តែពោលដោយពិសេសហើយ ក្នុងសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ការលះបង់សេចក្តីត្រេកអរ ដែលមានកាយសម្បត្តិជាមូល ដោយការកម្ចាត់ **អភិជ្ឈា** (និង) សេចក្តីមិនត្រេកអរ ដែលមានកាយវិបត្តិជាមូលទៀតផង ដោយការកម្ចាត់ **ទោមនស្ស** មួយទៀតត្រាស់ការលះបង់សេចក្តីត្រេកអរក្នុងកាយ ដោយការកម្ចាត់ **អភិជ្ឈា** ( និង ) សេចក្តីមិនត្រេកអរក្នុងការចម្រើន **កាយភាវនា** ដោយការកម្ចាត់ **ទោមនស្ស** ត្រាស់ការលះបង់ការបន្ថែម ភាពស្អាត និងសេចក្តីសុខជាដើម ដែលមិនមានពិតក្នុងកាយដោយ ការកម្ចាត់ **អភិជ្ឈា** និងការនាំចេញនូវភាពមិនស្អាត និងភាពជាទុក្ខ ដែលមាននៅពិតក្នុង **កាយ** ដោយការកម្ចាត់ **ទោមនស្ស** ។

ដោយពាក្យថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** នោះ ជាការដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងអានុភាពនៃការបំពេញសេចក្តីព្យាយាម និងភាពជាអ្នកអាចក្នុងការបំពេញសេចក្តីព្យាយាម របស់ព្រះយោគាវចរទុកហើយ ។ សេចក្តីពិត អានុភាពនៃសេចក្តីព្យាយាមនោះ បានដល់ ការដែលព្រះយោគាវចរជាអ្នកប្រាសចាកសេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរ ជាអ្នកគ្របសង្កត់សេចក្តីត្រេកអរ និងសេចក្តីមិន

ត្រេកអរបាន និង ជាអ្នកវៀរចាកការបំពេញវត្ថុដែលមិនពិតចូលទៅ និង នាំវត្ថុដែលពិតចេញមក ។ ក៏ព្រះយោគាវចរនេះ កាលប្រាសចាកសេចក្តីត្រេកអរ និងសេចក្តី មិនត្រេកអរ គ្របសង្កត់បាននូវសេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរ មិនបំពេញវត្ថុដែលមិនពិតចូលទៅ និងនាំវត្ថុដែលពិតចេញមក រមែងឈ្មោះថា ជាអ្នកអាចក្នុងការបំពេញសេចក្តីព្យាយាមនោះឯង ។

ន័យម្យ៉ាងទៀត គប្បីជ្រាបថា ព្រះអង្គត្រាស់កម្មដ្ឋានទុកដោយ **អនុបស្សនា** ( ការពិចារណារឿយ ៗ ) ក្នុងបទថា **កាយេ កាយានុបស្សី** នេះ ។ ត្រាស់ការបរិហារកាយទុក សម្រាប់អ្នកបំពេញកម្មដ្ឋានដោយការសម្រាក ដូចដែលពោលទុកហើយក្នុងបទថា **វិហរតិ** ។

ក្នុងបទថា **អាតាបី** ជាដើម ព្រះអង្គត្រាស់ **សម្មប្បធាន** ( សេចក្តីព្យាយាមប្រពៃ ) ទុកដោយ **អាតាប** ( សេចក្តីព្យាយាមជាហេតុឲ្យកិលេសក្តៅក្រហាយ ) ត្រាស់កម្មដ្ឋាន ដែលឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង ឬឧបាយសម្រាប់បរិហារកម្មដ្ឋានទុកដោយ **សតិសម្បជញ្ញ** ។ ម្យ៉ាងទៀត ត្រាស់ **សមថៈ** ដែលបានមកហើយដោយអំណាច **កាយានុបស្សនា** ទុកដោយសតិ ។ ត្រាស់ **វិបស្សនា** ដោយ **សម្បជញ្ញ** ។ ត្រាស់កម្លាំងនៃ**ភាវនា** ទុកដោយការកម្ចាត់ **អភិជ្ឈា** និង **ទោមនស្ស** ចេញ ។

---

# អធិប្បាយបទ អនុបស្សី

ប៉ុន្តែក្នុង **គម្ពីរវិភង្គ** ព្រះអង្គត្រាស់ទុកថា បទថា **អនុបស្សី** សេចក្តីថា បណ្តាធម៌ទាំងនោះ **អនុបស្សនា** គឺ អ្វី ?

គឺ **បញ្ញា** ការដឹងទូទៅដល់ ។លៗ **សម្មាទិដ្ឋិ** នេះ ហៅថា **អនុបស្សនា** ។ ភិក្ខុចូលដល់ ចូលដល់រៀបរយល្អហើយ ចូលមកដល់ហើយ ចូលមកដល់រៀបរយល្អហើយ ចូលទៅដល់ហើយ ដល់ព្រមហើយ ប្រកបហើយដោយ **អនុបស្សនា** នេះ ព្រោះហេតុនោះ ទើបត្រាស់ហៅថា **អនុបស្សី** អ្នកពិចារណាឃើញរឿយ ៗ ។

បទថា **វិហរតិ** សេចក្តីថា រមែងផ្លាស់ប្តូរ ប្រព្រឹត្តទៅរក្សាទុកដំណើរទៅឯង ឲ្យ (រាងកាយ) ដំណើរទៅ នាំទៅ សម្រាក ដោយហេតុនោះ ទើបត្រាស់ហៅថា **វិហរតិ** ។

បទថា **អាតាបី** សេចក្តីថា បណ្តាធម៌ទាំងនោះ **អាតាបៈ** (សេចក្តីព្យាយាម) គឺអ្វី ?

គឺ ការប្រារព្ធសេចក្តីព្យាយាមផ្លូវចិត្ត ។លៗ សេចក្តីព្យាយាមប្រពៃនេះ ហៅថា **អាតាប** ភិក្ខុជាអ្នកចូលដល់ហើយ ។លៗ ប្រកបព្រមហើយដោយ **អាតាប** នេះ ដោយហេតុនោះ ទើបត្រាស់ហៅថា **អាតាបី** ។

បទថា **សម្បជានោ** សេចក្តីថា បណ្តាធម៌ទាំងនោះ **សម្បជញ្ញ** គឺអ្វី ?

គឺ **បញ្ញា** សេចក្តីដឹងទូទៅ ។លៗ **សម្មាទិដ្ឋិ** នេះហៅថា **សម្ប-**

ជញ្ញ ។ ភិក្ខុជាអ្នកចូលដល់ហើយ ។ល។ ប្រកបព្រមហើយដោយសម្បជញ្ញៈនេះ ដោយហេតុនោះ ទើបត្រាស់ហៅថា **សម្បជានោ** ។

បទថា **សតិមា** សេចក្តីថា បណ្តាធម៌ទាំងនោះ **សតិ** គឺអ្វី ?

គឺ **សតិ** សេចក្តីរឭកបាន **អនុស្សតិ** ការរឭកឃើញរឿយៗ ។ល។ **សម្មាសតិ** ការរឭកប្រពៃ នេះហៅថា **សតិ** ។ ភិក្ខុជាអ្នកចូលដល់ហើយ ។ល។ ប្រកបព្រមហើយដោយសតិនេះ ដោយហេតុនោះ ទើបត្រាស់ហៅថា **អ្នកមានសតិ** ។

បទថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** សេចក្តីថា បណ្តាធម៌ទាំងនោះ **លោក** គឺអ្វី ?

កាយនោះឯង ឈ្មោះថា **លោក** លោក គឺ **ឧបាទានក្ខន្ធ** ទាំង ៥ នេះហៅថា **លោក** ។

បណ្តាធម៌ទាំងនោះ **អភិជ្ឈា** គឺអ្វី ?

គឺ ការត្រេកត្រអាល ការត្រេកត្រអាលខ្លាំងក្លា ការត្រេកអរតាមសេចក្តីភ្លើតភ្លើន ការត្រេកត្រអាលដោយអំណាចសេចក្តីភ្លើតភ្លើន ការត្រេកត្រអាលខ្លាំងនៃចិត្ត នេះហៅថា **អភិជ្ឈា** ។

បណ្តាធម៌ទាំងនោះ **ទោមនស្ស** គឺអ្វី ?

គឺ ការមិនត្រេកអរផ្លូវចិត្ត សេចក្តីទុក្ខផ្លូវចិត្ត ការមិនត្រេកអរទុក្ខវេទនាកើតអំពីមនោសម្ផស្ស នេះហៅថា **ទោមនស្ស** ។

ទាំង **អភិជ្ឈា** ទាំង **ទោមនស្ស** ក្នុងលោក គឺ កាយនេះ ជាការ

ដែលត្រូវកម្ចាត់ហើយ ត្រូវកម្ចាត់ចេញហើយ ស្ងប់ហើយ ស្ងាត់ស្ងៀមហើយ រម្ងាប់ហើយ ដល់ការរលត់ហើយ ដល់ការតាំងនៅមិនបានហើយ ដល់ការរលត់សូន្យទៅហើយ អស់ត្រេកអរហើយ រីងស្ងួតហើយ ស្វិតស្រពោនហើយ ធ្វើឲ្យវិនាសហើយ ដោយហេតុនោះ ទើបព្រះអង្គត្រាស់ថា កម្ចាត់បង់បាននូវ *អភិជ្ឈា* និង *ទោមនស្ស* ក្នុងលោក គឺ កាយ , សេចក្តីនៃបទទាំងនោះ ខ្ញុំបានពោលទុកហើយ ដូចដែលពណ៌នាមកនេះ អ្នកសិក្សាគប្បីជ្រាបន័យនៃអដ្ឋកថានេះ ព្រមដោយន័យនោះ ដោយការប្រៀបធៀបគ្នាចុះ ។

នេះជាកថាពណ៌នាសេចក្តីនៃឧទ្ទេសរបស់ *កាយានុបស្សនាសតិប្បដ្ឋាន* ដូច្នេះ ។

## អធិប្បាយ វេទនានុបស្សនា

ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាបប្រយោជន៍ក្នុងការពោលដដែល ៗ នូវ *វេទនា* ជាដើម ក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា *វេទនាសុ វេទនានុបស្សី វិហរតិ* ( ដែលមានរួមនៅក្នុងពាក្យនេះថា *វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ល។ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ* ដោយន័យដូចដែលបានពោលទុកហើយក្នុង *កាយានុបស្សនា* ។

ក៏ក្នុងពាក្យថា *វេទនាសុ វេទនានុបស្សី វិហរតិ ចិត្តេ ចិត្តានុបស្សី ធម្មេសុ ធម្មានុបស្សី* នេះ ពាក្យថា *វេទនា* បានដល់ *វេទនា* ៣

ហើយវេទនានោះ ជា **លោកិយ** តែម្យ៉ាង សូម្បីចិត្តក៏ដូចគ្នា ជា **លោកិយ** ។ **ធម៌** ក៏ដូច្នោះដូចគ្នា ( ជាលោកិយ ) ។ ការបែកវេទនា ជាដើមទាំងនោះ នឹងប្រាកដក្នុង **និទ្ទេសវារៈ** ។ ប៉ុន្តែក្នុងទីនេះគប្បីជ្រាប ការបែកវេទនាសុទ្ធ ៗ ទុកថា វេទនាត្រូវពិចារណាឃើញ យ៉ាងណា ព្រះយោគាវចរ កាលបើពិចារណាឃើញយ៉ាងនោះ ក៏ឈ្មោះថា ពិចារណាឃើញវេទនាក្នុងវេទនា ។ ក្នុង **ចិត្តានុបស្សនា** និង **ធម្មានុបស្សនា** ក៏ន័យនេះដូចគ្នា ។

សួរថា ក៏វេទនាគួរពិចារណាឃើញ ដូចម្ដេច ?

ឆ្លើយថា មុនដំបូង **សុខវេទនា** គួរពិចារណាឲ្យឃើញដោយភាពជាទុក្ខ **ទុក្ខវេទនា** គួរពិចារណាឲ្យឃើញថាដូចជា កូនសរ , **អទុក្ខម-សុខវេទនា** ( វេទនាមិនទុក្ខមិនសុខ ) គួរពិចារណាឲ្យឃើញថា ជារបស់មិនទៀង ។ ដូចដែលត្រាស់ទុកថា ៖

> **ភិក្ខុរូបណាបានឃើញសេចក្ដីសុខដោយភាពជាទុក្ខ បានឃើញសេចក្ដីទុក្ខថា ដូចជាកូនសរ បានឃើញសេចក្ដីមិនទុក្ខមិនសុខ ដែលមាននៅ ដោយជារបស់មិនទៀងហើយ ភិក្ខុរូបនោះជាអ្នកឃើញប្រពៃ និងជាអ្នកស្ងប់ត្រាច់ទៅ ។**

ក៏វេទនាគ្រប់យ៉ាងនេះ គួរពិចារណាឲ្យឃើញថា ជាទុក្ខ ។ សមពិត តាមដែលព្រះមានព្រះភាគជាម្ចាស់ បានត្រាស់ទុកថា ធម្មជាតិឯណានីមួយ ដែលបានសោយហើយ តថាគតពោលធម្មជាតិនោះទាំងអស់ថា

( រួមចុះក្នុង ) ទុក្ខ ។

ម្យ៉ាងទៀត **សុខវេទនា** ក៏គួរពិចារណាឲ្យឃើញថា ជាទុក្ខ ។ ដូចដែលត្រាស់ទុកថា វេទនានេះជាសុខ សុខក្នុងពេលដែលតាំងនៅ , ជា **វិបរិណាមទុក្ខ** ទុក្ខ ព្រោះប្រែប្រួល ព្រោះដូច្នោះ គួរធ្វើឲ្យពិស្តារគ្រប់ប្រការ ។

ម្យ៉ាងទៀត វេទនា ក៏គួរពិចារណាឲ្យឃើញសូម្បីដោយ **អនុបស្សនា** ទាំង ៧ មាន **អនិច្ចានុបស្សនា** ជាដើម ។ ពាក្យដ៏សេសនឹងមានប្រាកដក្នុង **និទ្ទេសវារៈ** នោះឯង ។

សូម្បីបណ្ដា ចិត្ត និងធម៌ ចិត្តក៏គួរពិចារណាឲ្យឃើញដោយការចែកចេញទៅជាចិត្ត មានរាគៈជាដើម ដែលមានមកហើយក្នុងនិទ្ទេសវារៈនៃ **អនិច្ចានុបស្សនា** ជាដើម ដែលចែកចេញផ្សេង ៗ គ្នា **មានអារម្មណ៍ អធិបតី សហជាត ធម៌ ភូមិ កម្ម វិបាក** និង **កិរិយា** ជាដើម ។

(ធម៌) ក៏គួរពិចារណាឲ្យឃើញដោយលក្ខណៈរបស់ខ្លួន ( វិសេសលក្ខណៈ ) និងលក្ខណៈដែលស្មើគ្នា ( សាមញ្ញលក្ខណៈ ) របស់ធម៌ ។ ដោយ **សុញ្ញតធម៌** ដោយ **អនុបស្សនាទាំង** ៧ មាន **អនិច្ចានុបស្សនា** ជាដើម និងដោយចែកចេញជា **សន្តធម៌** ( ធម៌ដែលស្ងប់ ) និង **អសន្តធម៌** ( ធម៌ដែលមិនស្ងប់ ) ជាដើម ដែលមកហើយក្នុងនិទ្ទេសវារៈ ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយ នោះឯង ។

ក៏ក្នុងការលះ **អភិជ្ឈា** និង **ទោមនស្ស** ជាដើមនេះ អ្នកណាកម្ចាត់

បង់ **អភិជ្ឈា** និង **ទោមនស្ស** ក្នុងលោក ពោលគឺ កាយបានហើយ អ្នកនោះក៏លះ **អភិជ្ឈា** និង **ទោមនស្ស** សូម្បីក្នុងលោក គឺ វេទនាជាដើមបាននោះឯងក៏ពិត តែព្រះអង្គក៏បានត្រាស់គ្រប់ ៗ និទ្ទេសវារៈ ដោយបុគ្គលផ្សេងគ្នា និងដោយ **សតិប្បដ្ឋានភាវនា** ដែលប្រាកដឡើង ក្នុងខណៈចិត្តផ្សេងគ្នា ។ ម្យ៉ាងទៀត គប្បីជ្រាបថា ដោយហេតុដែលអភិជ្ឈា និងទោមនស្ស ដែលលះបានក្នុងវារៈមួយហើយ ជាការដែលលះបាន សូម្បីក្នុងវារៈដ៏សេសនោះឯង ដើម្បីទ្រង់សម្តែងការលះ អភិជ្ឈា និងទោមនស្សទុកក្នុងវារៈនោះ ទើបបានត្រាស់ទុកយ៉ាងនេះ ដូច្នេះឯង ។

( ចប់ អដ្ឋកថាពោលដោយឧទ្ទេសវារៈ )

# សមាធិ ៤

[១៣៣] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់មានពុទ្ធបំណងនឹងឲ្យសត្វទាំងឡាយ សម្រេចគុណវិសេសច្រើនប្រការ ដោយព្រះធម៌ទេសនា ពោលដោយ **សតិប្បដ្ឋាន** ទើបទ្រង់ចែក **សម្មាសមាធិ** ចេញជា ៤ តាមអារម្មណ៍ ដោយមានន័យជាអាទិ៍ថា **សតិប្បដ្ឋាន** មាន ៤ យ៉ាង , ៤ យ៉ាង តើអ្វីខ្លះ ? គឺ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញកាយក្នុងកាយ ដូច្នេះហើយ តទៅកាលនឹងទ្រង់លើកយក **សតិប្បដ្ឋាន** នីមួយ ៗ មកចែកចេញទៅ ( ទៀត ) ទើបបានទ្រង់ប្រារព្ធ ដើម្បីត្រាស់និទ្ទេសវារៈទុក ដោយន័យមានជាអាទិ៍ថា **កថញ្ច ភិក្ខវេ** ( ម្នាលភិក្ខុទាំងឡាយ តើដូចម្តេច ? ) ឧបមាដូចជាងតម្បាញដែលឆ្លាត ប្រាថ្នានឹងធ្វើគ្រឿងប្រើប្រាស់មានកន្ទេលកក់ កន្ទេលចែងម៉ែង ក្លាក់ ហិប និងកញ្ច្រែង ជាដើម , បានឫស្សីធំ ១ ដើម មកពុះចេញជា ៤ ចម្រៀក , យកតែមួយចម្រៀកមក ( ពុះឲ្យជាបន្ទះ ) ហើយត្បាញជាគ្រឿងប្រើប្រាស់ ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **កថញ្ច** ជាដើម ជាពាក្យសួរ ដោយទ្រង់បំណងនឹងត្រាស់ឆ្លើយឲ្យពិស្តារដោយព្រះអង្គឯង ។ ក៏ក្នុងបទនេះ មានអត្ថាធិប្បាយដោយសង្ខេប ដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ ដោយប្រការដូចម្តេច ? ភិក្ខុទើបជាអ្នកពិចារណាឃើញកាយក្នុងកាយ ។ ន័យនេះមាននៅក្នុងគ្រប់វារៈនៃពាក្យសួរ ។

បទថា **ឥធ ភិក្ខវេ ភិក្ខុ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង

សាសនានេះ ។ ព្រោះថា **ឥធ** ស័ព្ទនេះ ក្នុងពាក្យថា **ឥធ ភិក្ខវេ ភិក្ខុ** នេះ បញ្ជាក់ដល់សាសនា ដែលជាទីពំនាក់អាស្រ័យ របស់បុគ្គលអ្នកឲ្យកើត **កាយានុបស្សនា** គ្រប់ប្រការ និងបដិសេធសាសនាដទៃថា មិនជាយ៉ាងនោះ ។ សមពិតដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះប៉ុណ្ណោះ មានសមណៈ , សាសនាដទៃ ( បរប្បវាទៈលទ្ធិដទៃ ) សាបសូន្យចាកសមណៈពួកដទៃ ។ ដោយហេតុនោះ ទើបព្រះអង្គត្រាស់ទុកថា ភិក្ខុក្នុងសាសនានេះ ។

ពាក្យថា **អរញ្ញគតោ វា ។បេ។ សុញ្ញាគារគតោ វា** ( ទៅកាន់ព្រៃ ។ល។ ឬទៅកាន់ផ្ទះស្ងាត់ ) នេះ ជាពាក្យសម្ដែងដល់ការទ្រទ្រង់កំណត់សេនាសនៈ ដ៏សមគួរដល់ការបំពេញ **សតិប្បដ្ឋាន** ។

## ឧបមា ចិត្តដូចកូនគោ

ព្រោះថា ចិត្តរបស់ភិក្ខុនេះ ដែលត្រាច់ទៅក្នុងរូបារម្មណ៍ជាដើមមកជាយូរហើយ មិនប្រាថ្នានឹងចូលគន្លងកម្មដ្ឋាន រត់ចេញក្រៅផ្លូវតែម្យ៉ាងប៉ុណ្ណោះ ដូចរថដែលទឹមដោយគោខូចក៏ដូចគ្នា ព្រោះដូច្នោះ ទើបឧបមាថា អ្នកចិញ្ចឹមគោ (ម្ចាស់គោ) កាលប្រាថ្នានឹងហ្វឹកហាត់កូនគោខូច ដែលផឹកទឹកដោះគ្រប់តំណក់អំពីមេគោខូច ធំធាត់ឡើងមកត្រូវពង្រាត់ ( វា ) ចេញពីមេ ដាំបង្គោលធំមួយ ទុកក្នុងទីដ៏សមគួរហើយ យកខ្សែចង ( វា ) ទុកនឹងបង្គោលនោះ ។ លុះកូនគោនោះ ស្ទុះលោតទៅខាងនោះ ខាងនេះ

ក៏មិនអាចគេចចេញទៅបាន នឹងត្រូវឈរជិត ឬដេកជិតបង្គោលនោះឯង យ៉ាងណា ។ ភិក្ខុរូបនេះឯង ក៏ដូច្នោះដូចគ្នា កាលប្រាថ្នានឹងទូន្មានចិត្តខូច របស់ខ្លួន ដែលចម្រើនឡើងអំពីការក្រេបរសនៃរូបារម្មណ៍ជាដើម មកយូរ ហើយ ត្រូវពង្រាត់វាអំពីរូបារម្មណ៍ជាដើម ចូលទៅកាន់ព្រៃ ឬរុក្ខមូល ឬ ផ្ទះស្ងាត់ យកខ្សែ គឺ សតិចងទុកនឹងបង្គោល គឺ អារម្មណ៍របស់ **សតិប្បដ្ឋាន** នោះ ។ ចិត្តរបស់ភិក្ខុនោះ សូម្បីនឹងរើបម្រះទៅខាងនោះ ខាងនេះ យ៉ាងនេះ កាលមិនបានអារម្មណ៍ ដែលធ្លាប់សេពមកពីមុន មិន អាចនឹងទំលាយខ្សែ គឺ សតិ (ឲ្យដាច់) ហើយគេចចេញទៅ ក៏នឹងដួល ជ្រប់ ហើយស្ងៀមនៅនឹងអារម្មណ៍នោះឯង ដោយ **ឧបចារសមាធិ** ។ ដោយហេតុនោះ ព្រះបុរាណាចារ្យ ទើបបានពោលទុកថា ៖

> ព្រះយោគាវចរ (អ្នកបំពេញសេចក្តីព្យាយាម) ត្រូវយក
> សតិចងចិត្តរបស់ខ្លួនទុកនឹងអារម្មណ៍ (កម្មដ្ឋាន) ឲ្យមាំ
> ដូចមនុស្សក្នុងលោកនេះ កាលនឹងហ្វឹកហាត់គោ ត្រូវចង
> គោ ដែលនឹងត្រូវហ្វឹកហាត់ទុកនឹងបង្គោល ដូច្នោះ ។

សេនាសនៈនោះ ជាសេនាសនៈសមគួរដែលនឹងបំពេញ (កម្មដ្ឋាន) សម្រាប់លោក ដោយប្រការដូចដែលពណ៌នាមកនេះ ។ ដោយហេតុនោះ ព្រះអង្គទើបបានត្រាស់ថា **អរញ្ញគតោ វា ។បេ។ សុញ្ញាគារគតោ វា** នេះ បញ្ជាក់ដល់ការកំណត់សេនាសនៈដ៏សមគួរដល់ការបំពេញ **សតិប្បដ្ឋាន** ។

---

## សំឡេងជាសត្រូវដល់ឈាន

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះយោគាវចរលះបង់សេនាសនៈចុង ស្រុកដែលគឹកកង ដោយសំឡេងស្ត្រី សំឡេងបុរស សំឡេងដំរី សំឡេងសេះជាដើម មិនបាននឹងញុំាងអានាបានស្សតិកម្មដ្ឋាន ដែលជាកំពូលនៃកាយានុបស្សនា ជាហេតុជិតនៃការសម្រេចគុណវិសេស និង ទិដ្ឋធម្ម-សុខវិហារធម៌ របស់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះសាវកគ្រប់ ៗ ព្រះអង្គនេះ ឲ្យសម្បូណ៌ មិនមែនរបស់ដែលនឹងធ្វើបានងាយ ព្រោះឈានមានសំឡេង ជាសត្រូវ ( ឧបសគ្គ ) ។ តែក្នុងព្រៃដែលមិនមានភូមិ ការកំណត់យកព្រះកម្មដ្ឋាននេះហើយ ញុំាងឈានទី ៤ មានអានាបានស្សតិជាអារម្មណ៍ ធ្វើឈាននោះឯង ឲ្យជាបាទ ( របស់វិបស្សនា ) ពិចារណាសង្ខារធម៌ហើយ បានសម្រេចអរហត្ត ដែលជាផលដ៏កំពូល ជារបស់ដែលព្រះយោគាវចរធ្វើបានងាយ ដូច្នោះ ព្រះមាន-ព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងសេនាសនៈដ៏សមគួរដល់ព្រះយោ-គាវចរនោះ ទើបត្រាស់ថា **អរញ្ញគតោ វា** ដូច្នេះ ជាដើម ។

ដោយថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ដូចជាអាចារ្យអ្នកដែលចេះជ័យភូមិ ( អ្នកត្រួតមើលភូមិ ឬអ្នកធរណីវិទ្យា ) ។ កាលព្រះអង្គទ្រង់ពិចារណាឃើញសេនាសនៈ ដែលសមគួរដល់ព្រះយោគាវចរយ៉ាងនេះហើយ ទើបទ្រង់បង្ហាញថា គួរបំពេញព្រះកម្មដ្ឋានក្នុងទីនេះ តអំពីនេះទៅ ព្រះយោគី

( ភិក្ខុអ្នកបំពេញព្យាយាម ) បំពេញកម្មដ្ឋាន កាលបានសម្រេចព្រះអរហត្ត តាមលំដាប់ហើយ ព្រះអង្គទ្រង់ទទួលសក្ការៈយ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយពាក្យសរសើរថា ព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គនោះ ទ្រង់ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ ( ពិត ៗ ) ហ្ន៎ ដូចអាចារ្យដែលចេះជ័យភូមិ មើលផ្ទៃដីដែលនឹងត្រូវសាងព្រះនគរ ពិចារណាមើលសព្វគ្រប់ហើយចង្អុលប្រាប់ថា អ្នកទាំងឡាយចូរសាងព្រះនគរក្នុងទីនេះ កាលព្រះនគរសាងស្រេចដោយសិរីសួស្តី ( រៀបរយ ) ហើយ នឹងបានទទួលព្រះរាជទានសក្ការៈច្រើនសន្ធឹកសន្ធាប់ អំពីព្រះរាជត្រកូល ដូច្នោះ ។

## ទ្រង់ប្រៀបភិក្ខុដូចខ្លាដំបង

តែភិក្ខុរូបនេះ លោកពោលថា ដូចជាខ្លាដំបង អធិប្បាយថា ស្តេចខ្លាធំអាស្រ័យក្នុងព្រៃក្រាស់ ឬព្រៃស្មៅក្រាស់ក្នុងព្រៃ ពួនចាំចាប់ពួកម្រឹគមានក្របីព្រៃ ក្តាន់ និងជ្រូកព្រៃជាដើម ( ស៊ី ) យ៉ាងណាមិញ ភិក្ខុនេះក៏ដូច្នោះដូចគ្នា បំពេញកម្មដ្ឋានរឿយ ៗ ក្នុងព្រៃជាដើម និងសម្រេចអរិយមគ្គ ៤ អរិយផល ៤ តាមលំដាប់ ។ ព្រោះដូច្នោះ ព្រះបុរាណាចារ្យទើបបានពោលទុកថា ៖

> ភិក្ខុអ្នកជាពុទ្ធបុត្រ បំពេញវិបស្សនា ប្រកបសេចក្តីព្យាយាម
> នេះ ចូលទៅកាន់ព្រៃ ហើយសម្រេចព្រះអរហត្តផល ដូច
> ខ្លាដំបងពួនចាំចាប់ម្រឹគស៊ី ដូច្នោះ ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងសេនាសនៈក្នុងព្រៃ ដែលជាសេនាសនៈដ៏សមគួរ ដល់ការប្រញាប់ប្រញាល់ក្នុងការប្រកបសេចក្តីព្យាយាមដល់ភិក្ខុនោះ ទើបបានត្រាស់ទុកថា **អរញ្ញ-គតោ វា** ដូច្នេះ ជាដើម ។

តអំពីនេះទៅ ពាក្យណាដែលខ្ញុំម្ចាស់នឹងត្រូវពោល ( អធិប្បាយ ) ក្នុង **អានាបានបព្វៈ** នេះ ពាក្យនោះ ខ្ញុំម្ចាស់បានពោលទុកក្នុង **គម្ពីរ-វិសុទ្ធិមគ្គ** នោះហើយ ។

## ចម្រើនអានាបានស្សតិ

ក៏កាលព្រះយោគាវចរនោះ សិក្សាដោយអំណាចនៃខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញទាំងនេះ ដែលព្រះមានព្រះភាគជាម្ចាស់ បានត្រាស់ទុកយ៉ាងនេះថា ភិក្ខុសិក្សាថា កាលដកដង្ហើមចេញវែងក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឈានទាំង ៤ នឹងកើតឡើង ព្រោះក្នុង **និមិត្ត គឺ អស្សាស និង បស្សាស** ។

លោកចេញចាកឈានហើយ កំណត់ខ្យល់ដកដង្ហើមចេញ ខ្យល់ដកដង្ហើមចូល ឬកំណត់អង្គឈាន ក្នុងចំនួន **អស្សាសបស្សាសៈ** និងអង្គឈានទាំង ២ យ៉ាងនោះ ។ ( បើ ) ជាអ្នកកំណត់ **អស្សាសបស្សាសៈ** ជាអារម្មណ៍ ក៏កំណត់រូបយ៉ាងនេះថា **អស្សាសបស្សាសៈ** អាស្រ័យនឹងអ្វី ? អាស្រ័យនឹង **វត្ថុ** , **ករជកាយ** ឈ្មោះថា **វត្ថុ** ។ **មហាភូតរូប ៤** និង

ឧបាទាយរូប ( ២៤ ) ឈ្មោះថា **ករជកាយ** ។

តមក កំណត់នាមរូបយ៉ាងនេះថា នាម មាននៅក្នុងអារម្មណ៍នោះ មានផស្សៈជាទី ៥ កាលស្វែងរកបច្ច័យរបស់នាមរូបនោះ នឹងឃើញ **បដិច្ចសមុប្បាទ** មាន **អវិជ្ជា** ជាដើម ធ្វើសេចក្តីសង្ស័យបានថា នេះត្រឹមតែជាបច្ច័យ និងធម៌ដែលអាស្រ័យបច្ច័យកើតឡើងប៉ុណ្ណោះ មិនមែនសត្វ ឬបុគ្គលដទៃផ្សេង ( ពី **អស្សាសបស្សាស** នោះ ) លើកយកនាមរូបព្រមទាំងបច្ច័យ ឡើងកាន់ត្រៃលក្ខណ៍ ចម្រើន **វិបស្សនា** សម្រេចព្រះអរហត្ត-ផល តាមលំដាប់ ។

នេះជាផ្លូវនៃការចេញ ( ចាកទុក្ខ ) រហូតដល់ព្រះអរហត្តរបស់ភិក្ខុមួយរូប ។

ចំណែកអ្នកកំណត់ឈានជាអារម្មណ៍ និងកំណត់នាមរូបថា អង្គឈានទាំងឡាយនេះ អាស្រ័យនឹងអ្វី ? អាស្រ័យនឹងវត្ថុ , ករជកាយ ឈ្មោះថា **វត្ថុ** អង្គឈាន ជានាម , **ករជកាយ** ជារូប កាលស្វែងរកបច្ច័យនៃនាមរូបនោះ នឹងឃើញ **បច្ចយាការ** មាន **អវិជ្ជា** ជាដើម កន្ទួងសេចក្តីសង្ស័យចេញបានថា នេះត្រឹមតែជាបច្ច័យ និងធម៌ដែលអាស្រ័យបច្ច័យកើតឡើងប៉ុណ្ណោះ មិនមែនសត្វ ឬបុគ្គលផ្សេង ( អំពីនាមរូបនោះ ) លើកយកនាមរូបព្រមទាំងបច្ច័យឡើងកាន់ត្រៃលក្ខណ៍ ចម្រើន **វិបស្សនា** សម្រេចអរហត្តតាមលំដាប់ , នេះជាផ្លូវនៃការចេញ ( ចាកទុក្ខ ) រហូតដល់ព្រះអរហត្តរបស់ភិក្ខុមួយរូប ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ គឺ ខ្យល់ដកដង្ហើមចេញ ដកដង្ហើមចូលរបស់ខ្លួន យ៉ាងនេះ ។

បទថា **ពហិទ្ធា វា** សេចក្តីថា ឬ ( ពិចារណាឃើញកាយ ) ក្នុងកាយ គឺ ខ្យល់ដកដង្ហើមចេញ ដកដង្ហើមចូលរបស់អ្នកដទៃ ។

បទថា **អជ្ឈត្តពហិទ្ធា វា** សេចក្តីថា ក្នុងកាយ គឺ ដកដង្ហើមចេញ ដកដង្ហើមចូលរបស់ខ្លួន ( និង ) របស់អ្នកដទៃតាមកាលវេលា យ៉ាងនេះ ។

ដោយបទថា **អជ្ឈត្តពហិទ្ធា វា** នេះ ព្រះអង្គត្រាស់ដល់កាលវេលាដែលខ្យល់ដកដង្ហើមនោះ ចេញ ៗ ចូល ៗ ដោយមិនបញ្ឈប់កម្មដ្ឋានដែលស្ទាត់ជំនាញទុក ។ តែទាំង ២ យ៉ាងនេះ នឹងមានក្នុងវេលាតែមួយជាមួយគ្នាមិនបាន ។

បទថា **សមុទយធម្មានុបស្សី វា** សេចក្តីថា ឧបមាដូចស្នប់របស់ជាងមាស ទាំងដងស្នប់ និងសេចក្តីព្យាយាម ដែលកើតអំពីរបស់ទាំង ២ យ៉ាងនោះ ( ស្នប់ និងដងស្នប់ ) ខ្យល់ទើបកើត ដើរទៅមកបាន យ៉ាងណាមិញ ។ កាយ គឺ **អស្សាសបស្សាស** របស់ភិក្ខុក៏ដូច្នោះ អាស្រ័យ**ករជកាយ ក្តោងប្រមុះ** និង **ចិត្ត** ទើបសញ្ចរទៅមកបាន ។ ធម៌ទាំងឡាយ មានកាយជាដើម ជាសមុទយៈ ភិក្ខុកាលពិចារណាធម៌ទាំងនោះហៅថា ពិចារណាឃើញរឿយ ៗ នូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ ។

បទថា **វយធម្មានុបស្សី វា** សេចក្តីថា កាលកាយបែកធ្លាយ ក្តោងប្រមុះត្រូវកម្ចាត់ហើយ និងកាលចិត្តរលត់ ដែលឈ្មោះថា **កាយ** គឺ ខ្យល់

អស្សាសៈ និងបស្សាសៈ នឹងសញ្ចរមិនបាន ដូចកាលស្នប់ត្រូវនាំចេញទៅហើយ កាលជងស្នប់បាក់ និងកាលមិនមានសេចក្តីព្យាយាមដែលកើតអំពីស្នប់ និងជងស្នប់នោះ ខ្យល់នោះនឹងមិនដើរដូច្នោះ ព្រោះដូច្នោះខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលរលត់ទៅ ព្រោះកាយជាដើមបែកធ្លាយទៅ ភិក្ខុកាលពិចារណាឃើញយ៉ាងនេះ ទើបព្រះអង្គត្រាស់ហៅថា ពិចារណាឃើញរឿយ ៗ នូវធម៌ដែលសូន្យទៅក្នុងកាយ ។

បទថា **សមុទយវយធម្មានុបស្សី** សេចក្តីថា ពិចារណាឃើញការកើតតាមកាលវេលា រលត់ទៅតាមកាលវេលា ។

បទថា **អត្ថិ កាយោតិ វា បនស្ស** សេចក្តីថា **សតិ** ជាកាលដែលលោកចូលទៅតាំងទុកយ៉ាងនេះថា កាយ មានមែន តែមិនមែនសត្វមិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមែនរបស់ដែលជាប់ដោយខ្លួន មិនមែនយើង មិនមែនរបស់យើង មិនមែនអ្នកណាមិនមែនរបស់អ្នកណា ។

ពាក្យថា **យាវទេវ** នេះ ជាពាក្យកំណត់ការបង្ហាញប្រយោជន៍ ។ មានពាក្យអធិប្បាយថា **សតិ** ដែលចូលទៅតាំងទុកនោះ មិនមែនដើម្បីប្រយោជន៍យ៉ាងដទៃ ។ សេចក្តីពិត ត្រឹមតែដើម្បីការដឹងប៉ុណ្ណោះ គឺដើម្បីប្រយោជន៍ដល់ញាណដ៏ក្រៃលែងជាប្រមាណនៃការដឹងដ៏ក្រៃលែង ៗ និងដើម្បីត្រូវការសតិជាប្រមាណ អធិប្បាយថា ដើម្បីត្រូវការឲ្យសតិ និងសម្បជញ្ញៈចម្រើនឡើង ។

បទថា **អនិស្សិតោ ច វិហរតិ** សេចក្តីថា ជាអ្នកមិនអាស្រ័យ ( អ្វី ) ដោយអំណាចនៃ **តណ្ហានិស្សយ** និង **ទិដ្ឋិនិស្សយ** សេចក្តីថា **ន ច កិញ្ចិ លោកេ ឧបាទិយតិ** ( លោកមិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោក ) សេចក្តីថា លោកនឹងមិនប្រកាន់អ្វី គឺ រូប ។ល។ ឬវិញ្ញាណក្នុងលោកថា នេះជាខ្លួន ឬរបស់ដែលជាប់ដោយខ្លួនយើង ។

**បិ** អក្សរ ក្នុងពាក្យថា **ឯវំបិ** ប្រើក្នុងសេចក្តីថា រួមយកសេចក្តីខាងមុខមកទុក ។ ម្យ៉ាងទៀត ដោយបទនេះ ព្រះមានព្រះភាគទ្រង់សម្តែងព្រះធម្មទេសនា ពោលដោយ **អានាបានបព្វ** ប្រគល់ឲ្យ ( សាវកទាំងឡាយ ) ដូច្នេះឯង ។

## អរិយសច្ច ៤ ក្នុងអានាបាន

បណ្តា **សច្ច** ទាំងនោះ **សតិ** ដែលកំណត់ **អស្សាស** និង **បស្សាស** ជា **ទុក្ខសច្ច** តណ្ហាដែលមានមកអំពីមុន ជាសមុដ្ឋានរបស់សតិនោះ ជា **ទុក្ខសមុទយសច្ច** ការមិនប្រព្រឹត្តទៅនៃ **សតិ** និង **តណ្ហា** ទាំងពីរយ៉ាងនោះជា **និរោធសច្ច** អរិយមគ្គដែលមានការកំណត់ដឹងទុក្ខ មានការលះ **សមុទយសច្ច** មាន **និរោធសច្ច** ជាអារម្មណ៍ ជា **មគ្គសច្ច** ។

លោកខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះហើយ នឹងសម្រេចព្រះ ( និព្វាន ) ដូច្នោះ សេចក្តីនេះ ទើបជាផ្លូវនៃការចេញចាក ( ទុក្ខ ) រហូតដល់អរហត្តរបស់ភិក្ខុអ្នកមិនប្រកាន់មាំ ដោយអំណាច **អស្សាស**

និង *បស្សាស មួយរូប ។*

( ចប់ អានាចានបព្វៈ )

## ពិចារណាកាយ ដោយឥរិយាបថ

[១៣៤] ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកការពិចារណាមើលកាយដោយ អស្សាសៈ និងបស្សាសៈ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយឥរិយាបថ ទើបត្រាស់ពាក្យមានជាអាទិ៍ទុកថា **បុន ច បរំ** ។

នឹងវិនិច្ឆ័យក្នុងបទទាំងនោះតទៅ ៖

## ការដើរដែលជាសតិប្បដ្ឋានភាវនា

សុនខ្ចីឆ្កែស្រុក និងឆ្កែព្រៃ កាលដើរទៅ ក៏ដឹងដោយពិតថា យើងកំពុងដើរ ។ តែការដឹងនោះ ព្រះអង្គមិនបានត្រាស់សំដៅយកការដឹងបែបនេះទេ ។ ព្រោះថា ការដឹងបែបនេះ លះ **សត្តូបលទ្ធិ** ( ការប្រកាន់ថាជាសត្វ ) មិនបាន ។ ដក **អត្តសញ្ញា** ( សេចក្ដីសម្គាល់ថា ជាអត្តា ) មិនបាន ។ មិនជា **កម្មដ្ឋាន ឬ សតិប្បដ្ឋានភាវនា** ។

តែការដឹងរបស់ភិក្ខុនេះ លះ **សត្តូបលទ្ធិ** បាន ដក **អត្តសញ្ញា** បាន **ជាកម្មដ្ឋាន ឬ ជាសតិប្បដ្ឋានភាវនា** ។

សេចក្ដីពិត ការដឹងនេះ ព្រះអង្គត្រាស់សំដៅយកការដឹងខ្លួនយ៉ាងនេះថា នរណាដើរ ? ការដើររបស់នរណា ? ដើរបានព្រោះអ្វី ? សូម្បីក្នុងការឈរ ក៏ន័យនេះដូចគ្នា ។

បណ្ដាបទទាំងនោះ បទថា **នរណាដើរ** សេចក្ដីថា មិនមែនសត្វណា ឬបុគ្គលណាដើរ ។

បទថា **ការដើររបស់នរណា** សេចក្តីថា មិនមានការដើររបស់សត្វណា ៗ ឡើយ ។

បទថា **ដើរបានព្រោះអ្វី** សេចក្តីថា ដើរទៅបានព្រោះការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ។

## វាយោធាតុកើតអំពីចិត្ត

ព្រោះដូច្នោះ ភិក្ខុនេះ នឹងដឹងច្បាស់ ( ឥរិយាបថ ) យ៉ាងនេះថា ចិត្ត ( ការគិត ) កើតឡើងថា យើងនឹងដើរ ចិត្តនោះនឹងឲ្យវាយោកើត នឹងឲ្យការកម្រើកវាយោកើត ។ ការកម្រើកកាយទាំងអស់ ទៅខាងមុខដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា **ការដើរ** ។ សូម្បី ក្នុងការឈរជាដើម ក៏មានន័យនេះដូចគ្នា ។

សូម្បីក្នុងការឈរជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ចិត្ត ( ការគិត ) កើតឡើងថា យើងនឹងឈរ ចិត្តនោះនឹងឲ្យវាយោកើត នឹងឲ្យការកម្រើកវាយោកើត ។

ការៈដែលកាយទាំងអស់ តាំងពីទីបំផុត ( គឺ ពីក្បាលដល់ចុងជើង ) ទាញឡើងដោយការផ្សាយនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា **ការឈរ** ។

ចិត្តកើតឡើងថា យើងនឹងអង្គុយ ចិត្តនោះនឹងឲ្យវាយោកើត នឹងឲ្យការកម្រើកវាយោកើត ការបត់កាយចំណែកខាងក្រោមចូល ទាញកាយ

ចំណែកខាងលើឡើង ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា **ការអង្គុយ** ។

ចិត្តកើតឡើងថា យើងនឹងដេក ចិត្តនឹងឲ្យវាយោនោះកើត នឹងឲ្យការកម្រើកវាយោកើត ។ ការសណ្ដូកកាយទាំងអស់ចេញទៅខាងបណ្ដោយ ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា **ការដេក** ។

កាលភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះ រមែងមានការគិតឃើញយ៉ាងនេះថា គេហៅថា **សត្វដើរ សត្វឈរ** ។

សួរថា មានសត្វណាដើរ សត្វណាឈរ ?

ឆ្លើយថា មិនមាន ។

តែដូចពាក្យដែលហៅថា រទេះទៅ រទេះឈប់ ។ ក៏មិនមានអ្វីដែលឈ្មោះថា រទេះនឹងទៅ ឬនឹងឈប់ ។ តែកាលសារថីអ្នកឈ្លាសវៃ ទឹមគោ ៤ បរទៅ ក៏នឹងមានត្រឹមតែការសន្មតិគ្នាថា រទេះទៅ រទេះឈប់យ៉ាងណា ។ កាយដូចរទេះ ព្រោះអត្ថថា មិនដឹង ខ្យល់ដែលកើតអំពីចិត្តដូចគោ , ចិត្ត ដូចសារថី កាលចិត្តកើតឡើងថា យើងនឹងដើរ វាយោ-ធាតុដែលនឹងឲ្យកើតវិញ្ញត្តិ ក៏នឹងកើតឡើង ការដើរទៅជាដើម នឹងប្រព្រឹត្តទៅដោយការផ្សាយរបស់វាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត នឹងមានត្រឹមតែការសន្មតិគ្នាថា សត្វដើរ សត្វឈរ ខ្ញុំទៅ ខ្ញុំឈរ ដូច្នោះដូចគ្នា ។

ទូកស្ទុះទៅបាន ព្រោះកម្លាំងរបស់ខ្យល់ កូនសរស្ទុះទៅបាន ព្រោះកម្លាំងរបស់ខ្សែ យ៉ាងណា រាងកាយនេះក៏ដូច្នោះ ដើរទៅបានព្រោះខ្យល់ (ខាងក្នុង) បក់ ។ សូម្បីសរីរយន្តនេះ ដែល ( នាយជាង គឺ តណ្ហាសាងទុក ) ដើរ ឈរ អង្គុយបាន ដោយអំណាចនៃខ្សែញាក់ គឺចិត្ត, ដូចរូបទីងមោងកម្រើកបាន ដោយអំណាចនៃខ្សែញាក់ ។ ក្នុងរឿងនេះ នឹងមានសត្វណា ក្រៅអំពីហេតុបច្ច័យ ដែលឈរ ឬដើរទៅ ដោយអានុភាពរបស់ខ្លួន ។

ព្រោះដូច្នោះ ព្រះយោគាវចរនោះ កំណត់នូវឥរិយាបថដើរជាដើម ដែលប្រព្រឹត្តទៅ ដោយហេតុ និងបច្ច័យប៉ុណ្ណោះ យ៉ាងនេះ គប្បីជ្រាបចុះថា បុគ្គលនោះ កាលដើរ ក៏ដឹងច្បាស់ថា យើងដើរ ( កាលឈរ អង្គុយ ឬដេក ) ក៏ដឹងច្បាស់ថា យើងឈរ អង្គុយ ឬដេក ។

ពាក្យថា យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា នំ បជានាតិ ( ឬក៏ថា លោករមែងដឹងច្បាស់ កាយនោះ តាមដែលខ្លួនតម្កល់នៅ ដោយអាការយ៉ាងណាៗ ហើយ ) នេះ ជាពាក្យប្រមូលឥរិយាបថគ្រប់យ៉ាងទុក ។

មានពាក្យអធិប្បាយទុកដូចតទៅនេះថា កាយរបស់លោកស្ថិតនៅហើយ ដោយអាការណា ៗ លោកក៏ដឹងច្បាស់កាយនោះ ដោយអាការនោះ ៗ គឺ ដឹងច្បាស់កាយ ដែលស្ថិតនៅដោយអាការដែលដើរថា កំពុង

ដើរ ដឹងច្បាស់កាយ ដែលតាំងនៅដោយអាការដែលឈរ អង្គុយ ឬដេក ថា ( កំពុង ) ដេក ជាដើម ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ឬលោកពិចារណាឃើញកាយក្នុងកាយ ដោយការពិចារណាឥរិយាបថទាំង ៤ របស់ខ្លួនយ៉ាងនេះ ។

បទថា **ពហិទ្ធា វា** សេចក្តីថា ឬដោយការកំណត់ឥរិយាបថទាំង ៤ របស់អ្នកដទៃ ។

បទថា **អជ្ឈត្តពហិទ្ធា វា** សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថទាំង ៤ របស់ខ្លួន ( ឬ ) របស់អ្នកដទៃតាមកាល ។

ចំណែកក្នុងបទថា **សមុទយធម្មានុបស្សី វា** ជាដើម អ្នកសិក្សាគួរនាំយកការកើតឡើង និងការរលត់ទៅនៃរូបខន្ធដោយអាការ ៥ យ៉ាងមក ដោយន័យមានជាអាទិ៍ថា ព្រោះអវិជ្ជាកើត រូបខន្ធទើបកើត ។

ពិតណាស់ ពាក្យថា **សមុទយធម្មានុបស្សី វា** នេះ ក្នុងឥរិយាបថបព្វៈនេះ ព្រះអង្គត្រាស់សំដៅយកពាក្យនោះ ។

ពាក្យថា **អត្ថិ កាយោតិ វា បនស្ស** ជាដើម ក៏ដូចគ្នានឹងពាក្យដែលពោលមកហើយ នោះឯង ។

## អរិយសច្ចក្នុងឥរិយាបថ

តែក្នុងឥរិយាបថបព្វៈនេះ សតិដែលកំណត់ឥរិយាបថទាំង ៤ ជា **ទុក្ខសច្ច** តណ្ហាដែលជាសមុដ្ឋានរបស់សតិជា **សមុទយសច្ច** ការមិន

ប្រព្រឹត្តទៅនៃសតិ និងតណ្ហាទាំង ២ យ៉ាងនោះ ជា **និរោធសច្ច** អរិយ-មគ្គដែលកំណត់ដឹងទុក្ខ លះបង់ **សមុទយ** ដែលមាន **និរោធជាអារម្មណ៍ ជាមគ្គសច្ច** ។

ព្រះយោគាវចរ ខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះ ហើយ នឹងសម្រេចដល់ទីរំលត់ទុក្ខ ( និព្វាន ) ។ ពាក្យដូចដែលពណ៌នាមកនេះ ជាផ្លូវនៃការនាំចេញ ( ចាកទុក្ខ ) រហូតដល់ព្រះអរហត្ត របស់ភិក្ខុអ្នកកំណត់ឥរិយាបថ ៤ មួយរូប ដូច្នេះឯង ។

( ចប់ ឥរិយាបថបព្វៈ )

# ពិចារណាកាយដោយសម្បជញ្ញ ៤

[១៣៥] ព្រះមានព្រះភាគ លុះទ្រង់ចែកនូវការពិចារណាឃើញកាយក្នុងកាយ ដោយឥរិយាបថយ៉ាងនេះហើយ ឥឡូវនេះដើម្បីនឹងទ្រង់ចែកដោយ **សម្បជញ្ញ** ៤ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **បុន ចបរំ** ទុក ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **អភិក្កន្តេ បដិក្កន្តេ** នេះ ការដើរទៅ ព្រះអង្គត្រាស់ហៅថា **អភិក្កន្ត** , ការដើរត្រឡប់ ត្រាស់ហៅថា **បដិក្កន្ត** ។ សូម្បីទាំង ២ យ៉ាងនោះ បានក្នុងឥរិយាបថទាំង ៤ ។

( នឹងថា ) **ក្នុងការដើរមុន** កាលយោកកាយទៅខាងមុខ ក៏ឈ្មោះថា ឈានទៅ ។ កាលបែរត្រឡប់ ក៏ឈ្មោះថា ថយត្រឡប់ ។ សូម្បីក្នុងការឈរ អ្នកឈរនោះឯង កាលយោកកាយទៅខាងមុខ ក៏ឈ្មោះថា ឈានទៅ កាលបែរខ្លួនមកខាងក្រោយ ក៏ឈ្មោះថា ថយត្រឡប់ ។ ក្នុងការអង្គុយ អ្នកអង្គុយនោះឯង កាលបង្អោនខ្លួនទៅខាងមុខ ចំពោះមុខអាសនៈឈ្មោះថា ឈានទៅ កាលយោកពង់កាយផ្អែកខាងក្រោយ ឈ្មោះថា ថយត្រឡប់ ។ សូម្បីក្នុងការដេក ក៏មានន័យនេះដូចគ្នា ។

បទថា **សម្បជានការី ហោតិ** សេចក្ដីថា ជាអ្នកប្រកបកិច្ចគ្រប់យ៉ាងដោយ **សម្បជញ្ញ** ( សេចក្ដីដឹងខ្លួន ) ជាប្រក្រតី ឬជាអ្នកធ្វើសេចក្ដីដឹងខ្លួននោះឯងជាប្រក្រតី ព្រោះថា លោកធ្វើសេចក្ដីដឹងខ្លួន ក្នុងការឈានទៅខាងមុខជាដើម មិនថា ក្នុងឥរិយាបថណា ៗ ក៏មិនវៀរចាក **សម្បជញ្ញ** ។

# សម្បជញ្ញ ៤

សម្បជញ្ញៈក្នុងពាក្យថា **សម្បជានការី** នោះ មាន ៤ យ៉ាង គឺ សាត្ថកសម្បជញ្ញ ១ សប្បាយសម្បជញ្ញ ១ គោចរសម្បជញ្ញ ១ អសម្មោហសម្បជញ្ញ ១ ។

## ១. សាត្ថកសម្បជញ្ញ

បណ្ដាសម្បជញ្ញៈទាំង ៤ យ៉ាងនោះ ការមិនទៅតាមអំណាចនៃការគិត ដែលកើតឡើងនោះឯង ក្នុងកាលគិតនឹងឈានទៅ ការកំណត់ប្រយោជន៍ និងមិនមានប្រយោជន៍ ( ជាមុន ) ថា ការទៅទីនោះនឹងមានប្រយោជន៍ដល់យើង ឬមិនមានប្រយោជន៍ ហើយកាន់យកតែប្រយោជន៍ ឈ្មោះថា **សាត្ថកសម្បជញ្ញ** ។

ក៏បណ្ដា **អត្ថ** និង **អនត្ថ** ( ប្រយោជន៍ និងមិនមែនប្រយោជន៍ ) ទាំង ២ យ៉ាងនោះ ការចម្រើនផ្លូវធម៌ដោយបានឃើញព្រះចេតិយ៍ បានឃើញដើមពោធិ៍ បានឃើញព្រះសង្ឃ បានឃើញព្រះថេរៈ និងបានឃើញ អសុភារម្មណ៍ជាដើម ឈ្មោះថា **អត្ថ** ។ ព្រោះថា សូម្បីបានឃើញព្រះចេតិយ៍ហើយ ញ៉ាំងបីតិដែលមានព្រះពុទ្ធជាអារម្មណ៍ឲ្យកើតឡើងបាន ( និង ) ព្រោះបានឃើញព្រះសង្ឃ ក៏ញ៉ាំងនូវបីតិដែលមានព្រះសង្ឃជាអារម្មណ៍ឲ្យកើតឡើងបាន ហើយកាលពិចារណាអារម្មណ៍នោះឯង ដោយការអស់ទៅ និងសូន្យទៅ ក៏នឹងសម្រេចព្រះអរហត្ត ។ បានឃើញព្រះថេរៈ

ទាំងឡាយហើយ តាំងនៅក្នុងឱវាទរបស់លោក បានឃើញអសុភារម្មណ៍ហើយ ញ៉ាំងបឋមជ្ឈានឲ្យកើតក្នុងអសុភារម្មណ៍នោះឡើងបាន កាលពិចារណាអសុភារម្មណ៍នោះឯង ដោយការអស់ទៅ និងការសូន្យទៅ ក៏នឹងសម្រេចព្រះអរហត្ត ។ ព្រោះដូច្នោះ ការឃើញវត្ថុទាំងនោះ ទើបឈ្មោះថា មានប្រយោជន៍ ។ តែអាចារ្យពួកខ្លះពោលថា ការបម្រើនផ្នែកខាងអាមិស ក៏ឈ្មោះថា ជាប្រយោជន៍ ( ផល ) បាន ដូចគ្នា ព្រោះអាស្រ័យប្រយោជន៍នោះហើយ បានបដិបត្តិ ( ធម៌ ) ដើម្បីអនុគ្រោះព្រហ្មចរិយៈ ។

## ២. សប្បាយសម្បជញ្ញ

ចំណែកការកំណត់ **សប្បាយ** និង **អសប្បាយ** ( សេចក្ដីសប្បាយ ឬមិនសប្បាយ ) ក្នុងការដើរនោះ ហើយកំណត់យក **សប្បាយ** ឈ្មោះថា **សប្បាយសម្បជញ្ញ** ។

បានដល់អ្វី ?

បានដល់ ការឃើញព្រះចេតិយ៍ ឈ្មោះថា មានប្រយោជន៍ ក៏បើបរិស័ទប្រជុំគ្នារយៈ ១០ ឬ ១២ យោជន៍ ដើម្បីបូជាមហាចេតិយ៍ ជាការប្រជុំធំ ស្ត្រីខ្លះ បុរសខ្លះ តែងខ្លួនដោយគ្រឿងប្រដាប់តាមសមគួរដល់សម្បត្តិរបស់ខ្លួន ( តាមឋានានុរូប ) ដើរជាមួយគ្នាទៅ ដូចភាពវិចិត្រកម្ម ( រូបគំនូរ ) សោត លោកក៏នឹងកើតចំណង់ ( លោភៈ ) ក្នុង **ឥដ្ឋារម្មណ៍** នោះ នឹងកើតការទាស់ចិត្តក្នុង **អនិដ្ឋារម្មណ៍** នឹងកើតសេចក្ដីវង្វេងឡើង ក្នុងការ

មើលមិនសមរម្យ ។ នឹងត្រូវអាបត្តិ **កាយសំសគ្គ** ( ចាប់ពាល់កាយស្ត្រី ) ឬនឹងមានអន្តរាយដល់ជីវិត និងព្រហ្មចរិយៈ ។ ស្ថានទីដូចដែលពណ៌នាមកនេះ ឈ្មោះថា ជា **អសប្បាយ** ។ សូម្បីការឃើញព្រះសង្ឃ ដែលជា **សប្បាយ** ឈ្មោះថា មានប្រយោជន៍ ព្រោះមិនមានអន្តរាយ មានប្រការដូចដែលពោលមកហើយ ។

តែបើកាលមនុស្សនាំគ្នាសាងបារាំធំ ទុកខាងក្នុងភូមិហើយ ស្តាប់ធម្មទេសនារហូតមួយយប់ ការប្រជុំរបស់ប្រជាជន និងអន្តរាយ ក៏នឹងមានដោយប្រការដូចដែលពោលមកហើយ នោះឯង ។ ស្ថានទីដូចពោលមកហើយនេះ ជាអសប្បាយៈ ( តែ ) ជាសប្បាយៈបាន ព្រោះមិនមានអន្តរាយ សូម្បីក្នុងការឃើញព្រះថេរៈទាំងឡាយអ្នកមានបរិស័ទច្រើន ក៏មានន័យនេះដូចគ្នា ។ សូម្បីការឃើញអសុភារម្មណ៍ ក៏ឈ្មោះថា មានប្រយោជន៍ ។ នឹងមានរឿងដូចតទៅនេះ ជាការសម្តែងសេចក្តីនោះ ( ជាតួយ៉ាង ) ៖

## រឿងភិក្ខុកំលោះ

តំណាលមកថា ភិក្ខុកំលោះមួយរូប នាំសាមណេរទៅរកឈើជម្រះធ្មេញ ។ សាមណេរគេចចេញអំពីផ្លូវ ដើរហួសទៅមុខឃើញ **អសុភារម្មណ៍** ហើយញុំាងបឋមជ្ឈានឲ្យកើតឡើង ធ្វើបឋមជ្ឈាននោះឯងឲ្យជាបាទ **ពិចារណាសង្ខារ** ធ្វើផលទាំង ៣ ឲ្យជាក់ច្បាស់ហើយ បានឈរកំណត់កម្មដ្ឋាន ដើម្បីផលប្រយោជន៍ដល់មគ្គជាន់ខ្ពស់ ( អរហត្តមគ្គ ) ។

ភិក្ខុកំលោះ កាលមិនឃើញសាមណេរនោះ ទើបស្រែកហៅថា សាមណេរ ។ សាមណេរនោះគិតថា តាំងអំពីបួសហើយ យើងមិនដែលឲ្យភិក្ខុហៅដល់ ២ ដងឡើយ យើងនឹងឲ្យគុណវិសេសជាន់ខ្ពស់កើតឡើង ក្នុងថ្ងៃដទៃចុះ ដូច្នេះហើយ ទើបឆ្លើយថា មានការអ្វីលោកម្ចាស់ ? ហើយ សាមណេរនោះ ដែលភិក្ខុកំលោះប្រាប់ថា មកណេះសាមណេរ ត្រឹមតែពាក្យមួយម៉ាត់ប៉ុណ្ណោះ ក៏មក ហើយបាននិយាយថា លោកម្ចាស់ សូមមេត្តាដើរទៅតាមផ្លូវនេះសិន ហើយឈរបែរមុខសម្លឹងមើលទៅទិសខាងកើតមួយសន្ទុះ ក្នុងឱកាសដែលខ្ញុំឈរ ។ លោកបានធ្វើតាមសាមណេរនោះ ហើយបានសម្រេចគុណវិសេស ដែលសាមណេរនោះបានសម្រេចហើយ ។ អសុភា-រម្មណ៍មួយ បានកើតប្រយោជន៍ដល់បុគ្គល ២ នាក់ ដូចដែលពណ៌នាមកនេះ ។

ក៏អសុភារម្មណ៍នេះ សូម្បីនឹងមានប្រយោជន៍ដូចដែលពណ៌នាមកនេះ ( តែ ) **អសុភារម្មណ៍ គឺ ស្ត្រី** ក៏ជា **អសប្បាយរបស់បុរស** ហើយ **អសុភារម្មណ៍ គឺ បុរស** ក៏ជា **អសប្បាយរបស់ស្ត្រី** ។ អសុភារម្មណ៍ដែលជាសភាគៈនឹងគ្នាប៉ុណ្ណោះ ទើបនឹងជា **សប្បាយ** ព្រោះដូច្នោះ **ការកំណត់សប្បាយ** យ៉ាងនេះ ឈ្មោះថា **សប្បាយសម្បជញ្ញ** ។

## ៣. គោចរសម្បជញ្ញ

តែការរៀនយក **គោចរ** ពោលគឺ កម្មដ្ឋានដែលជាទីពេញចិត្តរបស់

ខ្លួន ក្នុងចំនួនកម្មដ្ឋាន ៣៨ ប្រការ ហើយទទួលយកកម្មដ្ឋាននោះ ដើរទៅក្នុងទីគោចរដើម្បីភិក្ខាចារ ឈ្មោះថា **គោចរសម្បជញ្ញ** សម្រាប់អ្នកមានសប្បាយៈដែលមានប្រយោជន៍ ដែលកំណត់ហើយយ៉ាងនេះ ។

ដើម្បីសេចក្ដីជាក់ច្បាស់នៃ **គោចរសម្បជញ្ញ** នោះ អ្នកសិក្សាគួរជ្រាប **សម្បជញ្ញ ៤ ពួក** ដូចតទៅនេះ គឺ ភិក្ខុរូបខ្លះក្នុងសាសនានេះ នាំទៅ មិននាំត្រឡប់ , រូបខ្លះមិននាំទៅ មិននាំត្រឡប់ , រូបខ្លះទាំងនាំទៅ ទាំងនាំត្រឡប់ ។

## ភិក្ខុនាំទៅ មិននាំត្រឡប់

បណ្ដាភិក្ខុទាំង ៤ ពួកនោះឯង ភិក្ខុរូបណា ជម្រះចិត្តឲ្យផូរផង់ចាក **នីវរណធម៌** ដោយការបង្ក្រម ដោយការអង្គុយរហូតមួយថ្ងៃ រហូតបឋមយាមនៃរាត្រីក៏ដូច្នោះ ក្នុងមជ្ឈិមយាម លោកសឹង សូម្បីក្នុងបច្ឆិមយាម ក៏ឲ្យវេលាកន្លងទៅដោយការអង្គុយ ការបង្ក្រម នឹងពោលទៅថា ដល់ការនឹងធ្វើវត្ត ទីលានព្រះចេតិយ៍ លានព្រះពោធិព្រឹក្ស និងស្រោចទឹកដើមពោធិ៍ និងតម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ទុក សមាទានបដិបត្តិវត្តក្នុងគម្ពីរខន្ធកៈគ្រប់យ៉ាង មានអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម លោកធ្វើធុរៈទាក់ទងនឹងរាងកាយហើយ ចូលទៅកាន់ទីអង្គុយ ទីដេក និងអង្គុយពែនភ្នែន ចម្រើនកម្មដ្ឋាន ក្រោកឡើងក្នុងវេលាភិក្ខាចារ កាន់យកបាត្រ និងចីវរចេញអំពីសេនាសនៈ មនសិការកម្មដ្ឋានដោយ មាតិកាកម្មដ្ឋាន

នោះឯង ដើរទៅកាន់លានព្រះចេតិយ៍ ប្រសិនបើមានព្រះកម្មដ្ឋាន មាន ពុទ្ធានុស្សតិជាអារម្មណ៍សោត ក៏កុំបោះបង់កម្មដ្ឋាននោះចោល ចូលទៅ កាន់លានព្រះចេតិយ៍ ។ បើមានកម្មដ្ឋានយ៉ាងដទៃ គួរបញ្ឈប់កម្មដ្ឋាន នោះទុក ដូចយកដៃចាប់វត្ថុដាក់ទុកលើជើងជណ្តើរ ហើយកំណត់បីតិ មាន ព្រះពុទ្ធជាអារម្មណ៍ ឡើងទៅកាន់លានព្រះចេតិយ៍ ( បើ ) ចេតិយ៍ធំ គួរ ធ្វើប្រទក្សិណ ៣ ជុំហើយ ថ្វាយបង្គំទិសទាំង ៤ ( បើ ) ចេតិយ៍តូច គួរ ធ្វើប្រទក្សិណយ៉ាងនោះដូចគ្នា ហើយថ្វាយបង្គំទិសទាំង ៨ ។ លុះថ្វាយ បង្គំព្រះចេតិយ៍ហើយ ទៅដល់លានព្រះពោធិព្រឹក្ស គួរធ្វើវត្តកិច្ចព្រះ ពោធិព្រឹក្ស សម្តែងសេចក្តីកោតក្រែង ដូចនៅចំពោះព្រះភក្ត្រព្រះមាន-ព្រះភាគជាម្ចាស់ ។ លោកថ្វាយបង្គំព្រះចេតិយ៍ និងដើមពោធិព្រឹក្ស យ៉ាងនេះហើយ ទៅកាន់ទីដែលខ្លួនបន្ទាក់កម្មដ្ឋានទុក ទទួលយកកម្មដ្ឋាន ដែលបន្ទាក់ទុក ( រក្សាទុកបណ្តោះអាសន្ន ) ដូចយកដៃចាប់យកវត្ថុដែល ខ្លួនរក្សាទុក ដូច្នោះ ហើយឃ្លុំចីវរក្នុងទីជិតស្រុក ដោយមានកម្មដ្ឋានជា សំខាន់នោះឯង ចូលទៅស្រុកដើម្បីបិណ្ឌបាត ។

លុះមនុស្សទាំងឡាយ ឃើញលោកហើយ បានប្រាប់គ្នាថា លោក ម្ចាស់របស់យើងមកហើយ នាំគ្នាក្រោកទទួលលោក ទទួលយកបាត្រ និង ឲ្យលោកគង់លើសាលាឆាន់ ឬលើផ្ទះ ថ្វាយយាគូ លាងជើង លាបដោយ ប្រេងថ្វាយដល់លោក លុះលោកធ្វើភត្តកិច្ចស្រេចហើយ នាំគ្នាអង្គុយ ខាងមុខ ខ្លះក៏សួរបញ្ហា ខ្លះក៏ត្រូវការស្តាប់ធម៌ ។ តែបើគេនឹងឲ្យសម្តែង

( ធម្មកថា ) ព្រះអដ្ឋកថាចារ្យពោលទុកថា ដែលឈ្មោះថា ធម្មកថា គួរសម្តែងដោយពិត ដើម្បីសង្គ្រោះប្រជាជន ។ ព្រោះដែលឈ្មោះថា ធម្មកថា ក្រៅចាកកម្មដ្ឋានមិនមាន ព្រោះដូច្នោះ លុះលោកសម្តែង ធម៌ ដោយមានកម្មដ្ឋានជាសំខាន់នោះឯង ឆាន់អាហារ ដោយមានកម្មដ្ឋានជាសំខាន់នោះឯង ធ្វើអនុមោទនាហើយ កាលគេឲ្យត្រឡប់ ក៏ឲ្យត្រឡប់តាមគេទៅ ក៏ត្រឡប់ក្នុងទីនោះឯង ទើបធ្វើដំណើរតទៅ ។ លុះសាមណេរ និងភិក្ខុកំលោះដែលចេញទៅមុន ឆាន់ស្រេចហើយ ឃើញលោក ទើបនាំគ្នាទៅទទួលបាត្រ និងចីវររបស់លោក ។

បានជ្រាបថា ភិក្ខុចាស់មើលមុខ ឃើញថា មិនមែនឧបជ្ឈាយាចារ្យរបស់ខ្លួនហើយ ធ្វើ ( អាគន្តុកៈ ) វត្ត តែធ្វើតាមកំណត់ដែលមកជួបគ្នាប៉ុណ្ណោះ ។ ភិក្ខុទាំងនោះនឹងសួរលោកថា បុគ្គលទាំងនោះជាអ្វីនឹងលោក ទាក់ទងគ្នាខាងញោមស្រី ឬខាងចំណែកញោមប្រុស ?

លោកនឹងឆ្លើយថា ពួកលោកឃើញអ្វី ទើបសួរ ?

សាមណេរ និងភិក្ខុកំលោះទាំងនោះ ប្រាប់ថា បុគ្គលទាំងនោះមានសេចក្តីស្រឡាញ់រាប់អានចំពោះខ្ញុំព្រះករុណាយ៉ាងខ្លាំង ។

លោកម្ចាស់ វត្តណាសូម្បីតែញោមស្រី ញោមប្រុស ( របស់ខ្ញុំ ) ក៏ធ្វើបានលំបាក អ្នកទាំងនោះធ្វើរបស់នោះឲ្យខ្ញុំ សូម្បីបាត្រ និងចីវររបស់ខ្ញុំ ក៏ជារបស់អ្នកទាំងនោះ ដូចគ្នា ( ថ្វាយ ) ដោយអានុភាពរបស់អ្នកនោះ កាលមានភ័យ ខ្ញុំក៏មិនស្គាល់ភ័យឡើយ កាលមានសេចក្តីស្រេក

ឃ្លាន ខ្ញុំក៏មិនស្គាល់ ការស្រែកឃ្លាន ដែលឈ្មោះថា ពួកជនអ្នកមាន ឧបការៈដល់ខ្ញុំ ដូច្នេះ នឹងមិនមាន លោកនិយាយដល់គុណរបស់មនុស្ស ទាំងនោះ យ៉ាងនេះ ដើរទៅ ភិក្ខុនេះលោកហៅថា ឈ្មោះថា **នាំទៅ មិននាំត្រឡប់** ។

## ភិក្ខុមិននាំទៅ មិននាំត្រឡប់

តែថានឹងពោលថ្វីដល់ ភិក្ខុមិននាំទៅ មិននាំត្រឡប់ កាលភិក្ខុណា ធ្វើវត្តបដិបត្តិ មានប្រការដូចដែលពោលមកហើយ តេជៈដែលកើតអំពីកម្ម នឹងសម្តែងចេញ និងលែង **អនុបាទិន្នកសង្ខារ** ចាប់យក **ឧបាទិន្នក-សង្ខារ** ញើសនឹងហូរចេញអំពីរាងកាយ នឹងមិនឡើងកាន់វិថីនៃកម្មដ្ឋាន ។ នឹងចាំបាច់ពោលថ្វី សូម្បីភិក្ខុនោះនឹងកាន់យកបាត្រ និងចីវរ នឹងប្រញាប់ទៅថ្វាយបង្គំព្រះចេតិយ ចូលស្រុកដើម្បីបាយយាគូ និងភិក្ខាក្នុងវេលា ដែលគោទាំងឡាយចេញទៅ ( រកស៊ី ) នោះឯង បានបាយយាគូហើយ ទៅកាន់អាសនៈសាលា ( រោងឆាន់ ) ហើយឆាន់ ។ ខាងក្រោយដោយ ហេតុត្រឹមតែការឆាន់បាយយាគូ ២-៣ ម៉ាត់របស់លោក ប៉ុណ្ណោះ តេជៈ ( ភាពក្តៅ ) ដែលកើតអំពីកម្ម នឹងលែង **ឧបាទិន្នកសង្ខារ** ចាប់យក **អនុបាទិន្នកសង្ខារ** ។ លោកនឹងរំលត់ ការក្រវល់ក្រវាយដែលកើតអំពី **តេជោធាតុ** ដូចងូតទឹកមួយរយឆ្នាំង ឆាន់បាយយាគូ ដោយមានកម្មដ្ឋានជា សំខាន់ លាងបាត្រ និងខ្ពុរមាត់ហើយ មនសិការកម្មដ្ឋានក្នុងរវាងកត្ត ត្រាច់

ទៅបិណ្ឌបាតក្នុងទីដ៏សេស ឆាន់អាហារ ដោយមានកម្មដ្ឋានជាសំខាន់ តាំងពីនោះទៅ នឹងទទួលយកកម្មដ្ឋាន ដែលប្រាកដឡើងជាប់តគ្នាទៅ ហើយដើរទៅ ភិក្ខុនេះហៅថា **មិននាំទៅ ប៉ុន្តែនាំត្រឡប់** ។ ក៏ដែលឈ្មោះថា ភិក្ខុទាំងឡាយអ្នកឆាន់យាគូ ប្រារព្ធវិបស្សនា ហើយសម្រេចព្រះអរហត្តក្នុងព្រះពុទ្ធសាសនាដូច្នេះ រាប់ចំនួនមិនបាន ។ ក្នុង **កោះសីហឡ:** នោះឯង លើអាសនសាលា អាសនៈសម្រាប់អង្គុយឆាន់យាគូ ក៏មិនមានភិក្ខុដែលឆាន់យាគូហើយ សម្រេចអរហត្ត ក៏មិនមាន ។ ប៉ុន្តែភិក្ខុណាជាអ្នករស់នៅដោយការប្រមាទជាប្រក្រតី បោះបង់ចោលធុរៈ ទម្លាយវត្តគ្រប់យ៉ាង មានចិត្តជាប់ជំពាក់នឹង **ចេតោខីលធម៌ ៥ ប្រការ** មិនធ្វើសញ្ញាទុកខ្លះថា ដែលឈ្មោះថា កម្មដ្ឋានមាន ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ត្រាច់ទៅប្រឡូកប្រឡំ ដោយការប្រឡូកប្រឡំនឹងគ្រហស្ថ ដែលមិនសមគួរនឹងឆាន់ ( មានបាត្រ ) ទទេចេញទៅ ភិក្ខុនេះហៅថា **មិននាំទៅ និងមិននាំត្រឡប់** ។

## ភិក្ខុទាំងនាំទៅ ទាំងនាំត្រឡប់

ចំណែកភិក្ខុនេះណា ដែលពោលថា នាំទៅផង នាំត្រឡប់ផង ភិក្ខុនោះ គប្បីជ្រាបបានដោយគតប្បច្ចាគតិវត្ត របស់ភិក្ខុអ្នកដើរត្រឡប់ទៅត្រឡប់មក ព្រោះថា កុលបុត្រទាំងឡាយអ្នកប្រាថ្នាប្រយោជន៍ បួសក្នុងសាសនាហើយ កាលនឹងនៅដោយម្នាក់ឯងចំនួន ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ

៥០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ នៅដោយធ្វើកតិកាវត្តទុកថា លោកម្ចាស់ទាំងឡាយ មិនមែនបួសគេចបំណុល មិនមែនបួសគេចភ័យ មិនមែនបួសចិញ្ចឹមជីវិត ប៉ុន្តែប្រាថ្នានឹងរួចផុតចាកទុក្ខ ទើបបានបួសក្នុងព្រះពុទ្ធសាសនានេះ ព្រោះដូច្នោះ ក្នុងខណៈដើរនោះឯង លោកទាំងឡាយចូរគ្របសង្កត់កិលេសដែលកើតឡើងក្នុងវេលាដើរ ក្នុងខណៈឈរ ក៏គ្របសង្កត់កិលេសដែលកើតឡើងក្នុងវេលាឈរ ក្នុងខណៈអង្គុយ ក៏ចូរគ្របសង្កត់កិលេសដែលកើតឡើងក្នុងវេលាអង្គុយ ក្នុងខណៈដេកនោះឯង ក៏ចូរគ្របសង្កត់កិលេសដែលកើតឡើងក្នុងវេលាដេក ។ ភិក្ខុទាំងនោះ លុះធ្វើកតិកាវត្តទុកយ៉ាងនេះហើយ កាលត្រាច់ទៅភិក្ខាចារ ក៏ដើរទៅ មានមនសិការកម្មដ្ឋានតាមសញ្ញានោះ ប្រសិនបើកិលេសកើតឡើងដល់នរណា ក្នុងខណៈដើរក្នុងរវាងកន្លះឧសភៈ មួយឧសភៈ កន្លះគាវុត ឬមួយគាវុត មានដុំថ្មភិក្ខុនោះនឹងគ្របសង្កត់កិលេសនោះ ក្នុងទីនោះឯង កាលមិនអាច ( គ្របសង្កត់បាន ) ដូច្នោះ ក៏នឹងឈប់ ឈរ ។ បន្ទាប់ពីនោះ ភិក្ខុ ( រូបដទៃ ) សូម្បីតាមពីក្រោយលោកមក ក៏នឹងឈប់ ឈរតាមលោក នឹងដាស់តឿនខ្លួនឯងថា ភិក្ខុនេះដឹងវិតក្កៈដែលកើតដល់យើង សេចក្តីនេះមិនសមគួរដល់លោកទេ ហើយចម្រើនវិបស្សនា ឈានចុះកាន់អរិយភូមិក្នុងទីនោះនុ៎ះឯង ក្នុងពាក្យថា **កាលមិនអាចយ៉ាងនោះ** លោកក៏នឹងអង្គុយ បន្ទាប់ពីនោះ ភិក្ខុអ្នកមកខាងក្រោយ លោកក៏នឹងអង្គុយតាម ក៏មានន័យនោះដូចគ្នា ។ សូម្បីមិនអាចឈានចុះកាន់អរិយភូមិបាន ក៏នឹងគ្របសង្កត់កិលេស

នោះទុក ដើរមនសិការតែម្យ៉ាង មិនលើកជើងឡើង ទាំងដែលមានចិត្តប្រាសចាកកម្មដ្ឋាន បើលើក ( ដោយមានចិត្តប្រាសចាកកម្មដ្ឋាន ) ក៏នឹងត្រឡប់ទៅកាន់កន្លែងដើមនោះឯង ដូច **មហាបុស្សទេវត្ថេរ** អ្នកស្រុក **អាលិន្ទកៈ** ។

## រឿងព្រះមហាបុស្សទេវត្ថេរ

តំណាលមកថា លោកបានបំពេញ **គតប្បច្ចាគតិកវត្ត** ( វត្តរបស់អ្នកដើរត្រឡប់ទៅ ត្រឡប់មក) នៅកន្លែងតែមួយ អស់វេលា ១៩ វស្សា ។ បានឮថា សូម្បីមនុស្សទាំងឡាយកំពុងភ្ជួរ កំពុងសាបព្រោះ កំពុងប្របាច់ធ្វើការជាមួយគ្នា ឃើញព្រះថេរៈដើរយ៉ាងនោះ ទើបសន្ទនាគ្នាថា ព្រះថេរៈរូបនេះដើរត្រឡប់ទៅ ត្រឡប់មក គង់នឹងវង្វេងផ្លូវ ឬភ្លេចអ្វីទេដឹង ? លោកមិនយកចិត្តទុកដាក់ក្នុងពាក្យទាំងនោះ ធ្វើសមណធម៌ ដោយទាំងចិត្តដែលប្រកបដោយកម្មដ្ឋាននោះឯង បានសម្រេចអរហត្ត ខាងក្នុងវស្សាទី ២០ ។ ក្នុងថ្ងៃដែលលោកបានសម្រេចព្រះអរហត្តនោះឯង ទេវតាដែលស្ថិតនៅខាងចុងផ្លូវចង្ក្រមរបស់លោក បានឈរលើកម្រាមដៃជំនួសប្រទីប សូម្បី **មហារាជទាំង ៤ សក្កទេវរាជ** និង **សហម្បតីព្រហ្ម** ក៏បាននាំគ្នាមកកាន់សម្នាក់របស់ ( លោក ) ។ **ព្រះវនវាសីតិស្សមហាថេរ** ឃើញពន្លឺនោះហើយ ក្នុងថ្ងៃទី ២ ទើបបានសួរ **មហាបុស្សត្ថេរ** អ្នកស្រុកអាលិន្ទកៈថា វេលារាត្រី ក្នុងសម្នាក់របស់លោក បានមានពន្លឺ ពន្លឺនុ៎ះជា

ពន្លឺអ្វី ? ព្រះថេរៈកាលនឹងពោលបន្តប់សេចក្តី ទើបបាននិយាយពាក្យមានជាអាទិ៍យ៉ាងនេះថា ធម្មតាពន្លឺ ក៏គង់ជាពន្លឺរបស់ប្រទីបខ្លះ ជាពន្លឺរបស់កែវមុនីខ្លះ ។ តមកលោកបញ្ជាក់ **ព្រះវនវាសីតិស្ស មហាថេរ** ថា លោកចូរបិទបាំងទុក ដឹងថា លោកទទួលពាក្យហើយ ទើបប្រាប់ ។ ដូច **ព្រះមហានាគត្ថេរ** អ្នកស្រុក **កាលវល្លិមណ្ឌប** ។

## រឿងព្រះមហានាគត្ថេរ

បានជ្រាបថា សូម្បីព្រះថេរៈរូបនោះ កាលបំពេញគតប្បច្ចាគតិកវត្ត បានអធិដ្ឋានចង្រ្កមតែម្យ៉ាង អស់វេលា ៧ ឆ្នាំ ថា យើងនឹងបូជាសេចក្តីព្យាយាម ដ៏ធំក្រៃលែងរបស់ព្រះមានព្រះភាគជាម្ចាស់ជាបឋមមុន បានបំពេញគតប្បច្ចាគតិកវត្ត ១៦ ឆ្នាំទៀត ទើបបានសម្រេចព្រះអរហត្ត លោកមានចិត្តប្រកបដោយព្រះកម្មដ្ឋាននោះឯង លើកជើងឡើងថយត្រឡប់ ក្នុងខណៈលើក ( ជើង ) ឡើង ដោយចិត្តប្រាសចាកកម្មដ្ឋាន ដើរទៅជិតស្រុក ឈរឃ្លុំចីវរក្នុងទីដែលធ្វើឲ្យមនុស្សសង្ស័យថា មេគោ ឬភិក្ខុ ? ប្រើទឹកអំពីទីចន្លោះដើមជ្រៃ លាងបាត្រ ហើយក៏បៀមទឹកទុកក្នុងមាត់ ។ ព្រោះហេតុអ្វី ? ព្រោះលោកគិតថា សូមយើងកុំបានបោះបង់ចោលកម្មដ្ឋាន សូម្បីដោយហេតុដែលនិយាយនឹងមនុស្ស ដែលមកថ្វាយភិក្ខា ឬមនសិការថា សូមមានអាយុយឺនយូរចុះ ។ តែ ( បើ ) ត្រូវសួរដល់ថ្ងៃថា ថ្ងៃនេះជាថ្ងៃអ្វី លោកម្ចាស់ ឬសួរចំនួនភិក្ខុ សួរបញ្ហា ក៏នឹងលេបទឹក ហើយ

ប្រាប់ ប្រសិនបើមិនមានអ្នកសួរដល់ថ្ងៃជាដើម វេលាចេញទៅ ក៏ខ្ចាទឹកចេញ ( អំពីមាត់ ) ត្រង់ខ្លោងទ្វារស្រុកហើយ ទើបទៅជួបភិក្ខុ ៥០ រូប ដែលចាំវស្សាឯ កលម្ពតិត្ថវិហារ ។

# រឿងភិក្ខុ ៥០ រូប

បានឮមកថា ក្នុងថ្ងៃ អាសាឡ្ហបុណ្ណមី ( ពាក់កណ្ដាលខែ ៨ ) លោកទាំងនោះ បានធ្វើកតិកាវត្តទុកថា បើពួកយើងមិនទាន់សម្រេចព្រះអរហត្តទេ នឹងមិននិយាយជជែកគ្នា ។ ហើយកាលនឹងចូលកាន់ស្រុកបិណ្ឌបាត ( មួយរូប ៗ ) ក៏បៀមទឹកហើយ ទើបចូលទៅ កាលត្រូវសួរដល់ថ្ងៃជាដើម ក៏បដិបត្តិដូចដែលពោលមកហើយនោះឯង ។ មនុស្សទាំងឡាយឃើញស្នាមខ្ចាទឹក ក្នុងទីនោះហើយ ក៏ដឹងថា ថ្ងៃនេះភិក្ខុមកមួយរូប ថ្ងៃនេះមក ២ រូប ទើបគិតគ្នាយ៉ាងនេះថា លោកទាំងនេះមិននិយាយរកចំពោះតែពួកយើង ឬយ៉ាងណា ? ឬសូម្បីពួកគ្នាលោកក៏មិននិយាយដែរ ? ប្រសិនបើលោកមិននិយាយគ្នា លោកនឹងវិវាទគ្នា ជាពិតប្រាកដ ណ្ហើយចុះ យើងទាំងឡាយនឹងឲ្យលោកសូមខមាទោសគ្នា គ្រប់អង្គ ទើបនាំគ្នាទៅវត្ត ក៏មិនបានឃើញព្រះភិក្ខុក្នុងទីតែមួយ ដល់ ២ រូប ក្នុងចំនួនភិក្ខុ ៥០ រូប ។ តមក បណ្ដាមនុស្សទាំងឡាយនោះ អ្នកមានបញ្ញាល្អ ក៏និយាយថា អ្នកទាំងឡាយអើយ មនុស្សឈ្លោះប្រកែកគ្នានឹងមិនមានឱកាស ដូច្នេះ លានព្រះចេតិយ៍ លានព្រះពោធិព្រឹក្ស ក៏បោស

យ៉ាងស្អាត អំបោសក៏រក្សាទុកយ៉ាងល្អ ទឹកឆាន់ ទឹកប្រើប្រាស់ ក៏ចាត់ចែងទុកយ៉ាងល្អ ។ តពីនោះ ពួកមនុស្សទាំងនោះ ក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ ។ ក្នុងខាងក្នុងព្រះវស្សានោះឯង ព្រះភិក្ខុសូម្បីទាំងនោះ ក៏សម្រេចអរហត្តក្នុងថ្ងៃ **មហាបវារណា** ទើបបវារណាគ្នាដោយ **វិសុទ្ធិបវារណា** ។ ភិក្ខុមានចិត្តប្រកបដោយកម្មដ្ឋាននោះឯង លើកជើងឡើង ( ដើរទៅ ) សូម្បីជិតដល់ស្រុកហើយ បៀមទឹកទុកក្នុងមាត់ ពិចារណាមើលផ្លូវច្រើនខ្សែ ដែលមិនមានមនុស្សឈ្លោះគ្នា មិនមានអ្នកលេងសុរា និងអ្នកលេងល្បែងក្ដាលជាដើម ឬមិនមានដំរីកាច សេះកាចជាដើម ហើយដើរទៅផ្លូវនោះ ដូច **ព្រះនាគត្ថេរ** អ្នកស្រុក **កាលវល្លិមណ្ឌប** និងដូចភិក្ខុចាំវស្សាក្នុង **កលម្ពតិត្ថវិហារ** ដូចដែលបានពណ៌នាមកនេះ លោកកាលនឹងត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនោះ ក៏មិនដើរលឿន ដូចមនុស្សប្រញាប់ប្រញាល់ ។ ព្រោះថា មិនមានធុតង្គអ្វី ដែលមានឈ្មោះថា ជាធុតង្គសម្រាប់អ្នកដើរបិណ្ឌបាតលឿន ។ តែថា ដើរមិនគ្រលែងកាយ ដូចរទេះផ្ទុកទឹកពេញ ( ទៅ ) ដល់ផ្ទៃដីដែលរាបស្មើ ។ ហើយចូលទៅតាមលំដាប់ផ្ទះ ( ឈរ ) រង់ចាំពេលវេលាដ៏សមគួរដើម្បីសង្កេតមើលថា គេប្រាថ្នានឹងថ្វាយ ( ដាក់បាត្រ ) ឬមិនប្រាថ្នានឹងថ្វាយ ទទួលភិក្ខាហើយ ( នៅ ) ក្នុងស្រុក ឬក្រៅស្រុក ឬមកកាន់វិហារនោះឯង អង្គុយក្នុងឱកាសដែលសមគួរតាមសប្បាយហើយ មនសិការកម្មដ្ឋាន កំណត់បដិកូលសញ្ញាក្នុងអាហារ ពិចារណាដោយការប្រៀបធៀបនឹងប្រេងបន្តក់ភ្លៅរទេះ

សំពត់រុំជំពៅ និងសាច់កូន នាំអាហារដែលប្រកបដោយអង្គ ៨ មក ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងប្រដាប់តាក់តែង ដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឲ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ នឹងឆាន់ហើយ រៀបចំទុកដាក់ទឹក (ឆាន់,លាង) ជាស្រេច រំងាប់សេចក្តីលំបាកដែលកើតអំពីអាហារ (ស្រវឹងបាយ) មួយរំពេច ទើបមនសិការកម្មដ្ឋាននោះឯង ក្នុងវេលាក្រោយពីឆាន់ ដូចវេលាមុនឆាន់ ក្នុងវេលាបច្ឆិមយាម ដូចវេលាបឋមយាម ។ ភិក្ខុរូបនេះ ហៅបានថា **ទាំងនាំទៅ និងនាំ ត្រឡប់** ។

ក៏លោកកាលបំពេញ **គតប្បច្ចាគតិកវត្ត** ពោលគឺ ការនាំទៅ និងនាំត្រឡប់នេះ បើមានឧបនិស្ស័យសម្បូណ៌សោត ក៏នឹងសម្រេចអរហត្តក្នុងបឋមយាមនោះឯង ប្រសិនបើមិនសម្រេចក្នុងបឋមយាម តទៅក៏នឹងសម្រេចក្នុងមជ្ឈិមយាម ប្រសិនបើក្នុងមជ្ឈិមយាមមិនសម្រេច តទៅនឹងសម្រេចក្នុងមរណសម័យ ប្រសិនបើក្នុងមរណសម័យមិនសម្រេច តទៅក៏នឹងជាទេវបុត្រហើយសម្រេច ប្រសិនបើជាទេវបុត្រក៏នៅមិនបានសម្រេចកាលព្រះពុទ្ធជាម្ចាស់ស្តេចមិនទាន់ឧប្បត្តិ នឹងកើតឡើង ក៏ធ្វើឲ្យជាក់ច្បាស់នូវ **បច្ចេកពោធិញ្ញាណ** បើមិនធ្វើឲ្យជាក់ច្បាស់ជា **បច្ចេកពោធិញ្ញាណ** តទៅនឹងជាអ្នកត្រាស់ដឹងដោយឆាប់រហ័ស (ខិប្បាភិញ្ញាបុគ្គល) ចំពោះព្រះភក្ត្ររបស់ **ព្រះពុទ្ធជាម្ចាស់ទាំងឡាយ** ដូច **ព្រះពាហិយទារុចីរិយត្ថេរ** , នឹងមានបញ្ញាច្រើនដូច **ព្រះសារីបុត្រ** និងមានឫទ្ធិច្រើនដូច **ព្រះមហា-មោគ្គល្លានត្ថេរ** និងជាអ្នកប្រាប់ធុតង្គដូច **ព្រះមហាកស្សបត្ថេរ** និងជាអ្នក

មានទិព្វចក្ខុដូច **ព្រះអនុរុទ្ធត្ថេរ** និងជាព្រះវិន័យធរដូច **ព្រះឧបាលិត្ថេរ** និងជាព្រះធម្មថិកដូច **ព្រះបុណ្ណមន្តានីបុត្រត្ថេរ** និងជាអ្នកនៅព្រៃជាប្រចាំដូច **ព្រះរេវតត្ថេរ** និងជាពហុស្សូតដូច **ព្រះអានន្ទត្ថេរ** ឬនឹងជាអ្នកប្រាថ្នាការសិក្សាដូច **ព្រះរាហុលត្ថេរពុទ្ធបុត្ត** ដូច្នេះ ។

ភិក្ខុអ្នកនាំទៅ និងនាំត្រឡប់ក្នុង ៤ វារៈនេះ នឹងមាន **គោចរ-សម្បជញ្ញ** ដល់កំពូល ( វិបស្សនា ) ដោយប្រការដូចដែលពណ៌នាមកនេះ ។

## ៤. អសម្មោហសម្បជញ្ញៈ

ចំណែកការមិនវង្វេង ក្នុងការឈានទៅមុខជាដើម ឈ្មោះថា **អសម្មោហសម្បជញ្ញ** , **អសម្មោហសម្បជញ្ញ** នោះ គប្បីជ្រាបយ៉ាងនេះ ។ ភិក្ខុក្នុងព្រះសាសនានេះ កាលឈានទៅខាងមុខ ឬថយត្រឡប់ នឹងមិនវង្វេងដូច **អន្ធបុថុជ្ជន** ( វង្វេង ) ថា ខ្លួនឈានទៅខាងមុខ ខ្លួនឲ្យកើតការឈានទៅខាងមុខ ឬថា យើងឈានទៅខាងមុខ យើងឲ្យកើតការឈានទៅខាងមុខ ក្នុងការឈានទៅខាងមុខជាដើម កាលកើតការគិត ( ចិត្ត ) ឡើងថា យើងនឹងមិនវង្វេង ឈានទៅខាងមុខ **វាយោធាតុ** ដែលមានចិត្តជាសមុដ្ឋាន កាលឲ្យកើតវិញ្ញត្តិឡើង នឹងកើតឡើងព្រមជាមួយចិត្តដូងនោះ ៗ ឯង ។ គ្រោងឆ្អឹង ដែលសម្មតិថាកាយនេះ នឹងឈានទៅខាងមុខ ដោយអំណាចនៃការផ្សាយទៅនៃ **វាយោធាតុ** ដែលកើតអំពី

កិរិយារបស់ចិត្ត ដោយប្រការយ៉ាងនេះ កាលគ្រោងឆ្អឹងនោះៗ ឯង ឈានទៅខាងមុខ ក្នុងការលើកជើងតែម្ខាងឡើង ធាតុ ២ យ៉ាង គឺ **បឋវីធាតុ** និង **អាបោធាតុ** នឹងតិច នឹងថយចុះ ៗ ធាតុ ២ យ៉ាង ទៀត ក្រៅអំពីនេះ ( តេជោធាតុ ) នឹងមានកម្លាំងខ្លាំងក្រៃលែងឡើង ៗ ក្នុងការឈានទៅ និងការបន្តជំហានទៅ **តេជោធាតុ វាយោធាតុ** ( ដែល ប្រព្រឹត្តទៅហើយ ) ក្នុងការលើក ( ជើង ) ចេញទៅនឹងតិច នឹងថយចុះ ៗ ធាតុ ២ យ៉ាងទៀតក្រៅអំពីនេះ ( **បឋវី** , **អាបោ** ) នឹងមានកម្លាំងខ្លាំងក្រៃលែងឡើង ៗ ក្នុងការជាន់ និងការទប់ **រូបធម៌ និងអរូបធម៌** ដែលប្រើក្នុងការលើក ( ជើង ) ឡើងនោះ ក៏យ៉ាងនោះ មិនដល់ការឈានទៅក្នុងទីដែលប្រើក្នុងការឈានជើងទៅ ក៏ទំនងដូចគ្នា មិនដល់ការបន្តជំហានទៅ មិនដល់ការបោះ ( ជើង ) ចេញ មិនប្រើក្នុងការបោះ ( ជំហាន ) ចេញទៅ ក៏មិនមានដល់ការជាន់ ដែលប្រើក្នុងការជាន់ ក៏មិនដល់ការទប់ ៗ កដៃ កជើងគ្រប់យ៉ាង និងទី.តគ្រប់កន្លែង ប្រព្រឹត្តទៅតាមទំនងក្នុងទីនោះនុ៎ះឯង នឹងលាន់ឮប្រេះប្រោះ ដូចគ្រាប់ល្ងដែលបោះចុះក្នុងខ្ទះដែលក្តៅ ៗ ក្នុងរឿងនោះ នឹងមាននរណាម្នាក់ឈានទៅ ឬនឹងមានការឈានទៅរបស់នរណាម្នាក់ ការពិត ( ពោល ) ដោយបរមត្ថហើយ គឺ ការដើររបស់ធាតុប៉ុណ្ណោះ ការឈរ , ការអង្គុយ ការដេក , ក៏របស់ធាតុ ( មិនមែនរបស់នរណា ) ៗ

ព្រោះថា ក្នុងចំណែកនោះ ៗ ចិត្តដូងដទៃកើត ដួងដទៃ

វេលាព្រមជាមួយនឹងរូប (មួយដួងៗ មិនមែនដួងដូចគ្នា) ដូចក្រសែទឹកដែលហូរជាប់តគ្នាទៅ មានរលក ដូច្នោះ ដូច្នេះឯង ។

ការមិនវង្វេង ក្នុងការឈានទៅខាងមុខជាដើម ដូចដែលពណ៌នាមកនេះ ឈ្មោះថា **អសម្មោហសម្បជញ្ញ** ដូច្នេះឯង ។ ជាការដែលបញ្ចប់ការអធិប្បាយថា ជាអ្នកធ្វើសេចក្តីដឹងខ្លួនក្នុងការឈានទៅមុខ និងការថយក្រោយ ។ ក៏ការសម្លឹងមើលទៅខាងមុខ ឈ្មោះថា **អាលោកិត** ( ការក្រឡេកមើលទៅខាងមុខ ) ក្នុងពាក្យថា **អាលោកិតេ វិលោកិតេ** នេះ ការសម្លឹងមើលទៅតាមអនុទិស ( ទិសឆៀង ) ឈ្មោះថា **វិលោកិត** ( ការងាកមើលខាងឆ្វេង-មើលខាងស្តាំ ) មានឥរិយាបថសូម្បីយ៉ាងដទៃទៀត ឈ្មោះថា ឱនចុះ ការងើយឡើង និងការបែរទៅមក ដោយការសម្លឹងមើលខាងក្រោម សម្លឹងមើលខាងលើ សម្លឹងសងខាង ។ ឥរិយាបថទាំងនេះ ទ្រង់មិនកាន់យកក្នុងទីនេះ ។ តែដោយការសមគួរ ទ្រង់កាន់យក ២ យ៉ាងនេះ ប៉ុណ្ណោះ ឬដោយសេចក្តីសំខាន់ ( មុខ ) នេះ ទ្រង់កាន់យកសូម្បីទាំងអស់នោះឯង ដូច្នេះ ។

បណ្តា **សម្បជញ្ញ** ទាំងនោះ ការគិតដល់ប្រយោជន៍ ដោយមិនសម្លឹងមើលដោយអំណាចនៃចិត្តប៉ុណ្ណោះ កាលកើតការគិតឡើងថា យើងនឹងសម្លឹងមើល ឈ្មោះថា **សាត្ថកសម្បជញ្ញ** ។ **សាត្ថកសម្បជញ្ញ** នោះគប្បីជ្រាបដោយលើកយក **ព្រះនន្ទ** អ្នកមានកាយជាសាក្សី ( មកឧបមា ) ។

សមពិតដូចដែលព្រះមានព្រះភាគជាម្ចាស់បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ នន្ទ ចាំបាច់សម្លឹងមើលទិសខាងកើត នន្ទ ក៏នឹងប្រមូលយកវត្ថុគ្រប់យ៉ាងដោយចិត្តហើយ ទើបសម្លឹងមើលទិសខាងកើតដោយគិតថា កាលយើងសម្លឹងមើលទិសខាងកើតយ៉ាងនេះហើយ អភិជ្ឈាទោមនស្ស គឺ អកុសលកម្មដ៏លាមក នឹងមិនគ្របសង្កត់យើង ។ ដោយប្រការដូច្នេះ ភិក្ខុក្នុងធម្មវិន័យនេះ នឹងជាអ្នកមានសេចក្ដីដឹងខ្លួន ក្នុងសាត្ថកសម្បជញ្ញៈនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ នន្ទ នឹងត្រូវសម្លឹងមើលទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ទិសខាងលើ ទិសខាងក្រោម និងទិសទៀងទាំងឡាយ នន្ទ ក៏នឹងប្រមូលយកគ្រប់យ៉ាងដោយចិត្តហើយ ទើបនឹងសម្លឹងមើលទិសទៀងទាំងឡាយ ដោយគិតថា កាលយើងសម្លឹងមើលទិសទៀងទាំងឡាយ យ៉ាងនេះ ។ល។ នឹងជាអ្នកមានសេចក្ដីដឹងខ្លួនក្នុង **សាត្ថកសម្បជញ្ញ** នោះ ។

ក៏ម្យ៉ាងទៀត សូម្បីក្នុងសម្បជញ្ញបព្វៈនេះ គួរនឹងជ្រាប **សាត្ថកសម្បជញ្ញ** និង **សប្បាយសម្បជញ្ញ** ដោយការឃើញព្រះចេតិយ៍ ដែលបានពោលមកហើយក្នុងខាងដើម ជាដើមចុះ ។

ចំណែកការមិនលះបង់កម្មដ្ឋាននោះឯង ឈ្មោះថា **គោចរសម្បជញ្ញ** ព្រោះដូច្នោះ អ្នកចម្រើនកម្មដ្ឋាន មានខន្ធ ធាតុ និងអាយតនៈជាអារម្មណ៍ គួរធ្វើការក្រឡេកមើលខាងមុខ និងការក្រឡេកឆ្វេងស្ដាំដោយអំណាចកម្មដ្ឋានរបស់ខ្លួនប៉ុណ្ណោះ ឬថា អ្នកចម្រើនកម្មដ្ឋានមានកសិណ

ជាដើម ( ជាអារម្មណ៍ ) គួរធ្វើការក្រឡេកមើលខាងមុខ និងការក្រឡេកមើលឆ្វេងស្តាំ ដោយអាការ មានកម្មដ្ឋានជាការសំខាន់ដូចគ្នា ។ ធម្មតាអត្តាក្នុងខាងក្នុងឈ្មោះថា ជាអ្នកក្រឡេកមើលទៅខាងមុខ និងងាកឆ្វេងស្តាំមិនមាន តែកាលកើតការគិតឡើងថា យើងនឹងក្រឡេកមើលទៅខាងមុខ **វាយោធាតុ** ដែលកើតអំពីចិត្ត កាលនឹងឲ្យវិញ្ញាណកើត ក៏នឹងកើតឡើងព្រមជាមួយនឹងចិត្តដួងនោះ ៗ ឯង ។ ដោយប្រការដូច្នេះ សំបកភ្នែក ( ត្របកភ្នែក ) ខាងក្រោម ក៏នឹងបង្ខិតចុះខាងក្រោម សំបកភ្នែកខាងលើ ក៏នឹងបើកឡើងខាងលើ ដោយអំណាចការផ្សាយទៅនៃវាយោ-ធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ។ មិនមាននរណាដែលឈ្មោះថាបើក ( ត្របកភ្នែក ) ដោយគ្រឿងយន្តកែច្នៃ ។

តពីនោះទៅ ចក្ខុវិញ្ញាណនឹងកើតឡើងធ្វើ **ទស្សនកិច្ច** ( ការឃើញ ) ក៏សេចក្តីដឹងខ្លួនដូចដែលពណ៌នាមកនេះ ឈ្មោះថា **អសម្មោហ-សម្បជញ្ញ** ក្នុងអធិការនៃ **សម្បជញ្ញ** នេះ ។

ម្យ៉ាងទៀត ក្នុងរឿងសម្បជញ្ញៈនេះ គប្បីជ្រាប **អសម្មោហសម្ប-ជញ្ញ** សូម្បីដោយអំណាចជា **មូលបរិញ្ញា** ( ការកំណត់ដឹងថ្នាក់ដើម ) ជា **អាគន្តុកៈ** ( ជាភ្ញៀវ ) និងជា **តាវកាលិក** ( ប្រព្រឹត្តទៅមួយគ្រា ) ។ គួរជ្រាប **អសម្មោហសម្បជញ្ញ** ដោយអំណាច **មូលបរិញ្ញា** (ដូចតទៅនេះ) ៖

**ភវង្គៈ** (ចិត្តនៅក្នុងភវង្គៈ) ១ , **អាវជ្ជនៈ** (ការរឭកដល់
អារម្មណ៍ ) ១ , **ទស្សនៈ** ( ការឃើញអារម្មណ៍ ) ១ ,

សម្បដិច្ឆន្នៈ ( ការទទួលអារម្មណ៍ ) ១ , សន្តីរណៈ ( ការពិចារណាអារម្មណ៍ ) ១ , វោដ្ឋព្វនៈ ( ការកាត់ក្តីអារម្មណ៍ ) ១ , ទី ៧ គឺ ជវន ១ ។

## នាទីរបស់ចិត្ត មួយខណៈ ៗ

បណ្តាចិត្តទាំង ៧ នោះ ភវង្គធ្វើកិច្ច គឺ ជាហេតុនៃឧបបត្តិភព ឲ្យសម្រេច កិរិយាមនោធាតុ ញុំាងភវង្គនោះឲ្យវិលត្រឡប់ ហើយធ្វើ អាវជ្ជនកិច្ចឲ្យសម្រេច ព្រោះ អាវជ្ជនកិច្ច នោះរលត់ទៅ ចក្ខុវិញ្ញាណ នឹងធ្វើ ទស្សនកិច្ច ឲ្យប្រព្រឹត្តទៅ ព្រោះ ទស្សនកិច្ច នោះរលត់ទៅ វិបាកមនោធាតុ នឹងធ្វើ សម្បដិច្ឆន្នកិច្ច ឲ្យប្រព្រឹត្តទៅ ព្រោះ សម្បដិច្ឆន្នកិច្ច រលត់ទៅ មនោវិញ្ញាណធាតុ ដែលជាវិបាកធ្វើ សន្តីរណកិច្ច ព្រោះ សន្តីរណកិច្ច នោះរលត់ទៅ មនោវិញ្ញាណធាតុ ដែលជាកិរិយា នឹងឲ្យ វោដ្ឋព្វនកិច្ច ប្រព្រឹត្តទៅ ព្រោះ វោដ្ឋព្វនកិច្ច នោះ រលត់ទៅ ជវន នឹងស្ទុះទៅ ៧ ខណៈ បណ្តា ជវន ទាំង ៧ នោះ ចំពោះ ជវន ដំបូង ការសម្លឹងមើល និងការងាកឆ្វេងស្តាំ ដោយអំណាចសេចក្តីត្រេកអរ និងការថ្នាំងថ្នាក់ និងសេចក្តីវង្វេងថា នេះជាស្ត្រី នេះជាប្រុស និង មិនមានក្នុងជវនទី ២ ក្តី ។ល។ ក្នុងជវនទី ៧ ក្តី ( ក៏នឹងមិនមាន ) ។ តែកាល វិថីចិត្ត ទាំងនេះបែកធ្លាយទៅហើយ ដោយអំណាចចិត្តដួង ដំបូង រហូតដល់ចិត្តដួងចុងក្រោយ ។ ដូចទាហានក្នុងសមរភូមិ កាលក្រឡេក

មើលទៅខាងមុខ និងការក្រឡេកឆ្វេង-ស្ដាំ ដោយអំណាចសេចក្ដីប្រកាន់ជាដើមថា នេះជាស្ត្រី នេះជាបុរសក៏នឹងមាន ។ គប្បីជ្រាប **អសម្មោហ-សម្បជញ្ញ** ដោយអំណាចជា **មូលបរិញ្ញា** ក្នុង **ឥរិយាបថបព្វ** នេះ ដូចដែលពណ៌នាមកនេះមុន ។

ក៏កាលរូបប្រាកដក្នុងចក្ខុទ្វារហើយ តអំពី **ភវង្គចលន** ( ភវង្គ-ញ័រ ) ទៅ កាលវិថីចិត្តមាន **អាវជ្ជន** ជាដើម កើតឡើងហើយរលត់ទៅ ដោយអំណាចធ្វើកិច្ចរបស់ខ្លួនឲ្យសម្រេចក្នុងទីបំផុត ជវន ក៏កើតឡើង ជវននោះ នឹងដូចបុរសដែលជាភ្ញៀវរបស់ **វិថីចិត្ត** មានអាវជ្ជនៈជាដើមដែលកើតឡើងមុន ( មកដល់ ) ទ្វារ គឺ ភ្នែក ( ចក្ខុទ្វារ ) ដែលប្រៀបដូចផ្ទះ សូម្បីកាលវិថីចិត្ត មានអាវជ្ជនៈជាដើម មិនត្រេកអរ មិនអាក់អន់ចិត្ត មិនវង្វេងក្នុង **ចក្ខុទ្វារ** ដែលដូចជាផ្ទះរបស់អាវជ្ជនៈជាដើម ជវនៈនោះ នឹងត្រេកអរ នឹងថ្នាំងថ្នាក់ចិត្ត នឹងវង្វេងក៏មិនត្រូវ ដូចជាបុរសដែលជាភ្ញៀវចូលទៅសុំអ្វី ៗ ក្នុងផ្ទះអ្នកដទៃ កាលម្ចាស់ផ្ទះអង្គុយស្ងៀម នឹងធ្វើការបង្គាប់ក៏មិនត្រូវដូច្នោះ គប្បីជ្រាប **អសម្មោហសម្បជញ្ញ** ប្រៀបដូចជាភ្ញៀវ ដូចដែលពណ៌នាមកនេះ ។

ម្យ៉ាងទៀត ចិត្តមាន **វោដ្ឋព្វន** ជាទីបំផុតដែលកើតឡើងក្នុងចក្ខុទ្វារទាំងនេះ នឹងរលត់ទៅក្នុងទីនោះ ៗ ព្រមជាមួយ **សម្បយុត្តធម៌** នឹងមិនបានជួបគ្នាឡើយ ព្រោះដូច្នោះ ចិត្តក្រៅពីនេះ ទើបប្រព្រឹត្តទៅមួយគ្រា មួយខណៈប៉ុណ្ណោះ ។

ក្នុងសេចក្តីនោះ អ្នកសិក្សាគួរជ្រាប **អសម្មោហសម្បជញ្ញ** ដោយការប្រព្រឹត្តទៅមួយជួរខណៈ យ៉ាងនេះថា ក្នុងផ្ទះមួយជាមួយគ្នា កាលមនុស្សស្លាប់អស់ហើយ មនុស្សម្នាក់ដែលនៅសល់ ដែលធម្មតាក៏នឹងស្លាប់ទៅទៀត ក្នុងកាលមិនយូរដូចគ្នា ឈ្មោះថា នឹងនៅមានសេចក្តីរីករាយក្នុងការរាំរែក និងការច្រៀងជាដើម មិនត្រឹមត្រូវយ៉ាងណា កាល **អាវជ្ជនចិត្ត** ជាដើម ដែលសម្បយុត្តក្នុងទ្វារតែមួយ រលត់ទៅក្នុងទីនោះ ៗ ឯង សូម្បី **ជវនចិត្ត** ដ៏សេស ក៏នឹងមានការរលត់ទៅជាធម្មតា ខាងក្នុងមិនយូរប៉ុន្មានដូចគ្នា ឈ្មោះថា នឹងនៅមានសេចក្តីរីករាយ នៅដោយអំណាចការរីករាយ ការអាក់ អន់ចិត្ត និងការវង្វេង មិនត្រឹមត្រូវឡើយ ដូច្នោះ ដូចគ្នា ។

ម្យ៉ាងទៀត គប្បីជ្រាប **អសម្មោហសម្បជញ្ញ** នេះ ដោយការពិចារណា ខន្ធ អាយតនៈ ធាតុ និងបច្ច័យ ( ដូចតទៅនេះ ) ៖

អធិប្បាយថា ក្នុងពាក្យថា ខន្ធជាដើមនេះ ទាំងចក្ខុ ទាំងរូប ឈ្មោះថា **រូបក្ខន្ធ** ការឃើញ ឈ្មោះថា **វិញ្ញាណក្ខន្ធ** ការសោយអារម្មណ៍ដែលសម្បយុត្តជាមួយនឹងវិញ្ញាណក្ខន្ធនោះ ឈ្មោះថា **វេទនាខន្ធ** ការចាំបានសម្គាល់បាន ឈ្មោះថា **សញ្ញាខន្ធ** ធម៌មាន **ផស្ស** ជាដើម ឈ្មោះថា **សង្ខារក្ខន្ធ** ព្រោះខន្ធទាំងនេះ មកប្រជុំគ្នា ការក្រឡេកមើលទៅខាងមុខ និងការក្រឡេកមើលឆ្វេង ក្រឡេកមើលស្តាំ ទើបប្រាកដ ។ កាលការក្រឡេកមើលទៅមុខ និងការក្រឡេកមើលឆ្វេង ក្រឡេកមើលស្តាំ ប្រាកដ

ដោយអំណាចបញ្ចក្ខន្ធនោះ ( នឹងមាន ) សូម្បីនរណាត្រឹមតែម្នាក់ក្រឡេក មើលទៅមុខ នឹងមាននរណាត្រឹមតែម្នាក់ក្រឡេកមើលខាងស្តាំ ។

ប្រការមួយទៀត **ចក្ខុ** ឈ្មោះថា ចក្ខាយតនៈ **រូប** ឈ្មោះថា រូបាយតនៈ **ការឃើញ** ឈ្មោះថា មនាយតនៈ **សម្បយុត្តធម៌ទាំងឡាយ មានវេទនាជាដើម** ឈ្មោះថា ធម្មាយតនៈ ព្រោះអាយតនៈ ៤ នោះ មកប្រជុំគ្នាយ៉ាងនោះឯង ការក្រឡេកមើលទៅមុខ និងការក្រឡេកមើលឆ្វេង ក្រឡេកមើលស្តាំ ទើបប្រាកដ ។ កាលការក្រឡេកមើលទៅមុខ និងការក្រឡេកមើលឆ្វេង ក្រឡេកមើលស្តាំ ប្រាកដមានដោយអំណាចអាយតនៈ ៤ នោះ បើដូច្នេះ នឹងមាននរណាម្នាក់ក្រឡេកមើលទៅមុខ ក្រឡេកឆ្វេង ស្តាំទៅ ។ ម្យ៉ាងទៀត **ចក្ខុ** ឈ្មោះថា ចក្ខុធាតុ **រូប** ឈ្មោះថា រូបធាតុ **ការឃើញ** ឈ្មោះថា ចក្ខុវិញ្ញាណធាតុ **វេទនាជាដើម** ដែលសម្បយុត្តជាមួយនឹងចក្ខុវិញ្ញាណធាតុ នោះ ឈ្មោះថា ធម្មធាតុ ព្រោះធាតុ ៤ នេះ មកប្រជុំគ្នាយ៉ាងនេះ ការក្រឡេក មើលទៅមុខ និងការក្រឡេកមើលទៅទិសផ្សេង ៗ ទើបប្រាកដ កាលការក្រឡេកមើលទៅមុខ និងការក្រឡេកមើលទៅទិសផ្សេង ៗ ប្រាកដដោយអំណាចធាតុ ៤ នោះ នឹងមាននរណាត្រឹមតែម្នាក់ មកក្រឡេកមើលទៅមុខ និងមាននរណាត្រឹមតែម្នាក់ មកក្រឡេកមើលទៅទិសផ្សេង ៗ ទៅ ។

ម្យ៉ាងទៀត **ចក្ខុ** ជានិស្សយប្បច្ច័យ , **រូប** ជាអារម្មណប្បច្ច័យ **អាវជ្ជន** ជាអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ នត្ថិប្ប-

ច្ច័យ និងវិគតប្បច្ច័យ , **អាលោក** ( ពន្លឺ ) ជាឧបនិស្សយប្បច្ច័យ , **វេទនា** ជាដើម ជាសហជាតប្បច្ច័យ ។ ព្រោះបច្ច័យទាំងនោះ ប្រជុំគ្នា យ៉ាងនោះ ការក្រឡេកមើលទៅមុខ និងការក្រឡេក មើលទៅទិសផ្សេង ៗ ទើបប្រាកដ កាលការក្រឡេកមើលទៅខាងមុខ និងការក្រឡេកមើលទៅ ទិសផ្សេង ៗ ប្រាកដដោយអំណាចបច្ច័យទាំងនោះ នឹងមាននរណាត្រឹម តែម្នាក់ មកមើលទៅមុខ និងមាននរណាត្រឹមតែម្នាក់ មកក្រឡេកមើល ទៅទិសផ្សេង ៗ ។ គប្បីជ្រាប **អសម្មោហសម្បជញ្ញ** សូម្បីដោយការ ពិចារណា **ខន្ធ អាយតន ធាតុ** និង **បច្ច័យ** ក្នុងការក្រឡេកមើលទៅមុខ និងការក្រឡេកមើលទៅទិសផ្សេង ៗ នេះ ដូចដែលពណ៌នាមកនេះឯង ។

បទថា **សម្មិញ្ជិតេ បសារិតេ** បានដល់ ការបត់ដៃជើងចូល និង លាដៃជើងចេញ ។ បណ្ដាសម្បជញ្ញៈទាំង ៤ នោះ ការមិនធ្វើការបត់ និង ការលាចេញទៅ ដោយអំណាចចិត្ត ( ការគិត ) តែម្យ៉ាង តែពិគ្រោះ ពិចារណាមើលប្រយោជន៍ ឬមិនប្រយោជន៍ ព្រោះមានការបត់ចូល និង ការលាដៃ ឬជើងចេញទៅជាបច្ច័យ ហើយលើកយកតែប្រយោជន៍ ឈ្មោះ ថា **សាត្ថកសម្បជញ្ញ** ក្នុងការបត់ចូល និងការលាចេញទៅនោះ គប្បី ជ្រាបការពិគ្រោះពិចារណាដល់ការមិនមានប្រយោជន៍ យ៉ាងនេះថា កាល ដៃ ឬជើងបត់ចូលមកយូរ ៗ ឬលាដៃ ឬជើងចេញទៅយូរ ៗ វេទនា នឹងកើតគ្រប់ ៗ កាល ។ ចិត្តក៏នឹងមិនជាឯកគ្គតាចិត្ត ( មិនជាសមាធិ ) កម្មដ្ឋានក៏នឹងមិនចម្រើន លោកនឹងមិនបានសម្រេចគុណវិសេស ។ តែបត់

ចូលសមល្មម លាចេញទៅសមល្មម វេទនានឹងមិនកើតឡើង ( ឡើយ ) ចិត្តនឹងជា **ឯកគ្គតា** កម្មដ្ឋានក៏នឹងដល់សេចក្តីចម្រើន លោកនឹងបានសម្រេចគុណវិសេស រីឯចំណែកបច្ច័យ សូម្បីមានព្រះយោគាវចរនៅពិគ្រោះពិចារណាស្ថានទីដែលជាទីសប្បាយ និងមិនសប្បាយ ហើយជ្រើសយកស្ថានទីដែលសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញ** ។ ក្នុង **សប្បាយសម្បជញ្ញ** មានន័យដូចតទៅនេះ៖

បានឮថា ភិក្ខុកំលោះៗ នាំគ្នាសូធ្យមន្តត្រង់លានព្រះចេតិយ៍ធំខាងក្រោយភិក្ខុទាំងនោះ ភិក្ខុនីក្រមុំ ៗ កំពុងស្តាប់ធម៌ ។ ក្នុងចំនួនភិក្ខុទាំងនោះ ភិក្ខុមួយរូបលាដៃចេញទៅ ត្រូវកាយភិក្ខុនីហើយ បានក្លាយទៅជាគ្រហស្ថ ព្រោះហេតុនោះ ៗ ឯង ។ ភិក្ខុមួយរូបទៀត កាលលាជើងចេញទៅ បានលាទៅលើភ្លើង ឆេះជើងដល់ឆ្អឹង ។ ភិក្ខុមួយរូបទៀត លាចេញទៅត្រង់ជំបូកកណ្តៀរ លោកត្រូវអសិរពិសខាំ ។ ភិក្ខុមួយរូបទៀតលាទៅត្រង់ដងក្លស់ ត្រូវពស់វែកខាំលោក ។ ព្រោះដូច្នោះ ( កាលនឹងលាជើង ) ក៏កុំលាទៅក្នុងទីដែលមិនសប្បាយ ដូច្នេះ ។ គួរលាទៅក្នុងទីដែលសប្បាយ ។ នេះជា **សប្បាយសម្បជញ្ញ** ក្នុងឥរិយាបថបព្វៈនេះ ចំណែក **គោចរសម្បជញ្ញ** គួរសម្តែង ដោយរឿងព្រះមហាថេរៈ ។

## រឿង ព្រះមហាថេរៈ

បានឮមកថា ព្រះមហាថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃ កាលសន្ទនា

ជាមួយនឹងអន្តេវាសិក បានបត់ដៃចូល ហើយលាចេញដូចដើម ( បន្ទាប់ពីនោះ ) ទើបសន្សឹម ៗ បត់ដៃចូលទៀត ។ ពួកអន្តេវាសិក បានសួរលោកថា លោកម្ចាស់ ហេតុដូចម្តេចលោកម្ចាស់ ទើបបត់ដៃចូលយ៉ាងរហ័ស ហើយត្រឡប់លាចេញទុកដូចដើមវិញ បន្ទាប់ពីនោះ ទើបសន្សឹម ៗ បត់ដៃចូលទៀត ។ ព្រះមហាថេរៈឆ្លើយថា អាវុសោ តាំងពីខ្ញុំផ្តើមមនសិការកម្មដ្ឋាន ខ្ញុំមិនដែលលះបង់កម្មដ្ឋាន ហើយបត់ចូលឡើយ តែវេលានេះ ខ្ញុំនិយាយនឹងពួកលោកបានលះកម្មដ្ឋានហើយ ទើបបត់ដៃចូល ព្រោះដូច្នោះ ខ្ញុំទើបលាដៃចេញដូចដើម ហើយបត់ចូលបន្តិចម្តងៗ ទៅវិញទៀត ។ អន្តេវាសិកទាំងឡាយពិតថេរដីកាថា ល្អហើយ ល្អហើយ លោកម្ចាស់ ធម្មតាភិក្ខុគួរយ៉ាងហ្នឹង ។ សូម្បីក្នុងឥរិយាបថបព្វៈនេះ ការមិនលះបង់កម្មដ្ឋាន គប្បីជ្រាបថា ឈ្មោះថា **គោចរសម្បជញ្ញ** ដោយប្រការដូច្នេះ ។ មិនមានអ្វីខាងក្នុងដែលឈ្មោះថា **អត្តា** បត់ដៃចូលមក ឬលាដៃចេញទៅ ។ តែការបត់ដៃចូល និងលាជើងចេញ មានបានដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត មានប្រការដូចដែលពោលមកហើយ ដូចការកម្រើកដៃ និងជើង របស់ទីងមោងដោយការទាញខ្សែ ព្រោះដូច្នោះ ក៏ការកំណត់ដឹង ( ដូចដែលពោលមកនេះ ) គប្បីជ្រាបចុះថា ឈ្មោះថា មាន **អសម្មោហសម្បជញ្ញ** ក្នុងឥរិយាបថបព្វៈនេះ ។

ការប្រើសង្ឃាដី និងចីវរដោយការស្លៀកការដណ្តប់ ការប្រើ

បាត្រ ដោយការរក្សា ជាដើម ឈ្មោះថា **ធារណៈ** ក្នុងពាក្យថា **សង្ឃាដិ-បត្តចីវរធារណេ** នេះ ។ ការបានអាមិសរបស់ភិក្ខុអ្នកស្លៀក និងដណ្តប់ ហើយត្រាច់ទៅបិណ្ឌបាត និងប្រយោជន៍ មានប្រការដូចដែលព្រះមាន-ព្រះភាគត្រាស់ទុកនោះឯង ដោយន័យមានជាអាទិ៍ថា **សីតស្សបដិឃា-តាយ** ( ដើម្បីបំបាត់ភាពរងា ) ។ ឈ្មោះថា ប្រយោជន៍ក្នុងការទ្រទ្រង់ សង្ឃាដី និងចីវរនោះ អ្នកសិក្សាគប្បីយល់សាត្ថកសម្បជញ្ញៈ ដោយ អំណាចនៃប្រយោជន៍នោះ ដូច្នេះ ។ ចំណែកចីវរសាច់ម៉ដ្ឋ ជាសប្បាយៈ របស់អ្នកមានប្រក្រតីក្តៅ ( ញើសចេញងាយ ) និងអ្នកមានកម្លាំង ( តិច ) ចីវរសាច់ក្រាស់គ្រោតគ្រាត ជាទីសប្បាយរបស់អ្នក មានប្រក្រតីរងាច្រើន (ធាប់រងា) ខុសអំពីនេះក៏មិនជាទីសប្បាយ ។ ចីវរចាស់មិនជាទីសប្បាយ របស់នរណា ៗ ឡើយ ។ ព្រោះវាធ្វើការកង្វល់ចិត្តឲ្យលោក ដោយការ ជាប់ចិត្តជាដើម ។ សំពត់ចីវរមួយផ្ទាំង ( មិនបានកាត់ឲ្យជាខណ្ឌ ) និង សំពត់សំបកឈើជាដើម ដែលជាទីតាំងនៃសេចក្តីលោភ ក៏យ៉ាងនោះ ព្រោះសំពត់ដូច្នោះ ធ្វើអន្តរាយដល់ការនៅ តែឯងក្នុងព្រៃ ឬធ្វើអន្តរាយ ដល់ជីវិតក៏មាន និងដោយត្រង់ហើយ សំពត់ចីវរឯណានីមួយ ដែលកើត ឡើង ( បានមក ) ដោយអំណាចមិច្ឆាជីវៈ មានការធ្វើនិមិត្តជាដើម និង ចីវរណា កាលលោកប្រើទៅ អកុសលធម៌ចម្រើនឡើង កុសលធម៌សាប-សូន្យទៅ ចីវរនោះ **ជាអសប្បាយ** ប៉ុន្តែចីវរដែលខុសអំពីនេះ **ជាសប្បាយ** ។

ក្នុងសម្បជញ្ញបព្វៈនេះ អ្នកសិក្សាគប្បីយល់ **សប្បាយសម្បជញ្ញ**

ដោយអំណាចនៃចីវរនោះឯង និង គោចរសម្បជញ្ញ ដោយអំណាចការមិនបោះបង់ចោលកម្មដ្ឋាន ។

មិនមានអ្វីដែលឈ្មោះថា អត្តា ក្នុងខាងក្នុងរបស់ភិក្ខុអ្នកដណ្តប់ចីវរ មានតែការដណ្តប់ចីវរ ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយា របស់ចិត្ត មានប្រការដូចដែលពោលហើយប៉ុណ្ណោះ ។ បណ្តាចីវរ និងកាយ ទាំង ២ យ៉ាងនោះ សូម្បីចីវរ ក៏មិនមានការតាំងចិត្ត សូម្បីកាយក៏មិនមានការតាំងចិត្ត ចីវរក៏មិនដឹងថា យើងគ្របដណ្តប់កាយ ។ សូម្បីកាយក៏មិនដឹងថា ចីវរគ្របដណ្តប់យើង ។ ធាតុទាំងឡាយប៉ុណ្ណោះគ្របដណ្តប់ធាតុ ដូចយកសំពត់ចាស់ខ្ទប់រូប គឺគម្ពីរ ព្រោះដូច្នេះ បានចីវរដែលល្អហើយ ក៏មិនគួរធ្វើសេចក្តីត្រេកអរឡើយ បានមិនល្អ ក៏មិនគួរទោមនស្ស អធិប្បាយថា មនុស្សពួកខ្លះ នាំគ្នាសក្ការបូជា នាគ ដំបូកចេតិយ៍ និងដើមឈើ [១] ជាដើម ដោយផ្កា គ្រឿងក្រអូប និងសំពត់ជាដើម ។ តែមនុស្សពួកខ្លះ ធ្វើវត្ថុដែលមិនមែនសក្ការៈ ដូចបន្ទោបង់ឧច្ចារៈបស្សាវៈដាក់ យកកក់លាប យកកំណាត់ឈើវាយ និងសស្ត្រាប្រហារជាដើម នាគ ដំបូក និងដើមឈើជាដើម និងមិនធ្វើសេចក្តីត្រេកអរ សេចក្តីមិនត្រេកអរចំពោះសក្ការៈ ឬអសក្ការៈនោះ ( យ៉ាង

---

[១] បាឋៈថា នានាវម្មិកចេតិយរុក្ខាទីសុ ច្បាប់ភូមាជា នាគវម្មិកចេតិយរុក្ខាទីសុ ប្រែតាមច្បាប់ភូមា ។

ណា ) ភិក្ខុក៏ដូច្នេះដូចគ្នា បានចីវរល្អហើយ ក៏មិនគួរធ្វើសេចក្ដីត្រេកអរ បានចីវរមិនល្អ ក៏មិនគួរទោមនស្ស ។ ក្នុងសម្បជញ្ញបព្វៈនេះ អ្នកសិក្សា គួរយល់ **អសម្មោហសម្បជញ្ញ** ដោយអំណាចការពិចារណាដែលប្រព្រឹត្ត ទៅហើយ ដូចដែលពណ៌នាមកនេះចុះ ។

សូម្បីក្នុងការបើបាត្រ ក៏គប្បីជ្រាប **អសម្មោហសម្បជញ្ញ** ដោយ អំណាចប្រយោជន៍ដែលនឹងគប្បីបាន ព្រោះមានការកាន់បាត្រ ជាបច្ច័យ យ៉ាងនេះថា យើងនឹងមិនប្រញាប់ប្រញាល់កាន់បាត្រ តែនឹងកាន់យកបាត្រ ( ដោយមានកម្មដ្ឋានជាសំខាន់ ) ត្រាច់ទៅបិណ្ឌបាត ក៏នឹងបានភិក្ខា ។

ចំណែកបាត្រធ្ងន់ មិនជាសប្បាយសម្រាប់ភិក្ខុអ្នកមានរាងកាយស្គម និងកម្លាំងតិច ហើយបាត្រដែលផ្សារភ្ជាប់ ( ដែក ) រួមគ្នា ៤-៥ ផ្ទាំងខាត់ មិនរាបស្មើល្អ មិនជាសប្បាយដល់បុគ្គលណានីមួយឡើយ ។ ព្រោះថា បាត្រដែលលាងលំបាក មិនជាទីសប្បាយ ក៏កាលលាងបាត្រនោះឯង លោក នឹងមានការកង្វល់ ។ ចំណែកបាត្រដែលមានពណ៌ដូចកែវមណី ជាទីតាំង នៃលោភៈ មិនជាសប្បាយ ដោយន័យដែលបានពោលទុកហើយក្នុងចីវរ នោះឯង តែបាត្រដែលបានពោលមក ដោយការធ្វើនូវនិមិត្តជាដើម បាត្រ ណាកាលភិក្ខុនោះប្រើ អកុសលធម៌នឹងចម្រើនឡើង ឯកុសលធម៌នឹងសាប- សូន្យទៅ បាត្រនេះ ជាអសប្បាយដោយចំណែកមួយប៉ុណ្ណោះ បាត្រដែល ផ្សេង ( ក្រៅពីនោះ ) ជាសប្បាយ ។ គប្បីជ្រាប **សប្បាយសម្បជញ្ញ** ដោយអំណាចនៃបាត្រនោះ គប្បីជ្រាប **គោចរសម្បជញ្ញ** ដោយមិនលះបង់

កម្មដ្ឋាន ។

មិនមានអ្វីដែលឈ្មោះថា **ជាអត្តា** ក្នុងខាងក្នុងសូម្បីដល់ភិក្ខុបីបាត្រ ធម្មតាការបីបាត្រនឹងមានបាន ក៏ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតឡើងព្រោះកិរិយារបស់ចិត្ត មានប្រការដូចដែលពោលមកហើយ បណ្ដាដៃ និងបាត្រទាំង ២ យ៉ាងនោះ ទាំងបាត្រក៏មិនមានការតាំងចិត្ត ទាំងដៃក៏មិនមានការតាំងចិត្ត បាត្រក៏មិនដឹងថាដៃបីយើង សូម្បីដៃក៏មិនដឹងថាយើងបីបាត្រ ធាតុទាំងឡាយប៉ុណ្ណោះ បីពួកធាតុ ដូចក្នុងវេលាយកដង្កាប់ចាប់បាត្រដែលដុតនឹងភ្លើង ព្រោះដូច្នោះ ក្នុងសម្បជញ្ញបព្វៈនេះ គប្បីជ្រាប **អសម្មោហសម្បជញ្ញ** ដោយការពិចារណាអត្តដែលប្រព្រឹត្តទៅ ដូចដែលពណ៌នាមកនេះ ។

មួយ៉ាងទៀត ភិក្ខុណាពិចារណាឃើញចីវរដូចសំពត់រុំដំបៅ បាត្រដូចជាអំបែងដាក់ថ្នាំ ភិក្ខាដែលបានមកក្នុងបាត្រ ដូចថ្នាំក្នុងអំបែង ភិក្ខុនេះគប្បីជ្រាបចុះថា ជាអ្នកមានប្រក្រតីធ្វើសេចក្ដីដឹងខ្លួនដ៏ខ្ពង់ខ្ពស់ ជាទីបំផុត ជាប្រក្រតីដោយ **អសម្មោហសម្បជញ្ញ** ក្នុងការទ្រទ្រង់សង្ឃាដី បីបាត្រ និងដណ្ដប់ចីវរ ដូចបុរសដែលមានករុណា ឃើញមនុស្សអនាថាដេកនៅក្នុងសាលាសម្រាប់មនុស្ស អនាថាមានដៃជើងកំបុត មានទឹករងៃ និងឈាម ទាំងពួកដង្កូវហូរចេញអំពីមុខដំបៅ មានរុយក្បាលខៀវទំបីតដំបៅ ទើបបានស្វែងរកសំពត់រុំមុខដំបៅ និងថ្នាំ ព្រមទាំងអំបែងដាក់ថ្នាំទៅឲ្យពួកគេទាំងនោះ ក្នុងចំនួនវត្ថុទាំងនោះ សូម្បីសំពត់ដែលមានសាច់ម៉ដ្ឋ ក៏

ធ្លាក់ដល់ពួកគេខ្លះ ដែលមានសាច់គ្រោតគ្រាតធ្លាក់ដល់ពួកគេខ្លះ សូម្បីត្រឡោកដូងដាក់ថ្នាំ ដែលមានទ្រង់ទ្រាយស្អាត ក៏ធ្លាក់ដល់ពួកគេខ្លះ ដែលមានទ្រង់ទ្រាយមិនស្អាត ក៏ធ្លាក់ដល់ពួកគេខ្លះ ពួកគេនឹងមិនត្រេកអរ ឬទោមនស្សក្នុងវត្ថុទាំងនោះ ព្រោះពួកគេមានសេចក្ដីត្រូវការសំពត់ត្រឹមតែប្រើបិទដំបៅប៉ុណ្ណោះ និងត្រឡោកដូងត្រឹមតែប្រើដាក់ថ្នាំប៉ុណ្ណោះ ដូច្នោះ ។

គប្បីជ្រាបការវិនិច្ឆ័យក្នុងការឆាន់ ជាដើម ( ដូចតទៅនេះ ) ៖

បទថា **អសិតេ** សេចក្ដីថា ក្នុងការឆាន់បិណ្ឌបាត ។

បទថា **បីតេ** សេចក្ដីថា ក្នុងការផឹកទឹកបបរជាដើម ។

បទថា **ខាទិតេ** សេចក្ដីថា ក្នុងការទំពាស៊ីនូវខាទនីយៈ ដែលធ្វើដោយម្សៅជាដើម ។

បទថា **សាយិតេ** សេចក្ដីថា ក្នុងការទទួលរស មានស្ករអំពៅជាដើម ។ ក្នុងការឆាន់ជាដើមនោះ ប្រយោជន៍ទាំង ៨ យ៉ាង ដែលព្រះពុទ្ធត្រាស់ទុកដោយន័យមានជាអាទិ៍ថា **នេវ ទវាយ** ( មិនមែនដើម្បីលេង ) ឈ្មោះថា ប្រយោជន៍ អ្នកសិក្សាគប្បីជ្រាប **សាត្ថកសម្បជញ្ញ** ដោយអំណាចនៃប្រយោជ៍នោះ ។

ក៏បុគ្គលណាមានសេចក្ដីមិនសប្បាយ ព្រោះភោជនណា ភោជននោះ ជាអសប្បាយសម្រាប់បុគ្គលនោះ ចំណែកភោជនណាបានមកដោយការធ្វើនូវនិមិត្តជាដើម ហើយកាលលោកឆាន់ភោជនណា អកុសលធម៌ទាំងឡាយចម្រើនឡើង កុសលទាំងឡាយសាបសូន្យទៅ ។ ភោជននោះ

ជាអសប្បាយតែម្យ៉ាងប៉ុណ្ណោះ ។ តែភោជនក្រៅពីនេះ ជាសប្បាយ ។

អ្នកសិក្សាគួរយល់ **សប្បាយសម្បជញ្ញ** ដោយអំណាចនៃភោជនដែលជាសប្បាយនោះ នឹងគប្បីជ្រាប **គោចរសម្បជញ្ញ** ដោយមិនលះបង់កម្មដ្ឋានឡើយ ។

មិនមាននរណាឈ្មោះថាជាអត្តា ក្នុងខាងក្នុងជាអ្នកបរិភោគ មានតែការទទួលបាត្រ ធម្មតាដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត មានប្រការដូចដែលពោលមកហើយប៉ុណ្ណោះ មានតែការលូកដៃចុះក្នុងបាត្រធម្មតា ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ប៉ុណ្ណោះ មានតែការពូតដុំបាយ ការលើកដុំបាយឡើង និងការបើកមាត់ទទួល ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ មិនមានអ្នកណាយកកូនសោ និងគ្រឿងយន្តបើកថ្គាមបាន មានតែការដាក់ពំនូតបាយក្នុងមាត់ ការឲ្យធ្មេញខាងលើធ្វើនាទីជំនួសអង្រែ ការឲ្យធ្មេញខាងក្រោម ធ្វើនាទីជំនួសត្បាល់ និងការឲ្យអណ្ដាតធ្វើនាទីជំនួសដៃ ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ ។

ដោយហេតុយ៉ាងនេះ ទឹកមាត់ចំនួនតិចតួចចុងអណ្ដាត ក្នុងបណ្ដាចុង និងគល់នោះ ( និង ) ទឹកមាត់ចំនួនច្រើនត្រង់គល់អណ្ដាត ក៏នឹងលាយឡំពំនូតបាយនោះ ពំនូតបាយនោះនឹងប្រមៀលទៅមកដោយដៃ គឺអណ្ដាត ក្នុងត្បាល់ គឺ ធ្មេញ ( ថ្គាម ) ក្រោម សើមទៅដោយទឹកមាត់ គឺ

សេស្ម៍ ឬកយ៉ាងល្អិតដោយអង្រែ គឺ ធ្មេញ ( ថ្គាម ) លើ , ឈ្មោះថា នរណា ៗ នឹងយកស្លាបព្រា ឬវែកសិកចូលទៅខាងក្នុង ( មាត់ ) មិនមាន , ( ពំនូតបាយ ) ចូលទៅបាន ព្រោះវាយោធាតុនោះឯង ពំនូតបាយដែលចូលទៅហើយ នរណា ៗ ឈ្មោះថា នឹងឲ្យបញ្ឈប់ទុកធ្វើឲ្យ ( ដូច ) ជាគំនរចំបើងទុក មិនមាន តែនឹងបញ្ឈប់ទុកបានដោយអំណាចវាយោ-ធាតុប៉ុណ្ណោះ , ដែលបញ្ឈប់ទុកហើយ នរណា ៗ ឈ្មោះថា នឹងតាំងចង្ក្រាន បង្កាត់ភ្លើងបបរឲ្យរលួយមិនមាន តែនឹងរលួយបានព្រោះតេជោ-ធាតុប៉ុណ្ណោះ , ដែលរលួយហើយ ៗ នរណា ៗ ឈ្មោះថា នឹងយកឈើប្រត់កៀរចេញទៅខាងក្រៅក៏មិនមាន , វាយោធាតុប៉ុណ្ណោះ នឹងនាំចេញទៅ , ដោយហេតុយ៉ាងនេះ វាយោធាតុនាំ ( ពំនូតបាយ ) ចូលទៅផងនាំចេញទៅផង ឲ្យឈប់នៅផង ឲ្យប្រមៀលទៅមកផង ឲ្យរលាយទៅផង ឲ្យនាំ ( កាក ) ចេញទៅផង , បឋវីធាតុទ្រទ្រង់ទុកផង ឲ្យប្រមៀលទៅមកផង , ឲ្យរលាយផង , អាបោប្រមូលផ្តុំផង រក្សាទុកឲ្យស្រស់ផង , តេជោធាតុនឹងរំលាយនូវអាហារ ដែលចូលទៅខាងក្នុងហើយ អាកាសធាតុជាចន្លោះ វិញ្ញាណធាតុនឹកដល់ ដោយអាស្រ័យការប្រកបគ្នាដោយប្រពៃក្នុងធាតុនោះ ៗ អ្នកសិក្សាគប្បីយល់សម្មោហសម្បជញ្ញៈ ក្នុងសម្បជញ្ញ-បព្វៈដោយការពិចារណា ដែលប្រព្រឹត្តទៅហើយ ដូចដែលពណ៌នាមកនេះចុះ ។

---

## បដិកូល ១០

ម្យ៉ាងទៀត ព្រះយោគាវចរគួរជ្រាប **អសម្មោហសម្បជញ្ញ** ក្នុងសម្បជញ្ញបព្វ នេះ ដោយការពិចារណាដល់បដិកូល ១០ យ៉ាងនេះ គឺ ដោយការទៅ ១ ដោយការស្វែងរក ១ ដោយការឆាន់ ១ ដោយអធ្យាស្រ័យ ១ ដោយការរក្សាទុក ( ក្នុងក្រពះអាហារ ) ១ ដោយចំណែកដែលនៅមិនទាន់រលាយ ១ ដោយចំណែកដែលរលាយហើយ ១ ដោយផល ១ ដោយជ្រួតជ្រាប ១ ដោយប្រឡាក់ប្រឡូស ១ ចំណែកកថាយ៉ាងពិស្តារក្នុងសម្បជញ្ញបព្វៈនេះ គួរកាន់យកអំពីនិទ្ទេសនៃ **អាហារេបដិកូលសញ្ញា** ក្នុង **គម្ពីរវិសុទ្ធិមគ្គ** ចុះ ។

បទថា **ឧច្ចារបស្សាវកម្មេ** សេចក្តីថា បន្ទោបង់ឧច្ចារៈ និងបស្សាវៈ ( ព្រោះថា ) ដល់វេលានោះហើយ កាលមិនបន្ទោបង់ឧច្ចារបស្សាវៈ ញើសនឹងហូរចេញទូទាំងសព៌ាង្គកាយ ភ្នែកនឹងព្រិល ចិត្តមិនជាឯកគ្គតា ហើយរោគដទៃៗ ក៏នឹងកើតឡើង ។ តែកាលបន្ទោបង់ហើយ វត្ថុទាំងអស់នោះនឹងមិនមាន ព្រោះដូច្នេះ សេចក្តីនេះជាអត្ថាធិប្បាយក្នុងពាក្យថា **ឧច្ចារបស្សាវកម្មេ** នេះ អ្នកសិក្សាគប្បីជ្រាបសាត្ថកសម្បជញ្ញៈ ដោយអំណាចនៃសេចក្តីនោះ ។

តែកាលបន្ទោបង់ឧច្ចារបស្សាវៈក្នុងទីដែលមិនសមគួរនឹងជាអាបត្តិ នឹងវិនាសយស ( ខូចកិត្តិយស ) និងមានអន្តរាយដល់ជីវិត តែកាលបន្ទោបង់ក្នុងទីដ៏សមគួរ វត្ថុទាំងអស់នោះ នឹងមិនមាន ព្រោះដូច្នោះ ការ

បន្ទោបង់ក្នុងទីដ៏សមគួរនេះ ទើបជាសប្បាយក្នុងឧច្ចារបស្សាវកម្មនេះ អ្នកសិក្សាគប្បីជ្រាប **សប្បាយសម្បជញ្ញ** ដោយអំណាចនៃសប្បាយនោះ ចំណែក **គោចរសម្បជញ្ញ** គប្បីជ្រាបដោយអំណាចការមិនបោះបង់ចោលកម្មដ្ឋាននោះឯង ។ មិនមាននរណាៗ ឈ្មោះថាជាអត្តាក្នុងខាងក្នុង បន្ទោបង់ឧច្ចារបស្សាវៈ មានតែការបន្ទោបង់ឧច្ចារបស្សាវៈ ព្រោះការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ ។ ក៏ឧច្ចារៈ និងបស្សាវៈ ដែលនៅក្នុងពោះវៀន និងក្រពះ បស្សាវៈត្រូវកម្លាំងខ្យល់រុញច្រានទៅ ក៏នឹងចេញទៅឯង ដោយមិនប្រាថ្នាឲ្យចេញឡើយ ដូចកាលបូសចាស់ហើយ ខ្ទុះ និងឈាមហូរចេញទៅឯង ដោយមិនប្រាថ្នា ( ឲ្យហូរ ) ព្រោះបូសបែក និងដូចទឹកដែលហូរចេញចាកភាជនៈដាក់ទឹក ដែលប្រោលហើយ ដោយមិនប្រាថ្នា ( ឲ្យហូរ ) ដូច្នោះ ។

ក៏ឧច្ចារៈ និងបស្សាវៈនេះណា ដែលបន្ទោបង់ចេញទៅហើយ ឧច្ចារៈ និងបស្សាវៈនេះនោះ នៃអត្តារបស់ភិក្ខុនោះ នឹងមិនមានឡើយ របស់អ្នកដទៃក៏មិនមាន មានតែការបន្ទោបង់របស់រាងកាយប៉ុណ្ណោះ ។

ដូចអ្វី ?

ដូចកាលចាក់ទឹកចេញពីធ្នាំង ធ្នាំងក៏មិនមានទឹកនោះឡើយ វត្ថុដទៃក៏មិនមាន មានត្រឹមតែការបដិបត្តិម្យ៉ាងប៉ុណ្ណោះ យ៉ាងណាមិញ អ្នកសិក្សាគប្បីយល់ **សម្មោហសម្បជញ្ញ** ក្នុង **សម្បជញ្ញបព្វ** នេះ ដោយការពិចារណាកិរិយាអាការដែលប្រព្រឹត្តទៅហើយ ដូច្នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការដើរជាដើម ( ដូចតទៅនេះ ) ៖

បទថា **គតេ** បានដល់ ក្នុងការដើរទៅ ។

បទថា **ឋិតេ** បានដល់ ក្នុងការឈរ ។

បទថា **និសិន្នេ** បានដល់ ក្នុងការអង្គុយ ។

បទថា **សុត្តេ** បានដល់ ក្នុងការដេកលក់ ។

បទថា **ជាគរិតេ** បានដល់ ក្នុងការភ្ញាក់ ។

បទថា **ភាសិតេ** បានដល់ ក្នុងការពោល ។

បទថា **តុណ្ហីភាវេ** បានដល់ ក្នុងការមិននិយាយ ។

ព្រះអង្គបានត្រាស់ឥរិយាបថវែងឆ្ងាយទុកក្នុងឋានៈនេះថា កាលដើរទៅ ក៏ដឹងច្បាស់ថា យើងកំពុងដើរទៅខ្លះ , ឈរហើយក៏ដឹងច្បាស់ថា យើងឈរហើយខ្លះ , អង្គុយ ក៏ដឹងថាយើងអង្គុយខ្លះ ដេក ក៏ដឹងច្បាស់ថា យើងដេកខ្លះ ។ ត្រាស់ឥរិយាបថកណ្ដាល ៗ ទុកក្នុងឋានៈនេះថា ក្នុងការឈានទៅមុខ , ក្នុងការឈានទៅក្រោយ , ក្នុងការក្រឡេកមើលទៅមុខ ។ ក្នុងការក្រឡេកមើលឆ្វេងស្ដាំ , ក្នុងការលាចេញ តែក្នុងបទ្ទៈនេះ ត្រាស់ឥរិយាបថតូច ៗ ទុកថា ក្នុងការដើរ ក្នុងការឈរ ក្នុងការអង្គុយ ក្នុងការដេក ក្នុងការភ្ញាក់ ព្រោះដូច្នោះ គប្បីជ្រាបភាពជាអ្នកធ្វើសេចក្ដីដឹងខ្លួនជាប្រក្រតី ដោយន័យដែលត្រាស់ទុកក្នុងឋានទាំងនេះ នោះឯង ។

ក៏ព្រះមហាសិវត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក បានពោលទុកថា អ្នក

ណាដើរទៅ ឬឈរចង្រ្កមយូរ ៗ ហើយតមក ទើបឈរពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយក្នុងវេលាចង្រ្កម បានរលត់ទៅហើយក្នុងវេលាចង្រ្កមនេះឯង អ្នកនេះនោះ ឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការដើរ ។

អ្នកណា កាលធ្វើការស្វាធ្យាយន៍ , ឆ្លើយបញ្ហា ឬមនសិការកម្មដ្ឋាន ឈរនៅយូរ ៗ ហើយតមក ទើបអង្គុយពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយក្នុងវេលាឈរ បានរលត់ទៅហើយ ក្នុងវេលាឈរនោះឯង អ្នកនោះ ឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការឈរ ។

អ្នកណាអង្គុយយូរៗ ដោយធ្វើការស្វាធ្យាយន៍ជាដើមនោះឯង ហើយតមក ទើបដេកពិចារណាឃើញយ៉ាងនេះ រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយក្នុងវេលាអង្គុយ បានរលត់ទៅហើយ ក្នុងវេលាអង្គុយនោះឯង អ្នកនេះ ឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការអង្គុយ ។

បុគ្គលណាដេកបណ្តើរ ធ្វើការស្វាធ្យាយបណ្តើរ ឬមនសិការកម្មដ្ឋានបណ្តើរ ឈានចុះកាន់ភាពលង់លក់ ក្រោយមកទើបក្រោកឡើងពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយក្នុងវេលាដេក បានរលត់ទៅហើយក្នុងវេលាដេកនោះឯង បុគ្គលនេះ ឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការដេកលក់ ទាំងក្នុងការភ្ញាក់ ។ ព្រោះថា ចិត្តដែលសម្រេចដោយកិរិយា មិនមានការប្រព្រឹត្តទៅ ( មិនឡើងកាន់វិថី )

ឈ្មោះថា ដេកលក់ មានការប្រព្រឹត្តទៅ ឈ្មោះថា ភ្ញាក់ ព្រោះដូច្នោះ ( អ្នកនោះទើបឈ្មោះថា ធ្វើការដឹងខ្លួនទាំងក្នុងការដេកលក់ ទាំងក្នុងការភ្ញាក់ ) ។

ចំណែកបុគ្គលណា កាលនិយាយ ក៏និយាយមានសតិសម្បជញ្ញៈថា ធម្មតាសំឡេងនេះ អាស្រ័យបបូរមាត់ អាស្រ័យធ្មេញ អណ្តាត ពិដាន និងប្រយោគរបស់ចិត្ត ដែលសមគួរនឹងចិត្តនោះ ទើបកើតឡើងបាន ។

ម្យ៉ាងទៀត បុគ្គលណាធ្វើការស្វាធ្យាយន៍ធម៌ ប្រាប់ធម៌ ប្រែធម៌ ( បង្រៀន ) កម្មដ្ឋាន ឬវិសជ្ជនាបញ្ហាអស់វេលាយូរ តមកទើបស្ងៀម ពិចារណាយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយក្នុងវេលានិយាយ ក៏រលត់ទៅហើយក្នុងវេលានិយាយនេះឯង ។ បុគ្គលនេះឈ្មោះថា មានសម្បជញ្ញៈក្នុងការនិយាយ ។

បុគ្គលណា មានតុណ្ហីភាព មនសិការដល់ធម៌ ឬកម្មដ្ឋានអស់វេលាយូរ តមកពិចារណាឃើញយ៉ាងនេះថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅហើយ ក្នុងវេលាស្ងៀម ក៏បានរលត់ទៅហើយក្នុងវេលាស្ងៀមនោះឯង កាលមានការប្រព្រឹត្តទៅនៃឧបាទាយរូប ( គេ ) ក៏ឈ្មោះថានិយាយ កាលមិនមាន ក៏ឈ្មោះថាជាអ្នកស្ងៀម បុគ្គលនេះឈ្មោះថាមានសម្បជញ្ញៈក្នុងការនៅស្ងៀម ។

សម្បជញ្ញៈ ដែលមានអសម្មោហៈជាធុរៈ ដែលព្រះមហាថេរៈពោលទុកហើយនោះ ព្រះអង្គទ្រង់បំណងយកហើយ ក្នុងសតិប្បដ្ឋានសូត្រ

នេះ ។ ចំណែកក្នុងសាមញ្ញផលសូត្រ បានសម្បជញ្ញៈទាំងអស់ ៤ យ៉ាង ។ ព្រោះដូច្នោះ ក្នុង **សាមញ្ញផលសូត្រ** នេះ អ្នកសិក្សាគប្បីជ្រាបចំពោះសម្បជញ្ញៈទុកជាពិសេស ដោយអំណាចសម្បជញ្ញៈ ដែលមិនវង្វេង ។ ហើយក្នុងគ្រប់ ៗ បទថា **សម្បជានការី សម្បជានការី** អ្នកសិក្សាគប្បីជ្រាបសេចក្ដីអធិប្បាយ ដោយអំណាចសម្បជញ្ញៈ ដែលប្រកបដោយសតិដូចគ្នា ។

ចំណែកក្នុងវិភង្គប្បករណ៍ ព្រះអង្គទ្រង់ចែកបទទាំងនេះ ទុកយ៉ាងនេះ ដូចគ្នាថា ព្រះយោគាវចរមានសតិ មានសម្បជញ្ញៈ ឈានទៅខាងមុខ មានសតិ មានសម្បជញ្ញៈថយក្រោយ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរឈ្មោះថាពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬរបស់អ្នកដទៃ គឺ ក្នុងកាយរបស់ខ្លួនតាមកាល ( ដែលគួរ ) របស់អ្នកដទៃតាមកាល ( ដែលគួរ ) ដោយការកំណត់ដោយសម្បជញ្ញៈ ៤ ប្រការយ៉ាងនេះ ។ សូម្បីក្នុង **ចតុសម្បជញ្ញបព្វ** នេះ ក៏គួរនាំយកការកើតការរលត់នៃរូបក្ខន្ធនោះឯងទៅប្រកបក្នុងពាក្យទាំងឡាយមានជាអាទិ៍ថា **សមុទយវយធម្មានុបស្សី វា** ពាក្យដ៏សេសដូចគ្នានឹងពាក្យ ដែលបានពោលមកហើយនោះឯង ។

## អរិយសច្ចៈ ក្នុងសម្បជញ្ញៈ

ក្នុងទីនេះ សតិដែលកំណត់ដោយសម្បជញ្ញៈ ៤ ប្រការ ជាទុក្ខសច្ចៈ

តណ្ហាពីអតីត ដែលញុំាងសតិឲ្យប្រាកដ ( ជាសមុដ្ឋានរបស់សតិ ) ជាសមុទយសច្ចៈ ការមិនប្រព្រឹត្តទៅនៃសតិ និងតណ្ហាទាំងពីរនោះ ជានិរោធសច្ចៈ អរិយមគ្គ មានប្រការដូចដែលពោលមកហើយ ជាមគ្គសច្ចៈ ព្រះយោគាវចរខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះហើយ នឹងសម្រេចការរលត់ ( តណ្ហា ) ព្រោះដូច្នោះ ទើបជាផ្លូវនាំចេញចាកទុក្ខរហូតដល់អរហត្ត ដោយអំណាចនៃព្រះយោគាវចរ អ្នកកំណត់ដោយសម្បជញ្ញៈ ៤ ប្រការ មួយរូបនោះឯង ។

( ចប់ ចតុសម្បជញ្ញបព្វៈ )

## បដិកូលមនសិការបព្វៈ

[១៣៦] ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកកាយានុបស្សនាដោយអំណាចនៃសម្បជញ្ញៈ ៤ ប្រការដូចពណ៌នាមកនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយអំណាចមនសិការ ដោយជារបស់បដិកូល ទើបបានត្រាស់ពាក្យមានជាអាទិ៍ថា **បុន ចបរំ** ដូច្នេះ ។

គប្បីជ្រាបការវិនិច្ឆ័យក្នុងបដិកូលមនសិការបព្វៈ ដូចតទៅនេះ ៖

ពាក្យណាដែលនឹងត្រូវពោលក្នុងពាក្យថា **ឥមមេវ កាយំ** ជាដើម ពាក្យនោះទាំងអស់ [១] បានពោលទុកហើយក្នុង **កាយគតាសតិកម្មដ្ឋាន** ក្នុងគម្ពីរវិសុទ្ធិមគ្គដោយពិស្តារ ដោយអាការគ្រប់យ៉ាង ។

បទថា **ឧភតោមុខា** សេចក្តីថា ( ថៃ ) ប្រកបដោយមាត់ពីរខាង គឺ ទាំងខាងក្រោម ទាំងខាងលើ ។ បទថា **នានាវិហិតស្ស** ប្រែថា មានប្រភេទផ្សេងៗ ។

ក៏ក្នុងរឿងនេះ មានសេចក្តីឧបមាជាការប្រៀបធៀបដូច្នេះ ៖

អធិប្បាយថា **កាយ** គឺ មហាភូតរូប ៤ គប្បីជ្រាបថា ដូចថៃដែលមានមាត់ទាំងពីរខាង អាការ ៣២ មានសក់ជាដើម គប្បីជ្រាបថា ដូចធញ្ញជាតិច្រើនប្រភេទដែលលាយចម្រុះគ្នាក្នុងថៃ ព្រះយោគាវចរ គប្បីជ្រាបថា ដូចបុរសមានភ្នែកល្អ ។ ការប្រាកដច្បាស់នៃអាការ ៣២ ដល់

[១] ច្បាប់ភូមាមានពាក្យថា សព្វំ ទើបប្រែតាមបាលីរបស់ភូមា ។

ព្រះយោគី គប្បីជ្រាបថា ដូចវេលាដែលធញ្ញជាតិច្រើនគ្រប់ប្រភេទ [២] ប្រាកដដល់បុរសនោះអ្នកស្រាយទៃនោះ ហើយពិនិត្យមើល ដូច្នោះ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរ ឈ្មោះថាពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺក្នុងកាយរបស់ខ្លួនតាមកាល (ដ៏សមគួរ) ឬក្នុងកាយរបស់អ្នកដទៃតាមកាល (ដ៏សមគួរ) ដោយការកំណត់ក្នុងសក់ជាដើម ។

ពាក្យតអំពីនេះទៅ មានន័យដូចដែលបានពោលហើយនោះឯង ។ ពិតណាស់ ក្នុង **បដិកូលមនសិការបព្វ** នេះ សតិដែលកំណត់អាការ ៣២ ជាទុក្ខសច្ចតែម្យ៉ាង អ្នកសិក្សាគួរធ្វើការប្រកបសេចក្ដីដូចដែលពណ៌នាមកយ៉ាងនេះ គប្បីជ្រាបផ្លូវនៃការចេញ ( ចាកទុក្ខ ) ។ ពាក្យដ៏សេស ( អំពីពាក្យដែលអធិប្បាយមកហើយនេះ ) ដូចគ្នានឹងពាក្យមុននោះឯង ។

( ចប់ បដិក្កូលមនសិការបព្វៈ )

---

[២] បាឋៈថា បក្ខិតនានាវិធធញ្ញំ ច្បាប់ភូមាជា បក្ខិត្តនានាវិធធញ្ញស្ស ប្រែតាមភូមា ។

## ធាតុមនសិការបព្វ

[១៣៧] ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកកាយានុបស្សនា ដោយអំណាចបដិកូលមនសិការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយអំណាចមនសិការដល់ធាតុ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **បុនចបរំ** ទុក ៗ ក្នុងពាក្យទាំងនោះ មានការពណ៌នាសេចក្តី ព្រមទាំងពាក្យឧបមាជាការប្រៀបធៀបគ្នា ដូច្នេះ ។

## ប្រៀបធៀបភិក្ខុ ដូចបុគ្គលសម្លាប់គោ

បុគ្គលអ្នកសម្លាប់គោ ឬអន្តេវាសិកនៃបុរសអ្នកសម្លាប់គោ ដែលប៉ិនប្រសប់សម្លាប់គោ ហើយរំលែកជាចំណែក ៗ អង្គុយនៅទៀបផ្លូវធំបែកជា ៤ ពោលគឺ ត្រង់កណ្តាលថ្នល់ធំដែលបែកចេញទៅ ៤ ទិស យ៉ាងណា ភិក្ខុក៏យ៉ាងនោះដូចគ្នា ពិចារណានូវកាយតាមដែលតាំងនៅដោយអាការយ៉ាងណានីមួយ នៃឥរិយាបថទាំង ៤ តាមដែលតម្កល់នៅហើយ ព្រោះតាមដែលបានតាំងសច្ចាបណិធានទុកយ៉ាងនេះថា មាននៅក្នុងកាយនេះ ( គឺ ) ធាតុដី ។ល។ ធាតុខ្យល់ ។

មានពុទ្ធាធិប្បាយទុកដូចម្តេច ?

មានពុទ្ធាធិប្បាយទុកថា បុរសអ្នកសម្លាប់គោ កាលកំពុងចិញ្ចឹមគោក្តី កំពុងដឹកទៅកាន់ទីសម្លាប់ក្តី លុះដឹកទៅហើយកំពុងចង ឲ្យឈរនៅទីនោះក្តី កំពុងសម្លាប់ក្តី កំពុងមើលគោដែលគេសម្លាប់ហើយក្តី ការ

សម្គាល់ថា មេគោ នៅមិនទាន់បាត់ទៅ រហូតវេលាដែលមិនទាន់រំលែក មេគោនោះបែងចេញជាចំណែក ៗ តែកាលអន្ទុយបែងចែក (សាច់) ហើយ សេចក្តីដឹងខ្លួនថា មេគោក៏បាត់ទៅ , ការសម្គាល់ថា សាច់ក៏នឹងប្រព្រឹត្ត ទៅចូលមកជំនួស គេនឹងមិនមានការគិតយ៉ាងនេះថា យើងលក់មេគោ គេ ទាំងនេះទិញមេគោ , ដោយពិត គេនឹងមានការគិតយ៉ាងនេះប៉ុណ្ណោះថា យើងលក់សាច់គោគេទាំងនេះ ទិញសាច់ យ៉ាងណា ។ ក្នុងវេលាដែលភិក្ខុ សូម្បីរូបនេះនៅជាពាលបុថុជ្ជននៅឡើយ ក៏ដូច្នោះដូចគ្នា ការសម្គាល់ថា សត្វ ឬបុគ្គលរបស់លោក កាលនៅជាគ្រហស្ថក្តី បួសហើយក្តី នៅមិន ទាន់អន្តរធានទៅ រហូតវេលាដែលនៅមិនទាន់បានធ្វើ កាយនេះនោះឯង តាមដែលស្ថិតនៅហើយ តាមដែលតាំងនៅហើយ ឲ្យជាការចែកចេញអំពី ដុំហើយ ឃើញដោយភាពជាធាតុ តែកាលលោកពិចារណាឃើញដោយ ភាពជាធាតុ **សត្តសញ្ញា** (សេចក្តីសម្គាល់ថាជាសត្វ) របស់លោកក៏នឹង អន្តរធានទៅ ចិត្តនឹងតាំងនៅដោយអំណាចនៃធាតុនោះឯង ។

ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបបានទ្រង់ត្រាស់ទុកថា អ្នកនឹងពិចារណាឃើញកាយនេះ តាមដែលស្ថិតនៅហើយ តាំងនៅហើយ ដោយភាពជាធាតុថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុ- ខ្យល់ , ម្នាលភិក្ខុទាំងឡាយ នាយគោឃាតក៍អ្នកមិនប្រសប់ ឬ ។ល។ វាយោធាតុ សូម្បីយ៉ាងណា ។

អធិប្បាយថា ភិក្ខុបំពេញព្យាយាម (យោគី) ដូចបុរសអ្នកសម្លាប់

គោ សេចក្ដីសម្គាល់ថាសត្វ ដូចសេចក្ដីសម្គាល់ថា មេគោ ឥរិយាបថ ៤ ដូចផ្លូវធំបែកជា ៤ ការពិចារណាឃើញ (កាយ) ដោយជាធាតុ ដូចនាយគោឃាតក៍អ្នកអង្គុយបែងចែក ( សាច់ ) ចេញជាចំណែក ៗ ។ នេះគឺការពណ៌នាសេចក្ដីតាមព្រះបាលីក្នុង **ធាតុមនសិការបព្វ** នេះ ។ ចំណែកកថាពោលដោយកម្មដ្ឋាន បានអធិប្បាយ ពិស្ដារទុកហើយក្នុងគម្ពីរវិសុទ្ធិ-មគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺ មានប្រក្រតីពិចារណាឃើញកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាល យ៉ាងនេះ គឺ ដោយការកំណត់ធាតុ ៤ ពាក្យតពីនេះ មានន័យដូចដែលពោលមកហើយនោះឯង ។ ព្រោះថាក្នុង **ធាតុមនសិការបព្វ** នេះ សតិដែលកំណត់ធាតុ ៤ ជាទុក្ខសច្ចតែម្យ៉ាង ។

បណ្ឌិតគប្បីជ្រាបឧបាយនៃធម៌ជាគ្រឿងនាំចេញ ( ចាកទុក្ខ ) តាមដែលបានអធិប្បាយសេចក្ដីប្រកបមកយ៉ាងនេះឯង ។ ពាក្យដ៏សេស ដូចពាក្យមុននោះឯង ។

( ចប់ ធាតុមនសិការបព្វ: )

## នវសីវថិកាបព្វ

[១៣៨] ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកកាយានុបស្សនា ដោយអំណាចការមនសិការដល់ធាតុយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយ **នវសីវថិកាបព្វ** (ធម៌ដែលពោលដោយព្រៃស្មសាន ៩) ទើបត្រាស់ពាក្យជាដើមថា **បុន ចបរំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សេយ្យថាបិ បស្សេយ្យ** បានដល់ យថាបស្សេយ្យ (ប្រែថា គប្បីឃើញយ៉ាងណា) ។ បទថា **សរីរំ** បានដល់ រាងកាយរបស់មនុស្សដែលស្លាប់ហើយ ។

បទថា **សីវថិកាយ ឆឌ្ឌិតំ** សេចក្ដីថា ដែលគេបោះបង់ចោលក្នុងព្រៃស្មសាន ។ រាងកាយរបស់មនុស្សដែលស្លាប់ហើយមួយថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះថា **ឯកាហមត** ។

រាងកាយរបស់មនុស្សដែលស្លាប់ហើយពីរថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះថា **ទ្វីហមត** ។

រាងកាយរបស់មនុស្សដែលស្លាប់ហើយបីថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះថា **តីហមត** ។ សាកសពដែលហើមប៉ោងដូចសប់ ឈ្មោះថា **ឧទ្ធុមាតក** (ហើមប៉ោង) ព្រោះហើមប៉ោង ដោយការហើមប៉ោងឡើងទៅតាមលំដាប់ ក្រោយពីការអស់ជីវិតហើយ ។

ពណ៌ខៀវ គេហៅថា **វិនីល** ។ **វិនីលក** ក៏គឺ **វិនីល** នោះឯង ។

ម្យ៉ាងទៀត សរីរៈដែលមានពណ៌ខៀវក្រៃលែង គួរខ្ពើមព្រោះជា

របស់បដិកូល ព្រោះដូច្នោះ ទើបឈ្មោះថា **វិនីលក** ។ ពាក្យថា **វិនីលក** នេះ ជាឈ្មោះរបស់សាកសពដែលមានពណ៌ក្រហម ក្នុងទីដែលមានសាច់ កំពុងមានពណ៌សក្នុងទីដែលមានខ្ទុះកក តែដោយច្រើនមានពណ៌ខៀវក្នុង ទីដែលមានពណ៌ខៀវ ក៏ដូចរុំដោយសំពត់ពណ៌ខៀវ ។

ម្យ៉ាងទៀត ខ្ទុះដែលហូរចេញតាមទ្វារទាំង ៩ សូម្បីក្នុងទីដែលបែក ប្រេះ ហើយឈ្មោះថា **វិបុព្វ** ។ **វិបុព្វ** ក៏គឺ **វិបុព្វក** នោះឯង ។ ម្យ៉ាងទៀត ខ្ទុះដែលជោកជាំគួរខ្ពើមព្រោះបដិកូល ព្រោះដូច្នោះ ទើបឈ្មោះថា **វិបុព្វក** ។ សាកសពដែលក្លាយជាខ្ទុះជោកជាំ គឺ ដល់ភាវៈយ៉ាងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **វិបុព្វកជាត** ។

បទថា **សោ ឥមមេវ កាយំ** សេចក្តីថា ភិក្ខុនោះបង្អោនកាយ របស់ខ្លួននេះចូលទៅ ( ប្រៀបផ្ទឹម ) នឹងកាយនោះដោយញាណ ។

បទថា **ឧបសំហរតិ** ប្រែថា បង្អោននាំចូលទៅ ។

បង្អោននាំចូលទៅ ដូចម្តេច ?

បង្អោនចូលទៅយ៉ាងនេះថា សូម្បីកាយនេះ ក៏ជាធម្មតាយ៉ាងនេះ មានសភាពយ៉ាងនេះ មិនកន្លងផុតភាពជាយ៉ាងនេះឡើយ ។

លោកពោលអធិប្បាយទុក ដូចម្តេច ?

លោកពោលអធិប្បាយទុកថា ព្រោះមានធម៌បីយ៉ាងនេះ គឺ អាយុ ភ្លើងធាតុ វិញ្ញាណ កាយនេះទើបតាំងនៅ និង (ផ្លាស់ប្តូរឥរិយាបថ) មាន ឈរ និងដើរជាដើមបាន តែព្រោះមិនមានធម៌បីនេះ រាងកាយនេះ ទើបមាន

សភាពយ៉ាងនេះជាធម្មតា គឺ មានសភាពជារបស់ពុកផុយយ៉ាងនេះដូចគ្នា ។

បទថា **ឯវំភាវី** សេចក្តីថា ( កាយនេះ ) នឹងជាយ៉ាងនេះដូចគ្នា គឺ នឹងជាប្រភេទ ( ផ្សេង ៗ ) មានជាពងកាយហើមប៉ោងជាដើម ។

បទថា **ឯវំ អនតីតោ** សេចក្តីថា មិនអាចកន្លងចាកសភាពយ៉ាងនេះ គឺ ភាពជាពងកាយដែលហើមប៉ោងជាដើមទៅបាន ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺ មានប្រក្រតីពិចារណាឃើញកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាលដោយអាការយ៉ាងនេះ គឺ ដោយការកំណត់ពងកាយ មានពង-កាយដែលហើមប៉ោងជាដើម ។

បទថា **ខជ្ជមានំ** សេចក្តីថា សរីរៈដែលត្រូវសត្វទាំងឡាយ មានក្អែក និងត្មាតជាដើម ចឹកស៊ី ដោយទំព្រង់អវយវៈ មានពោះជាដើម ហើយចឹកយកសាច់ពោះ សាច់បបូរមាត់ (និង) ត្របកភ្នែកជាដើម ចេញមក ( ស៊ី ) ។

បទថា **សមំសលោហិតំ** សេចក្តីថា សរីរៈដែលប្រកបទៅដោយសាច់ និងឈាមដែលសេសសល់ជាប់នៅ ។

បទថា **និម្មំសលោហិតមក្ខិតំ** សេចក្តីថា សូម្បីកាលសាច់អស់ទៅហើយឈាមនៅមិនទាន់ស្ងួត ព្រះមានព្រះភាគទ្រង់សំដៅយកឈាមនោះទើបត្រាស់ថា **លោហិតមក្ខិតំ** ដូច្នេះ ។

បទថា **អញ្ឆេន** បានដល់ ដោយទិសាភាគដទៃ ។

បទថា **ហត្ថិដ្ឋិកំ** សេចក្តីថា ឆ្អឹងដៃទាំង ៦៤ កំណាត់ខ្ចាត់ខ្ចាយទៅតាមទិសផ្សេង ៗ ពីគ្នា ។ សូម្បីក្នុងឆ្អឹងជើងជាដើម ក៏ន័យដូចគ្នានេះ ។

បទថា **តេរោវស្សិកានិ** បានដល់ ( ឆ្អឹង ) កន្លងទៅ ១ ឆ្នាំហើយ ។

បទថា **បូតីនិ** សេចក្តីថា ឆ្អឹងដែលនៅកណ្តាលវាល កាលត្រូវខ្យល់កម្តៅថ្ងៃ និងទឹកភ្លៀង ទើបពុកផុយ ឆ្អឹងដែលកន្លងទៅ ១ ឆ្នាំ មិនទាន់ពុកផុយ តែឆ្អឹងដែលកប់នៅក្នុងដី រមែងនៅបានយូរជាង ។

បទថា **ចុណ្ណកជាតានិ** បានដល់ លំអិតតូចៗ ខ្ចាត់ខ្ចាយទៅ ។

ក្នុងគ្រប់បទ បណ្ឌិតគប្បីតែងពាក្យប្រកបសេចក្តីដោយអំណាចនៃកាយ ដែលត្រូវសត្វក្អែក និងសត្វខ្លាតចឹកស៊ីជាដើម តាមន័យដែលពោលទុកហើយថា **សោ ឥមមេវ** ដូច្នេះ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺ មានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាល ដោយអាការយ៉ាងនេះ គឺ ដោយការកំណត់កាយ មានកាយដែលត្រូវសត្វខ្លាត សត្វក្អែកជាដើម ចឹកស៊ីជាអាទិ៍ រហូតដល់ជារបស់ពុកផុយខ្ទេចខ្ទី ជាលម្អិតតូច លម្អិតធំ ។

---

# ព្រៃស្មសាន ៩ ( ព្រៃខ្មោច )

ក៏ព្រៃស្មសាន ៩ គប្បីប្រមូលទុកត្រង់នេះ ( គឺ ) ៖

ព្រៃស្មសានទាំងអស់ ដែលត្រាស់ទុកដោយន័យជាដើមថា **ឯកាហមតំ វា** ( សាកសពដែលស្លាប់ហើយបាន ១ ថ្ងៃ ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ជាដើមថា **កាកេហិ វា ខជ្ជមានំ** ( សាកសពដែលត្រូវពួកក្អែកចឹកស៊ី ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **អដ្ឋិសង្ខលិកំ សមំសលោហិតំ នហារុសម្ពន្ធំ** ( សាកសពដែលមានរាងឆ្អឹងព្រមទាំងសាច់ និងឈាម មានសរសៃជាគ្រឿងចង ) ១ ។

ព្រៃស្មសាន (ដែលត្រាស់ទុក) ថា **និម្មំសលោហិតមក្ខិតំ នហារុសម្ពន្ធំ** (សាកសពដែលមិនមានសាច់ តែប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចងរឹត) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក) ថា **អបគតមំសលោហិតំ នហារុសម្ពន្ធំ** ( សាកសពដែលនៅមានតែឆ្អឹង ឥតមានសាច់ និងឈាម តែនៅមានសរសៃជាគ្រឿងចង ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **អដ្ឋិកានិ អបគតសម្ពន្ធនានិ** ( មានតែរាងឆ្អឹងទទេ មិនមានសរសៃជាគ្រឿងចងរួបរឹត ខ្ចាត់ខ្ចាយរាត់រាយទៅកាន់ទិសផ្សេងៗ ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **អដ្ឋិកានិ សេតានិ សង្ខវណ្ណ-**

**បដិកាគានិ** ( នៅសល់តែកង់ឆ្អឹងទទេ មានពណ៌សដូចជាពណ៌នៃស័ង្ខ ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **បុញ្ជកិតានិ តេរោវស្សិកានិ** ( សល់តែឆ្អឹងរោយរាយជាពំនូតៗ កន្លងទៅ ១ ឆ្នាំហើយ ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **បូតីនិ ចុណ្ណកជាតានិ** ( ឆ្អឹងពុកផុយបែកខ្ទេចខ្ទីជាម្សៅ ) ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងព្រៃស្មសាន ៩ យ៉ាងទុកក្នុងទីនេះហើយ កាលនឹងបញ្ចប់កាយានុបស្សនាសតិប្បដ្ឋាន ទើបត្រាស់សម្តែងថា **ឯវំ ខោ ភិក្ខវេ** ដូច្នេះ ។

## អរិយសច្ច ក្នុងនវសីវថិកាបព្វ

សតិជាគ្រឿងកំណត់ព្រៃស្មសាន ៩ ក្នុងនវសីវថិកាបព្វៈនោះ ជា **ទុក្ខសច្ច** តណ្ហាពីអតីតជាហេតុឲ្យកើតសតិនោះ ជា **សមុទយសច្ច** ការមិនប្រព្រឹត្តទៅនៃទុក្ខសច្ច និងសមុទយសច្ចទាំង ២ ជានិរោធសច្ច ។ អរិយមគ្គដែលជាតួកំណត់ដឹងទុក្ខ លះសមុទយៈ មាននិរោធ ( និព្វាន ) ជាអារម្មណ៍ ជាមគ្គសច្ច ។

ព្រះយោគាវចរ រមែងសម្រេចព្រះនិព្វានដោយអំណាចនៃសច្ចៈ ៤ ដូចពណ៌នាមកនេះ សរុបមក នេះជាផ្លូវនៃធម៌ដែលជាគ្រឿងនាំចេញចាកទុក្ខរហូតដល់ព្រះអរហត្ត របស់ភិក្ខុអ្នកកំណត់ព្រៃស្មសាន ៩ ។

( ចប់ នវសីវថិកាបព្វៈ )

ក៏កាយានុបស្សនា ១៤ បព្វៈ គឺ អនាបានបព្វៈ ១ ឥរិយាបថបព្វៈ ១ ចតុសម្បជញ្ញបព្វៈ ១ បដិកូលមនសិការបព្វៈ ១ ធាតុមនសិការបព្វៈ ១ នវសីវថិកាបព្វៈ ៩ ចប់ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

បណ្តាបព្វៈទាំងនោះ ចំពោះ ២ បព្វៈនេះ គឺ អានាបានបព្វៈ ១ បដិកូលមនសិការបព្វៈ ១ ជា **អប្បនាកម្មដ្ឋាន** ( កម្មដ្ឋានដែលឲ្យសម្រេចដល់អប្បនាសមាធិ ) ចំណែកបព្វៈដ៏សេសទាំង ១២ បព្វៈ ជាឧបចារ-កម្មដ្ឋាន ( កម្មដ្ឋានដែលឲ្យសម្រេចដល់ឧបចារសមាធិ ) ប៉ុណ្ណោះ ព្រោះត្រាស់ព្រៃស្មសានទាំងឡាយទុក ដោយអំណាច **អាទីនវានុបស្សនា** នេះ ឯង ។

( ចប់ កាយានុបស្សនា )

## វេទនានុបស្សនា

[១៣៩] ព្រះមានព្រះភាគជាម្ចាស់ លុះត្រាស់កាយានុបស្សនាសតិប្បដ្ឋាន ដោយ វិធី ១៤ យ៉ាង ដូចពណ៌នាមកនេះហើយ ឥឡូវនេះ ដើម្បីនឹងត្រាស់ វេទនានុបស្សនាដោយវិធី ៩ យ៉ាង ទើបត្រាស់ពាក្យមានជាអាទិ៍ថា **កថញ្ច ភិក្ខវេ** ។

## ការដឹងដែលមិនមែនជាសតិប្បដ្ឋានភាវនា

បណ្ដាបទទាំងនោះ បទថា **សុខំ វេទនំ** មានអធិប្បាយថា ព្រះ-យោគាវចរ កាលសោយសុខវេទនាដែលប្រព្រឹត្តទៅតាមផ្លូវកាយ ឬប្រព្រឹត្តទៅតាមផ្លូវចិត្ត រមែងដឹងច្បាស់ថា យើងកំពុងសោយសុខវេទនា ដូច្នេះ ។ ក្នុងសេចក្ដីនោះ សូម្បីទារកដែលដេកផ្ងារ កាលសោយសេចក្ដីសុខ ក្នុងវេលាផឹកទឹកដោះជាដើម ក៏ដឹងច្បាស់ថា យើងកំពុងសោយសុខក៏ពិត សូម្បីដូច្នោះ ពាក្យនេះ ព្រះអង្គក៏មិនបានត្រាស់សំដៅយកការដឹងយ៉ាងនេះ ព្រោះថា ការដឹងយ៉ាងនេះ លះបង់ **សត្តូបលទ្ធិ** មិនបាន ដកសត្តសញ្ញាមិនបាន មិនមែនជាកម្មដ្ឋាន ឬមិនមែនជា **សតិប្បដ្ឋានភាវនា** ។

## ការដឹងដែលជាសតិប្បដ្ឋានភាវនា

ចំណែកការដឹងរបស់ភិក្ខុនេះ លះបង់ **សត្តូបលទ្ធិ** បាន ដក **សត្ត-សញ្ញា** បាន ទាំងជា **កម្មដ្ឋាន** ទាំងជា **សតិប្បដ្ឋានភាវនា** ។ ក៏ការដឹងនេះ

ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយកការសោយ ដោយការដឹងខ្លួនយ៉ាង នេះថា **នរណាសោយ ការសោយរបស់នរណា ព្រោះហេតុអ្វីទើបសោយ** ។

បណ្ដាបទទាំងនោះ បទថា **កោ វេទយតិ** (នរណាសោយ) សេចក្ដីថា មិនមាននរណា គឺ សត្វ ឬបុគ្គលណាសោយឡើយ ។

បទថា **កស្ស វេទនា** ( ការសោយរបស់នរណា ) សេចក្ដីថា មិនមែនការសោយរបស់នរណា គឺ របស់សត្វ ឬបុគ្គលឡើយ ។

បទថា **កឹ ការណា វេទនា** ( ព្រោះហេតុអ្វីទើបសោយ ) សេចក្ដីថា ក៏ព្រោះមានវត្ថុជាអារម្មណ៍ គេទើបមានការសោយ ។

ព្រោះហេតុនោះ ភិក្ខុដឹងច្បាស់យ៉ាងនេះថា វេទនានោះឯងសោយ ដោយធ្វើវត្ថុនៃសេចក្ដីសុខជាដើមនោះ ៗ ឲ្យជាអារម្មណ៍ ។ តែព្រោះសំដៅយកការប្រព្រឹត្តទៅនៃវេទនានោះ ។ ពាក្យថា **អហំ វេទយាមិ** ( អញសោយវេទនា ) ទើបមានត្រឹមតែវោហារប៉ុណ្ណោះ ។

ព្រះយោគាវចរនោះកាលកំណត់ដឹងថា វេទនានោះឯងសោយដោយធ្វើវត្ថុឲ្យជាអារម្មណ៍យ៉ាងនេះ អ្នកសិក្សាគប្បីយល់ថា លោកដឹងច្បាស់ថា អញកំពុងសោយសុខវេទនា ។

ដូចព្រះថេរៈមួយរូប ដែលនៅក្នុងចិត្តលតាបពិតដូច្នោះ ។

## រឿងព្រះថេរៈមួយរូប

បានឮថា ព្រះថេរៈក្នុងវេលាដែលលោកមានអាពាធ ដកដង្ហើមបណ្ដើរ

ដេកបង្រ្គះនទៀលទៅមក ។

ភិក្ខុកំលោះមួយរូបសួរលោកថា លោកម្ចាស់ រោគចាក់ដោតលោកត្រង់កន្លែងណា ?

ព្រះថេរៈឆ្លើយថា អាវុសោ ឈ្មោះថា ទីដែលរោគចាក់ដោតចំពោះកន្លែងមិនមាន វេទនាផ្សេង ៗ សោយដោយធ្វើវត្ថុឲ្យជាអារម្មណ៍ ។ ភិក្ខុកំលោះប្រាប់ថា កាលបើដូច្នោះ លោកគួរនឹងទប់ទល់តាំងពីពេលដែលដឹងមិនមែនឬ លោកម្ចាស់ ? ព្រះថេរៈឆ្លើយថា ខ្ញុំកំពុងទប់ទល់ណា៎លោក ។ ភិក្ខុកំលោះប្រាប់ថា លោកម្ចាស់ ការទប់ទល់ជារបស់ប្រសើរ ។

ព្រះថេរៈបានទប់ទល់ហើយ ។

លំដាប់នោះ ខ្យល់ចាក់ដោតដល់បេះដូង ។ ពោះវៀនធំបានលៀនចេញមកគរនៅលើគ្រែ ព្រះថេរៈបានបង្ហាញឲ្យភិក្ខុកំលោះមើលថា ទប់ទល់ប៉ុណ្ណេះ សមគួរឬនៅលោក ភិក្ខុកំលោះក៏នៅស្ងៀម ។ ព្រះថេរៈប្រកបសេចក្ដីព្យាយាមជានិច្ច ហើយបានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាជាព្រះអរហន្ត ( ប្រភេទ ) ជីវិតសមសីសី ហើយបរិនិព្វាន ។

កាលព្រះយោគាវចរដឹងច្បាស់ ( ថា ) សុខយ៉ាងណា ទុក្ខយ៉ាងនោះ ។ល។ កាលសោយអទុក្ខមសុខវេទនា មិនអាស្រ័យដោយអាមិស ក៏ដឹងច្បាស់ថា អញកំពុងសោយអទុក្ខមសុខវេទនា មិនអាស្រ័យដោយអាមិស ។

---

## រូបកម្មដ្ឋាន-អរូបកម្មដ្ឋាន

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់ប្រាប់រូបកម្មដ្ឋានដោយអាការយ៉ាងនេះហើយ កាលនឹងត្រាស់អរូបកម្មដ្ឋាន ទើបបានត្រាស់ប្រាប់ដោយអំណាចនៃវេទនា ព្រោះថា កម្មដ្ឋាន មាន ២ យ៉ាងគឺ **រូបកម្មដ្ឋាន** ១ **អរូបកម្មដ្ឋាន** ១ ។ **រូបកម្មដ្ឋាន** និង **អរូបកម្មដ្ឋាន** នេះនោះឯង ត្រាស់ហៅថា **រូបបរិគ្គហ** ( ការកំណត់រូប ) **អរូបបរិគ្គហ** ( ការកំណត់អរូប ) ក៏មាន ។

បណ្តា **រូបកម្មដ្ឋាន** និង **អរូបកម្មដ្ឋាន** នោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងត្រាស់ប្រាប់ **រូបកម្មដ្ឋាន** ទើបត្រាស់ **ចតុធាតុវវដ្ឋាន** ( ការកំណត់ធាតុ ៤ ) ទុកដោយអំណាចនៃ **មនសិការ** ដោយសង្ខេបខ្លះ ដោយអំណាចនៃការមនសិការដោយពិស្តារខ្លះ ។ កម្មដ្ឋានសូម្បីទាំង ២ យ៉ាងនោះ បានសម្តែងទុកហើយក្នុង **គម្ពីរវិសុទ្ធិមគ្គ** ដោយអាការទាំងពួងនោះឯង ។ តែព្រះមានព្រះភាគជាម្ចាស់ កាលនឹងត្រាស់ប្រាប់អរូបកម្ម-ដ្ឋាន ដោយច្រើន ក៏នឹងត្រាស់ប្រាប់ដោយអំណាចនៃវេទនា ។ ព្រោះថា ការធ្វើទុកក្នុងចិត្តនូវអរូបកម្មដ្ឋាន មាន ៣ យ៉ាង គឺ ( ផ្តោតចិត្ត ) **ដោយអំណាចនៃផស្សៈ ១ ដោយអំណាចនៃវេទនា ១ ដោយអំណាចនៃចិត្ត ១** ។

ផ្តោតចិត្តដូចម្តេច ?

( ផ្តោតចិត្តយ៉ាងនេះ គឺ ) ពិតណាស់ ផស្សៈ កាលពាល់ត្រូវអារម្មណ៍នោះកើតឡើង ក្នុងខណៈដែលចិត្ត និងចេតសិកប្រព្រឹត្តទៅ ចំពោះ

គ្រាដំបូងនៃអារម្មណ៍នោះ នឹងមកប្រាកដដល់ព្រះយោគាវចររូបខ្លះ ក្នុងរូបកម្មដ្ឋាន ដែលលោកកំណត់ហើយដោយសង្ខេប ឬដោយពិស្តារ ។ វេទនាកាលសោយអារម្មណ៍នោះកើតឡើង នឹងប្រាកដដល់ព្រះយោគាវចររូបខ្លះ វិញ្ញាណកាលកំណត់អារម្មណ៍នោះ ដឹងហើយកើតឡើងដល់យោគាវចររូបខ្លះ ។ បណ្ដាផស្សៈ វេទនា វិញ្ញាណទាំងនោះ ផស្សៈ ប្រាកដដល់ព្រះយោគាវចរណា មិនចំពោះតែផស្សៈប៉ុណ្ណោះ ដែលកើតឡើង សូម្បីវេទនាដែលសោយអារម្មណ៍នោះ ក៏កើតឡើងជាមួយនឹងផស្សៈដែរ សូម្បីសញ្ញាដែលចាំបាន សូម្បីចេតនាដែលតាំងចិត្ត សូម្បីវិញ្ញាណដែលដឹងច្បាស់នូវអារម្មណ៍នោះ ៗ នឹងកើតឡើងព្រមជាមួយផស្សៈនោះដែរ ព្រោះដូច្នោះ ព្រះយោគាវចរនោះ រមែងកំណត់ចេតសិកធម៌ មានផស្សៈជាទី ៥ នោះឯង ។

វេទនាណា ប្រាកដដល់ព្រះយោគាវចរ មិនចំពោះវេទនាម្យ៉ាងនោះប៉ុណ្ណោះទេដែលកើតឡើង សូម្បីផស្សៈដែលពាល់ត្រូវ ក៏នឹងកើតឡើងជាមួយនឹងវេទនានោះដែរ សូម្បីសញ្ញាដែលចាំអារម្មណ៍ សូម្បីចេតនាដែលតាំងចិត្ត សូម្បីវិញ្ញាណដែលដឹងច្បាស់ ក៏នឹងកើតឡើងជាមួយនឹងវេទនានោះដែរ ព្រោះដូច្នោះ ព្រះយោគាវចរនោះ ក៏រមែងកំណត់ចេតសិកធម៌មានផស្សៈជាទី ៥ នោះឯង ។

សូម្បីវិញ្ញាណ នឹងប្រាកដដល់ព្រះយោគាវចរណា មិនចំពោះតែវិញ្ញាណនោះតែម្យ៉ាងប៉ុណ្ណោះនឹងកើតឡើង សូម្បីផស្សៈ ដែលពាល់ត្រូវ

អារម្មណ៍នោះ ៗ ឯង ក៏នឹងកើតឡើងជាមួយនឹងវិញ្ញាណនោះដែរ សូម្បីវេទនាដែលសោយ សូម្បីសញ្ញាដែលចាំបានសម្គាល់បាន សូម្បីចេតនាដែលតាំងចិត្តចំពោះអារម្មណ៍នោះ ក៏នឹងកើតឡើងជាមួយវិញ្ញាណនោះដែរ ព្រោះដូច្នោះ ព្រះយោគាវចរនោះ រមែងកំណត់ដឹងចេតសិកធម៌ មានផស្សៈជាទី ៥ នោះឯង ។

ព្រះយោគាវចរនោះ កាលពិចារណាថា ធម៌មានផស្សៈជាទី ៥ ទាំងនេះអាស្រ័យនឹងអ្វី ។

នឹងជ្រាបច្បាស់ថា អាស្រ័យវត្ថុ ។

ករជកាយ ឈ្មោះថា វត្ថុ ព្រះមានព្រះភាគជាម្ចាស់ត្រាស់សំដៅយកថា ក៏ឯវិញ្ញាណរបស់យើងនេះ អាស្រ័យនៅក្នុងករជកាយនេះ ជាប់ជំពាក់នៅក្នុងករជកាយនេះ ។

ដោយសេចក្តី ព្រះយោគាវចរនោះ រមែងឃើញទាំង ( មហា ) ភូតរូប ទាំងឧបាទាយរូប កាលបើដូច្នោះ ក្នុងវេទនាបព្វៈនេះ ព្រះយោគាវចរនឹងឃើញត្រឹមតែនាមរូបប៉ុណ្ណោះថា វត្ថុ ជារូប ចេតសិកធម៌មានផស្សៈជាទី ៥ ជានាម ។ ក្នុងសេចក្តីនេះ រូប បានដល់ រូបក្ខន្ធ នាម បានដល់ អរូបក្ខន្ធទាំង ៤ ព្រោះដូច្នោះ ទើបមានត្រឹមតែបញ្ចក្ខន្ធប៉ុណ្ណោះ ។ ព្រោះថា បញ្ចក្ខន្ធ ដែលនឹងផុតចាកនាមរូប ឬនាមរូប ដែលនឹងផុតអំពីបញ្ចក្ខន្ធមិនមាន ។

ព្រះយោគាវចរនោះ កាលវិគ្រោះពិចារណាថា បញ្ចក្ខន្ធទាំងនេះ

មានអ្វីជាហេតុ ក៏នឹងឃើញថា មានអវិជ្ជាជាដើមហេតុ ។ បន្ទាប់ពីនោះ ព្រះយោគាវចរនឹងលើកយក ( បញ្ចក្ខន្ធ ) ឡើងកាន់ត្រៃលក្ខណ៍ដោយ អំណាចនាមរូបព្រមទាំងបច្ច័យថា នេះ ( ត្រឹមតែ ) បច្ច័យ និងធម៌ដែល អាស្រ័យបច្ច័យកើតឡើង មិនមានអ្វីយ៉ាងដទៃដែលជាសត្វ ឬបុគ្គល មាន ត្រឹមតែគំនរសង្ខារសុទ្ធ ៗ ប៉ុណ្ណោះ ហើយពិចារណាត្រួតត្រាទៅថា **អនិច្ចំ ទុក្ខំ អនត្តា** តាមលំដាប់នៃវិបស្សនា ។

លោកសង្ឃឹមចំពោះបដិវេធថា (នឹងបានសម្រេច) ថ្ងៃនេះ ថ្ងៃនេះ បាន **ឧតុសប្បាយ** ( អាកាសសប្បាយ ) **បុគ្គលសប្បាយ** ( បុគ្គលសប្បាយ ) **ភោជនសប្បាយ** ( ភោជនសប្បាយ ) **ធម្មស្សវនសប្បាយ** ( ការស្តាប់ ធម៌សប្បាយ ) អង្គុយពែនភ្នែន ញ៉ាំងវិបស្សនាឲ្យដល់ទីបំផុត ហើយតាំង នៅក្នុងព្រះអរហត្តមគ្គ ដោយប្រការដូចពោលមកនេះ ជាការដែលត្រាស់ ប្រាប់ព្រះកម្មដ្ឋានដល់ជនទាំង ៣ សូម្បីទាំងនេះ រហូតដល់ព្រះអរហត្ត ។

## វេទនា គឺ អរូបកម្មដ្ឋាន

ប៉ុន្តែក្នុងសតិប្បដ្ឋានសូត្រនេះ ព្រះមានព្រះភាគ កាលទ្រង់ត្រាស់ ប្រាប់អរូបកម្មដ្ឋាន ទើបបានត្រាស់ទុកដោយអំណាចនៃវេទនា ។ ព្រោះថា កាលត្រាស់ប្រាប់ដោយអំណាចនៃផស្សៈ ឬដោយអំណាចនៃវិញ្ញាណ កម្ម-ដ្ឋាននឹងមិនប្រាកដ នឹងប្រាកដដូចកាពងងឹត ។ ចំណែកដែលត្រាស់ប្រាប់ ដោយអំណាចនៃវេទនា កម្មដ្ឋាននឹងប្រាកដ ។

ព្រោះហេតុអ្វី ?

ព្រោះកម្មដ្ឋាននឹងប្រាកដ ក៏ព្រោះវេទនាកើតឡើង ។ ពិតណាស់ ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនា នឹងប្រាកដ ចំពោះកាលសេចក្តីសុខកើតឡើង បានដល់ សុខដែលកើតឡើងធ្វើឲ្យញាប់ញ័រពេញសព៌ាង្គកាយ ជ្រួតជ្រាបទៅរហូតពេញ (បេះដូង) ដូចការបានផឹកទឹកដោះថ្លាដែលគូររាប់រយដង ដូចឲ្យលាបប្រេងដែលដាំហើយ ១ រយដង និងដូចឲ្យរំលត់កាពក្តៅអន្ទះអន្ទែងដោយទឹកមួយពាន់ផ្ទាំង ធ្វើឲ្យបន្លឺវាចាចេញទៅថា សុខហ្ន៎ សុខហ្ន៎ ដូច្នេះ ( ហើយ ) កាលសេចក្តីទុក្ខកើតឡើង បានដល់ សេចក្តីទុក្ខដែលកើតឡើង ធ្វើឲ្យញាប់ញ័រទូទាំងរាងកាយ ហូរជ្រួតជ្រាបទៅពេញប្រៀប ( ក្នុងបេះដូង ) ដូចឲ្យចូលទៅកាន់អណ្តាតភ្លើងដែលក្តៅគគុក ក្រាស់ដោយទឹកទង់ដែង ដែលរលាយវិលវល់ និងដូចបោះដុំភ្លើងចូលទៅក្នុងព្រៃ ដែលមានស្មៅស្ងួត និងឈើងាប់ ហើយឲ្យស្រែកថ្ងូរថា ទុក្ខណាស់ហ្ន៎ ទុក្ខណាស់ហ្ន៎ ។ ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនា នឹងប្រាកដឡើងបាន ដោយអាការយ៉ាងនេះ ។

ចំណែកអទុក្ខមសុខវេទនា សំដែង (ឲ្យឃើញ) បានលំបាក ងងឹតមិនជាក់ច្បាស់ ។ អទុក្ខមសុខវេទនានោះ នឹងប្រាកដដល់ព្រះយោគាវចរអ្នកប្រកាន់មាំ ដោយន័យថា អទុក្ខមសុខវេទនា មានអាការជាកណ្តាលដោយការលះបង់ចោលសេចក្តីសុខ និងទុក្ខ ក្នុងកាលសុខ និងទុក្ខអស់ទៅ ។

ប្រៀបដូចអ្វី ?

ប្រៀបដូចនាយព្រានម្រឹគ ដើរតាមស្នាមជើងម្រឹគ ដែលលោតឡើងលើថ្មចន្លោះផ្លូវ ហើយគេចទៅ (គេ) ឃើញស្នាមជើងទាំងខាងនេះ ទាំងខាងនោះនៃផ្ទាំងថ្ម សូម្បីនឹងមិនឃើញ (ស្នាមជើង) ត្រង់កណ្តាល (លើផ្ទាំងថ្ម ) ក៏ជ្រាបបានដោយន័យថា ម្រឹគឡើងតាមផ្លូវនេះ ហើយចុះទៅតាមផ្លូវនោះ គង់នឹងឆ្លងកាត់ទៅខាងនេះ លើផ្ទាំងថ្មត្រង់កណ្តាល យ៉ាងណា ការកើតឡើងនៃសុខវេទនាក៏ដូច្នោះ នឹងប្រាកដដូចស្នាមជើង ( ម្រឹគដែលប្រាកដ ) ក្នុងទីដែលវានឹងឡើងទៅ ការកើតនៃទុក្ខវេទនា នឹងប្រាកដដូចស្នាមជើង ( ម្រឹគ) ក្នុងទីដែលវាចុះទៅដូច្នោះ ។ អទុក្ខមសុខវេទនានឹងប្រាកដដល់ព្រះយោគាវចរ អ្នកប្រកាន់មាំដោយន័យថា អទុក្ខមសុខវេទនាមានអាការជាកណ្តាល ដោយរលាស់ចោលការសប្បាយ និងមិនសប្បាយក្នុងកាលសុខវេទនា និងទុក្ខវេទនាបាត់ទៅ ដូចការសម្គាល់ថា ឆ្លងទៅត្រង់កណ្តាលនេះឯង ដោយឡើងតាមផ្លូវខាងនេះ ហើយចុះទៅតាមផ្លូវខាងនោះ ដូច្នោះ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងសតិប្បដ្ឋានដោយត្រាស់រូបកម្មដ្ឋានមុនហើយ ញ៉ាំងអរូបកម្មដ្ឋានឲ្យកើតឡើង ដោយអំណាចវេទនាក្នុងខាងក្រោយ ។ វេទនា គឺ អរូបកម្មដ្ឋាន មានក្នុងព្រះសូត្រច្រើនកន្លែង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកយ៉ាងនេះ តែក្នុងសតិប្បដ្ឋាន-សូត្រនេះ តែម្យ៉ាងក៏ទេ (តែ) ទ្រង់ត្រាស់សម្តែងដោយត្រាស់រូបកម្មដ្ឋានហើយញ៉ាំងអរូបកម្មដ្ឋានឲ្យកើតឡើងដោយអំណាច វេទនាក្នុងខាងក្រោយ

ក្នុងព្រះសូត្រច្រើនព្រះសូត្រ ច្រើនកន្លែងយ៉ាងនេះ គឺ ក្នុង ចុល្លតណ្ហាសង្ខយសូត្រ ក្នុង មហាតណ្ហាសង្ខយសូត្រ ក្នុង ចុល្លវេទល្លសូត្រ ក្នុង មហាវេទល្លសូត្រ ក្នុង រដ្ឋបាលសូត្រ ក្នុង មាគណ្ឌិយសូត្រ ក្នុង ធាតុវិភង្គសូត្រ ក្នុង អានេញ្ជសប្បាយសូត្រ ក្នុង មហានិទានសូត្រ ក្នុង សក្កបញ្ហសូត្រ ក្នុង មហាសតិប្បដ្ឋានសូត្រ ក្នុង ទីឃនិកាយ ក្នុង ចុល្លនិទានសូត្រ ក្នុង វេក្ខាបមសូត្រ ក្នុង បរិវីមង្សនសូត្រ និងក្នុង វេទនាសំយុត្ត ទាំងអស់ ក្នុង សំយុត្តនិកាយ ហើយសូម្បីក្នុង សតិប្បដ្ឋានសូត្រ នេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងដោយត្រាស់ប្រាប់រូបកម្មដ្ឋានមុន ទើបទ្រង់ញ៉ាំងអរូបកម្មដ្ឋានឲ្យកើតដោយអំណាចនៃវេទនាខាងក្រោយ ដូចក្នុងព្រះសូត្រទាំងនោះ ។ បណ្ដាបទទាំងនោះ មានបរិយាយនៃការដឹងច្បាស់នូវវេទនាមយ៉ាងទៀត ដូចតទៅនេះ ៖

## សុខវេទនាប្រែប្រួល

សេចក្ដីថា **សុខំ វេទនំ វេទិយាមីតិ បជានាតិ** សេចក្ដីថា ព្រោះមិនមានទុក្ខវេទនា ក្នុងខណៈនៃសុខវេទនា ព្រះយោគាវចរ កាលសោយសុខវេទនា ក៏ដឹងច្បាស់ថា យើងកំពុងសោយសុខវេទនា ។ វេទនាឈ្មោះថា មិនទៀង មិនស្ថិតស្ថេរ មានការប្រែប្រួលជាធម្មតា ព្រោះទុក្ខវេទនាដែលធ្លាប់សោយមកពីមុន ក្នុងកាលឥឡូវនេះមិនមានឡើយ ព្រោះសុខវេទនានេះ មុនអំពីនេះក៏មិនមាន ព្រោះដូច្នោះ ព្រះយោគាវចរទើបជា

ការដែលដឹងច្បាស់ក្នុងសុខវេទនា និងទុក្ខវេទនានោះ ដូចពណ៌នាមកនេះ ដោយពាក្យថា **សុខំ វេទនំ វេទិយាមីតិ បជានាតិ** នោះ ។

សមពិតដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកដូច្នេះថា ( ម្នាលអគ្គិវេស្សនៈ ក្នុងសម័យណា បុគ្គលសោយសុខវេទនា ក្នុងសម័យនោះ នឹងមិនសោយទុក្ខវេទនា នឹងមិនសោយអទុក្ខមសុខ-វេទនា ក្នុងសម័យនោះ សោយតែសុខវេទនាតែម្យ៉ាង ម្នាលអគ្គិវេស្សនៈ ក្នុងសម័យណាបុគ្គលសោយទុក្ខវេទនា ។ល។ សោយនូវអទុក្ខមសុខ-វេទនា ក្នុងសម័យនោះនឹងមិនសោយសុខវេទនាឡើយ ក្នុងសម័យនោះ សោយអទុក្ខមសុខតែម្យ៉ាង ម្នាលអគ្គិវេស្សនៈ សូម្បីសុខវេទនាក៏មិនទៀង ត្រូវបច្ច័យប្រជុំតាក់តែង អាស្រ័យបច្ច័យទើបកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការបន្ទោបង់តម្រេកជាធម្មតា មានការរលត់ជាធម្មតា សូម្បីទុក្ខវេទនា ។ល។ ម្នាលអគ្គិវេស្សនៈ សូម្បីអទុក្ខមសុខវេទនាក៏មិនទៀង ។ល។ មានការរលត់ជាធម្មតា ម្នាលអគ្គិ-វេស្សនៈ ព្រះអរិយសាវកអ្នកបានស្តាប់ កាលឃើញយ៉ាងនេះ រមែងនឿយណាយទាំងក្នុងសុខវេទនា រមែងនឿយណាយទាំងក្នុងទុក្ខវេទនា រមែងនឿយណាយទាំងក្នុងអទុក្ខមសុខវេទនា កាលនឿយណាយ រមែងបន្ទោ-បង់តម្រេក ព្រោះបន្ទោបង់តម្រេក ទើបរួចផុត រួចផុតហើយក៏ដឹងច្បាស់ថា យើងរួចផុតហើយ រមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈនៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើស្រេចហើយ កិច្ចដែលគួរធ្វើយ៉ាង

ដទៃ សូម្បីការៈជាយ៉ាងនេះមិនមាន ។

ក្នុងពាក្យថា **សាមិសំ វា សុខំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

**សោមនស្សវេទនា** ដែលអាស្រ័យ ( កើតមកពី ) ផ្ទះ ( **តណ្ហាឧបាទាន** ) ៦ យ៉ាង លាយឡំដោយអាមិស គឺ បញ្ចកាមគុណ ឈ្មោះថា **សាមិសសុខវេទនា** ។

សោមនស្សវេទនាដែលអាស្រ័យ (កើតមកពី) នេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា **និរាមិសសុខវេទនា** ។

ទោមនស្សវេទនាដែលអាស្រ័យ ( កើតមកពី ) ផ្ទះ ( តណ្ហា-ឧបាទាន ) ៦ យ៉ាង ឈ្មោះថា **សាមិសទុក្ខវេទនា** ។

ទោមនស្សវេទនាដែលអាស្រ័យ ( កើតមកពី ) នេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា **និរាមិសទុក្ខវេទនា** ។

ឧបេក្ខាវេទនាដែលអាស្រ័យ ( កើតមកពី ) ផ្ទះ ( **តណ្ហាឧបាទាន** ) ៦ យ៉ាង ឈ្មោះថា **សាមិសអទុក្ខមសុខវេទនា** ។

ឧបេក្ខាវេទនា ដែលអាស្រ័យ ( កើតមកពី ) នេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា **និរាមិសអទុក្ខមសុខវេទនា** ។ ការបែកវេទនាទាំងនោះ មកច្បាស់ហើយក្នុងព្រះបាលី ក្នុង **ឧបរិបណ្ណាសក** ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយរបស់ខ្លួន ឬក្នុងវេទនាទាំងឡាយ

របស់អ្នកដទៃ គឺ ក្នុងវេទនាទាំងឡាយរបស់ខ្លួនតាមកាល ឬក្នុងវេទនាទាំងឡាយ របស់អ្នកដទៃតាមកាល ។

ក៏បទថា **សមុទយវយធម្មានុបស្សី វា** នេះ គប្បីជ្រាបសេចក្ដីថា ព្រះយោគាវចរ កាលឃើញការកើតឡើង និងការសូន្យទៅនៃវេទនាទាំងឡាយ ដោយអាការ ៥ មានជាអាទិ៍ គឺ ព្រោះអវិជ្ជាកើត វេទនាទើបកើត ឈ្មោះថា មានប្រក្រតីពិចារណាឃើញធម៌ គឺ ការកើតឡើងក្នុងវេទនាទាំងឡាយ ឬមានប្រក្រតីពិចារណាឃើញធម៌ គឺ ការសូន្យទៅក្នុងវេទនាទាំងឡាយ គឺ មានប្រក្រតីពិចារណាឃើញធម៌ គឺ ការកើតឡើងក្នុងវេទនាទាំងឡាយតាមកាល ឬមានប្រក្រតីពិចារណាឃើញធម៌ គឺ ការអស់ទៅក្នុងវេទនាទាំងឡាយតាមកាល ។ ពាក្យក្រៅពីនេះ មានន័យដូចពោលហើយក្នុងកាយានុបស្សនា នោះឯង ។

## អរិយសច្ច ក្នុងវេទនា

ក៏សតិជាគ្រឿងកំណត់វេទនាក្នុងវេទនានុបស្សនានេះ ជាទុក្ខសច្ចៈ តែម្យ៉ាង បណ្ឌិតគប្បីជ្រាបផ្លូវនៃធម៌ជាគ្រឿងនាំចេញចាកទុក្ខរបស់ភិក្ខុអ្នកកំណត់វេទនា ព្រោះអធិប្បាយប្រកបសេចក្ដីដូចពោលមកនេះឯង ពាក្យដ៏សេស ( ដូចពាក្យដែលពោលមកហើយ ) នោះឯង ។

( ចប់ វេទនានុបស្សនា )

# អធិប្បាយ ចិត្តានុបស្សនា

[១៤០] ព្រះមានព្រះភាគ លុះទ្រង់ត្រាស់សតិប្បដ្ឋាន គឺ វេទនានុបស្សនា ដោយអាការ ៩ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងត្រាស់ចិត្តានុបស្សនា ដោយអាការ ១៦ យ៉ាង ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សរាគំ** បានដល់ ចិត្តដែលសហគត ដោយលោភៈ ៨ យ៉ាង ។

បទថា **វីតរាគំ** បានដល់ កុសលចិត្តផ្នែកលោកិយៈ និងអព្យាកតចិត្ត ក៏ចិត្តដែលប្រាសចាករាគៈនេះ ក្នុងចិត្តានុបស្សនានេះ មិនបាន សំដៅ ដល់លោកុត្តរចិត្តសូម្បីតែក្នុងមួយបទ ព្រោះការពិចារណាមិនមែន ជាការប្រជុំធម៌ ( ចំណែក ) **អកុសលចិត្ត ៤ ដួង** ដ៏សេស មិនចាត់ចូល ក្នុងបទដំបូង ទាំងមិនចាត់ចូលក្នុងបទក្រោយ ។

បទថា **សទោសំ** បានដល់ ចិត្តដែលសហគតដោយទោមនស្ស ២ ដួង ។

បទថា **វីតទោសំ** បានដល់ កុសលចិត្តផ្នែកលោកិយៈ និងអព្យាកតៈ ។

**អកុសលចិត្ត ១០** ដួងដ៏សេស មិនចាត់ចូលក្នុងបទដំបូង ទាំងមិន ចាត់ចូលក្នុងបទក្រោយ ។

បទថា **សមោហំ** បានដល់ អកុសលចិត្ត ២ ដួង គឺ អកុសលចិត្ត ដែលសហគតដោយវិចិកិច្ឆា ១ ដួង អកុសលដែលសហគតដោយឧទ្ធច្ចៈ

១ ដួង ។

ព្រោះមោហៈ រមែងកើតឡើងក្នុងអកុសលចិត្តគ្រប់ដួង ដូច្នោះ អកុសលចិត្តទាំងអស់ សូម្បីទាំងពីរនោះ ទើបសមគួរ ( នឹងចាត់ចូល ) ក្នុងចិត្តានុបស្សនានេះ ដោយពិត ។

ពិតណាស់ ក្នុងចិត្តដែលជាគូគ្នានេះឯង លោកចាត់អកុសលចិត្ត ១២ ដួងទុកហើយ ។

បទថា **វីតមោហំ** បានដល់ លោកិយកុសលចិត្ត និងអព្យាកតចិត្ត ។

បទថា **សង្ខិត្តំ** បានដល់ ចិត្តដែលសហគតដោយថីនមិទ្ធៈ ក៏ចិត្តដែលសហគតដោយថីនមិទ្ធៈនោះ ឈ្មោះថា ចិត្តរួញរា ។

បទថា **វិក្ខិត្តំ** បានដល់ ចិត្តដែលសហគតដោយឧទ្ធច្ចៈ ក៏ចិត្តដែលសហគតដោយឧទ្ធច្ចៈនោះ ឈ្មោះថា ចិត្តរាយមាយ ។

បទថា **មហគ្គតំ** បានដល់ រូបាវចរចិត្ត និងអរូបាវចរចិត្ត ។

បទថា **អមហគ្គតំ** បានដល់ កាមាវចរចិត្ត ។

បទថា **សឧត្តរំ** បានដល់ កាមាវចរចិត្ត ។

បទថា **អនុត្តរំ** បានដល់ រូបាវចរចិត្ត អរូបាវចរចិត្ត ។

ម្យ៉ាងទៀត ក្នុងបទទាំង ២ ថា **សឧត្តរំ អនុត្តរំ** នោះ **សឧត្តរចិត្ត** បានដល់ រូបាវចរចិត្ត **អនុត្តរចិត្ត** បានដល់ អរូបាវចរចិត្តនោះឯង ។

បទថា **សមាហិតំ** បានដល់ ចិត្តដែលមានអប្បនាសមាធិ ឬឧបចារសមាធិ ។

បទថា **អសមាហិតំ** បានដល់ ចិត្តដែលមិនមានសមាធិទាំង ២ ។

បទថា **វិមុត្តំ** បានដល់ ចិត្តដែលរួចផុតហើយ ដោយ **តទង្គវិមុត្តិ** និង **វិក្ខម្ភនវិមុត្តិ** ។

បទថា **អវិមុត្តំ** បានដល់ ចិត្តដែលមិនមានវិមុត្តិទាំង ២ ។

ចំណែក **សមុច្ឆេទវិមុត្តិ បដិប្បស្សទ្ធិវិមុត្តិ** និង **និស្សរណវិមុត្តិ** មិនមានឱកាស ( មិនបាននិយាយដល់ ) ក្នុងចិត្តានុបស្សនានេះឡើយ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរកាលកំណត់ចិត្តដែលប្រព្រឹត្តទៅគ្រប់ខណៈ ដោយការកំណត់ចិត្ត មានសរាគចិត្តជាដើម យ៉ាងនេះ ឈ្មោះថា មានប្រក្រតីតាមឃើញចិត្តក្នុងចិត្តរបស់ខ្លួន ឬក្នុងចិត្តរបស់អ្នកដទៃ ( ខ្លះ ) ឈ្មោះថា មានប្រក្រតីតាមឃើញចិត្តក្នុងចិត្តរបស់ខ្លួនតាមកាល ឬក្នុងចិត្តរបស់បុគ្គលដទៃតាមកាល ( ខ្លះ ) ។

ចំណែកក្នុងបទថា **សមុទយវយធម្មានុបស្សី** ( មានប្រក្រតីតាមឃើញធម៌ គឺ ការកើតឡើង និងការសូន្យទៅ ) នេះ គួរពង្រីកការកើត និងការរលត់នៃវិញ្ញាណ ១ ដួង ៗ ចែកចេញជា ៥ អាការដូច្នេះ គឺ ព្រោះអវិជ្ជាកើត វិញ្ញាណទើបកើតជាដើម ។ ពាក្យក្រៅពីនេះ មានន័យដូចពោលហើយនោះឯង ។

## អរិយសច្ច ក្នុងចិត្តានុបស្សនា

ក៏សតិជាគ្រឿងកំណត់ចិត្តក្នុងចិត្តានុបស្សនានេះ ជាទុក្ខសច្ចតែម្យ៉ាង

បណ្ឌិតគប្បីជ្រាប មុខនាទីនៃធម៌នាំចេញចាកទុក្ខ របស់ភិក្ខុអ្នកកំណត់ចិត្ត តាមដែលបានអធិប្បាយមកយ៉ាងនេះឯង ។ ពាក្យដ៏សេស ( មានន័យ ) ដូច ( ពោលមកនោះឯង ) ។

( ចប់ ចិត្តានុបស្សនា )

# អធិប្បាយ ធម្មានុបស្សនា

[១៤១] កាលព្រះអង្គត្រាស់ចិត្តានុបស្សនាសតិប្បដ្ឋាន ដោយអាការ ១៦ យ៉ាង ដូចពណ៌នាមកនេះ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងធម្មានុបស្សនា ដោយអាការ ៥ យ៉ាង ។ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

ប្រការមួយទៀត ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ការកំណត់រូបសុទ្ធ ៗ ដោយកាយានុបស្សនា ត្រាស់ការកំណត់នាមសុទ្ធ ៗ ដោយវេទនានុបស្សនា និងចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីនឹងត្រូវការត្រាស់ការកំណត់រួមគ្នាទាំងរូប និងនាម ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

មួយ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ចំពោះការកំណត់រូបក្ខន្ធ ដោយកាយានុបស្សនា ត្រាស់ការកំណត់វេទនាខន្ធ ដោយវេទនានុបស្សនា ត្រាស់ការកំណត់វិញ្ញាណក្ខន្ធ ដោយចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីនឹងត្រាស់ការកំណត់វិញ្ញាណក្ខន្ធ និងសង្ខារក្ខន្ធខ្វះ ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះ ជាដើម ។

## នីវរណបព្វ

បណ្តាបទទាំងនោះ បទថា **សន្តំ** បានដល់ មានដោយការកើតឡើងរឿយ ៗ ។

បទថា **អសន្តំ** បានដល់ មិនមានដោយការមិនកើតឡើង ឬមិនមាន ព្រោះលះបង់បានហើយ ។

បទថា **យថា ច** សេចក្តីថា **កាមច្ឆន្ទ** រមែងកើតឡើងបានដោយហេតុណា ។

បទថា **តញ្ច បជានាតិ** បានដល់ រមែងដឹងនូវហេតុនោះផងដែរ ។ គប្បីជ្រាបអធិប្បាយក្នុងគ្រប់ៗ បទ ដោយន័យនេះ ។

ក្នុងបទថា **យថា ច** ជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យថា ៖

## អធិប្បាយ សុភនិមិត្ត

**កាមច្ឆន្ទ** រមែងកើតឡើង ព្រោះការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃក្នុងអសុភនិមិត្ត ។ ដែលឈ្មោះថា សុភនិមិត្ត បានដល់ សុភនិមិត្តដែលស្អាតខ្លះ សុភនិមិត្ត ដែលមានអារម្មណ៍ស្អាតខ្លះ ដែលឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ បានដល់ ការធ្វើទុកក្នុងចិត្តដោយមិនត្រូវឧបាយ ការធ្វើទុកក្នុងចិត្តដោយមិនត្រូវផ្លូវ គឺ ការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀង ថាទៀងខ្លះ ក្នុងវត្ថុដែលជាទុក្ខ ថាសុខខ្លះ ក្នុងវត្ថុដែលជាអនត្តា ថាជាអត្តាខ្លះ ក្នុងវត្ថុដែលមិនស្អាត ថាស្អាតខ្លះ កាលព្រះយោគាវចរញុំាងការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃនោះ ឲ្យប្រព្រឹត្តទៅក្នុងសុភនិមិត្តនោះច្រើនគ្រា ច្រើនដង កាមច្ឆន្ទៈរមែងកើតឡើង ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

សុភនិមិត្ត ការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនង និងការធ្វើទុកក្នុងចិត្តរឿយ ៗ ក្នុងសុភនិមិត្តនោះ នេះជាអាការ ( បច្ច័យ ) ឲ្យកាមច្ឆន្ទៈដែលមិនទាន់កើតឲ្យកើតឡើងខ្លះ ធ្វើឲ្យកាមច្ឆន្ទៈដែលកើត ឡើងហើយចម្រើនឡើងយ៉ាងក្រៃលែងខ្លះ ។

## អធិប្បាយ អសុភនិមិត្ត

ចំណែកក្នុងអសុភនិមិត្ត ការលះបង់ រមែងមានបានដោយការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ដែលឈ្មោះថា **អសុភនិមិត្ត** បានដល់ **អសុភនិមិត្ត** ដែលមិនស្អាតខ្លះ អសុភនិមិត្តដែលមានអារម្មណ៍មិនស្អាតខ្លះ ដែលឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ បានដល់ ការធ្វើទុកក្នុងចិត្តដោយត្រូវឧបាយ ការធ្វើទុកក្នុងចិត្តដោយត្រូវផ្លូវ គឺ ការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀង ថាមិនទៀងខ្លះ ក្នុងវត្ថុដែលជាទុក្ខថាជាទុក្ខខ្លះ ក្នុងវត្ថុដែលជាអនត្តាថា ជាអនត្តាខ្លះ ក្នុងវត្ថុមិនស្អាតថា មិនស្អាតខ្លះ កាលព្រះយោគាវចរញ៉ាំងការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃនោះ ឲ្យប្រព្រឹត្តទៅក្នុងអសុភនិមិត្តនោះរឿយ ៗ ក៏រមែងលះកាមច្ឆន្ទៈបាន ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មានអសុភនិមិត្ត ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃនិងការធ្វើរឿយ ៗ ក្នុងអសុភនិមិត្តនោះ នេះជាអាហារ ( បច្ច័យ ) ឲ្យកាមច្ឆន្ទៈ ដែលនៅមិនទាន់កើតឡើង កើតឡើងមិនបានខ្លះ ឲ្យលះកាមច្ឆន្ទៈ

ដែលកើតឡើងហើយខ្លះ ។

## លះកាមច្ឆន្ទៈដោយធម៌ ៦ ប្រការ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺ ការរៀនយកនូវអសុភនិមិត្ត ១ ប្រកបសេចក្ដីព្យាយាមរឿយ ៗ ក្នុងអសុភភាវនា ១ ភាពជាអ្នកគ្រប់គ្រងល្អក្នុងឥន្ទ្រីយ៍ទាំងឡាយ ១ ភាពជាអ្នកស្គាល់ប្រមាណក្នុងភោជន ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ភាពជាអ្នកពោល ឬស្ដាប់នូវពាក្យដែលជាទីសប្បាយ ១ ។

កាលព្រះយោគាវចរ សូម្បីរៀនយកនូវអសុភនិមិត្ត ១០ យ៉ាង ( ចន្ទោះនេះ ) កាមច្ឆន្ទៈជាការដែលលោករមែងលះបាន កាលលោកចម្រើននូវអសុភនិមិត្តក្ដី បិទទ្វារនៅក្នុងឥន្ទ្រីយ៍ទាំងឡាយក្ដី ស្គាល់ប្រមាណក្នុងភោជន ដែលមានឱកាសនឹងអាចឆាន់បាន ៤-៥ ដុំទៀត ( តែលោកក៏ឈប់ឆាន់ ) ហើយផឹកទឹកជំនួសជាប្រចាំក្ដី កាមច្ឆន្ទៈក៏ជាការដែលលោកអាចលះបាន ។ ដោយហេតុនោះ លោកទើបបានពោលគាថាប្រព័ន្ធនេះទុកថា ៖

> ( នៅ ៤-៥ ដុំទៀតទើបនឹងឆ្អែត ព្រះយោគាវចរកុំឆាន់
> គួរផឹកទឹកជំនួស ( ព្រោះថា ) ត្រឹមតែប៉ុណ្ណោះ ក៏សមល្មម
> ដែលនឹងនៅដោយសប្បាយ សម្រាប់ភិក្ខុអ្នកមានខ្លួនដែល
> បញ្ជូនទៅហើយ ។

សូម្បីកាលព្រះយោគាវចរ គប់រកកល្យាណមិត្ត អ្នកត្រេកអរក្នុងអសុភភាវនា ដូចជាព្រះតិស្សត្ថេរអ្នកចម្រើនអសុភកម្មដ្ឋាន កាមច្ឆន្ទៈដែលលោកអាចលះបាន លោករមែងលះកាមច្ឆន្ទៈបាន សូម្បីដោយការសន្ទនាដោយកថាដែលជាសប្បាយ ដែលអាស្រ័យអសុភ ១០ ក្នុង ឥរិយាបថទាំងឡាយ មានឥរិយាបថឈរ និងអង្គុយជាដើម ។ ដោយហេតុនោះលោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ ។ ក៏ព្រះយោគាវចរ រមែងដឹងច្បាស់ថា កាមច្ឆន្ទៈដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ នឹងកើតឡើងមិនបានតទៅទៀត ដោយអរហត្តមគ្គ ។

## អធិប្បាយ បដិឃនិមិត្ត

ម្យ៉ាងទៀត ព្រោះការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃនូវបដិឃ-និមិត្ត ព្យាបាទរមែងកើតឡើងបាន ។ ក្នុងបដិឃនិមិត្តនោះ បានដល់បដិឃនិមិត្ត ដែលជាបដិឃៈខ្លះ បដិឃនិមិត្តដែលមានបដិឃៈជាអារម្មណ៍ខ្លះ ។ ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ មានលក្ខណៈតែម្យ៉ាងដូចគ្នាក្នុងទីគ្រប់កន្លែងនោះឯង ។ កាលព្រះយោគាវចរ ញ៉ាំងការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃនោះ ឲ្យប្រព្រឹត្តទៅក្នុងនិមិត្តនោះ ច្រើនគ្រាព្យាបាទរមែងកើតឡើងបាន ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បដិឃនិមិត្ត ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ និងធ្វើច្រើនដងក្នុងបដិឃនិមិត្តនោះ នេះជាអាហារ ( បច្ច័យ ) ឲ្យ

ព្យាបាទដែលនៅមិនទាន់កើត កើតឡើងបានខ្លះ ឲ្យព្យាបាទដែលកើតឡើង ហើយចម្រើនក្រៃលែងឡើងខ្លះ ក៏ការលះព្យាបាទនោះ រមែងមានដោយការធ្វើមេត្តាចេតោវិមុត្តិទុកក្នុងចិត្ត ដោយឧបាយដ៏ប្រពៃក្នុង មេត្តាចេតោ-វិមុត្តិនោះ គប្បីជ្រាបការវិនិច្ឆ័យដូចតទៅនេះ ៖

កាលព្រះមានព្រះភាគត្រាស់ថា មេត្តា រមែងគួរដល់អប្បនាសមាធិ និងឧបចារសមាធិ កាលត្រាស់ថា ចេតោវិមុត្តិ រមែងគួរចំពោះអប្បនាតែម្យ៉ាង ការធ្វើ (ចេតោវិមុត្តិ) ទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ មានលក្ខណៈដូចពោលមកហើយនោះឯង កាលព្រះយោគាវចរញ៉ាំងការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃនោះ ឲ្យប្រព្រឹត្តទៅក្នុងមេត្តាចេតោវិមុត្តិនោះរឿយ ៗ លោកក៏រមែងលះព្យាបាទបាន ។

ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា មាន , ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិមានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រ-ពៃ និងការធ្វើឲ្យច្រើនក្នុងមេត្តាចេតោវិមុត្តិនោះ នេះជាអាហារ (បច្ច័យ) មិនឲ្យព្យាបាទដែលនៅមិនទាន់កើត កើតឡើងមិនបានខ្លះ លះព្យាបាទដែលកើតឡើងហើយខ្លះ ។

## លះព្យាបាទដោយធម៌ ៦ ប្រការ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺ

ការរៀននូវមេត្តានិមិត្ត ១ ការប្រកបព្យាយាមរឿយៗ ក្នុងមេត្តាភាវនា ១ ការពិចារណាថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន ១ ភាពជាអ្នកច្រើនទៅដោយការពិចារណា ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការសន្ទនាដល់រឿងដែលជាទីសប្បាយ ១ ។

អធិប្បាយថា កាលព្រះយោគាវចររៀននូវមេត្តា ដោយអំណាចការផ្សាយទៅចំពោះទិស និងមិនចំពោះទិសយ៉ាងណាមួយ លោករមែងលះព្យាបាទបាន ។

សូម្បីកាលព្រះយោគាវចរចម្រើនមេត្តា ដោយការផ្សាយទៅកាន់ទិសដោយចំពោះ លោករមែងលះព្យាបាទបាន ។

កាលព្រះយោគាវចរ ពិចារណាឃើញថា ខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួនយ៉ាងនេះថា ឯងក្រោធនឹងគេ តើធ្វើអ្វីគេបាន ឯងនឹងអាចធ្វើគុណធម៌ មានសីលគុណជាដើម របស់គេឲ្យវិនាសបានឬ ? ឯងមកតាមកម្មរបស់ខ្លួន ក៏នឹងទៅតាមកម្មរបស់ខ្លួននោះឯង មិនមែនឬ ? ដែលឈ្មោះថា ការក្រោធដល់អ្នកដទៃ ដូចជាបុគ្គលប្រាថ្នាស្រវាចាប់យកផេះដែលប្រាសចាកអណ្តាតភ្លើង លំពែងដែកដ៏ក្តៅ និងលាមកជាដើម គ្រវែងសំដៅបុគ្គលដទៃ សូម្បីគេក្រោធនឹងឯង ក៏ធ្វើអ្វីបាន គេនឹងអាចឲ្យគុណ-ធម៌ មានសីលជាដើម របស់ឯងវិនាសបានឬ ? គេមកតាមកម្មរបស់ខ្លួន ក៏នឹងទៅតាមកម្មរបស់ខ្លួនដូចគ្នា សេចក្តីក្រោធនោះ ក៏នឹងធ្លាក់ស្រោចក្បាលគេនោះទាំងស្រុង ដូចរបស់ដែលឲ្យទៅ មិនមាននរណាទទួល ( ក៏

នឹងត្រឡប់មករកអ្នកឲ្យវិញ) និងដូចធូលីបាចបញ្ច្រាសខ្យល់ ( ក៏នឹងរសាត់ត្រឡប់មកត្រូវអ្នកបាចវិញ ) ដូច្នេះខ្លះ ពិចារណាឃើញថា ទាំងខ្លួនឯងទាំងអ្នកដទៃ មានកម្មជារបស់ខ្លួន និងស្ថិតនៅក្នុងការពិចារណាខ្លះ គប់រកកល្យាណមិត្តអ្នកត្រេកអរក្នុងមេត្តាភាវនា ដូចជា ព្រះអស្សគុត្តត្ថេរខ្លះ លោករមែងលះព្យាបាទបាន ។ លោករមែងលះព្យាបាទបាន សូម្បីដោយការសន្ទនាដល់រឿងដែលជាទីសប្បាយ ទាក់ទងដោយមេត្តាក្នុងឥរិយាបថទាំងឡាយ មានឥរិយាបថ អង្គុយ និងឈរជាដើម ។

ក៏ព្រះយោគាវចរ រមែងដឹងច្បាស់ថា ព្យាបាទដែលលះបានហើយដោយធម៌ ៦ ប្រការនេះ នឹងកើតឡើងមិនបានតទៅ ដោយអនាគាមិមគ្គ ។

## អធិប្បាយ អរតិ ជាដើម

ព្រោះធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃក្នុងធម៌ទាំងឡាយ គឺ **សតិ** ជាដើម **ថីនមិទ្ធ** រមែងកើតឡើងបាន ។

ដែលឈ្មោះថា **អរតិ** បានដល់ ភាពជាអ្នកមិនត្រេកអរ ។

ដែលឈ្មោះថា **តន្ទិ** បានដល់ ភាពជាអ្នកទម្រន់ផ្លូវកាយ ។

ដែលឈ្មោះថា **វិជម្ភិកា** បានដល់ ការមិតពត់ផ្លូវកាយ ។

ដែលឈ្មោះថា **ស្រវឹងអាហារ** បានដល់ សេចក្តីសញ្ជប់សញ្ជឹងដែលកើតពីអាហារ និងសេចក្តីក្រវល់ក្រវាយដែលកើតពីអាហារ ។

ដែលឈ្មោះថា **ការរួញរានៃចិត្ត** បានដល់ សភាពដែលចិត្តធន្ធុយ

ងោកងក់ ។

ក៏កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ ឲ្យប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយមាន **អរតិ** ជាដើមនេះរឿយ ៗ **ថីនមិទ្ធ** រមែងកើតឡើងបាន ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការមិនត្រេកអរ ការមិនមិតពត់កាយ សេចក្ដីខ្ជិលប្រអូស ការស្រវឹងអាហារ និងការដែលចិត្តរួញរា ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ និងការធ្វើឲ្យច្រើនក្នុងធម៌ទាំងឡាយមាន **អរតិ** ជាដើមនោះនេះជាអាហារ ( បច្ច័យ ) ឲ្យថីនមិទ្ធៈដែលមិនទាន់កើត កើតឡើងបានខ្លះឲ្យថីនមិទ្ធៈដែលកើតឡើងហើយ ចម្រើនក្រៃលែងខ្លះ ។

## អធិប្បាយ អារព្ភធាតុ ជាដើម

ក៏ការលះថីនមិទ្ធៈនោះ រមែងមានបានដោយយោនិសោមនសិការក្នុងធាតុទាំងឡាយ មាន **អារព្ភធាតុ** ជាដើម ។

ដែលឈ្មោះថា **អារព្ភធាតុ** បានដល់ សេចក្ដីព្យាយាមដែលប្រារព្ធឡើងជាដំបូង ។

ដែលឈ្មោះថា **និក្កមធាតុ** បានដល់ សេចក្ដីព្យាយាមដែលមានកម្លាំងខ្លាំងជាងសេចក្ដីព្យាយាម ដែលប្រារព្ធឡើងជាដំបូងនោះ ព្រោះជាគ្រឿងចេញចាកកោសជ្ជៈ ។

ដែលឈ្មោះថា **បរក្កមធាតុ** បានដល់ សេចក្ដីព្យាយាមដែលមានកម្លាំងខ្លាំងជាង **និក្កមធាតុ** សូម្បីនោះ ព្រោះឈានទៅកាន់ឋានៈដ៏ក្រៃលែងឡើង ៗ ។

កាលព្រះយោគាវចរ ញុំាងយោនិសោមនសិការឲ្យប្រព្រឹត្តទៅ ក្នុងសេចក្ដីព្យាយាម ៣ ប្រភេទនេះរឿយ ៗ លោករមែងលះថីនមិទ្ធៈបាន ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ **អារព្ភធាតុ និក្កមធាតុ** ( និង ) **បរក្កមធាតុ** ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និងការធ្វើឲ្យច្រើនក្នុង **អារព្ភធាតុ** ជាដើមនោះ នេះជាអាហារ ( បច្ច័យ ) មិនឲ្យថីមិទ្ធៈដែលនៅមិនទាន់កើត មិនកើតឡើងខ្លះ ឲ្យលះថីនមិទ្ធៈដែលកើតឡើងហើយខ្លះ ។

## លះថីនមិទ្ធៈដោយធម៌ ៦ ប្រការ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ គឺការកាន់យកនូវនិមិត្តក្នុងការបរិភោគហួសប្រមាណ ១ ការផ្លាស់ប្តូរឥរិយាបថ ១ មនសិការដល់អាលោកសញ្ញា ១ ការនៅក្នុងទីវាលស្រឡះ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការសន្ទនាដល់រឿងដែលជាទីសប្បាយ ១ ។

ក៏កាលព្រះយោគាវចរធាន់ (ច្រើនពេក) ដូចយ៉ាង **ហត្ថកព្រាហ្មណ៍ កុត្ថអនិមិត្តព្រាហ្មណ៍ តត្រវដ្ដព្រាហ្មណ៍ អលង្សាដកព្រាហ្មណ៍** និង **កាកមាសកព្រាហ្មណ៍** ដែលអង្គុយបំពេញ **សមណធម៌** ក្នុងទីសម្រាកពេល

យប់ និងក្នុងទិសម្រាកពេលថ្ងៃ ថីនមិទ្ធៈ រមែងមកគ្របសង្កត់បាន ដូចដំរីធំមកជាន់ ដូច្នោះ ។

តែសម្រាប់ភិក្ខុអ្នកវៀរឱកាសដែលនឹងឆាន់បាន ៤-៥ ដុំទៀត ក៏ផឹកទឹកជំនួសជាប្រចាំ **ថីនមិទ្ធ** នោះ រមែងមិនមាន កាលព្រះយោគាវចរសូម្បីកាន់យកនិមិត្តក្នុងការបរិភោគនូវភោជនហួសប្រមាណ ដូចពោលមកនេះ លោករមែងលះ **ថីនមិទ្ធ** បាន ។

ក្នុងឥរិយាបថណា ព្រះយោគាវចរធ្លាក់នៅក្រោមអំណាចថីនមិទ្ធៈ កាលលោកផ្លាស់ឥរិយាបថដទៃអំពីឥរិយាបថនោះក្តី មនសិការដល់ពន្លឺព្រះច័ន្ទក្តី ពន្លឺប្រទីប និងពន្លឺភ្លើងគប់ក្នុងពេលយប់ និងពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃក្តី នៅក្នុងទីវាលស្រឡះក្តី គប់រកកល្យាណមិត្តអ្នកលះថីន-មិទ្ធៈបានហើយ ដូចព្រះមហាកស្សបត្ថេរក្តី លោករមែងលះថីនមិទ្ធៈបាន ។

លោករមែងលះថីនមិទ្ធៈបាន សូម្បីដោយការសន្ទនាដល់រឿងដែលជាទីសប្បាយទាក់ទងនឹងធុតង្គក្នុងឥរិយាបថទាំងឡាយ មានឥរិយាបថឈរ និងអង្គុយ ជាដើម ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ ។ ក៏ព្រះយោគាវចររមែងដឹងច្បាស់ថា ថីនមិទ្ធៈ ដែលលះបានហើយដោយធម៌ ៦ ប្រការនេះ នឹងកើតឡើងមិនបានតទៅទៀត ដោយអរហត្តមគ្គ ។

# អធិប្បាយ ឧទ្ធច្ចកុក្កុច្ចៈ

កាលចិត្តមិនស្ងប់ ឧទ្ធច្ចកុក្កុច្ចៈ រមែងកើតឡើងបានដោយអយោ-និសោមនសិការ ( មិនមានយោនិសោមនសិការ ) ។ អាការដែលចិត្តមិនស្ងប់ ឈ្មោះថា **អវូបសម** ។ ដោយអត្ថ ពាក្យថា **អវូបសម** នោះ គឺ ឧទ្ធច្ចកុក្កុច្ចៈនោះឯង ។ កាលព្រះយោគាវចរញ៉ាំងអយោនិសោមនសិការឲ្យប្រព្រឹត្តទៅក្នុងអវូបសមៈនោះជារឿយ ៗ ឧទ្ធច្ចកុក្កុច្ចៈ រមែងកើតឡើង ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការមិនស្ងប់ចិត្ត ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ និងធ្វើឲ្យច្រើនដងក្នុងការមិនស្ងប់ចិត្តនោះ នេះជាអាហារ (បច្ច័យ) ដើម្បីឲ្យឧទ្ធច្ចកុក្កុច្ចៈដែលនៅមិនទាន់កើត ឲ្យកើតឡើងខ្លះ ដើម្បីការបរិបូរណ៍ក្រៃលែងឡើង ៗ នៃឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយខ្លះ ។

ក៏ការលះឧទ្ធច្ចកុក្កុច្ចៈនោះបាន ដោយយោនិសោមនសិការក្នុងចិត្តស្ងប់ ពោលគឺ សមាធិ ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្ងប់ចិត្ត ការមនសិការដោយឧបាយ និងការធ្វើរឿយ ៗ ក្នុងការស្ងប់ចិត្តនោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីមិនឲ្យឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើតឡើង ឲ្យកើតឡើងខ្លះ ដើម្បីលះឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយខ្លះ ។

## លះឧទ្ធច្ចកុក្កុច្ចដោយធម៌ ៦ ប្រការ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ ភាពជាពហុស្សូត ១ ភាពជាអ្នកសាកសួរ ១ ភាពជាអ្នកដឹងប្រក្រតីក្នុងព្រះវិន័យ ១ ការគប់រកបុគ្គលដែលចម្រើន ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាទីសប្បាយ ១ ។

អធិប្បាយថា លោកសូម្បីរៀន ១ និកាយខ្លះ , ២ និកាយខ្លះ , ៣ និកាយខ្លះ , ៤ និកាយខ្លះ , ៥ និកាយខ្លះ ទាំងព្រះបាលី ទាំងព្រះអដ្ឋកថា រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។

លោកអ្នកច្រើនទៅដោយការសាកសួរនូវវត្ថុដែលជាកប្បិយៈ និងអកប្បិយៈក្តី ។ លោកជាអ្នកចេះដឹងជាប្រក្រតីក្នុងវិនយប្បញ្ញត្តិ ព្រោះភាពជាអ្នកប្រព្រឹត្តទៅក្នុងអំណាចវិន័យ ដែលខ្លួនស្ទាត់ជំនាញហើយក្តី ចូលទៅរកលោកអ្នកដ៏ចម្រើន គឺ ព្រះថេរៈអ្នកជាធំក្តី គប់រកកល្យាណមិត្តអ្នកទ្រទ្រង់វិន័យ ដូចព្រះឧបាលិត្ថេរក្តី រមែងលះបង់ឧទ្ធច្ចកុក្កុច្ចៈបាន ។

ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម លោករមែងលះបានដោយការពោលពាក្យដែលជាទីសប្បាយ ទាក់ទងនឹងវត្ថុដែលជាកប្បិយៈ និងអកប្បិយៈ ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ធម៌ ៦ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីលះបង់ឧទ្ធច្ចកុក្កុច្ចៈ ។ លោករមែងដឹងច្បាស់

ថា [១] បណ្តាឧទ្ធច្ចកុក្កុច្ចៈ ដែលលះបានហើយដោយធម៌ ៦ យ៉ាងនេះ ឧទ្ធច្ចៈនឹងកើតឡើងតទៅមិនបាន ដោយអរហត្តមគ្គ កុក្កុច្ចៈមិនមានការកើតឡើងតទៅ ដោយអនាគាមិមគ្គ ។

## អធិប្បាយ វិចិកិច្ឆា

វិចិកិច្ឆា រមែងកើតឡើងបាន ដោយមិនមានមនសិការក្នុងធម៌ទាំងឡាយដែលជាទីតាំងនៃវិចិកិច្ឆា ។ ដែលឈ្មោះថា ធម៌ជាទីតាំងនៃវិចិកិច្ឆា ក៏បានដល់វិចិកិច្ឆានោះឯង ព្រោះជាហេតុនៃសេចក្តីសង្ស័យ ។ កាលយើងញ៉ាំងអយោនិសោមនសិការក្នុងវិចិកិច្ឆានោះ ឲ្យប្រព្រឹត្តទៅរឿយ ៗ វិចិកិច្ឆារមែងកើតឡើង ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃវិចិកិច្ឆា ការធ្វើទុកក្នុងចិត្តដោយមិនត្រូវទំនង និងការធ្វើឲ្យច្រើនក្នុងធម៌នោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីឲ្យវិចិកិច្ឆា ដែលនៅមិនទាន់កើតឲ្យកើតឡើងខ្លះ ដើម្បីធ្វើឲ្យបរិបូណ៌ក្រៃលែងឡើងនៃវិចិកិច្ឆា ដែលកើតឡើងហើយខ្លះ ។

ក៏ការលះវិចិកិច្ឆានោះ រមែងមានបាន ដោយយោនិសោមនសិការក្នុងធម៌ទាំងឡាយ មានកុសលជាដើម ។ ដោយហេតុនោះ ព្រះមានព្រះ-

---

[១] បាឋៈថា ឥមេហិ បន ឆហិ ធម្មេហិ បហីនស្ស ឧទ្ធច្ចស្ស អរហត្តមគ្គេន ។ល។ បជានាតិ ។ ច្បាប់ ភូមាជា ឥមេហិ បន ឆហិ ធម្មេហិ បហីនេ ឧទ្ធច្ចកុក្កុច្ចេ ឧទ្ធច្ចំ ។ល។ បជានាតិ ប្រែតាមច្បាប់ភូមា ។

ភាគ ទ្រង់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាកុសល និង អកុសល ធម៌ដែលមានទោស និងមិនមានទោស ធម៌ដែលគួរសេព និង មិនគួរសេព ធម៌ដែលថោកទាប និងប្រណីត ធម៌ដែលមានចំណែក ស្រដៀងនឹងធម៌ខ្មៅ និងធម៌ស ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និងការធ្វើឲ្យច្រើនក្នុងធម៌ទាំងនោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីមិន ឲ្យវិចិកិច្ឆា ដែលមិនទាន់កើត ឲ្យកើតឡើងខ្លះ ដើម្បីលះវិចិកិច្ឆាដែល កើតឡើងហើយខ្លះ [១] ។

ម្យ៉ាងទៀត ធម៌ទាំង ៦ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ ភាពជាពហុស្សុត ១ ភាពជាអ្នកសាកសួរ ១ ភាពជាអ្នកស្ទាត់ជំនាញ ដឹងប្រក្រតីក្នុងព្រះវិន័យ ១ ភាពជាអ្នកច្រើនទៅដោយអធិមោក្ខៈ ១ ភាព ជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាទីសប្បាយ ១ ។

អធិប្បាយថា សូម្បីលោករៀន ១ និកាយខ្លះ ។ល។ ៥ និកាយខ្លះ ទាំងបាលី ទាំងអដ្ឋកថា រមែងលះវិចិកិច្ឆាបាន សូម្បីដោយពាហុសច្ចៈ ។ អ្នកច្រើនទៅដោយការសាកសួរ ដោយការប្រារព្ធព្រះរតនត្រ័យក្តី អ្នកមាន ការស្ទាត់ជំនាញ ប៉ិនប្រសប់នៅក្នុងព្រះវិន័យក្តី អ្នកច្រើនទៅដោយអធិ-មោក្ខៈ ពោលគឺ មានសទ្ធាមុតមាំក្នុងព្រះរតនត្រ័យក្តី អ្នកគប់រកកល្យាណ-

---

[១] បាឋៈថា អយមាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ ឧប្បាទាយ ឧប្បន្នាយ វា វិចិកិច្ឆាយ ភិយ្យោភាវាយ វេបុល្លាយាតិ ។ ច្បាប់ភូមាជា អយមាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ អនុប្បាទាយ វា វិចិកិច្ឆា វា បហានាយាតិ ។ ប្រែតាមច្បាប់ភូមា ។

មិត្តដែលជាសទ្ធាវិមុត្តិ ដូចព្រះវក្កលិត្ថេរក្តី រមែងលះវិចិកិច្ឆាបាន ដោយពាហុសច្ចៈ ។

ក្នុងឥរិយាបថទាំងឡាយ មានការឈរ ការអង្គុយជាដើម លោករមែងលះវិចិកិច្ឆាបាន សូម្បីដោយពាក្យដែលជាទីសប្បាយទាក់ទងនឹងគុណព្រះរតនត្រៃ ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ធម៌ ៦ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ក៏ព្រះយោគាវចរ រមែងដឹងច្បាស់វិចិកិច្ឆា ដែលលះបានដោយធម៌ ៦ យ៉ាងនេះ នឹងមិនមានការកើតឡើងតទៅ ព្រោះសោតាបត្តិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ឬក្នុងធម៌ទាំងឡាយរបស់អ្នកដទៃ គឺ ក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាល (ដ៏សមគួរ) ឬរបស់អ្នកដទៃតាមកាល (ដ៏សមគួរ) ដោយការកំណត់ឃើញនីវរណធម៌ ៥ ប្រការ យ៉ាងនេះ ។

តែក្នុងនីវរណបព្វៈនេះ ព្រះយោគាវចរនាំយកការកើតឡើង និងការសូន្យទៅដោយអយោនិសោមនសិការ ឬយោនិសោមនសិការក្នុងសុភ-និមិត្តជាដើម ដោយន័យដូចដែលត្រាស់ទុកហើយក្នុងនីវរណៈ ៥ ។ សេចក្តីតអំពីនេះទៅ មានន័យដូចពោលហើយនោះឯង ។

---

# អរិយសច្ចក្នុងនីវរណ

សតិជាគ្រឿងកំណត់នីវរណៈ ក្នុងនីវរណបព្វៈនេះ ជាទុក្ខសច្ចតែម្យ៉ាង បណ្ឌិតគប្បីប្រកបសេចក្ដីដូចដែលពណ៌នាមកនេះ ហើយដឹងនូវធម៌ដែលជាគ្រឿងនាំចេញចាកទុក្ខនៃភិក្ខុអ្នកកំណត់នីវរណៈជាអារម្មណ៍ សេចក្ដីដ៏សេស ក៏ដូចេ្នាះដូចគ្នា ។

( ចប់ នីវរណបព្វៈ )

## ខន្ធបព្វៈ

[១៤២] ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនាដោយនីវរណៈ ៥ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយបញ្ចក្ខន្ធ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **បុន ចបរំ** ។

បណ្ដាបទទាំងនោះ បទថា **បញ្ចសុ ឧបាទានក្ខន្ធេសុ** សេចក្ដីថា គំនរនៃឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ អធិប្បាយថា ពួកនៃធម៌ គឺគំនរនៃធម៌ដែលជាបច្ច័យនៃឧបាទាន ឈ្មោះថា **ធម្មរាសី** សេចក្ដីសង្ខេបក្នុងបញ្ចក្ខន្ធនេះ មានប៉ុណ្ណេះ ។ ចំណែកសេចក្ដីពិស្ដាររឿងខន្ធពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ រូបំ** សេចក្ដីថា ដឹងរូបដោយសភាវៈថា នេះរូប រូបប៉ុណ្ណោះ រូបដទៃអំពីនេះមិនមាន ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ សេចក្ដីសង្ខេបក្នុងពាក្យនេះ មានប៉ុណ្ណេះ ។ ចំណែកដោយពិស្ដាររូបជាដើម លោកពោលទុកហើយក្នុងរឿងខន្ធ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

បទថា **ឥតិ រូបស្ស សមុទយោ** សេចក្ដីថា ការកើតនៃរូបដោយអាការ ៥ ដោយមានអវិជ្ជាជាទីកើតជាដើមយ៉ាងនេះ ។

បទថា **ឥតិ រូបស្ស អត្ថង្គមោ** សេចក្ដីថា ការរលត់ទៅនៃរូបដោយអាការ ៥ ដោយមានការរលត់ទៅនៃអវិជ្ជាជាដើមយ៉ាងនេះ ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ នេះជាសេចក្ដីសង្ខេបក្នុងសេចក្ដីនេះ ចំណែកសេចក្ដីពិស្ដារពោលទុកហើយក្នុងរឿង ឧទយព្វយញ្ញាណ ក្នុង

គម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយមិនថា របស់ខ្លួន ឬរបស់អ្នកដទៃ មិនថា តាមកាលរបស់ខ្លួន ឬរបស់អ្នកដទៃ ដោយការកំណត់បញ្ចក្ខន្ធជាអារម្មណ៍យ៉ាងនេះ ។ ក៏ក្នុងពាក្យនេះ **សមុទយធម្ម** និង **វយធម្ម** គប្បីលើកឡើងពិចារណាលក្ខណៈ ៥០ ដែលលោកពោលទុកក្នុងខន្ធទាំងឡាយ មានជាអាទិ៍ថា ព្រោះអវិជ្ជាកើត រូបទើបកើត ។ តអំពីនេះ ក៏មានន័យដូចពោលមកហើយនោះឯង ។

## អរិយសច្ចក្នុងបញ្ចក្ខន្ធ

សតិជាគ្រឿងកំណត់ខន្ធជាអារម្មណ៍ ក្នុងខន្ធបព្វៈនេះ ជាទុក្ខសច្ចតែម្យ៉ាង គប្បីប្រកបសេចក្តីដូចពោលមកនេះ ហើយគប្បីជ្រាបវត្តបដិបត្តិដែលជាគ្រឿងនាំចេញចាកទុក្ខរបស់ភិក្ខុអ្នកកំណត់ខន្ធជាអារម្មណ៍ ។ ពាក្យដ៏សេស ក៏យ៉ាងនោះដូចគ្នា ។

( ចប់ ខន្ធបព្វៈ )

## អាយតនបព្វ:

[១៤៣] ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនាដោយបញ្ចក្ខន្ធយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយអាយតន: ទើបត្រាស់ពាក្យមានជាអាទិ៍ថា **បុន ចបរំ** ។

បណ្ដាបទទាំងនោះ បទថា **ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ** បានដល់ អាយតន:ខាងក្នុង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ( និង ) អាយតន:ខាងក្រៅ ៦ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វ: និងធម្មារម្មណ៍ ។

បទថា **ចក្ខុំ ច បជានាតិ** បានដល់ ដឹងនូវចក្ខុបសាទដោយលក្ខណ:នៃកិច្ចតាមសេចក្ដីពិត ។

បទថា **រូបេ ច បជានាតិ** សេចក្ដីថា ដឹងនូវរូបដែលមានសមុដ្ឋាន ៤ យ៉ាង ខាងក្រៅផង ដោយលក្ខណ:នៃកិច្ចតាមសេចក្ដីពិត ។

សេចក្ដីថា **យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ** សេចក្ដីថា ក៏ព្រោះអាស្រ័យអាយតន:ទាំង ២ យ៉ាង គឺ ទាំងភ្នែកផង ទាំងរូបផង សំយោជន: ១០ យ៉ាងគឺ **កាមរាគសំយោជន , បដិឃ , មាន: , ទិដ្ឋិ , វិចិកិច្ឆា , សីលព្វតបរាមាស , ភវរាគ , ឥស្សា , មច្ឆរិយ** , និង **អវិជ្ជាសំយោជន** ឯណា រមែងកើតឡើង លោកដឹងច្បាស់សំយោជន:នោះ ដោយលក្ខណ:តាមសេចក្ដីពិតផង ។

# ការកើតឡើងនៃសំយោជនៈ

សួរថា ក៏សំយោជនៈនេះ កើតឡើងបានដូចម្ដេច ?

ឆ្លើយថា ក៏នឹងពោលក្នុងចក្ខុទ្វារមុន កាលលោកពេញចិត្តត្រេកត្រអាល ត្រេកអរនឹងឥដ្ឋារម្មណ៍ដែលមកកាន់គន្លង (ចក្ខុ) ដោយអំណាចនៃការពេញចិត្តក្នុងឥដ្ឋារម្មណ៍ **កាមរាគសំយោជនៈ** នឹងកើតឡើង ។ កាលក្រោធក្នុងអនិដ្ឋារម្មណ៍ **បដិឃសំយោជនៈ** នឹងកើតឡើង ។ ការសម្គាល់ថា ក្រៅអំពីយើងហើយ មិនមាននរណាដទៃនឹងអាចសម្ដែងអារម្មណ៍[១] នេះ ឲ្យជាក់ច្បាស់បាន , **មានះសំយោជនៈ** នឹងកើតឡើង ។ កាលប្រកាន់ថា រូបារម្មណ៍នេះ[២] ទៀង ស្ថិតស្ថេរ **ទិដ្ឋិសំយោជនៈ** នឹងកើតឡើង ។ កាលសង្ស័យថា រូបារម្មណ៍នេះ[២] ជាសត្វឬហ្ន៎ ឬជារបស់សត្វ **វិចិកិច្ឆា-សំយោជនៈ** នឹងកើតឡើង ។ កាលប្រាថ្នាភពថា ភព ( ការកើត ) នេះ មិនមែននឹង[៣] រកបានងាយក្នុងសម្បត្តិភពឡើយ **ភវរាគសំយោជនៈ**[៤] នឹងកើតឡើង ។ ការប្រកាន់មាំនូវសីល និងវត្តថា យើងសមាទានសីល និងវត្តបែបនេះហើយ អាចនឹងបាន (សម្រេចគុណវិសេស) តទៅ **សីល-ព្វតបរាមាសសំយោជនៈ** នឹងកើតឡើង ។ កាលឥស្សាថា ធ្វើដូចម្ដេចហ្ន៎

---

[១] បាឋៈថា ឯកំ ច្បាប់ភូមាជា ឯតំ ប្រែតាមច្បាប់ភូមា ។

[២] បាឋៈថា ឯវំ ច្បាប់ភូមាជា ឯតំ ប្រែតាមច្បាប់ភូមា ។

[៣] បាឋៈថា សម្បត្តិភវេ អត្ថនោ ភូមាជា សម្បត្តិភវេ វត នោ ប្រែតាមច្បាប់ភូមា ។

[៤] បាឋៈថា ភវសំយោជនំ ច្បាប់ភូមាជា ភវរាគសំយោជនំ ប្រែតាមច្បាប់ភូមា ។

អ្នកដទៃទើបនឹងមិនបានរូបារម្មណ៍នេះ **ឥស្សាសំយោជនៈ** នឹងកើតឡើង ។ កាលកំណាញ់រូបារម្មណ៍ ដែលខ្លួនបានហើយចំពោះអ្នកដទៃ **មច្ឆរិយ-សំយោជនៈ** នឹងកើតឡើង ។ ការមិនដឹង ដោយមិនដឹងធម៌ដែលកើតឡើងព្រមជាមួយនឹងធម៌ទាំងអស់នោះឯង **អវិជ្ជាសំយោជនៈ** នឹងកើតឡើងបាន ។

បទថា **យថា ច អនុប្បន្នស្ស** សេចក្តីថា សំយោជនៈទាំង ១០ យ៉ាងនោះ ដែលមិនទាន់កើត នឹងកើតឡើងដោយហេតុ គឺ ដោយការមិនផុសផុលឡើង យ៉ាងណា លោកដឹងច្បាស់នូវហេតុនោះផង ។

បទថា **យថា ច ឧប្បន្នស្ស** សេចក្តីថា ចំណែកការលះសំយោជនៈសូម្បីទាំង ១០ យ៉ាងនោះ ដែលកើតឡើងហើយ ដោយសេចក្តីថា នៅលះមិនទាន់បានក្តី ដោយការផុសផុលឡើងក្តី ដោយហេតុណា លោករមែងដឹងច្បាស់នូវហេតុនោះផង ។

បទថា **យថា ច បហីនស្ស** សេចក្តីថា សំយោជនៈ ១០ យ៉ាងនោះ សូម្បីដែលលះបានហើយ ដោយតទង្គប្បហាន និងវិក្ខម្ភនប្បហាន នឹងមិនមានការកើតឡើងតទៅ ដោយហេតុយ៉ាងណា លោកក៏ដឹងហេតុនោះផង ។ អធិប្បាយថា ក៏សំយោជនៈនោះ នឹងមិនមានការកើតឡើងតទៅ គឺ សំយោជនៈ ៥ យ៉ាង ផ្សេងដោយ **ទិដ្ឋិ , វិចិកិច្ឆា , សីល-ព្វតបរាមាស , ឥស្សា និង មច្ឆរិយៈ** មិនមានការកើតឡើងតទៅទៀតដោយសោតាបត្តិមគ្គ ។

សំយោជនៈទាំងគូ គឺ កាមរាគៈ និងបដិឃៈយ៉ាងគ្រោតគ្រាត ទីងមិនមានការកើតឡើងតទៅដោយសកទាគាមិមគ្គ សំយោជនៈទាំងគូ គឺ កាមរាគៈ និងបដិឃៈ ដែលប្រព្រឹត្តទៅជាមួយគ្នាយ៉ាងល្អិត ទីងមិនមានការកើតឡើងតទៅ ដោយអនាគាមិមគ្គ សំយោជនៈ ៣ យ៉ាង គឺ **មានះ** , **ភវរាគ** , និង **អវិជ្ជា** ទីងមិនមានការកើតឡើងតទៅ ដោយអរហត្តមគ្គ ដោយហេតុណា លោកដឹងច្បាស់នូវហេតុនោះ ។ សូម្បីក្នុងបទថា ក្នុងសំឡេងជាដើម ក៏ន័យនេះដូចគ្នា ។ មយ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបកថាដែលពោលដោយអាយតនៈ ដោយពិស្តារ តាមន័យដែលបានពោលទុកហើយក្នុង **អាយតននិទ្ទេស** ក្នុងគម្ពីរវិសុទ្ធិមគ្គនោះចុះ ។

ព្រះយោគាវចរ ពិចារណាឃើញ ធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ដោយការកំណត់អាយតនៈខាងក្នុង ឬក្នុងធម៌ទាំងឡាយរបស់អ្នកដទៃ ដោយការកំណត់អាយតនៈខាងក្រៅ គឺ ក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាល ( ដ៏សមគួរ ) ឬរបស់អ្នកដទៃតាមកាល ( ដ៏សមគួរ ) ដោយប្រការយ៉ាងនេះ ។ ក៏ក្នុងអាយតនបព្វៈនេះ **សមុទយធម៌** និង **វយធម៌** គួរនាំចេញទៅដោយន័យនៃរូបាយតនៈ ដែលត្រាស់ទុកហើយក្នុងរូបក្ខន្ធនៃអាយតនៈ ក្នុងបណ្តាអរូបាយតនៈទាំងឡាយ ដែលត្រាស់ទុកក្នុង វិញ្ញាណក្ខន្ធនៃធម្មាយតនៈ ដែលត្រាស់ទុកក្នុងខន្ធដ៏សេសថា ព្រោះអវិជ្ជាកើត ចក្ខុទើបកើត ។ មិនគួរសំដៅដល់លោកុត្តរធម៌ ។ ពាក្យតអំពីនេះទៅ មានន័យដូចដែលពោលមកនេះឯង ។

## អរិយសច្ចក្នុងអាយតនៈ

*សតិជាគ្រឿងកំណត់អាយតនៈ ក្នុងអាយតនបព្វៈនេះ ជាទុក្ខសច្ច គប្បីប្រកបសេចក្តីដូចដែលពោលមកនេះ ហើយដឹងបដិបទាដែលជាហេតុនាំចេញ ( ចាកទុក្ខ ) នៃភិក្ខុអ្នកកំណត់យកអាយតនៈជាអារម្មណ៍ ។ ពាក្យដ៏សេស ក៏យ៉ាងនោះដូចគ្នា ។*

( ចប់ អាយតនបព្វៈ )

## ពោជ្ឈង្គបព្វៈ

[១៨៤] ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកធម្មានុបស្សនាដោយអាយតនៈដែលប្រព្រឹត្តទៅក្នុងខាងក្នុង និងខាងក្រៅយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយពោជ្ឈង្គ ទើបត្រាស់ពាក្យមានជាអាទិ៍ថា បុន ចបរំ ។

បណ្តាបទទាំងនោះ បទថា **ពោជ្ឈង្គេសុ** បានដល់ អង្គនៃបុគ្គលអ្នកជាប់នៅក្នុងការត្រាស់ដឹង ។

បទថា **សន្តំ** បានដល់ មាននៅដោយការត្រឡប់បាន ។

បទថា **សតិសម្ពោជ្ឈង្គំ** បានដល់ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹងពោលគឺ សតិ ។

## អត្ថនៃពាក្យថា សម្ពោជ្ឈង្គ

អធិប្បាយថា ព្រះយោគាវចររមែងដឹងសព្វគ្រប់ក្នុងធម៌ ៧ នេះ ចាប់ផ្តើមពីប្រារព្ធចំពោះវិបស្សនា ព្រោះដូច្នោះ ធម៌ទាំង ៧ នោះ ទើបឈ្មោះថា **សម្ពោជ្ឈង្គ** ។ ម្យ៉ាងទៀត ព្រះយោគាវចរនោះភ្ញាក់ គឺ ក្រោកឡើងអំពីការលង់លក់ក្នុងកិលេស ឬចាក់ធ្លុះសច្ចៈទាំងឡាយ ដោយធម្ម-សាមគ្គី ៧ ប្រការណា មានសតិជាដើម ធម្មសាមគ្គីនោះ ឈ្មោះថា **សម្ពោធិ** ។ ដែលឈ្មោះថា **សម្ពោជ្ឈង្គ** ព្រោះជាអង្គនៃសម្ពោធិធម៌ ឬ

សម្ពោធិធម្មសាមគ្គីនោះ ។ ដោយហេតុនោះ លោកទើបពោលថា **សម្ពោជ្ឈង្គ** ពោលគឺ សតិ ។ សូម្បីក្នុងសម្ពោជ្ឈង្គៈដ៏សេស ក៏គប្បីជ្រាបអត្ថរបស់ពាក្យ ដោយន័យនេះដូចគ្នា ។

បទថា **អសន្តំ** សេចក្តីថា មិនមានដោយការមិនត្រឡប់បាន ។ ក៏ក្នុងបទទាំងឡាយមានជាអាទិ៍ថា **យថា ច អនុប្បន្នស្ស** មានវិនិច្ឆ័យដូចតទៅនេះ ៖

## ការកើតឡើងនៃសតិសម្ពោជ្ឈង្គ

សតិសម្ពោជ្ឈង្គៈ នឹងមានការកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ ធម៌ជាដែលទីតាំងនៃសតិសម្ពោជ្ឈង្គៈ ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និងការធ្វើឲ្យច្រើនក្នុងធម៌ទាំងនោះ នេះជាអាហារ (បច្ច័យ) រមែងប្រព្រឹត្តទៅដើម្បីឲ្យសតិសម្ពោជ្ឈង្គៈ ដែលមិនទាន់កើត ឲ្យកើតឡើងផង ដើម្បីសេចក្តីចម្រើនក្រៃលែង ដើម្បីសេចក្តីបរិបូរណ៍នៃការចម្រើនសតិសម្ពោជ្ឈង្គៈ ដែលកើតឡើងហើយផង ។ កាលសតិនោះ មានធម៌ទាំងឡាយនោះឯង ដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គៈ មានយោនិសោមនសិការ មានលក្ខណៈដូចពោលមកហើយនោះឯង កាលព្រះយោគាវចរញុំាងយោនិសោមនសិការនោះ ឲ្យប្រព្រឹត្តទៅក្នុងធម៌ទាំងនោះរឿយ ៗ សតិសម្ពោជ្ឈង្គៈ រមែងកើតឡើង ។

ម្យ៉ាងទៀត ធម៌ ៤ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើង

នៃសតិសម្ពោជ្ឈង្គៈ គឺ សតិសម្បជញ្ញ ១ ការវៀរចាកបុគ្គលអ្នកវង្វេងភ្លេចសតិ ១ ការគប់រកសមាគមនឹងបុគ្គលអ្នកមានសតិតាំងមាំ ១ ភាពជាអ្នកបង្អោនទៅរកសតិ ១ ។

ពិតណាស់ សតិសម្ពោជ្ឈង្គៈ នឹងកើតឡើងក្នុងទី ៧ ស្ថាន មានការឈានទៅខាងមុខជាដើម ព្រោះមានសតិសម្បជញ្ញៈ ព្រោះវៀរបុគ្គលអ្នកវង្វេងភ្លេចសតិ ដូចការរក្សាអាហារទុក ព្រោះគប់រកសមាគមជាមួយនឹងបុគ្គលអ្នកមាន សតិតាំងមាំ ដូច ព្រះតិស្សទត្តត្ថេរ និង អភយត្ថេរជាដើម និងព្រោះជាអ្នកមានចិត្តបង្អោនទៅដើម្បីឲ្យសតិតាំងឡើង ក្នុងឥរិយាបថទាំងឡាយ មានការអង្គុយ ការដេកជាដើម ។ លោករមែងដឹងច្បាស់ថា សេចក្តីបរិបូរណ៍នៃការចម្រើនសតិសម្ពោជ្ឈង្គៈនោះ ដែលកើតឡើងហើយដោយហេតុ ៤ យ៉ាងនេះ នឹងមានបានដោយអរហត្តមគ្គ ។

## ការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ

ចំណែកធម្មវិចយសម្ពោជ្ឈង្គៈ មានការកើតឡើងយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយកុសលធម៌ និងអកុសលធម៌ទាំងឡាយ ។លៗ ធម៌ដែលមានចំណែកប្រហាក់ប្រហែលនឹងកណ្ហធម៌ និងសុក្កធម៌ពួកណា ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃក្នុងធម៌ទាំងនោះ នេះជាអាហារ ( បច្ច័យ ) ប្រព្រឹត្តទៅដើម្បីឲ្យធម្មវិចយសម្ពោជ្ឈង្គៈ ដែលមិនទាន់កើត ឲ្យកើតឡើងផង ដើម្បីភិយ្យោភាព ដើម្បីបរិបូណ៌នៃធម្មវិចយសម្ពោជ្ឈង្គៈ ដើម្បីចម្រើន

ធម្មវិចយសម្ពោជ្ឈង្គៈ ដើម្បីឲ្យធម្មវិចយសម្ពោជ្ឈង្គៈបរិបូណ៌ផង ។

ម្យ៉ាងទៀត ធម៌ទាំង ៧ ប្រការ គឺ ការសាកសួរ ១ ការធ្វើវត្ថុឲ្យស្អាតផូរផង់ ១ ការធ្វើឥន្ទ្រីយ៍ឲ្យស្មើគ្នា ១ ការវៀរបុគ្គលអ្នកអាប់ឥតបញ្ញា ១ ការគប់រកសមាគមនឹងអ្នកមានបញ្ញា ១ ការពិចារណានូវការប្រព្រឹត្តដោយញាណដ៏ជ្រាលជ្រៅ ១ ការបង្អោនចិត្តទៅក្នុងធម្មវិចយៈនោះ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ ។ ភាពជាអ្នកច្រើនដោយការសាកសួរ ទាក់ទងនឹងសេចក្ដីនៃ **ខន្ធ អាយតនៈ ធាតុ ឥន្ទ្រីយ៍ ពលៈ ពោជ្ឈង្គៈ មគ្គ អង្គឈាន សមថៈ** និង **វិបស្សនា** ឈ្មោះថា **បរិបុច្ឆកតា** ក្នុងបណ្ដាធម៌ ៧ ប្រការនោះ ។

ការធ្វើវត្ថុទាំងខាងក្នុង និងខាងក្រៅឲ្យស្អាតផូរផង់ ឈ្មោះថា **វត្ថុ-វិសទកិរិយា** ។ ព្រោះថា កាលណាសក់ ក្រចក និងរោម របស់លោកវែងពេកទៅ ឬរាងកាយរបស់លោកមានរោគ ( ទោស ) ច្រើន និងមិនស្អាតស្អំ ដោយភាពកខ្វក់ គឺ ញើស កាលនោះ វត្ថុដែលមាននៅក្នុងខាងក្នុងចិត្ត និងមិនស្អាតផូរផង់ មិនបរិសុទ្ធ ។ តែកាលណាចីវររបស់លោកចាស់សៅហ្មង មានក្លិន ឬសេនាសនៈប្រឡាក់ប្រឡូស កាលនោះ វត្ថុដែលមានក្នុងខាងក្រៅ និងមិនស្អាតផូរផង់ មិនបរិសុទ្ធ ព្រោះដូច្នោះ វត្ថុខាងក្នុង លោកត្រូវធ្វើឲ្យស្អាត ផូរផង់ ដោយការកោរសក់ជាដើម ដោយការធ្វើរាងកាយឲ្យស្រាលសប្បាយ ដោយការជម្រះទាំងខាងលើ ទាំង

ខាងក្រោមជាដើម ( និង ) ដោយការអប់ឧណ្ហ ។

វត្ថុខាងក្រៅត្រូវធ្វើឲ្យស្អាតផូរផង់ ដោយការដេរ ការបោក ការជ្រលក់ និងការធ្វើគ្រឿងប្រើប្រាស់ជាដើម ។ ព្រោះថា សូម្បីញាណក្នុងចិត្ត និងចេតសិកដែលកើតឡើង ព្រោះវត្ថុខាងក្នុង និងខាងក្រៅនេះ ដែលមិនស្អាតផូរផង់ ក៏នឹងមិនស្អាតផូរផង់ ( ផងដែរ ) ដូចពន្លឺនៃអណ្តាតប្រទីបដែលកើតឡើងដោយអាស្រ័យប្រឆេះ និងប្រេងដែលមិនស្អាតដូច្នោះ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ការធ្វើវត្ថុឲ្យស្អាតផូរផង់ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ ។

ការធ្វើឥន្ទ្រិយ៍ មានសទ្ធាជាដើមឲ្យមានការស្មើគ្នា ឈ្មោះថា ការធ្វើឥន្ទ្រីយ៍ឲ្យស្មើគ្នា ។ ព្រោះប្រសិនបើសទ្ធិន្ទ្រីយ៍របស់លោក មានកម្លាំងឥន្ទ្រីយ៍ក្រៅអំពីនេះទន់ខ្សោយ ។ តពីនោះទៅ វិរិយៈក៏មិនអាចនឹងធ្វើនាទីផ្គត់ផ្គង់ទុកបាន សតិន្ទ្រីយ៍ក៏មិនអាចធ្វើនាទីប្រាកដបាន ។ សមាធិន្ទ្រីយ៍ក៏មិនអាចធ្វើនាទី ដែលមិនរាយមាយបាន បញ្ញាក៏មិនអាចនឹងពិចារណាឃើញច្បាស់បាន ។ ព្រោះដូច្នោះ ព្រះយោគាវចរ គប្បីឲ្យសទ្ធិន្ទ្រីយ៍នោះខ្សោយកម្លាំង ដោយការពិចារណាដល់សភាវធម៌ ឬដោយមិនយកចិត្តទុកដាក់ដល់សទ្ធិន្ទ្រីយ៍ដែលមានកម្លាំង ។ ក៏ក្នុងសេចក្តីនេះ មានរឿងរបស់ព្រះវក្កលិជាតួយ៉ាង ។ តែបើវិរិយិន្ទ្រីយ៍មានកម្លាំង ខាងក្រោយសទ្ធិន្ទ្រីយ៍នឹងមិនអាចធ្វើនាទីបង្អោនចិត្តជឿបានឡើយ ឥន្ទ្រីយ៍ក្រៅពីនេះ ក៏មិនអាចធ្វើនាទីផ្សេងក្រៅពីនេះបាន ព្រោះដូច្នោះ ព្រះយោគាវចរ គប្បីឲ្យវិរិយិន្ទ្រីយ៍

នោះ ថយចុះមកដោយការចម្រើនបស្សទ្ធិជាដើម ។ សូម្បីក្នុងសេចក្តីនោះ គប្បីសម្តែងរឿងរបស់ព្រះសោណត្ថេរ ជាឧទាហរណ៍ ។ សូម្បីក្នុងឥន្ទ្រិយ៍ដ៏សេស ក៏គប្បីជ្រាបយ៉ាងនោះ កាលឥន្ទ្រិយ៍តែមួយមានកម្លាំង គប្បីជ្រាបថា ឥន្ទ្រិយ៍ក្រៅពីនេះ ក៏អស់សមត្ថភាពក្នុងនាទីរបស់ខ្លួន ។

តែក្នុងរឿងនេះ លោកសរសើរដល់សទ្ធា និងបញ្ញាស្មើគ្នា , សមាធិ និងវិរិយៈស្មើគ្នាទុកដោយពិសេស ។ ព្រោះថា អ្នកមានសទ្ធាមានកម្លាំង តែមានបញ្ញាខ្សោយ នឹងមានសេចក្តីជ្រះថ្លាយ៉ាងងាយ គឺ ជ្រះថ្លាក្នុងវត្ថុដែលមិនមែនវត្ថុ អ្នកមានបញ្ញាមានកម្លាំង ( តែ ) មានសទ្ធាទន់ខ្សោយ រមែងក្រអឺតក្រទមអួតអាង ទូន្មានលំបាក ដូចរោគកើតថ្នាំ មិនធ្វើកុសលមានទានជាដើម ដោយគិតខុសថា កុសលនឹងមានបានដោយហេតុត្រឹមតែចិត្តុប្បាទប៉ុណ្ណោះ រមែងកើតក្នុងនរក ។ ( តែ ) ព្រោះសទ្ធា និងបញ្ញាទាំងពីរនេះស្មើគ្នា គេនឹងជ្រះថ្លាក្នុងព្រះរតនត្រ័យតែម្យ៉ាង ។ ចំណែកសមាធិមានកម្លាំង តែវិរិយៈទន់ខ្សោយ កោសជ្ជៈ ( ភាពខ្ជិលច្រអូស ) នឹងគ្របសង្កត់ ( លោក ) ព្រោះសមាធិជាបក្សពួកនៃកោសជ្ជៈ ។ បើវិរិយៈមានកម្លាំង តែសមាធិទន់ខ្សោយ ឧទ្ធច្ចៈ ( ការរាយមាយ ) នឹងគ្របសង្កត់លោក ព្រោះវិរិយៈជាបក្ខពួកនៃឧទ្ធច្ចៈ ។ ក៏សមាធិដែលប្រកបទៅដោយវិរិយៈ នឹងមិនធ្លាក់ទៅក្នុងកោសជ្ជៈ ការខ្ជិលច្រអូស ។ វិរិយៈដែលប្រកបទៅដោយសមាធិ នឹងមិនធ្លាក់ទៅក្នុងអំណាចឧទ្ធច្ចៈ ព្រោះដូច្នោះ ទើបគប្បីធ្វើសមាធិ និងវិរិយៈទាំងពីរនោះ ឲ្យស្មើគ្នា ។

ម្យ៉ាងទៀត សម្រាប់អ្នកផ្ដើមបំពេញសមាធិ សទ្ធាសូម្បីនឹងមានកម្លាំង ក៏ប្រើបាន ។ កាលបើដូច្នេះ នឹងសម្រេចអប្បនាបាន ។ ក្នុងសមាធិនិងបញ្ញា សម្រាប់អ្នកផ្ដើមបំពេញសមាធិ ឯកគ្គតា ( សមាធិ ) មានកម្លាំងរមែងប្រើបាន សេចក្ដីថា កាលបើដូច្នេះ លោកក៏នឹងសម្រេចអប្បនា ។ សម្រាប់អ្នកផ្ដើមបំពេញវិបស្សនាបញ្ញាមានកម្លាំង រមែងប្រើបាន ។ សេចក្ដីថា កាលបើដូច្នោះ លោកក៏នឹងចាក់ធ្លុះលក្ខណៈ ( ព្រះត្រៃលក្ខណ៍ ) ។ ក៏ព្រោះឥន្ទ្រិយ៍ទាំងពីរយ៉ាងនោះស្មើគ្នា អប្បនាក៏នឹងមានយ៉ាងពិតប្រាកដ ។ ចំណែកសតិមានកម្លាំង ប្រើបានក្នុងទីគ្រប់ស្ថាន ។ ព្រោះថា សតិនឹងរក្សាចិត្តទុកបានអំពីការធ្លាក់ទៅកាន់ឧទ្ធច្ចៈ ដោយអំណាចនៃសទ្ធា វិរិយៈ និងបញ្ញា ដែលជាបក្ខពួកនៃឧទ្ធច្ចៈ នឹងរក្សាចិត្តទុកបាន មិនឲ្យធ្លាក់ទៅកាន់កោសជ្ជៈដោយសមាធិ ដែលជាបក្ខពួកនៃកោសជ្ជៈ ព្រោះដូច្នោះ សតិនោះទើបត្រូវប្រាថ្នាក្នុងទីទាំងពួង ដូចក្នុងសម្លគ្រប់យ៉ាង ត្រូវការអំបិល និងដូចក្នុងរាជកិច្ចគ្រប់ប្រភេទ ត្រូវការអ្នកសម្រេចរាជការ ។ ដោយហេតុនោះ ទើបលោកពោលថា ក៏ឯសតិចាំបាច់ត្រូវប្រាថ្នាក្នុងទីទាំងពួង ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកហើយ ។

ព្រោះហេតុអ្វី ?

ព្រោះថា ចិត្ត មានសតិជាទីពឹងអាស្រ័យ និងសតិ មានការរក្សាជាគ្រឿងប្រាកដ វៀរសតិចេញហើយ ការផ្គង និងការគ្របសង្កត់ចិត្ត នឹងប្រព្រឹត្តទៅមិនបាន ។

ការវៀរឲ្យឆ្ងាយអំពីបុគ្គលអ្នកអប្បឥតបញ្ញា គឺ អ្នកមិនមានបញ្ញាឈានចុះក្នុងធម៌ ប្រភេទមានខន្ធជាដើម ឈ្មោះថាការវៀរបុគ្គលអ្នកអប្បឥតបញ្ញា ។ ការគប់រកបុគ្គលអ្នកប្រកបដោយបញ្ញាជាគ្រឿងពិចារណាឃើញការកើត និងការរលត់ ដែលកំណត់លក្ខណៈ ( ការកើតការរលត់ ) ៥០ យ៉ាង ឈ្មោះថា ការគប់រកបុគ្គលអ្នកមានបញ្ញា ។ ការពិចារណាប្រភេទនៃបញ្ញាដ៏ជ្រាលជ្រៅ ដែលប្រព្រឹត្តទៅហើយក្នុងខន្ធទាំងឡាយ ដ៏ជ្រាលជ្រៅ ឈ្មោះថា ការពិចារណាដល់ការប្រព្រឹត្តទៅនៃញាណដ៏ជ្រាលជ្រៅ ។ ការដែលចិត្តនោះបង្អោនទៅ ដើម្បីឲ្យធម្មវិចយសម្ពោជ្ឈង្គៈតាំងឡើងក្នុងឥរិយាបថអង្គុយ និងឥរិយាបថដេកជាដើម ឈ្មោះថា ការបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គៈនោះ ។ លោកដឹងច្បាស់ថា ក៏ធម្មវិចយ-សម្ពោជ្ឈង្គៈនោះ ដែលកើតឡើងហើយយ៉ាងនេះ នឹងមានការធ្វើឲ្យការនាបរិបូណ៌ដោយអរហត្តមគ្គ ។

## ការកើតឡើងនៃវិរិយសម្ពោជ្ឈង្គ

វិរិយសម្ពោជ្ឈង្គៈ មានការកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ **អារព្ភធាតុ និក្កមធាតុ បរក្កមធាតុ** មានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និងការធ្វើឲ្យច្រើនក្នុងអារព្ភធាតុជាដើមនោះ នេះជាអាហារ ( បច្ច័យ ) នឹងប្រព្រឹត្តទៅឲ្យវិរិយសម្ពោជ្ឈង្គៈ ដែលមិនទាន់កើត ឲ្យកើតឡើងផង ដើម្បីភិយ្យោភាព ដើម្បីភាពបរិបូណ៌ ដើម្បីសេចក្ដីចម្រើន ដើម្បី

ការបរិបូណ៌នៃវិរិយសម្ពោជ្ឈង្គៈ ដែលកើតឡើងហើយផង ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ គឺ ការពិចារណាឃើញភ័យក្នុងអបាយ ១ ការឃើញអានិសង្ស ១ ការពិចារណាឃើញផ្លូវដំណើរទៅ ១ ការគោរពកោតក្រែងចំពោះបិណ្ឌបាត ១ ការពិចារណាឃើញភាពជាធំដោយការៈជាទាយាទ ១ ការពិចារណាឃើញភាពជាធំរបស់ព្រះសាស្តា ១ ការពិចារណាឃើញភាពជាធំដោយជាតិ ១ ការពិចារណាឃើញភាពជាធំដោយជាមិត្តសព្រហ្មចារី ១ ការវៀរចាកបុគ្គលអ្នកខ្ជិលច្រអូស ១ ការគប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម ១ ភាពជាអ្នកមានចិត្តបង្អោនទៅក្នុងវិរិយសម្ពោជ្ឈង្គៈនោះ ១ រមែងប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃវិរិយសម្ពោជ្ឈង្គៈ ។

ក្នុងធម៌ ១១ ប្រការនោះ គប្បីជ្រាបការវិនិច្ឆ័យដូចតទៅនេះ ៖

យើងមិនអាចដើម្បីឲ្យវិរិយសម្ពោជ្ឈង្គៈ កើតឡើងក្នុងវេលាសោយទុក្ខយ៉ាងខ្លាំង ចាប់ផ្តើមតាំងតែពីកម្មករណ៍ដោយគ្រឿងចង ៥ ប្រការ ក្នុងនរកទាំងឡាយក្តី ក្នុងវេលាត្រូវចាប់ដោយគ្រឿងចាប់សត្វក្នុងទឹក មានការបង់សំណាញ់ និងដាក់ទ្រូជាដើម និងក្នុងវេលាដែលអូសរទេះជាដើមទៅនៃសត្វអ្នកត្រូវបញ្ជា ដោយការចាក់ដោយជន្លួញ និងវាយដោយខ្សែតីជាដើម ក្នុងកំណើតតិរច្ឆានក្តី ក្នុងវេលាសោយទុក្ខដោយការស្រេកឃ្លានអស់វេលាច្រើនពាន់ឆ្នាំខ្លះ មួយពុទ្ធន្តរខ្លះ ក្នុងវិស័យនៃប្រេតក្តី ក្នុងវេលា

សោយទុក្ខ មានខ្យល់ និងកំដៅជាដើម ដោយអត្តភាពដែលមានត្រឹមតែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ (ខ្ពស់) ប្រមាណ ៦០ ហត្ថ និង ៨០ ហត្ថ ក្នុងពួកអសុរឈ្មោះ **កាឡកញ្ជិក** ក្តី ម្នាលភិក្ខុទាំងឡាយ វេលានេះនោះឯងជាវេលាដែលអ្នកនឹងបំពេញសេចក្តីព្យាយាម[១] សូម្បីកាលអ្នកពិចារណាឃើញភ័យក្នុងអបាយដូចពណ៌នាមកនេះ វីរិយសម្ពោជ្ឈង្គៈក៏នឹងកើតឡើង ។ វីរិយសម្ពោជ្ឈង្គៈ ក៏នឹងកើតឡើង សូម្បីដល់អ្នកឃើញអានិសង្ស ( នៃសេចក្តីព្យាយាម ) យ៉ាងនេះថា អ្នកខ្ជិលច្រអូសមិនអាចនឹងបាន **នវលោកុត្តរធម៌** អ្នកប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ទើបអាចបាន នេះជាអានិសង្សនៃវីរិយៈ ។

វីរិយសម្ពោជ្ឈង្គៈ នឹងកើតឡើង សូម្បីដល់អ្នកពិចារណាឃើញដំណើរផ្លូវយ៉ាងនេះថា អ្នកគប្បីដើរផ្លូវដែលព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងមហាសាវកនៃព្រះពុទ្ធជាម្ចាស់ទាំងអស់ ស្តេចបានធ្វើដំណើរទៅ និងដើរទៅហើយ ហើយផ្លូវនោះអ្នកខ្ជិលច្រអូសមិនអាច មិនអាចនឹងធ្វើដំណើរទៅបាន ។

វីរិយសម្ពោជ្ឈង្គៈ មែងកើតឡើង សូម្បីដល់ភិក្ខុអ្នកមានការគោរពកោតក្រែងចំពោះបិណ្ឌបាត ដូចដែលកើតឡើងដល់ **ព្រះមហាមិត្តត្ថេរ** យ៉ាង

---

[១] បាឋៈថា **កាលោតិ ឯវំ** ច្បាប់ភូមាជា **កាលោ វីរិយការណាយាតិ ឯវំ** ប្រែតាមច្បាប់ភូមា ។

នេះថា ពួកជនអ្នកទំនុកបម្រុងយើងដោយបច្ច័យ មានបិណ្ឌបាតជាដើម អ្នកទាំងនេះមិនមែនញាតិរបស់យើងឡើយ មិនមែនទាសកម្មកររបស់យើង ទាំងគេមិនបានឲ្យបិណ្ឌបាតជាដើមដ៏ប្រណីតដល់យើង ដោយគិតថា ពួកយើងនឹងតាំងនៅបាន ព្រោះអាស្រ័យអាត្មាអញ ការពិត គឺ គេសង្ឃឹមថា សក្ការៈរបស់ខ្លួននឹងមានផលច្រើន ទើបនាំគ្នាថ្វាយ សូម្បីព្រះសាស្តា ក៏ទ្រង់មិនបានឃើញយ៉ាងនេះថា ភិក្ខុនេះបរិភោគបច្ច័យទាំងនេះហើយ នឹងជាអ្នកមានកាយមាំមួន នៅយ៉ាងសប្បាយ ទ្រង់បានអនុញ្ញាតទុកដល់អ្នកដោយពិត ទ្រង់បានអនុញ្ញាតបច្ច័យទាំងនោះ ព្រោះទ្រង់បំណងថា ភិក្ខុនេះកាលបរិភោគបច្ច័យទាំងនេះ នឹងបំពេញសមណធម៌ ហើយរួចផុតចាកទុក្ខឥឡូវនេះ អ្នកខ្ជិលច្រអូស នឹងមិនកោតក្រែងចំពោះបិណ្ឌបាតនោះ ព្រោះដែលឈ្មោះថា ការកោតក្រែងចំពោះបិណ្ឌបាតនឹងមានដល់ភិក្ខុអ្នកប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ។

## រឿងព្រះមហាមិត្តត្ថេរ

បានជ្រាបថា ព្រះថេរៈ អាស្រ័យនៅក្នុងទីមួយឈ្មោះថា កស្សកលេណៈ ហើយមហាឧបាសិកាម្នាក់នៅក្នុងគោចរគ្រាមរបស់ព្រះថេរៈនោះ បានបដិបត្តិព្រះថេរៈដូចកូនប្រុស ។ ថ្ងៃមួយ មុនពេលចូលព្រៃ គាត់បានប្រាប់កូនស្រីថា នាង អង្ករនៅទីនោះ ទឹកដោះនៅទីនោះ ទឹកដោះថ្លានៅ

ទីនោះ ទឹកអំពៅនៅទីនោះ ក្នុងវេលាដែលលោកម្ចាស់បងប្រុសរបស់កូនឯងមក កូនចូរដាំបាយ ថ្វាយព្រមនឹងទឹកដោះ ទឹកដោះថ្លា និងទឹកអំពៅ កូនឯងក៏បរិភោគដែរទៅ ចំណែកម៉ែ បរិភោគបាយកកនឹងទឹកជ្រក់បានហើយ ។

កូនស្រីសួរថា ពេលថ្ងៃម៉ែនឹងពិសាអ្វីទៅម៉ែ ?

ម្ដាយប្រាប់ថា កូនចូរ យកអង្ករខ្ទិច (កញ្ចុំងអង្ករ) ដាំឲ្យជាបបរជូរដាក់ជ្រក់ទៅ រៀបទុកចុះកូន ។

ព្រះថេរៈដណ្ដប់ចីវរហើយ នាំបាត្រចេញ បានឮសំឡេងនោះហើយពោលទូន្មានខ្លួនថា បានឮថា មហាឧបាសិកាបរិភោគបាយកកនឹងទឹកជ្រក់ សូម្បីពេលថ្ងៃ នឹងត្រូវបរិភោគបបរជាមួយទឹកជ្រក់ទៀត ។ តែប្រាប់ (ឲ្យដាំបាយ) ដោយអង្ករស្រូវចាស់ជាដើម ដើម្បីប្រយោជន៍ ដល់អាត្មាអញ្ញ ឯនាងមិនបានប្រាថ្នាស្រែចំការ កត្ត សំពត់ អំពីអាត្មាអញ្ញទេ តែប្រាថ្នាសម្បត្តិ ៣ ទើបថ្វាយ អាត្មាអញ្ញនឹងអាចឲ្យសម្បត្តិទាំងនោះដល់នាង ឬថានឹងមិនអាចទេ ឯបិណ្ឌបាតនេះ ដែលអាត្មាអញ្ញនៅមានរាគៈ ទោសៈនិងមោហៈ មិនអាចនឹងទទួលបាន ទើបយកបាត្រ ប្រកបចូលថង់បិទទុកហើយត្រឡប់ទៅកាន់កស្សកលេណៈវិញ យកបាត្រទុកក្រោមគ្រែ ពាក់ចីវរទុកលើស្នចីវរ គិតថា អាត្មាអញ្ញមិនទាន់សម្រេចព្រះអរហត្តផលដរាបណា នឹងមិនចេញទៅដរាបនោះ អង្គុយព្យាយាម ដោយសេចក្តីមិនប្រមាទជាភិក្ខុរក្សាខ្លួននៅដោយការមិនប្រមាទរហូតអស់កាលយូរ ចម្រើនវិបស្សនា

សម្រេចអរហត្តមុនគេទាន់នោះឯង ជាព្រះមហាខីណាស្រព ញញឹមញញែម ចេញមកដូចជាផ្កាបទុមដែលរីកស្រស់ដូច្នោះ ទេវតាដែលស្ថិតនៅឯដើមឈើជិតទ្វារគុហា ( ឃើញលោកហើយ ) បន្លឺឧទាន យ៉ាងនេះថា ៖

បពិត្របុរសអាជានេយ្យ ខ្ញុំម្ចាស់សូមនមស្ការក្រាបថ្វាយ
បង្គំដល់លោក បពិត្រលោកដ៏ប្រសើរ ខ្ញុំម្ចាស់សូមថ្វាយ
បង្គំចំពោះលោក បពិត្រលោកអ្នកនិរទុក្ខ លោកលះបង់
អាសវៈបានហើយ ទើបជាអ្នកសមគួរទទួលទក្ខិណា ។

ដូច្នេះហើយ ពោលថា លោកម្ចាស់ ពួកស្ត្រីចាស់ថ្វាយភិក្ខាដល់ព្រះអរហន្ត ដូចលោកដែលចូលទៅទទួលបិណ្ឌបាតហើយ នឹងរួចផុតទុក្ខបាន ។

ព្រះថេរៈក្រោកឡើងបើកទ្វារមើលវេលា ជ្រាបថា នៅព្រឹកនៅឡើយ ទើបឱបបាត្រ យុំចីវរចូលទៅកាន់ស្រុក ។ ចំណែកកូនស្រីត្រៀមភត្តហើយ (ក៏ចេញមក) អង្គុយចាំមើលផ្លូវត្រង់ទ្វារ ដោយសង្ឃឹមថា លោកបងរបស់យើងនឹងមកឥឡូវនេះ នឹងមកឥឡូវនេះ ។ កាលព្រះថេរៈមកដល់ទ្វារផ្ទះ នាងក៏ទទួលបាត្រទៅដាក់ពំនូតបាយ ដែលផ្សំដោយទឹកដោះផ្សំដោយទឹកដោះថ្លា និងទឹកអំពៅរហូតពេញ ហើយនាំយកទៅប្រគេនដល់ដៃ ។ ព្រះថេរៈធ្វើការអនុមោទនាថា ចូរមានសេចក្តីសុខចុះ ដូច្នេះហើយគេចចេញទៅ ។ ចំណែកកូនស្រីនោះ ក៏បានឈរមើលលោកភ្លេចខ្លួន ។ ព្រោះវេលានោះ ឆវិវណ្ណរបស់ព្រះថេរៈផូរផង់ក្រៃលែងណាស់

ឥន្ទ្រិយ៍ទាំងឡាយក៏ស្រស់ថ្លា ដួងភ្នែកក៏ស្រស់បស់ត្រចះត្រចង់ យ៉ាងក្រៃលែង ដូចផ្លែត្នោតទុំដែលជ្រុះចាកទង ដូច្នោះ ។

មហាឧបាសិកាត្រឡប់អំពីព្រៃ សួរថា នាង លោកបងរបស់កូនមកហើយឬ ?

នាងបានតំណាលរឿងរ៉ាវទាំងអស់ឲ្យស្តាប់ ។ ឧបាសិកាជ្រាបថា ថ្ងៃនេះ កិច្ចបព្វជិតនៃកូនប្រុសរបស់យើងដល់ទីបំផុតហើយ ទើបនិយាយថា កូនអើយ បងប្រុសរបស់ឯងនៅអភិរម្យមិននឿយណាយក្នុងព្រះពុទ្ធ-សាសនាទេ ។

វិរិយសម្ពោជ្ឈង្គៈ រមែងកើតឡើងដល់ភិក្ខុ អ្នកពិចារណាឃើញភាពក្រៃលែងនៃមត៌ក ក៏ឯមត៌ករបស់ព្រះសាស្តា គឺ អរិយទ្រព្យ ៧ ជារបស់ធំក្រៃលែង អ្នកខ្ជិលច្រអូសមិនអាចទទួលមត៌កនោះទុកបាន ដូចយ៉ាងថា មាតាបិតារមែង កម្ចាត់បង់បុត្រដែលខិលខូចឲ្យចេញចាកគំនរមត៌ក ដោយសម្គាល់ថា អានេះ មិនមែនកូនរបស់អញ ( តទៅទៀត ) ព្រោះបច្ច័យ (គឺការកាត់ផ្តាច់) របស់ឪពុកម្តាយនោះ បុត្រដែលខូចខិលនោះ រមែងមិនបានទទួលមត៌កយ៉ាងណា សូម្បីភិក្ខុអ្នកខ្ជិលច្រអូស ក៏ដូច្នោះ នឹងមិនបានទទួលមត៌ក គឺ អរិយទ្រព្យនេះ ភិក្ខុអ្នកប្រារព្ធនូវសេចក្តីព្យាយាមប៉ុណ្ណោះ ទើបនឹងទទួលបាន ។

វិរិយសម្ពោជ្ឈង្គៈ រមែងកើតឡើងដល់ភិក្ខុ អ្នកសូម្បីពិចារណាដល់ភាពអស្ចារ្យរបស់ព្រះសាស្តាយ៉ាងនេះថា ព្រះសាស្តាជាម្ចាស់ អស្ចារ្យ

ណាស់ ព្រោះថា ក្នុងវេលាដែលព្រះសាស្តាទ្រង់ចុះចាប់បដិសន្ធិក្នុងព្រះគភ៌ព្រះមាតាក្តី ក្នុងពេលស្តេចចេញសាងមហាអភិនេស្រ្កមណ៍ក្តី ក្នុងពេលត្រាស់ដឹងអនុត្តរសម្មោធិញ្ញាណក្តី ក្នុងពេលសម្តែងព្រះធម្មចក្កក្តី ក្នុងពេលទ្រង់សម្តែងយមកប្បាដិហារ្យក្តី ស្តេចចុះអំពីទេវលោក និងដាក់ព្រះជន្មាយុសង្ខារក្តី មុនលោកធាតុក៏កម្រើកញាប់ញ័រ គួរដែរឬ ដែលអ្នកបួសក្នុងសាសនានៃព្រះសាស្តាបែបនេះហើយ នឹងមកខ្ជិលច្រអូស ។

វិរិយសម្ពោជ្ឈង្គៈ រមែងកើតឡើងដល់ភិក្ខុអ្នកពិចារណាសូម្បីដល់ភាពក្រៃលែងនៃជាតិ ( កំណើត ) យ៉ាងនេះថា សូម្បីលោកពោលដោយកំណើត ឥឡូវនេះអ្នកក៏មិនមែនមនុស្សដែលមានកំណើតថោកទាប អ្នកមកអំពីត្រកូលនៃព្រះបាទមហាសម្មតៈ មិនលាយឡំ ( នឹងមនុស្សវណ្ណៈដទៃ ) ទាំងបានកើតក្នុងព្រះរាជវង្សនៃព្រះបាទឱក្កាករាជ បានជាព្រះនត្តានៃព្រះបាទសុទ្ធោទនមហារាជ និងព្រះនាងមហាមាយាទេវី ( និង ) ជាព្រះកនិដ្ឋភាតារបស់ព្រះម្ចាស់បងរាហុល ដែលធម្មតាថា អ្នកបានជាជិនបុត្របែបនេះ នឹងរស់តែខ្ជិលច្រអូស មិនសមគួរឡើយ ។

វិរិយសម្ពោជ្ឈង្គៈ រមែងកើតឡើងដល់ភិក្ខុ អ្នកសូម្បីពិចារណាដល់ភាពក្រៃលែងនៃមិត្តសព្រហ្មចារី យ៉ាងនេះថា ព្រះសារីបុត្រ ព្រះមោគ្គល្លាន និងព្រះអសីតិមហាសាវ័ក ចាក់ធ្លុះលោកុត្តរធម៌ដោយសេចក្តីព្យាយាមដោយពិត អ្នកនឹងធ្វើដំណើរទៅតាមផ្លូវនៃមិត្ត សព្រហ្មចារីទាំងនោះ ឬនឹងមិនធ្វើដំណើរទៅតាម ។

វិរិយសម្ពោជ្ឈង្គៈ រមែងកើតឡើងដល់ភិក្ខុ អ្នកវៀរចាកបុគ្គលដែលខ្ជិលច្រអូស លោះបង់ចោលសេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ប្រៀបដូចពស់វែក ហេលហាល ដោយហេតុតឹងពោះ ព្រោះបរិភោគអាហារច្រើនហួសកំណត់ ដល់ភិក្ខុអ្នកគប់រកបុគ្គលដែលមានខ្លួនតាំងមាំ ប្រារព្ធសេចក្តីព្យាយាម ទាំងដល់ភិក្ខុអ្នកមានចិត្តបង្អោនទៅដើម្បីឲ្យកើតសេចក្តីព្យាយាមក្នុងឥរិយាបថទាំងឡាយ មានឥរិយាបថឈរ និងអង្គុយជាដើម ។

កាលវិរិយសម្ពោជ្ឈង្គៈនោះ កើតឡើងហើយយ៉ាងនេះ ភិក្ខុរមែងជ្រាបច្បាស់ថា ការចម្រើនពេញលេញ (នៃវិរិយសម្ពោជ្ឈង្គៈ) មានបានដោយព្រះអរហត្តមគ្គ ។

## ការកើតឡើងនៃបីតិសម្ពោជ្ឈង្គ

បីតិសម្ពោជ្ឈង្គៈ រមែងកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយធម៌ទាំងឡាយ ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ មានការធ្វើទុកក្នុងចិត្តដោយប្រពៃ និងការធ្វើឲ្យច្រើនក្នុងធម៌នោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីឲ្យបីតិសម្ពោជ្ឈង្គៈ ដែលនៅមិនទាន់កើត ឲ្យកើតឡើង ឬប្រព្រឹត្តទៅដើម្បីឲ្យបីតិសម្ពោជ្ឈង្គៈ ដែលកើតឡើងហើយ ឲ្យជាភិយ្យោភាព ។

ក្នុងព្រះពុទ្ធវចនៈនោះ បីតិនុ៎ះឯង ឈ្មោះថា ធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ ការធ្វើទុកក្នុងចិត្តដែលឲ្យបីតិសម្ពោជ្ឈង្គៈនោះកើតឡើងឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ។

*ម្យ៉ាងទៀត ធម៌ ១១ ប្រការ គឺ ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ឧបសមានុស្សតិ ១ ការចៀសវាងបុគ្គលដែលមានទោស ១ ការសេពគប់រកបុគ្គលដែលមានគុណ ១ ការពិចារណាដល់ព្រះសូត្រដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងបីតិសម្ពោជ្ឈង្គៈនោះ ១ ។ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គៈ ។*

*អធិប្បាយថា ចំពោះភិក្ខុ ជាអ្នកព្យាយាមរឭកដល់ព្រះពុទ្ធគុណ បីតិសម្ពោជ្ឈង្គៈរមែងកើតឡើងផ្សាយទៅសព្វសព៌ាង្គកាយ រហូតដល់ឧបចារសមាធិ ។ ចំពោះភិក្ខុដែលព្យាយាមរឭកដល់ព្រះធម្មគុណ ព្រះសង្ឃគុណក្ដី អ្នកពិចារណាដល់ចតុប្បារិសុទ្ធិសីលដែលរក្សាទុកមិនដាច់ រហូតអស់កាលយូរក្ដី បីតិសម្ពោជ្ឈង្គៈ ក៏រមែងកើតឡើងបាន ។*

*សូម្បីចំពោះគ្រហស្ថ អ្នកពិចារណាដល់សីល ១០ សីល ៥ ក្ដី អ្នកថ្វាយភោជនដ៏ប្រណីតដល់លោកដែលជាសព្រហ្មចារី ក្នុងគ្រាកើតទុព្ភិក្ខភ័យជាដើម ហើយពិចារណាដល់ការបរិច្ចាគ (របស់ខ្លួន) ថា យើងបានថ្វាយយ៉ាងនេះក្ដី បីតិសម្ពោជ្ឈង្គៈនឹងកើតឡើងបាន ។*

*ម្យ៉ាងទៀត ចំពោះគ្រហស្ថអ្នកពិចារណាដល់ទាន ដែលថ្វាយដល់លោកអ្នកមានសីលក្នុងកាលដូច្នេះក្ដី បានពិចារណាឃើញថា ទេវតាប្រកបដោយគុណទាំងឡាយណា ទើបដល់ភាពជាទេវតា គុណទាំងនោះ មាននៅក្នុងខ្លួនក្ដី បីតិសម្ពោជ្ឈង្គៈ ក៏កើតឡើងបាន ។*

ចំពោះភិក្ខុ អ្នកពិចារណាឃើញកិលេស ដែលគ្របសង្កត់បានហើយ ដោយសមាបត្តិថា (កិលេសទាំងនេះ) មិនកើតឡើងអស់វេលា ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះក្តី អ្នកចៀសវាងបុគ្គលសៅហ្មង ដែលប្រាកដច្បាស់ដោយការមិនធ្វើសេចក្តីគោរពក្នុងកាលបានឃើញព្រះចេតិយ៍ ឃើញដើមពោធិព្រឹក្ស និងឃើញព្រះថេរៈអ្នកឈ្មោះថា ដូចជាលំអងធូលី ( ដែលជាប់ ) លើដំបូល ព្រោះមិនមានសេចក្តីជ្រះថ្លា និងសេចក្តីស្រឡាញ់ក្នុងព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើមក្តី ដែលសេពគប់អ្នកបរិសុទ្ធ មានចិត្តទន់ភ្លន់ ច្រើនដោយសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើមក្តី អ្នកពិចារណាដល់ព្រះសូត្រ ដែលជាហេតុឲ្យកើតសេចក្តីជ្រះថ្លា សម្តែងគុណរបស់ព្រះរតនត្រៃក្តី អ្នកមានចិត្តបង្អោនទៅដើម្បីឲ្យកើតបីតិក្នុងឥរិយាបថឈរ និងអង្គុយជាដើមក្តី បីតិសម្ពោជ្ឈង្គៈ រមែងកើតឡើងបាន ។

ក៏កាលបីតិសម្ពោជ្ឈង្គៈនោះ កើតឡើងហើយយ៉ាងនោះ ភិក្ខុរមែងដឹងច្បាស់ថា ការចម្រើនដោយបរិបូណ៌ (នៃបីតិសម្ពោជ្ឈង្គៈ) បានដោយអរហត្តមគ្គ ។

## ការកើតឡើងរបស់បស្សទ្ធិសម្ពោជ្ឈង្គ

បស្សទ្ធិសម្ពោជ្ឈង្គៈ រមែងកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ កាយបស្សទ្ធិ ចិត្តបស្សទ្ធិ មានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏

ប្រេតៃ និងការធ្វើឲ្យច្រើនក្នុងកាយបស្សទ្ធិនោះ នេះជាអាហារ ( បច្ច័យ ) ឲ្យបស្សទ្ធិសម្ពោជ្ឈង្គៈ ដែលមិនទាន់កើត ឲ្យកើតឡើង ឬរមែងប្រព្រឹត្ត ទៅដើម្បីឲ្យបស្សទ្ធិសម្ពោជ្ឈង្គៈ ដែលកើតឡើងហើយ បរិបូណ៌ជាកិយ្យោ-ភាព ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ គឺ **ការបរិភោគភោជនដ៏ប្រណីត ១ ការសេពសុខតាមរដូវ ១ ការសេពសុខតាមឥរិយាបថ ១ ភាពជាអ្នកមានមជ្ឈត្តប្បយោគ ១ ការចៀសវាងបុគ្គលអ្នកមានកាយសោប់សេល់ ១ ការគប់រកបុគ្គលអ្នកមានកាយស្ងប់ ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងបស្សទ្ធិ-សម្ពោជ្ឈង្គនោះ ១** រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបស្សទ្ធិសម្ពោ-ជ្ឈង្គៈ ។

អធិប្បាយថា ចំពោះភិក្ខុដែលបរិភោគភោជន ដែលជាទីសប្បាយ មានរសជាតិឆ្ងាញ់ប្រណីតក្តី អ្នកសេពរដូវជាទីសប្បាយ ក្នុងបណ្តារដូវត្រជាក់ និងរដូវក្តៅ និងឥរិយាបថជាទីសប្បាយ ក្នុងបណ្តាឥរិយាបថឈរជាដើមក្តី បស្សទ្ធិរមែងកើតឡើង ។

ចំណែកភិក្ខុណា មានលក្ខណនិស្ស័យជាមហាបុរស រមែងអត់ធន់ចំពោះរដូវ និងឥរិយាបថទាំងពួងបានយ៉ាងក្រៃលែង ពាក្យនេះលោកមិនបានពោលសំដៅយកភិក្ខុនោះទេ ។

ចំពោះភិក្ខុណា មានរដូវ និងឥរិយាបថដែលជាសភាគៈ ( ដែលជាទីសប្បាយ ) និងវិសភាគៈ ( អសប្បាយ ) បស្សទ្ធិ រមែងកើតឡើងដល់

ភិក្ខុនោះឯង សូម្បីលោកវៀរផ្លូវ និងឥរិយាបថ ដែលជាវិសភាគៈចេញហើយ សេពផ្លូវ និងឥរិយាបថដែលជាសភាគៈ ។

ការពិចារណាឃើញថា ខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួនលោកហៅថា មជ្ឈត្តប្បយោគ បស្សទ្ធិរមែងកើតឡើងបាន ព្រោះមជ្ឈត្តប្បយោគនេះ ។

ភិក្ខុត្រូវចៀសវាងបុគ្គលអ្នកមានកាយសោហ់សល់ អ្នកដើរបៀតបៀនបុគ្គលដទៃគ្រប់វេលាដោយដុំដី និងកំណាត់ឈើជាដើម ត្រូវគប់រកបុគ្គលអ្នកមានកាយស្ងប់ អ្នកសង្រួមដៃ និងជើងក្តី អ្នកមានចិត្តបង្អោនទៅដើម្បីឲ្យកើតបស្សទ្ធិក្នុងឥរិយាបថទាំងឡាយ មានឈរ និងអង្គុយជាដើមក្តី បស្សទ្ធិ រមែងកើតឡើងបាន ។

កាលបស្សទ្ធិសម្ពោជ្ឈង្គៈកើតឡើងហើយយ៉ាងនោះ ភិក្ខុរមែងដឹងច្បាស់ថា ការបរិបូណ៌ (នៃបស្សទ្ធិសម្ពោជ្ឈង្គៈ) រមែងមានដោយអរហត្តមគ្គ ។

## ការកើតឡើងនៃសមាធិសម្ពោជ្ឈង្គ

សមាធិសម្ពោជ្ឈង្គៈ រមែងកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ សមថនិមិត្ត ដែលជាអព្យគ្គនិមិត្ត មានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និងការធ្វើឲ្យច្រើនក្នុងសមថនិមិត្តនោះ នេះឯងជាអាហារ ( បច្ច័យ ) ឲ្យសមាធិសម្ពោជ្ឈង្គៈដែលមិនទាន់កើត ឲ្យកើតឡើង ឬរមែងប្រព្រឹត្តទៅដើម្បីឲ្យសមាធិសម្ពោជ្ឈៈ ដែលកើតឡើងហើយចម្រើនបរិបូណ៌

ក្នុងសមាធិសម្ពោជ្ឈង្គៈនោះ សមថនិមិត្ត ជាសមថៈផង ឈ្មោះថា ជា អព្យគ្គនិមិត្ត ព្រោះអត្ថថា មិនរាយមាយផង ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ គឺ ការធ្វើវត្ថុឲ្យស្អាតបរិសុទ្ធិ ១ ការធ្វើ ឥន្ទ្រីយ៍ឲ្យស្មើគ្នា ១ ភាពជាអ្នកឈ្លាសវៃក្នុងនិមិត្ត ១ ការលើកចិត្តឡើងក្នុងសម័យ ( ដែលគួរលើក ) ១ ការសង្កត់ចិត្តក្នុងសម័យ ( ដែលគួរសង្កត់ ) ១ ការធ្វើចិត្តឲ្យរីករាយក្នុងសម័យ ( ដែលគួរធ្វើឲ្យរីករាយ ) ១ ការសម្លឹងមើលចិត្តព្រងើយៗក្នុងសម័យ ( ដែលគួរសម្លឹងមើល ) ១ ការចៀសវាងបុគ្គលអ្នកមានចិត្តមិនជាសមាធិ ១ ការគប់រកបុគ្គលអ្នកមានចិត្តជាសមាធិ ១ ការពិចារណាឈាន និងវិមោក្ខ ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គៈ ១ រមែងប្រព្រឹត្តទៅ ដើម្បីការកើតឡើងនៃសមាធិសម្ពោជ្ឈង្គៈ ។

បណ្តាធម៌ ១១ ប្រការនោះ ការធ្វើវត្ថុឲ្យស្អាតបរិសុទ្ធិ និងការធ្វើឥន្ទ្រីយ៍ឲ្យប្រព្រឹត្តទៅស្មើគ្នា គប្បីជ្រាបតាមន័យ ដែលបានពោលហើយនោះចុះ ។

ភាពជាអ្នកឈ្លាសវៃក្នុងការរៀនកសិណនិមិត្ត ឈ្មោះថា ភាពជាអ្នកឈ្លាសវៃក្នុងនិមិត្ត ។

បទថា **សមយេ ចិត្តស្ស បគ្គណ្ហនតា** ( ការផ្គងចិត្តក្នុងសម័យដែលគួរផ្គង ) មានអធិប្បាយថា ក្នុងសម័យណា ចិត្តជាធម្មជាតិរួញរាដោយហេតុទាំងឡាយ មានសេចក្តីព្យាយាមតិចតួចហួសប្រមាណជាដើម

ការលើកចិត្តនោះ ក្នុងសម័យនោះ ដោយការញ៉ាំងធម្មវិចយសម្ពោជ្ឈង្គៈ វិរិយសម្ពោជ្ឈង្គៈ និងបីតិសម្ពោជ្ឈង្គៈឲ្យកើតឡើងព្រមគ្នា ។

បទថា **សមយេ ចិត្តស្ស និគ្គណ្ហនតា** ( ការសង្កត់ចិត្តក្នុងសម័យដែលគួរសង្កត់ ) សេចក្តីថា ក្នុងសម័យណាចិត្តជាធម្មជាតិរាយមាយ ដោយហេតុទាំងឡាយ មានការប្រារព្ធសេចក្តីព្យាយាមខ្លាំងហួសប្រមាណជាដើម ការសង្កត់ចិត្តនោះ ក្នុងសម័យនោះ ដោយការញ៉ាំងបស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និងឧបេក្ខាសម្ពោជ្ឈង្គៈ ឲ្យកើតឡើងព្រមគ្នា ។

បទថា **សមយេ សម្បហំសនតា** (ការផ្គងចិត្តឲ្យរីករាយក្នុងសម័យដែលគួរផ្គងចិត្តឲ្យរីករាយ ) សេចក្តីថា ក្នុងសម័យណាចិត្តជាធម្មជាតិមិនស្រស់ថ្លា ព្រោះមានបញ្ញា និងការព្យាយាមតិច ឬព្រោះមិនបានសម្រេចដល់សេចក្តីសុខដែលកើតពីការចូលទៅស្ងប់ ក្នុងសម័យនោះ ព្រះយោ-គាវចរ គប្បីញ៉ាំងចិត្តឲ្យសង្វេគដោយការពិចារណាសង្វេគវត្ថុ ( ទីតាំងនៃសេចក្តីសង្វេគ ) ៨ យ៉ាង ដែលឈ្មោះថា សង្វេគវត្ថុ ៨ យ៉ាងនោះ បានដល់ ជាតិ ជរា ព្យាធិ និងមរណៈ រួមជា ៤ ទុក្ខក្នុងអបាយជាទី ៥ ទុក្ខដែលមានវដ្តៈជាមូលក្នុងអតីត ១ ទុក្ខដែលមានវដ្តៈជាមូលក្នុងអនាគត ១ ទុក្ខមានការស្វែងអាហារជាមូលក្នុងបច្ចុប្បន្ន ១ ។ និងឲ្យកើតសេចក្តីជ្រះថ្លា ដោយការព្យាយាមរឭកដល់គុណរបស់ព្រះរតនត្រៃ ។ នេះហៅថា ការផ្គងចិត្តឲ្យរីករាយក្នុងសម័យ ( ដែលគួរផ្គងចិត្តរីករាយ ) ។

ដែលឈ្មោះថា ការសម្លឹងមើលចិត្តព្រងើយ ៗ ក្នុងសម័យដែល

( គួរសម្លឹងមើលចិត្តយ៉ាងព្រងើយ ៗ ) បានដល់ ក្នុងសម័យណា ចិត្តជាធម្មជាតិមិនរួញរា មិនរាយមាយ មានភាពរីករាយប្រព្រឹត្តទៅក្នុងអារម្មណ៍យ៉ាងស្មើប្រពៃ ដំណើរទៅតាមវិថីនៃសមថៈ ព្រោះអាស្រ័យការបដិបត្តិដ៏ប្រពៃក្នុងការលើកចិត្ត ការសង្កត់ចិត្ត និងការផ្គងចិត្តនោះ ឲ្យរីករាយប្រៀបដូចនាយសារថី មិនចាំបាច់ខ្វល់ខ្វាយនឹងសេះ ដែលរត់ទៅស្មើត្រង់នេះហៅថា ការសម្លឹងមើលចិត្តព្រងើយក្នុងសម័យ (ដែលគួរសម្លឹងមើលព្រងើយ ៗ ) ។

ដែលឈ្មោះថា ការចៀសវាងបុគ្គលមានចិត្តមិនសមាធិ បានដល់ការចៀសវាងឲ្យឆ្ងាយនូវបុគ្គលអ្នកមិនបានសម្រេចឧបចារសមាធិ ឬអប្បនាសមាធិ អ្នកមានចិត្តរាយមាយ ។

ដែលឈ្មោះថា ការគប់រកបុគ្គលអ្នកមានចិត្តជាសមាធិ បានដល់ការសេពគប់ ការគប់រក ការចូលទៅអង្គុយជិតបុគ្គលអ្នកមានចិត្តតាំងមាំដោយឧបចារសមាធិ ឬអប្បនាសមាធិ ។

ដែលឈ្មោះថា ភាពជាអ្នកបង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គៈនោះ បានដល់ ភាពជាអ្នកមានចិត្តបង្អោនទៅក្នុងឥរិយាបថទាំងឡាយ មានឈរនិងអង្គុយជាដើម ។

ក៏កាលព្រះយោគាវចរបដិបត្តិយ៉ាងនេះ សមាធិសម្ពោជ្ឈង្គៈនោះ រមែងកើតឡើង ។ ក៏កាលសមាធិសម្ពោជ្ឈង្គៈនោះ កើតឡើងយ៉ាងនោះ ព្រះយោគាវចរ រមែងជ្រាបច្បាស់ថា ការចម្រើនដ៏បរិបូណ៌ ( នៃសមាធិ-

សម្ពោជ្ឈង្គៈ ) បាន ដោយអរហត្តមគ្គ ។

## ការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ

ឧបេក្ខាសម្ពោជ្ឈង្គៈ រមែងកើតឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គៈ មានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និងការធ្វើឲ្យច្រើនក្នុងធម៌នោះ នេះជាអាហារ ( បច្ច័យ ) ឲ្យឧបេក្ខាសម្ពោជ្ឈង្គៈដែលនៅមិនទាន់កើត ឲ្យកើតឡើង ឬរមែងប្រព្រឹត្តទៅដើម្បីឲ្យឧបេក្ខាសម្ពោជ្ឈង្គៈដែលកើតឡើងហើយ ឲ្យចម្រើនបរិបូណ៌ ។ ក្នុងព្រះតម្រាស់នោះ ឧបេក្ខានោះឯង ឈ្មោះថា ធម៌ ដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គៈ ។

ម្យ៉ាងទៀត ធម៌ ៥ ប្រការ គឺ ភាពជាអ្នកដាក់ខ្លួនជាកណ្តាលក្នុងសត្វ ១ ភាពជាអ្នកដាក់ខ្លួនជាកណ្តាលក្នុងសង្ខារ ១ ការចៀសវាងបុគ្គលអ្នកជាប់ជំពាក់ក្នុងសត្វ និងសង្ខារ ១ ការគប់រកបុគ្គលអ្នកដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងឧបេក្ខាសម្ពោជ្ឈង្គៈនោះ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គៈ ។

បណ្តាធម៌ ៥ ប្រការនោះ ព្រះយោគាវចររមែងញុំាងការដាក់ខ្លួនជាកណ្តាលក្នុងសត្វ ឲ្យកើតឡើងដោយអាការ ២ យ៉ាងគឺ ដោយការពិចារណាឃើញថា សត្វមានកម្មជារបស់ខ្លួនយ៉ាងនេះថា ឯងមកតាមកម្ម

របស់ខ្លួនហើយ ក៏នឹងទៅតាមកម្មរបស់ខ្លួន ( ដូចគ្នា ) ។

ឯងនឹងទៅជាប់ជំពាក់នឹងនរណាទៅ និងដោយការពិចារណាឃើញថា មិនមែនសត្វ យ៉ាងនេះថា ពោលដោយបរមត្ថហើយសត្វមិនមានឡើយ ឯងនឹងទៅជាប់ជំពាក់នឹងនរណាទៅ ។

គប្បីញ៉ាំងការដាក់ខ្លួនជាកណ្ដាលក្នុងសង្ខារ ឲ្យកើតឡើងដោយអាការ ២ យ៉ាង គឺ ដោយពិចារណាឃើញថា មិនមានម្ចាស់យ៉ាងនេះថា សំពត់ចីវរនេះ ចូលដល់ការប្រែប្រួលពណ៌ និងការគ្រាំគ្រាទៅតាមលំដាប់ ហើយក្លាយទៅជាសំពត់ជូតជើង នឹងត្រូវគេច្រឹះបោលដោយចុងឈើប្រត់ ក៏ប្រសិនបើចីវរនោះ នឹងគប្បីមានម្ចាស់សោត អ្នកក៏នឹងមិនព្រមឲ្យចីវរនោះវិនាសទៅយ៉ាងនោះ ១ ហើយដោយការពិចារណាឃើញថា ជារបស់បណ្ដោះអាសន្នយ៉ាងនេះថា ចីវរនេះ មិនស្ថិតស្ថេរ នៅបានមួយរយៈពេលខ្លី ១ ។

មួយ៉ាងទៀត បណ្ឌិតគប្បីធ្វើការប្រកបសេចក្ដីសូម្បីក្នុងបាត្រជាដើម ដូចជាក្នុងចីវរ ដូច្នោះ ។

ក្នុងពាក្យថា **សត្តសង្ខារកេលាយនបុគ្គលបរិវជ្ជនតា** ( ការចៀសវាងបុគ្គលអ្នកជាប់ជំពាក់ក្នុងសត្វ និងសង្ខារ ) គប្បីជ្រាបការវិនិច្ឆ័យដូចតទៅនេះ ៖

បុគ្គលណាជាគ្រហស្ថ រមែងប្រកាន់នូវបិយជនទាំងឡាយ មានបុត្រា និងបុត្រីជាដើមរបស់ខ្លួនថា ជារបស់យើង ។ ចំពោះបព្វជិត រមែងប្រកាន់

អន្តេវាសិក សទ្ធិវិហារិក និងអ្នករួមឧបជ្ឈាយ៍ជាដើម របស់ខ្លួនថា ជារបស់យើង ចុះដៃធ្វើការងារទាំងឡាយ មានការកោរសក់ ដេរសំពត់ ជ្រលក់ចីវរ និងដុតបាត្រជាដើម ឲ្យដល់បុគ្គលទាំងឡាយនោះឯង មិនឃើញត្រឹមតែមួយភ្លែត ក៏ទៅតាមរកយ៉ាងវីវក់ មិនខុសអ្វីនឹងម្រឹគដែលភ្ញាក់ផ្អើល ( ស្រែកសួរថា ) សាមណេររូបនោះទៅណា ? ភិក្ខុកំលោះរូបនោះទៅណាហើយ ? សូម្បីត្រូវអ្នកដទៃសំណូមពរថា សូមលោកបញ្ជូនភិក្ខុកំលោះ ឬសាមណេររូបនោះ ឲ្យទៅជួយកោរសក់ ត្រឹមតែបន្តិចបន្តួចជាដើម ក៏មិនព្រមឲ្យទៅដោយអាងថា សូម្បីពួកយើង មិនទាន់ហ៊ានប្រើពួកគេឲ្យធ្វើការងាររបស់ខ្លួនផង ពួកលោកនឹងមកយកគេទៅ ( បម្រើការងារ ) នាំឲ្យលំបាក បុគ្គលនេះឈ្មោះថា ជាអ្នកជាប់ជំពាក់ក្នុងសត្វ ។

ចំណែកបុគ្គលណាប្រកាន់បាត្រ ចីវរ បំពង់ម្ជុល និងឈើច្រត់ជាដើមថា ជារបស់យើង មិនព្រមឲ្យអ្នកដទៃ ដោយហោចទៅសូម្បីនឹងយកដៃប៉ះ លុះត្រូវសូមខ្ចីក៏និយាយថា ពួកយើងទាំងឡាយស្រឡាញ់របស់នេះ មិនហ៊ានប្រើប្រាស់ផង ពួកយើងនឹងឲ្យពួកលោកបានដូចម្តេច បុគ្គលនេះឈ្មោះថា អ្នកជាប់ជំពាក់ក្នុងសង្ខារ ។

ចំណែកបុគ្គលណា ជាអ្នកមានខ្លួនជាកណ្តាល ព្រងើយកន្តើយក្នុងវត្ថុទាំង ២ នោះ បុគ្គលនោះ ឈ្មោះថា ដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ ។

ឧបេក្ខាសម្ពោជ្ឈង្គៈនេះ រមែងកើតឡើងដល់ព្រះយោគាវចរ ដែល

ចៀសវាងឲ្យឆ្ងាយពីបុគ្គលអ្នកជាប់ជំពាក់ក្នុងសត្វ និងសង្ខារបែបនេះខ្លះ អ្នកគប់រកបុគ្គលដែលដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារខ្លះ អ្នកមានចិត្តបង្អោនទៅដើម្បីឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គៈនោះ ក្នុងឥរិយាបថទាំងឡាយ មានឈរ និងអង្គុយជាដើមខ្លះ ដូចពណ៌នាមកដូច្នេះ ។

កាលឧបេក្ខាសម្ពោជ្ឈង្គៈនោះ កើតឡើងយ៉ាងនោះ ព្រះយោគាវចរ រមែងជ្រាបច្បាស់ថា ការចម្រើនបរិបូណ៌ ( នៃឧបេក្ខាសម្ពោជ្ឈង្គៈ ) មានបានដោយអរហត្តមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរនោះ កំណត់ពោជ្ឈង្គៈ ៧ របស់ខ្លួន ឬរបស់បុគ្គលដទៃយ៉ាងនេះហើយ គឺ កំណត់ពោជ្ឈង្គៈរបស់ខ្លួនតាមកាល ឬពោជ្ឈង្គៈរបស់បុគ្គលដទៃតាមកាល ជាអ្នកមានប្រក្រតីពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយយ៉ាងនេះ ។ ចំណែកការកើតឡើង និងការរលត់ទៅក្នុងពោជ្ឈង្គបព្វៈនេះ គប្បីជ្រាបដោយអំណាចការកើត និងការរលត់នៃសម្ពោជ្ឈង្គៈទាំងឡាយ , ពាក្យដទៃអំពីនេះ មានន័យដូចពោលហើយ ។

## អរិយសច្ចក្នុងពោជ្ឈង្គ

សេចក្តីថា ក្នុងពោជ្ឈង្គបព្វៈនេះ សតិដែលកំណត់ពោជ្ឈង្គៈ ជាទុក្ខសច្ចៈតែម្យ៉ាង អ្នកសិក្សាគប្បីជ្រាបផ្លូវនៃធម៌ជាគ្រឿងចេញចាករបស់ភិក្ខុអ្នកកំណត់ពោជ្ឈង្គៈ ព្រោះការប្រកបសេចក្តី ដូចពោលមកនេះឯង ។

ពាក្យដ៏សេសមានន័យ ( ដូចដែលពោលមកហើយ ) នោះ ដូចគ្នា ។

( ចប់ ពោជ្ឈង្គបព្វៈ )

## សច្ចបព្វៈ

លុះទ្រង់ចែកធម្មានុបស្សនា ដោយអំណាចពោជ្ឈង្គៈ ៧ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយអំណាចសច្ចៈ ៤ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ពាក្យថា **បុន ចបរំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ** សេចក្ដីថា ព្រះយោគាវចរ រមែងជ្រាបច្បាស់នូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ វៀរតែតណ្ហា តាមសេចក្ដីពិតថា នេះទុក្ខ ( ក៏រមែងជ្រាបច្បាស់តណ្ហាអំពីអតីត ដែលជាតួហេតុឲ្យទុក្ខនោះឯងកើត គឺ តាំងឡើងតាមសេចក្ដីពិតថា នេះទុក្ខសមុទយៈ រមែងជ្រាបច្បាស់នូវព្រះនិព្វាន គឺ ការមិនប្រព្រឹត្តទៅនៃទុក្ខ និងតណ្ហាទាំងពីរ តាមសេចក្ដីពិតថា នេះទុក្ខនិរោធ រមែងជ្រាបច្បាស់នូវអរិយមគ្គ ដែលជាតួកំណត់ដឹងទុក្ខ លះបង់សមុទយៈ ធ្វើនិរោធឲ្យជាក់ច្បាស់ តាមសេចក្ដីពិតថា នេះទុក្ខនិរោធគាមិនីបដិបទា ។ កថាពោលដោយអរិយសច្ចដ៏សេស បានអធិប្បាយឲ្យពិស្ដារហើយក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរកំណត់សច្ចៈ ៤ របស់ខ្លួន ឬរបស់អ្នកដទៃហើយ គឺ កំណត់សច្ចៈទាំង ៤ របស់ខ្លួនតាមកាល ឬរបស់អ្នកដទៃតាមកាល ជាអ្នកមានប្រក្រតីពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ចំណែកការកើតឡើង និងការរលត់ទៅក្នុងចតុសច្ចបព្វៈនេះ គប្បីជ្រាប ដោយអំណាចការកើត និងការរលត់របស់សច្ចៈទាំង ៤

តាមសេចក្តីពិត ។ ពាក្យដទៃក្រៅពីនេះ មានន័យដូចពោលហើយនោះឯង ។

## អរិយសច្ច ក្នុងអរិយសច្ច

សេចក្តីថា ក្នុងចតុសច្ចបព្វៈនេះ សតិគ្រឿងកំណត់សច្ចៈ ៤ ជាទុក្ខសច្ចៈតែម្យ៉ាង បណ្ឌិតគប្បីជ្រាប ផ្លូវនៃធម៌ជាគ្រឿងនាំចេញរបស់ភិក្ខុអ្នកកំណត់សច្ចៈ ព្រោះការប្រកបសេចក្តីដូចពោលមកនេះឯង ។ ពាក្យដ៏សេស ដូច ( ពាក្យដែលពោលមកហើយ ) នោះឯង ។

( ចប់ ចតុសច្ចបព្វៈ )

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់កម្មដ្ឋានទុក ២១ យ៉ាង គឺ **អានាបានៈ** ( ដង្ហើមចេញចូល ) ១ **ចតុឥរិយាបថៈ** ( ឥរិយាបថ ៤ ) ១ **ចតុសម្បជញ្ញៈ** ( សម្បជញ្ញៈ ៤ ) ១ **ទ្វត្តឹសាការ** ( អាការ ៣២ ) ១ **ចតុធាតុវវដ្ឋាន** ( ការកំណត់ធាតុ ៤ ) ១ **នវសីវថិកា** ( ព្រៃស្មសាន ៩ ) ១ **វេទនានុបស្សនា** ( ការកំណត់វេទនា ) ១ **ចិត្តានុបស្សនា** ( ការពិចារណាឃើញចិត្ត ) ១ **នីវរណបរិគ្គហៈ** ( ការកំណត់នីវរណៈ ) ១ **ខន្ធបរិគ្គហៈ** ( ការកំណត់ខន្ធ ) ១ **អាយតនបរិគ្គហៈ** ( ការកំណត់អាយតនៈ ) ១ **ពោជ្ឈង្គបរិគ្គហៈ** ( ការកំណត់ពោជ្ឈង្គៈ ) ១ **សច្ចបរិគ្គហៈ** ( ការកំណត់សច្ចៈ ) ១ ។

*បណ្តាកម្មដ្ឋាន ២១ យ៉ាងនោះ អានាបានៈ ១ ទ្វត្តឹសាការៈ ១ នវសីវថិកា ( ព្រៃស្មសាន ៩ ) ១ រួមជាកម្មដ្ឋាន ដែលឲ្យដល់អប្បនា ១១ ។*

*ចំណែក **ព្រះមហាសិវត្ថេរ** អ្នកពោលគម្ពីរទីឃនិកាយ ពោលថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់នវសីវថិកាទុក ដោយអំណាចការពិចារណាឃើញទោស ។ ព្រោះហេតុដូច្នោះ តាមមតិរបស់ព្រះមហាសិវត្ថេរនោះ កម្មដ្ឋាន ២ ( គឺ **អានាបាន** និង **ទ្វត្តឹសាការ** ) ប៉ុណ្ណោះ ជាកម្មដ្ឋានដែលឲ្យដល់អប្បនា កម្មដ្ឋានដ៏សេស ជាកម្មដ្ឋានដែលឲ្យដល់ឧបចារៈ ។*

*សួរថា ក៏ការប្រកាន់មាំ នឹងកើតក្នុងកម្មដ្ឋានទាំងអស់នោះឬ ?*

*ឆ្លើយថា មិនកើត ព្រោះថា ការប្រកាន់មាំ រមែងមិនកើតក្នុងឥរិយាបថៈ សម្បជញ្ញៈ នីវរណៈ និងសម្ពោជ្ឈង្គៈ តែនឹងកើតក្នុងកម្មដ្ឋានដ៏សេស ។*

*ចំណែក **ព្រះមហាសិវត្ថេរ** ពោលថា រមែងកើតការប្រកាន់មាំក្នុងកម្មដ្ឋានសូម្បីទាំងនោះ ( មានឥរិយាបថជាដើម ) ព្រោះថា ព្រះយោគាវចរនេះ រមែងកំណត់យ៉ាងនោះថា ឥរិយាបថ ៤ របស់យើងមាន ឬមិនមាន , សម្បជញ្ញៈ ៤ របស់យើងមាន ឬមិនមាន , នីវរណៈ ៥ របស់យើងមាន ឬមិនមាន , ពោជ្ឈង្គៈ ៧ របស់យើងមាន ឬមិនមាន ព្រោះហេតុដូច្នោះ ទើបកើតការប្រកាន់មាំក្នុងកម្មដ្ឋានគ្រប់ប្រការ ។*

## អានិសង្សនៃការចម្រើនសតិប្បដ្ឋាន

បទថា **យោ ហិ កោចិ ភិក្ខវេ** សេចក្តីថា បុគ្គលណាទីមួយនឹងជាភិក្ខុ ឬភិក្ខុនី ឧបាសក ឬឧបាសិកាក៏ដោយ ។

បទថា **ឯវំ ភាវេយ្យ** សេចក្តីថា គប្បីចម្រើន ( សតិប្បដ្ឋាន ) ទៅតាមលំដាប់នៃការនា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកតាំងពីដំបូង ។

បទថា **បាដិកង្ខំ** ប្រែថា គប្បីសង្ឃឹម ។ អធិប្បាយថា មានពិតប្រាកដ ។

បទថា **អញ្ញា** បានដល់ ព្រះអរហត្តផល ។

បទថា **សតិ វា ឧបាទិសេសេ** សេចក្តីថា ឬកាលនៅមានឧបាទានសល់ គឺ នៅមិនទាន់អស់ទៅ ។

បទថា **អនាគាមិតា** បានដល់ ភាពជាព្រះអនាគាមី ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងនូវការដែលសាសនធម៌ជាគ្រឿងនាំចេញដោយអំណាច ( រយៈវេលា ) ៧ ឆ្នាំ យ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងរយៈដ៏ខ្លីជាងនោះទៅទៀត ទើបត្រាស់ថា **តិដ្ឋន្តុ ភិក្ខវេ** ដូច្នេះជាដើម ហើយធម៌ទាំងអស់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុក ដោយអំណាចវេនេយ្យបុគ្គល អ្នក (មានសតិបញ្ញា) មធ្យមប៉ុណ្ណោះ ។ ចំណែកព្រះបុរាណាចារ្យ សំដៅយកបុគ្គលអ្នកមានបញ្ញាចាស់ក្លា ទើបពោលទុកថា ៖

បុគ្គលអ្នកមានបញ្ញាចាស់ក្លា បានទទួលពាក្យប្រៀនប្រដៅ
ក្នុងពេលព្រឹក ក៏នឹងសម្រេចគុណវិសេសបានក្នុងពេលល្ងាច
បានទទួលព្រះធម្មទេសនាក្នុងពេលល្ងាច ក៏នឹងសម្រេចគុណ
វិសេសបានក្នុងពេលព្រឹក ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ សាសនធម៌របស់តថាគត ជាធម៌គ្រឿងនាំចេញយ៉ាងនេះ ដូចពណ៌នាមក ដូច្នេះហើយ កាលនឹងទ្រង់រៀបចំព្រះធម៌ទេសនា ដែលព្រះអង្គទ្រង់សម្តែងហើយ ឲ្យដល់កំពូល គឺ ព្រះអរហត្ត ក្នុងឋានៈសូម្បី ២១ យ៉ាង ដល់ព្រះសាវក ទើបទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវឯក ។បេ។ ព្រោះអាស្រ័យពាក្យដែលពោលទុកហើយយ៉ាងនេះ តថាគតទើបសម្តែងសតិប្បដ្ឋានសូត្រនេះទុក ។ ពាក្យដ៏សេស មានសេចក្តីងាយស្រួលទាំងអស់នោះឯង ៕

ចប់ អដ្ឋកថាសតិប្បដ្ឋានសូត្រ ទី ១០
នៃមូលបរិយាយវគ្គ

# អដ្ឋកថា

## ចុល្លសីហនាទសូត្រ ទី ១

### វណ្ណនាសីហនាទវគ្គ

[១៥៣] ចុល្លសីហនាទសូត្រ មានពាក្យផ្ដើមថា ខ្ញុំម្ចាស់បានស្ដាប់មកយ៉ាងនេះ ៖

ក៏ព្រោះចុល្លសីហនាទសូត្រនោះ មានការសរុបដល់ការកើតឡើងនៃរឿង ព្រោះដូច្នោះ ខ្ញុំម្ចាស់សម្ដែងការសរុបនោះហើយ នឹងធ្វើការពណ៌នាបទដោយ មិនតាមលំដាប់នៃចុល្លសីហនាទនោះ ក៏រឿងនេះបានលើកឡើងពោលក្នុងការកើតឡើងនៃរឿងអ្វី ក្នុងរឿងតិរ្ថិយចំបែង ព្រោះលាភសក្ការៈជាបច្ច័យ បានឮថា លាភសក្ការៈធំបានកើតឡើងហើយដល់ព្រះមានព្រះ-ភាគជាម្ចាស់ ដូចន័យដែលពោលហើយក្នុងធម្មទាយាទសូត្រ ។

ក៏លោកសន្និវាសនេះ មានប្រមាណ ៤ តាំងនៅហើយ ដោយ ៤ យ៉ាង ដោយអំណាចនៃបុគ្គលទាំងនេះ គឺ បុគ្គលមានប្រមាណក្នុងរូប ជ្រះថ្លាក្នុងរូប , មានប្រមាណក្នុងសំឡេង ជ្រះថ្លាក្នុងសំឡេង , មានប្រមាណក្នុងសេចក្ដីសៅហ្មង ជ្រះថ្លាក្នុងសេចក្ដីសៅហ្មង , មានប្រមាណក្នុងធម៌ ជ្រះថ្លាក្នុងធម៌ ។ សូម្បីធ្វើឲ្យផ្សេងគ្នារបស់បុគ្គលទាំងនោះ ដូច្នេះ ។ បុគ្គលដែលមានប្រមាណក្នុងរូប ជ្រះថ្លាក្នុងរូប យ៉ាងណា បុគ្គលខ្លះក្នុង លោកនេះ

ឃើញសេចក្តីចម្រើន ឬឃើញសេចក្តីចម្រើនពេញលេញ ឃើញសេចក្តីបរិបូណ៌ ឬឃើញសណ្ឋានរូបរាង កាន់ប្រមាណក្នុងរូបនោះហើយ ញុំាងសេចក្តីជ្រះថ្លាឲ្យកើតឡើង នេះហៅថា បុគ្គលអ្នកមានប្រមាណក្នុងរូបជ្រះថ្លាក្នុងរូប ។

ក៏បុគ្គលអ្នកមានប្រមាណក្នុងសំឡេង ជ្រះថ្លាក្នុងសំឡេង យ៉ាងណា បុគ្គលពួកខ្លះក្នុងលោកនេះ កាន់ប្រមាណក្នុងសំឡេងនោះ ដោយការពណ៌នារបស់អ្នកដទៃ ដោយការលើកសរសើររបស់អ្នកដទៃ ដោយការសរសើររបស់អ្នកដទៃ ដោយអ្នកនាំគុណរបស់អ្នកដទៃ ហើយញុំាងសេចក្តីជ្រះថ្លាឲ្យកើតឡើង នេះហៅថា អ្នកមានប្រមាណក្នុងសំឡេង ជ្រះថ្លាក្នុងសំឡេង ។ ក៏បុគ្គលអ្នកមានប្រមាណក្នុងសេចក្តីសៅហ្មង ជ្រះថ្លាក្នុងសេចក្តីសៅហ្មង យ៉ាងណា បុគ្គលពួកខ្លះក្នុងលោកនេះ ឃើញសេចក្តីសៅហ្មងក្នុងចីវរ ឬឃើញសេចក្តីសៅហ្មង ក្នុងបាត្រ ឬឃើញសេចក្តីសៅហ្មងក្នុងសេនាសនៈ ឬឃើញការបំពេញទុក្ករកិរិយាផ្សេង ៗ ហើយគឺ ប្រមាណក្នុងសេចក្តីសៅហ្មងនោះ ញុំាងសេចក្តីជ្រះថ្លាឲ្យកើតឡើង នេះហៅថា បុគ្គលអ្នកមានប្រមាណក្នុងសេចក្តីសៅហ្មង ជ្រះថ្លាក្នុងសេចក្តីសៅហ្មង ។ ក៏បុគ្គលអ្នកមានប្រមាណក្នុងធម៌ ជ្រះថ្លាក្នុងធម៌ យ៉ាងណា បុគ្គលពួកខ្លះក្នុងលោកនេះ ឃើញសីល ឬឃើញសមាធិ ឬឃើញបញ្ញា ហើយ គឺ ប្រមាណក្នុងធម៌នោះ ញុំាងសេចក្តីជ្រះថ្លាឲ្យកើតឡើង នេះហៅថា បុគ្គលអ្នកមានប្រមាណក្នុងធម៌ ជ្រះថ្លាក្នុងធម៌ ។

ក្នុងបុគ្គល ៤ ពួកនេះ ចំណែកបុគ្គលមានប្រមាណក្នុងរូប មានសេចក្ដីចម្រើនឡើង និងសេចក្ដីចម្រើនពេញលេញនៃសណ្ឋានរូបកាយ ការបរិបូណ៌របស់ព្រះមានព្រះភាគជាម្ចាស់ ទ្រង់មានព្រះឆវីវណ្ណស្រស់ល្អ ដូចវិចិត្រដោយរតនៈផ្សេង ៗ ព្រោះប្រដាប់ដោយអនុព្យញ្ជនៈ ៨០ យ៉ាង ដូចផ្ទាំងធំនៃមាស ដែលរុងរឿងដោយពពួកផ្កាយ និងប្រកបព្រមដោយមហាបុរិសលក្ខណៈ ៣២ ប្រការ និងដូចផ្ទៃមេឃដែលភ្លឺស្រឡះ ដូច្នោះ មានព្រះសរីរៈប្រៀបផ្ទឹមពុំបាន មានបារិច្ឆត្តកម្ពស់រយយោជន៍ មានព្រះសរីរៈហែហមដោយរស្មីប្រមាណ ១ ព្យាម កម្ពស់ ១៨ ហត្ថ ហើយជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះតែម្ដង ។

ចំណែកបុគ្គល មានប្រមាណក្នុងសំឡេង បានស្ដាប់សំឡេងដែលប្រព្រឹត្តទៅហើយនៃព្រះមានព្រះភាគជាម្ចាស់ ដោយន័យជាដើមថា រហូត ៤ អសង្ខេយ្យ ក្រៃលែងដោយសែនកប្ប ព្រះអង្គទ្រង់បំពេញបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ទ្រង់ធ្វើអង្គបរិច្ចាគ បុត្តទារបរិច្ចាគ រជ្ជបរិច្ចាគ ធនបរិច្ចាគ និងនយនបរិច្ចាគ ហើយជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធជាម្ចាស់តែម្យ៉ាង ។

ចំណែកបុគ្គល មានប្រមាណក្នុងសេចក្ដីសៅហ្មង ឃើញសេចក្ដីសៅហ្មងក្នុងចីវររបស់ព្រះមានភាគជាម្ចាស់ហើយ គិតថា បើព្រះមានព្រះភាគជាម្ចាស់ នៅគ្រប់គ្រងសម្បត្តិ ក៏នឹងស្លៀកដណ្ដប់តែសំពត់ដែលធ្វើអំពីក្រុងកាសីប៉ុណ្ណោះ តែព្រះអង្គកាលទ្រង់ផ្នួសហើយ ទ្រង់រីករាយដោយ

ចីវរបង្សុកូល ដែលធ្វើដោយសំបកឈើ ទ្រង់ធ្វើការងារធ្ងន់ ដូច្នេះ រមែងជ្រះថ្លាក្នុងព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គនេះ កាលទ្រង់នៅគ្រប់គ្រងផ្ទះ បានសោយភោជនបាយសាលី ដែលមានក្លិនក្រអូបសមគួរដល់ភោជនរបស់ព្រះចៅចក្រពត្តិ ក្នុងភាជន៍មាសដ៏ប្រសើរ ពណ៌ក្រហម តែកាលបើទ្រង់ផ្នួសហើយ ទ្រង់កាន់បាត្រថ្ម ស្តេចបិណ្ឌបាត តាមប្រកនៃទ្វារត្រកូលខ្ពស់ ទ្រង់ត្រេកអរដោយដុំបាយដែលបានហើយ ទ្រង់ធ្វើកិច្ចដ៏ធ្ងន់ ដូច្នេះ រមែងជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធនោះឯង ។ សូម្បីបានឃើញភាពសៅហ្មងក្នុងសេនាសនៈ ក៏គិតថា ព្រះមានព្រះភាគអង្គនេះ កាលទ្រង់នៅគ្រប់គ្រងផ្ទះ មានស្រីរបាំ ៣ ពួក ជាបរិវារ សោយរាជ្យសិរីដូចសម្បត្តិទិព្វក្នុងប្រាសាទ ទាំង ៣ ដ៏សមគួរដល់រដូវទាំង ៣ ឥឡូវនេះ ទ្រង់ផ្នួសហើយ ទ្រង់ត្រេកអរដោយវត្ថុ មានក្តារឈើ ផ្ទាំងសិលា និងគ្រែ ឫស្សីជាដើម ក្នុងរុក្ខមូលនោះ និងសេនាសនៈជាដើម ទ្រង់ធ្វើការធ្ងន់ ដូច្នេះ រមែងជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធនោះ ។ សូម្បីបានឃើញ សេចក្តីបំពេញទុក្ករកិរិយារបស់ព្រះមានព្រះភាគអង្គនោះ ហើយគិតថា ព្រះមានព្រះភាគទ្រង់ញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយវត្ថុ មានទឹកស្ងោរសណ្តែកខៀវ ទឹកស្ងោរសណ្តែកក្ដួប និងទឹកស្ងោរហារេណុជាដើម ត្រឹមតែមួយទូកដៃ ហើយចម្រើនឈានដែលមិនមានប្រមាណ ទ្រង់មិនហួងហែងសរីរៈ និងជីវិត រហូត ៦ ឆ្នាំ ឱហ្ន៎ ! ព្រះមានព្រះភាគ ទ្រង់ធ្វើកិច្ចដែលធ្វើបានដោយលំបាក ដូច្នេះ រមែងជ្រះថ្លាក្នុងព្រះសម្មាសម្ពុទ្ធ នោះតែម្តង ។

ចំណែកបុគ្គលមានប្រមាណក្នុងធម៌ ឃើញសីលគុណ សមាធិគុណ បញ្ញាគុណ ឈានវិមោក្ខ សមាធិសម្បត្តិ សម្បទា ការបរិបូណ៌នៃអភិញ្ញា យមកប្បាដិហារិយៈ ទេវោរោហនៈ និងភាពអស្ចារ្យច្រើនប្រការ មានការទូន្មានបាដិកបុត្តជាដើមរបស់ព្រះមានព្រះភាគហើយ រមែងជ្រះថ្លានឹងព្រះសម្មាសម្ពុទ្ធនោះតែម្យ៉ាង ។

បុគ្គលទាំងនោះ ជ្រះថ្លាយ៉ាងនេះហើយ រមែងនាំលាភសក្ការៈជាច្រើន ថ្វាយដល់ព្រះមានព្រះភាគ តែលាភសក្ការៈរបស់តិរ្ថិយ៍ទាំងឡាយក៏ថយចុះទៅ ដូចក្អែកក្នុងពាវេរុជាតក ដូចលោកពោលថា ៖

*ជនទាំងឡាយបានយកសាច់ និងផ្លែឈើ បូជាក្អែកក្នុងដែននោះ ព្រោះមិនទាន់បានឃើញសត្វក្ងោកជាសត្វ មានសិរ្យ៍ មានសំឡេងពីរោះ ។ ក្ងោកជាសត្វបរិបូណ៌ដោយសំឡេងពីរោះ បានមកដល់ដែនពាវេរុក្នុងកាលណា លាភ និងសក្ការៈរបស់ក្អែក ក៏សាបសូន្យក្នុងកាលនោះ ។*

*ព្រះពុទ្ធជាធម្មរាជ ទ្រង់ធ្វើនូវពន្លឺមិនទាន់កើតឡើងដរាបណាពួកជនឯទៀត បានបូជាសមណព្រាហ្មណ៍ដ៏ច្រើនដរាបនោះ ។*

ព្រះពុទ្ធជាម្ចាស់ ព្រះអង្គបរិបូណ៌ដោយសំឡេង បានសម្តែងព្រះធម៌ក្នុងកាលណា លាភ និងសក្ការៈរបស់តិរ្ថិយ៍ទាំងឡាយ ក៏សាបសូន្យអស់ក្នុងកាលនោះ តិរ្ថិយ៍ទាំងនោះ សាបសូន្យចាកលាភ និងសក្ការៈយ៉ាងនេះ

ហើយសូម្បីទឹកញាំង រាត្រីឲ្យភ្លឺត្រឹមតែម្រាមដៃមួយ ម្រាមដៃពីរ ក៏ជាអ្នកសាបសូន្យចាករស្មី ដូចសត្វអំពិលអំពែកទាំងឡាយក្នុងវេលាព្រះអាទិត្យរះឡើង ដូច្នោះ ។ អំពិលអំពែកទាំងឡាយ រមែងសម្តែងចេញនូវពន្លឺក្នុងរាត្រីខែរនោចនោះ ជាវិស័យរបស់សត្វអំពិលអំពែកទាំងនោះ ក្នុងវេលាព្រះអាទិត្យដែលដល់ព្រមដោយរស្មីកើតមាន ក្នុងពេលណា ពន្លឺរបស់ហ្វូងអំពិលអំពែកទាំងឡាយ ក៏បាត់ទៅពេលនោះ សូម្បីតិរ្ថិយ៍ទាំងឡាយក្នុងលោកនេះ ភាគច្រើនក៏ដូចគ្នានឹងអំពិលអំពែកដូច្នោះ រមែងសម្តែងគុណក្នុងលោក ដែលប្រៀបដូចខែរនោច តែក្នុងវេលាណាព្រះពុទ្ធអង្គ មានរស្មីរកអ្វីប្រៀបពុំបាន បានឧប្បត្តិឡើងក្នុងលោក ក្នុងវេលានោះ តិរ្ថិយ៍ទាំងឡាយក៏អស់រស្មី ដូចជាអំពិលអំពែកទាំងឡាយក្នុងពេលព្រះអាទិត្យរះឡើង ដូច្នោះ ។ តិរ្ថិយ៍ទាំងនោះ ជាអ្នកប្រាសចាករស្មីយ៉ាងនេះ សរីរៈពោរពេញទៅដោយរមាស់ និងពងតូច ៗ ជាដើម ដល់ការសាបសូន្យយ៉ាងក្រៃលែង ទៅរកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងទីប្រជុំនៃមហាជន ហើយឈរត្រួញត្រែរក្នុងរវាងផ្លូវខ្វះ តាមច្រកខ្វះ ក្នុងផ្លូវបែកជាបួនខ្វះ ក្នុងទីប្រជុំជនខ្វះ ស្រែកដោយប្រការផ្សេង ៗ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សមណគោតមប៉ុណ្ណោះឬ ជាសមណៈ ពួកយើងមិនមែនជាសមណៈទេឬ សាវករបស់ព្រះសមណគោតមប៉ុណ្ណោះឬ ជាសមណៈ សូម្បីសាវកពួកយើង មិនមែនជាសមណៈទេឬ ទានដែលឲ្យសមណគោតម និងសាវករបស់សមណគោតមប៉ុណ្ណោះឬ ដែលមានផលច្រើន ទានដែលឲ្យដល់ពួក

យើងមិនមានផលច្រើនឬ សមណគោតមក៏ជាសមណៈដែរ ពួកយើងក៏ជាសមណៈដែរ សាវ័ករបស់សមណគោតម ក៏ជាសមណៈ សាវ័ករបស់ពួកយើងក៏ជាសមណៈដែរ ទានដែលឲ្យសមណគោតម និងដល់សាវ័ករបស់សមណគោតមនោះ ក៏មានផលច្រើនដែរ ទានដែលឲ្យដល់ពួកយើង និងដល់សាវ័ករបស់ពួកយើងក៏មានផលច្រើនដែរ មិនមែនឬ អ្នកទាំងឡាយចូរឲ្យ ចូរធ្វើដល់សមណគោតម និងដល់សាវ័ករបស់សមណគោតមនោះផង ចូរឲ្យចូរធ្វើដល់ពួកយើង និងដល់សាវ័ករបស់ពួកយើងផង សមណ-គោតមឧប្បត្តិហើយអស់ថ្ងៃមុនៗ មិនមែនឬ តែពួកយើងកាលកើតឡើងក្នុងលោក ក៏បានកើតហើយយ៉ាងនេះ លំដាប់នោះបរិស័ទបួន គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា បានស្តាប់សម្តីរបស់តិរ្ថិយ៍ទាំងនោះហើយ ក្រាបទូលដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន តិរ្ថិយ៍ទាំងឡាយពោលពាក្យនេះ និងពាក្យនេះ យ៉ាងនេះ ព្រះមានព្រះភាគសណ្តាប់ពាក្យនេះហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំសម្គាល់ថា សមណៈមានក្នុងទីដទៃតាមពាក្យពួកតិរ្ថិយ៍ កាលទ្រង់បដិសេធភាពជាសមណៈក្នុងអន្យតិរ្ថិយ៍ទាំងឡាយហើយ កាលនឹងទ្រង់អនុញ្ញាតភាពជាសមណៈ ក្នុងសាសនានេះប៉ុណ្ណោះ ទើបទ្រង់ត្រាស់ព្រះសូត្រដល់ការកើតឡើងនៃរឿងនេះ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សមណៈមាននៅតែក្នុងសាសនានេះប៉ុណ្ណោះ ។

[១៥៤] ក្នុងបទនោះ បទថា ***ឥធេវ*** គឺ ក្នុងសាសនានេះប៉ុណ្ណោះ ។

ក៏ការកំណត់នេះ គប្បីជ្រាបសូម្បីក្នុងបទដ៏សេស ។ ក៏សមណៈទាំងឡាយ សូម្បីមានសមណៈ ទី ២ ជាដើម ក៏មានក្នុងសាសនានេះប៉ុណ្ណោះ មិនមានក្នុងទីដទៃ ។ បទថា សមណោ បានដល់ ព្រះសោតាបន្ន ។ ដោយហេតុ នោះឯង ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏សមណៈដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះអស់ទៅនៃសំយោជនៈ ៣ ជាសោតាបន្នៈ មានការមិនធ្លាក់ចុះជាធម្មតា ជាអ្នកទៀងមានការត្រាស់ដឹងជាខាងមុខ ម្នាលភិក្ខុទាំងឡាយ នេះជាសមណៈទី ១ ។ ព្រះសកទាគាមី ឈ្មោះថា ជាសមណៈទី ២ ដោយហេតុនោះហើយ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏សមណៈទី ២ ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាសកទាគាមី ព្រោះសំយោជនៈ ៣ អស់ទៅ ព្រោះការដែលរាគៈ ទោសៈ និងមោហៈ ស្រាលស្តើង ត្រឡប់មកកាន់លោកនេះតែម្តងប៉ុណ្ណោះ ។ ក៏នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ម្នាលភិក្ខុទាំងឡាយ នេះជាសមណៈ ទី ២ ។ ព្រះអនាគាមី ឈ្មោះថា សមណៈទី ៣ ដោយហេតុនោះឯង ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏សមណៈទី ៣ ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះការអស់ទៅនៃសំយោជនៈ ខាងក្រោម ៥ ជាឱបបាតិកៈ បរិនិព្វានក្នុងភពនោះ មិនវិលត្រឡប់មកលោកនេះ ម្នាលភិក្ខុទាំងឡាយ នេះជាសមណៈ ទី ៣ ។ ព្រះអរហន្ត ឈ្មោះថា សមណៈទី ៤ ដោយហេតុនោះឯង ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង

ឡាយ ក៏សមណៈទី ៤ ដូចម្តេច ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលរកអាសវៈមិនមាន ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ ដោយអភិញ្ញារបស់ខ្លួនឯងនៅក្នុងទិដ្ឋធម៌ ម្នាលភិក្ខុទាំងឡាយ នេះជាសមណៈ ទី ៤ ។ លោកបំណងយកសមណៈ ដែលតាំងនៅក្នុងផល ៤ ក្នុងទីនេះ ដោយប្រការដូច្នេះ ។ បទថា **សុញ្ញា** បានដល់ សូន្យ ។ បទថា **បរប្បវាទា** សេចក្តីថា វាទៈថាទៀង ៤ , វាទៈថាទៀងដោយចំណែកខ្លះ ៤ , វាទៈថាមានទីបំផុត និងមិនមានទីបំផុត ៤ , វាទៈដែលហាមការមិនស្លាប់ ៤ , វាទៈកើតឡើងចំពោះ ២ , សញ្ញីវាទ ១៦ , អសញ្ញីវាទ ៨ , នេវសញ្ញីនាសញ្ញីវាទ ៨ , ឧច្ឆេទវាទ ៧ , ទិដ្ឋធម្មនិព្វានវាទ ៥ , សូម្បីទាំងអស់ដូចពោលមកនេះ មានហើយក្នុងព្រហ្មជាលសូត្រ វាទៈរបស់ពួកក្រៅដទៃពីនេះ ៦២ ឈ្មោះថា បរប្បវាទៈ វាទៈនោះ សូម្បីទាំងអស់សាបសូន្យចាកសមណៈ អ្នកតាំងនៅក្នុងផល ៤ នេះ ដូច្នេះ ។ ក៏វាទៈទាំងនេះ មិនមានក្នុងសមណៈនោះ ។ ក៏វាទៈទាំងឡាយនោះ មានតែម្យ៉ាងក៏ទេ តែសូន្យចាកសមណៈទាំងនោះ ។ ម្យ៉ាងទៀត សូន្យចាកសមណៈសូម្បី ១២ នោះ គឺ ចាកសមណៈ ដែលតាំងនៅក្នុងមគ្គ ៤ ខ្លះ ចាកសមណៈជាវិបស្សកៈ ដែលប្រារព្ធដើម្បីប្រយោជន៍ដល់មគ្គ ៤ ខ្លះ ។

ព្រះមានព្រះភាគ ទ្រង់សំដៅដល់សេចក្តីនោះឯង ទើបទ្រង់ត្រាស់ទុកក្នុងមហាបរិនិព្វានសូត្រថា ៖

*ម្នាលសុភទ្ទៈ តថាគតមានវ័យបាន ២៩ ឆ្នាំ បួសហើយ តាមស្វែងរកអ្វីជាកុសល ម្នាលសុភទ្ទៈ តាំងពីតថាគត បួសហើយបាន ៥០ ឆ្នាំសេស សូម្បីសមណៈដែលប្រព្រឹត្ត ទៅក្នុងប្រទេសនៃធម៌ ដែលជាគ្រឿងនាំចេញ មិនមានទៅ ខាងក្រៅធម្មវិន័យនេះទេ ។*

សមណៈសូម្បីទី ២ ក៏មិនមាន សមណៈសូម្បីទី ៤ ក៏មិនមាន លទ្ធិរបស់សាសនាដទៃសាបសូន្យចាកសមណៈ ដែលដឹងទូទៅ ។ ក៏លោក បំណាងយកអ្នកប្រារព្ធវិបស្សនា ។ **បទេសវត្តិ** ក្នុងមហាបរិនិព្វានសូត្រ នោះ ។ ព្រោះដូច្នោះ ។ ព្រះអង្គទ្រង់ធ្វើអ្នកប្រារព្ធវិបស្សនា ដើម្បី សោតាបត្តិមគ្គ ដែលតាំងនៅក្នុងមគ្គ និងផល សូម្បីទាំង ៣ ដូចពោល ចូលជាមួយគ្នា ហើយត្រាស់ថា សូម្បីសមណៈក៏មិនមាន ដូច្នេះ ។ ទ្រង់ ធ្វើអ្នកប្រារព្ធវិបស្សនាដើម្បីសកទាគាមិមគ្គ ដែលតាំងនៅក្នុងមគ្គ ដែល តាំងនៅក្នុងផល សូម្បីទាំង ៣ ដូចពោលចូលជាមួយគ្នា ត្រាស់ថា សូម្បី សមណៈ ទី ២ ក៏មិនមាន ។ ក្នុងបទទាំង ២ នេះ ក៏មានន័យដូចគ្នា ។ ក៏សមណៈទាំងនោះ មិនមានក្នុងលទ្ធិដទៃ ព្រោះហេតុអ្វី ព្រោះលទ្ធិដទៃ នោះ មិនមានព្រំដែន ។ ក៏គ្រាប់ស្ពៃមិនតាំងនៅលើចុងដែកស្រួច ភ្លើង មិនឆេះសន្ធោសន្ធៅនៅលើទឹក ដំណាំទាំងឡាយ មិនដុះនៅលើផែនថ្ម យ៉ាងណា សមណៈទាំងនេះ រមែងមិនកើតក្នុងលទ្ធិតិរ្ថិយ៍ ដូច្នោះដូចគ្នា ។ ក្នុងសាសនានេះប៉ុណ្ណោះ ព្រោះហេតុអ្វី ព្រោះសាសនានេះមានព្រំដែនល្អ ។

ក៏ការដែលតិត្ថិយ៍មិនមានព្រំដែន និងការដែលសាសនានេះ មានព្រំដែន គប្បីជ្រាបដោយការមិនមាន និងការមានអរិយមគ្គ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា ម្នាលសុភទ្ទៈ មគ្គមានអង្គ ៨ ដ៏ប្រសើរ ដែលបុគ្គលមិនបានក្នុងធម្មវិន័យណា សូម្បីសមណៈក៏មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក៏មិនមានក្នុងធម្មវិន័យនោះ ម្នាលសុភទ្ទៈ មគ្គមានអង្គ ៨ ដ៏ប្រសើរ រមែងមានក្នុងធម្មវិន័យណាហើយ សមណៈរមែងមានក្នុងធម្មវិន័យនោះ សូម្បីសមណៈទី ២ ក៏រមែងមានក្នុងធម្មវិន័យនោះ ។ល។ សូម្បីសមណៈទី ៤ ក៏រមែងមានក្នុងធម្មវិន័យនោះ ម្នាលសុភទ្ទៈ មគ្គមានអង្គ ៨ ដ៏ប្រសើរ ក៏រមែងមានក្នុងធម្មវិន័យនោះឯង ម្នាលសុភទ្ទៈ សមណៈមានតែក្នុងសាសនានេះប៉ុណ្ណោះ សមណៈទី ២ ក៏មានក្នុងសាសនានេះ សមណៈទី ៣ ក៏មានក្នុងសាសនានេះ សមណៈ ទី ៤ ក៏មានក្នុងសាសនានេះ លទ្ធិរបស់សាសនាដទៃ សូន្យចាកសមណៈអ្នកដឹងទូទៅ ដូច្នេះ ។ ព្រោះលទ្ធិតិត្ថិយ៍មិនមានព្រំដែន សាសនាមានព្រំដែនយ៉ាងនេះ ព្រោះដូច្នោះ **រាជសីហ៍** មានពន្លឺក្លីស្វាងចិញ្ចាចចិញ្ចែងជាស្តេចម្រឹគ ដែលមានជើងមុខ និងជើងក្រោយក្រហមឆ្អៅ រមែងមិនអាស្រ័យនៅក្នុងព្រៃខ្មោច ឬគំនរសំរាម តែងចូលទៅកាន់ហេមវន្ត ដែលមានទំហំ ៣.០០០ យោជន៍ នៅក្នុងល្អាងកែវមណី យ៉ាងណា ។ ស្តេច**ដំរីឆទ្ទន្ត** រមែងមិនកើតក្នុងត្រកូលដំរី ៩ មានត្រកូលដំរីគោចរិយាជាដើម តែងកើតក្នុងត្រកូលដំរីឆទ្ទន្ត ប៉ុណ្ណោះឯង ។ ស្តេចសេះ **វលាហកៈ** មិន

កើតក្នុងត្រកូលលា ឬក្នុងត្រកូលអូដ្ឋ តែងកើតក្នុងត្រកូល សេះសន្ធពនៅ មាត់ស្ទឹងសិន្ធុប៉ុណ្ណោះឯង យ៉ាងណា ។ មណីរតនៈ ដែលនាំការពេញចិត្ត ឲ្យសម្រេចនូវរបស់ដែលប៉ងប្រាថ្នាគ្រប់យ៉ាង រមែងមិនកើតក្នុងគំនរសំរាម ឬក្នុងភ្នំ មានភ្នំដីជាដើម រមែងកើតក្នុងចន្លោះភ្នំវេបុលបពិតប៉ុណ្ណោះ យ៉ាងណា ។ ស្ដេចត្រី **តិមិរមិង្គលៈ** រមែងមិនកើតក្នុងអណ្ដូង និងស្រះបោ-ក្ខរណីតូច ៗ រមែងកើតក្នុងមហាសមុទ្រដ៏ជ្រៅមាន ៨៤.០០០ យោជន៍ ប៉ុណ្ណោះ យ៉ាងណា ។ ស្ដេចគ្រុឌទំហំ ១៥០ យោជន៍ រមែងមិនអាស្រ័យ ក្នុងព្រៃល្ហុងជាដើម នៅជិតខ្លោងទ្វារស្រុក តែហោះហើរឆ្លងមហាសមុទ្រ ហើយអាស្រ័យនៅក្នុងសិម្ពលិទហវនប៉ុណ្ណោះ យ៉ាងណា ។ ស្ដេចហង្ស **មាសធតរដ្ឋ** មិនអាស្រ័យក្នុងទីទាំងឡាយ មានអណ្ដូងទឹកជាដើម ដែល ជិតខ្លោងទ្វារស្រុក តែមានហង្ស ៩ ម៉ឺន ជាបរិវារ អាស្រ័យនៅក្នុងភ្នំ ចិត្តកូដបពិតប៉ុណ្ណោះ យ៉ាងណា ។ ស្ដេចចក្រពត្តិ ដែលជាធំក្នុងទ្វីបទាំង ៤ រមែងមិនកើតក្នុងត្រកូលថោកទាប រមែងកើតក្នុងត្រកូលសត្វដ៏បរិសុទ្ធ ប៉ុណ្ណោះ យ៉ាងណា ។ ក្នុងសមណៈទាំងនេះ សូម្បីសមណៈតែ ១ ក៏មិន កើតក្នុងលទ្ធិអន្យតិរ្ថិយ៍ តែងកើតក្នុងព្រះពុទ្ធសាសនា ដែលហែហមទៅ ដោយអរិយមគ្គប៉ុណ្ណោះ ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈមានក្នុងសាសនានេះ ប៉ុណ្ណោះ ។ល។ លទ្ធិនៃសាស្ដាដទៃ សូន្យចាកសមណៈទាំងឡាយ ដែល ដឹងទូទៅដូច្នេះ ។ បទថា **សម្មា** ក្នុងបទថា **សម្មា សីហនាទំ នទថ** នោះ

បានដល់ ដោយហេតុ ដោយន័យ ដោយការណ៍ ។ បទថា **សីហនាទំ** គឺ ការបន្លឺដ៏ប្រសើរបំផុត គឺ ការបន្លឺដែលមិនគួរខ្លាច ការបន្លឺដែលមិនគួរស្ញើប ក៏ព្រោះភាពដែលសមណៈ ៤ នេះ មានក្នុងសាសនានេះ ប៉ុណ្ណោះ ការបន្លឺនេះ ជាការបន្លឺដ៏ខ្ពស់បំផុត ឈ្មោះថា ការបន្លឺដ៏ប្រសើរបំផុត ។ ការបន្លឺរបស់ភិក្ខុ ដែលពោលថា សមណៈទាំងនេះ មាននៅក្នុងសាសនានេះប៉ុណ្ណោះ ឈ្មោះថា ការបន្លឺមិនគួរខ្លាច ព្រោះភ័យ ឬការញាប់ញ័រ កោតក្រែងអំពីទីដទៃមិនមាន ។ ការបន្លឺនេះថា សមណៈទាំងនេះ មាននៅក្នុងសាសនាសូម្បីរបស់ពួកយើង ឈ្មោះថា បន្លឺមិនស្ញើប ព្រោះបណ្តាម្ចាស់លទ្ធិទាំងឡាយ មានបូរណៈជាដើម សូម្បីតែម្នាក់ ក៏មិនអាចដើម្បីនឹងក្រោកឡើងពោលបាន ។ ដោយហេតុនោះ លោកទើបពោលថា បទថា **សីហនាទំ** គឺ ការបន្លឺដ៏ប្រសើរជាទីបំផុត គឺ ការបន្លឺដែលមិនគួរខ្លាច ការបន្លឺដែលមិនគួរស្ញើប ដូច្នេះ ។ បទថា **ឋានំ ខោ បនេតំ វិជ្ជតិ** សេចក្តីថា គង់មានហេតុ ជាទំនងយ៉ាងនេះ ។ បទថា **យំ អញ្ញតិត្ថិយា** គឺ ពួកអន្យតិរ្ថិយ៍ ដោយហេតុណា ។ម្យ៉ាងទៀតគប្បីជ្រាប **តិត្ថ** គប្បីជ្រាបតិត្ថករ គប្បីជ្រាបតិរ្ថិយ៍ គប្បីជ្រាបតិត្ថិយសាវកក្នុងទីនេះ ។ ទិដ្ឋិ ៦២ យ៉ាងឈ្មោះថា **តិត្ថ** ។ ក៏សត្វទាំងឡាយរមែងហ្វូង រមែងអណ្តែតទៅ រមែងធ្វើការផុសឡើង មុជចុះក្នុងកំពង់នោះ ព្រោះដូច្នោះ ទើបហៅថា **តិត្ថ** ប្រែថា ជាទីច្រាំងរបស់សត្វទាំងឡាយ ។ ការដែលឲ្យទិដ្ឋិនេះកើតឡើង ឈ្មោះថា **តិត្ថករ** ប្រែថា ម្ចាស់លទ្ធិ ។ អ្នកកាន់លទ្ធិរបស់ម្ចាស់លទ្ធិនោះ ហើយ

បួស ឈ្មោះថា **តិរ្ថិយ៍** ។ អ្នកឲ្យបច្ច័យដល់តិរ្ថិយ៍អស់នោះ គប្បីជ្រាបថា **តិរ្ថិយ៍សាវក** ប្រែថា សាវករបស់តិរ្ថិយ៍ ។ អ្នកដែលលះចំណង់ខាងយកវាស ហើយ ចូលដល់ការបួស ឈ្មោះថា **បរិព្វាជក** ។ ទីពឹង ការតាំងនៅ ការទំនុកបម្រុង ឈ្មោះថា **អស្សាសៈ** ។ កម្លាំងពលំ ឈ្មោះថា **ពលៈ** ។ បទថា **យេន តុម្ហេ** សេចក្តីថា ពួកអ្នកចូរពោលយ៉ាងនេះ ដោយអស្សាសៈ ឬដោយពលៈណា ។ ក្នុងបទនេះថា លោកដ៏មានអាយុទាំងឡាយ ធម៌ ៤ ប្រការ ដែលព្រះមានព្រះភាគអង្គនោះបានដឹង បានឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធត្រាស់ហើយដូច្នេះ មានសេចក្តីសង្ខេបដូច្នេះ ។ ព្រះមានព្រះភាគអង្គនោះ បំពេញបារមី ៣០ កម្ចាត់បង់កិលេសទាំងពួង ត្រាស់ដឹងដោយប្រពៃ នូវសម្មាសម្ពោធិញ្ញាណដ៏កំពូល ព្រះមានព្រះភាគអង្គនោះ ជាអ្នកដឹងអាសយានុសយៈរបស់សត្វទាំងឡាយនោះ ៗ ព្រះអង្គឃើញធម៌ ដែលគួរដឹងទាំងអស់ ដូចផ្លែកន្ទួតព្រៃ ដែលដាក់ទុកលើបាតព្រះហស្ត ដូច្នោះ ។ មួយវិញទៀត ទ្រង់ដឹងដោយញាណទាំងឡាយ មានបុព្វេនិវាសញ្ញាណ ជាដើម ទ្រង់ឃើញដោយទិព្វចក្ខុ ។ មួយវិញទៀត ទ្រង់ដឹងដោយវិជ្ជា ៣ ឬអភិញ្ញា ៦ ទ្រង់ឃើញដោយសមន្តចក្ខុ ដែលមិនទើសទាក់ក្នុងទីទាំងពួង ។ ទ្រង់ដឹងដោយបញ្ញា ដែលអាចនឹងដឹងធម៌ទាំងពួង ទ្រង់ឃើញរូបទាំងឡាយ ដែលកន្លងចក្ខុវិស័យរបស់សត្វទាំងពួង ឬដែលនៅក្នុងកំពែងជាដើម ដោយមំសចក្ខុដ៏បរិសុទ្ធក្រៃលែង ទ្រង់ដឹងដោយបដិវេធបញ្ញា ដែលជាបទដ្ឋាននៃសមាធិ ដែលញុំាងប្រយោជន៍ខ្លួនឲ្យសម្រេច

ទ្រង់ឃើញដោយទេសនាបញ្ញា ដែលជាបទដ្ឋាននៃករុណា ដែលញ៉ាំង ប្រយោជន៍អ្នកដទៃឲ្យសម្រេច ។ ឈ្មោះថា ជាព្រះអរហន្ត ព្រោះកិលេស ដែលជាសឹកសត្រូវទាំងឡាយ ទ្រង់លះបានហើយ និងព្រោះការដែលព្រះអង្គ ជាអ្នកសមគួរដល់បច្ច័យជាដើម ។ ឈ្មោះថា សម្មាសម្ពុទ្ធ ព្រោះសច្ចៈ ទាំងឡាយ ដែលព្រះអង្គត្រាស់ដឹងហើយដោយប្រពៃ និងដោយព្រះអង្គ ឯង ។ ម្យ៉ាងទៀត ទ្រង់ដឹងធម៌ដែលប្រកបដោយអន្តរាយទាំងឡាយ ទ្រង់ ឃើញធម៌ ដែលជាគ្រឿងនាំសត្វចេញចាកទុក្ខទាំងឡាយ ។

ឈ្មោះថា ជាព្រះអរហន្ត ព្រោះការៈដែលជាសត្រូវ គឺ កិលេសទាំង ឡាយ ព្រះអង្គលះបង់បានហើយ ឈ្មោះថា សម្មាសម្ពុទ្ធ ព្រោះការៈនៃ ធម៌ទាំងពួង ព្រះអង្គត្រាស់ដឹងហើយដោយព្រះអង្គឯង ដែលមហាជនបាន សរសើរហើយដោយអាការៈ ៤ , ដោយអំណាចនៃវេសារជ្ជៈ ៤ , បាន ត្រាស់ដឹងធម៌ ៤ ដោយប្រការដូច្នេះ ។ ពួកយើងឃើញធម៌ទាំងនេះ ក្នុង ខ្លួន ចូរពោលយ៉ាងនេះ ចូរកុំពោលដល់ការទំនុកបម្រុងជួយសង្គ្រោះ ឬ កម្លាំងកាយរបស់ព្រះរាជា និងរាជមហាមាត្យជាដើម ។

បទថា **សត្ថរិ បសាទោ** បានដល់ សេចក្តីជ្រះថ្លាដែលកើតឡើង ដល់អ្នករលឹកក្នុងព្រះពុទ្ធគុណ ដោយន័យមានអត្ថថា សូម្បីព្រោះហេតុ នេះ ព្រះមានព្រះភាគអង្គនោះ ។ បទថា **ធម្មេ បសាទោ** បានដល់ សេចក្តីជ្រះថ្លា ដែលកើតឡើងដល់អ្នករលឹកក្នុងព្រះធម្មគុណ ដោយន័យ មានអត្ថថា ព្រះធម៌ ដែលព្រះមានព្រះភាគត្រាស់ទុកល្អហើយ ។ បទថា

***សីលេសុ បរិបូរការិតា*** គឺ ភាពជាអ្នកធ្វើបរិបូរក្នុងសីលទាំងឡាយដែលព្រះអរិយៈសរសើរហើយ ។ សីល ៥ ឈ្មោះថា ***អរិយកន្តសីល*** ពិតណាស់ ព្រះអរិយសាវកសូម្បីនៅក្នុងភវាងកត សូម្បីកាលមិនដឹងខ្លួនជាព្រះអរិយៈ ក៏មិនកន្លងល្មើសសីល ៥ នោះ បើនឹងមានអ្នកណាគប្បីពោលនឹងអរិយសាវកនោះថា សុំឲ្យលោកទទួលយកពជសម្បត្តិ របស់ព្រះចៅចក្រពត្តិទាំងអស់នេះ ហើយចូរសម្លាប់រុយតូច ដូច្នេះ ។ ការដែលព្រះអរិយសាវក នឹងគប្បីធ្វើតាមពាក្យរបស់អ្នកនោះ ៗ មិនជាឋានៈនឹងមានបាន ។ សីលទាំងឡាយជាទីប្រាថ្នា គឺ ជាទីស្រឡាញ់ ជាទីពេញ ចិត្តរបស់ព្រះអរិយៈទាំងឡាយ ដោយប្រការដូច្នេះ ។ ទ្រង់សំដៅដល់សីលទាំងនោះ ទើបត្រាស់ថា ភាពជាអ្នកធ្វើឲ្យបរិបូរក្នុងសីលទាំងឡាយ ទើបត្រាស់ថា ***សហធម្មិកា ខោ បន*** បានដល់ អ្នកមានប្រក្រតីប្រព្រឹត្តធម៌រួមគ្នា ៧ ពួក នោះ គឺ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ឧបាសក ឧបាសិកា ។ ពិតណាស់ ក្នុងសហធម្មចារីទាំងនោះ ភិក្ខុឈ្មោះថា ប្រព្រឹត្តធម៌រួមជាមួយភិក្ខុទាំងឡាយ ព្រោះភាពជាអ្នកមានសិក្ខាស្មើគ្នា ភិក្ខុនីក៏ប្រព្រឹត្តធម៌រួមជាមួយភិក្ខុនីទាំងឡាយ ដូចគ្នា ។ល។ ឧបាសិកាក៏ប្រព្រឹត្តធម៌រួមជាមួយឧបាសិកាទាំងឡាយ ព្រះសោតាបន្ន ក៏ប្រព្រឹត្តរួមជាមួយព្រះសោតាបន្នទាំងឡាយ ព្រះសកទាគាមី ។ល។ ព្រះអនាគាមីក៏ប្រព្រឹត្តធម៌រួមជាមួយព្រះអនាគាមីទាំងឡាយ ព្រោះដូច្នោះ សហធម្មចារីទាំងនោះទាំងអស់ ហៅថា ***សហធម្មិក*** ។ ម្យ៉ាងទៀត ក្នុងទីនេះលោកបំណង

យកព្រះអរិយសាវកតែម្យ៉ាង ។ ព្រោះព្រះអរិយសាវកទាំងនោះ មិនមានការវិវាទក្នុងការឃើញមគ្គ សូម្បីក្នុងវាងកត ព្រោះដូច្នោះ ព្រះអរិយ-សាវកទាំងនោះ ទើបឈ្មោះថា សហធម្មិក ព្រោះមានប្រក្រតីប្រព្រឹត្តធម៌ដូចគ្នាដោយពិត ។ លោកសម្តែងសេចក្តីជ្រះថ្លា ដែលកើតដល់អ្នករលឹកក្នុងព្រះសង្ឃ ដោយន័យមានជាអាទិ៍ថា ព្រះសង្ឃសាវករបស់ព្រះមាន-ព្រះភាគ ជាអ្នកបដិបត្តិល្អ ដោយបទនេះ ។ អង្គទាំងឡាយរបស់សោតា-បន្ន ៤ ជាការដែលលោកសម្តែងហើយ ដោយប្រការដូច្នេះ ។ បទថា **ឥមេ ខោ នោ អាវុសោ** សេចក្តីថា ម្នាលអ្នកមានអាយុ ធម៌ ៤ ពួកនេះ ដែលព្រះមានព្រះភាគអង្គនោះត្រាស់ថា ជាការទុកចិត្ត និងជាកម្លាំងរបស់ពួកយើង ពួកយើងមើលឃើញធម៌ទាំងនេះ ក្នុងខ្លួន ចូរពោលយ៉ាងនេះ ។ បរិព្វាជក សម្តែងអាងសាស្តាទាំង ៦ មានបូរណកស្សបៈជាដើម ដោយបទនេះថា អ្នកណាជាសាស្តារបស់ពួកយើង ។

ក៏ឥឡូវនេះ មានការស្រឡាញ់ដែលអាស្រ័យផ្ទះថា អាចារ្យរបស់ពួកយើង ឧបជ្ឈាយ៍របស់ពួកយើង ក្នុងបុគ្គលទាំងឡាយ មានអាចារ្យនិងឧបជ្ឈាយ៍ជាដើម ក្នុងសាស្តាដោយប្រការណា បរិព្វាជកពោលថា សេចក្តីជ្រះថ្លាក្នុងសាស្តា សំដៅដល់ សេចក្តីស្រឡាញ់បែបនោះ ។ ក៏ព្រះថេរៈពោលថា ព្រោះព្រះសាស្តាមិនមែនជារបស់មនុស្សតែម្នាក់ មិនមែនជារបស់ ២ នាក់ តែជាព្រះសាស្តាមួយព្រះអង្គតែប៉ុណ្ណោះ របស់លោកព្រមទាំងទេវលោក ព្រោះដូច្នោះ តិរ្ថិយ៍ទាំងឡាយ បានចែកសាស្តាជាផ្នែកដោយ

បទមួយប៉ុណ្ណោះថា សាស្តារបស់យើងជាអ្នកក្លាត់ហើយ ចាញ់ហើយ ដោយបទនេះ ដូច្នេះ ។ ក៏ក្នុងបទថា **ធម្មេ បសាទោ** នេះ បរិព្វាជកទាំងឡាយសម្គាល់ថា ទីឃនិកាយរបស់ពួកយើង មជ្ឈិមនិកាយរបស់ពួកយើង ក្នុងសាសនាឥឡូវនេះ យ៉ាងណា រមែងពោលសំដៅដល់សេចក្តីស្រឡាញ់ដែលអាស្រ័យផ្ទះ ក្នុងបរិយត្តិធម៌រៀងៗ ខ្លួន ដូច្នោះ ។ បទថា **សីលេសុ** គឺ ក្នុងសីលទាំងឡាយ មានសីលពពែ សីលគោ សីលចៀម សីលឆ្កែជាដើម ។ បរិព្វាជកទាំងឡាយពោលសំដៅដល់ សេចក្តីជ្រះថ្លាថា ឥធ ក្នុងបទនេះថា **ឥធ នោ អាវុសោ** ដូច្នោះ ។ បទថា **កោ អធិប្បាយោ** បានដល់ មានអធិប្បាយដូចម្តេច ។ បទថា **យទិទំ** សេចក្តីថា បរិព្វាជកទាំងឡាយជាអ្នកមានធុរៈស្មើគ្នា ស្ថិតនៅដោយពាក្យថា លោកគប្បីពោលសេចក្តីដែលធ្វើឲ្យផ្សេងគ្នា រវាងពួកលោក និងពួកយើងនេះ ដូចម្តេចសេចក្តីជ្រះថ្លាក្នុងឋានៈ ៤ របស់ពួកលោក ក៏ជាសេចក្តីជ្រះថ្លាក្នុងឋានៈ ១ ជាមួយគ្នានឹងពួកយើងដែរមិនមែនឬ ពួកលោក និងពួកយើង ជាក្រុមតែមួយដូចគ្នា ដូចមាសដែលបំបែកចេញជាពីរចំណែកហើយ ដូច្នោះ ។ លំដាប់នោះ ព្រះមានព្រះភាគកាលនឹង ទ្រង់ទម្លាយភាពជាអ្នកមានធុរៈស្មើគ្នានោះ របស់បរិព្វាជកទាំងនោះ ទើបត្រាស់ថា **ឯវំ វាទិនោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ឯកា និដ្ឋា** មានសេចក្តីថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ពួកអ្នកចូរសួរយ៉ាងនេះថា ការសម្រេចដែលជាទីបំផុតនៃសេចក្តីជ្រះថ្លានោះ ការសម្រេចនោះ មានតែមួយ៉ាង ឬ

មានច្រើនយ៉ាង ។ ក៏ព្រោះអ្នកបញ្ញត្តិការសម្រេចក្នុងលទ្ធិនោះ ៗ មិនមាន អសញ្ញីកព ទើបត្រូវកំណត់យ៉ាងនេះថា ព្រហ្មលោកជារបស់ពួកព្រាហ្មណ៍ ការសម្រេច គឺ ការរលត់ មានអាភស្សរជារបស់ពួកតាបស សុភកិណ្ហា-ជារបស់ពួកបរិព្វាជក ដោយទីបំផុតជារបស់ពួកអាជីវក ។ ក៏អរហត្ត គឺ ជាការសម្រេចក្នុងសាសនានេះ ។ ក៏ពួកបរិព្វាជកទាំងអស់នោះ រមែង ពោលថា អរហត្ត ប៉ុណ្ណោះ គឺ ការសម្រេច ។ មួយវិញទៀត រមែងបញ្ញត្តិ លោកទាំងឡាយ មានព្រហ្មលោកជាដើម ដោយអំណាចទិដ្ឋិ ព្រោះដូច្នោះ ទើបបញ្ញត្តិសេចក្តីសម្រេចតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃលទ្ធិរបស់ ខ្លួន ៗ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការសម្រេចនោះ ទើបទ្រង់ ត្រាស់ថា ការព្យាករណ៍ដ៏ប្រពៃជាដើម ។

ឥឡូវនេះ លុះកាលសេចក្តីសម្រេចពីរយ៉ាង គឺ ការសម្រេចមាន ម្យ៉ាង ក្នុងសាសនានេះ សម្រាប់ភិក្ខុទាំងឡាយផង ការសម្រេចមានម្យ៉ាង សម្រាប់តិរ្ថិយ៍ទាំងឡាយផង តាំងនៅដូចកូនក្តីទាំងឡាយដូច្នោះ ព្រះមាន-ព្រះភាគ កាលទ្រង់សម្តែងវត្តនៃការប្រកបរឿយៗ ទើបព្រះអង្គទ្រង់ត្រាស់ ថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ សេចក្តីសម្រេចនោះ ជារបស់អ្នក មានរាគៈ ឬរបស់អ្នកប្រាសចាករាគៈ ដូច្នេះជាដើម ។ ក្នុងទីនេះ ព្រោះ ធម្មតាសេចក្តីសម្រេចរបស់អ្នកមានកិលេសទាំងឡាយ ជាអ្នកជោកជាំដោយ រាគៈមិនមាន ព្រោះដូច្នោះ ទើបទ្រង់សម្តែងព្យាករណ៍ដោយន័យ មាន អត្ថថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ការសម្រេចនោះ ជារបស់អ្នកប្រាស

ចាករាគៈ ចំពោះតិរិយ៍ទាំងឡាយជាអ្នកឃើញទោស ដូច្នេះថា សូម្បីផ្លែស្រុក និងផ្លែបចកជាដើម នឹងគប្បីមានសោត ក៏នឹងគប្បីមាន ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **វិទូសុនោ** បានដល់ បណ្ឌិត ។ បទថា **អនុរុទ្ធបដិវិរុទ្ធស្ស** បានដល់ អ្នកត្រេកអរដោយរាគៈ អ្នកមិនពេញចិត្តដោយសេចក្តីក្រោធ ។ បទថា **បបញ្ចារាមស្ស បបញ្ចរតិនោ** នោះ សត្វទាំងឡាយ រមែងត្រេកអរក្នុងបបញ្ចធម៌នោះ ព្រោះដូច្នោះ បបញ្ចធម៌នោះ ទើបឈ្មោះថា **អារាមោ** ជាទីមកនៃការត្រេកអរ ។ បបញ្ចធម៌ជាទីមកនៃសេចក្តីត្រេកអររបស់បុគ្គលនោះ ព្រោះដូច្នោះ បុគ្គលនោះទើបឈ្មោះថា **បបញ្ចារាមោ** ប្រែថា អ្នកមានបបញ្ចធម៌ជាទីត្រេកអរ ។

ការត្រេកអរក្នុងបបញ្ចធម៌របស់បុគ្គលនោះ ព្រោះដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា **បបញ្ចរតី** អ្នកត្រេកអរក្នុងបបញ្ចធម៌ ។ បទថា **បបញ្ចា** នោះ ជាឈ្មោះរបស់តណ្ហា ទិដ្ឋិ និងមានះ ដែលប្រព្រឹត្តទៅហើយដោយភាពជាអាការរបស់អ្នកស្រវឹង និងអ្នកប្រមាទហើយ ។ ក៏ក្នុងទីនេះ លោកសំដៅយក តណ្ហា និងទិដ្ឋិ ប៉ុណ្ណោះ ។ កិលេសម៉្យាងប៉ុណ្ណោះ មានហើយក្នុងស្ថាន ៥ ថា របស់អ្នកមានរាគៈជាដើម គប្បីជ្រាបអាការ និងសេចក្តីផ្សេង ៗ របស់កិលេសនោះ ។ លោកកាន់យកកិលេស ដោយអំណាចរាគៈលាយដោយកាមគុណ ៥ ដែលព្រះអង្គទ្រង់ត្រាស់ថា **សរាគស្ស** ។ កាន់យកកិលេស ដោយអំណាចភវតណ្ហា ក្នុងបទថា **សតណ្ហស្ស** ។ កាន់យកកិលេសដោយអំណាចការប្រកាន់ ក្នុងបទ

ថា **សឧបាទានស្ស** ។ កាន់យកកិលេសដោយអំណាចគូ ក្នុងបទថា **អនុរុទ្ធបដិវិរុទ្ធស្ស** ។ កាន់យកកិលេសដោយអំណាចការសម្តែងការកើតឡើងនៃកិលេសជាគ្រឿងយឺតយូរ ក្នុងបទថា **បបញ្ចារាមស្ស** ។ម្យ៉ាងទៀត កាន់យកកិលេសដោយអំណាចអកុសលមូល ក្នុងបទនេះថា **សរាគស្ស** ។ កាន់យកកិលេសដោយអំណាចឧបាទាន ព្រោះតណ្ហាជាបច្ច័យ ក្នុងបទនេះថា **សតណ្ហស្ស** ។ បទដ៏សេស ក៏ដូចបទមុននោះឯង ។ ក៏ព្រះថេរៈពោលថា លោកចូរកម្មាត់យ៉ាងនេះ ព្រោះហេតុអ្វី ព្រោះលោកៈតែមួយនេះប៉ុណ្ណោះ ពោលថា រាគៈ ដោយអំណាចនៃការត្រេកអរ ក៏ឈ្មោះថា **តណ្ហា** ដោយអំណាចនៃការធ្វើសេចក្តីប្រាថ្នាក្រៃលែង ហៅថា **ឧបាទាន** ដោយអត្ថថា ប្រកាន់មាំ ឈ្មោះថា ការត្រេកអរ និងការមិនពេញចិត្ត ដោយអំណាចជាគូ ហៅថា **បបញ្ច** ដោយអត្ថថា កើតឡើងនៃកិលេសជាគ្រឿងយឺតយូរ ។

[១៥៤] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងទិដ្ឋិវាទដែលជាឫសគល់របស់កិលេសទាំងនេះ ទើបត្រាស់ថា **ទ្វេមា ភិក្ខវេ ទិដ្ឋិយោ** ដូច្នេះ ជាដើម ។ បណ្តាបទទាំងនោះ បទថា **ភវទិដ្ឋិ** បានដល់ ការឃើញថាទៀង ។ បទថា **វិភវទិដ្ឋិ** បានដល់ ការឃើញថា ដាច់សូន្យ ។ បទថា **ភវទិដ្ឋិ អល្លីនា** សេចក្តីថា អ្នកអាងការឃើញថាទៀង ដោយអំណាចតណ្ហា ទិដ្ឋិ ។ បទថា **ឧបគតា** សេចក្តីថា ចូលដល់ដោយអំណាចតណ្ហា ទិដ្ឋិ ។ បទថា **អជ្ឈោសិតា** សេចក្តីថា លេបចូលទៅ ដោយអំណាច

តណ្ហា ទិដ្ឋិ នោះ ។ បទថា **វិភវទិដ្ឋិយា តេ បដិវិរុទ្ធា** សេចក្តីថា សមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ ជាអ្នកមិនពេញចិត្តថា ពួកលោកល្ងង់ខ្លៅ ព្រមដោយអ្នកពោលថា ដាច់សូន្យ មិនដឹងថា លោកនេះទៀងលោកនេះមិនដាច់សូន្យ ខ្វល់ខ្វាយក្នុងការឈ្លោះជានិច្ច ។ សូម្បី ក្នុងវារៈទី ២ ក៏ន័យនេះដូចគ្នា ។ ក្នុងបទថា **សមុទយញ្ច** ជាដើម ជាដែនកើតរបស់ទិដ្ឋិទាំងឡាយមាន ២ យ៉ាង គឺ ខណិកសមុទយៈ ១ , បច្ចយសមុទយៈ ១ ។ ការកើតរបស់ទិដ្ឋិទាំងឡាយ ឈ្មោះថា ខណិកសមុទយៈ ឋានៈដែលតាំងនៅមិនបាននៃទិដ្ឋិទាំងឡាយ ឈ្មោះថា បច្ចយសមុទយៈ ។ យ៉ាងណា គឺ ខន្ធក្តី អវិជ្ជាក្តី ផស្សៈក្តី វិតក្កក្តី អយោនិសោមនសិការក្តី បាបមិត្តក្តី បរឃោសៈក្តី ចាត់ជាទិដ្ឋិឋានៈ ខន្ធទាំងឡាយជាហេតុ ខន្ធទាំងឡាយជាបច្ច័យនៃការកើតឡើងរបស់ទិដ្ឋិទាំងឡាយ ព្រោះអត្ថថា តាំងឡើងព្រម ។ សូម្បីខន្ធទាំងឡាយឈ្មោះថា ទិដ្ឋិឋានៈ ដោយប្រការដូច្នេះ ។ អវិជ្ជា ផស្សៈ សញ្ញា វិតក្ក អយោនិសោមនសិការ បាបមិត្ត សំឡេងគឹកកងដទៃ ៗ ជាហេតុ ជាបច្ច័យនៃការកើតឡើងរបស់ទិដ្ឋិទាំងឡាយ ព្រោះអត្ថថា តាំងឡើងព្រម ។ សូម្បីសំឡេងគឹកកងដទៃ ៗ ឈ្មោះថា ទិដ្ឋិឋានៈ ដោយប្រការដូច្នេះ ។ សូម្បីការតាំងនៅមិនបាន មាន ២ យ៉ាងប៉ុណ្ណោះ គឺ ខណិកត្ថង្គមៈ ១ , បច្ចយត្ថង្គមៈ ១ ។ ការអស់ទៅ ការសូន្យ ការបែកធ្លាយ ការមិនទៀង ការបាត់ទៅ ឈ្មោះថា ខណិកត្ថង្គមៈ ។ សោតាបត្តិមគ្គ ឈ្មោះថា បច្ចយត្ថង្គមៈ ក៏សោតាបត្តិមគ្គ លោកពោលថា ទម្លាយនូវទិដ្ឋិ

ទាំងឡាយ ។ បទថា **អស្សាទំ** គឺ ពោលសំដៅដល់អានិសង្សដែលមាន ទិដ្ឋិជាមូល អធិប្បាយថា ព្រះសាស្តាទ្រង់មានទិដ្ឋិណា សាវកទាំងឡាយ ក៏មានទិដ្ឋិនោះ សាវកទាំងឡាយ រមែងធ្វើសក្ការៈ គោរពរាប់អានបូជា រមែងបានព្រះសាស្តា ទ្រង់មានទិដ្ឋិណា ទិដ្ឋិនោះ ជាដើមហេតុនៃចីវរ , បិណ្ឌបាត , សេនាសនៈ , គិលានប្បច្ច័យភេសជ្ជៈ និងបរិក្ខារទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សដែលប្រកបដោយទិដ្ឋិធម៌នៃទិដ្ឋិ ។ បទថា **អាទីនវំ** បានដល់ **ឧបទ្ទវំ** ដែលមានការ ប្រកាន់ទិដ្ឋិជាមូល ។ អាទីនវៈនោះ គប្បីជ្រាបដោយអំណាចនៃវត្តទាំងឡាយ មានជាអាទិ៍ថា វគ្គុលិវត្ត ឧក្កុដិកបធាន កណ្តកាបស្សយតា បញ្ចាតបតប្បន មរុប្បបាត- បតន កេសមស្សុលោចន អប្បាណកឈាន ។

បទថា **និស្សរណំ** បានដល់ **និព្វាន** ឈ្មោះថា រលាស់ចេញនូវទិដ្ឋិ ទាំងឡាយ មានអត្ថថា **យថាភូតំ នប្បជានន្តិ** សេចក្តីថា សមណៈ ឬ ព្រាហ្មណ៍ពួកណា មិនដឹងសមុទយៈជាដើមនោះទាំងអស់ តាមសភាវៈ ។ បទថា **ន បរិមុច្ចន្តិ ទុក្ខស្មា** សេចក្តីថា មិនរួចចាកវដ្តទុក្ខទាំងអស់ ។ ដោយបទនេះ ទ្រង់សម្តែងថា ឈ្មោះថា ការសម្រេចរបស់សមណៈ ឬ ព្រាហ្មណ៍ទាំងនោះមិនមាន ។ បទថា **បរិមុច្ចន្តិ ទុក្ខស្មា** សេចក្តីថា រមែង រួចផុតចាកវដ្តទុក្ខទាំងអស់ ។ ដោយបទនេះ ទ្រង់តាំងទុកនូវសេចក្តី សម្រេចមានក្នុងសាសនាប៉ុណ្ណោះ ដូចទ្រង់កាត់ក្តីនៃកូនក្តីទាំង ២ ថា សេចក្តីសម្រេចរបស់សមណៈ ឬព្រាហ្មណ៍ទាំងនោះមានហើយ ដូច្នេះ ។

[១៥៦] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការកាត់ទិដ្ឋិ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាទាន ៤ យ៉ាងនេះ ជាដើម ។ កថា ពោលដោយសេចក្តីពិស្តារនៃឧបាទាននោះ បានពោលហើយក្នុងវិសុទ្ធិមគ្គ នោះឯង ។ បទថា **សព្វុបាទានបរិញ្ញាវាទា បដិជានមានា** សេចក្តីថា ប្តេជ្ញាយ៉ាងនេះថា យើងទាំងឡាយ រមែងពោលនូវការកំណត់ដឹងជុំវិញ គឺ ការឈានកន្លងឧបាទានគ្រប់យ៉ាង ។ បទថា **ន សម្មា សព្វុបាទានស្ស បរិញ្ញំ បញ្ញបេន្តិ** សេចក្តីថា រមែងមិនបញ្ញត្តការឈានកន្លងឧបាទានគ្រប់យ៉ាងដោយប្រពៃទេ ។

ពួកខ្លះបញ្ញត្តតែការកំណត់ដឹងនូវកាមុបាទានប៉ុណ្ណោះ ពួកខ្លះបញ្ញត្តតែការកំណត់ដឹងនូវទិដ្ឋុបាទានប៉ុណ្ណោះ ពួកខ្លះបញ្ញត្តតែការកំណត់ដឹងជុំវិញនូវសីលព្វតុបាទានប៉ុណ្ណោះ ។ តែអ្នកឈ្មោះថា បញ្ញត្តការដឹងជុំវិញនូវអត្តវាទុបាទានមិនមាន ។ ក៏កាលទ្រង់សម្តែងចែកឧបាទានទាំងនោះ ទើបត្រាស់ថា បញ្ញត្តនូវការកំណត់ដឹងជុំវិញកាមុបាទាន ដូច្នេះ ជាដើម ។ ក្នុងឧបាទានទាំងនោះ សូម្បីសមណព្រាហ្មណ៍ទាំងអស់ បញ្ញត្តតែការកំណត់ដឹងជុំវិញនូវកាមុបាទានប៉ុណ្ណោះ ។ សូម្បីការឃើញក្រៅទំនៀម ក្រៅស្នាម ៩៦ ប្រការ ក៏គឺ កាមហ្នឹងឯង ដែលបព្វជិតមិនគប្បីសេព ព្រោះដូច្នោះ សមណព្រាហ្មណ៍ ទើបមិនបញ្ញត្តថា អ្នកសេពវត្ថុរមែងគួរ ធ្វើឲ្យជាអកប្បិយប៉ុណ្ណោះ ហើយទើបបញ្ញត្ត ។ ក៏បុគ្គលពួកណាសេព បុគ្គលពួកនោះ សេពដោយថេយ្យចិត្ត ។ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា

រមែងបញ្ញត្តនូវការកំណត់ដឹងជុំវិញកាមុបាទាន ដូច្នេះ ។ ព្រោះសមណ-ព្រាហ្មណ៍ប្រកាន់ថា ទានដែលឲ្យហើយ មិនបានផល ដូច្នេះជាដើម រមែងប្រកាន់ថា ការបរិសុទ្ធិដោយសីល ការបរិសុទ្ធិដោយវត្ត មិនមែនការបរិសុទ្ធិដោយការនា ឈ្មោះថា មិនលះបង់នូវអត្តូបលទ្ធិ ព្រោះដូច្នោះ ទើបមិនបញ្ញត្តនូវការកំណត់ដឹងជុំវិញទិដ្ឋុបាទាន អត្តវាទុបាទាន ។ បទថា **តំ កិស្ស ហេតុ** សេចក្តីថា ការមិនបញ្ញត្តនោះ ព្រោះហេតុអ្វី នៃឧបាទានទាំងនោះ គឺ ព្រោះហេតុអ្វី ។ បទថា **ឥមានិ ហិ តេ ភោន្តោ** សេចក្តីថា ព្រោះសមណព្រាហ្មណ៍ទាំងនោះ មិនដឹងហេតុការណ៍ ៣ យ៉ាងនេះ តាមសភាវៈ ។ ក៏សមណព្រាហ្មណ៍ពួកណា រមែងដឹងតាមសភាវៈ ក្នុងបទនោះថា ហេតុនៃការបញ្ញត្តិនូវការកំណត់ដឹង ២ យ៉ាង គឺ ទិដ្ឋិ និងសីលព្វតៈនោះ គប្បីលះ ទ្រង់សំដៅដល់សមណព្រាហ្មណ៍ទាំងនោះ ទើបត្រាស់វារៈ ២ យ៉ាង ទុកខាងមុខ ។ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកណាប្រកាន់ថា ទាន ដែលឲ្យហើយមានផល ដូច្នេះជាដើម សមណព្រាហ្មណ៍ពួកនោះ រមែងបញ្ញត្តការកំណត់ដឹងនូវទិដ្ឋុបា-ទាន ។ ចំណែកពួកណាប្រកាន់ថា ការបរិសុទ្ធិដោយសីល ការបរិសុទ្ធិដោយវត្ត ការបរិសុទ្ធិដោយការនាទាំងនោះ រមែងបញ្ញត្តការកំណត់ដឹងដោយជុំវិញ សូម្បីសីលព្វតុបាទាន ។ សូម្បីតែម្នាក់ក៏មិនអាចដើម្បីបញ្ញត្តការកំណត់ដឹងជុំវិញនូវអត្តវាទុបាទាន ។ តិរ្ថិយ៍ទាំងឡាយ ដែលបានសមាបត្តិ ៨ ក្តី អ្នកដែលអាចយកដៃស្ទាបអង្អែលព្រះចន្ទ និងព្រះអាទិត្យក្តី

រមែងបញ្ញត្តការកំណត់ដឹងដោយជុំវិញ ៣ យ៉ាង តែមិនអាចនឹងដើម្បីដោះចេញនូវអត្តវាទបាន ព្រោះដូច្នោះ ទើបត្រាច់រង្គាត់ទៅក្នុងវដ្តៈរឿយ ៗ នោះឯង ។ តិរ្ថិយ៍ទាំងនោះ ដូចទន្សាយស្អប់ខ្ពើមផែនដី ។ ឧបមាទាក់ទងនឹងការសន្ទនារឿងក្នុងទីនេះ ដូច្នេះ ៖

បានឮថា ផែនដីពោលនឹងទន្សាយថា នែ ! ទន្សាយ ។ ទន្សាយសួរថា អ្នកណាហ្នឹង ។ ផែនដី ។ ឯងសម្រេចឥរិយាបថទាំងអស់ បន្ទោបង់ឧច្ចារៈ និងបស្សាវៈលើយើង ដូចម្តេចបានជាមិនស្គាល់យើង ។ ទន្សាយ ។ អ្នកឃើញយើងដោយល្អ ក៏ការដែលយើងជាន់ ដូចជា ការដែលពាល់ត្រូវដោយចុងម្រាម ទឹកមូត្រចេញមក ក៏មានប្រមាណតិច ករីសៈក៏ប៉ុនគ្រាប់តុមកា ឯដំរី និងសេះជាដើម ជាន់ហើយ ក៏ក្លាយទៅជាទីជំបស្សាវៈរបស់សត្វទាំងនោះ ប្រមាណពេញមួយថ្នាំង ឧច្ចារៈក៏ប្រមាណមួយជាលយួរ យើងនឹងចេញចាកពីអ្នក ទើបលោតទៅកាន់ទីដទៃ ។ ពេលនោះ ផែនដីពោលនឹងទន្សាយនោះថា សូម្បីឯងលោតទៅដល់ណាឯងក៏នៅលើយើងដដែល ។ ទន្សាយនោះ កាន់តែមានការស្អប់ផែនដីទើបលោតទៅកាន់ទីដទៃ ទន្សាយលោតហើយលោតទៀត សូម្បីមួយពាន់ឆ្នាំយ៉ាងនេះ ក៏មិនអាចផុតពីផែនដីបាន តិរ្ថិយ៍ទាំងឡាយ ក៏ដូច្នោះ សូម្បីបញ្ញត្តការកំណត់ដឹងដោយជុំវិញនូវឧបាទានគ្រប់យ៉ាង ក៏រមែងបញ្ញត្តការឈានកន្លងឧបាទាន ៣ យ៉ាង មានកាមុបាទានជាដើម ប៉ុណ្ណោះ ។ តែមិនអាចនឹងផុតអត្តវាទៈបាន ការដែលមិនអាចផុត ទើបធ្លាក់នៅក្នុងវដ្តៈ

រឿយ ៗ នោះឯង ។ ដោយប្រការដូច្នេះ តិរ្ថិយ៍ទាំងឡាយ មិនអាច ឈានកន្លងនូវឧបាទានណា ព្រះមានព្រះភាគ ទ្រង់ត្រាស់ដល់វាទៈដែល កាត់ផ្តាច់ទិដ្ឋិដោយអំណាចនៃឧបាទាននោះហើយ ឥឡូវនេះ កាលទ្រង់សម្តែង ការកាត់សេចក្តីជ្រះថ្លា ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យ បែបនេះឯង ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ធម្មវិនយេ** បានដល់ ក្នុងធម៌ និងវិន័យ ។ ទ្រង់សម្តែងដល់សាសនា ដែលមិនមែន ជាគ្រឿងនាំសត្វចេញចាកទុក្ខ សូម្បីដោយបទទាំងពីរ ។ បទថា **យោ សត្ថរិ បសាទោ សោ ន សម្មគ្គតោ** សេចក្តីថា ក៏សាស្តាក្នុងសាសនា ដែលមិនមែនជាគ្រឿងនាំសត្វចេញចាកទុក្ខ លុះធ្វើកាលកិរិយាហើយ កើត ជាសីហៈខ្លះ ខ្លាធំខ្លះ ខ្លាដំបងខ្លះ ខ្លាឃ្មុំខ្លះ ខ្លារខិនខ្លះ ។

ចំណែកសាវ័កទាំងឡាយរបស់សាស្តានោះ កើតជាម្រឹគខ្លះ ជ្រូកខ្លះ ទន្សាយខ្លះ ។ វាមិនធ្វើការអត់ធន់ ឬការមានបំណងល្អ ឬការអាណិត អាសូរថា សត្វទាំងនេះធ្លាប់ជាឧបដ្ឋាកឲ្យបច្ច័យដល់យើង ក៏សម្លាប់សត្វ ទាំងនោះ ហើយហុតឈាមខ្លះ ស៊ីសាច់ទាំងឡាយខ្លះ ។ ប្រការមួយទៀត សាស្តាកើតជាឆ្មា ។ សាវ័កទាំងឡាយ កើតជាមាន់ ឬកណ្តុរ ។ លំដាប់ នោះ ឆ្មាក៏មិនធ្វើសេចក្តីអនុគ្រោះ រមែងស៊ីមាន់ ឬកណ្តុរទាំងនោះ ដោយ ន័យដូចពោលហើយ ។ម្យ៉ាងទៀត សាស្តាជានាយនិរយបាល សាវ័ក ទាំងឡាយជាសត្វនរក ។ នាយនិរយបាលទាំងនោះ មិនធ្វើការអនុគ្រោះ ថា សត្វទាំងនេះធ្លាប់ឲ្យបច្ច័យដល់យើង ក៏រមែងដាក់ទណ្ឌកម្មផ្សេងៗ មាន

ដាក់ក្នុងរថដែលក្ដៅដ៏ខ្លាំងខ្លះ ឲ្យឡើងភ្នំភ្លើងខ្លះ ទម្លាក់ក្បាលទៅក្នុងឆ្នាំង លោហៈខ្លះ ប្រកបដោយទុក្ខច្រើនយ៉ាង ។ ឬក៏សាវកទាំងឡាយស្លាប់ទៅកើតជាសត្វ មានសីហៈជាដើម ។ សាស្ដាជាសត្វណាមួយ មានម្រឹគជាដើម ។ សត្វទាំងនោះ មិនមានការអត់ធន់ ឬមានបំណងល្អ ឬការអាណិតអាសូរក្នុងសត្វនោះថា យើងធ្លាប់ឧបដ្ឋាកដោយបច្ច័យ ៤ សត្វនេះធ្លាប់ជាសាស្ដារបស់ពួកយើង ដូច្នេះ រមែងឲ្យដល់នូវការវិនាស ដោយន័យដូចពោលហើយនោះ ។ ក្នុងសាសនា ដែលមិនមែនជាគ្រឿងនាំសត្វចេញចាកទុក្ខ ដោយប្រការដូច្នេះ ការជ្រះថ្លាក្នុងសាស្ដាណា ការជ្រះថ្លានោះមិនប្រព្រឹត្តទៅដោយប្រពៃ សូម្បីទៅកាន់សេចក្ដីស្លាប់យ៉ាងណាហើយ នឹងវិនាសទៅជាខាងក្រោយនោះឯង ។

បទថា **យោ ធម្មេ បសាទោ** សេចក្ដីថា ក៏ធម្មតា ការជ្រះថ្លាក្នុងធម៌ ក្នុងសាសនាដែលមិនមែនជាគ្រឿងនាំសត្វចេញចាកទុក្ខ ជាសេចក្ដីជ្រះថ្លាក្នុងតន្តិធម៌ ត្រឹមតែរៀន សិក្សារៀនចាំទុក និងប្រាប់ តែការផុតចាកវដ្ដៈមិនមានក្នុងសេចក្ដីជ្រះថ្លានោះ ព្រោះដូច្នោះ សេចក្ដីជ្រះថ្លាក្នុងធម៌នោះ សេចក្ដីជ្រះថ្លានោះ រឹងរិតតែធ្វើវដ្ដៈឲ្យវែងឆ្ងាយឡើង ព្រោះដូច្នោះ តថាគតពោលថា មិនប្រព្រឹត្តទៅដោយប្រពៃ គឺ មិនទៅហើយដោយសការៈ ។ បទថា **យា សីលេសុ បរិបូរការិតា** សេចក្ដីថា ការធ្វើឲ្យបរិបូរដោយអំណាចនៃសីលទាំងឡាយ មានសីលពពែជាដើម ។

ក្នុងសាសនាដែលមិនមែនជាគ្រឿងនាំសត្វចេញចាកទុក្ខ ការធ្វើឲ្យ

បរិបូរនោះ មិនញ៉ាំងឲ្យដល់ការរួចផុតចាកវដ្តៈ គឺ ការរលាស់ចេញចាក ភពបាន តែកាលណាដល់ព្រម រមែងនាំមកកាន់កំណើតតិរច្ឆាន ការឲ្យ ផលរមែងនាំមកកាន់នរក ព្រោះដូច្នោះ ទើបយើងមិនពោលថា ទៅហើយ មិនដោយប្រពៃ ។ បទថា **យា សហធម្មិកេសុ** សេចក្តីថា ក៏ក្នុងសាសនា ដែលមិនមែនជាគ្រឿងនាំសត្វចេញចាកទុក្ខ ពួកសហធម្មិកខ្លះ លុះធ្វើកាល កិរិយាហើយកើតជាសត្វ មានសីហៈជាដើម ពួកខ្លះជាសត្វ មានម្រឹគជា ដើម ក្នុងសត្វទាំងនោះ ពួកសត្វមានសីហៈជាដើម មិនធ្វើកិច្ច មានការ អត់ធន់ជាដើម ក្នុងសត្វទាំងឡាយដែលកើតជាម្រឹគជាដើមថា សត្វទាំង នោះ ជាសហធម្មិករបស់ពួកយើង ដូច្នេះ ហើយញ៉ាំងមហាទុក្ខឲ្យកើត ឡើងដល់សត្វទាំងឡាយ មានម្រឹគជាដើមនោះ តាមន័យដូចពោលហើយ ក្នុងបទមុននោះឯង ព្រោះដូច្នោះ ភាពជាទីស្រឡាញ់ និងគួរពេញចិត្ត ក្នុងពួកសហធម្មិកនោះ យើងទើបពោលថា មិនប្រព្រឹត្តទៅហើយដោយ ប្រពៃ ។ ក៏ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃហេតុ សូម្បីទាំង អស់នេះរួមគ្នា ទើបត្រាស់ថា សេចក្តីនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុ ទាំងឡាយ ព្រោះសេចក្តីនោះ ដូច្នេះជាដើម សេចក្តីសង្ខេបក្នុងបទនេះ ដូច្នេះ ។ បទថា **ម្នាលភិក្ខុទាំងឡាយ** ព្រោះសេចក្តី ដែលតថាគតពោល ថា ការជ្រះថ្លាក្នុងសាស្តាណាមិនប្រព្រឹត្តទៅដោយប្រពៃ រមែងពោលយ៉ាង នេះ ដូច្នេះជាដើម ព្រោះហេតុអ្វី ព្រោះការជ្រះថ្លាជាដើមនោះ ក្នុងធម្ម- វិន័យដែលសាស្តានោះពោល អាក្រក់ហើយ ។ល។ មិនមែនជាការដែល

ដឹងដោយខ្លួនឯងដោយប្រពៃ ហើយប្រកាសទុក ។ ក៏ក្នុងបទនោះ បទថា **យថាតំ** ជានិបាតចុះក្នុងអត្ថនៃតតិយាវិភត្ត ។ បណ្ដាបទទាំងនោះ បទថា **ទុរក្ខាតេ** បានដល់ ពោលទុកមិនល្អ ។ ឈ្មោះថា ប្រកាសទុកមិនល្អ ហើយ ព្រោះការដែលធម្មវិន័យនោះ ពោលទុកមិនល្អ ។ ក៏ធម្មវិន័យនេះ នោះ រមែងមិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់មគ្គ និងផល ព្រោះដូច្នោះ ទើបពោលថា **អនិយ្យានិកោ** ប្រែថា មិនជាគ្រឿងនាំចេញចាកទុក្ខ ។ ឈ្មោះថា មិនប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ ព្រោះមិនប្រព្រឹត្តទៅដើម្បី សេចក្ដីស្ងប់កិលេសទាំងឡាយ មានរាគៈជាដើម ។ ឈ្មោះថា មិនមែន ជាអ្នកដឹងដោយខ្លួនឯងដោយប្រពៃ ហើយប្រកាសទុក ព្រោះអ្នកដឹងដោយ ខ្លួនឯងដោយប្រពៃ គឺ **សព្វញ្ញូ** មិនប្រកាសទុក ។ ក្នុងធម្មវិន័យនោះ មិនមែនជាសភាពនាំចេញចាកទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ មិន មែនជាអ្នកដឹងដោយខ្លួនឯងដោយប្រពៃ ហើយប្រកាសទុក ។ ព្រះមាន-ព្រះភាគទ្រង់សម្ដែងថា ការជ្រះថ្លាក្នុងតិរ្ថិយ៍ទាំងឡាយ ឥតប្រយោជន៍ ដូចសេចក្ដីជ្រះថ្លាក្នុងឆ្កែចចកឆឹកសុរា ដោយប្រការដូច្នោះ ។

បានឮថា ឆ្កែចចកខ្វាក់ភ្នែកម្ខាង ចូលទៅក្នុងនគរពេលយប់ ស៊ី មេស្រា ហើយដេកលក់ក្នុងព្រៃបុន្នាគ ភ្ញាក់ឡើងក្នុងពេលព្រះអាទិត្យរះ ក៏គិតថា យើងមិនអាចទៅក្នុងពេលនេះបាន សត្វដែលមានពៀរជាមួយ យើងមានច្រើន សមគួរនឹងបញ្ឆោតមនុស្សម្នាក់ ដូច្នេះ ។ ឆ្កែចចកនោះ ឃើញព្រាហ្មណ៍ម្នាក់ដើរទៅ ទើបគិតថា យើងនឹងបញ្ឆោតព្រាហ្មណ៍នេះ

ហើយពោលថា ម្នាលព្រាហ្មណ៍ ព្រាហ្មណ៍និយាយថា អ្នកណាហៅព្រាហ្មណ៍ ។ ចែ្កចចកឆ្លើយថា យើងនាយ ! អ្នកចូរមកនេះសិន ។ ព្រាហ្មណ៍ ។ អ្វីនាយ ! ។ ចែ្កចចក ។ អ្នកចូរនាំយើងទៅក្រៅភូមិ យើងនឹងឲ្យកហាបណៈ ២០០ ដល់អ្នក ។ ព្រាហ្មណ៍នោះនិយាយថា យើងនឹងទៅ ហើយក៏ចាប់ជើងទាំងឡាយ , ចែ្កចចកនិយាយថា ណែ ! ព្រាហ្មណ៍ល្អ យើងមិនមានកហាបណៈទេ អ្នកដាក់យើងចុះទៅ កហាបណៈជារបស់រកបានដោយលំបាក អ្នកចូរចាប់យើងស្រាល ៗ ។ ព្រាហ្មណ៍ ។ យើងនឹងចាប់យ៉ាងណាល្អ ។ ចែ្កចចក ។ អ្នកចូរយកសំពត់រុំស្លាយយើង ។ ព្រាហ្មណ៍ចាប់ចែ្កចចកយ៉ាងនោះ ហើយទៅកាន់ទីជិតខ្លោងទ្វារខាងត្បូងហើយសួរថា យើងនឹងលែងក្នុងទីនេះ ។ ចែ្កចចក ។ ទីកន្លែងណា ? ។ ព្រាហ្មណ៍ ។ នុ៎ះទ្វារធំ ។ ចែ្កចចក ។ អើ ព្រាហ្មណ៍ល្អ ញាតិរបស់អ្នករក្សាកហាបណៈ ទុកក្នុងខាងក្នុងទ្វារឬ ចូរនាំយើងទៅកន្លែងដទៃ ។ ព្រាហ្មណ៍នោះទៅបណ្តើរ សួរបណ្តើរថា យើងនឹងលែងកន្លែងនេះឬ មួងនេះត្រូវចែ្កចចកតាមគំរាម ហើយប្រាប់ថា អ្នកចូរនាំយើងទៅកាន់ទីផុតភ័យ ហើយលែងក្នុងទីនោះ ដូច្នេះ សឹមស្រាយលែងពីសំពត់សាដក ។ កាណសិង្គាល ពោលថា យើងបាននិយាយទុកថា យើងនឹងឲ្យកហាបណៈ ២០០ ដល់អ្នក ។ តែយើងមានកហាបណៈច្រើន មិនមែនមានត្រឹមតែ ២០០ ប៉ុណ្ណោះទេ អ្នកចូរឈរសម្លឹងមើលព្រះអាទិត្យរហូត ទម្រាំយើងនឹងយកកហាបណៈមកឲ្យអ្នកហើយ សឹមទៅ ចែ្កចចកនិយាយនឹងព្រាហ្មណ៍

ទៀតថា ព្រាហ្មណ៍ អ្នកកុំសម្លឹងមើលទីនេះ ចូរឈរសម្លឹងមើលតែព្រះអាទិត្យតែម្យ៉ាងចុះ ។ ឆ្កែចចកនិយាយយ៉ាងនេះហើយ ក៏ចូលទៅកាន់ព្រៃការកេត គេចទៅបានតាមសេចក្តីពេញចិត្ត ។ ចំណែកព្រាហ្មណ៍សម្លឹងមើលព្រះអាទិត្យនោះ រហូតញើសហូរស្រក់ចេញអំពីថ្ពាស និងក្លៀក ។ លំដាប់នោះ ទុក្ខវេទនាបានពោលនឹងព្រាហ្មណ៍នោះថា ៖

ម្នាលព្រាហ្មណ៍ អ្នកជឿឆ្កែចចកផឹកស្រា ឆ្កែចចកទាំងវយ
មិនមានសិល្បៈ កហាបណៈទាំង ២០០ នឹងមានមកពី
ណា ។ ដោយប្រការដូច្នេះ សេចក្តីជ្រះថ្លាក្នុងកាណ-
សិង្គាល ឥតមានប្រយោជន៍ យ៉ាងណា បីតិយ៉ាងល្អក្នុង
តិរីយ៍ ក៏ឥតប្រយោជន៍ ដូច្នោះ ។

[១៥៧] ព្រះមានព្រះភាគ លុះទ្រង់សម្តែងនូវសេចក្តីជ្រះថ្លាក្នុងសាសនាដែលមិនមែនជាគ្រឿងនាំចេញចាកទុក្ខ ជារបស់ឥតប្រយោជន៍ហើយ ដើម្បីទ្រង់សម្តែងការជ្រះថ្លានោះ ក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខថាជារបស់មានប្រយោជន៍ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **កាមុបាទានស្ស បរិញ្ញំ បញ្ញាបេតិ** សេចក្តីថា ទ្រង់បញ្ញត្តិការកំណត់ដឹងដោយជុំវិញ ក្នុងការលះគឺ ការឈានកន្លងកាមុបាទានដោយអរហត្តមគ្គ ទ្រង់បញ្ញត្តិការកំណត់ដឹងដោយជុំវិញនូវឧបាទាន ៣ យ៉ាង ក្រៅពីនេះ ដោយសោតាបត្តិមគ្គ ។ បទថា **ឯវរូបេ ខោ ភិក្ខវេ ធម្មវិនយេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ

ក្នុងធម្មវិន័យនេះ ដូច្នេះ ។ ទ្រង់សម្ដែងសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខ ដោយបទសូម្បីទាំង ២ ។ បទថា **សត្ថរិ បសាទោ** សេចក្ដីថា ក្នុងសាសនាបែបនេះ សេចក្ដីជ្រះថ្លាក្នុងសាស្ដាណា សេចក្ដីជ្រះថ្លានោះ តថាគតពោលថា ទៅហើយដោយប្រពៃ គឺ រមែងប្រព្រឹត្តទៅដើម្បីរលាស់ចេញចាកទុក្ខក្នុងភព ។ ក្នុងសេចក្ដីនោះ មានរឿងដូច្នេះ ៖

បានឮថា ព្រះមានព្រះភាគទ្រង់អាស្រ័យនៅក្នុងគុហា ( ឥន្ទសាល ) នៅក្នុងវេទិស្សកបព៌ត ។ ពេលនោះសត្វទីទុយមួយ កាលព្រះមានព្រះភាគទ្រង់ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ក៏ហើរបានពាក់កណ្ដាលផ្លូវ លុះព្រះមានព្រះភាគស្ដេចចេញមក ក៏ធ្វើការក្រោកទទួលពាក់កណ្ដាលផ្លូវ ។ ក្នុងថ្ងៃមួយ សត្វទីទុយនោះហើរចុះពីភ្នំ ថ្វាយបង្គំព្រះសម្មាសម្ពុទ្ធដែលមានព្រះភិក្ខុសង្ឃហែហម ប្រថាប់គង់ក្នុងវេលាសៀល ដោយត្រដាងស្លាបផ្គងអញ្ជលី ធ្វើសីសៈឲ្យទាបចុះ ឈរនមស្ការព្រះទសពល ។ ព្រះមានព្រះភាគទ្រង់ក្រឡេកមើលសត្វទីទុយនោះ ហើយធ្វើការញញឹម ។ ព្រះអានន្ទត្ថេរទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីជាបច្ច័យនៃការញញឹមឲ្យប្រាកដ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកចូរមើលសត្វទីទុយនេះ សត្វទីទុយនេះ ញុំាងចិត្តឲ្យជ្រះថ្លាចំពោះតថាគត និងចំពោះព្រះភិក្ខុសង្ឃ ហើយត្រាច់ទៅក្នុងទេវលោក និងមនុស្សទាំងឡាយរហូត ១ សែនកប្ប និងបានជាព្រះបច្ចេកពុទ្ធ មាននាមថា **សោមនស្ស** ដូច្នេះហើយ ទើបទ្រង់ត្រាស់គាថា ថា ៖

*ម្នាលសត្វទីមួយក្អែកមួល រស់នៅអស់កាលយូរ លើភ្នំវេទិសក: សត្វទីមួយឯងមានសេចក្តីសុខ ហើយអ្នកបានឃើញព្រះពុទ្ធដ៏ប្រសើរ អ្នកក្រោកឡើងតាមកាល ញុំាងចិត្តឲ្យជ្រះថ្លាចំពោះតថាគត និងចំពោះព្រះសង្ឃដ៏កំពូល នឹងមិនទៅកាន់ទុគ្គតិរហូតសែននៃកប្ប លុះចុតិចាកទេវលោកហើយ ដែលកុសលមូលដាស់តឿន នឹងបានជាព្រះបច្ចេកពុទ្ធ មានញាណដែលរកទីបំផុតមិនបាន ប្រាកដនាមថា សោមនស្ស ។*

*ក៏រឿងទាំងឡាយ មានរឿងសុមនមាលាការក្នុងនគររាជគ្រឹះ រឿងមហាភេរីវាទកៈ រឿងមោរជាតក រឿងវីណាវាទៈ រឿងសង្ខធមកៈ ដូច្នេះជាដើម សូម្បីរឿងដទៃ ៗ គប្បីធ្វើឲ្យពិស្តារក្នុងរឿងនោះចុះ ការជ្រះថ្លាក្នុងព្រះសាស្តា ក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ ជាការដែលទៅហើយដោយប្រពៃ ដោយប្រការដូច្នេះ ។*

*បទថា **ធម្មេ បសាទោ** សេចក្តីថា ការជ្រះថ្លាក្នុងធម៌ក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ ជាការដែលទៅហើយដោយប្រពៃ ការជ្រះថ្លានោះ រមែងឲ្យសម្បត្តិសូម្បីតិរច្ឆានទាំងឡាយ ដែលកាន់យកនិមិត្តត្រឹមតែស្តាប់សំឡេង សេចក្តីនេះ គប្បីជ្រាបដោយអំណាចនៃរឿងរបស់មណ្ឌុកទេវបុត្តជាដើម ។ បទថា **សីលេសុ បរិបូរការិតា** សេចក្តីថា សូម្បីការធ្វើឲ្យបរិបូណ៌ក្នុងសីល ក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ ជាការ*

ដែលទៅហើយដោយប្រពៃ គឺ រមែងនាំមកនូវសុគតិសម្បត្តិ និងវិមោក្ខ-សម្បត្តិ ។ ក្នុងទីនោះ គប្បីសម្តែងរឿងទាំងឡាយ មានរឿងឆត្តមាណវកៈ និងសាមណេរជាដើម ។ បទថា **សហធម្មិកេសុ** សេចក្តីថា សូម្បីភាពជាទីស្រឡាញ់ និងគួរពេញចិត្តក្នុងពួកសហធម្មិកៈក្នុងសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខ ដែលជាការទៅហើយដោយប្រពៃ គឺ រមែងនាំមកនូវមហាសម្បត្តិ ។ សេចក្តីនេះ គប្បីសម្តែងរឿង ដោយវិមានប្រេតទាំងឡាយ ក៏លោកបានពោលពាក្យនោះទុកថា យើងបានឲ្យទឹកដោះដល់ភិក្ខុអ្នកត្រាច់បិណ្ឌបាត យើងបានឲ្យទឹកអំពៅ ។ល។ ដើមអំពៅ ផ្លែទន្លាប់ ត្រសក់ ល្ពៅ បាច់បន្លែ អំបុក ត្រាវ បាច់ល្ពៅ ទឹកក្រូច នំក្រៀម វត្ថពន្ធ សំពត់អង្សក សំពត់សម្រាប់ធ្វើសេចក្តីព្យាយាម ផ្ចិតស្ទឹកត្នោត ឆត្រ ស្បែកជើង នំ ដុំនំ គ្រឿងចង ដល់ភិក្ខុត្រាច់បិណ្ឌបាត លោកសូមមើលវិមានរបស់យើង នុ៎ះ ទេពធីតាដែលមានពណ៌គួរប្រាថ្នា ដូច្នេះ ។ ពាក្យថា **តំ កិស្ស ហេតុ** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយចុះ ។

[១៥៨] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងបច្ច័យនៃឧបាទានទាំងឡាយ ដែលតិរ្ថិយ៍ទាំងឡាយមិនបញ្ញត្តការកំណត់ដឹងដោយជុំវិញ ដ៏ប្រពៃ តថាគតទ្រង់បញ្ញត្ត ទើបត្រាស់ថា **ឥមេ ច ភិក្ខវេ** ជាដើម ។ ពាក្យទាំងឡាយ មាននិទានជាដើម ក្នុងបទទាំងឡាយថា **កឹ និទានា** ជាដើម ក្នុងបទនោះ ។ ទាំងអស់ជាវេវចនៈនៃហេតុ ។ ពិតណាស់ ហេតុរមែងប្រគល់ឲ្យដល់ផល ដូចបញ្ជាឲ្យថា ណ្ហើយចុះ អ្នកទាំងឡាយ ចូរ

កាន់យកផលនោះ ព្រោះដូច្នោះ ទើបហៅថា និទាន ។ ព្រោះនិទាននោះ រមែងកើត រមែងតាំងឡើង ផលិតចេញអំពីការណ៍នោះ ព្រោះដូច្នោះ ទើបហៅថា សមុទយៈ ជាតិ បភវៈ សេចក្តីនៃបទក្នុងទីនេះ ដូច្នេះ អ្វីជាដើមហេតុនៃឧបាទានទាំងនោះ ព្រោះដូច្នោះ ឧបាទានទាំងនោះ មានអ្វីជាដើមហេតុ ។ អ្វីជាហេតុកើតនៃឧបាទានទាំងឡាយនោះ ព្រោះដូច្នោះ ឧបាទានទាំងនោះ មានអ្វីជាហេតុកើត ។ អ្វីជាកំណើតនៃ ឧបាទានទាំងនោះ ព្រោះដូច្នោះ ឧបាទានទាំងនោះ មានអ្វីជាកំណើត ។ អ្វីជាដែនកើតរបស់ឧបាទានទាំងនោះ ព្រោះដូច្នោះ ឧបាទានទាំងនោះ មានអ្វីជាដែនកើត ។ ក៏ព្រោះតណ្ហាជាដើមហេតុ ជាហេតុកើត ជាកំណើត និងជាដែនកើតនៃឧបាទានទាំងនោះ ដោយសេចក្តីតាមដែលពោលហើយ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា មានតណ្ហាជាដើមហេតុ ដូច្នេះជាដើម ។

គប្បីជ្រាបសេចក្តីក្នុងបទទាំងនោះ យ៉ាងនេះ ។ ក៏ព្រោះព្រះមានព្រះភាគ ទ្រង់ជ្រាបបច្ច័យនៃឧបាទានតែម្យ៉ាងប៉ុណ្ណោះ រមែងទ្រង់ជ្រាបដល់បច្ច័យនៃតណ្ហា ដែលជាបច្ច័យនៃឧបាទានផង នៃធម៌ទាំងឡាយ មានវេទនាជាដើម ដែលមានតណ្ហាជាដើម ជាបច្ច័យផង ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក៏តណ្ហានេះ ដូច្នេះជាដើម ។ បទថា **យតោ ច ខោ** បានដល់ ក្នុងកាលណា ។ បទថា **អវិជ្ជា បហីនា ហោតិ** សេចក្តីថា អវិជ្ជាជាឫសគល់នៃវដ្តៈ ជាការដែលលះបង់ហើយដោយអនុប្បាទនិរោធ ។ បទថា **វិជ្ជា ឧប្បន្នា** បានដល់ វិជ្ជា គឺ អរហត្តមគ្គកើត

កើតឡើងហើយ ។ បទថា **សោ អវិជ្ជាវិរាគា វិជ្ជុប្បាទា** សេចក្តីថា ភិក្ខុនោះ ព្រោះការដែលអវិជ្ជាលះបង់បានហើយ ព្រោះវិជ្ជាកើតឡើងហើយ រមែងមិនប្រកាន់មាំនូវកាមុបាទាន បទថា **នេវ កាមុបាទានំ ឧបាទិយតិ** សេចក្តីថា រមែងមិនប្រកាន់មាំ គឺ មិនចូលដល់កាមុបាទាន រមែងមិនប្រកាន់មាំ នឹងមិនចូលដល់ឧបាទានទាំងឡាយដ៏សេស ។

បទថា **អនុបាទិយំ ន បរិតស្សតិ** សេចក្តីថា កាលមិនប្រកាន់មាំនូវឧបាទានណា ៗ យ៉ាងនេះ ឈ្មោះថា មិនតក់ស្លុតដោយការតក់ស្លុត គឺ តណ្ហា ។ បទថា **អបរិតស្សំ** បានដល់ កាលមិនតក់ស្លុត គឺ មិនញុាំងតណ្ហាឲ្យកើតឡើង ។ បទថា **បច្ចត្តំយេវ បរិនិព្វាយតិ** សេចក្តីថា រមែងបរិនិព្វាន ដោយការរលត់កិលេសចំពោះខ្លួននោះពិត ដូច្នេះ ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងការអស់ទៅនៃអាសវៈដល់ភិក្ខុនោះ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងបច្ចវេក្ខណញ្ញាណដល់ភិក្ខុដែលមានអាសវៈអស់ហើយ ទើបទ្រង់ត្រាស់ថា ជាតិអស់ហើយ ដូច្នេះជាដើម ។ បទដ៏សេស មានសេចក្តីដូចពោលហើយនោះឯង ។

( ចប់ អដ្ឋកថាចុល្លសីហនាទសូត្រទី ១ )

# អដ្ឋកថា

## មហាសីហនាទសូត្រ ទី ២

[១៥៩] *មហាសីហនាទសូត្រ មានពាក្យផ្ដើមថា ខ្ញុំម្ចាស់បានស្ដាប់មកយ៉ាងនេះ ៖*

*ក្នុងមហាសីហនាទសូត្រនោះ បទថា **វេសាលិយំ** មានសេចក្ដីថា ជិតព្រះនគរ ដែលមានឈ្មោះយ៉ាងនោះ ។ បានឮមកថា ព្រះនគរនោះឈ្មោះវេសាលី ព្រោះជានគរចម្រើនដោយសម្បត្តិមហាសាលរឿយ ៗ ។ ក្នុងមហាសីហនាទសូត្រនេះ មានការពោលតាមលំដាប់ដូច្នេះ ។*

*បានឮមកថា ព្រះអគ្គមហេសីរបស់ព្រះបាទក្រុងពារាណសី ទ្រង់តាំងព្រះគភ៌ ព្រះនាងបានជ្រាបហើយ ក៏ទូលព្រះរាជាឲ្យទ្រង់ជ្រាប ព្រះ រាជាបានព្រះរាជទានគ្រឿងរក្សាព្រះគភ៌ ។ ព្រះនាងកាលបានទទួលនូវការរក្សាដោយល្អ ក៏ស្ដេចយាងទៅកាន់ប្រាសាទដែលជាកន្លែងទ្រង់ប្រសូត បុត្រក្នុងកាលដែលព្រះនាងមានគភ៌ចាស់ ។ ក្នុងពេលទៀបភ្លឺ អ្នកមានបុណ្យទាំងឡាយ ក៏បានប្រសូតចាកព្រះគភ៌ ។ ព្រះនាងអគ្គមហេសី ក្រៅអំពីព្រះទេវីទាំងនោះ ទ្រង់បានប្រសូតនូវដុំសាច់ ដូចជាផ្កាច្បា ដែលមិនស្វិតស្រពោន ក្នុងពេលទៀបភ្លឺ ។ ព្រះនាងទេវីដទៃ ក្រៅពីអគ្គមហេសីនោះ ទ្រង់ប្រសូតព្រះឱរសទាំងឡាយ ដូចជាពុម្ពមាស ។ ព្រះនាងអគ្គមហេសី ទ្រង់ជ្រាបថា ជាដុំសាច់ ទើបទ្រង់គិតថា សេចក្ដីអាប់យសរបស់យើងនឹង*

កើតឡើងចំពោះព្រះកត្រ្កនៃព្រះរាជា ដូច្នេះ ព្រោះទ្រង់ខ្លាចដល់ការអាប់យសនោះ ទើបទ្រង់ដាក់ដុំសាច់នោះ ក្នុងភាជន៍មួយបិទគម្រប ហើយព្រះនាងប្រថាប់ត្រាព្រះរាជា រួចទ្រង់ឲ្យគេបណ្តែតតាមក្រសែទឹកគង្គា ។ កាលភាជន៍នោះ ដែលគេបានបណ្តែតទៅហើយ ទេវតាទាំងឡាយ ក៏ចាត់ចែងរក្សានូវភាជន៍នោះ ។ មនុស្សទាំងឡាយ ក៏បានចារឹកផែនមាសពណ៌ក្រហមចងទុកក្នុងភាជន៍នោះថា " រាជឱរសរបស់ព្រះអគ្គមហេសី នៃព្រះបាទក្រុងពារាណសី " តពីនោះមក ភាជន៍នោះ ក៏មិនមានអន្តរាយទាំងឡាយមានភ័យអំពីទឹករលកជាដើម បៀតបៀនឡើយ បានអណ្តែតទៅតាមក្រសែទឹកគង្គា ។ ក៏សម័យនោះ មានតាបសម្នាក់ អាស្រ័យត្រកូលអ្នកចិញ្ចឹមគោ នៅក្បែរស្ទឹងគង្គា តាបសបានចុះកាន់ស្ទឹងគង្គាពីព្រលឹម បានឃើញភាជន៍នោះអណ្តែតមក ទើបស្រង់ឡើង ដោយសម្គាល់ថា ជារបស់បង្សុកូល លំដាប់នោះ ក៏បានឃើញផ្ទាំងអក្សរ និងស្នាម ព្រះរាជត្រាក្នុងភាជន៍នោះ ហើយបានស្រាយមើល ក៏ឃើញដុំសាច់នោះ ។ តាបសនោះ លុះឃើញហើយ ក៏គិតថា ប្រហែលជាគភ៌ តែហេតុដូចម្តេច ក៏គភ៌នោះមិនស្អុយ មិនរលួយ ទើបកាន់យកមកអាស្រម ហើយរក្សាទុកក្នុងទីកន្លែងដ៏ប្រសើរ ។ លំដាប់នោះ កាលកន្លងទៅកន្លះខែ ដុំសាច់នោះ ក៏បែកទៅជាពីរចំណែក តាបសឃើញហើយ ក៏រក្សាទុកក្នុងកន្លែងល្អជាងមុន ដោយកន្លងទៅកន្លះខែទៀត ដុំសាច់មួយដុំ ៗ ក៏បែកជាពកប្រាំ ដើម្បីជាប្រយោជន៍ដល់និមិត្តនៃដៃ ជើង និងសីសៈ ។ ពេលវេលាកន្លងទៅកន្លះខែទៀត ដុំសាច់

មួយដុំជាទារកដូចជាពុម្ពមាស មួយដុំទៀតជាទារិកា ។ តាបសកើតសេចក្ដីស្រឡាញ់ពេញចិត្តចំពោះទារកទាំងនោះ ដូចជាបុត្ររបស់ខ្លួន ។ ទឹកដោះបានកើតឡើងអំពីមេដៃរបស់តាបសនោះ ចាប់ពីពេលនោះមក ក៏បានទឹកដោះនោះជាភត្ត ។ តាបសនោះ បរិភោគភត្តរួចហើយ ក៏បន្តក់ទឹកដោះដាក់ក្នុងមាត់ទារកទាំងនោះ ។ ស្ថានទីទាំងអស់ ដែលតាបសចូលទៅ ប្រាកដដល់ទារកទាំងនោះ ដូចជានៅក្នុងភាជន៍កែវមណី ។ ទារកទាំងពីរប្រាសចាកឆវីយ៉ាងនេះ ។ អាចារ្យពួកខ្លះពោលថា ទារកទាំងនោះ មានឆវីលាក់កំបាំងនៃគ្នានិងគ្នាដូចខ្ទប់ទុក ។ ដោយប្រការដូច្នេះ ទារកទាំងនោះ ទើបឈ្មោះថា **លិច្ឆវី** ព្រោះទារកទាំងនោះ ប្រាសចាកសម្បុរ ឬមានសម្បុរលាក់កំបាំង ។ តាបសចិញ្ចឹមថែរក្សានូវទារកទារិកា ហើយចូលទៅក្នុងស្រុកនាពេលថ្ងៃដើម្បីភិក្ខា ។ មានការត្រឡប់មកវិញយឺតពេល ។ អ្នកចិញ្ចឹមគោទាំងឡាយ ដឹងសេចក្ដីកង្វល់នៃតាបសនោះ ទើបពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ការចិញ្ចឹមថែរក្សាទារក រមែងមានកង្វល់ច្រើនដល់អ្នកបួស សូមលោកម្ចាស់ឲ្យទារកទាំងនោះដល់ពួកខ្ញុំចុះ ពួកខ្ញុំនឹងចិញ្ចឹមថែរក្សានូវទារកទាំងនោះ លោកម្ចាស់សូមធ្វើនូវកិច្ចការរបស់លោកម្ចាស់ចុះ ។ តាបសឆ្លើយថា ល្អហើយ ៗ ។ ក្នុងថ្ងៃទីពីរ នាយគង្វាលគោទាំងឡាយ បានធ្វើផ្លូវឲ្យរាបស្មើ រោយដោយផ្កាទាំងឡាយ លើកទង់សំពត់មានគ្រឿងតូរ្យតន្ត្រីបន្លឺឡើង មកកាន់ផ្លូវដែលមិនរាបស្មើ ។ តាបសពោលថា ទារកទាំងនេះ ជាអ្នកមានបុណ្យច្រើន ។ អ្នកទាំងឡាយ ចូរឲ្យទារក

ទាំងនេះ ចម្រើនដោយសេចក្ដីមិនប្រមាទ លុះចម្រើនវ័យហើយ ចូររៀបអាវាហវិវាហៈដល់គ្នានិងគ្នា អ្នកទាំងឡាយត្រូវឲ្យព្រះរាជាទ្រង់ពេញព្រះទ័យ ដោយបញ្ចគោរស ចាប់ដីសាងនគរព្រម ទាំងអភិសេកកុមារក្នុងនគរនោះ ដូច្នេះ ទើបបានប្រគល់ទារកទាំងឡាយ ។ នាយគង្វាលគោទាំងនោះ ទទួលថា ល្អហើយ រួចនាំទារកទាំងឡាយទៅចិញ្ចឹមថែរក្សា ។ ទារកទាំងនោះអាស្រ័យសេចក្ដីចម្រើន កាលបានលេង ក៏ប្រហារក្មេងៗ ដល់កូននាយគង្វាលគោដទៃ ដោយដៃខ្លះ ជើងខ្លះ ក្នុងកន្លែងឈ្លោះគ្នា ។ ក្មេងរបស់នាយគង្វាលគោទាំងនោះ បានយំ អ្នកដែលជាមាតាបិតានិយាយថា ពួកឯងយំរឿងអ្វី ទើបប្រាប់ថា ក្មេងដែលមិនមានមាតាបិតា ដែលតាបសចិញ្ចឹមទាំងនេះ វាយពួកខ្ញុំយ៉ាងខ្លាំង ។ ពេលនោះ មាតាបិតារបស់ក្មេងទាំងនោះពោលថា ក្មេងទាំងពីរនាក់នេះ ញុំាងក្មេងដទៃឲ្យវិនាស ឲ្យដល់នូវសេចក្ដីទុក្ខ ពួកយើងមិនគប្បីសង្គ្រោះក្មេងទាំងនេះ គួរបណ្ដេញក្មេងទាំងនេះចេញទៅ ដូច្នេះ ។ បានឮថា ចាប់ពីពេលនោះមក ប្រទេសនោះទើបឈ្មោះថា វជ្ជី ។ លំដាប់នោះ នាយគង្វាលគោ ទាំងឡាយញុំាងព្រះរាជាឲ្យទ្រង់ពេញព្រះទ័យ ហើយបានទទួលប្រទេសនោះ ដោយប្រមាណ ១០០ យោជន៍ បានសាងនគរក្នុងប្រទេសនោះឯង ទើបអភិសេកកុមារដែលមានអាយុ ១៦ ឆ្នាំ ឲ្យសោយរាជ្យជាព្រះរាជា ។ បានឲ្យព្រះរាជាទ្រង់ អភិសេកនឹងក្មេងស្រីនោះ ហើយធ្វើកតិកាថា ពួកយើងមិនគប្បីនាំក្មេងស្រីមកពីខាងក្រៅ មិនគប្បីឲ្យក្មេងប្រុសពីត្រកូលនេះ ដល់អ្នកណា

ដូច្នេះ ៗ ដោយការនៅរួមគ្នាគ្រាដំបូង គេទាំងពីរនាក់នុ៎ះ មានបុត្រក្មេះ ពីរនាក់ គឺ បុត្រីមួយ បុត្រាមួយ ដោយប្រការដូច្នេះ ទើបមានបុត្រក្មេះ ដល់ទៅ ១៦ ដង ៗ

បន្ទាប់ពីនោះ ទារកទាំងនោះ ចម្រើនឡើងតាមលំដាប់ ទើបពង្រីក នគរដែលមិនទាន់គ្រប់គ្រាន់ ដើម្បីធ្វើជាអាវាម ឧទ្យាន ស្ថានទីនៅ និង បរិវារសម្បត្តិដល់ទៅ ៣ ដង ដោយឆ្ងាយពីគ្នាម្តង ១ គាវុត ៗ នគរនោះ ទើបមានឈ្មោះថា **វេសាលី** ព្រោះជានគរដែលមានសេចក្តីចម្រើនទូលំ-ទូលាយរឿយ ៗ ៗ ដោយហេតុនោះ ទើបលោកពោលថា **វេសាលិយំ** សេចក្តីថា ជិតនគរដែលមានឈ្មោះយ៉ាងនេះ ៗ

បទថា **ពហិនគរេ** មានសេចក្តីថា ខាងក្រៅនគរ គឺ មិនមែន ខាងក្នុងព្រះនគរ ដូចអម្ពបាលិវ័ន ៗ នេះគឺ ដងព្រៃខាងក្រៅព្រះនគរ ដូចជីវកម្ពវ័ន ព្រោះហេតុនោះ លោកទើបពោលថា ខាងក្រៅព្រះនគរ ៗ

បទថា **អបរបុរេ** មានសេចក្តីថា ផ្ទៃយទីងទិសខាងកើត គឺ ក្នុង ទិសខាងលិច ៗ

បទថា **វនសណ្ឌេ** សេចក្តីថា បានឮថា ដងព្រៃនោះ នៅក្នុងទី ប្រមាណ ១ គាវុត ក្នុងទិសខាងលិចព្រះនគរ ៗ ក្នុងដងព្រៃនោះ មនុស្ស ទាំងឡាយ ធ្វើព្រះគន្ធកុដិថ្វាយដល់ព្រះមានព្រះភាគ ជុំវិញព្រះគន្ធកុដិនោះ ធ្វើទីកន្លែងសម្រាកពេលយប់ និងកន្លែងសម្រាកពេលថ្ងៃ ទីចង្ក្រម ទីសំងំ កុដិ មណ្ឌបជាដើម ថ្វាយដល់ព្រះភិក្ខុសង្ឃទាំងឡាយ ៗ ព្រះមានព្រះភាគ

ទ្រង់ប្រថាប់គង់នៅក្នុងដងព្រៃនោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងដងព្រៃទិសខាងលិច ។ ពាក្យថា **សុនក្ខត្ត** នោះ ជាឈ្មោះរបស់សុនក្ខត្តៈនោះ ក៏សុនក្ខត្តនោះ ហៅថា **លិច្ឆវីបុត្រ** ព្រោះគេជាបុត្ររបស់លិច្ឆវីទាំងឡាយ ។ បទថា **អចិរប្បក្កន្តោ** មានសេចក្តីថា សឹកមកជាគ្រហស្ថកន្លងទៅមិនយូរប៉ុន្មាន ។ បទថា **បរិសតិ** បានដល់ កណ្តាលបរិស័ទ ។ កុសលកម្មបថ ១០ ឈ្មោះថា មនុស្សធម៌ ក្នុងបទនេះថា **ឧត្តរិមនុស្សធម្មា** សុនក្ខត្តៈ មិនអាចនឹងបដិសេធកុសលកម្មបថ ១០ នោះ ។ ព្រោះហេតុអ្វី ព្រោះខ្លាចអំពីពាក្យតិះដៀល ។ ព្រោះថា ក្នុងក្រុងវេសាលី មនុស្សចំនួនច្រើនជ្រះថ្លាហើយក្នុងព្រះរតនត្រ័យ រាប់អានព្រះពុទ្ធ រាប់អានព្រះធម៌ រាប់អានព្រះសង្ឃ មនុស្សទាំងនោះ កាលបើសុនក្ខត្តៈពោលថា សូម្បីត្រឹមតែកុសលកម្មបថ ១០ របស់ព្រះសមណគោតមមិនមាន ដូច្នេះ ក៏នឹងពោលពាក្យជាដើមថា លោកបានឃើញព្រះមានព្រះភាគ ទ្រង់សម្លាប់សត្វក្នុងទីណា ព្រះមានព្រះភាគ ទ្រង់កាន់យករបស់ដែលគេមិនបានឲ្យក្នុងទីណា នឹងគប្បីពោលថា លោកមិនស្គាល់ប្រមាណរបស់ខ្លួន លោកស៊ីថ្នាំនិងជុំគ្រូស ដោយគិតថា ធ្មេញរបស់យើងទាំងឡាយមានឬ លោកព្យាយាមដើម្បីនឹងចាប់កន្ទុយពស់ លោកប្រាថ្នាដើម្បី នឹងលេងក្បួងផ្កាក្នុងធ្មេញណារ ពួកយើងនឹងញាំងធ្មេញទាំងឡាយរបស់លោក ឲ្យរបូតធ្លាក់ចុះពីមាត់ ដូច្នេះ ។ គេមិនអាចនឹងពោលយ៉ាងនេះ ព្រោះខ្លាចការតិះដៀលនោះ ។ ក៏គេកាលបើនឹងបដិសេធការសម្រេចគុណវិសេស ក្រៅពីឧត្តរិមនុស្សធម៌នោះ ទើប

ពោលថា ញាណទស្សនវិសេស ដែលធ្វើខ្លួនឲ្យជាព្រះអរិយៈ ក្រៅពីមនុស្សធម៌ ដូច្នេះ ។ ក្នុងបទនោះ ឈ្មោះថា **អលមរិយ** ព្រោះគួរដឹងព្រះអរិយៈ អធិប្បាយថា ដែលអាចធ្វើខ្លួនឲ្យជា **ព្រះអរិយ** ។ ញាណទស្សនៈនោះឯង ឈ្មោះថា ញាណទស្សនវិសេស ញាណទស្សនៈនោះផង ដែលគួរដល់ព្រះអរិយៈនោះផង ព្រោះដូច្នោះ ទើបឈ្មោះថា **អលមរិយញ្ញាណទស្សនវិសេស** ទិព្វចក្ខុក្តី វិបស្សនាក្តី មគ្គក្តី ផលក្តី បច្ចវេក្ខណញាណក្តី សព្វញ្ញុតញ្ញាណក្តី ហៅថា **ញាណទស្សនៈ** ។ ពិតហើយ ទិព្វចក្ខុ ឈ្មោះថា ញាណទស្សនៈ ក្នុងបទនេះថា ជាអ្នកមិនប្រមាទ ហើយរមែងសម្រេចញាណទស្សនៈ ។ ក៏វិបស្សនាញាណ ឈ្មោះថា ញាណទស្សនៈ ក្នុងបទនេះថា នាំទៅចំពោះ បង្អោនទៅចំពោះ នូវចិត្តដើម្បីញាណទស្សនៈ ។ មគ្គ ឈ្មោះថា ញាណទស្សនៈ ក្នុងបទនេះថា គេទាំងនោះ មិនគួរដើម្បីញាណទស្សនៈ ដើម្បីត្រាស់ដឹងដ៏កំពូល ។ ផលញាណ ឈ្មោះថា ញាណទស្សនៈ ក្នុងបទនេះថា ញាណទស្សនវិសេស ដែលគួរដល់ព្រះអរិយៈ ក្រៅពីឧត្តរិមនុស្សធម៌នេះ ដែលនៅជាសុខ បានសម្រេចហើយទេដឹង ។ បច្ចវេក្ខណញាណ ឈ្មោះថា **ញាណទស្សនៈ** ក្នុងបទនេះថា ក៏ញាណទស្សនៈ បានកើតឡើងដល់យើងហើយ វិមុត្តិរបស់យើងមិនកម្រើក ជាតិនេះ ជាជាតិចុងក្រោយ ឥឡូវនេះ ភពថ្មីមិនមាន ។ សព្វញ្ញុតញ្ញាណ ឈ្មោះថា ញាណទស្សនៈ ក្នុងបទនេះថា ក៏ញាណទស្សនៈរបស់យើង បានកើតឡើងហើយ អាឡារតាបសកាឡាមគោត្រ បានអនិច្ចកម្ម ៧ ថ្ងៃហើយ ។ ចំណែកលោ-

កុត្តរមគ្គ លោកបំណងយកក្នុងទីនេះ ។ ក៏សុនក្ខត្តៈនោះ បានបដិសេធលោកុត្តរមគ្គ របស់ព្រះមានព្រះភាគ ។

ហាមអាចារ្យដោយបទនេះថា **តក្កបរិយាហតំ** ។ ន័យថា គេមានបរិវិតក្កៈយ៉ាងនេះថា ធម្មតាព្រះសមណគោតម ទ្រង់មិនចូលទៅរកអាចារ្យទាំងឡាយ ហើយកាន់យកលំដាប់ធម៌ដ៏ល្អិតទេ ក៏ព្រះសមណគោតម ទ្រង់សម្តែងធម៌ដោយការត្រិះរិះ គឺ ទ្រង់ត្រិះរិះ ទ្រង់ពិចារណា ហើយសម្តែងធម៌ ទ្រង់ត្រិះរិះថា នឹងជាយ៉ាងនេះ នឹងជាយ៉ាងនោះ ដូច្នេះ ។ រមែងទទួលស្គាល់លោកិយបញ្ញា របស់ព្រះសមណគោតមនុ៎ះ ដោយបទនេះថា **វីមំសានុចរិតំ** ។

ព្រះសមណគោតមទ្រង់មានបញ្ញា ។ ព្រះសមណគោតមនោះ ទ្រង់ញ៉ាំងព្រះវិមំសា ដែលប្រៀបដូចជាអាវុធរបស់ព្រះឥន្ទ ពោលគឺ បញ្ញានោះឲ្យត្រាច់ទៅខាងនោះខាងនេះថា នឹងប្រព្រឹត្តទៅយ៉ាងនោះ នឹងប្រព្រឹត្តទៅយ៉ាងនេះ រមែងទ្រង់សម្តែងធម៌ស្របតាមព្រះវិមំសា ។ ហាមការដែលព្រះសមណគោតមនោះ ទ្រង់ជាក់ច្បាស់ក្នុងធម៌ទាំងឡាយ ដោយបទនេះថា **សយំ បដិភាណំ** ។ ក៏សុនក្ខត្តៈនោះ មានការគិតយ៉ាងនេះថា វិបស្សនាឬមគ្គ ឬផល ដែលជាលំដាប់នៃធម៌ដ៏ល្អិត របស់ព្រះសមណគោតមនោះឈ្មោះថា រមែងមិនជាក់ច្បាស់ ឯព្រះសមណគោតមនេះ ទ្រង់បានទូវបរិស័ទ ៤ វណ្ណៈ រមែងហែហម ព្រះអង្គដូចស្តេចចក្រពត្តិ ក៏ឯព្រះទន្តរបស់ព្រះអង្គរៀបស្អិតល្អ ព្រះជីវ្ហាទន់ ព្រះសូរសៀងពីរោះ ព្រះវាចា មិនមានទោស

ព្រះអង្គទ្រង់កាន់យករបស់ដែលប្រាកដដល់ទេវតា ហើយត្រាស់ព្រះតម្រាស់តាមការឈ្លាសវៃរបស់ព្រះអង្គ ទ្រង់ញុំាងមហាជនឲ្យត្រេកអរ ។ បទថា **យស្ស ច ខ្វាស្សត្ថាយ ធម្មោ ទេសិតោ** មានសេចក្តីថា ក៏ធម៌នេះ ព្រះអង្គទ្រង់សម្តែងដើម្បីប្រយោជន៍ដល់គុណវិសេសណា ។ យ៉ាងណា គឺ អសុភកម្មដ្ឋាន ដើម្បីប្រយោជន៍ដល់ការកម្ចាត់រាគៈ , មេត្តាភាវនា ដើម្បីប្រយោជន៍ដល់ការកម្ចាត់ទោសៈ ។ ធម៌ ៥ ប្រការ ដើម្បី ប្រយោជន៍ដល់ការកម្ចាត់មោហៈ អនាបានស្សតិដើម្បីកម្ចាត់វិតក្កៈ ។

បទថា **សោ និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ** សេចក្តីថា សុនក្ខត្តៈពោលថា ធម៌នោះរមែងនាំចេញ គឺ ប្រព្រឹត្តទៅដើម្បីការអស់ទៅនៃវដ្តទុក្ខដោយប្រពៃ គឺ ដោយហេតុ ដោយន័យ ដោយការណ៍ ដល់អ្នកបដិបត្តិតាមធម៌ ដែលទ្រង់សម្តែងនោះ គឺ ញុំាងប្រយោជន៍នោះឲ្យសម្រេច ។ តែសុនក្ខត្តៈ មិនពោលដល់សេចក្តីនោះ ដោយអធ្យាស្រ័យរបស់ខ្លួន ។ ទើបពោលយ៉ាងនេះថា ក៏ធម៌របស់ព្រះពុទ្ធទាំងឡាយ មិនជាគ្រឿងនាំចេញចាកទុក្ខ ដូច្នេះ ។ តែមិនអាចនឹងពោលបាន ព្រោះហេតុអ្វី ។ ព្រោះខ្លាចពាក្យតិះដៀល ។

[១៦០] ពិតណាស់ ក្នុងក្រុងវេសាលី មានឧបាសកជាសោតាបន្នសកទាគាមី និងអនាគាមីចំនួនច្រើន ។ ឧបាសកទាំងនោះ គប្បីពោលថា នែ ! សុនក្ខត្តៈលោកពោលថា ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ មិនមែនជាគ្រឿងនាំចេញចាកទុក្ខបាន ដូចម្តេច ។ ប្រសិនបើជាធម៌នេះ នាំ

*ចេញចាកទុក្ខមិនបាន ព្រោះហេតុអ្វី ក្នុងនគរនេះ ឧបាសកទាំងនោះ ជាសោតាបន្នប្រមាណប៉ុណ្ណោះ , ជាសកទាគាមីប្រមាណប៉ុណ្ណោះ , ជាអនាគាមីប្រមាណប៉ុណ្ណោះ ។ ឧបាសកទាំងនោះ គប្បីធ្វើការជំទាស់ ដោយន័យដែលពោលហើយក្នុងបទមុន ។ សុនក្ខត្តៈនោះ កាលមិនអាចដើម្បីនឹងពោលថា ធម៌នេះមិនមែនជាគ្រឿងនាំចេញចាកទុក្ខបាន ព្រោះខ្លាចត្រូវពាក្យតិះដៀលនេះ ទើបពោលថា ធម៌របស់ព្រះសមណគោតមនោះ មិនជាមោឃៈ រមែងនាំសត្វចេញចាកទុក្ខបាន ដូចកំណាត់ឈើដែលគេបោះទុកដោយមិនបានដុត តែព្រះសមណគោតមនោះ មិនមានអ្វីក្នុងខាងក្នុងឡើយ ដូច្នេះ ។*

*បទថា **អស្សោសិ ខោ** សេចក្តីថា កាលសុនក្ខត្តៈពោលយ៉ាងនេះ ក្នុងចំណោមបរិស័ទនុ៎ះ ៗ ក្នុងត្រកូលទាំងឡាយ មានត្រកូលព្រាហ្មណ៍ និងត្រកូលសេដ្ឋីជាដើម ក្នុងព្រះនគរវេសាលី ព្រះសារីបុត្រ បានស្តាប់ពាក្យនោះហើយ មិនបដិសេធ ព្រោះហេតុអ្វី ព្រោះលោកមានសេចក្តីករុណា ។ ឮថា ព្រះសារីបុត្រនោះ មានការត្រិះរិះយ៉ាងនេះ សុនក្ខត្តៈនេះ រសាប់រសល់ដោយអំណាចនៃសេចក្តីក្រោធ ដូចដើមឫស្សីត្រូវដុត និងដូចអំបិល ដែលត្រូវដាក់ក្នុងចង្ក្រានភ្លើង ក៏សុនក្ខត្តៈនោះ កាលបើយើងជំទាស់ហើយ នឹងចងអាឃាតចំពោះយើង បើដូច្នោះ សុនក្ខត្តៈនោះ ក៏នឹងចងអាឃាតដែលជាការៈយ៉ាងក្រៃលែង ក្នុងជនទាំងពីរ គឺ ព្រះតថាគតហើយនឹងយើង ព្រោះដូច្នោះ ទើបមិនជំទាស់ ព្រោះលោកមានសេចក្តីករុណា ។ម្យ៉ាងទៀត ព្រះសារីបុត្រនោះ មានសេក្តីត្រិះរិះយ៉ាងនេះថា មនុស្សការពោលតិះដៀលព្រះពុទ្ធ*

ទាំងឡាយ ក៏ដូចជាការដាក់ទោសក្នុងព្រះច័ន្ទពេញវង់ ដូច្នោះ អ្នកណាទៅនឹងកាន់យកពាក្យសំដីរបស់សុនក្ខត្តៈនេះ គេនឹងឯង លុះអស់ទឹកមាត់ មាត់ស្ងួតហើយ នឹងបញ្ឈប់ការពោលពាក្យតិះដៀល ព្រោះដូច្នោះ ព្រះសារីបុត្រទើបមិនជំទាស់ ព្រោះសេចក្តីករុណានេះ ។

បទថា **បិណ្ឌបាតប្បដិក្កន្តោ** សេចក្តីថា ត្រឡប់ពីការស្វែងរកបិណ្ឌបាតហើយ ។

[១៦១] បទថា **កោធនោ** ជាមនុស្សក្រោធ គឺ ជាមនុស្សក្រោតក្រោធ ។

បទថា **មោឃបុរិសោ** សេចក្តីថា បុរសទទេ ពិតណាស់ ព្រះពុទ្ធទាំងឡាយ ហៅបុរសអ្នកមិនមានឧបនិស្ស័យនៃមគ្គ និងផលក្នុងអត្តភាពនោះថា មោឃបុរស ។ កាលបើឧបនិស្ស័យសូម្បីមានតែមគ្គ និងផលមិនមានក្នុងខណៈនោះ ក៏ហៅថា មោឃបុរសដូចគ្នា ។ តែសុនក្ខត្តៈនេះបានកាត់ផ្តាច់ឧបនិស្ស័យនៃមគ្គ និងផលទាំងឡាយ ក្នុងអត្តភាពនោះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅសុនក្ខត្តៈនោះថា មោឃបុរស ។

បទថា **កោធា ច បនស្ស ឯសា វាចា ភាសិតា** មានសេចក្តីថា ក៏វាចារបស់សុនក្ខត្តៈនោះ បានពោលហើយដោយសេចក្តីក្រោធ ។ ក៏ព្រោះហេតុអ្វីសុនក្ខត្តៈនោះ ទើបក្រោធនឹងព្រះមានព្រះភាគ ។ ព្រោះក្នុងកាលមុនសុនក្ខត្តៈនេះ ចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរដល់ការបរិកម្មទិព្វចក្ខុ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់បានត្រាស់ដល់សុនក្ខត្តៈនោះ ។ សុនក្ខត្តៈនោះញុំាង ទិព្វចក្ខុឲ្យកើតឡើង ព្រោះចម្រើនអាលោកសញ្ញា កាល

ក្រឡេកមើលទេវលោក បានឃើញទេវបុត្រទាំងឡាយ និងទេពធីតាទាំងឡាយ ដែលកំពុងសោយទិព្វសម្បត្តិក្នុងនន្ទវ័ន ចិត្តលតាវ័ន បារុសកវ័ន និងមិស្សកវ័ន ជាអ្នកប្រាថ្នានឹងស្តាប់សំឡេងទេវបុត្រ និងទេពធីតាទាំងនោះ ដែលតាំងនៅក្នុងអត្តភាព សម្បត្តិបែបនោះថា តើមានសំឡេងពីរោះយ៉ាងណាហ្ន៎ ! ទើបចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរដល់ការបរិកម្មទិព្វសោតធាតុ ។ តែព្រះមានព្រះភាគទ្រង់ជ្រាបថា សុនក្ខត្តៈនេះ មិនមានឧបនិស្ស័យនៃទិព្វសោតធាតុ ទើបទ្រង់មិនត្រាស់ប្រាប់ការបរិកម្មដល់គេ ។ ព្រោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងមិនត្រាស់ បរិកម្មដល់អ្នកប្រាសចាកឧបនិស្ស័យ ។ គេបានចងអាឃាតនឹងព្រះមានព្រះភាគ ហើយគិតថា យើងបានទូលសួរដល់ការបរិកម្មទិព្វ ចក្ខុក្នុងពេលមុន នឹងព្រះសមណគោតម ព្រះអង្គទ្រង់ត្រាស់ដល់យើងថា ទិព្វចក្ខុបរិកម្មនោះ ចូរសម្រេច ឬថា ចូរកុំសម្រេច តែយើងញ៉ាំងទិព្វចក្ខុបរិកម្មនោះឲ្យកើតឡើង ដោយការធ្វើរបស់បុរសចំពោះខ្លួន ហើយទើបទូលសួរដល់ការបរិកម្មទិព្វសោតធាតុ ព្រះអង្គមិនត្រាស់ប្រាប់ការបរិកម្មទិព្វសោតធាតុនោះដល់យើង ប្រហែលជាព្រះអង្គនឹងមានព្រះតម្រិះយ៉ាងនេះថា សុនក្ខត្តៈនេះបួសពីរាជត្រកូល ញ៉ាំងទិព្វ-ចក្ខុញាណឲ្យកើតឡើង ហើយញ៉ាំងទិព្វសោតញាណ ឲ្យកើតឡើង ញ៉ាំងចេតោបរិយញ្ញាណឲ្យកើត ញ៉ាំងញាណក្នុងការអស់ទៅនៃអាសវៈទាំងឡាយឲ្យកើតហើយនឹងស្មើយើងពិត ព្រះអង្គទើបមិនត្រាស់ប្រាប់ដល់ យើងដោយអំណាចនៃការប្រណែន និងការកំណាញ់ ដូច្នេះ ។ សុនក្ខត្តៈ ចងអាឃាត

ដោយប្រមាណយ៉ាងក្រៃលែង ហើយចោលសំពត់កាសាយៈទាំងឡាយ សូម្បីដល់កាលជាគ្រហស្ថ ក៏មិនព្រមនៅស្ងៀម ។ តែគេត្រាច់ទៅ ពោលមួលបង្កាច់ព្រះទសពលដោយសេចក្តីទទេ មិនពិត ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា វាចានោះ គេពោលព្រោះសេចក្តីក្រោធ ដូច្នេះ ។

បទថា **វណ្ណោ ហេសោ សារីបុត្ត** មានសេចក្តីថា ម្នាលសារីបុត្ត តថាគតបំពេញបារមីទាំងឡាយអស់ ៤ អសង្ខេយ្យកម្រៃ ១ សែនកប្ប បានបំពេញសេចក្តីព្យាយាម ដើម្បីប្រយោជន៍នៃបារមីទាំងនោះ ធម្មទេសនារបស់តថាគត នឹងជាគ្រឿងនាំសត្វចេញចាកទុក្ខបាន ព្រោះដូច្នោះ អ្នកណាពោលយ៉ាងនេះ អ្នកនោះឈ្មោះថា ពោលសរសើរតថាគត ដោយពិត ។ ព្រះអង្គទ្រង់សម្តែងថា ម្នាលសារីបុត្រ ក៏ការសរសើរនោះជាគុណ នោះជាគុណរបស់តថាគត ។

[១៦២] ទ្រង់សម្តែងអ្វី ដោយបទជាដើមថា **អយម្បិ ហិ នាម សារីបុត្ត** ដូច្នេះ ។ ទ្រង់ត្រាស់ដល់ឧត្តរិមនុស្សធម៌ ដែលសុនក្ខត្តៈបដិសេធមាននៅក្នុងព្រះអង្គ ។ បានឮថា ព្រះមានព្រះភាគទ្រង់ប្រារព្ធទេសនានេះ ដោយន័យថា **អយម្បិ ហិ នាម សារីបុត្ត** ជាដើម ដើម្បីទ្រង់សម្តែងអត្ថនោះថា ម្នាលសារីបុត្រ សុនក្ខត្តៈនេះ ជាមោឃបុរស រមែងពោលថា ឧត្តរិមនុស្សធម៌របស់តថាគត មិនមាន ដូច្នេះ ។ ឯតថាគត មានសព្វញ្ញុតញ្ញាណ មានឥទ្ធិវិធញ្ញាណ មានទិព្វសោតធាតុញ្ញាណ មានចេតោបរិយញ្ញាណ មានទសពលញ្ញាណ មានចតុវេសារជ្ជញ្ញាណ មានញាណដែល

មិនញាប់ញ័រក្នុងបរិស័ទទាំង ៨ មានញាណកំណត់កំណើត ៤ មានញាណកំណត់គតិ ៥ ក៏ធម៌ទាំងនោះសូម្បីទាំងអស់ ក៏គឺ ឧត្តរិមនុស្សធម៌នោះឯង ក៏ធម្មតាសូម្បីត្រឹមតែថា ការយល់តាមធម៌ដែល អាចដឹងឧត្តរិមនុស្សធម៌ សូម្បីមួយចំណែកក្នុងបណ្តាឧត្តរិមនុស្សធម៌បែបនេះ នឹងមិនមានដល់មោឃបុរសនោះ ដូច្នេះ ។

[១៦៣-១៦៥] ក្នុងបទទាំងនោះ ឈ្មោះថា **អន្វយ** ព្រោះអត្ថថា យល់តាម អធិប្បាយថា ដឹង គឺ ដឹងតាម ។ ការយល់តាមធម៌ឈ្មោះ **ធម្មន្វយ** ។ នោះជាឈ្មោះនៃ បញ្ញាជាគ្រឿងដឹងធម៌ មានសព្វញ្ញុតញ្ញាណជាដើមនោះៗ ទ្រង់សម្តែងថា សូម្បី **ធម្មន្វយ** នឹងមិនមានដល់មោឃបុរសនោះ ដើម្បីឲ្យដឹងឧត្តរិមនុស្សធម៌ ពោលគឺ សព្វញ្ញុតញ្ញាណ សូម្បីបែបនេះ របស់តថាគតដែលមានហើយនោះថា មានដោយបទថា **ឥតិបិ សោ ភគវា** ជាដើម ។ គប្បីជ្រាបការប្រកបយ៉ាងនេះ សូម្បីក្នុងញាណទាំងឡាយ មានឥទ្ធិវិធញ្ញាណជាដើម ។

[១៦៦] ម្យ៉ាងទៀត គប្បីពោលវិជ្ជា ៣ ក្នុងលំដាប់នៃចេតោបរិយញ្ញាណ ក្នុងបទនោះដោយពិត ។ សូម្បីដូច្នេះ កាលបើវិជ្ជា ៣ ទាំងនោះ ពោលហើយ ធម្មតាទសពលញ្ញាណជាន់ខ្ពស់រមែងបរិបូរ ព្រោះដូច្នោះ ទើបទ្រង់មិនត្រាស់វិជ្ជា ៣ នោះ ទ្រង់សម្តែងធ្វើឲ្យបរិបូរដោយទសពលញ្ញាណរបស់ព្រះតថាគត ទើបទ្រង់ត្រាស់ថា **ទស ខោ បនិមានិ សារីបុត្ត** ជាដើម ។ បណ្តាបទទាំងនោះ បទថា **តថាគតពលានិ** បានដល់ កម្លាំងរបស់ព្រះតថាគត

ប៉ុណ្ណោះ មិនទូទៅដល់បុគ្គលពួកដទៃ គឺ កម្លាំងដែលមកហើយដោយប្រការដែលកម្លាំងរបស់ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ដែលបានមកដោយបុញ្ញ-សម្បត្តិ និងឥស្សរិយសម្បត្តិ ។ ក្នុងកម្លាំងទាំងនោះ កម្លាំងរបស់ព្រះតថាគតមានពីរ យ៉ាងគឺ ៖ **កាយពលៈ ១ ញាណពលៈ ១** ។

ក្នុងពលៈទាំងនោះ **កាយពលៈ** គប្បីជ្រាបដោយទំនងនៃត្រកូលដំរី ។ សមដូចគាថាប្រព័ន្ធ ដែលបុរាណាចារ្យទាំងឡាយពោលហើយ យ៉ាងនេះថា ៖

ត្រកូលដំរី ១០ ត្រកូលនេះ គឺ កាឡាវកៈ ១ , គង្គេយ្យៈ ១ , បណ្ឌរៈ ១ , តម្ពៈ ១ , បិង្គលៈ ១ , គន្ធៈ ១ , មង្គលៈ ១ , ហេមៈ ១ , ឧបោសថ ១ , និងឆទ្ទន្តៈ ១ ។ ក៏ត្រកូលនៃដំរី ១០ ត្រកូល ទាំងនេះ ។ ក្នុងត្រកូលដំរីទាំងនោះ គប្បីឃើញត្រកូលដំរីធម្មតាថា កាឡាវកៈ ។ កម្លាំងកាយរបស់បុរស ១០ នាក់ ស្មើនឹងកម្លាំងដំរីកាឡាវកៈ ១ ។

| | | |
|---|---|---|
| កម្លាំងដំរី កាឡាវកៈ | ១០ ស្មើនឹងកម្លាំងដំរី គង្គេយ្យៈ | ១ |
| កម្លាំងដំរី គង្គេយ្យៈ | ១០ ស្មើនឹងកម្លាំងដំរី បណ្ឌរៈ | ១ |
| កម្លាំងដំរី បណ្ឌរៈ | ១០ ស្មើនឹងកម្លាំងដំរី តម្ពៈ | ១ |
| កម្លាំងដំរី តម្ពៈ | ១០ ស្មើនឹងកម្លាំងដំរី បិង្គលៈ | ១ |
| កម្លាំងដំរី បិង្គលៈ | ១០ ស្មើនឹងកម្លាំងដំរី គន្ធៈ | ១ |
| កម្លាំងដំរី គន្ធៈ | ១០ ស្មើនឹងកម្លាំងដំរី មង្គលៈ | ១ |
| កម្លាំងដំរី មង្គលៈ | ១០ ស្មើនឹងកម្លាំងដំរី ហេមវតៈ | ១ |

កម្លាំងដំរី ហេមវតៈ ១០ ស្មើនឹងកម្លាំងដំរី ឧបោសថ ១

កម្លាំងដំរី ឧបោសថ ១០ ស្មើនឹងកម្លាំងដំរី ឆទ្ទន្តៈ ១

កម្លាំងដំរីឆទ្ទន្តៈ ១០ ស្មើនឹងកម្លាំងព្រះតថាគត ១

ព្រះអង្គ ។

តថាគតពលៈនេះ នោះហៅថា កម្លាំងរួមរបស់ព្រះនរាយណៈ ខ្លះ ។ **កម្លាំងនេះ នោះជាកម្លាំងដំរី ១០០០ កោដិ ដោយការរាប់ដំរីធម្មតា ជាកម្លាំងរបស់បុរស ១០ ពាន់កោដិ ដោយការរាប់បុរស ។ នេះជាកម្លាំងកាយព្រះតថាគត ។ ចំណែកញាណពលៈ ៖**

មានមកហើយក្នុងបាលីនោះឯង ញាណច្រើនពាន់ សូម្បីពួកដទៃយ៉ាងនេះ គឺ ទសពលញ្ញាណ ចតុវេសារជ្ជញ្ញាណ ញាណដែលទ្រង់មិនញាប់ញ័រក្នុងបរិស័ទ ៨ ពួក , ញាណកំណត់កំណើត ៤ , ញាណកំណត់គតិ ៥ , ញាណ ៧៣ , ញាណ ៧៧ , ដែលមាននៅក្នុង សំយុត្តនិកាយនោះ ឈ្មោះថា **ញាណពលៈ** ។ ញាណពលៈនោះ លោកបំណងយកហើយសូម្បីក្នុងទីនេះ ។ **ញាណ** លោកពោលថា **ពលៈ** ដោយអត្ថថា មិនញាប់ញ័រ និងអត្ថថា គាំទ្រ ។ បទថា **យេហិ ពលេហិ សមន្នាគតោ** សេចក្តីថា ទ្រង់ដល់ គឺ ទ្រង់ដល់ព្រមដោយ ញាណពលៈ ១០ ប្រការ ។

បទថា **អាសភណ្ឌានំ** គឺ ឋានៈដ៏ប្រសើរបំផុត គឺ ឋានៈឧត្តម ។ អធិប្បាយថា ឋានៈនៃព្រះពុទ្ធក្នុងកាលមុន ដែលជាបុរសដឹកនាំដ៏ប្រសើរ

ខ្ពង់ខ្ពស់ ។ មួយវិញទៀត មេហ្វូងគោ ក្នុងគោរាប់រយឈ្មោះថា ឧសភៈ មេហ្វូងគោ ១០០០ ឈ្មោះថា វសភៈ , ប្រការមួយទៀត មេហ្វូងគោ ក្នុងក្រោលគោ ១០០ ក្បាល ឈ្មោះថា ឧសភៈ , មេហ្វូងគោ ក្នុងក្រោលគោ ១០០០ ក្បាល ឈ្មោះថា វសភៈ , គោដែលជាមេហ្វូង ក្នុងគោទាំងពួងជាអ្នកនាំហ្វូងគោទាំងអស់ (សសុទ្ធ) គួរជ្រះថ្លា នាំការៈច្រើន មិនញាប់ញ័រដោយសំឡេងរន្ទះ ១០០ ដង ឈ្មោះថា និសភៈ , និសភៈនុ៎ះ លោកសំដៅយកឧសភៈក្នុងទីនេះ ។ ពិតណាស់ ពាក្យនេះ ជាពាក្យដោយផ្លូវអមរបស់ឧសភៈនោះ ។ ឈ្មោះថា អាសភៈ ព្រោះអត្ថរបស់ឧសភៈ ។ បទថា **ឋានំ** សេចក្តីថា ក៏ឋានៈដែលឈូសទូវផែនដីដោយជើងទាំងបួន ហើយមិនញាប់-ញ័រ នេះដូចជាគោឧសភៈ ព្រោះដូច្នោះ ទើបឈ្មោះថា ឧសភៈ ។ គោឧសភៈ ពោលគឺ និសភៈ ដល់ព្រមដោយកម្លាំងនៃគោឧសភៈ ឈូសទូវផែនដីដោយជើងទាំងបួន ហើយឈរនៅដោយការមិនញាប់ញ័រ យ៉ាងណាសូម្បីព្រះតថាគត ក៏ដូច្នោះដូចគ្នា ទ្រង់ដល់ព្រមដោយកម្លាំងរបស់ព្រះតថាគត ១០ ប្រការ ទ្រង់ឈូសទូវផែនដី គឺ បរិស័ទ ៨ ដោយព្រះបាទ គឺ វេសារជ្ជៈ ៤ ប្រការ ហើយមិនញាប់ញ័រចំពោះសត្រូវ គឺ បច្ចាមិត្រណា ៗ ក្នុងលោកព្រមទាំងទេវលោក ទ្រង់តាំងនៅដោយមិនញាប់ញ័រ ។ កាលបើទ្រង់ស្ថិតនៅយ៉ាងនោះ ឈ្មោះថា ទ្រង់ប្រកាស គឺ ទ្រង់ចូលដល់ឋានៈនៃភាពជាអ្នកដឹកនាំ គឺ ទ្រង់លើកទុកចំពោះព្រះអង្គឯង រមែងមិនប្រចក្ស ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា **អាសភណ្ឌានំ បដិជានាតិ** ។ បទថា **បរិសាសុ** គឺ ក្នុង

បរិស័ទ ៨ ។ បទថា **សីហនាទំ នទតិ** សេចក្ដីថា ទ្រង់បន្លឺដល់ការបន្លឺដ៏ប្រសើរបំផុត គឺ មិនមានអ្នកណាខ្វាច ឬទ្រង់បន្លឺដល់នូវការបន្លឺ ដែលដូចជាការបន្លឺរបស់សីហៈ ។ សេចក្ដីនេះ គប្បីសម្ដែងដោយសីហនាទសូត្រ ។ ប្រការមួយទៀត រាជសីហ៍ហៅថា សីហៈ ព្រោះគ្របសង្កត់ និងព្រោះសម្លាប់យ៉ាងណា ព្រះតថាគតហៅថា សីហៈ ព្រោះគ្របសង្កត់លោកធម៌ទាំងឡាយ និងព្រោះកម្ចាត់លទ្ធិរបស់សាស្ដាដទៃ ៗ ដូច្នោះ ។ ការបន្លឺរបស់សីហៈតាមដែលពោលមកហើយយ៉ាងនេះ ឈ្មោះថា សីហនាទ ។ ក្នុងបទនោះមានអធិប្បាយថា សីហៈ ដល់ព្រមដោយកម្លាំងរបស់សីហៈ ហើយក្លាហានប្រាសចាកការព្រឺរោម រមែងធ្វើការបន្លឺសីហនាទក្នុងទីទាំងពួង យ៉ាងណាសូម្បីសីហៈ គឺ ព្រះតថាគត ក៏ដល់ព្រមដោយកម្លាំងរបស់ព្រះតថាគតទាំងឡាយ ហើយក្លាហាន ប្រាសចាកការព្រឺរោម ទ្រង់បន្លឺសីហនាទដែលដល់ព្រមដោយការទូលំទូលាយនៃទេសនា មានវិធីផ្សេងៗ ដោយន័យជាដើមថា រូបដោយប្រការដូច្នេះ ក្នុងបរិស័ទ ៨ ដូច្នេះ ។ ព្រោះហេតុនោះ ទើបត្រាស់ថា ទ្រង់បន្លឺសីហនាទក្នុងបរិស័ទទាំងឡាយ ដូច្នេះ ។ បទថា **ព្រហ្មចក្កំ បវត្តេតិ** នេះ បទថា ព្រហ្មំ បានដល់ ប្រសើរបំផុត គឺ ឧត្ដម ល្អស្អាត ។ ក៏ស័ព្ទនៃចក្រនេះ

*រមែងប្រាកដក្នុង សម្បត្តិ លក្ខណៈ អង្គនៃរថ ឥរិយាបថ*
*ទាន រតនៈ និងក្នុងចក្រទាំងឡាយ មានធម្មចក្រ ជាដើម*
*លោកសំដៅយកក្នុងធម្មចក្រនេះ ក៏ធម្មចក្រនោះ បែងចែក*

ជាពីរយ៉ាង ។

ពិតណាស់ ស័ព្ទថា ចក្រនេះ រមែងប្រាកដក្នុងសម្បត្តិ ក្នុងបទទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយ ដល់ព្រមដោយចក្រពួកណា ចក្រទាំងឡាយនោះមាន ៤ ។ ក្នុងលក្ខណៈនៃបទនេះថា ចក្រទាំងឡាយកើតឡើងហើយ ក្នុងផ្ទៃនៃព្រះយុគលបាទ ។ ក្នុងអង្គនៃរថ ក្នុងបទនេះថា ចក្រប្រព្រឹត្តទៅ ឈ្មោះថា ជាបទ ព្រោះនាំទៅ ។ ក្នុង **ឥរិយាបថ** ក្នុងបទនេះថា ចក្រ ៤ ទ្វារ ៩ ។ **ក្នុងទាន** ក្នុងបទនេះថា កាលណាឲ្យទាន ចូរបរិភោគ និងកុំប្រមាទ ចូរបង្វិលចក្រ ដើម្បីសត្វមានជីវិតទាំងឡាយ ។ **ក្នុងរតនចក្រ** ក្នុងបទនេះថា ចក្ករតនដែលជាទិព្វ បានប្រាកដហើយ ។ **ក្នុងធម្មចក្ក** ក្នុងបទនេះថា ចក្កដែលព្រះតថាគតឲ្យប្រព្រឹត្តទៅហើយ ។ **ខុរចក្ក** ក្នុងបទថា ចក្កខែក្បាលរបស់មនុស្ស ដែលមានសេចក្តីប្រណែនគ្របសង្កត់ហើយ។ ក្នុង **បហរចក្ក** ក្នុងបទនេះថា សូម្បីចក្កដែលមានមុខវឹងមុតដោយជុំវិញ ។ ក្នុង **អសនិមណ្ឌល** ក្នុងបទនេះថា **អសនិចក្រ** ។ ចំណែក ស័ព្ទ **ចក្ក** លោកសំដៅយកក្នុង **ធម្មចក្ក** នេះ ។

ធម្មចក្រនោះ មាន ២ យ៉ាង គឺ បដិវេធញ្ញាណ ១ , ទេសនាញ្ញាណ ១ ក្នុងធម្មចក្រ ២ យ៉ាងនោះ ធម្មចក្រ ដែលបញ្ញាអប់រំហើយ នាំមកនូវអរិយផលដល់ខ្លួន ឈ្មោះថា បដិវេធញ្ញាណ ។ ធម្មចក្រ ដែលករុណាអប់រំហើយ នាំមកនូវអរិយផលដល់សាវកទាំងឡាយ ឈ្មោះថា ទេសនាញ្ញាណ ។ ក្នុងញ្ញាណទាំង ២ នោះ បដិវេធញ្ញាណ មាន ២ យ៉ាង គឺ

កើតឡើង , កើតឡើងហើយ ។ បដិវេធញ្ញាណនោះ មានចាប់តាំងពីស្ដេចចេញអភិនេស្រ្កមណ៍ ដល់ព្រះអរហត្តមគ្គ ឈ្មោះថា កើតឡើង ។ បដិវេធ-ញ្ញាណ ក្នុងខណៈនៃផលឈ្មោះថា កើតឡើងហើយ ។ ម្យ៉ាងទៀត បដិ-វេធញ្ញាណ តាំងពីនៅស្ថានតុសិតរហូតដល់ព្រះអរហត្តមគ្គក្នុងមហាពោធិ-បល្ល័ង្ក ឈ្មោះថា កើតឡើង ។ បដិវេធញ្ញាណក្នុងខណៈនៃផល ឈ្មោះថា កើតឡើងហើយ ។ បដិវេធញ្ញាណ តាំងពីព្រះសម្ពុទ្ធទីបង្ករ រហូតដល់ព្រះអរហត្តមគ្គ ឈ្មោះថា កើតឡើង ។ ក្នុងខណៈនៃផល ឈ្មោះថា កើតឡើងហើយ ។ ចំណែកទេសនាញាណ ក៏មាន ២ យ៉ាង គឺ ប្រព្រឹត្តទៅ , ប្រព្រឹត្តទៅហើយ ។ ពិតណាស់ ទេសនាញាណនោះ តាំងពីព្រះអញ្ញាកោ-ណ្ឌញ្ញៈ សម្រេចជាព្រះសោតាបត្តិមគ្គ ឈ្មោះថា ប្រព្រឹត្តទៅ ។ ក្នុងខណៈនៃផល ឈ្មោះថា ប្រព្រឹត្តទៅហើយ ។ ក្នុងញាណទាំង ២ យ៉ាងនោះ បដិវេធញ្ញាណជាលោកុត្តរៈ ទេសនាញាណជាលោកិយៈ ញាណទាំង ២ នោះ មិនទូទៅដល់បុគ្គលពួកដទៃ ជាញាណរបស់ឱរសនៃព្រះពុទ្ធទាំងឡាយតែម្យ៉ាង ។

ព្រះតថាគត ទ្រង់ដល់ព្រមដោយពលៈទាំងឡាយណា ទ្រង់ប្រកាសឋានៈនៃភាពជាអ្នកនាំ និងពលៈទាំងឡាយណា ដែលលើកឡើងក្នុងខាងដើមថា ម្នាលសារីបុត្រ ក៏តថាគតពលញ្ញាណរបស់តថាគត ១០ យ៉ាងនេះឥឡូវនេះ ដើម្បីទ្រង់នឹងសម្ដែងពលៈទាំងឡាយនោះដោយពិស្ដារ ទើបត្រាស់ថា **កតមានិ ទស ឥធ សារីបុត្ត តថាគតោ ឋានញ្ច ឋានតោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឋានញ្ច ឋានតោ** សេចក្តីថា យល់ច្បាស់នូវហេតុតាមហេតុ ។ ពិតហើយ ហេតុ ហៅថា ឋានៈ ព្រោះជាទីតាំងនៃផល គឺជាទីកើត និងជាទីប្រព្រឹត្តទៅនៃផល ព្រោះការដែលផលប្រព្រឹត្តទៅ មកពីហេតុនោះ ។ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ដឹងច្បាស់នូវឋានៈនោះថា ធម៌ពួកណាៗ ជាហេតុបច្ច័យដល់ពួកធម៌ណា ៗ ព្រោះអាស្រ័យធម៌នោះ ៗ ទើបឈ្មោះថា **ឋានៈ** ធម៌ពួកណា ៗ មិនមែនជាហេតុបច្ច័យដល់ធម៌ ពួកណា ៗ ព្រោះអាស្រ័យធម៌នោះ ៗ ទើបហៅថា **អឋានៈ** ឈ្មោះថា ទ្រង់ដឹងច្បាស់នូវ **ឋានៈដោយឋានៈ** និង **អឋានៈដោយអឋានៈ** តាមសេចក្តីពិត ។ ហេតុនោះ បានមានហើយដោយពិស្តារ ក្នុងព្រះអភិធម្ម ដោយន័យជាដើមថា ក្នុងញាណទាំងនោះ ការដឹងឋានៈដោយឋានៈ និង អឋានៈដោយអឋានៈ តាមសេចក្តីពិតរបស់តថាគត តើធ្វើដូចម្តេច ដូច្នេះ ។ បទថា **យំបិ** សេចក្តីថា ដោយញាណណា ។ បទថា **ឥទំបិ សារីបុត្ត តថាគតស្ស** សេចក្តីថា ក៏ **ឋានាឋានញ្ញាណ** សូម្បីនេះ ឈ្មោះថា ជាកម្លាំងរបស់តថាគត ។ គប្បីជ្រាបយោជនាក្នុងបទទាំង ពួងយ៉ាងនេះ ។ បទថា **កម្មសមាទានានំ** សេចក្តីថា នៃកុសលកម្ម អកុសលកម្ម ដែលបានធ្វើហើយ ឬកម្មនោះឯងជាកម្មសមាទាន ។

បទថា **ឋានសោ ហេតុសោ** បានដល់ តាមហេតុតាមបច្ច័យ ។ ក្នុងបទនោះ **គតិ ឧបធិ កាល បយោគ** ជាឋានៈ គឺ ជាកម្ម ជាហេតុនៃវិបាក ។ ការពោលដោយពិស្តារនៃញាណនេះ មានមកហើយក្នុងព្រះអភិធម្ម ដោយន័យ

ជាដើមថា កម្មសមាទានខ្លះ ដែលជាបាបមានហើយ ត្រូវគតិសម្បត្តិហាម ទុក ទើបមិនឲ្យផល ដូច្នេះ ។ បទថា **សព្វត្ថគាមិនី** សេចក្តីថា ដែលឲ្យទៅ កាន់គតិក្នុងទីទាំងពួង និងដែលមិនឲ្យទៅកាន់គតិ ។ បទថា **បដិបទំ** បាន ដល់ មគ្គ ។ បទថា **យថាភូតំ បជានាតិ** សេចក្តីថា ទ្រង់ដឹងនូវសភាវៈ ដោយមិនខុសក្បាត់នៃការបដិបត្តិទាំងឡាយ ពោលគឺ កុសលចេតនា និង អកុសលចេតនា សូម្បីក្នុងវត្ថុមួយ ដោយន័យនេះថា កាលបើមនុស្សទាំង ឡាយច្រើននាក់ សម្លាប់សត្វសូម្បីមួយ ចេតនារបស់នាក់នេះ នឹងញ៉ាំងឲ្យ ទៅកាន់នរក ចេតនារបស់នាក់នេះ នឹងញ៉ាំងឲ្យទៅកាន់កំណើតតិរច្ឆាន ។ ការពោលដោយពិស្តារនៃញាណនេះ មានមកហើយក្នុងព្រះអភិធម្មនោះឯង ដោយន័យជាដើមថា ក្នុងញាណទាំងនោះ ការដឹងតាមសេចក្តីពិត ដែលជា បដិបទាឲ្យទៅកាន់ក្នុងទីទាំងពួងរបស់តថាគត យ៉ាងណា តថាគតក្នុងលោក នេះ រមែងដឹងច្បាស់ថា នេះមគ្គ នេះបដិបទាដែលញ៉ាំងសត្វឲ្យទៅកាន់នរក ។ បទថា **អនេកធាតុំ** សេចក្តីថា ធាតុជាច្រើន ដោយធាតុទាំងឡាយ មាន ចក្ខុធាតុជាដើម ឬកាមធាតុជាដើម ។ បទថា **នានាធាតុំ** សេចក្តីថា ធាតុ មានប្រការផ្សេងៗ ព្រោះការដែលធាតុទាំងនោះ មានលក្ខណៈពិសេស ។ បទថា **លោកំ** គឺ លោក បានដល់ ខន្ធ អាយតនៈ និងធាតុ ។ បទថា **យថាភូតំ បជានាតិ** សេចក្តីថា ទ្រង់ដឹងច្បាស់នូវសភាវៈដោយមិនខុសក្បាំង ក្បាត់នៃធាតុទាំងឡាយនោះ ៗ ។ ញាណនេះ មានពិស្តារហើយក្នុងព្រះ អភិធម្មនោះឯង ដោយន័យមានជាអាទិថា ក្នុងញាណទាំងនោះ ការដឹងសេចក្តី

ពិតនូវលោកដែលជាអនេកធាតុ , នានាធាតុរបស់តថាគត យ៉ាងណា តថាគតក្នុងលោកនេះ រមែងដឹងច្បាស់ដល់សភាពផ្សេង ៗ នៃខន្ធ ។ បទថា **នានាធិមុត្តិកតំ** បានដល់ ការមានអធិមុត្តិផ្សេង ៗ ដោយអធិមុត្តិទាំងឡាយ មានសភាពអាក្រក់ជាដើម ។ ញាណនេះ ក៏មានពិស្តារក្នុងព្រះអភិធម្មនោះឯង ដោយន័យមានជាអាទិ៍ថា ក្នុងញាណទាំងឡាយនោះ ការដឹងសេចក្តីពិតនូវការដែលសត្វទាំងឡាយមានអធិមុត្តិផ្សេង ៗ របស់តថាគតដូចម្តេច តថាគតក្នុងលោកនេះ រមែងដឹងច្បាស់ថា សត្វទាំងឡាយដែលមានអធិមុត្តិអាក្រក់ ។ បទថា **បរសត្តានំ** បានដល់ សត្វជាប្រធានទាំងឡាយ ។ បទថា **បរបុគ្គលានំ** សត្វថ្នាក់ទាបទាំងឡាយ ដទៃពីសត្វជាប្រធាននោះ ។ ម្យ៉ាងទៀត ពីរបទនោះ មានអត្ថតែមួយដូចគ្នា តែពោលទុកពីរយ៉ាង ដោយអំណាចនៃវេនេយ្យសត្វ ។ បទថា **ឥន្ទ្រិយបរោបរិយត្តំ** បានដល់ ការដែលឥន្ទ្រិយ៍ទាំងឡាយ មានសទ្ធាជាដើម ចាស់ក្លា និងទន់ខ្សោយ បានដល់ ការចម្រើន និងការអន់ថយ បានដល់ សេចក្តីចម្រើន និងសេចក្តីវិនាស ។ កថាពិស្តារនៃញាណនេះ មានហើយក្នុងព្រះអភិធម្មនោះឯង ដោយន័យមានជាអាទិ៍ថា ក្នុងញាណទាំងនោះ ការដឹងតាមសេចក្តីពិត ដល់សត្វដទៃទាំងឡាយ បុគ្គលដទៃទាំងឡាយមានឥន្ទ្រិយ៍ទន់ខ្សោយ និងចាស់ក្លា របស់តថាគតដូចម្តេច តថាគតក្នុងលោកនេះ រមែងដឹងអធ្យាស្រ័យ រមែងដឹងអនុស័យរបស់សត្វទាំងឡាយ ។

បទថា **ឈានវិមោក្ខសមាធិសមាបត្តីនំ** សេចក្តីថា ឈាន ៤ មាន

បឋមជ្ឈានជាដើម , វិមោក្ខ ៨ មានជាអាទិ៍ថា អ្នកមានរូប រមែងឃើញរូប ទាំងឡាយ , សមាធិ ៣ ដែលមានវិតក្កៈ និងវិចារៈជាដើម និងអនុបុព្វ-សមាបត្តិ ៩ មានបឋមជ្ឈានសមាបត្តិជាដើម ។ បទថា **សង្កិលេសំ** បាន ដល់ ធម៌ដែលជាចំណែកនៃសេចក្ដីសៅហ្មង ។ បទថា **វោទានំ** បានដល់ ធម៌ដែលជាចំណែកផូរផង់ ។ បទថា **វុដ្ឋានំ** សេចក្ដីថា ឈានដែលស្ទាត់ ជំនាញ និងភវង្គផលសមាបត្តិ ដែលពោលហើយយ៉ាងនេះថា សូម្បីសេចក្ដី បរិសុទ្ធិ ក៏គឺ ការចេញ សូម្បីការចេញពីសមាធិនោះៗ ក៏ជាការចេញ ។ ពិតហើយ ឈានដែលស្ទាត់ជំនាញ ដែលជាចំណែកខាងក្រោម រមែងជា បទដ្ឋានរបស់ឈានខ្ពស់ៗ សូម្បីសេចក្ដីបរិសុទ្ធិពីឈាននោះ ហៅថា ការ ចេញ ។ ការចេញពីឈានទាំងពួង រមែងមានដោយភវង្គ ។ ការចេញពី និរោធសមាបត្តិ រមែងមានដោយផលសមាបត្តិ ។ លោកសំដៅដល់ការ ចេញនោះ ទើបពោលថា សូម្បីការចេញពីសមាធិនោះៗ ថា ជាការចេញ ។ ញាណនេះ មានពិស្ដារក្នុងអភិធម្ម ដោយន័យមានជាអាទិ៍ថា ក្នុងញាណទាំង នោះ សេចក្ដីសៅហ្មង សេចក្ដីបរិសុទ្ធិ ការចេញនៃឈានវិមោក្ខ សមាធិ និងសមាបត្តិទាំងឡាយ ដែលជាយថាភូតញាណរបស់តថាគត តើដូចម្ដេច អ្នកមានឈាន ៤ ឈ្មោះថា **ឈាយី** មានឈាយី បុគ្គលខ្លះ រមែងសោយ សម្បត្តិដែលមានហើយនោះឯង ។ ក៏ការវិនិច្ឆ័យដល់សព្វញ្ញុតញ្ញាណ តាម ការពោលដោយពិស្ដារ បានពោលហើយក្នុងវិភង្គ អដ្ឋកថាឈ្មោះ សម្មោ-ហវិនោទនី ។ កថាពោលដោយ បុព្វេនិវាសានុស្សតិ និងទិព្វចក្ខុញ្ញាណ

មានពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។ កថាពោលដោយការអស់ទៅនៃអាសវៈ មានពិស្តារហើយក្នុងកយភេរវសូត្រ ។ បទថា **ឥមានិ ខោ សារីបុត្ត** សេចក្តីថា រមែងធ្វើអប្បនាថា យើងបានពោលថា ម្នាលសារីបុត្រ តថាគតពលៈរបស់ថាគត ១០ ក្នុងកាលមុនពួកណា តថាគតពលៈពួកនេះ នោះ ។

ក្នុងបទនោះ មានបរវាទិកថា ដូច្នេះ ។ ឈ្មោះថា ទសពលញ្ញាណ មិនមានការចែកចេញជាចំណែក ១ , សព្វញ្ញុតញ្ញាណប៉ុណ្ណោះ មានការចែកប្រភេទយ៉ាងនេះ ។ សេចក្តីនោះ មិនគប្បីឃើញយ៉ាងនោះ ។ ពិតហើយ ទសពលញ្ញាណម្យ៉ាង សព្វញ្ញុតញ្ញាណក៏ម្យ៉ាង ។ ទសពលញ្ញាណ រមែងដឹងចំពោះកិច្ចរបស់ខ្លួនប៉ុណ្ណោះ សព្វញ្ញុតញ្ញាណ រមែងដឹងកិច្ចរបស់ខ្លួននោះខ្លះ កិច្ចដ៏សេសអំពីកិច្ចរបស់ខ្លួននោះខ្លះ ។ ក្នុងទសពលញ្ញាណទាំងឡាយ **ញាណទី ១** រមែងដឹងចំពោះហេតុ និងមិនមែនហេតុ ប៉ុណ្ណោះ ។ **ញាណទី ២** រមែងដឹងលំដាប់នៃកម្ម និងលំដាប់នៃវិបាកប៉ុណ្ណោះ ។ **ញាណទី ៣** រមែងដឹងការកំណត់កម្មប៉ុណ្ណោះ ។ **ញាណ ទី ៤** រមែងដឹងចំពោះហេតុនៃធាតុ ដែលមានផ្សេងៗ គ្នាប៉ុណ្ណោះ ។ **ញាណទី ៥** រមែងដឹងអធ្យាស្រ័យ និងអធិមុត្តិរបស់សត្វទាំងឡាយ ប៉ុណ្ណោះ ។ **ញាណទី ៦** រមែងដឹងការៈនៃឥន្ទ្រីយ៍ទាំងឡាយចាស់ក្លា និងមិនទាន់ចាស់ក្លាប៉ុណ្ណោះ ។ **ញាណទី ៧** រមែងដឹងកិច្ច មានការសៅហ្មងជាដើម នៃឥន្ទ្រីយ៍ទាំងនោះ ព្រមជាមួយឈានប៉ុណ្ណោះ ។ **ញាណទី ៨** រមែងដឹងការបន្តនៃខន្ធដែលធ្លាប់ រស់នៅក្នុងជាតិមុនប៉ុណ្ណោះ ។ **ញាណទី ៩** រមែងដឹងចុតិ និងបដិសន្ធិរបស់សត្វទាំង

ឡាយ ប៉ុណ្ណោះ ។ ញាណទី ១០ រមែងដឹងការកំណត់សច្ចៈប៉ុណ្ណោះ ។

**ចំណែកសព្វញ្ញុតញ្ញាណ** រមែងដឹងច្បាស់កិច្ចដែលគួរដឹងដោយញាណទាំងនោះ និងរបស់ដ៏ក្រៃលែងជាងកិច្ចនោះ ក៏កិច្ចនៃញាណទាំងនោះ រមែងមិនធ្វើកិច្ចគ្រប់យ៉ាង ។ ព្រោះញាណនេះ ជាឈាន តែរមែងមិនអាចជាអប្បនា , ជាឥទ្ធិ តែមិនអាចដើម្បីសម្ដែងឫទ្ធិ , ជាមគ្គ ក៏មិនអាចញ៉ាំងកិលេសទាំងឡាយឲ្យអស់ទៅបាន ។ ប្រការមួយទៀត **បរវាទី** គប្បីត្រូវសួរយ៉ាងនេះថា ដែលឈ្មោះថា ទសពលញ្ញាណនោះ មានវិតក្កៈ ឬវិចារៈ , មិនមានវិតក្កៈ មានតែវិចារៈ , មិនមានវិតក្កៈ មិនមានវិចារៈ ជាកាមាវចរៈ ជារូបាវចរៈ ជាលោកិយៈ ជាលោកុត្តរៈ ដូច្នេះកាលដឹង ក៏នឹងឆ្លើយថា ញាណ ៧ តាមលំដាប់ មានវិតក្កៈ មានវិចារៈ ។ នឹងឆ្លើយថា ញាណ ២ ដទៃក្រៅពីញាណ ៧ នោះ មិនមានវិតក្កៈ មិនមានវិចារៈ ។ នឹងឆ្លើយថា **អាសវក្ខយញ្ញាណ** គប្បីមានវិតក្កៈ មានវិចារៈ គប្បីត្រឹមតែថា មិនមានវិតក្កៈ មានវិចារៈ ។ នឹងឆ្លើយថា ញាណ ៧ តាមលំដាប់យ៉ាងនោះ ជាកាមាវចរៈ , ញាណ ២ អំពីនោះ ជារូបាវចរៈ , ញាណ ១ ចុងក្រោយជាលោកុត្តរៈ ។ នឹងឆ្លើយថា ចំណែកសព្វញ្ញុតញ្ញាណ មានវិតក្កៈ មានវិចារៈផង ជាកាមាវចរៈផង ជាលោកិយៈផង ។ បណ្ឌិតជ្រាបការពណ៌នា តាមលំដាប់បទក្នុងទីនេះ ដោយប្រការដូច្នេះហើយ ឥឡូវនេះ គប្បីជ្រាប **ទសពល** ទាំងនេះថា បានពោលហើយតាមលំដាប់នេះ ព្រោះព្រះតថាគត ទ្រង់ឃើញការៈមានកិលេសជាគ្រឿងរាំង ដែលជាឋានៈ និងអឋានៈ នៃការសម្រេច

ការអស់ទៅនៃអាសវៈ និងការមិនសម្រេចរបស់វេនេយ្យសត្វដោយ **ឋានាឋានញ្ញាណ** ព្រោះទ្រង់ឃើញឋានៈនៃការឃើញដោយប្រពៃជាលោកិយៈ និងទ្រង់ឃើញការមានឋានៈនៃការឃើញខុស ដែលនាំទៅ លំដាប់នោះ ទ្រង់ឃើញការៈ មានវិបាកជាគ្រឿងរាំងវេនេយ្យសត្វទាំងនោះ ដោយកម្មវិបាកញ្ញាណ ព្រោះទ្រង់ឃើញហេតុបដិសន្ធិ ៣ , ទ្រង់ឃើញការៈ មានកម្មជាគ្រឿងរាំង ដោយសព្វត្ថគាមិនីបដិបទាញាណ , ព្រោះទ្រង់ឃើញការមិនមាននៃអនន្តរិយកម្ម , ទ្រង់ឃើញចរិយាពិសេស ដើម្បីទ្រង់សម្តែងធម៌ដែលសមគួរដល់វេនេយ្យសត្វទាំងឡាយ ដែលជាអ្នកមិនមានអាល័យយ៉ាងនេះ ដោយអនេកធាតុ នានាធាតុញ្ញាណ ព្រោះទ្រង់ឃើញការប្រព្រឹត្តទៅផ្សេង ៗ នៃធាតុ លំដាប់នោះ ទ្រង់ឃើញអធិមុត្តិរបស់វេនេយ្យសត្វទាំងនោះ ដោយ **នានាធិមុត្តិកតាញាណ** ព្រះអង្គមិនប្រកបការព្យាយាម ក៏ទ្រង់សម្តែងព្រះធម៌ដោយអំណាចនៃអធិមុត្តិ , លំដាប់នោះ ដើម្បីទ្រង់សម្តែងធម៌តាមសតិ តាមកម្លាំងដល់វេនេយ្យសត្វទាំងឡាយ ដែលជាអ្នកមានអធិមុត្តិបានឃើញហើយ យ៉ាងនេះ , ទ្រង់រមែងឃើញការដែលសត្វមានឥន្ទ្រីយ៍ទន់ខ្ចី និងចាស់ក្លា ដោយឥន្ទ្រិយបរោបរិយត្តិញ្ញាណ , ព្រោះទ្រង់ឃើញឥន្ទ្រីយ៍ទាំងឡាយ មានសទ្ធាជាដើម ជាធម្មជាតិចាស់ក្លា និងទន់ខ្ចី បើវេនេយ្យសត្វទាំងនោះ មានឥន្ទ្រីយ៍កំណត់ដឹងហើយយ៉ាងនេះ ទន់ខ្ចី និងចាស់ក្លា រមែងនៅក្នុងទីឆ្ងាយ ព្រោះការដែលវេនេយ្យសត្វជាអ្នកជំនាញក្នុងឈានទាំងឡាយ មានបឋមជ្ឈានជាដើម តែចូលដល់បានរហ័ស ដោយឥទ្ធិ-

*ពិសេសនោះហើយ និងការចូលដល់ហើយ ក៏ចូលដល់ថ្នាក់បព្វជាតិ របស់សត្វទាំងនោះ ដោយបុព្វេនិវាសានុស្សតិញ្ញាណ កាលទ្រង់ឃើញសម្បត្តិចិត្តពិសេសដោយចេតោបរិយញ្ញាណ ដែលទ្រង់សម្រេចដោយអានុភាព នៃទិព្វចក្ខុ ឈ្មោះថា ទ្រង់សម្តែងធម៌ដើម្បីការអស់ទៅនៃអាសវៈ ព្រោះព្រះអង្គប្រាសចាកការវង្វេង ដោយបដិបទាដែលញ៉ាំងសត្វឲ្យដល់ការអស់ទៅនៃអាសវៈ ដោយអានុភាពនៃអាសវក្ខយញ្ញាណ ។*

*ក៏ក្នុងបទជាដើមថា* ***តំ សារីបុត្ត វាចំ អប្បហាយ*** *ដូច្នេះ បុគ្គលពោលថា យើងនឹងមិនពោលវាចាបែបនេះ ឈ្មោះថា លះបង់វាចានោះ ។ កាលគិតថា យើងនឹងមិនញ៉ាំងការគិតបែបនេះឲ្យកើតឡើងទៀត ឈ្មោះថា លះបង់ការគិត ។ កាលលះបង់ថា យើងមិនប្រកាន់ ការឃើញបែបនេះទៀត ឈ្មោះថា រលាស់ចោលនូវការឃើញ ។ កាលមិនធ្វើយ៉ាងនោះ ឈ្មោះថា មិនលះបង់ មិនរលាស់ចេញ ។ បុគ្គលនោះ ក៏ទៀងតែនឹងធ្លាក់នរក ព្រោះដូច្នោះគប្បីជ្រាបថា ស្ថិតនៅក្នុងនរកនោះឯង ដូចត្រូវនាយនិរយបាលទាំងឡាយ នាំទៅទម្លាក់នរកយ៉ាងនោះដែរ ។ ឥឡូវនេះ កាលទ្រង់នឹងសម្តែងឧបមា ដែលឲ្យសម្រេចដល់គេ ទើបត្រាស់ថា* ***សេយ្យថាបិ*** *ជាដើម ។ ក្នុងបទទាំងនោះ គប្បីជ្រាប* ***សីល សមាធិ បញ្ញា*** *ដែលជាលោកិយៈ និងលោកុត្តរៈ ក្នុងបទជាដើមថា* ***សីលសម្បន្នោ*** *ដូច្នេះ ។ ភិក្ខុរមែងគួរដើម្បីនឹងឲ្យវិលត្រឡប់ដោយអំណាចនៃលោកុត្តរៈនោះឯង ។ ព្រោះភិក្ខុនោះ ដល់ព្រមហើយដោយសីល ដោយវាចាប្រពៃ ការងារប្រពៃ និងចិញ្ចឹមជីវិតប្រពៃ ។*

ដល់ព្រមដោយសមាធិ ដោយការព្យាយាមប្រពៃ រឭកប្រពៃ និងតាំងចិត្ត ប្រពៃ ។ ដល់ព្រមដោយបញ្ញា ដោយការឃើញប្រពៃ និងការត្រិះរិះប្រពៃ ។ ភិក្ខុអ្នកដល់ព្រមដោយសីលជាដើមយ៉ាងនេះ រមែងសម្រេចនូវព្រះអរហត្ត គឺ រមែងសម្រេចនូវព្រះអរហត្តក្នុងទិដ្ឋធម៌តែម្តង គឺ ក្នុងអត្តភាពនេះនោះឯង យ៉ាងណា ម្នាលសារីបុត្រ តថាគត រមែងពោលសេចក្តីឧបមេយ្យនេះ គឺ ហេតុមានសភាពដូច្នេះ ។ ទ្រង់សម្តែងថា ក៏ផលមិនឃ្លាតក្នុងលំដាប់នៃមគ្គ រមែងកើតឡើងយ៉ាងណា បដិសន្ធិក្នុងនរកមិនឃ្លាតក្នុងលំដាប់នៃចុតិរបស់ បុគ្គលនេះ ក៏រមែងមានបានដូចគ្នា ។ ដែលឈ្មោះថា **ឧបមា** ដែលត្រាស់ ឲ្យប្រាកដក្រៃលែងឡើង ដោយឧបមានេះ រមែងមិនមានក្នុងព្រះពុទ្ធវចនៈ ទាំងអស់ ។

[១៦៧] បទថា **វេសារជ្ជានិ** នេះ ជាបដិបក្ខចំពោះការភិតភ័យ ឈ្មោះថា **វេសារជ្ជៈ** នោះ ជាឈ្មោះនៃញាណ ដែលសម្រេចពីសោមនស្ស ដែលកើតឡើងដល់អ្នកពិចារណាដល់ការភិតភ័យ ក្នុងឋានៈ ៤ ។ បទថា **សម្មាសម្ពុទ្ធស្ស តេ បដិជានតោ** សេចក្តីថា ទ្រង់ប្តេជ្ញាយ៉ាងនេះថា ជា អរហន្តសម្មាសម្ពុទ្ធ ធម៌ទាំងអស់ តថាគតបានត្រាស់ដឹងក្រៃលែងហើយ ។ បទថា **អនភិសម្ពុទ្ធា** សេចក្តីថា ធម៌ទាំងនេះ ព្រះអង្គនៅមិនទាន់បានត្រាស់ ដឹង ។ បទថា **តត្រ វត** សេចក្តីថា ក្នុងធម៌ដែលសម្តែងយ៉ាងនេះថា មិន ទាន់បានត្រាស់ដឹងហើយ យ៉ាងនោះឯង ។ បទថា **សហធម្មេន** សេចក្តីថា ដោយពាក្យដែលមានហេតុ មានការណ៍ ដូចសុនក្ខត្តៈកាលនិយាយផ្តេសផ្តាស

មិនមានប្រមាណដូច្នោះ ។ បុគ្គលក្តី ធម៌ក្តី លោកមានបំណងថា **និមិត្ត** ក្នុងបទថា **និមិត្តមេតំ** នេះ ។ ក្នុងបទនោះ មានអធិប្បាយយ៉ាងនេះថា តថាគតមិនឃើញបុគ្គលដែលជំទាស់ថា តថាគតមិនឃើញធម៌ ដែលគេសម្តែងហើយ ជំទាស់នឹងតថាគតថា ធម៌ឈ្មោះនេះ ព្រះអង្គមិនបានត្រាស់ដឹងឡើយ ។ បទថា **ខេមប្បត្តោ** បានដល់ ដល់សេចក្តីក្សេម ។ ២ បទដ៏សេស ជាវេវចនៈរបស់បទនេះនោះឯង ។ បទទាំងអស់នោះ ត្រាស់សំដៅដល់ **វេសារជ្ជញ្ញាណ** ប៉ុណ្ណោះ ។ កាលព្រះទសពល មិនឃើញបុគ្គលអ្នកជំទាស់ ឬធម៌ដែលជាហេតុជំទាស់ ដែលមិនទាន់បានត្រាស់ដឹងហើយថា ធម៌ឈ្មោះនេះ លោកមិនទាន់ត្រាស់ដឹងហើយ ដូច្នេះ ឬកាលណាពិចារណាថា តថាគតជាព្រះពុទ្ធដោយសភាពនោះឯង ពោលថា តថាគតជាព្រះពុទ្ធ ដូច្នេះ សោមនស្សដែលមានកម្លាំងក្រៃលែង ក៏រមែងកើតឡើង ។ ញាណដែលសម្បយុត្តដោយសោមនស្សនោះ ឈ្មោះថា **វេសារជ្ជ** ។ ទ្រង់សំដៅដល់វេសារជ្ជៈនោះ ទើបត្រាស់ពាក្យជាអាទិ៍ថា **ខេមប្បត្តោ** ដូច្នេះ ។ គប្បីជ្រាបអធិប្បាយក្នុងបទទាំងពួង ដូច្នេះ ។ ក៏ធម៌ទាំងឡាយ ឈ្មោះថា **អន្តរាយិក** ព្រោះអត្ថថា ធ្វើអន្តរាយក្នុងបទនេះថា **អន្តរាយិកា ធម្មា** ដូច្នេះ ។ ធម៌ទាំងនោះ ដោយសេចក្តី ក៏បានដល់អាបត្តិ ៧ កង ដែលក្លែងកន្លងល្មើស ។ ពិតហើយ អាបត្តិទាំង ៧ កង ដែលក្លែងកន្លងល្មើសហើយ ដោយហោចទៅសូម្បីអាបត្តិទុក្កដ និងអាបត្តិទុព្ភាសិត ក៏ធ្វើអន្តរាយដល់មគ្គ និងផលទាំងឡាយបាន ។ តែក្នុងទីនេះលោកសំដៅយកមេថុនធម្ម ។ ក៏ការប្រាសចាក

នូវសេចក្ដីសង្ស័យម្យ៉ាង របស់ភិក្ខុរូបណា ១ អ្នកសេពមេថុន រមែងមាន អន្តរាយដល់មគ្គ និងផលទាំងឡាយបាន ។ បទថា **យស្ស ខោ បន តេសុ អត្ថាយ** សេចក្ដីថា ដើម្បីប្រយោជន៍ណា ក្នុងប្រយោជន៍ទាំងឡាយ មានការអស់ទៅនៃរាគៈជាដើម ។ បទថា **ធម្មោ ទេសិតោ** សេចក្ដីថា ធម៌មានការចម្រើនអសុភៈជាដើម ដែលលោកសម្ដែងទុកហើយ ។ បទថា **តត្រ វត មំ** បានដល់ ការប៉ាន់ស្មាន ចំពោះតថាគតក្នុងធម៌ជាគ្រឿងនាំចេញចាកទុក្ខនោះ ។ បទដ៏សេសគប្បីជ្រាបដោយន័យ ដែលពោលហើយនោះឯង ។

[១៦៨] បទថា **អថខោ ឥមេ សារីបុត្ត** នេះ ទ្រង់ប្រារព្ធព្រោះហេតុអ្វី ព្រោះដើម្បីទ្រង់សម្ដែងកម្លាំងនៃវេសារជ្ជញ្ញាណ ។ ដូចជាព្រះធម្មកថិកដ៏ឈ្លាសវៃ រមែងប្រាកដជាអ្នកឆ្លាតដោយពាក្យសម្ដី ដែលអាចញ៉ាំងចិត្តរបស់វិញ្ញូជនទាំងឡាយឲ្យត្រេកអរបាន យ៉ាងណា កាលដែលវេសារជ្ជ-ញ្ញាណ ជាធម្មជាតិឲ្យក្លៀវក្លា សូម្បីដល់បរិស័ទ ៨ ពួកនេះ អាចដើម្បីដឹងបានដូច្នេះ ព្រោះដូច្នោះ កាលទ្រង់សម្ដែងកម្លាំងនៃវេសារជ្ជញ្ញាណ ទើបទ្រង់ត្រាស់ថា **អថខោ ឥមា សារីបុត្ត** ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ បទថា **ខត្តិយបរិសា** បានដល់ ស្ថានទីអង្គុយប្រជុំរបស់ក្សត្រទាំងឡាយ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នា ។ ក៏ស្ថានទីដែលពួកកុមារទាំងឡាយអង្គុយប្រជុំ គប្បីជ្រាបថា មារបរិស័ទ ម្យ៉ាងទៀត សូម្បីបរិស័ទទាំងអស់របស់មារទាំងឡាយ ក៏មិនបានកាន់យកដោយអំណាចនៃការឃើញស្ថានទីដ៏ប្រសើរ ។ ព្រោះមនុស្សទាំងឡាយ រមែងមិនអាចពោលសូម្បីពាក្យធម្មតាថា ព្រះរាជា

អង្គុយប្រជាប់ក្នុងទីនេះ ញើសទាំងឡាយរមែងហូរចេញពីក្លៀក ។ **ខត្តិយ-បរិស័ទ** ប្រសើរយ៉ាងនេះ ។ ព្រាហ្មណ៍ទាំងឡាយ រមែងជាអ្នកឆ្លាតក្នុងវេទ ៣ គហបតីទាំងឡាយ រមែងជាអ្នកឆ្លាតក្នុងវោហារផ្សេង ៗ និងក្នុងការគិតអក្សរ ។ សមណៈទាំងឡាយ រមែងជាអ្នកឆ្លាតក្នុងវាទៈរបស់ខ្លួន និងវាទៈរបស់អ្នកដទៃ ។ ឈ្មោះថា ការពោលធម្មកថាក្នុងកណ្ដាលបរិស័ទទាំងនោះ ជាការៈធ្ងន់យ៉ាងខ្លាំង សូម្បីអមនុស្សទាំងឡាយ ក៏ជាអ្នកប្រសើរ ។ ព្រោះកាលបើគ្រាន់តែពោលថា អមនុស្ស សរីរៈទាំងអស់រមែងញ័រ ។ សត្វទាំងឡាយបានឃើញរូប ឬស្ដាប់សំឡេងរបស់អមនុស្សនោះ រមែងប្រាសចាកសញ្ញាបាន ។ បរិស័ទរបស់អមនុស្ស ប្រសើរយ៉ាងនេះ ។ ឈ្មោះថា ការសម្ដែងធម្មកថាក្នុងអមនុស្សបរិស័ទសូម្បីទាំងនោះ រមែងជាការៈធ្ងន់ដ៏ក្រៃលែង ។ អមនុស្សបរិស័ទទាំងនោះ គប្បីជ្រាបថា លោកកាន់យកហើយ ដោយអំណាចនៃការឃើញឋានៈដ៏ប្រសើរ ដោយប្រការដូច្នេះ ។ បទថា **អជ្ឈោគាហតិ** គឺ តាមចូលទៅ ។ បទថា **អនេកសតំ ខត្តិយបរិសំ** គឺ ដូចសមាគម **ព្រះបាទពិម្ពិសារ** សមាគមព្រះញាតិ និងសមាគម **ព្រះបាទ-លិច្ឆវី** ។ រមែងមានក្នុងចក្រវាឡសូម្បីដទៃ ។

ក៏ព្រះមានព្រះភាគ ស្ដេចទ្រង់យាងទៅកាន់សូម្បីចក្រវាឡដទៃឬ ។ អើ ! ស្ដេចទ្រង់យាងទៅ ។ ទៅយ៉ាងណា គេទាំងនោះយ៉ាងណា ព្រះអង្គក៏យ៉ាងនោះឯង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ម្នាលអានន្ទ ក៏តថាគតចូលទៅរកខត្តិយបរិស័ទច្រើនរយ រមែងដឹងចំពោះថា ក្នុង

បរិស័ទនោះ ពួកគេមានវណ្ណៈយ៉ាងណា តថាគត ក៏មានវណ្ណៈដូច្នោះ ពួកគេមានសំឡេងយ៉ាងណា តថាគតក៏មានសំឡេងយ៉ាងនោះ ហើយតថាគតឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថានឹងពួកគេ ឯពួកគេមិនស្គាល់តថាគត នឹងពោលថា នេះជាអ្នកណាហ្ន៎ ជាមនុស្ស ឬទេវតា នឹងកាលបើឲ្យឃើញច្បាស់ហើយ ឲ្យសមាទានហើយ ឲ្យអាចហ៊ានហើយ ឲ្យរីករាយហើយដោយធម្មីកថា ក៏បាត់ទៅ , ពួកគេមិនដឹងតថាគតទៅទីណា អ្នកដែលបាត់ទៅនេះ ជានរណា ជាទេវតា ឬមនុស្ស ដូច្នេះ ។ ពួកក្សត្រ ទ្រង់ប្រដាប់ដោយសង្វាមាលា និងរបស់ក្រអូបជាដើម ស្លៀកសំពត់ចម្រុះពណ៌ ទ្រង់ប្រដាប់កណ្ឌលកែវមណី ទ្រង់ចងសក់ ចំណែកព្រះមានព្រះភាគ ទ្រង់ប្រដាប់ព្រះវរកាយដូច្នេះឬ ក្សត្រទាំងឡាយនោះ មានព្រះឆវីសខ្លះ ខ្មៅខ្លះ ស្រគាំខ្លះ តើព្រះសាស្តាមានព្រះឆវី ដូច្នោះឬ ។ ព្រះសាស្តា ស្តេចទ្រង់យាងទៅដោយភេទបព្វជិតរបស់ព្រះអង្គឯង តែទ្រង់ប្រាកដដូចជាក្សត្រទាំងនោះ លុះស្តេចទៅហើយ ទ្រង់សម្តែងព្រះអង្គប្រថាប់លើរាជាសនៈ រមែងដូចជាក្សត្រទាំងនោះ ថា ក្នុងថ្ងៃនេះ ព្រះរាជារបស់ពួកយើងរុងរោចន៍ក្រៃលែងណាស់ ដូច្នេះ ។ បើក្សត្រទាំងនោះ មានព្រះសូរសេងបែក មិនច្បាស់ខ្លះ ក្រអួនខ្លះ ដូចសំឡេងក្អែកខ្លះ ។ ព្រះសាស្តាក៏ទ្រង់សម្តែងធម៌ដោយសំឡេងនៃព្រហ្មនោះឯង ក៏បទនេះថា តថាគតក៏មានសំឡេងដូច្នោះ ត្រាស់សំដៅដល់លំដាប់ភាសា ។ ក៏មនុស្សទាំងឡាយបានស្តាប់សំឡេងនោះហើយ រមែងមានការគិតថា ថ្ងៃនេះ ព្រះរាជាត្រាស់ដោយ

សំឡេងដ៏ពីរោះ ។ លុះកាលព្រះមានព្រះភាគត្រាស់ហើយ ស្តេចចៀសចេញទៅ ឃើញព្រះរាជា ស្តេចយាងមកទៀត ក៏កើតការពិចារណាថា បុគ្គលនេះជានរណាហ្ន៎ ! ព្រះអង្គទើបត្រាស់ព្រះតម្រិះនេះថា បុគ្គលនេះជានរណាហ្ន៎ នៅក្នុងទីនេះ ឥឡូវនេះ សម្តែងដោយសំឡេងដ៏ពីរោះដោយភាសាមគធៈ ដោយភាសាសីហឡៈបាត់ទៅ ជាទេវតា ឬមនុស្ស ដូច្នេះ ។

សួរថា ទ្រង់សម្តែងធម៌ដល់បុគ្គលទាំងឡាយ ដែលមិនដឹង យ៉ាងនេះដើម្បីអ្វី ។ ឆ្លើយថា ដើម្បីប្រយោជន៍ដល់វាសនា ។ ព្រះអង្គទ្រង់សម្តែងសំដៅអនាគតថា ធម៌ សូម្បីបានស្តាប់យ៉ាងនេះ រមែងជាបច្ច័យក្នុងអនាគតនោះពិត ។ បទថា **សន្និសិន្នបុព្វំ** បានដល់ ធ្លាប់អង្គុយរួមប្រជុំ ។ បទថា **សល្លបិតបុព្វំ** ធ្លាប់ធ្វើការសន្ទនា ។ បទថា **សាកច្ឆា** សេចក្តីថា ធ្លាប់ចូលទៅសន្ទនាធម៌ ។ ក៏គប្បីជ្រាបការចូលរួមប្រជុំដោយអំណាចសមាគម មានសមាគម **សោណទណ្ឌព្រាហ្មណ៍** ជាដើម និងដោយអំណាចចក្រវាឡដទៃដោយបទជាដើមថា **អនេកសតំ ព្រាហ្មណបរិសំ** ។

[១៦៩] ពាក្យថា **យោនិ** ក្នុងបទនេះថា **ចតស្សោ ខោ ឥមា សារីបុត្ត យោនិយោ** ជាឈ្មោះនៃចំណែកខន្ធខ្លះ នៃការណ៍ខ្លះ នៃផ្លូវបស្សាវៈខ្លះ ។ ចំណែកនៃខន្ធ ឈ្មោះថា **យោនិ** ក្នុងបទនេះថា ខន្ធរបស់នាគ ៤ ខន្ធរបស់គ្រុឌ ៤ , ការណ៍ ឈ្មោះថា **យោនិ** ក្នុងបទនេះថា ក៏ការណ៍នោះជាភូមិនៃការសម្រេចពូជ-ផល ។ ផ្លូវបស្សាវៈ ឈ្មោះថា **យោនិ** ក្នុងបទនេះថា ក៏យើងមិនហៅ បេតិសម្ភព ផ្លូវបស្សាវៈ ថាជាព្រាហ្មណ៍ ។ ក៏ក្នុង

ទីនេះ ចំណែកនៃខន្ធ លោកបំណងយកថា **យោនិ** ។ ក្នុងកំណើតទាំងនោះ សត្វដែលកើតក្នុងស៊ុត ឈ្មោះថា **អណ្ឌជ** ។ សត្វដែលកើតក្នុងគភ៌ ឈ្មោះថា **ជលាពុជ** ។ សត្វដែលកើតពីញើសក្អែល ឈ្មោះថា **សំសេទជ** ។ សត្វដែលកើតឡើងចំពោះ វៀរហេតុទាំងនោះ ដូចអណ្ដែតទៅកើត ឈ្មោះថា **ឱបបាតិក** ។ បទថា **អភិនិព្ពជ្ជ ជាយន្តិ** គឺ រមែងកើតដោយអំណាចនៃការទម្លាយហើយ ចេញមក ។ លោកសម្ដែងឋានៈ ដែលមិនគួរប្រាប្ថាទាំងឡាយដោយបទជាដើមថា **បូតិកុណបេ** សត្វទាំងឡាយ រមែងកើតក្នុងឋានៈដែលគួរប្រាប្ថា មានទឹកដោះប្ជា ស្អុរគ្នោត ទឹកឃ្មុំ និងទឹកអំពៅជាដើម ដូចគ្នា ។ ទេពជាន់ខ្ពស់ តាំងពីចាតុម្មហារាជិកា ក្នុងបទជាដើមថា **ទេវា** ចាត់ជាឱបបាតិកៈដូចគ្នា ។ ចំណែកភុម្មទេវតាទាំងឡាយ មានកំណើត ៤ ។ បទថា **ឯកច្ចេ ច មនុស្សា** សេចក្ដីថា ក្នុងមនុស្សទាំងឡាយ មនុស្សពួកខ្លះ ជាឱបបាតិកៈដូចទេវតា ។ តែមនុស្សពួកនោះ ដោយច្រើនកើតអំពីគភ៌ ។ ក្នុងទីនេះ សូម្បីដែលកើតពីស៊ុត ក៏ដូចកាតិយត្ថេរពីររូប ដែលជាបុត្រ **កោន្តៈ** ។ សូម្បីដែលកើតពីញើសក្អែល ក៏មាន ដូចបោក្ខរសាតិព្រាហ្មណ៍ និងព្រះនាងបុទុមវតីទេវី ដែលកើតក្នុងត្របកផ្កាឈូកជាដើម ។ ក្នុងវិនិបាតិកៈទាំងឡាយ និជ្ឈាមប្រេត និងតណ្ហិកប្រេត ជាឱបបាតិកៈដូចគ្នា ដូចសត្វនរកទាំងឡាយ ។ ដ៏សេសមានកំណើត ៤ ។ យក្សទាំងឡាយក្ដី សត្វទាំងឡាយ មានសត្វជើងបួន បក្សី និងពស់ទាំងពួងជាដើមក្ដី ទាំងអស់មានកំណើត ៤ ដូចវិនិបាតិកៈទាំងនោះ ។

គតិទាំងឡាយ គប្បីប្រព្រឹត្តទៅដោយអំណាចនៃកម្ម ដែលធ្វើទុកល្អ និងធ្វើទុកអាក្រក់ ក្នុងបទនេះថា ម្នាលសារីបុត្ត គតិ ៤ យ៉ាងនេះឯង ។

[១៧០] ប្រការមួយទៀតឈ្មោះថា **គតិ** មានច្រើនយ៉ាង គឺ **គតិគតិ** , **និព្វត្តិគតិ** , **អជ្ឈាសយគតិ** , **វិភវគតិ** និង **និប្ផត្តិគតិ** ។ ក្នុងគតិទាំងនោះ គតិនេះថា យើងស្លាប់ទៅនឹងទៅកាន់គតិណា នឹងថា ទេវតា គន្ធព្វ និងមនុស្ស រមែងមិនដឹងគតិរបស់នរណា ដូច្នេះ ឈ្មោះថា **គតិគតិ** ។

គតិនេះថា យើងមិនដឹងគតិ ឬអគតិរបស់ភិក្ខុទាំងឡាយអ្នកមានសីលទាំងនេះ ដូច្នេះ ឈ្មោះថា **និព្វត្តិគតិ** ។ គតិនេះថា ម្នាលព្រាហ្មណ៍ យើងដឹងច្បាស់គតិ និងដឹងច្បាស់ចុតិរបស់អ្នកយ៉ាងនេះឯង ឈ្មោះថា **អជ្ឈា-សយគតិ** ។ គតិនេះថា **វិភវ** ជាគតិធម៌ទាំងឡាយ និព្វានជាគតិរបស់ព្រះអរហន្ត ឈ្មោះថា **វិភវគតិ** ។ គតិនេះថា គតិមាន ២ យ៉ាងប៉ុណ្ណោះ មិនជាយ៉ាងដទៃ ឈ្មោះថា **និប្ផត្តិគតិ** ។ ក្នុងគតិទាំងនោះ លោកបំណងយក **គតិគតិ** ក្នុងទីនេះ ។ ឈ្មោះថា **និរយៈ** ដោយអត្ថថា ប្រាសចាកសេចក្តីត្រេកអរ ដោយអត្ថថា មិនមានការសប្បាយចិត្ត ក្នុងបទជាដើមថា **និរយោ** ។ ឈ្មោះថា **តិរច្ឆាន** ព្រោះអត្ថថា ដើរទទឹង ។ កំណើតរបស់តិរច្ឆានទាំងនោះ ឈ្មោះថា **តិរច្ឆានយោនិ** ។ ឈ្មោះថា **បេតវិស័យ** ព្រោះអត្ថថា ជាវិស័យនៃសត្វទាំងឡាយ ដែលដល់ការស្លាប់ទៅហើយ ។ ឈ្មោះថា **មនុស្ស** ព្រោះភាពជាអ្នកមានចិត្តខ្ពស់ ។ ឈ្មោះថា **ទេព** ព្រោះវិគ្រោះថា លេងជាមួយនឹងកាមគុណ ៥ ដោយអានុភាពនៃខ្លួន ។ ខន្ធទាំងឡាយ ព្រមជាមួយនឹង

ឱកាស ឈ្មោះថា **និរយៈ** ក្នុងបទជាដើមថា **និរយំ ចាហំ សារីបុត្ត** ។ ក្នុងបទនេះថា **តិរច្ឆានយោនឹ ច សូម្បី** ជាដើម ក៏ន័យនេះដូចគ្នា ។ ទ្រង់សម្ដែងកម្ម ដែលប្រព្រឹត្តទៅកាន់គតិប៉ុណ្ណោះ ដែលត្រាស់ទុកដោយបទទាំងពីរថា **មគ្គំ បដិបទំ** ។ បទថា **យថា ច បដិបន្នោ** សេចក្ដីថា ដំណើរទៅដោយផ្លូវណា ដោយបដិបទាណា ព្រោះដូច្នោះ សូម្បីទាំងពីរបទរួមចូលគ្នា រមែងប្រាកដឈ្មោះថា **អបាយ** ព្រោះជាការដែលប្រាសចាកការលូតលាស់ពោលគឺ ការចម្រើន ឬសេចក្ដីសុខ ក្នុងបទជាដើមថា **អបាយំ** ដូច្នេះ ។ ឈ្មោះថា **ទុគ្គតិ** ព្រោះអត្ថថា ជាគតិ គឺ ជាទីតាំងនៃទុក្ខ ។ ឈ្មោះថា **វិនិបាត** ព្រោះជាទីធ្លាក់ទៅនៃសត្វទាំងឡាយ ដែលធ្វើសេចក្ដីអាក្រក់ ក៏ព្រះមានព្រះភាគ ទ្រង់ត្រាស់បទនេះថា **និព្វានញ្ចាហំ** ដើម្បីទ្រង់សម្ដែងថា តថាគតមិនមែនដឹងចំពោះតែ **គតិគតិ** ម្យ៉ាងនោះទេ តថាគតដឹងសូម្បី **និព្វាន** ដែលជាគ្រឿងរលាស់ចេញពីគតិផងដែរ ។ លោកពោលអរិយមគ្គ ដោយបទទាំងពីរ គឺ មគ្គ និងបដិបទា ក្នុងទីនេះ ។

[១៧១] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអាការដែលប្រព្រឹត្តទៅហើយ ដោយញាណរបស់ព្រះអង្គ ក្នុងឋានៈទាំងឡាយតាមដែលពោលហើយ ទើបទ្រង់ត្រាស់ថា **ឥធាហំ សារីបុត្ត** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ឯកន្តទុក្ខា** គឺ មានទុក្ខជានិច្ច បានដល់ មានទុក្ខជានិរន្តរ៍ ។ បទថា **តិប្បា** គឺ ច្រើន ។ បទថា **កដុកា** បានដល់ រឹងមាំ ។ បទថា **សេយ្យថាបិ** ជាដើម ត្រាស់ហើយ ដើម្បីទ្រង់សម្ដែងចំណុចប្រៀបធៀប

រណ្តៅក្តី គំនរក្តី ហៅថា **កាសុ** ក្នុងបទនោះ ។ ក៏រណ្តៅ ឈ្មោះថា **កាសុ** ក្នុងគាថានេះថា ៖

នែ ! នាយសារថី អ្នកប្រញាប់ប្រញាល់ជីករណ្តៅ តើ
ព្រោះហេតុអ្វី ម្នាលសំឡាញ់អ្នកដែលត្រូវ ខ្ញុំសួរហើយចូរ
ប្រាប់មកចុះ អ្នកនឹងធ្វើនូវអ្វីដោយរណ្តៅ ។

**គំនរ** ឈ្មោះថា **កាសុ** ក្នុងគាថានេះថា មនុស្សទាំងឡាយដទៃកំពុងយំ មានខ្លួនក្តៅក្រហាយ ចោមរោមជីករណ្តៅរងើកភ្លើង ។ តែនៅក្នុងទីនេះ លោកបំណងយករណ្តៅ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា **សាធិកបោរិសំ** ជ្រៅជាងមួយជួរបុរស ។ ក្នុងបទនោះ រណ្តៅនោះ ជ្រៅជាងមួយជួរបុរសជាប្រមាណ ព្រោះដូច្នោះ ទើបជឿថា ជ្រៅជាងមួយជួរបុរស អធិប្បាយថា ជ្រៅហួសជាងប្រាំហត្ថ ។ បទថា **ប្រាសចាកអណ្តាតភ្លើង ប្រាសចាកផ្សែង** នោះ ត្រាស់ដើម្បីសម្តែងសេចក្តីក្រហល់ក្រហាយ ជាធម្មជាតិមានកម្លាំង ។ កាលបើអណ្តាតភ្លើងមានហើយ ឬផ្សែងមានហើយ ខ្យល់រមែងបក្កទ្បើង ព្រោះដូច្នោះ ការក្រហល់ក្រហាយទើបមិនមានកម្លាំង ។ បទថា **ឃម្មបរេតោ** បានដល់ ភាពក្តៅដុតរោល ។ បទថា **តសិតោ** សេចក្តីថា កើតការស្រេកឃ្លានអន្ទះសារ ។ បទថា **បិបាសិតោ** បានដល់ ប្រាថ្នានឹងផឹកទឹក ។ បទថា **ឯកាយនេន មគ្គេន** សេចក្តីថា ដោយផ្លូវមួយខ្សែ ដែលមានបន្លា ដើមឈើស្ដុកចង្អៀតជានិរន្តរ៍ទាំងសងខាង ដែលនឹងគប្បីដើរតាម ។ បទថា **បណិធាយ** សេចក្តីថា

ឈ្មោះថា មិនមានសេចក្តីប្រាថ្នា ក្នុងរណ្តៅភ្លើងធ្យូង ទ្រង់ប្រាប់ដល់រណ្តៅរងើកភ្លើង ទើបត្រាស់យ៉ាងនោះ ព្រោះការដែលឥរិយាបថតាំងហើយ ។ ការសម្តែងសេចក្តីឧបមាក្នុងបទថា **ឯវមេវ ខោ** នោះ មានដូច្នេះ ។ ក៏គប្បីឃើញនរក ដូចរណ្តៅរងើកភ្លើង ។ គប្បីឃើញកម្ម ដែលជាហេតុចូលដល់នរក ដូចផ្លូវទៅកាន់រណ្តៅរងើកភ្លើង គប្បីឃើញបុគ្គល ដែលបរិបូរណ៍ដោយកម្ម ដូចមនុស្សឡើងទៅកាន់ផ្លូវ ។ គប្បីឃើញព្រះមានព្រះភាគ ដែលមានទិព្វ-ចក្ខុ ដូចបុរសមានចក្ខុ បុរសនោះ ឃើញបុគ្គលដែលឡើងទៅកាន់ផ្លូវ រមែងដឹងថា បុគ្គលនេះទៅតាមផ្លូវនេះ នឹងធ្លាក់ក្នុងរណ្តៅរងើកភ្លើង យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ដឹងកម្មយ៉ាងណាមួយ ដែលធ្វើជីវិតសត្វឲ្យធ្លាក់ចុះ គឺការសម្លាប់សត្វជាដើម យ៉ាងនេះថា បុគ្គលនេះធ្វើកម្មនេះហើយ នឹងធ្លាក់នរក ដូច្នោះដូចគ្នា ។ ក្នុងកាលដទៃ បុរសនោះឃើញបុគ្គលនោះធ្លាក់ចុះក្នុងរណ្តៅរងើកភ្លើង យ៉ាងណា ក្នុងកាលដទៃ ព្រះមានព្រះភាគទ្រង់ញ៉ាំងពន្លឺភ្លឺឲ្យចម្រើនហើយថា បុរសនោះធ្វើកម្មនោះហើយ កើតហើយក្នុងទីណា ទ្រង់សម្លឹងមើលដោយទិព្វចក្ខុ រមែងឃើញបុរសអ្នកកើតហើយ ក្នុងនរកដែលសោយមហាទុក្ខ មានចំណង ៥ ប្រការដូច្នោះ ដូចគ្នា ។ កាលបើទ្រង់មើលឃើញថា ក្នុងនរកនោះ សត្វនោះ មានវណ្ណៈយ៉ាងដទៃ ក្នុងវេលាសន្សំកម្ម សត្វដែលកើតក្នុងនរកមានវណ្ណៈជាយ៉ាងដទៃ សូម្បីក៏ពិត ដល់យ៉ាងដូច្នោះ សត្វនោះ ធ្វើកម្មនោះហើយ កើតហើយក្នុងនរកនោះ សត្វនេះ សូម្បីស្ថិតនៅក្នុងកណ្តាលចំណោមសត្វច្រើនសែន ព្រោះដូច្នោះ សត្វនោះ រមែងមក

កាន់ផ្លូវ ព្រោះហេតុនោះ អាចារ្យទាំងឡាយទើបពោលថា នោះឈ្មោះថា កម្លាំងនៃទិព្វចក្ខុ ។

[១៧២] គប្បីជ្រាបអធិប្បាយឧបមាក្នុងប្រការទីពីរ ព្រោះការក្តៅក្រហល់ក្រហាយក្នុងរណ្តៅលាមក មិនដូចក្នុងរណ្តៅរងើកភ្លើង ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបមិនត្រាស់ថា **ឯកន្តទុក្ខា** ត្រាស់ពាក្យថា **ទុក្ខា** ជាដើម ។ គប្បីជ្រាបការប្រៀបធៀបឧបមា ដោយន័យមុននោះឯង សូម្បីក្នុងបទនោះ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលនេះកើតក្នុងកំណើតណាមួយ ក្នុងបណ្តាកំណើតទាំងឡាយ មានកំណើតដំរីជាដើម សោយទុក្ខច្រើន ដោយការសម្លាប់ ការឃុំឃាំង ការអូសទាញមក និងការអូសទាញទៅជាដើម ។

[១៧៣] គប្បីជ្រាបអធិប្បាយក្នុងឧបមាប្រការទី ៣ ក៏បទថា **តនុបត្តបលាសោ** បានដល់ ស្រទាប់ស្លឹកឈើដ៏ស្តើងមិនដូចផ្ទាំងពពក តែបទនេះ ត្រាស់សំដៅដល់ការមានស្លឹកស៊ើងរ៉ើង ។ បទថា **កពរច្ឆាយោ** បានដល់ មានម្លប់តិចតួច ។ បទថា **ទុក្ខពហុលំ** សេចក្តីថា ក៏ទុក្ខក្នុងបេតវិស័យមានច្រើន តែគប្បីសោយសុខបន្តិចបន្តួចក្នុងពេលខ្លះ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ គប្បីជ្រាបការប្រៀបធៀបសេចក្តីឧបមាដូចន័យមុនក្នុងទីនេះចុះ ។

[១៧៤] គប្បីជ្រាបអធិប្បាយក្នុងឧបមាប្រការទី ៤ បទថា **ពហលបត្តបលាសោ** បានដល់ ការមានស្រទាប់ស្លឹកក្រាស់ គឺ បិទបាំងដោយស្លឹក ។ បទថា **សណ្ឌច្ឆាយោ** សេចក្តីថា មានម្លប់ក្រាស់ត្រឈៃ ដូចម្លប់ផ្ទះ ។

បទថា **សុខពហុលា វេទនា** សេចក្តីថា វេទនាក្នុងត្រកូលទាំងឡាយ មានខត្តិយត្រកូលជាដើម ក្នុងមនុស្សលោក គប្បីជ្រាបថា វេទនាច្រើនដោយសេចក្តីសុខ ទ្រង់សម្តែងថា យើងឃើញបុគ្គលដេក ឬអង្គុយ សោយសុខ-វេទនា ។ គប្បីជ្រាបឧបមានេះ ដោយន័យមុននោះឯង ។

[១៧៥] គប្បីជ្រាបអធិប្បាយក្នុងឧបមាប្រការទី ៥ បទថា **បាសា-ទោ** បានដល់ ប្រាសាទវែង ។

បទថា **ឧល្លិត្តាវលិត្តំ** សេចក្តីថា លាបខាងក្នុង និងខាងក្រៅ ។ បទថា **ផុសិតគ្គឡំ** បានដល់ ទ្វារ និងបង្អួចបិទជិតបានល្អ ។ បទថា **គោនកត្ថតោ** សេចក្តីថា ក្រាលដោយសំពត់ពណ៌ខ្មៅរោមវែងជាងបួនធ្នាប់ ។ បទថា **បដិកត្ថតោ** បានដល់ ក្រាលដោយគ្រឿងកម្រាលពណ៌សដែលធ្វើពីរោមសត្វ ។ បទថា **បដលិកត្ថតោ** គឺ ក្រាលដោយគ្រឿងក្រាល ដែលធ្វើដោយស្បែកសត្វឈ្លូស ។ បទថា **កទលិមិគបវរបច្ចត្ថរណោ** សេចក្តីថា ក្រាលដោយគ្រឿងក្រាលថ្នាក់ខ្ពស់ ដែលធ្វើដោយស្បែកសត្វសំពោច ។ បានឮថា ជនទាំងឡាយបានក្រាលស្បែកសំពោច លើសំពត់ស ហើយដេរធ្វើជាគ្រឿងក្រាលនោះ ។ បទថា **សឧត្តរច្ឆទោ** សេចក្តីថា មានពិតានបាំងក្នុងខាងលើ គឺ មានពិតានពណ៌ក្រហមបាំងទុកខាងលើ ។ បទថា **ឧភតោលោហិតកូបធានោ** បានដល់ មានខ្នើយក្រហមដាក់នៅទាំង ២ ខាង នៃបល្ល័ង្ក គឺ ខ្នើយកើយក្បាល និងខ្នើយកល់ជើង ។ គប្បីជ្រាបការប្រៀបធៀបចំណុចឧបមាដោយន័យមុននេះ ក្នុងទីនេះ ។ យោជនាក្នុងចំណែកដទៃ ក្នុងបទនេះ

មានដូច្នេះ ។ បុរសនោះ រមែងដឹងបុគ្គលដែលឡើងកាន់ផ្លូវនោះថា បុគ្គលនេះ ទៅតាមផ្លូវនោះ ឡើងកាន់ប្រាសាទ ចូលកាន់កូដាគារ នឹងអង្គុយ ឬនឹងដេកលើបល្ល័ង្កយ៉ាងណា ព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលអ្នកសន្សំកុសលកម្មយ៉ាងណាមួយ ក្នុងបណ្តាបុញ្ញកិរិយាវត្ថុ មានទានជាដើម ទ្រង់រមែងដឹងថា បុគ្គលនេះ ធ្វើកម្មនេះហើយ នឹងកើតក្នុងទេវលោកដូច្នោះ ដូចគ្នា ។ ចំណែកកាលដទៃ បុរសនោះ រមែងឃើញបុគ្គលនោះ ឡើងកាន់ប្រាសាទនោះ ហើយចូលទៅកាន់កូដាគារ អង្គុយ ឬដេកលើបល្ល័ង្ក សោយវេទនាជាសុខតែម្យ៉ាង យ៉ាងណា ក្នុងកាលដទៃ ព្រះមានព្រះភាគទ្រង់ចម្រើនអាលោកសញ្ញាថា បុគ្គលនោះធ្វើកម្មល្អនោះហើយ កើតក្នុងទីណា កាលបើទ្រង់ប្រមើលដោយទិព្វចក្ខុ ទ្រង់រមែងឃើញបុគ្គលនោះ កើតក្នុងទេវលោកដែលមានពួកនាងរបាំហែហមចោមរោមក្នុងសួនឧទ្យានទាំងឡាយ មាននន្ទវ័នជាដើម សោយទិព្វសម្បត្តិក៏ដូច្នោះ ដូចគ្នា ។

[១៧៦] គប្បីជ្រាបវិនិច្ឆ័យក្នុង **អាសវក្ខយវារ** ប្រសិនបើជាមានពាក្យសួរថា សេចក្តីនោះ ព្រះមានព្រះភាគមិនត្រាស់ថា ដោយទិព្វចក្ខុ តែត្រាស់ថា តថាគតឃើញបុគ្គលនោះ ព្រោះហេតុអ្វី ។ ព្រោះមិនមានការកំណត់ ។ ព្រោះព្រះមានព្រះភាគ ទ្រង់នឹងឃើញបុគ្គលនេះដោយទិព្វចក្ខុខ្លះ និងទ្រង់ជ្រាបដោយចេតោបរិយញ្ញាណខ្លះ និងទ្រង់ដឹងដោយសព្វញ្ញុតញ្ញាណខ្លះ ។ ពាក្យថា **ឯកន្តសុខា វេទនា** នេះ ដោយព្យញ្ជនៈ ជាសុខដូចគ្នានិងសុខក្នុងទេវលោក សូម្បីដូច្នោះ សេចក្តីនោះ ដោយអត្ថថា ជាសុខផ្សេង

គ្នា ព្រោះសុខក្នុងទេវលោក មិនជាឯកន្តសុខតែម្យ៉ាង ព្រោះនៅមានសេចក្តីក្តៅក្រហាយ មានសេចក្តីក្តៅក្រហាយ ព្រោះរាគៈជាដើម ។ តែសុខក្នុងនិព្វាន ជាឯកន្តសុខ ដោយអាការទាំងពួង ព្រោះចូលទៅស្ងប់ភាពក្តៅ-ក្រហាយទាំងអស់ ។ សុខណា ដែលពោលសូម្បីក្នុងចំណុចឧបមាថា សុខដោយចំណែក ១ នៅក្នុងប្រាសាទ ក៏សុខនោះ ឈ្មោះថា សុខដោយចំណែក ១ ដូចគ្នា ព្រោះការដែលសេចក្តីក្តៅក្រហាយក្នុងផ្លូវ នៅមិនទាន់ស្ងប់ ព្រោះនៅមានសេចក្តីស្រេកឃ្លានជុតពេល ព្រោះនៅមានសេចក្តីស្រេកឃ្លាន គ្របសង្កត់ ។ តែក្នុងជង់ព្រៃ ក៏ឈ្មោះថា ជាសុខដោយចំណែក ១ ដោយអាការទាំងពួង ព្រោះមន្ទិល គឺ ធូលី ដែលបុគ្គលនោះចុះកាន់ស្រះបោក្ខរណី លាងជម្រះហើយ ព្រោះការដែលសេចក្តីនឿយហត់ក្នុងផ្លូវ ស្ងប់រំងាប់ហើយ ព្រោះសេចក្តីស្រេកឃ្លានទាំងឡាយ ត្រូវកម្ចាត់ហើយ ដោយការស៊ីក្រអៅឈូកនិងដោយការផឹកទឹកឆ្ងាញ់ហើយ ព្រោះការដែលគេផ្លាស់សំពត់ងូតទឹកហើយស្លៀកសំពត់សាច់ល្អិត ដេកកើយការុងអង្ករ យកសំពត់ងូតទឹកដាក់លើដើមទ្រូង ត្រូវខ្យល់រំភើយៗ បក់ ក៏ដេកលក់ ។ ក្នុងបទនេះថា **ឯវមេវ ខោ** មានការប្រៀបធៀបចំណុចឧបមាដូច្នេះ ។ គប្បីឃើញអរិយមគ្គ ដូចស្រះបោក្ខរណី ។ គប្បីឃើញការបដិបត្តិក្នុងចំណែកខាងដើម ដូចផ្លូវទៅកាន់ស្រះបោក្ខរណី ។ គប្បីឃើញបុគ្គលបរិបូរដោយការបដិបត្តិ ដូចបុគ្គលឡើងកាន់ផ្លូវ ។ គប្បីឃើញព្រះមានព្រះភាគ ទ្រង់មានទិព្វចក្ខុ ដូចបុរសដែលមានចក្ខុ ។ គប្បីឃើញនិព្វាន ដូចជង់ព្រៃ ។ បុរសនោះឃើញ បុគ្គលដែល

ឡើងកាន់ផ្លូវ រមែងដឹងថា បុគ្គលនេះ ទៅតាមផ្លូវនេះ ងូតទឹកក្នុងស្រះបោក្ខរណី ហើយនឹងអង្គុយ ឬនឹងដេកត្រង់គល់ឈើ ក្នុងជង្ងៃព្រៃដែលគួររីករាយ យ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះដូចគ្នា ទ្រង់ដឹងបុគ្គលដែលបំពេញបដិបទាកំណត់នាមរូប ធ្វើការកំណត់បច្ច័យ ធ្វើការផ្សារដោយវិបស្សនា ដែលមានលក្ខណៈជាអារម្មណ៍ថា បុគ្គលនេះបំពេញបដិបទានេះ ហើយញ៉ាំងអាសវៈទាំងពួងឲ្យអស់ទៅ ចូលដល់ផលសមាបត្តិ ដែលពោលហើយយ៉ាងនេះថា ចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលរកអាសវៈមិនបាន ។ ក្នុងចំណែកកាលដទៃ បុរសនោះឃើញ បុគ្គលនោះងូតទឹកក្នុងស្រះបោក្ខរណីនោះហើយ ចូលទៅក្នុងជង្ងៃព្រៃ ហើយអង្គុយ ឬដេកសោយវេទនា ដែលមានសេចក្តីសុខតែម្យ៉ាងយ៉ាងណា ក្នុងចំណែកកាលដទៃ ព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលនោះបំពេញបដិបទា ចម្រើនមគ្គ ធ្វើឲ្យច្បាស់នូវផល សម្រេចផលសមាបត្តិដែលមាននិព្វានជាអារម្មណ៍ ដែលដល់នូវការដេកដ៏ប្រសើរ គឺ និរោធ សោយវេទនាដែលមានសុខដោយចំណែក ១ ដូច្នោះ ដូចគ្នា ។

[១៧៧] បទនេះថា **ម្នាលសារីបុត្ត** ម្យ៉ាងទៀតតថាគត រមែងចូលចិត្តប្រព្រឹត្តព្រហ្មចរិយៈប្រកបដោយអង្គ ៤ ដូច្នេះ ទ្រង់ប្រារព្ធ ព្រោះហេតុអ្វី ។ ទ្រង់ប្រារព្ធដោយអំណាចការតភ្ជាប់ជាលំដាប់ ។ បានឮថា សុនក្ខត្តៈនេះ មានលទ្ធិយ៉ាងនេះថា សេចក្តីបរិសុទ្ធិ រមែងមានដោយការបំពេញទុក្ករកិរិយា ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះ ដើម្បីទ្រង់សម្តែងដល់សុនក្ខត្តៈនោះថា តថាគតស្ថិតនៅក្នុងអត្តភាពមួយ បានធ្វើទុក្ករកិរិយា

ដែលប្រកបដោយអង្គ ៤ ហើយ បុគ្គលដែលឈ្មោះថា ធ្វើទុក្ករកិរិយាដូចតថាគតមិនមាន បើសេចក្តីបរិសុទ្ធិមានដោយការធ្វើទុក្ករកិរិយា តថាគត គប្បីជាព្រះពុទ្ធ ដូច្នេះ ។ មួយាងទៀត សុនក្ខត្តៈនេះ ជ្រះថ្លាក្នុងការធ្វើទុក្ករកិរិយា ការដែលគេជ្រះថ្លានោះ គប្បីជ្រាប តាមន័យដែលមានហើយក្នុងបាដិកសូត្រ មានជាអាទិ៍យ៉ាងនេះថា សុនក្ខត្តលិច្ឆវីបុត្រ បានឃើញអាចេលក៍ឈ្មោះក្រោក្ខត្តិក ប្រព្រឹត្តវត្តលូនទំពាស៊ីអាហារ ដែលគេចាក់ចោលនៅលើផែនដីដោយមាត់ កាលដែលឃើញហើយ បានគិតថា សមណៈអ្នកលូនទំពាស៊ីអាហារ ដែលចាក់ចោលនៅលើផែនដីដោយមាត់នោះឯង យ៉ាងនេះ ល្អហ្ន៎ ! ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា សុនក្ខត្តៈជ្រះថ្លាក្នុងទុក្ករកិរិយា ក៏តថាគតស្ថិតនៅក្នុងអត្តភាពមួយ បានធ្វើទុក្ករកិរិយាដែលប្រកបដោយអង្គ ៤ ហើយសុនក្ខត្តៈនេះ កាលបើជ្រះថ្លាក្នុងការធ្វើទុក្ករ-កិរិយា ក៏គួរជ្រះថ្លាក្នុងតថាគត តែគេមិនមានសេចក្តីជ្រះថ្លាក្នុងតថាគតនោះទេ ដូច្នោះ បានទ្រង់ប្រារព្ធទេសនានេះ ។ ទានក្តី វេយ្យាវច្ចៈក្តី សិក្ខាបទក្តី ព្រហ្មវិហារក្តី ធម្មទេសនាក្តី មេថុនវិរតិក្តី សទារសន្តោសក្តី វីរិយៈក្តី ឧបោសថក្តី អរិយមគ្គក្តី សាសនាទាំងអស់ក្តី អជ្ឈាសយក្តី ហៅថា ព្រហ្មចរិយ ក្នុងទីនេះ ។

ទាន ហៅថា ព្រហ្មចរិយៈ ក្នុងបុណ្ណកជាតកថា ៖

អ្វីជាវត្តរបស់លោក អ្វីជាព្រហ្មចរិយៈ សេចក្តីសម្រេច
សេចក្តីរុងរឿង ពលៈ សេចក្តីព្យាយាម និងឧប្បត្តិនេះ

ជាវិបាករបស់អ្នកប្រព្រឹត្តល្អអ្វី បពិត្រលោកដ៏ចម្រើន សូមលោកប្រាប់មហាវិមានដល់ខ្ញុំម្ចាស់ផង ។ ខ្ញុំម្ចាស់ និងភរិយាទាំងពីរមានសទ្ធាជាទានបដិបត្តិចំពោះមនុស្សលោក ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំម្ចាស់ជាកោងទាន ហើយសមណៈព្រាហ្មណ៍ទាំងឡាយ ដែលយើងចិញ្ចឹមឲ្យបាន ឆ្អែតឆ្អន់ សប្បាយហើយ ទុំះជាវត្ថុរបស់ខ្ញុំម្ចាស់ ទុំះជាព្រហ្មចរិយៈ សេចក្ដីសម្រេច សេចក្ដីរុងរឿង ពលៈ សេចក្ដីព្យាយាម និងឧប្បត្តិនេះ ជាវិបាករបស់អ្នកប្រព្រឹត្តល្អ នោះជាលោកធីរៈ នេះជាវិមានរបស់ខ្ញុំម្ចាស់ ។

វេយ្យាវច្ច ហៅថា ព្រហ្មចរិយៈ ក្នុងអង្កុរបេតវត្ថុនោះថា ៖ បាទដៃរបស់លោក ឲ្យរបស់ដែលគួរប្រាថ្នា ជាទីហូរចេញនៃវត្ថុ មានរសឆ្ងាញ់ផលបុណ្យ រមែងសម្រេចត្រង់បាតដៃរបស់លោក ព្រោះព្រហ្មចរិយៈអ្វី ។ បាតដៃរបស់យើងឲ្យរបស់ដែលគួរប្រាថ្នាជាទីហូរចេញនៃវត្ថុ ដែលមានរសឆ្ងាញ់ ផលបុណ្យ រមែងសម្រេចក្នុងបាតដៃរបស់យើង ព្រោះព្រហ្មចារ្យនោះ ។

សិក្ខាបទ ៥ ឈ្មោះថា ព្រហ្មចរិយៈ ក្នុងតិត្តិរជាតកនោះ ថា ៖

ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា តិត្តិរិយវត្ត នេះឯងជាព្រហ្ម-ចរិយៈ ដូច្នេះ ។

ព្រហ្មវិហារ ហៅថា ព្រហ្មចរិយៈ ក្នុងមហាគោវិន្ទសូត្រនេះថា ៖ ម្នាលបញ្ចសិខៈ ក៏ព្រហ្មចរិយៈនោះឯង រមែងមិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ រមែងមិនប្រព្រឹត្តទៅ ដើម្បីលះបង់សេចក្តីត្រេកអរ រមែងប្រព្រឹត្តទៅ ត្រឹមតែដើម្បីការកើតឡើងក្នុងព្រហ្មលោក ប៉ុណ្ណោះ ។

ធម្មទេសនា ហៅថា ព្រហ្មចរិយៈ ក្នុងបទនេះថា ៖ ក្នុងព្រហ្មចារ្យ ១ មានអ្នកលះមច្ចុបាន ១០០០ នាក់ ។

មេថុនវិរតិ ហៅថា ព្រហ្មចរិយៈ ក្នុងសល្លេខសូត្រថា ៖ ពួកដទៃនឹងមិនប្រព្រឹត្តព្រហ្មចារ្យ ពួកយើងនឹងប្រព្រឹត្តព្រហ្ម-ចារ្យក្នុងទីនេះ ។

សទារសន្តោស ហៅថា ព្រហ្មចរិយៈ ក្នុងមហាធម្មបាលជាតកថា ៖ យើងមិនក្បត់ចិត្តភរិយា សូម្បីភរិយាក៏មិនក្បត់ចិត្តយើង យើងប្រព្រឹត្តព្រហ្មចារ្យវៀរភរិយាទាំងនោះ ព្រោះដូច្នោះ ហើយក្មេង ៗ របស់យើង ទើបមិនគប្បីស្លាប់ ។

ឧបោសថ ដែលប្រកបដោយអង្គ ៨ ដែលបានរក្សាហើយ ដោយ

អំណាចក្នុងការអប់រំខ្លួន ហៅថា ព្រហ្មចរិយៈ ក្នុងនិមិជាតក យ៉ាងនេះថា ៖

បុគ្គល រមែងកើតក្នុងខត្តិយៈដោយព្រហ្មចារ្យថ្នាក់ទាប នឹងរមែងកើតក្នុងទេពទាំងឡាយ ដោយព្រហ្មចារ្យថ្នាក់មធ្យម រមែងបរិសុទ្ធដោយព្រហ្មចារ្យថ្នាក់ខ្ពស់ ។

អរិយមគ្គ ហៅថា ព្រហ្មចរិយៈ ក្នុងមហាគោវិន្ទសូត្រនោះថា ៖

ម្នាលបញ្ចសិក្ខៈ ក៏ព្រហ្មចារ្យនេះហើយ រមែងប្រព្រឹត្តដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ដើម្បី បន្ទោបង់សេចក្តីត្រេកអរ ។បេ។ គឺ មគ្គមានអង្គ ៨ ដ៏ប្រសើរនេះ នោះឯង ។

ពាក្យប្រៀនប្រដៅទាំងអស់ ដែលបានសង្គ្រោះចូលក្នុងសិក្ខា ៣ យ៉ាង ហៅថា ព្រហ្មចរិយៈ ក្នុងបាសាទិកសូត្រថា ៖

ព្រហ្មចារ្យនេះនោះ ធំទូលំទូលាយ និងផ្សព្វផ្សាយទូទៅដ៏ពិស្តារ ពពួកជនដឹងច្រើន ជាគំនរបែបផែន រហូតដល់មនុស្សទាំងឡាយ បានប្រកាសល្អហើយនោះឯង ។

អធ្យាស្រ័យ ហៅថា ព្រហ្មចរិយៈ ក្នុងបទនេះថា ៖

ម្យ៉ាងទៀត សេចក្តីសង្ឃឹមផល រមែងសម្រេចដល់បុគ្គលអ្នកមិនតក់ក្រហល យើងជាអ្នកមានព្រហ្មចារ្យចាស់ក្លាហើយ

ម្នាលគាមិនី អ្នកចូរដឹងយ៉ាងនេះ ។

ក៏ **សេចក្តីព្យាយាម** លោកបំណងថា ព្រហ្មចារ្យក្នុងសូត្រនេះ ។ ក៏សូត្រនេះឯង ជាសូត្រនៃព្រហ្មចារ្យ គឺ សេចក្តីព្យាយាម សេចក្តីព្យាយាមនេះ លោកពោលថា ប្រកបដោយអង្គ ៤ ព្រោះការដែលទុក្ករកិរិយា ៤ យ៉ាង ដែលព្រះមានព្រះភាគ ទ្រង់បំពេញហើយ ក្នុងអត្តភាពមួយ ។

ពាក្យថា **សុទំ** ក្នុងបទថា **តបស្សី សុទំ ហោមិ** ត្រឹមតែជានិបាត អធិប្បាយថា យើងជាអ្នកមានសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។

បទថា **បរមតបស្សី** សេចក្តីថា មានសេចក្តីព្យាយាមជាគ្រឿងដុតកិលេសដ៏កំពូល គឺ ខ្ពស់បំផុតនៃបុគ្គលទាំងឡាយ អ្នកមានសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។ បទថា **លូខោ សុទំ ហោមិ** សេចក្តីថា យើងជាអ្នកសៅហ្មង ។ បទថា **ជេគុច្ឆិ** បានដល់ អ្នកស្អប់ខ្ពើមបាប ។ បទថា **បវិវិត្តោ សុទំ ហោមិ** សេចក្តីថា យើងជាអ្នកស្ងាត់ ។

[១៧៨] បទថា **តត្រស្សុ មេ ឥទំ សារីបុត្ត** សេចក្តីថា ក្នុងព្រហ្មចរិយៈ មានអង្គ ៤ នោះ ព្រហ្មចរិយៈនេះ ជាវត្តដែលមានសេចក្តីព្យាយាមជាគ្រឿងដុតកិលេសរបស់តថាគត ទ្រង់សម្តែងថា ព្រហ្មចរិយៈ នេះជាការដែលតថាគតធ្វើហើយ ក្នុងការដែលមានសេចក្តីព្យាយាមជាគ្រឿងដុតកិលេសមានវត្តអាក្រាតជាដើម ក្នុងការដែលព្រះតថាគត ទ្រង់អាស្រ័យសេចក្តីព្យាយាមដុតកិលេស ។ ក្នុងបទទាំងនោះ បទថា **អចេលកោ** បានដល់ អ្នកប្រាសចាកសំពត់ គឺ មនុស្សអាក្រាត ។ បទថា **មុត្តាចារោ** បានដល់

យើងមានមារយាទលះបង់ហើយ គឺ វៀរចាកមារយាទរបស់កុលបុត្តអ្នកស្រុកក្នុងកម្មទាំងឡាយ មានការបន្ទោបង់ឧច្ចារៈជាដើម ជាអ្នកឈរបន្ទោបង់ឧច្ចារៈ បន្ទោបង់បស្សាវៈ ទំពាបរិភោគ ។ **ហត្ថាវលេខនោ** សេចក្តីថា ទ្រង់សម្តែងថា លុះកាលដុំបាយនៅក្នុងដៃ តថាគតក៏ប្រើអណ្តាតលិទ្ធដៃ កាលបន្ទោបង់ឧច្ចារៈ យើងក៏ជាអ្នកមានការសម្គាល់ក្នុងដៃនោះឯងថា ជាកំណាត់ឈើយកដៃជូត ដូច្នេះ ។

បានឮថា ពួកគេបញ្ញត្តកំណាត់ឈើថា ជាសត្វ ព្រោះដូច្នោះ ព្រះអង្គទ្រង់បំពេញបដិបទារបស់ពួកគេ ទើបទ្រង់ធ្វើយ៉ាងនោះ ។ ទ្រង់សម្តែងថា អ្នកដែលគេពោលដើម្បីឲ្យទទួលអាហារថា មកចុះ លោកក៏មិនមក ព្រោះដូច្នោះ ទើបឈ្មោះថា គេអញ្ជើញឲ្យមកទទួលអាហារក៏មិនមក សូម្បីអ្នកដែលគេពោលថា បើយ៉ាងនោះ ចូរឈប់សិន លោកក៏មិនឈប់ ព្រោះដូច្នោះ ទើបឈ្មោះថា គេអញ្ជើញឲ្យឈប់ក៏មិនឈប់ ក៏តិរ្ថិយទាំងឡាយ រមែងមិនធ្វើការសូម្បីទាំងពីរយ៉ាងនោះ ដោយយល់ថា ពាក្យរបស់ពួកគេនឹងធ្វើហើយ សូម្បីយើង ក៏បានធ្វើយ៉ាងនេះ ។ បទថា **អភិហតំ** បានដល់ អាហារដែលគេបែងចែកទុកមុនហើយ នាំមកឲ្យ ។ បទថា **ឧទ្ទិស្ស កតំ** គឺ អាហារដែលគេប្រាប់យ៉ាងនេះថា បានធ្វើចំពោះលោកនេះ ។ បទថា **និមន្តនំ** សេចក្តីថា យើងមិនត្រេកអរ មិនកាន់យកសូម្បីអាហារដែលគេនិមន្ត យ៉ាងនេះថា លោកគប្បីចូលទៅកាន់ត្រកូលតាមដងផ្លូវ ឬស្រុកឈ្មោះឯណោះ ។ បទថា **ន កុម្ភិមុខា** គឺ យើងមិនទទួលអាហារដែលគេដួសអំពីឆ្នាំងឲ្យ ។ បទថា **ន**

**កឡោបិមុខា** សេចក្តីថា ឆ្នាំងបាយ ឬ **បច្ឆិ** ឈ្មោះថា **កឡោបិ** យើងមិនទទួលអាហារពីឆ្នាំងបាយនោះ ព្រោះហេតុអ្វី ព្រោះថា ម្ចាស់ឆ្នាំងបាយអាស្រ័យយើង នឹងបានការប្រហារដោយវែក ។ បទថា **ន ឯឡកមន្តរំ** សេចក្តីថា យើងមិនទទួល អាហារដែលគេឈរជិតធរណីទ្វារឲ្យ ព្រោះហេតុអ្វី ព្រោះថា បុគ្គលនេះអាស្រ័យយើងហើយ រមែងបានធ្វើក្នុងរវាងនោះ ។ សូម្បីក្នុងកំណាត់ឈើ និងអង្រែទាំងឡាយ ក៏ន័យនេះដូចគ្នា ។ បទថា **ន ទ្វិន្នំ** សេចក្តីថា កាលបើមនុស្ស ២ នាក់ កំពុងបរិភោគ ម្នាក់ក្រោកឡើងឲ្យយើង ក៏មិនទទួល ព្រោះហេតុអ្វី ព្រោះថា នឹងមានអន្តរាយពីការឈ្លោះគ្នា ។ ក្នុងបទទាំងឡាយ មានបទថា **ន គព្ភិនិយា** ជាដើម ទារកក្នុងផ្ទៃស្ត្រីមានគភ៌នឹងលំបាក កាលបើស្ត្រីកំពុងបំបៅដោះ ទារកនឹងមានអន្តរាយពីទឹកដោះ ។ បទថា **បុរិសន្តរគតាយ** សេចក្តីថា យើងមិនទទួលដោយគិតថា នឹងមានសេចក្តីអន្តរាយពីសេចក្តីត្រេកអរ ។ បទថា **ន សំកិត្តីសុ** សេចក្តីថា មិនទទួលអាហារដែលណាត់គ្នាធ្វើ ។ បានឮថា ក្នុងវេលាកើតទុរ្ភិក្ស សាវករបស់អចេលក៍ទាំងឡាយ ក៏នឹងបបួលគ្នាប្រមូលអង្ករជាដើម ពីទីនោះ ៗ ដាំបាយ ដើម្បីប្រយោជន៍ដល់អចេលក៍ទាំងឡាយ អចេលក៍អ្នកតឹងរឹងមិនទទួល ។ បទថា **ន យត្ថ សា** សេចក្តីថា ក្នុងទីណាសុនខបានទទួលការចិញ្ចឹមរក្សាថា យើងនឹងបានដុំបាយ យើងមិនទទួលអាហារ ដែលគេមិនឲ្យដល់សុនខក្នុងទីនោះ ហើយនាំមក ព្រោះហេតុអ្វី ព្រោះថា សុនខនោះនឹងមានអន្តរាយពីដុំបាយ ។ បទថា **សណ្ឌសណ្ឌចារិនី** សេចក្តីថា មានរុយរោម

កកកុញ ជាពួកៗ សូម្បីបើមនុស្សទាំងឡាយឃើញអចេលក៍ ហើយគិតថា យើងនឹងឲ្យអាហារដល់អចេលក៍នេះ ចូលទៅកាន់ផ្ទះបាយ ក៏កាលបើពួកគេ ចូលផ្ទះបាយ រុយទាំងឡាយទំនៅមាត់ឆ្នាំងបាយជាដើម ក៏នឹងហើរទំជាក្រុម ៗ យើងមិនទទួលអាហារ ដែលគេនាំយកមកពីឆ្នាំងបាយនោះ ព្រោះអ្វី ព្រោះ ថា រុយទាំងឡាយនឹងមានអន្តរាយពីអាហារ ព្រោះអាស្រ័យយើង សូម្បី យើង ក៏បានធ្វើយ៉ាងនោះដែរ ។

បទថា **ន ថុសោទកំ** សេចក្តីថា ទឹកដែលត្រាំអំបិល ដែលគេធ្វើ ដោយបាយត្រាំទាំងអស់ ក៏ក្នុងទីនេះ ការផឹកស្រានោះឯងមានទោស ពួក មនុស្សនេះ មានសេចក្តីសម្គាល់ថា មានទោស ។ អ្នកបានអាហារក្នុងផ្ទះ តែមួយប៉ុណ្ណោះ ហើយត្រឡប់មកវិញឈ្មោះថា **ឯកាគារិក** អ្នកចិញ្ចឹមជីវិត ដោយកិក្ខាមួយដុំប៉ុណ្ណោះ ឈ្មោះថា **ឯកាលោបិក** ។ សូម្បីក្នុងបទទាំង ឡាយ មាន **ទ្វា គារិកា** ជាដើម ក៏មានន័យដូចគ្នា ។ បទថា **ឯកិស្សាបិ ទត្តិយា** សេចក្តីថា ដោយថាសតូចមួយ ថាសតូចៗ ថាសមួយដែលគេដាក់ អាហារយ៉ាងល្អទុក ឈ្មោះថា **ទត្តិ** ។ បទថា **ឯកាហិកំ** បានដល់ អាហារ ដែលទុកក្នុងរវាងមួយថ្ងៃ ។ បទថា **អឌ្ឍមាសិកំ** បានដល់ អាហារទុកយូរ ក្នុងរវាងកន្លះខែ ។ បទថា **បរិយាយភត្តភោជនំ** សេចក្តីថា បរិភោគភត្តវារៈ គឺ បរិភោគភត្ត ដែលវិលមកតាមវារៈថ្ងៃយ៉ាងនេះ គឺ វារៈមួយថ្ងៃ វារៈពីរ ថ្ងៃ វារៈប្រាំពីរថ្ងៃ វារៈកន្លះខែ ។ បទថា **សាកភក្ខោ** បានដល់ បន្លែជា អាហារ ។ បទថា **សាមាកភក្ខោ** បានដល់ ស្រងែជាអាហារ ។ ស្រូវដំណើប

ដែលកើតឯង ក្នុងព្រៃឈ្មោះថា ស្រូវស្កួយ ក្នុងបទទាំងឡាយ មានបទថា **និវារ** ជាដើម ។ បទថា **ទទ្ទុលំ** បានដល់ ចំនៀរស្បែក ដែលគេចៀរហើយ បោះចោលជាអាហារ ។ សំបកឈើក្តី សារាយក្តី ជ័រឈើ មានកណិកា ជាដើមក្តី ឈ្មោះថា **ហដ** ។ បទថា **កណំ** បានដល់ កន្ទក់ ។ បទថា **អាចាមោ** បានដល់ បាយក្តាំងដែលជាប់ឆ្នាំងបាយ រើសយកបាយក្តាំងនោះ ក្នុងកន្លែងដែលគេចោល ហើយទំពាស៊ី ។ អាចារ្យទាំងឡាយពោលថា ទឹកបាយ ដូច្នេះខ្លះ ។ វត្ថុទាំងឡាយ មានម្សៅជាដើម ប្រាកដហើយ ។ បទថា **បវត្តផលភោជី** បានដល់ បរិភោគផ្លែ ឈើដែលធ្លាក់ហើយ ។ បទថា **សាណានិ** បានដល់ សំពត់សម្បកធ្មៃ ។ បទថា **មសាណានិ** គឺ សំពត់លាយគ្នា ។ បទថា **ឆវទុស្សានិ** បានដល់ សំពត់ដែលគេរុំសាកសព ឬសំពត់ដែលគេដេរវត្ថុ មានស្មៅ រៃទឹកជាដើម ធ្វើសំពត់ស្លៀក ។ បទថា **បំសុកូលានិ** បានដល់ សំពត់កខ្វក់ ដែលគេបោះចោលនៅលើផែនដី ។ បទថា **តិរីដានិ** បានដល់ សំពត់សម្បកឈើ ។ បទថា **អជិនំ** គឺ ស្បែកខ្លា ។ បទថា **អជិនក្ខិបំ** គឺ ស្បែកខ្លានោះឯង មានឆ្នូតពណ៌ត្រង់កណ្តាល លោកខ្លះពោលថា មានក្រចក ដូច្នេះខ្លះ ។ បទថា **កុសចីរំ** គឺ សំពត់ដែលគេក្រងដោយស្បូវធ្វើជាសំពត់ ។ សូម្បីក្នុងសំពត់សម្បកក្រចៅ និងសំពត់ធ្វើពីផ្លែឈើទាំងឡាយ ក៏មានន័យដូចគ្នា ។ បទថា **កេសកម្ពលំ** បានដល់ សំពត់កម្ពលដែលធ្វើដោយសក់មនុស្សទាំងឡាយ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំពត់បែបខ្លះដែលគេត្បាញហើយ សំពត់កម្ពល

ដែលធ្វើដោយសក់មនុស្សអាក្រក់ជាង សំពត់ទាំងនោះ ក្នុងពេលរងាក៏ត្រជាក់ ក្នុងពេលក្តៅក៏ក្តៅ មានតម្លៃតិច មានសម្ផស្សគ្រោតគ្រាត និងបញ្ចេញក្លិនស្អុយ ។ បទថា **វាលកម្ពលំ** គឺ សំពត់កម្ពលដែលធ្វើដោយរោមសត្វសេះជាដើម បទថា **ឧលូកបក្ខំ** បានដល់ សំពត់ដែលគេដេរដោយស្លាបសត្វមៀមធ្វើជាសំពត់ស្លៀក ។ បទថា **ឧព្ភដ្ឋកោ** បានដល់ ជាអ្នកក្រោកឈរ **ឧក្កុដិ-កប្បធានមនុយុត្តោ** គឺ តាមប្រកបសេចក្តីព្យាយាមអង្គុយច្រហោង សូម្បីកាលបើនឹងដើរ ក៏ជាអ្នកដើរជំទើត ៗ ដោយជាន់ដីមិនពេញជើង ដើរទៅ ។ បទថា **កណ្តកាបស្សយិកោ** សេចក្តីថា ទ្រង់សម្តែងថា យើងដាំបន្លាដែកឬបន្លាធម្មតាក្នុងដី ហើយក្រាលស្បែកលើបន្លានោះ ហើយធ្វើកិច្ច មានការឈរ និងការចង្ក្រមជាដើម ។ បទថា **សេយ្យំ** សេចក្តីថា កាលបើយើងដេកក៏សម្រេចការដេកលើបន្លានោះឯង ។ បទថា **សាយតតិយកំ** គឺ ១ ថ្ងៃ ៣ ដង ទ្រង់សម្តែងថា យើងខ្វល់ខ្វាយក្នុងការប្រកបរឿយៗ នូវការចុះទឹកថាយើងនឹងបណ្តែតបាប ១ ថ្ងៃ ៣ ដង គឺ ពេលព្រឹក ពេលថ្ងៃត្រង់ ពេលល្ងាច ។

[១៧៩] បទថា **នេកវស្សគណិកំ** បានដល់ ការសន្សំអស់ឆ្នាំដ៏ច្រើន ។ បទថា **រជោជល្លំ** បានដល់ មន្ទិល គឺ ធូលី ព្រះមានព្រះភាគ ទ្រង់សំដៅដល់ការសមាទាន **រជោជល្លកវត្ត** របស់ព្រះអង្គ ទើបត្រាស់ដល់មន្ទិល គឺធូលីនេះ ។

[១៨០] បទថា **ជេគុច្ឆិស្មឹ** គឺ ក្នុងការៈជាអ្នកខ្ពើមបាប ។ បទថា

*យាវ ឧទកពិន្ទុម្ហិបិ* សេចក្តីថា យើងបានតាំង សេចក្តីអាណិតចំពោះដំណក់ទឹក ក៏នឹងពោលទៅថ្វី ដល់គ្រួស ថ្ម កំណាត់ឈើ និងដីខ្សាច់ជាដើម ។

បានឮថា គេទាំងនោះ បញ្ញត្តដំណក់ទឹក និងវត្ថុទាំងឡាយ មានដុំគ្រួស និងដុំដីជាដើមទាំងនោះថា ជាសត្វតូចៗ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា តថាគតបានតម្កល់នូវសេចក្តីអាណិតចំពោះ ដំណក់ទឹក ដូច្នេះ ។ យើងមិនសម្លាប់ មិនលោងបំផ្លាញដំណក់ទឹក ព្រោះហេតុអ្វី ។ ព្រោះយើងមិនបានលោងបំផ្លាញសត្វតូចៗ ដែលនៅក្នុងទីដែលមិនស្មើឡើយ ព្រោះហេតុនោះ យើងទើបមិនលោងបំផ្លាញ គឺ សម្លាប់សត្វតូច ៗ ពោលគឺ ដំណក់ទឹកដែលនៅក្នុងទីស្មើ ដូចក្នុងទីទួល ទីគោក ចុងស្មៅ និងមែកឈើជាដើម ព្រោះដូច្នោះ ទើបទ្រង់សម្តែងខ្លឹមសារនោះថា តថាគតមានសតិឈានទៅខាងមុខ ដូច្នេះ ។ ក្នុងអចេលកទាំងឡាយ អចេលកឈ្មោះថា ជាអ្នកមានសីលចាប់ផ្តើម ពីកាលនៃខ្លួនជាន់ផែនដី មិនមានអចេលកទាំងឡាយ សូម្បីចូលទៅកាន់កិក្ខាចារ គឺ ជាអ្នកទ្រុស្តសីល សូម្បីបរិភោគក្នុងផ្ទះឧបដ្ឋាកទាំងឡាយ ក៏ជាអ្នកទ្រុស្តសីល បរិភោគ សូម្បីត្រឡប់មក ក៏ជាអ្នកទ្រុស្តសីលត្រឡប់មក ។ តែក្នុងពេលអចេលកទាំងឡាយចូលវង់ក្តារ ដោយវង់កន្ទុយក្ងោក អធិដ្ឋានសីលអន្តយក្នុងទីនោះ ទើបឈ្មោះថា ជាអ្នកមានសីល ។

[១៨១] បទថា *វនកម្មិកំ* បានដល់ អ្នកធ្វើដំណើរទៅក្នុងព្រៃ ដើម្បីប្រយោជន៍ដល់មើម និងផ្លែឈើជាដើម ។ បទថា *វនេន វនំ* គឺ ចេញពីព្រៃចូលកាន់ព្រៃ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នា ។ បទថា **បបតាមិ**

គឺ យើងទៅ ។ បទថា **អារញ្ញកោ** គឺ ម្រឹគនៅប្រចាំក្នុងព្រៃ ទ្រង់សំដៅដល់កាលនៃភាពជាអាជីវករបស់ព្រះអង្គ ទើបទ្រង់ត្រាស់ពាក្យនេះ ។ ឮថា ព្រះពោធិសត្វបួសជាអាជីវកនោះ ដើម្បីប្រយោជន៍ដល់ការនៅក្នុងព្រៃជាវត្ត សូម្បីទ្រង់ដឹងដល់ការបព្វជ្ជានោះ គ្មានប្រយោជន៍ តែក៏មិនបានសឹក ព្រោះព្រះពោធិសត្វទាំងឡាយ រមែងមិនវិលត្រឡប់ពីឋានៈដែលចូលទៅដល់ភាពជាធម្មតា តែកាលបើបួសហើយ ក៏ទ្រង់គិតថា នរណា ៗ កុំបានឃើញយើង ពេលនោះឯង ទើបស្ដេចចូលព្រៃ ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ថា ជនទាំងនោះកុំបានឃើញ តថាគត ហើយតថាគតកុំបានឃើញជនទាំងនោះ ដូច្នេះ ។

[១៨២] បទថា **គោដ្ឋា** បានដល់ ក្រោលគោ ។ បទថា **បតិដ្ឋិតគាវោ** គឺ ពួកគោចេញទៅហើយ ។ ក្នុងបទទាំងនោះ បទថា **ចតុកុណ្ឌិកោ** សេចក្ដីថា ត្រាច់ទៅ ឈរក្រឡេកមើលឃើញអ្នកឃ្វាលគោចេញទៅព្រមនឹងគោទាំងឡាយ ហើយដាក់ដៃទាំងពីរ និងជង្គង់ទាំងពីរចុះលើផែនដី លូនចូលទៅ យ៉ាងនេះ ។ បទថា **តានិ សុទំ អាហារេមិ** មានន័យថា អាចម៍គោរបស់កូនគោ រមែងមិនមានឱជារស ព្រោះដូច្នោះ វៀរអាចម៍គោទាំងនោះ ទើបស៊ីអាចម៍គោ ដែលមានឱជារសរបស់កូនគោខ្ចី ដែលនៅបៅដោះពេញពោះ ហើយចូលទៅកាន់ដងព្រៃនោះវិញ ។ ទ្រង់សំដៅដល់ពាក្យនេះ ទើបត្រាស់ថា យើងស៊ីអាចម៍គោទាំងនោះ ដូច្នេះ ។ បទថា **យាវកីវញ្ច មេ** សេចក្ដីថា មូត្រ និងករីសៈខ្លួនឯង របស់តថាគត មិនទាន់អស់ដរាបណា

តថាគតក៏ស៊ីទូវមូត្រ និងករីសៈរបស់ខ្លួនឯងដរាបនោះ ។ លុះកាលកន្លងទៅ ៗ សាច់ និងលោហិតអស់ទៅ ស្ពាមជើងក្នុងទ្វារអស់ទៅ យើងក៏ស៊ីអាចម៍គោរបស់កូនគោខ្ចី ។ បទថា **មហាវិកដភោជនស្មឹ** បានដល់ ក្នុងភោជនប្រភេទធំ អធិប្បាយថា ក្នុងភោជនខុសប្រក្រតី ។

[១៨៣] ពាក្យថា **តត្រ** ក្នុងបទថា **តត្រ សុទំ សារីបុត្ត ភឹសនកស្ស វនសណ្ឌស្ស ភឹសនកស្មឹ ហោតិ** ជាពាក្យចង្អុលបង្ហាញដល់ពាក្យដើម ។ សព្ទថា **សុទំ** ជានិបាត ចុះក្នុងពាក្យត្រឹមតែធ្វើបទឲ្យពេញ ។ បទថា **សារីបុត្ត** ជាពាក្យហៅ ។ ក៏អដ្ឋយោជនាក្នុងបទនោះ មានដូច្នេះ ។ បទថា **តត្រ** សេចក្តីថា ជាការតក់ស្លុតនឹងដងព្រៃដែលគួរខ្លាច ដែលទ្រង់ត្រាស់ទុកក្នុងបទថា ក្នុងដងព្រៃដែលគួរខ្លាចកន្លែងណាមួយ អធិប្បាយថា ជាការធ្វើដែលគួរខ្លាចជាយ៉ាងណា ជាយ៉ាងនោះថា បុគ្គលណាមួយមិនទាន់ប្រាសចាករាគៈ ចូលទៅកាន់ដងព្រៃនោះ ច្រើនតែព្រឺព្រួចរោម ដូច្នេះ ។ម្យ៉ាងទៀតបទថា **តត្រ** ជាសត្តមីវិភត្តិចុះក្នុងអត្ថឆដ្ឋីវិភត្តិ ។ ពាក្យថា **សុ** ជានិបាតដូចក្នុងពាក្យជាដើមថា **កឹសុ នាមតេ ភោន្តោ សមណព្រាហ្មណា** ។ បទថា **ឥទំ** ជា ពាក្យសម្តែងធ្វើសេចក្តីដែលប្រាថ្នាហើយ ដូចឲ្យប្រត្យក្ស ។ បទថា **សុឥទំ** ជា **សុទំ** គប្បីជ្រាបការលុប **ឥ** អក្សរដោយអំណាចសន្ធិ ដូចក្នុងពាក្យជាដើមថា **ចក្ខុន្ទ្រិយំ ឥត្ថិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ កឹសូធ វិត្តំ** ដូច្នេះ ។ ក៏យោជនាក្នុងបទនោះ ដូច្នេះ ។ ម្នាលសារីបុត្ត នេះហើយជាការគួរខ្លាចនៃដងព្រៃដែលគួរខ្លាចនោះ ។ បទថា **ភឹសនកត្តស្មឹ** សេចក្តីថា

ក្នុងភាវៈដែលគួរខ្លាច ។ គប្បីឃើញការលុប ត អក្សរមួយតួ ។ បាលីថា **ភឹសនកត្តស្មឹយេវ** ដូច្នេះក៏បាន ម្យ៉ាងទៀត កាលបើពោលថា **ភឹសនកត្តាយ** ចាត់ជាការធ្វើការឃ្លៀងឃ្លាតផ្លូវលិង្គ ។ ក៏ក្នុងបទនេះ ជាសត្តមីវិភត្តិចុះក្នុងអត្ថថា គ្រឿងសម្គាល់ ។ ព្រោះដូច្នោះ គប្បីជ្រាបការសម្ពន្ធយ៉ាងនេះ ។ នេះហើយជាការគួរខ្លាច គឺ មានភាពគួរខ្លាច ជានិមិត្តមានការគួរខ្លាចជាហេតុ មានការគួរខ្លាចជាបច្ច័យ បុគ្គលណាមួយនៅមិនទាន់ប្រាសចាករាគៈទេ ចូលទៅកាន់ព្រៃនោះ ច្រើនតែព្រឺរោម រមែងមានចុងរោមបះឡើងដូចម្ជុល និងដូចជាបន្លា ការមិនព្រឺមានតិច ឬរោមរបស់សត្វទាំងឡាយជាច្រើន រមែងព្រឺ ។ រោមរបស់បុរសដែលក្លាហាន រមែងមិនព្រឺ ដូច្នេះ ។ បទថា **អន្តរដ្ឋកា** សេចក្តីថា ៨ រាត្រីក្នុងរវាង ២ ខែយ៉ាងនេះ គឺ ខាងចុងខែ ៣-៤ រាត្រី ដើមខែ ៤ , ៤ រាត្រី ។ បទថា **អព្ភោកាសេ** សេចក្តីថា ព្រះមហាសត្វប្រថាប់នៅកណ្តាលវាលរហូត ១ រាត្រីក្នុងសម័យទឹកសន្សើមធ្លាក់ ។ លំដាប់នោះ ដំណក់ទឹកសន្សើមទាំងឡាយ គ្របស្រោបរណ្តៅរោមរបស់មហាពោធិ-សត្វនោះ ដូចកែវមុក្តា សរីរៈទាំងអស់ ដូចជាគ្របដោយសំពត់គគ្រោតពណ៌ស ដូច្នោះ ។ បទថា **ទិវា វនសណ្ឌេ** សេចក្តីថា កាលបើដំណក់ទឹកសន្សើមទាំងឡាយទៅប្រាសហើយ ព្រោះសម្ផស្សពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃ សូម្បីព្រះអស្សាសៈគប្បីមាន តែព្រះមហាសត្វនេះ កាលបើព្រះអាទិត្យរះឡើង ក៏ស្តេចយាងទៅកាន់ដងព្រៃ ។ សូម្បីក្នុងដងព្រៃនោះ ទឹកសន្សើមក៏ហួតហែង ដោយពន្លឺព្រះអាទិត្យ ចាំងត្រូវព្រះសរីរៈរបស់ព្រះពោធិសត្វ នោះឯង ។

បទថា **ទិវា អព្ភោកាសេ វិហរាមិ រត្តឹ វនសណ្ឌេ** សេចក្តីថា បានឮថា ព្រះពោធិសត្វនោះ ប្រថាប់នៅកណ្តាលវាល ពេញមួយថ្ងៃក្នុងគិម្ហកាល ។ ព្រោះហេតុនោះ ព្រះសេទ (ញើស) ទើបហូរចេញចាកព្រះកច្ឆៈ (ក្លៀក) ទាំងពីរខាងរបស់ព្រះពោធិសត្វនោះ គប្បីមានព្រះអស្សាសៈ រហូតមួយយប់ ក៏ព្រះពោធិសត្វនេះ កាលបើព្រះអាទិត្យអស្តង្គត ស្តេចក៏ចូលទៅកាន់ដងព្រៃ ។ លំដាប់នោះ ក្នុងដងព្រៃដែលមានចំហាយក្តៅគគុកក្នុងពេលថ្ងៃ អត្តភាពរបស់ព្រះពោធិសត្វ ក៏ក្តៅក្រហល់ក្រហាយ ដូចត្រូវដាក់ទៅក្នុងរណ្តៅរងើកភ្លើង ដូច្នេះ ។ បទថា **អនច្ឆរិយា** បានដល់ មិនគួរអស្ចារ្យ ។ បទថា **បដិភាសុ** បានដល់ ប្រាកដហើយ ។ បទថា **សោ តត្តោ** សេចក្តីថា ក្តៅធេះរោលដោយកម្តៅថ្ងៃ នៅពេលថ្ងៃ ដោយចំហាយក្តៅគគុកក្នុងព្រៃធំ ក្នុងពេលយប់ ។ បទថា **សោ សិនោ** សេចក្តីថា ទទឹកជោកសព្វទាំងអស់ ដោយទឹកសន្សើមក្នុងពេលយប់ ដោយទឹកសន្សើមក្នុងពេលថ្ងៃ ។ បទថា **ភិសនកេ** បានដល់ គួរឲ្យកើតសេចក្តីខ្លាច ។ បទថា **នគ្គោ** បានដល់ ការប្រាសចាកសំពត់ លោកសម្តែងថា កាលបើមានសំពត់ស្លៀក និងសំពត់ដណ្តប់ រងា ឬក្តៅ មិនគប្បីបៀតបៀនបាន សូម្បីសំពត់ស្លៀក និងសំពត់ដណ្តប់របស់យើង ក៏មិនមាន ។ បទថា **ន ចគ្គិមាសិនោ** គឺ មិនបានអាំងភ្លើង ។ បទថា **ឯសនាបសុតោ** បានដល់ ការខ្វល់ខ្វាយ ដើម្បីប្រយោជន៍ក្នុងការស្វែងរកសេចក្តីបរិសុទ្ធិ ។ បទថា **មុនី** សេចក្តីថា ក្នុងកាលនោះ ព្រះអង្គទ្រង់ធ្វើព្រះអង្គឯងឲ្យជាមុនី ហើយបានត្រាស់ ។

[១៨៤] បទថា **ឆវដ្ឋិកានិ** បានដល់ ឆ្អឹងទាំងឡាយ ដែលបោះបង់ចោលខ្ចាត់ខ្ចាយ ។ បទថា **អបណិធាយ** គឺ ទ្រង់សម្តែងថា ខ្នើយកើយក្បាល និងខ្នើយកល់ជើង រមែងប្រាកដយ៉ាងណា ព្រះអង្គទ្រង់ក្រាលហើយសម្រេចការផ្ទំលើគំនរឆ្អឹងនោះ ដូច្នេះ ។ បទថា **គោមណ្ឌលា** បានដល់ពួកក្មេងឃ្វាលគោ ។ បានឮថា ក្មេងទាំងនោះទៅកាន់សម្នាក់របស់ព្រះពោធិ-សត្វ ហើយពោលថា បពិត្រសុមេធៈ លោកអង្គុយពោលក្នុងទីនេះ ព្រោះហេតុអ្វី ព្រះពោធិសត្វទ្រង់អង្គុយជាក់ព្រះភក្ត្រ មិនឆ្លើយតប ។ លំដាប់នោះក្មេងឃ្វាលគោទាំងនោះនៅ ចោមរោមព្រះពោធិសត្វនោះ ហើយស្រែកបន្លឺកថា ពួកយើងនឹងធ្វើឲ្យឆ្លើយតប ទើបស្តោះទឹកមាត់ដាក់ព្រះសរីរៈ ។ សូម្បីពួកក្មេងធ្វើយ៉ាងនោះ ព្រះអង្គក៏នៅតែមិនឆ្លើយតប ។ លំដាប់នោះ ពួកក្មេងឃ្វាលគោខឹងនឹងព្រះពោធិសត្វថា លោកមិនព្រមពោលឬ ទើបបន្ទោបង់បស្សាវៈលើព្រះពោធិសត្វនោះ ។ សូម្បីយ៉ាងនោះ ព្រះពោធិសត្វ ក៏មិនឆ្លើយតប ។ បន្ទាប់ពីនោះ ទើបបាចធូលីលើព្រះពោធិសត្វនោះថា លោកចូរពោល ដូច្នេះ ។ សូម្បីយ៉ាងនេះ ព្រះពោធិសត្វក៏មិនឆ្លើយតបដដែល ។ លំដាប់នោះ ទើបពោលថា បើលោកមិនឆ្លើយតបទេ ពួកយើងនឹងយករំពាត់ឈើ ឆ្កៀលរន្ធត្រចៀករបស់លោកទាំងសងខាងថែមទៀត ។ ព្រះពោធិសត្វទ្រង់អត់ទ្រាំក្នុងទុក្ខវេទនាដ៏ខ្លាំងក្លា ទ្រង់ស្ថិតនៅ ហាក់ដូចជាបុគ្គលស្លាប់ យើងនឹងមិនឆ្លើយតបពាក្យអ្វីនឹងអ្នកណាឡើយ ។ ដោយហេតុនោះ ទើបត្រាស់ថា ម្នាលសារីបុត្ត តថាគត មិនគិតថា ញុំាងចិត្តដ៏លាមកឲ្យកើតឡើង

ក្នុងពួកក្មេងទាំងនោះឡើយ ។ អធិប្បាយថា សូម្បីចិត្តអាក្រក់ដែលយើងមិនឲ្យកើតឡើងដល់ពួកក្មេងទាំងនោះ ។ បទថា **ឧបេក្ខាវិហារស្មឹ ហោតិ** គឺ ជាអ្នកនៅដោយឧបេក្ខា ។ **វិហារ** ហៅថា **វិហារស្មឹ** ក៏ដោយបទនោះឯង គប្បីជ្រាបខ្ទឹមសារយ៉ាងនេះថា **អយំ សុ មេ** សូម្បីក្នុងបទនេះថា **ឥទំ សុ មេ** ក្នុងទីនេះ ។ គប្បីជ្រាបបទយ៉ាងនេះ សូម្បីបទដទៃក៏មានន័យដូចគ្នា ។ ទ្រង់សម្តែងឧបេក្ខាវិហារ ដែលទ្រង់បំពេញហើយរហូត ៩១ កប្ប ពីនេះដោយបទនេះ ។ ទ្រង់សំដៅដល់ឧបេក្ខាវិហារ ទើបត្រាស់ថា ៖

> កាលបើប្រសព្វនឹងសេចក្តីសុខ យើងក៏មិនត្រេកអរ
> ពេលប្រសព្វសេចក្តីទុក្ខ យើងក៏មិនតូចចិត្ត យើងមិន
> ជាប់នៅក្នុងសុខ និងទុក្ខទាំងពួង នោះជាឧបេក្ខាបារមី
> របស់យើង ។

[១៨៥] បទថា **អាហារេន សុទ្ធិ** គឺ ជាអ្នកមានការឃើញយ៉ាងនេះថា សត្វទាំងឡាយ អាចបរិសុទ្ធដោយអាហារបន្តិចបន្តួច ដូចជាពុទ្រាជាដើម ។ បទថា **ឯវមាហំសុ** បានដល់ និយាយយ៉ាងនេះ ។ បទថា **កោលេហិ** បានដល់ ពុទ្រាទាំងឡាយ ។ បទថា **កោលោទកំ** គឺ ទឹកផឹកដែលគេប្របាច់ផ្លែពុទ្រាទាំងឡាយហើយធ្វើ ។ បទថា **កោលវិកតឹ** បានដល់ ប្រភេទនៃផ្លែពុទ្រា ដូចបន្ទះពុទ្រា នំពុទ្រា និងដុំពុទ្រាជាដើម ។ បទថា **ឯតបរមោ** សេចក្តីថា នោះជាប្រមាណយ៉ាងក្រៃលែងរបស់ផ្លែពុទ្រានោះ ព្រោះដូច្នោះ ពុទ្រានោះ ទើបឈ្មោះថា **ឯតបរមោ** មានផ្លែធំ អធិប្បាយថា ក៏ក្នុងកាលនោះ

ក្នុងទីបំផុត ៩១ កប្ប ពុទ្រាមិនធំប៉ុនផ្លែក្រៅទុំ និងផ្លែត្នោតទុំ ក៏ធំប៉ុនផ្លែពុទ្រាក្នុងឥឡូវនេះប៉ុណ្ណោះ ។ បទថា **អធិមត្តកសិមានំ** សេចក្តីថា ទ្រង់ស្គមយ៉ាងក្រៃលែង ។ បទថា **អសីតិកបព្វានិ វា កាឡបព្វានិ វា** គឺ ទ្រង់សម្តែងថា វល្លិ៍ដែលមានថ្នាំងច្រើន ឬវល្លិ៍ដែលមានថ្នាំងខ្មៅ ដែលស្វិតស្ងួតត្រង់ថ្នាំង រមែងកំពុងឡើង និងផតចុះត្រង់កណ្តាល យ៉ាងណា អវយវៈតូចធំរបស់យើង ក៏ដូច្នោះ ។ បទថា **ឱដ្ឋបទំ** សេចក្តីថា ជើងអូដ្ឋ ជាធម្មជាតិជ្រៅត្រង់កណ្តាល យ៉ាងណា លុះកាលបើសាច់ និងឈាមហួតហែង ត្រគាករបស់ព្រះពោធិសត្វ ក៏ជ្រៅត្រង់កណ្តាល ព្រោះការដែលវច្ចទ្វារចូលទៅខាងក្នុង ដូច្នោះ ដូចគ្នា ។ ពេលនោះ ទីអង្គុយនៅលើផែនដីរបស់ព្រះពោធិសត្វនោះ ក៏នឹងកំពុងឡើងត្រង់កណ្តាល ដូចប្រថាប់ដោយបំពង់ដាក់ព្រួញសរ ។ បទថា **វដ្ដនាវឡី** សេចក្តីថា វល្លិ៍អង្គញ់ដែលគេកាត់ធ្វើជាខ្សែ ក៏នឹងផតចុះចន្លោះៗនៃផ្លែអង្គញ់ និងកំពុងឡើងនៅត្រង់ថ្នូងយ៉ាងណា ឆ្អឹងខ្នងកំពុងឡើងពកៗដូច្នោះ ។ បទថា **ជរសាលាយ គោបាណសិយោ** បានដល់ បង្កង់នៃសាលាចាស់ ។ បង្កង់ទាំងនោះ របូតពីគ្រោងហើយ តាំងនៅក្នុងបរិវេណរួចក៏របូតធ្លាក់ចុះនៅលើផែនដី ព្រោះដូច្នោះ ក៏ធ្លាក់គងលើគ្នា គឺ ១ លើ ១ ក្រោម ។ ក៏ឆ្អឹងជំនីរបស់ព្រះពោធិសត្វ មិនជាយ៉ាងនោះ ។ ព្រោះការខ្វះព្រះលោហិត ព្រះមំសៈ ( សាច់ ) ស្ងួតហួតហែង ព្រះពោធិសត្វនោះ ក៏មានព្រះចម្មៈ ( ស្បែក ) ផតចុះក្នុងចន្លោះឆ្អឹងជំនីរ ទ្រង់សំដៅដល់ឆ្អឹងជំនីរនោះ ទើបទ្រង់ត្រាស់បទនេះ ។ បទថា **ឱក្ខាយិកា** បានដល់ ខូងជ្រៅទៅខាងក្រោម ។

ឮថា កាលខ្លះព្រះលោហិត ព្រះមំសៈស្ងិតជ្រួញ គ្រាប់ភ្នែករបស់ព្រះពោធិ-សត្វនោះ ក៏ខូងជ្រៅចុះក្នុងរណ្តៅភ្នែក ព្រោះហេតុនោះ គ្រាប់ភ្នែករបស់ព្រះពោធិសត្វនោះ ទើបជាយ៉ាងនោះ ។

បទថា **អាមកច្ឆិន្នោ** បានដល់ កាត់ហើយនៅវលាខ្ចី ។ ក៏នទោងព្រៃនោះ កាលពាល់ត្រូវខ្យល់ និងកម្តៅថ្ងៃ រមែងស្ងិតស្រពោន ។ បទថា **យាវស្សុ មេ សារីបុត្ត** សេចក្តីថា ម្នាលសារីបុត្ត ស្បែកពោះរបស់យើងស្ងិតជាប់នឹងឆ្អឹងខ្នង ។ ប្រការមួយទៀត គប្បីជ្រាបការសម្ព័ន្ធ ក្នុងបទនោះយ៉ាងនេះថា ម្នាលសារីបុត្ត ការបំពេញទុក្ករកិរិយារបស់យើងនៅជាការៈធ្ងន់ត្រឹមណា ស្បែកពោះរបស់យើង ក៏ស្ងិតជាប់ឆ្អឹងខ្នងត្រឹមនោះ ។ បទថា **បិដ្ឋិកណ្តកញ្ញេវ បរិគ្គណ្ហាមិ** សេចក្តីថា យើងគិតថា នឹងចាប់ស្បែកពោះស្ទាបអង្អែលស្បែកពោះ តែក៏ពាល់ត្រូវឆ្អឹងខ្នងវិញ ។ បទថា **អវកុជ្ជោ បបតាមិ** សេចក្តីថា កាលព្រះអង្គនោះ អង្គុយដើម្បីប្រយោជន៍ដល់ការបន្ទោបង់ឧច្ចារៈ បស្សាវៈ បស្សាវៈមិនចេញសោះ ប៉ុន្តែវច្ចៈមានត្រឹមតែ ១ ឬ ២ ដុំ ក៏ញាំងទុក្ខដ៏មានកម្លាំងឲ្យកើតឡើង ញើសទាំងឡាយក៏ហូរចេញចាកសរីរៈ ។ ព្រះអង្គក៏ឈឺ ដួលទ្រោបលើផែនដីក្នុងទីនោះឯង ។ ដោយហេតុនោះ ទើបត្រាស់ថា យើងដួលទ្រោប ដូច្នេះ ។ បទថា **តមេវ កាយំ** បានដល់ កាយទីបំផុត ក្នុង ៩១ កប្ប ។ ក៏ទ្រង់សំដៅដល់កាយក្នុងភពចុងក្រោយ ក្នុងមហាសច្ចកសូត្រ ទើបត្រាស់ថា **ឥមមេវ កាយំ** ដូច្នេះ ។ បទថា **បូតិមូលានិ** សេចក្តីថា កាលព្រះមំសៈ ឬព្រះលោហិតនៅមានព្រះលោមា

ទាំងឡាយ ក៏តាំងនៅបាន តែព្រោះមិនមានព្រះមំសៈ ព្រះលោហិតនោះ ព្រះលោមាទាំងឡាយ ដូចជាប់នៅក្នុងផ្ទាំងស្បែក ក៏ជ្រុះជាប់ព្រះហត្ថា ដែរទ្រង់សំដៅដល់អាការនោះ ទើបត្រាស់ថា រោមទាំងឡាយ មានគល់ស្អុយក៏ជ្រុះចេញពីកាយ ដូច្នេះ ។

[១៨៦] បទថា **អលមរិយញាណទស្សនវិសេសំ** បានដល់ លោកុត្តរមគ្គដែលអាចដើម្បីធ្វើភាពជាអរិយៈបាន ។ បទថា **ឥមិស្សាយេវ អរិយាយ បញ្ញាយ** សេចក្តីថា ព្រោះមិនសម្រេចវិបស្សនាបញ្ញា ។ បទថា **យាយំ អរិយា** បានដល់ សម្រេចមគ្គប្បញ្ញានេះ ។ លោកពោលទុកដូច្នេះថា ឈ្មោះថា សម្រេចមគ្គប្បញ្ញា ព្រោះវិបស្សនាបញ្ញាបានសម្រេចហើយក្នុងឥឡូវនេះ យ៉ាងណា យើងមិនសម្រេចលោកុត្តរមគ្គប្បញ្ញា ព្រោះវិបស្សនាបញ្ញាមិនបានសម្រេចហើយ ក្នុងទីបំផុត ៩១ កប្ប ដូច្នេះ ។ ចំណែកមជ្ឈិមភាណកត្ថេរៈ ពោលថា បញ្ញាដែលពោលថា **ឥមិស្សាយេវ** ក្តី បញ្ញាដែលពោលថា **យាយំ អរិយា** ក្តី គឺ មគ្គប្បញ្ញានោះឯង ។ លំដាប់នោះ ភិក្ខុទាំងឡាយបានពោលនឹងមជ្ឈិមភាណកត្ថេរៈនោះថា បពិត្រលោកដ៏ចម្រើន បើដូច្នោះពាក្យថា យើងមិនបានសម្រេចមគ្គ ព្រោះការដែលមគ្គបានសម្រេចហើយនេះ លោកបានពោលហើយ ។ ព្រះថេរៈពោលថា ម្នាលអាវុសោ យើងមិនអាចដើម្បីសម្តែងក៏ពិត តែបញ្ញាសូម្បី ២ យ៉ាងនោះ គឺ មគ្គប្បញ្ញានោះឯង ។ ពាក្យនោះឯង សមគួរហើយក្នុងទីនេះ ។ ដោយប្រការនេះ និទ្ទេសថា **យា អយំ** ក៏មិនសមគួរ ។

[១៨៧] បទថា **សំសារេន សុទ្ធិ** គឺ ពោលថា សត្វទាំងឡាយត្រាច់ទៅដោយច្រើនជាតិ រមែងបរិសុទ្ធ ។

[១៨៨] បទថា **ឧបបត្តិយា សុទ្ធិ** បានដល់ ពោលថា កើតឡើងច្រើនជាតិ រមែងបរិសុទ្ធ ។

[១៨៩] បទថា **អាវាសេន សុទ្ធិ** គឺ ពោលថា នៅក្នុងទីទាំងឡាយច្រើន រមែងបរិសុទ្ធ ។ លោកពោលដល់ខន្ធទាំងឡាយនោះឯង ក្នុងឋានៈសូម្បី ៣ ថា **សង្សារ** ដោយអំណាចអ្នកត្រាច់ទៅ , **ឧប្បត្តិ** ដោយអំណាចអ្នកកើត , **អាវាស** ដោយអំណាចអ្នករស់នៅ ។

[១៩០] បទថា **យញ្ញេន** បានដល់ ពោលថា បូជាយញ្ញច្រើន រមែងបរិសុទ្ធ ។ បទថា **មុទ្ធាវសិត្តេន** សេចក្តីថា អភិសេកជាក្សត្រដោយសង្ខ ៣ ។

[១៩១] បទថា **អគ្គិបារិចរិយាយ** បានដល់ ពោលថា រមែងបរិសុទ្ធដោយការបម្រើភ្លើង ។

[១៩២] បទថា **ទហរោ** គឺ ក្មេងកំលោះ ។ បទថា **យុវា** បានដល់ ដល់ព្រមដោយភាពជាក្មេងកំលោះ ។ បទថា **សុសុកាឡកេសោ** គឺ មានសក់ខ្មៅរលោង ។ បទថា **បញ្ញាវេយ្យត្តិយេន** បានដល់ ភាពជាអ្នកមានបញ្ញាដ៏ឈ្លាសវៃ ។ បទថា **ជិណ្ណោ** គឺ អ្នកដែលជរាគ្របសង្កត់ ។ បទថា **វុឌ្ឍោ** បានដល់ មានអវយវៈតូចធំ ចម្រើនពេញលេញហើយ ។ បទថា **មហល្លកោ** គឺ អ្នកធំដោយជាតិ ។ បទថា **អទ្ធគតោ** បានដល់ កន្លងអស់កាលជាយូរហើយ ។ បទថា **វយោ អនុប្បត្តោ** មានន័យថា ធ្លងបច្ឆិមវ័យ

ដែលជាចំណែកទី ៣ នៃ ១០០ ឆ្នាំ ។ បទថា **អសីតិកោ មេ វយោ វត្តតិ** មានន័យថា ព្រះមានព្រះភាគទ្រង់ត្រាស់ព្រះសូត្រនេះ ក្នុងឆ្នាំដែលបរិនិព្វាន ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **បរមាយ** គឺ ឧត្តម ។ រមែងពោលដល់ ១០០ បទខ្លះ ១០០០ បទខ្លះ ក្នុងបទថា **សតិយា** ជាដើម ភាពជាអ្នកអាចរៀន ឈ្មោះថា **សតិ** ។ ភាពជាអ្នកទ្រទ្រង់ទុក និងចាំទុក ឈ្មោះថា **គតិ** សេចក្តីព្យាយាមដើម្បីសិក្សា រៀនសូត្រ ស្វាធ្យាយ និងទ្រទ្រង់ចាំទុកយ៉ាងនេះ ឈ្មោះថា **ធិតិ** ភាពជាអ្នកអាចយល់នូវអត្ថ និងហេតុនៃធិតិ ឈ្មោះថា **បញ្ញាវេយ្យត្តិយ** ។ បទថា **ទឡ្ហធម្មោ ធនុគ្គហោ** មានន័យថា អ្នកកាន់ធ្នូដ៏រឹងមាំ ។ កម្លាំង ២០០០ ហៅថា ទឡ្ហធ្នូ ធ្នូណាដែលលើកឡើងហើយ មានខ្សែចងមានទម្ងន់ស្មើដុំដែកជាដើម រួចចាប់ដងលើកឡើងផុតពីផែនដី ប្រមាណត្រឹមកធ្នូនោះ ឈ្មោះថា មានកម្លាំង ២០០០ ។ បទថា **សិក្ខិតោ** មានន័យថា មានសិល្បៈដែលរៀនហើយ ក្នុងត្រកូលអាចារ្យ ១២ ឆ្នាំ ។ បទថា **កតហត្ថោ** មានន័យថា អ្នកខ្លះរៀនត្រឹមសិល្បៈប៉ុណ្ណោះ មិនបានទទួលការហ្វឹកហាត់ តែនាយធ្នូនេះ បានទទួលការហ្វឹកហាត់ហើយយ៉ាងស្ទាត់ជំនាញ យ៉ាងចំណាប់ ធ្លាប់បង្ហាញថ្វីដៃមកហើយ គឺ មានសិល្បៈដែលបានបញ្ចេញហើយក្នុងទីទាំងឡាយ មានរាជត្រកូលជាដើម ។ បទថា **លហុកេន អសនេន** សេចក្តីថា ដោយកូនព្រួញខ្នាតស្រាល ដែលលាបលនដោយល័ក្ត ដែលចោះរន្ធទុកខាងក្នុង ហើយធ្វើឲ្យស្មើខ្សែជាដើម ។ ព្រួញសរដែលធ្វើយ៉ាងនេះ អាចចាក់ទម្លុះគោឧសភៈ ១ ក្បាល , ធ្លុះគោ

ឧសភៈ ២ ក្បាលបាន , ព្រួញដែលធ្ងុះគោឧសភៈ ៨ ក្បាល , ១៦ ក្បាល បាន ។ បទថា **អប្បកសិរេន** បានដល់ ដោយមិនលំបាក ។ បទថា **អតិបាតេយ្យ** គឺ គប្បីឲ្យធ្ងុះ ។ បទថា **ឯវំ អធិ មត្តសតិមន្តោ** សេចក្តីថា ធ្នូនោះ រមែងបាញ់ស្រមោល ១ ចំអាម ៤ ធ្នាប់ បានលឿនរហ័ស យ៉ាងណា អាចដើម្បីរៀន ដើម្បីចងចាំ ដើម្បីស្វាធ្យាយ ១០០ បទខ្លះ ១០០០ បទខ្លះ និងដើម្បីពិចារណាខ្លឹមសារ និងហេតុទាំងឡាយបាន ដូច្នោះ ។ បទថា **អញ្ញត្រ អសិតបីតខាយិតសាយិតា** សេចក្តីថា ក៏កិច្ចទាំងឡាយមានការស៊ី និងការផឹកជាដើម ជាកិច្ចដែលព្រះមានព្រះភាគក្តី ភិក្ខុទាំងឡាយក្តីគប្បីធ្វើ ព្រោះដូច្នេះ ទើបសម្តែងថា លើកលែងតែពេលធ្វើកិច្ចទាំងឡាយមានការស៊ី និងការផឹកជាដើមនោះ ។ បទថា **អបរិយាទិន្នាយេវ** មានន័យថា ដែលមិនចេះចប់ ។ ក៏បើភិក្ខុ ១ អង្គ សួរកាយានុបស្សនា , ១ អង្គទៀតសួរវេទនានុបស្សនា , ១ អង្គទៀត សួរចិត្តានុបស្សនា , ១ អង្គទៀត សួរធម្មានុបស្សនា , ភិក្ខុ ១ អង្គ ៗ រមែងមិនសម្លឹងមើលគ្នាថា ត្រូវភិក្ខុនេះសួរហើយ ក៏នឹងសួរដែរ ។ សូម្បីកាលបើដូច្នេះ វារៈរបស់ភិក្ខុទាំងនោះ រមែងប្រាកដ ។ តែវារៈរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ រមែងមិនប្រាកដយ៉ាងនេះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ កាយានុបស្សនាដោយ ១៤ វិធី , វេទនានុបស្សនាដោយ ៩ វិធី , ចិត្តានុបស្សនាដោយ ១៦ វិធី , ធម្មានុបស្សនាដោយ ៥ វិធី លឿនជាងការបាញ់ស្រមោល ១ ចំអាម ៤ ធ្នាប់ យ៉ាងធាប់រហ័សទៅទៀត ។ សតិប្បដ្ឋាន ៤ នោះ ចូរលើកទុកសិន ។

ក៏បើភិក្ខុ ៤ អង្គដទៃ គប្បីសួរបញ្ហាក្នុងសម្មប្បធានទាំងឡាយ មួយពួកទៀត សួរបញ្ហាក្នុងឥទ្ធិបាទ , មួយពួកទៀត គប្បីសួរបញ្ហាក្នុងឥន្ទ្រិយ៍ ៥ , មួយពួកទៀតគប្បីសួរបញ្ហាក្នុងពលៈ ៥ , មួយពួកទៀត គប្បីសួរបញ្ហាក្នុងពោជ្ឈង្គៈ ៧ , មួយពួកទៀតគប្បីសួរបញ្ហាក្នុងអង្គមគ្គ ៨ សោតព្រះមានព្រះភាគ គប្បីត្រាស់បញ្ហាបានដោយងាយ ។ម្យ៉ាងទៀត អង្គមគ្គ ៨ គួរលើកទុក ។

បើជន ៣៧ នាក់ គប្បីសួរបញ្ហាក្នុងពោធិបក្ខិយធម៌ទាំងឡាយសោតព្រះមានព្រះភាគ ក៏គប្បីត្រាស់បញ្ហាសូម្បីទាំងនោះ បានយ៉ាងរហ័ស ។ ព្រោះហេតុអ្វី ព្រោះមហាជនក្នុងលោក រមែងពោលបាន ១ បទ ដោយប្រមាណប៉ុនណា ព្រះអានន្ទត្ថេរ រមែងពោលបាន ៨ បទ ដោយប្រមាណប៉ុណ្ណោះ ។ ក៏កាលបើព្រះអានន្ទត្ថេរពោលបាន ១ បទ ប៉ុណ្ណោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់បាន ១៦ បទ ។ ព្រោះហេតុអ្វី ព្រោះជីវ្ហាព្រះមានព្រះភាគ ទន់ ព្រះទន្តស្មើស្និទ្ធ ព្រះវចនៈមិនជាប់គ្នា ភវង្គបរិវាសរហ័ស ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ម្នាលសារីបុត្រ ធម្មទេសនារបស់តថាគតនោះ ទើបមិនចេះអស់ ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ធម្មទេសនា** បានដល់ ដាក់ របៀប បែប ផែន ។ បទថា **ធម្មបទព្យញ្ជនំ** សេចក្តីថា បទព្យញ្ជនៈនៃបាលី គឺ អក្សរដែលជាតួព្យញ្ជនៈនៃអត្ថនោះៗ ។ បទថា **បញ្ហបដិភាណំ** បានដល់ បញ្ហាព្យាករណ៍ ទ្រង់សម្តែងអ្វីដល់បទនេះ ។ ទ្រង់សម្តែងយ៉ាងនេះថា ក្នុងកាលមុនពេលនៅកំលោះ តថាគតរមែងអាច

ប្រមូលអក្សរទាំងឡាយ ពោលជាបទបាន រមែងអាចប្រមូលបទទាំងឡាយ ពោលជាគាថាបាន រមែងអាចពោលអត្ថដោយគាថា ដែលប្រកបដោយបទ មាន ៤ អក្សរខ្លះ មាន ១៦ អក្សរខ្លះ តែដល់ពេលចាស់ដូចឥឡូវនេះ មិនអាចដើម្បីប្រមូលអក្សរទាំងឡាយពោលជាបទ ឬប្រមូលបទទាំងឡាយ ពោលជាគាថា ឬពោលអត្ថដោយគាថាបាន ដូចពោលមកនេះ រមែងមិនមាន ក្នុងពេលកំលោះ និងក្នុងពេលចាស់ ធម្មទេសនាជាដើមទាំងអស់នោះរបស់ តថាគតមិនចេះអស់ ។ បទថា **មញ្ចកេន ចេបិ មំ** សេចក្តីថា ទ្រង់ កំណត់បទនេះហើយ ទ្រង់ត្រាស់សម្តែងកម្លាំងរបស់ព្រះពុទ្ធនោះឯង ។ ដែល ឈ្មោះថា កាលក្នុងការលើកព្រះទសពលឡើងកាន់គ្រែជម្មាសនៈតូចហើយ គប់គ្រងទូទៅក្នុងស្រុកនិគម និងរាជធានីមិនមាន ។ ក៏ព្រះតថាគតទាំង ឡាយ មានលក្ខណៈព្រះទន្តបាក់ជាដើម មិនគ្របសង្កត់ហើយក្នុងចំណែក នៃអាយុទី ៥ មិនមានការផ្លាស់ប្តូរនូវវណ្ណៈនៃព្រះសរីរៈ ដែលមានពណ៌ដូច មាសឡើយ ហើយរមែងបរិនិព្វានក្នុងកាលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ ទេវតា និងមនុស្សទាំងឡាយនោះឯង ។

[១៩៣] បទថា **នាគសមាលោ** ជាឈ្មោះរបស់ ព្រះថេរៈនោះ ។ ក៏ក្នុងបឋមពោធិកាល រវាងខាងក្នុង ២០ ឆ្នាំ ព្រះនាគសមាលៈនេះ ជា ឧបដ្ឋាករបស់ព្រះមានព្រះភាគ ដូចព្រះឧបវានត្ថេរ ព្រះនាគិតត្ថេរ និង ព្រះមេឃិយត្ថេរ ។ បទថា **វីជយមានោ** គឺ ញុំាងសេចក្តីសុខក្នុងរដូវ ឲ្យតាំងឡើងដល់ព្រះមានព្រះភាគជាម្ចាស់ ដោយខ្យល់បក់ពីផ្ចិតស្លឹក ត្នោត

ដ៏ទន់ ៗ បទថា **ឯតទវោច** សេចក្តីថា ព្រះថេរៈស្តាប់ព្រះសូត្រទាំងអស់ចប់ហើយ អាស្រ័យការបំពេញទុក្ករកិរិយា ដែលធ្លាប់បំពេញមកក្នុងកាលមុនរបស់ព្រះមានព្រះភាគជាម្ចាស់ ជ្រះថ្លាហើយ ទើបក្រាបទូលមានពាក្យជាអាទិ៍ថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនេះអស្ចារ្យពេកណាស់ ដូច្នេះ ។ ក្នុងបទនោះ ឈ្មោះថា **អច្ឆរិយ** ព្រោះគួរហើយ ដើម្បីទះដៃអបអរ ។ ឈ្មោះថា **អព្ភូត** ព្រោះមិនធ្លាប់មាន ក៏ត្រឡប់ជាមាន ។ ព្រះថេរៈសម្តែងសេចក្តីប្លែករបស់ខ្លួនឯង ដោយបទទាំងពីរ ។ ក្រាបទូលពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះឈ្មោះអ្វី ដោយសេចក្តីបំណងថា ធម្មបរិយាយនេះ ប្រសើរហ្ន៎ ! ណ្ហើយចុះ យើងនឹងទូលសូមព្រះមានព្រះភាគឲ្យទ្រង់ដាក់ឈ្មោះនូវធម្មបរិយាយនេះ ។ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ដាក់ឈ្មោះដល់ធម្មបរិយាយនោះ ទើបត្រាស់ថា **តស្មា តិហ ត្វំ** ជាដើម ។ ខ្លឹមសារនៃធម្មបរិយាយនោះថា រោមទាំងឡាយរបស់អ្នកបះឡើង ព្រោះស្តាប់ព្រះសូត្រនេះ ព្រោះហេតុនោះ នាគសមាលៈ អ្នកចូរទ្រទ្រង់ចាំធម្មបរិយាយនេះថា **លោមហំសនបរិយាយ** ដូច្នេះឯង ។

( ចប់អដ្ឋកថា មហាសីហនាទសូត្រទី ២ )

# អដ្ឋកថា

## មហាទុក្ខក្ខន្ធសូត្រ ទី ៣

[១៩៤-១៩៥] មហាទុក្ខក្ខន្ធសូត្រមានពាក្យផ្តើមថា ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ ៖

ក្នុងមហាទុក្ខក្ខន្ធសូត្រនោះ ក្នុងវិនយបរិយាយ ជន ៣ នាក់ ហៅថា **សម្ពហុលា** ច្រើនជាងនោះ ហៅថា **សង្ឃ** ។ ក្នុងសុត្តន្តបរិយាយ ជន ៣ នាក់ គឺជា ៣ នាក់នោះឯង ច្រើនជាង ៣ នាក់នោះ ហៅថា **សម្ពហុលា** ។ គប្បីជ្រាបថា **សម្ពហុលា** ដោយសុត្តន្តបរិយាយក្នុងសូត្រនេះ ។ បទថា **បិណ្ឌាយ បាវិសឹសុ** បានដល់ ចូលទៅហើយ ។ ក៏ភិក្ខុទាំងនោះ មិនបានចូលទៅ ហើយគិតថា ពួកយើងនឹងចូលទៅ តែកាលចេញមក ទើបពោលថា **បាវិសឹសុ** យ៉ាងណា ដូចជាបុរសដែលចេញទៅថា យើងនឹងទៅកាន់ស្រុក សូម្បីមិនទាន់ដល់ស្រុកនោះ លុះគេពោលថា បុរសឈ្មោះនេះទៅណា ហៅថាទៅកាន់ស្រុកហើយ យ៉ាងណា ភិក្ខុទាំងឡាយក៏ដូច្នោះ ។ បទថា **បរិ-ព្វាជកានំ អារាមោ** សេចក្តីថា មានអារាមរបស់ពួកអន្យតិរ្ថិយបរិព្វាជកក្នុងទីមិនឆ្ងាយពីវត្តជេតពន សំដៅដល់អារាមនោះ ទើបពោលយ៉ាងនោះ ។ បទថា **សមណោ អាវុសោ** សេចក្តីថា ម្នាលអ្នកដ៏មានអាយុ ព្រះសម-ណគោតម ព្រះសាស្តារបស់ពួកលោក ។ បទថា **កាមានំ បរិញ្ញំ** សេចក្តីថា ព្រះសមណគោតមទ្រង់បញ្ញត្តការលះ គឺ ការឈានកន្លងកាមទាំងឡាយ ។

សូម្បីក្នុងរូប វេទនាជាដើម ក៏ន័យនេះដូចគ្នា ។ ក្នុងសេចក្ដីនោះ ពួកតិត្ថិយ អ្នកដឹងលទ្ធិរបស់ខ្លួន គប្បីបញ្ញត្តការកំណត់ ដឹងនូវកាមទាំងឡាយ ការពោល ដល់បឋមជ្ឈាន គប្បីបញ្ញត្តការកំណត់ដឹងនូវរូបទាំងឡាយ កាលពោលដល់ អរូបកព គប្បីបញ្ញត្តការកំណត់ដឹងនូវវេទនា កាលពោលដល់អសញ្ញីភព ក៏គប្បីបញ្ញត្តការកំណត់ដឹងនូវវេទនាទាំងឡាយ ។ តែតិត្ថិយទាំងនោះ រមែង មិនដឹងថា នេះបឋមជ្ឈាន នេះរូបភព នេះអរូបភព កាលមិនអាចបញ្ញត្ត ទើបនិយាយថា ពួកយើងនឹងបញ្ញត្តតែម្យ៉ាង ។ ព្រះតថាគត ទ្រង់បញ្ញត្ត ការកំណត់ដឹងនូវកាមទាំងឡាយ ដោយអនាគាមិមគ្គ ទ្រង់បញ្ញត្តការកំណត់ ដឹងនូវរូប និងវេទនាទាំងឡាយ ដោយអរហត្តមគ្គ តិត្ថិយទាំងនោះ កាលមាន សេចក្ដីប្លែកគ្នាយ៉ាងនេះ ទើបពោលថា **ឥធ នោ អាវុសោ កោ វិសេសោ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ឥធ** គឺ ក្នុងការបញ្ញត្តិនេះ ឬ ក្នុងការសម្ដែងធម៌នេះ ។ បទថា **ធម្មទេសនំ** សេចក្ដីថា តិត្ថិយទាំងឡាយ ពោលថា ពួកលោកពោលវត្ថុឲ្យផ្សេងគ្នា ប្រារព្ធនូវធម្មទេសនារបស់ពួក យើង និងធម្មទេសនារបស់សមណគោតម ឬប្រារព្ធធម្មទេសនារបស់ព្រះ សមណគោតម និងធម្មទេសនារបស់ពួកយើងនេះ មានហេតុផ្សេងគ្នា យ៉ាង ណា ។ សូម្បីក្នុងបទទាំងពីរ ក៏មានន័យដូចគ្នា ។ តិត្ថិយទាំងនោះ តាំង ធុរៈស្មើគ្នាដោយហេតុត្រឹមតែពោលថា លទ្ធិរបស់ខ្លួន និងសាសនា ដូចមាស បែកចំកណ្ដាល ដោយប្រការដូច្នេះ ។ បទថា **នេវ អភិនន្ទឹសុ** គឺ មិនព្រម ទទួលថា ពាក្យនុ៎ះ ជាយ៉ាងនោះ ។ បទថា **នប្បដិក្កោសឹសុ** បានដល់

ការមិនបដិសេធថា ពាក្យនោះមិនជាយ៉ាងដូច្នេះ ។ ព្រោះហេតុអ្វី ។

បានឮថា ធម្មតាតិរ្ថិយទាំងនោះ ដូចជាមនុស្សខ្វាក់ ដឹងហើយក៏ដោយ មិនដឹងក៏ដោយ ក៏គប្បីពោល ព្រោះដូច្នោះ ភិក្ខុទាំងឡាយ ទើបមិនត្រេកអរ ។ មិនហាមឃាត់ថា ក្ខិនរបស់សាសនាមានតិចតួច ដោយពាក្យថា **បរិញ្ញំ** ។ បានធ្វើទាំង ២ យ៉ាង ដោយគិតថា តិរ្ថិយទាំងនោះ ជាអ្នកជនបទមិនច្បាស់ក្នុងលទ្ធិរបស់ខ្លួន និងលទ្ធិដទៃ ។

[១៩៦] បទថា **ន ចេវ សម្បាយិស្សន្តិ** សេចក្ដីថា នឹងមិនអាចដោះស្រាយឲ្យពេញចិត្តបាន ។ បទថា **ឧត្តរិញ្ច វិឃាតំ** សេចក្ដីថា ព្រមដោយការចង្អៀតចង្អល់យ៉ាងក្រៃលែង ។ ទុក្ខ រមែងកើតឡើងដល់តិរ្ថិយទាំងឡាយ ដែលសូម្បីមិនអាចនឹងដោះស្រាយបានដោយសេចក្ដីពេញចិត្ត ។ ពាក្យថា **តំ** ក្នុងបទនេះថា **យថាតំ ភិក្ខវេ អវិសយស្មឹ** ត្រឹមតែជានិបាត ពាក្យថា **យថា** ជាតតិយាវិភត្តិ អធិប្បាយថា ព្រោះជាអ្នកត្រូវសួរហើយក្នុងបញ្ហាដែលមិនមែនជាវិស័យ ។ បទថា **សទេវកេ** បានដល់ ប្រព្រឹត្តទៅជាមួយទេវលោក សូម្បីក្នុងបទថា **សមារកេ** ជាដើម ក៏ន័យដូចគ្នា ។ ព្រះមានព្រះភាគបន្ថែមឋានៈ ៣ ចូល ជាលោកយ៉ាងនេះហើយ ទ្រង់កំណត់សត្វលោកនោះថា ពួកសត្វ ២ រួមជា ៥ ហើយ ទ្រង់សម្ដែងថា តថាគតមិនឃើញទេវតា ឬមនុស្សណា ៗ ក្នុងលោក ដែលផ្សេងដោយទេវលោកជាដើមនោះ ។ បទថា **ឥតោ វា បន សុត្វា** សេចក្ដីថា ឬក៏ស្ដាប់អំពីនេះ គឺពីសាសនារបស់តថាគត ។ ទ្រង់សម្ដែងថា អ្នកមិនមែនជាតថាគតក្ដី សាវក

របស់អ្នកមិនមែនជាតថាគតក្តី ស្តាប់អំពីនេះហើយ គប្បីត្រេកអរ គប្បីពេញចិត្ត ដែលឈ្មោះថា សេចក្តីត្រេកអរដោយប្រការដទៃ មិនមាន ។

[១៩៧] ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងការញ៉ាំងចិត្តឲ្យត្រេកអរ ដោយការព្យាករណ៍បញ្ហាទាំងនោះរបស់ព្រះអង្គ ទើបទ្រង់ត្រាស់ថា **កោ ច ភិក្ខវេ** ដូច្នេះជាដើម ។ បទថា **កាមគុណា** សេចក្តីថា ឈ្មោះថា **កាម** ព្រោះអត្ថថា ដែលបុគ្គលគប្បីត្រេកអរ ឈ្មោះថា **គុណ** ព្រោះអត្ថថា គ្រឿងចង អត្ថថា **បូក** ឈ្មោះថា **គុណ** អត្ថក្នុងបទនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងអនុញ្ញាតសង្ឃាដី ២ ជាន់ សម្រាប់សំពត់ដែលបានមក ។ អត្ថថា **នៅ** ឈ្មោះថា **គុណ** អត្ថក្នុងបទនេះថា កាលវែងកន្លងទៅ រាត្រីវែងកន្លងទៅ ជំនាន់នៃវ័យវែងអស់ទៅតាមលំដាប់ ។ អត្ថថា **អានិសង្ស** ឈ្មោះថា **គុណ** អត្ថក្នុងបទនេះថា ទក្ខិណាដែលមានគុណទាំងរយ ដែលបុគ្គលគប្បីប្រាថ្នា ។ អត្ថថា **គ្រឿងចង** ឈ្មោះថា **គុណ** អត្ថក្នុងបទនេះថា គប្បីធ្វើទីបំផុត ក្រុមទីបំផុតពួកមាលាមានច្រើន ។ លោកបំណងយកអត្ថថា **គ្រឿងចង** នោះតែម្យ៉ាង ។ សូម្បីក្នុងបទនេះ ។ ព្រោះដូច្នោះ លោកទើបពោលថា ឈ្មោះថា **គុណ** ព្រោះអត្ថថា **គ្រឿងចង** ដូច្នេះ ។ បទថា **ចក្ខុវិញ្ញេយ្យា** សេចក្តីថា គប្បីឃើញដោយចក្ខុវិញ្ញាណ ។ គប្បីជ្រាបអត្ថសូម្បីក្នុង **សោតវិញ្ញេយ្យ** ជាដើម ដោយទំនងនេះ ។ បទថា **ឥដ្ឋា** សេចក្តីថា ចូរត្រេកអរក៏ដោយ មិនត្រេកអរក៏ដោយ ក៏ជាឥដ្ឋារម្មណ៍ ។ បទថា **កន្តា** បានដល់ គប្បីឲ្យ ។ បទថា **មនាបា** គឺ ឲ្យចម្រើនចិត្ត ។ បទថា

**បិយរូបា** គឺ កើតសេចក្តីស្រឡាញ់ ។ បទថា **កាមូបសញ្ហិតា** សេចក្តីថា ប្រកបហើយដោយកាមដែលធ្វើជាអារម្មណ៍ ឲ្យកើតឡើង ។

បទថា **រជនីយា** បានដល់ គប្បីត្រេកត្រអាល អធិប្បាយថា ជាហេតុកើតឡើងនៃរាគៈ ។

[១៩៨] ក្នុងបទទាំងឡាយថា **យទិ មុទ្ទាយ** ជាដើម ។ បទថា **មុទ្ទាយ** បានដល់ ដោយការតាំងសញ្ញាក្នុងសេចក្តីនេះ ហើយរាប់ម្រាមដៃ ។ បទថា **គណនាយ** បានដល់ ដោយការរាប់ចំនួនមិនខុស ។ បទថា **សង្ខាន** សេចក្តីថា ជនទាំងឡាយ មើលស្រែហើយរាប់ថា ក្នុងស្រែនេះ ប្រហែលជាបានស្រូវប៉ុណ្ណេះ ឬមើលដើមឈើហើយរាប់ថា ដើមឈើនេះ ប្រហែលជាមានផ្លែប៉ុណ្ណេះ ក្រឡេកមើលអាកាស ក៏ដឹងថា ក្នុងអាកាស នឹងមានបក្សីប្រមាណប៉ុណ្ណេះ ។ បទថា **កសិ** បានដល់ កសិកម្ម ។ បទថា **វណិជ្ជា** បានដល់ ការជួញដូរ មានការជួញតាមផ្លូវទឹក និងការជួញ តាមផ្លូវគោក ជាដើម ។ បទថា **គោរក្ខំ** បានដល់ ការរក្សាគោរបស់ខ្លួន ឬរបស់អ្នកដទៃ ធ្វើការចិញ្ចឹមជីវិតដោយការលក់បញ្ចគោរស ។ ការកាន់អាវុធ ហើយធ្វើការបដិបត្តិ ហៅថា ការបាញ់ធ្នូ ។ បទថា **រាជបោរិសំ** បានដល់ ការធ្វើរាជការដោយអាវុធឲ្យប្រាកដ ។ បទថា **សិប្បញ្ញតរំ** បានដល់ សិល្បៈ មានសិល្បៈព្រោះដំរី ឬសិល្បៈព្រោះ សេះជាដើមដ៏សេសអំពីទីដែលបញ្ជាក់ទុកហើយ ។ បទថា **សីតស្ស បុរក្ខតោ** សេចក្តីថា ប្រឈមមុខនឹងកាពរងារ ដូចទីដៅប្រឈមមុខ នឹងព្រួញសរដូច្នេះ អធិប្បាយថា អ្នកត្រូវកាពរងារ

បៀត បៀន សុម្ភី នៅក្នុងសភាពក្តៅ ក៏មានន័យដូចគ្នា ។ ក្នុងបទថា **ឌំសា** ជាដើម បទថា **ឌំសា** បានដល់ របោម ។ បទថា **មកសា** បានដល់ សត្វល្អិតគ្រប់ប្រភេទ ។ បទថា **សិរឹសបា** បានដល់ ពពួកសត្វលូន ។ បទថា **រិស្សមានោ** បានដល់ កម្រើកញ័រ អន្ទះអន្ទែង ។

បទថា **មិយ្យមានោ** បានដល់ ស្លាប់ ។ បទថា **អយំ ភិក្ខវេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីលំបាក ដែលអាស្រ័យការចិញ្ចឹមជីវិតដោយសិល្បៈ មានការរាប់លេខទព្វន្តជាដើម មានភាពរងារជាដើម ជាបច្ច័យ ។ បទថា **កាមានំ អាទីនវោ** គឺ ជាអន្តរាយ សេចក្តីថា ជាឧបសគ្គក្នុងកាមទាំងឡាយ ។ បទថា **សន្ទិដ្ឋិកោ** គឺ ប្រចក្ស បានដល់ គប្បីឃើញដោយខ្លួនឯង ។ បទថា **ទុក្ខក្ខន្ធោ** បានដល់ ជាកងទុក្ខ ។ ក្នុងបទទាំងឡាយ មានកាមហេតុជាដើម កាមទាំងឡាយឈ្មោះថា ជាហេតុនៃទោសនោះ ព្រោះអត្ថថា ជាបច្ច័យ ព្រោះដូច្នោះ ទោសនោះ ទើបឈ្មោះថា **កាមហេតុ** ប្រែថា មានកាមជាហេតុ ។ កាមទាំងឡាយ ឈ្មោះថា ជាដើមចមរបស់ទោសនោះ ព្រោះអត្ថថា ជាឫសគល់ ព្រោះដូច្នោះ ទោសនោះទើបឈ្មោះថា **កាមនិទាន** ប្រែថា មានកាមជាដើមហេតុ ។ តែលោកពោលថា **កាមនិទានំ** ព្រោះឃ្លៀងឃ្លាតផ្លូវលិង្គ កាមទាំងឡាយឈ្មោះថា ជាតួបង្កើតនៃទោសនោះ ព្រោះអត្ថថា ការណ៍ ព្រោះដូច្នោះ ទោសនោះទើបឈ្មោះថា **កាមាធិករណ** ប្រែថា មានកាមជាតួបង្កើត ។ តែលោកពោលថា **កាមាធិករណំ** ព្រោះការឃ្លៀងឃ្លាតផ្លូវលិង្គ ។ បទថា **កាមានមេវ**

**ហេតុ** នេះជាពាក្យកំណត់ អធិប្បាយថា ទោសកើតឡើង ព្រោះកាមជាបច្ច័យនោះឯង ។ បទថា **ឧដ្ឋហតោ** គឺ ឧស្សាហ៍ ដោយសេចក្ដីព្យាយាមជាហេតុ ឲ្យមានអាជីពជាលក្ខគោល ។ បទថា **ឃដតោ** បានដល់ បន្តការព្យាយាមនោះឲ្យច្រើនឡើងជាងក្នុងថ្ងៃមុន ៗ ។ បទថា **វាយមតោ** សេចក្ដីថា ធ្វើការព្យាយាម ការឧស្សាហ៍ ការប្រកប ។ បទថា **នាភិនិប្ផជ្ជន្តិ** សេចក្ដីថា ភោគៈនោះ រមែងមិនសម្រេច គឺ មិនមកដល់ដៃ ។ បទថា **សោចតិ** គឺ រមែងសោយសោក ដោយសេចក្ដីសោយសោកដ៏ខ្លាំងក្លាកើតឡើងក្នុងចិត្ត ។ បទថា **កិលមតិ** បានដល់ រមែងលំបាកដោយទុក្ខដែលកើតឡើងក្នុងកាយ ។ បទថា **បរិទេវតិ** បានដល់ រមែងត្អូញត្អែរដោយវាចា ។ បទថា **ឧរត្តាឡឹ** គឺ គក់ទ្រូង ។ បទថា **កន្ទតិ** បានដល់ រមែងទ្រហោយំ ។ បទថា **សម្មោហំ អាបជ្ជតិ** សេចក្ដីថា ជាអ្នកវង្វេងវាយដោយការប្រាសចាកការដឹងខ្លួន ។ បទថា **មោឃំ** ប្រែថា ទទេ ។ បទថា **អផលោ** បានដល់ ឥតផល ។ បទថា **អារក្ខាធិករណំ** គឺ មានការគ្រប់គ្រងជាហេតុ ។ បទថា **កិន្តិ មេ** គឺ ដោយឧបាយដូចម្ដេចហ្ន៎ ។ បទថា **យំបិ មេ** សេចក្ដីថា ទ្រព្យដែលយើងធ្វើការងារ មានកសិកម្មជាដើម ឲ្យកើតហើយយ៉ាងណា ។ បទថា **តម្បិ នោ នត្ថិ** សេចក្ដីថា ឥឡូវនេះ សូម្បីទ្រព្យរបស់យើងនោះ ក៏មិនមាន ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងការណ៍ ដោយបទសូម្បីមានជាដើមថា **បុន ចបរំ ភិក្ខវេ ហេតុ** ដូច្នេះ ហើយទ្រង់សម្ដែង ទោស ។

ក្នុងបទទាំងនោះ បទថា **កាមហេតុ** សេចក្ដីថា សូម្បីពួកក្សត្រ

ក៏វិវាទគ្នាជាមួយពួកក្សត្រ ព្រោះកាមជាបច្ច័យ ។ បទថា **កាមនិទានំ** ជាការនៃបុំសកលិង្គ អធិប្បាយថា ធ្វើកាមទាំងឡាយឲ្យជាដើមចម ហើយវិវាទគ្នា ។ សូម្បីបទថា **កាមាធិករណំ** ក៏ជាការនៃបុំសកលិង្គដូចគ្នា អធិប្បាយថា ធ្វើកាមទាំងឡាយឲ្យជាតួបង្គាប់ ហើយវិវាទគ្នា ។ បទថា **កាមានមេវ ហេតុ** សេចក្តីថា វិវាទគ្នា ព្រោះហេតុនៃស្រុកនិគម សេនាបតី បុរោហិត និងឋានន្តរៈជាដើម ។ បទថា **ឧបក្កមន្តិ** គឺ ប្រហារ ។ បទថា **អសិចម្មំ** បានដល់ ដាវ និងវត្ថុ មានខែលជាដើម ។ បទថា **ធនុកលាបំ សន្នយ្ហិត្វា** សេចក្តីថា កាន់ធ្នូហើយសៀតបំពង់ធ្នូ ។ បទថា **ឧភតោ ព្យូឡ្ហំ** បានដល់ ចម្បាំងគ្នាទាំងពីរខាង ។ បទថា **បក្ខន្ទន្តិ** គឺ ស្ទុះទៅ ។ បទថា **ឧសូសុ** កាលកូនសរទាំងឡាយ ។ បទថា **វិជ្ជោតលន្តេសុ** គឺ ព្រលែងទៅ ។ បទថា **តេ តត្ថ** គឺ ហ្វូងជនទាំងនោះ ក្នុងសង្គ្រាមនោះ ។ ក្នុងបទថា **អដ្ដាវលេបនា ឧបការិយោ** នោះ ក៏មនុស្សទាំងឡាយ សាងកំពែងដោយឥដ្ឋទាំងឡាយ មានសណ្ឋានដូចក្រចកសេះ ហើយលាបបូកកំបោរសខាងលើ ជើងកំពែងទាំងឡាយ ដែលធ្វើយ៉ាងនេះ ហៅថា **ឧបការិយោ** ជើងកំពែងទាំងនោះ លាបដោយភក់ក្តៅ ទើបឈ្មោះថា **អដ្ដាវលេបនា** ។ បទថា **បក្ខន្ទន្តិ** សេចក្តីថា ជនទាំងនោះ កាលបើត្រូវបាញ់ដោយអាវុធ មានព្រួញដែកស្រួចមុតជាដើម ខាងក្រោមជើងកំពែងទាំងនោះខ្លះ កាលបើមិនអាចដើម្បីរត់គេច ព្រោះកំពែងរអិលដូចខ្លាញ់ខ្លះ ទើបរត់លូនទៅមក ។ បទថា **ឆកណាដិយា** ដោយអាចម៍គោដ៏ក្តៅ ។ បទថា **អភិវគ្គេន** សេចក្តីថា ជន

ទាំងឡាយឈរត្រង់ទ្វារជាន់លើ ដែលមកដល់ថា ពួកយើងនឹងធ្វើរនាស់នោះ ព្រមទាំងធ្នេញ ដោយអាការមានធ្មេញ ៨ ទម្លាយទ្វារនគរ ចូលទៅហើយ កាត់គ្រឿងចង និងខ្សែនៃរនាស់នោះ ដោយធ្មេញនោះ ។ បទថា **សន្ធឹបិ ឆិន្ទន្តិ** គឺ កាត់ទី-តនៃផ្ទះខ្លះ ។ បទថា **និល្លោបំ** សេចក្តីថា ឡោមព័ទ្ធវាយស្រុកជាដើម ហើយធ្វើការប្លន់ធំ ។ បទថា **ឯកាគារិកំ** សេចក្តីថា ហ្វូងជនប្រមាណ ៥០ នាក់ខ្លះ ប្រមាណ ៦០ នាក់ខ្លះ ចោមវាយប្រហារ ហើយចាប់ទាំងរស់ឲ្យនាំចេញមក ។ បទថា **បរិបន្ថេ តិដ្ឋន្តិ** សេចក្តីថា ធ្វើការស្ទាក់វាយក្នុងវាងផ្លូវ ។ បទថា **អឌ្ឍទណ្ឌកេហិ** សេចក្តីថា ដោយញញួរទាំងឡាយ ឬដោយដំបង ដែលគេកាត់កំណាត់ឈើប្រមាណ ៤ ហត្ថ ដើម្បីឲ្យសម្រេចការប្រហារ ឲ្យទៅជាពីរចំណែកកាន់ទុក ។ បទថា **ពិលង្គ-ថាលិកំ** បានដល់ កម្មករណ៍ គឺ ស្ងោរដោយឆ្នាំងបាយ ។ ព្រះរាជាទាំងឡាយ កាលទ្រង់ធ្វើកម្មករណ៍នោះ ក៏បកស្បែកក្បាលចេញហើយយកដង្កាប់ចំពុះសេកចាប់ដុំដែកដែលក្តៅ ដាក់លើលលាដ៍ក្បាលនោះ ខួរក្នុងក្បាលនោះក៏ផុលឡើងលើ ។ បទថា **សំខមុណ្ឌកំ** បានដល់ អំពើដែលគេចៀរស្បែកតាំងអំពីបបូរមាត់ខាងលើរហូតដល់គំត្រចៀក ទាំងពីរវៀងមក រហូតដល់កញ្ចឹង-ក ហើយយកសក់រុំនឹងកំណាត់ឈើ រួចទាញកន្ត្រាក់ឲ្យរបើកស្បែកក្បាលចេញ ហើយយកដុំថ្មដុសខាត់លលាដ៍ក្បាលឲ្យរលីង រួចលាងទឹកឲ្យស្អាត ឲ្យសល់តែត្រឹងលលាដ៍ក្បាលដែល-ស ដូចជាសំបកស័ង្ខ ។ បទថា **រាហុមុខំ** បានដល់ អំពើដែលគេយកកន្ធារដែកថ្ពក់ មាត់ឲ្យហារ ហើយដុត

ប្រទីបក្នុងមាត់ ហើយយកពន្លាកដាប់មាត់ឲ្យរយះដល់គំត្រចៀកទាំងពីរ ឲ្យដូចជាមាត់រាហូ ។ បទថា **ជោតិមាលកំ** បានដល់ អំពើដែលគេយកក្រណាត់សំពត់ជ្រលក់ប្រេង រុំសរីរៈទាំងអស់ ហើយដុតភ្លើង ។ បទថា **ហត្ថបជ្ជោតិកំ** បានដល់ អំពើដែលគេយកក្រណាត់សំពត់ជ្រលក់ប្រេងរុំដៃទាំងពីរ ហើយដុតភ្លើងឲ្យឆេះ ។ បទថា **ឯរកវត្តិកំ** បានដល់ អំពើដែលគេធូតស្បែកពីត្រឹម-ក រហូតដល់ក-ជើង ហើយយកខ្សែចងស្បែកនោះទាញពន្លាត់ចេញ រួចឲ្យអ្នកទោសនោះ ជាន់ផ្ទាំងស្បែកឲ្យទាល់តែដួលខ្លួនចុះទៅ ។ បទថា **ចីរកវាសិនំ** បានដល់ អំពើដែលគេធូតស្បែក តាំងពីត្រឹម-កទុកត្រឹមចង្កេះ ធូតពីចង្កេះមកទុកត្រឹម-កជើង ឲ្យស្បែកខាងលើមកគ្របសរីរៈខាងក្រោម ដូចជាស្លៀកសំពត់សំបកឈើ ។ បទថា **ឯណេយ្យកំ** បានដល់ អំពើដែលគេដាក់កងដែកត្រង់ជុំដៃទាំងពីរ និងជង្គង់ទាំងពីរ ហើយលើកដាក់លើដែកអណ្តោតទាំង ៤ មានសណ្ឋានដូចជាជើងទ្រាយ អ្នកទោសនោះ ក៏ស្ថិតនៅលើដែកទាំង ៤ ដែលគេបោះជាប់នៅលើផែនដី ។ បទថា **ពឡិសមំសិកំ** បានដល់ អំពើដែលគេយកកាងបោះឲ្យជាប់សាច់ស្បែក និងសរសៃ ហើយទាញកន្ត្រាក់ឲ្យដាច់ ។ បទថា **កហាបណកំ** បានដល់ អំពើដែលគេយកចុងកាំបិតដ៏មុត ទៅឆ្កៀលយកសាច់ ឲ្យមានរណ្តៅប្រមាណប៉ុនកហាបណៈមួយ ៗ ។ បទថា **ខរាបតច្ឆិកំ** បានដល់ អំពើដែលគេយកអាវុធទៅចិញ្ច្រាំសរីរៈ ហើយយកទឹកផ្សាស្រោចឲ្យសាច់ស្បែក សរសៃរលួយជ្រុះចេញអស់ទៅ នៅសល់តែរាងឆ្អឹងទទេ ។ បទថា

*បលាលបីឋកំ* បានដល់ អំពើដែលគេឲ្យមនុស្សដេកផ្ងៀងម្ខាង ហើយយកដែកស្រួចទៅបោះប្រហោងត្រចៀក ខាងលើ ឲ្យធ្លុះរហូតដល់ប្រហោងត្រចៀកខាងក្រោមជាប់នឹងផែនដី ហើយនាំគ្នាចាប់ជើងទាញបង្វិលជុំវិញ ។ បទថា *សុនខេហិ* បានដល់ អំពើដែលគេកាត់ស្បែក ហើយយកថ្មសំលៀងកាំបិតទៅជំបំបាក់ឆ្អឹងឲ្យខ្ទេចខ្ទី ហើយចាប់ផ្នួងសក់លើកឡើងគ្រវាត់គ្រវែងឲ្យឆ្អឹងជ្រុះចេញ ឲ្យនៅសល់ជុំសាច់តែម្យ៉ាង ។ បទថា *សម្បរាយិកោ* សេចក្ដីថា ជាវិបាកក្នុងសម្បរាយភព ក្នុងអត្តភាពទី ២ ។

[១៩៩] ការកម្ចាត់បង់ឆន្ទរាគៈ ការលះបង់ឆន្ទរាគៈ គឺ និព្វាន ។ ពិតហើយ ឆន្ទរាគៈក្នុងកាមទាំងឡាយ រមែងត្រូវកម្ចាត់ និងត្រូវលះបានព្រោះអាស្រ័យនិព្វាន ព្រោះដូច្នោះ លោកទើបពោលថា ការកម្ចាត់ឆន្ទរាគៈការលះបង់ឆន្ទរាគៈ គឺ និព្វាន ។

[២០០] បទថា *សាមំ វា កាមេ បរិជានិស្សន្តិ* សេចក្ដីថា ពួកនោះឬនឹងកំណត់ដឹងកាមទាំងឡាយដោយ ខ្លួនឯងដោយបរិញ្ញា ៣ ។ បទថា *តថត្តាយ* បានដល់ ដើម្បីភាពជា តួយ៉ាងដល់អ្នកដែលបដិបត្តិ ។ បទថា *យថាបដិបន្នោ* សេចក្ដីថា បដិបត្តិហើយ ដោយបដិបទាណា ។

[២០១] បទថា *ខត្តិយកញ្ញា វា* ជាដើម ត្រាស់ហើយ ដើម្បីទ្រង់សម្ដែងស្ត្រីដែលកើតហើយក្នុងឋានៈ ដែលបានវត្ថុទាំងឡាយ មានសំពត់និងគ្រឿងប្រដាប់ជាដើម ដែលមានបដិសន្ធិដោយកុសលដ៏ច្រើន គឺ ទទួលហើយដោយបរិបូណ៌ ។ បទថា *បណ្ណរសវស្សុទ្ទេសិកា* គឺ មានវ័យ ១៥ ឆ្នាំ ។

សុម្ពីក្នុងបទទី ២ ក៏មានន័យដូចគ្នា ។ សួរថា ធ្វើម្តេច ទើបទ្រង់ប្រកាន់យកកំឡុងវ័យ ។ ឆ្លើយថា ដើម្បីទ្រង់សម្តែងសម្បត្តិ គឺ ពណ៌សម្បុរ ព្រោះអាយតនៈ គឺ ពណ៌សម្បុររបស់ស្ត្រី សុម្បីកើតក្នុងត្រកូលក្រលំបាក រមែងស្រស់ស្អាតបន្តិចម្តង ៗ ស្រស់ ប្រិមប្រិយ៍ក្នុងកាលមួយ ឯអាយតនៈ គឺ ពណ៌សម្បុររបស់បុរសទាំងឡាយ រមែងស្រស់ស្អាត ប្រិមប្រិយ៍ ក្នុងវេលាមានអាយុ ២០ ឬ ២៥ ឆ្នាំ ។ ទ្រង់បង្ហាញសម្បត្តិ គឺ សរីរៈដែលប្រាសចាកទោស ៦ ប្រការ ដោយបទទាំងឡាយថា មិនខ្ពស់ពេកជាដើម ។ បទថា **វណ្ណនិភា** គឺ មានវណ្ណៈនោះឯង ។

[២០២] បទថា **ជិណ្ណំ** គឺ ចាស់ព្រោះជរា ។ បទថា **គោបានសិវង្កំ** បានដល់ មានគ្រោងឆ្អឹងកោងដូចគន្ទឹះទ្វារផ្ទះ ។ បទថា **ភោគ្គំ** បានដល់ រាងកោង-ង ។ ទ្រង់សម្តែងការដែលរាងកាយនោះ កោងដោយ បទនេះនោះឯង ។ បទថា **ទណ្ឌបរាយនំ** គឺ អាស្រ័យឈើច្រត់ជាគម្រប់ពីរ ។ បទថា **បវេធមានំ** បានដល់ ខ្ញូនញ័រ ។ បទថា **អាតុរំ** បានដល់ ការរសាប់រសល់ព្រោះជរា ។ បទថា **ខណ្ឌទន្តំ** គឺ មានធ្មេញបាក់ ព្រោះភាពជាមនុស្សចាស់ ។ បទថា **បលិតកេសំ** បានដល់ មានសក់ស្កូវ ។ បទថា **វិលូនំ** បានដល់ សក់ជ្រុះ ដូចសក់ដែលត្រូវដក ដូច្នោះ ។ បទថា **ខល្លិតសិរំ** គឺ ក្បាលទំពែក ។ បទថា **វលិនំ** បានដល់ ស្បែកជ្រីវជ្រួញ ដែលកើតព្រមហើយ ។ បទថា **តិលកាហតគត្តំ** គឺ មានរាងកាយពោរពេញដោយស្នាមអុច ៗ ស ៗ និងពណ៌ខ្មៅ ។ បទថា **អាពាធិកំ** បានដល់ មានអាពាធ ។

បទថា ទុក្ខិតំ គឺ ដល់ហើយនូវទុក្ខ ។ បទថា ពាឡ្ហគិលានំ បានដល់មានការឈឺចាប់ ដែលមានប្រមាណក្រៃលែង ។ បទថា សីវថិកាយ ឆឌ្ឌិតំ គឺ ឲ្យធ្លាក់ហើយក្នុងព្រៃខ្មោច ។ បទដ៏សេស បានពោលហើយក្នុងសតិប្បដ្ឋាន នោះឯង ។

[២០៣-២០៨] និព្វាននោះឯង ឈ្មោះថា ឆន្ទរាគវិនយ ស្ងប់ក្នុងទីនេះ ។ បទថា នេវ តស្មឹ សមយេ អត្តព្យាពាធាយ សេចក្ដីថា ក្នុងសម័យនោះ រមែងមិនគិតដើម្បីប្រយោជន៍នៃទុក្ខសម្បីរបស់ខ្លួន ។ បទថា អព្យាបជ្ឈំយេវ បានដល់ មិនមានសេចក្ដីទុក្ខនោះឯង ។ បទថា យំបិ ភិក្ខវេ វេទនា អនិច្ចា សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រោះវេទនា មិនទៀង ព្រោះដូច្នោះ អាការ មានការមិនទៀងជាដើមនេះ ជាទោសនៃវេទនា ។ ការរលាស់ចេញទៅ មានប្រការដូចពោលហើយនោះឯង ។

( ចប់ អដ្ឋកថា មហាទុក្ខក្ខន្ធសូត្រ ទី ៣ )

# អដ្ឋកថា

## ចុលទុក្ខក្ខន្ធសូត្រ ទី ៤

ចុលទុក្ខក្ខន្ធសូត្រ មានពាក្យផ្ដើមថា ខ្ញុំម្ចាស់បានស្ដាប់មកហើយយ៉ាងនេះ ៖

បណ្ដាបទទាំងនោះ បទថា **សក្កេសុ** បានដល់ ក្នុងជនបទដែលមានឈ្មោះ យ៉ាងនោះ ។ ក៏ជនបទនោះ ដែលរាប់ថា សក្យៈ ព្រោះជាទីនៅរបស់រាជកុមារមានជាតិសក្យៈទាំងឡាយ ។ ក៏ការឧប្បត្តិនៃសក្យៈទាំងឡាយ មានហើយក្នុងអម្ពដ្ឋសូត្រនោះឯង ។ បទថា **កបិលវត្ថុស្មឹ** គឺ ក្នុងនគរ ដែលមានឈ្មោះយ៉ាងនោះ ។ ពិតហើយ នគរនោះហៅថា កបិលពស្តុ ព្រោះជានគរកសាងឡើងក្នុងស្ថានជាទីនៅរបស់ឥសី ឈ្មោះថាកបិល ។ ធ្វើនគរនោះ ជាទីគោចរគាម ។ បទថា **និគ្រោធារាមេ** សេចក្ដីថាព្រះបាទសក្យៈព្រះនាមថា និគ្រោធ កាលព្រះមានព្រះភាគ ស្ដេចយាងមកកាន់ក្រុងកបិលពស្តុ ក្នុងកាលនៃញាតិសមាគម ព្រះអង្គទ្រង់ឲ្យសាងវត្តក្នុងសួនរបស់ព្រះអង្គ ថ្វាយដល់ព្រះមានព្រះភាគ ព្រះមានព្រះភាគប្រថាប់នៅក្នុងនិគ្រោធារាមនោះ ។ បទថា **មហានាមោ** បានដល់ ព្រះបាទមហានាម ដែលជាបងរបស់ព្រះអនុរុទ្ធត្ថេរ ទ្រង់ជាឱរសរបស់ព្រះបាទ

សុក្កោទនៈ ។ ក្សត្រទាំង ៥ អង្គនេះ គឺ ព្រះបាទសុទ្ធោទនៈ ព្រះបាទសុក្កោទនៈ ព្រះបាទសក្កោទនៈ ព្រះបាទធោតោទនៈ និងព្រះបាទអមិតោទនៈ ទ្រង់ជាបងប្អូនគ្នា ព្រះទេវីព្រះនាមថា អមិតា ទ្រង់ជាព្រះភគិនីនៃក្សត្រទាំងនោះ ព្រះតិស្សត្ថេរជាបុត្ររបស់ព្រះនាងអមិតានោះ ព្រះតថាគតនិងព្រះនន្ទត្ថេរ ជាព្រះឱរសរបស់ព្រះបាទសុទ្ធោទនៈ ព្រះបាទមហានាមនិងព្រះអនុរុទ្ធត្ថេរៈ ជាព្រះឱរសរបស់ព្រះបាទសុក្កោទនៈ ព្រះអានន្ទត្ថេរជាព្រះឱរសរបស់ព្រះអមិតោទនៈ ព្រះអានន្ទត្ថេរៈ ជាព្រះកនិដ្ឋរបស់ព្រះមានព្រះភាគ ព្រះបាទមហានាមទ្រង់ចាស់ជាង ជាសកទាគាមីអរិយសាវក ។ បទថា **ទិឃរត្តំ** សេចក្តីថា ទ្រង់សម្តែងថា ខ្ញុំព្រះអង្គដឹងតាំងពីខ្ញុំព្រះអង្គសម្រេចសកទាគាមិផលអស់កាលយូរ ។ បទថា **លោភធម្មា** បានដល់ធម៌ ពោលគឺ លោភៈ ទ្រង់ពោលសំដៅដល់ លោភៈប៉ុណ្ណោះ មានប្រការផ្សេង ៗ , ក្នុង ២ បទ សូម្បីក្រៅពីនេះ ក៏មានន័យដូចគ្នា ។ បទថា **បរិយាទាយ តិដ្ឋន្តិ** សេចក្តីថា នៅគ្របសង្កត់ ។ ក៏ធម្មតា **បរិយាទាន** ( ការគ្របសង្កត់ ) នេះ មានហើយក្នុងការកាន់យកក្នុងបទនេះថា ( ព្រះអគ្គមហេសីទ្រង់ ) កាន់ពលដំរី ពលសេះ ពលរថពលចម្បាំងទាំងអស់នោះ ដែលមានជីវិតនោះឯង ។

មកក្នុង **ការលះបង់** ក្នុងបទនេះថា ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញា ចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងលះបង់កាមរាគៈទាំងពួងដូច្នេះ ។ លោកបំណងយកអត្ថថា **លះបង់** សូម្បីក្នុងបទនេះ ។ ដោយ

ហេតុនោះ ទើបពោលថា បទថា **បរិយាទិយិត្វា** បានដល់ លះបង់ចោល ហើយ ។ បទថា **យេន មេ ឯកទា លោភធម្មាបិ** សេចក្ដីថា ទ្រង់ទូល សួរថា សូម្បីលោភធម៌ទាំងឡាយ នៅគ្របសង្កត់ចិត្តរបស់ខ្ញុំព្រះអង្គបាន ក្នុងពេលខ្លះ ព្រោះហេតុអ្វី ។ បានឮថា ព្រះរាជានេះ ទ្រង់មានការសម្គាល់ ថា លោភៈ ទោសៈ និងមោហៈ បានលះអស់មិនមានសល់ដោយសក-ទាគាមិមគ្គ ។ ព្រះរាជានេះ ទ្រង់ដឹងថា របស់ដែលនៅមិនទាន់បានលះ របស់យើងនៅមាន ទ្រង់កាន់យករបស់ដែលនៅមិនទាន់បានលះ ជាអ្នក មានសេចក្ដីសម្គាល់ថា របស់ដែលលះបានហើយ រមែងប្រព្រឹត្តទៅខាង ក្រោយ ដូច្នេះ ។ ព្រះអរិយសាវកកើតសេចក្ដីសង្ស័យយ៉ាងនេះឬ ។ អើ ! ការសង្ស័យរមែងកើតឡើង ។ ព្រោះហេតុអ្វី ។ ព្រោះភាពជាអ្នកមិន ឆ្លាតក្នុងបញ្ញត្តិ ។ ពិតហើយ សូម្បីអរិយសាវកដែលមិនឆ្លាតក្នុងបញ្ញត្តិ នេះថា កិលេសនេះ ត្រូវសម្លាប់ដោយមគ្គនោះ រមែងមានការសង្ស័យ យ៉ាងនេះ ។ អរិយសាវកនោះ មិនមានការពិចារណាឬ ។ មាន តែការ ពិចារណានោះ រមែងមិនបរិបូរដល់អរិយសាវកទាំងពួង ។ សេចក្ដីថា បុគ្គលខ្លះពិចារណាចំពោះកិលេសដែលលះបានហើយប៉ុណ្ណោះ បុគ្គលខ្លះ ពិចារណាចំពោះកិលេសដែលមិនទាន់បានលះប៉ុណ្ណោះ បុគ្គលខ្លះពិចារណា ចំពោះមគ្គ បុគ្គលខ្លះពិចារណាដល់ផល បុគ្គលខ្លះ ពិចារណាចំពោះនិព្វាន ក៏ក្នុងការពិចារណា ៥ ប្រការនេះ ការពិចារណាប្រការ ១ ឬ ប្រការ ២ មិនគួរដើម្បីនឹងបានក៏ទេ ដោយប្រការដូច្នេះ អរិយសាវកណា មានការ

ពិចារណាមិនបរិបូរ អរិយសាវ័កនោះរមែងមាន សេចក្តីសង្ស័យយ៉ាងនេះ ព្រោះភាពជាអ្នកមិនផ្តាច់ក្នុងកិលេសបញ្ញត្តិ ដែលគប្បីសម្លាប់ដោយមគ្គ ។ បទថា **សោ ឯវំ ខោ តេ** សេចក្តីថា ទ្រង់សម្តែងថា លោភៈ ទោសៈ និង មោហៈនោះឯង នៅមិនទាន់បានលះក្នុងសន្តានរបស់លោក តែលោកជាអ្នកមានសេចក្តីសម្គាល់ថា លះបានហើយ ។ បទថា **សោ ច ហិ តេ** សេចក្តីថា ធម៌ គឺ លោភៈ ទោសៈ និងមោហៈរបស់លោកនោះ ។ បទថា **កាមេ** បានដល់ កាម ២ យ៉ាង ។ បទថា **ន បរិភុញ្ជេយ្យាសិ** គឺ ទ្រង់សម្តែងថា លោកក៏គប្បីបួសដូចពួកយើង ។ បទថា **អប្បស្សាទា** បានដល់ មានសុខបន្តិចបន្តួច ។ **ពហុទុក្ខា** បានដល់ ទុក្ខដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងក្នុងសម្បរាយភពនោះឯងជាច្រើន ក្នុងទីនេះ ។ បទថា **ពហុបាយាសា** បានដល់ កិលេស គឺ ឧបាយាសៈ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភពនោះឯងជារបស់ច្រើន ក្នុងទីនេះ ។ បទថា **អាទីនវោ** គឺ ឧបទ្ទវៈ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភព ។ បទថា **ឯត្ថ ភិយ្យោ** សេចក្តីថា ក្នុងកាមទាំងនោះ មានទោសច្រើនយ៉ាងនេះឯង តែមានសេចក្តីត្រេកអរតិច គឺ បន្តិចបន្តួចដូចគ្រាប់ស្ពៃអាស្រ័យក្នុំហិមពាន្ត ឲ្យផលតិច ដូច្នោះ ។ បទថា **ឥតិ ចេបិ មហានាម** សេចក្តីថា ម្នាលមហានាម សូម្បីបើអរិយសាវ័កយ៉ាងនេះ ។ បទថា **យថាភូតំ** បានដល់ ទ្រង់សម្តែងថា សម្លឹងឃើញដោយល្អដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិត គឺ ដោយន័យ ដោយការណ៍ ។ បណ្តាបទទាំងនោះ បទថា **បញ្ញាយ**

បានដល់ ដោយវិបស្សនាបញ្ញា អធិប្បាយថា ដោយញាណ គឺ មគ្គ ២ ខាងដើម ។ បទថា **សោវ** គឺ អរិយសាវកអ្នកឃើញទោសរបស់កាម ដោយមគ្គ ២ យ៉ាង នោះឯង ។ ទ្រង់សម្តែងញាណ ២ យ៉ាង ដែលមានបីតិ ដោយបទនេះថា **បីតិសុខំ** ។ បទថា **អញ្ញំ វា តតោ សន្តតរំ** បានដល់ ឈាន ២ យ៉ាង និងមគ្គ ២ យ៉ាង ថ្នាក់ខ្ពស់ដទៃ ដែលស្ងប់ជាងឈាន ២ យ៉ាងនោះ ។ បទថា **នេវ តាវ អនាវដ្ដី កាមេសុ ហោតិ** សេចក្តីថា អរិយសាវក សូម្បីសម្រេចមគ្គទាំង ២ នោះ នៅជាអ្នកមិនវិលមកក្នុងកាមទាំងឡាយ មិនបានដោយពិត ព្រោះការដែលនៅមិនទាន់សម្រេចឈាន ឬមគ្គជាន់ខ្ពស់ រមែងមិនជា **អាភោគ** (ការចងចិត្ត) ដល់អ្នកមិនវិលមកក៏ទេ តែនឹងមានអាភោគៈដល់អ្នកវិលមក ប៉ុណ្ណោះ ព្រោះហេតុអ្វី ព្រោះមិនមានវិក្ខម្ភនប្បហានដោយឈាន ៤ មិនមានសមុច្ឆេទ-ប្បហានដោយមគ្គ ២ ។ បទថា **មយ្ហំបិ ខោ** សេចក្តីថា មិនមែនលោកតែម្នាក់ប៉ុណ្ណោះទេ សូម្បីយើងក៏ដូច្នោះ ។ បទថា **បុព្វេវ សម្ពោធា** បានដល់ មុនការត្រាស់ដឹងដោយមគ្គនោះ ។ លោកបំណងយក **ឧភោធនា-ជកាបជហាណបញ្ញា** ( បញ្ញាក្នុងការលះបង់ពួកស្នំ និងពួករបាំ ) ក្នុងបទនេះថា **បញ្ញាយ សុទិដ្ឋំ អហោសិ** ដូច្នេះ ។ បទថា **បីតិសុខំ នាជ្ឈគមឹ** បានដល់ យើងមិនបានឈាន ២ យ៉ាង ដែលមានបីតិ ។ លោកប៉ងប្រាថ្នាយកឈានថ្នាក់ខ្ពស់ ២ យ៉ាង និងមគ្គ ៤ ក្នុងបទនេះថា **អញ្ញំវា តតោ សន្តតរំ** ដូច្នេះ ។ បទថា **បច្ចញ្ញាសឹ** បានដល់ ប្តេជ្ញាហើយ ។ ព្រោះហេតុអ្វី

ទើបទ្រង់ប្រារព្ធថា ម្នាលមហានាម ក្នុងសម័យមួយ តថាគត ដូច្នេះ ។ ព្រោះមានអនុសន្ធិជាផ្នែក ដូច្នេះ ។ ទ្រង់សម្តែងសេចក្តីត្រេកអរខ្លះ ទោសខ្លះ នៃកាមទាំងឡាយ ក្នុងខាងក្រោម មិនបានត្រាស់ដល់ការរលាស់ចេញ ទ្រង់ប្រារព្ធទេសនានេះ ដើម្បីទ្រង់សម្តែងដល់ការរលាស់ចេញនោះ ព្រោះការប្រកបខ្លួនឲ្យជាប់នឹងសុខក្នុងកាមជាទីបំផុតមួយ ការប្រកបខ្លួនឲ្យលំបាកជាទីបំផុតមួយ សាសនារបស់តថាគតផុតចាកទីបំផុតទាំងនេះ ព្រោះដូច្នោះ ទើបទ្រង់ប្រារព្ធទេសនានេះ ដើម្បីទ្រង់សម្តែងសាសនាទាំងអស់ ដោយមាតិកានៃផលសមាបត្តិថ្នាក់ខ្ពស់ ។ បទថា **គិជ្ឈកូដេ បព្វតេ** សេចក្តីថា ភ្នំនោះ មានកំពូលស្រដៀងសត្វត្មាត ព្រោះដូច្នោះទើបហៅថា **គិជ្ឈកូដ** ឬត្មាតទាំងឡាយ អាស្រ័យនៅលើកំពូលទាំងឡាយនៃភ្នំនោះខ្លះ ព្រោះដូច្នោះទើបហៅថា គិជ្ឈកូដ ។ បទថា **ឥសិគិលិបស្សេ** បានដល់ នៅខាងភ្នំឥសិគិលិ ។ បទថា **កាឡសិលាយំ** បានដល់ ផ្ទាំងថ្មមានពណ៌ខ្មៅ ។ បទថា **ឧព្ភដ្ឋកា ហោន្តិ** សេចក្តីថា ជាអ្នកប្រកាន់ការឈរជាវត្ត មិនអង្គុយ ។ បទថា **ឱបក្កមិកា** សេចក្តីថា ដែលកើតពីសេចក្តីព្យាយាមរបស់ខ្លួន មានការឈរជាវត្តជាដើម ។ បទថា **និគន្ថោ អាវុសោ** សេចក្តីថា កាលណាមិនអាចដើម្បីនឹងពោលហេតុដទៃ ទើបបោះឲ្យនិគ្រន្ថ ។ បទថា **សព្វញ្ញូ សព្វទស្សាវី** សេចក្តីថា និគ្រន្ថទាំងឡាយសម្តែងថា សាស្តារបស់ពួកយើងនោះ ដឹងគ្រប់យ៉ាង ឃើញគ្រប់យ៉ាង ដែលជាអតីតៈ អនាគត និងបច្ចុប្បន្ន ។ បទថា **អបរិសេសំ ញាណទស្សនំ បដិជានាតិ**

សេចក្តីថា សាស្តារបស់ពួកយើងនោះ រមែងដឹងច្បាស់ញាណទស្សនៈ ពោលគឺ អស់គ្រប់ចំណែក ព្រោះដឹងធម៌គ្រប់ចំណែកទាំងអស់ នឹងកាលបើអះអាង ក៏អះអាងយ៉ាងនេះថា កាលយើងដើរទៅក្តី ឈរក្តី ។ល។ ញាណទស្សនៈ ប្រាកដដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សតតំ** បានដល់ ជាប់ជានិច្ច ។ បទថា **សមិតំ** ជាវេវចនៈនៃបទនោះឯង ។ ពាក្យនេះថា ម្នាលនិគ្រន្ថអ្នកដ៏មានអាយុ ពួកលោកជ្រាបទេថា ទុក្ខប៉ុណ្ណោះ យើងរលាស់បានហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងថា ធម្មតាបុរសរមែងដឹងកិច្ចដែលធ្វើជំពាក់បំណុល ២០ កហាបណៈ សងហើយ ១០ កហាបណៈ ក៏ដឹងថា យើងសងហើយ ១០ កហាបណៈ នៅជំពាក់ ១០ កហាបណៈ លុះសងកហាបណៈសូម្បីទាំងនោះអស់ហើយ ក៏រមែងដឹងកិច្ចទាំងពួងថា បំណុលទាំងអស់យើងជម្រះហើយ , ច្រូតចំណែកទីបីនៃស្រែ ក៏ដឹងថា ចំណែកមួយច្រូតហើយ នៅសល់ពីរចំណែក កាលបើច្រូតមួយចំណែកទៀត ក៏ដឹងថា សល់មួយចំណែក កាលច្រូតមួយចំណែកទៀត ក៏ដឹងថា នៅសល់មួយចំណែក , លុះចំណែកនោះច្រូតហើយ ក៏ដឹងថា កិច្ចគ្រប់យ៉ាងស្រេចហើយ រមែងដឹងកិច្ចដែលធ្វើហើយ និងនៅមិនទាន់បានធ្វើ ក្នុងកិច្ចទាំងពួងយ៉ាងនេះ សូម្បីពួកលោកក៏គប្បីដឹងយ៉ាងនោះ ។ ដោយពាក្យនេះថា ការលះអកុសលធម៌ទាំងឡាយ ត្រាស់សួរថា ឈ្មោះថា និគ្រន្ថអ្នកលះអកុសលធម៌ ចម្រើនកុសលដល់ភាពជាអ្នកបរិសុទ្ធហើយ មាននៅក្នុងសាសនារបស់ពួកអ្នកឬ ។ បទថា **ឯវំ សន្តេ**

សេចក្ដីថា លុះការដែលពួកលោកដឹងយ៉ាងនេះ មាន ។ បទថា លុទ្ទា បានដល់ មានមារយាទថោកទាប ។

បទថា លោហិតបាណិនោ បានដល់ អ្នកសម្លាប់សត្វ ឈ្មោះថា មានដៃប្រឡាក់ដោយឈាម ។ ក៏ធម្មតាដៃរបស់អ្នកសម្លាប់សត្វណារមែង ប្រឡាក់ដោយឈាម អ្នកនោះហៅថា មានដៃប្រឡាក់ឈាមដូចគ្នា ។ បទថា កុរូរកម្មន្តា បានដល់ ទារុណកម្ម គឺ ធ្វើការខុសក្នុងមាតាបិតា និង សមណព្រាហ្មណ៍អ្នកមានធម៌ជាដើម ឬកម្មដ៏គ្រោតគ្រាត មានព្រានម្រឹគ ជាដើម ។ និគ្រន្ថទាំងឡាយសម្គាល់ថា សមណគោតមនេះ ឲ្យទោស ក្នុងវាទៈរបស់ពួកយើង សូម្បីពួកយើងនឹងលើកទោសដល់សមណគោតម នោះ ទើបប្រារព្ធពាក្យនេះថា ម្នាលព្រះសមណគោតមដ៏មានអាយុ ដូច្នេះ ។ បទនេះមានសេចក្ដីថា ម្នាលព្រះគោតមដ៏មានអាយុ ព្រះអង្គទ្រង់ចីវរដ៏ ប្រណីត សោយបាយសាលី សាច់ និងទឹក ប្រថាប់នៅក្នុងព្រះគន្ធកុដិ មានពណ៌ដូចទេពវិមាន ជួបប្រសព្វតែសេចក្ដីសុខ បានដោយសេចក្ដីសុខ យ៉ាងណា បុគ្គលមិនគប្បីប្រសព្វសេចក្ដីសុខ ដោយសេចក្ដីសុខ ដូច្នោះ ។ម្យ៉ាងទៀត ពួកខ្ញុំម្ចាស់សោយសេចក្ដីទុក្ខច្រើនប្រការ ដោយសេចក្ដីព្យាយាម ទាំងឡាយ មានសេចក្ដីព្យាយាមក្នុងការអង្គុយប្រហោងជាដើម យ៉ាងណា បុគ្គលគប្បីប្រសព្វសេចក្ដីសុខបានដោយសេចក្ដីទុក្ខដូច្នោះ យ៉ាងនេះ ។ បទថា សុខេន ច អាវុសោ នេះ ពោលហើយ ដើម្បីសម្ដែងថា បើ បុគ្គលគប្បីប្រសព្វសេចក្ដីសុខបានដោយសេចក្ដីសុខទៀតសោត ព្រះរាជា

ក៏ប្រសព្វដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **មាគធោ** បានដល់ ទ្រង់មានឥស្សរៈលើដែនមគធៈ ។ បទថា **សេនិយោ** គឺ ព្រះនាមរបស់ស្តេចផែនដីមគធៈនោះ ។ បទថា **ពិម្ពិ** បានដល់ ព្រះនាមនៃអត្តភាព ។ ព្រះអង្គជាសារៈនៃដែនមគធៈនោះ ទ្រង់គួរមើល គួរជាទីជ្រះថ្លា ទើបថ្វាយព្រះនាមថា ពិម្ពិសារ ព្រោះការសម្រេចក្នុងអត្តភាព ។ ពួកនិគ្រន្ថនោះ សំដៅដល់ការសោយសម្បត្តិ ព្រមទាំងនាងរបាំទាំងឡាយ ដែលមានវ័យទាំងបី ក្នុងប្រាសាទទាំងបីរបស់ព្រះរាជា ទើបពោលពាក្យនេះថា ទ្រង់នៅជាសុខជាង ដូច្នេះ ។ បទថា **អទ្ធា** បានដល់ ដោយចំណែកមួយ ។ បទថា **សហសា អប្បដិសង្ខា** បានដល់ ទ្រង់សម្តែងថា ពួកនិគ្រន្ថតក់-ក្រហល់ មិនទាន់ពិចារណា ទើបមានវាចាយ៉ាងនោះ ដូចមនុស្សដែលមានតម្រេកហើយ និយាយដោយអំណាចរាគៈ មនុស្សក្រោធហើយ និយាយដោយអំណាចទោសៈ មនុស្សវង្វេងហើយ និយាយដោយអំណាចមោហៈដូច្នោះ ។ បណ្តាបទទាំងនោះ បទថា **បដិបុច្ឆិស្សាមិ** សេចក្តីថា យើងនឹងសួរក្នុងអត្ថនោះ ។ បទថា **យថា វោ ខមេយ្យ** សេចក្តីថា ពួកលោកគប្បីពេញចិត្តយ៉ាងណា ។ បទថា **បហោតិ** បានដល់ រមែងអាច ។ បទថា **អនិញ្ជមានោ** បានដល់ មិនញាប់ញ័រ ។ បទថា **ឯកន្តសុខប្បដិសំវេទី** បានដល់ សោយសេចក្តីសុខជានិរន្តរ៍ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេចក្តីសុខក្នុងផលសមាបត្តិរបស់ព្រះអង្គ ទើបទ្រង់ត្រាស់ពាក្យនេះថា ម្នាលនិគ្រន្ថដ៏មានអាយុ តថាគតជាអ្នកអាច ។ល។ សោយសេចក្តី

សុខចំណែកមួយ ដូច្នេះ ។ ក៏ទ្រង់ធ្វើវារៈនៃព្រះរាជាជាដើម ដល់ ៧ វារៈ ហើយទ្រង់ធ្វើសំណួរ ដើម្បីឲ្យចប់សំនួនពាក្យក្នុងទីនេះ ។ ក៏កាលបើពោលថា មិនអាចដល់ ៧ យប់-៧ ថ្ងៃ ៦ យប់-៦ថ្ងៃ ៥ យប់-៥ ថ្ងៃ ៤ យប់-៤ ថ្ងៃ ដូច្នេះ ។ តែក្នុងពុទ្ធវារៈ លុះត្រាស់ដល់ ៧ យប់-៧ថ្ងៃ និងត្រាស់ទៀតថា ៦ យប់-៦ ថ្ងៃ ៥ យប់-៥ ថ្ងៃ ៤ យប់-៤ ថ្ងៃ ក៏នឹងមិនអស្ចារ្យ ព្រោះដូច្នោះ ទើបត្រាស់រួមជាមួយ ហើយទ្រង់សម្តែងធម៌ទេសនា ។ បទដ៏សេសក្នុងបទទាំងអស់ មានសេចក្តីងាយទាំងអស់ ។

( ចប់អដ្ឋកថា ចុល្លទុក្ខក្ខន្ធសូត្រ ទី ៤ )

# អដ្ឋកថា

## អនុមានសូត្រ ទី ៥

អនុមានសូត្រមានពាក្យផ្ដើមថា ខ្ញុំម្ចាស់បានស្ដាប់មកយ៉ាងនេះ ៖

បណ្ដាបទទាំងនោះ បទថា **ភគ្គេសុ** បានដល់ ក្នុងជនបទមានឈ្មោះយ៉ាងនោះ ។

ក៏សេចក្ដីនៃពាក្យ គប្បីជ្រាបដោយទំនងដែលពោលហើយក្នុងទីនេះ ។ បទថា **សុំសុមារគិរេ** បានដល់ ក្នុងនគរមានឈ្មោះយ៉ាងនោះ ។

បានឮថា ក្នុងថ្ងៃជាទីកំណត់ផ្ទៃដីដែលសាងនគរនោះ ក្រពើក្នុងស្រះនៅមិនឆ្ងាយ បានពោលឡើងបញ្ចេញសំឡេងថា **គិរ** លុះសាងនគរនោះស្រេចហើយ ប្រជាជនទាំងឡាយ ទើបតាំងឈ្មោះនគរនោះថា **សុំសុ-មារគិរ** ។ បទថា **ភេសកឡាវនេ** បានដល់ ក្នុងព្រៃដែលមានឈ្មោះ **ភេសកឡា** បាលីថា **ភេសកវនេ** ដូច្នេះក៏បាន ។ បទថា **មិគទាយេ** សេចក្ដីថា ព្រៃនោះ បានកើតក្នុងទីដែលជាទីឲ្យអភ័យដល់ម្រឹគ និងបក្សីទាំងឡាយ ព្រោះដូច្នោះ ទើបហៅថា **មិគទាយ** ។ បទថា **បវារេតិ** បានដល់ រមែងប្រាថ្នា ។ បទថា **វទន្តុ** សេចក្ដីថា ចូរប្រៀនប្រដៅ គឺចូរឲ្យឱវាទ ចូរបង្រៀនដោយអំណាចនៃឱវាទ និងអនុសាសនី ។ បទថា

**វចនីយោម្ហិ** សេចក្ដីថា យើង ដែលលោកគប្បីប្រៀនប្រដៅ គឺ គប្បីបង្រៀន គប្បីឲ្យឱវាទ ។ បទថា **សោ ច ហោតិ ទុព្វចោ** សេចក្ដីថា ក៏ភិក្ខុនោះជាអ្នកប្រដៅបានដោយលំបាក គឺ ទូន្មានហើយ មិនអត់ធន់ ។ បទថា **ទោវចស្សករណេហិ** សេចក្ដីថា ដោយធម៌ ១៦ ប្រការ ដែលមានហើយក្នុងខាងមុខ ដែលជាធម៌ធ្វើឲ្យទៅជាអ្នកទូន្មានបានដោយលំបាក ។ បទថា **អបទក្ខិណគ្គាហី អនុសាសនី** សេចក្ដីថា ក៏ភិក្ខុណា កាលត្រូវទូន្មាន ទើបនិយាយថា លោកទាំងឡាយទូន្មានខ្ញុំ ព្រោះហេតុអ្វី ខ្ញុំតែងតែដឹងរបស់គួរ និងមិនគួរ ទោស និងមិនមែនទោស ប្រយោជន៍ និងមិនមែនប្រយោជន៍របស់ខ្លួន ភិក្ខុនោះឈ្មោះថា មិនទទួលពាក្យប្រៀន-ប្រដៅដោយចំណែកខាងស្ដាំ រមែងទទួលដោយចំណែកខាងឆ្វេង ព្រោះដូច្នោះ ទើបហៅថា មិនទទួលពាក្យប្រៀនប្រដៅដោយគោរព ។ បទថា **បាបកានំ ឥច្ឆានំ** គឺ សេចក្ដីប្រាថ្នា ដែលបង្កឲ្យកើតសេចក្ដីមិនស្ងប់លាមក ។ បទថា **បដិប្ផរតិ** គឺ រមែងតាំងខ្លួនជាអ្នករឹងទទឹង ជាសឹកសត្រូវ ។ បទថា **អបសាទេតិ** សេចក្ដីថា រមែងព្យាយាមយ៉ាងនេះថា ខ្ញុំម្ចាស់បានទូន្មានហើយដល់លោក ជាមនុស្សពាល មិនឆ្លាត ជម្ទាតាសូម្បីអ្នកនឹងសម្គាល់ពាក្យ ដែលគប្បីពោលមែនឬ ។ បទថា **បច្ចារោបេតិ** សេចក្ដីថា ត្រឡប់មួលបង្កាច់យ៉ាងនេះថា សូម្បីអ្នក ក៏ត្រូវអាបត្តិឈ្មោះនេះ អ្នកចូរសម្ដែងអាបត្តិនោះសិន ។ បទថា **អញ្ញេនញ្ញំ បដិចរតិ** គឺ បិទបាំងដោយរឿងដទៃ ដោយពាក្យដទៃ ឬបង្វែរសេចក្ដីទៅក្នុងរឿងដទៃ

ពាក្យដទៃ ។ កាលបើភិក្ខុដទៃពោលថា អ្នកត្រូវអាបត្តិ ក៏និយាយថា អ្នកណាត្រូវ ត្រូវអាបត្តិអ្វី ត្រូវត្រង់កន្លែងណា លោកនិយាយនឹងអ្នកណា លោកនិយាយអ្វី ដូច្នេះ កាលបើភិក្ខុដទៃនិយាយថា លោកបានឃើញអ្វី ៗ បែបនេះ ក៏បែរប្រកែកថា យើងមិនស្តាប់ ដូច្នេះ ។ បទថា **ពហិទ្ធា កថំ អបនាមេតិ** សេចក្តីថា ភិក្ខុនោះ ត្រូវភិក្ខុជាអ្នកចោទ ក៏សួរថា លោកត្រូវអាបត្តិឈ្មោះនេះ ក៏និយាយថា យើងទៅកាន់ក្រុងបាតលីបុត្រ បើភិក្ខុអ្នកចោទពោលទៀតថា ពួកយើងមិនបានសួរដល់ការទៅក្រុងបាតលីបុត្ររបស់លោក ពួកយើងសួរដល់អាបត្តិនោះ ក៏ពោលពាក្យមានជាអាទិ៍ថា ខ្ញុំម្ចាស់ទៅកាន់ក្រុងរាជគ្រឹះ លោកចូរទៅកាន់ក្រុងរាជគ្រឹះឬ លោកត្រូវអាបត្តិក្នុងស្រុកព្រាហ្មណ៍ លោកបានសាច់ជ្រូកក្នុងស្រុកព្រាហ្មណ៍នោះ ដូច្នេះ ឈ្មោះថា និយាយក្រៅរឿង ។ បទថា **អបទានេ** គឺ ក្នុងការប្រព្រឹត្តរបស់ខ្លួន ។ បទថា **ន សម្បាយតិ** សេចក្តីថា ភិក្ខុត្រូវភិក្ខុចោទ ក៏សួរដល់ការប្រព្រឹត្ត ដោយន័យមានជាអាទិ៍ថា ម្នាលអ្នកដ៏មានអាយុ លោកនៅទីណា លោកអាស្រ័យអ្នកណា ឬថា លោកនិយាយនឹងអ្នកណា អ្នកនោះត្រូវអាបត្តិដែលខ្ញុំម្ចាស់ឃើញហើយ ឬថា ក្នុងសម័យនោះ លោកធ្វើអ្វី ខ្ញុំម្ចាស់ធ្វើអ្វី ឬលោកនៅទីណា ខ្ញុំម្ចាស់នៅទីណា ដូច្នេះ ក៏មិនអាចដើម្បីឲ្យពេញចិត្តទូន្មាន ។ បទថា **តត្រាវុសោ** សេចក្តីថា ម្នាលអ្នកដ៏មានអាយុ ក្នុងធម៌ ១៦ ប្រការនោះ ។ បទថា **អត្តនាវ អត្តានំ ឯវំ អនុមានិតព្វំ** សេចក្តីថា គប្បីអនុមាន គប្បីថ្លឹង គប្បីប្រៀបធៀប គប្បី

ពិចារណាខ្លួន ដោយខ្លួនឯង យ៉ាងនេះ ។ បទថា **អហោរត្តានុសិក្ខិនា** សេចក្តីថា ភិក្ខុកាលសិក្សាសូម្បីទាំងថ្ងៃទាំងយប់ គប្បីសិក្សានូវកុសល-ធម៌ទាំងឡាយ ទាំងយប់ទាំងថ្ងៃ ញ៉ាំងបីតិ និងបាមោជ្ជៈនោះឲ្យកើតឡើង ។ បទថា **អច្ឆេ វា ឧទកបត្តេ** គឺ ក្នុងភាជន៍ទឹកដ៏ថ្លា ។ បទថា **មុខនិមិត្តំ** បានដល់ ស្រមោលមុខ ។ បទថា **រជំ** បានដល់ ធូលីដែលហុយមក ។ បទថា **អង្គណំ** បានដល់ អាចម៍រុយ ឬមុន ដែលកើតលើផ្ទៃមុខនោះ ។ ព្រះថេរៈសម្តែងការលះបង់ទាំងអស់ ដោយបទនេះថា អកុសលធម៌ដ៏អាក្រក់ទាំងនេះ សូម្បីទាំងអស់ ដែលនៅលះមិនទាន់បាន យ៉ាងណា ។ យ៉ាងនេះ គឺ ព្រះថេរៈសម្តែង **បដិសង្ខានប្បហាន** ដល់ភិក្ខុដែលញ៉ាំងការពិចារណាឲ្យកើតឡើងថា អកុសលធម៌ប្រមាណប៉ុណ្ណេះ មិនសមគួរដល់បព្វជិត , សម្តែង **វិក្ខម្ភនប្បហាន** ដល់ភិក្ខុដែលធ្វើសីលឲ្យជាបទដ្ឋាន ហើយប្រារព្ធកសិណបរិកម្ម ញ៉ាំងសមាបត្តិ ៨ ឲ្យកើតឡើង , សម្តែង **តទង្គប្បហាន** ដល់ភិក្ខុដែលធ្វើសមាបត្តិឲ្យជាបទដ្ឋាន ហើយចម្រើនវិបស្សនា , សម្តែង **សមុច្ឆេទប្បហាន** ដល់ភិក្ខុដែលចម្រើនវិបស្សនា ហើយអប់រំមគ្គ , សម្តែង **បដិបស្សទ្ធិប្បហាន** កាលបើផលមានហើយ , សម្តែង **និស្សរណប្បហាន** កាលណានិព្វានប្រាកដហើយ ព្រោះដូច្នោះ **បហាន** ទាំងអស់ ក៏គឺ ព្រះថេរៈសម្តែងហើយក្នុងសូត្រនេះ ដោយប្រការដូច្នេះ ។ បុរាណាចារ្យទាំងឡាយពោលថា ក៏សូត្រនេះឈ្មោះថា **ភិក្ខុបាតិមោក្ខ** ។

បុរាណាចារ្យទាំងឡាយពោលថា ភិក្ខុគប្បីពិចារណា ១ ថ្ងៃ ៣ ដង

ដោយប្រការដូច្នេះ ភិក្ខុចូលទៅកាន់កន្លែងតាំងពីព្រលឹម ហើយអង្គុយពិចារណាថា កិលេសមានប្រមាណប៉ុណ្ណោះរបស់យើងនៅមានទេហ្ន៎ ! បើឃើញថាមាន គប្បីព្យាយាមដើម្បីលះកិលេសទាំងនោះ បើឃើញថាមិនមាន គប្បីជាអ្នកមានចិត្តជារបស់ខ្លួនថា យើងបួសល្អហើយ ធ្វើកត្តកិច្ចអង្គុយ ក្នុងទីសម្រាកពេលយប់ ឬទីសម្រាកពេលថ្ងៃ ហើយគប្បីពិចារណាខ្លះ អង្គុយនៅក្នុងពេលល្ងាច គប្បីពិចារណាខ្លះ កាលណាបើមិនអាចពិចារណាក្នុង ១ ថ្ងៃ ៣ ដង ក៏ពិចារណាត្រឹមតែ ២ ដង តែកាលណាមិនអាចដល់ ២ ដង ក៏ពិចារណាត្រឹមតែ ១ ដង ដ៏សេសមិនពិចារណាមិនសមគួរ ដូច្នេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្តីងាយទាំងអស់ ។

( ចប់អដ្ឋកថា អនុមានសូត្រទី ១៥ )

# អដ្ឋកថា

## ចេតោខីលសូត្រ ទី ៦

ចេតោខីលសូត្រផ្តើមឡើងថា ខ្ញុំម្ចាស់បានស្តាប់មកយ៉ាងនេះ ៖

ក្នុងចេតោខីលសូត្រនោះ ការដែលចិត្តជាធម្មជាតិរឹងត្អឹង ការដែលចិត្តដូចជាក្រោះ ការដែលចិត្តដូចជាគល់ឈើ ឈ្មោះថា **ចេតោខីលា** ។

បទថា **ចេតសោ វិនិពន្ធា** សេចក្តីថា កិលេសគ្រឿងទាញដ៏ល្អិតរបស់ចិត្ត ព្រោះអត្ថថា ចងចិត្តទុក ដូចក្តោបទុកក្នុងកណ្តាប់ដៃ ។ ការចម្រើនដោយសីល ការដុះលូតលាស់ល្អដោយមគ្គ ការបរិបូរណ៍ដោយនិព្វាន ការចម្រើនដោយសីល និងសមាធិ ការលូតលាស់ល្អដោយវិបស្សនាមគ្គ ការបរិបូរណ៍ដោយផល និងនិព្វាន ក្នុងបទជាដើមថា **វុឌ្ឍឹ** ។

បទថា **សត្ថរិ កង្ខតិ** សេចក្តីថា ភិក្ខុសង្ស័យក្នុងព្រះសរីរៈ ឬព្រះគុណរបស់ព្រះសាស្តា ភិក្ខុកាលណាសង្ស័យក្នុងព្រះសរីរៈ ក៏រមែងសង្ស័យថា ព្រះសរីរៈដែលប្រដាប់ប្រដាដោយព្រះលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានទេហ្ន៎ ! ឬក៏មិនមាន ។ កាលណាសង្ស័យក្នុងព្រះគុណ ក៏រមែងសង្ស័យថា ព្រះសព្វញ្ញុតញ្ញាណដែលអាចដឹងអតីត អនាគត និងបច្ចុប្បន្ន មានឬមិនមានទេហ្ន៎ ! ។ បទថា **វិចិកិច្ឆតិ** សេចក្តីថា កាលណាពិចារណា រមែងងឿងឆ្ងល់ គឺ រមែងដល់ទុក្ខ រមែងមិនអាច វិនិច្ឆ័យ ។ បទថា **នាធិមុច្ចតិ**

សេចក្តីថា រមែងមិនបានទទួលការបង្អោនទៅថា នោះត្រូវជាយ៉ាងនេះ ។

បទថា **ន សម្បសីទតិ** សេចក្តីថា រមែងមិនអាចដើម្បីស្ងប់ក្នុងព្រះគុណទាំងឡាយ ហើយជ្រះថ្លាដោយភាពជាអ្នកប្រាសចាកការងឿងឆ្ងល់ជាអ្នកអស់ការសង្ស័យ ។ បទថា **អាតប្បាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការធ្វើសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។ បទថា **អនុយោគាយ** សេចក្តីថា ដើម្បីប្រកបការព្យាយាមរឿយ ៗ ។ បទថា **សាតច្ចាយ** សេចក្តីថា ដើម្បីធ្វើតរៀងទៅ ។ បទថា **បធានាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការតាំងមាំ ។ បទថា **អយំ បឋមោ ចេតោខីលោ** សេចក្តីថា ការដែលចិត្តជាធម្មជាតិរឹងត្អឹង ពោលគឺ សេចក្តីងឿងឆ្ងល់ក្នុងព្រះសាស្តាចំណុចទី ១ នេះ រមែងជាការដែលភិក្ខុនោះ នៅលះមិនទាន់បាន ដោយហេតុយ៉ាងនេះ ។

បទថា **ធម្មេ** គឺ ក្នុងបរិយត្តិធម៌ បដិបត្តិធម៌ បដិវេធធម៌ ។ កាលណាសង្ស័យក្នុងបរិយត្តិធម៌ រមែងសង្ស័យថា បណ្ឌិតទាំងឡាយពោលថា ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដកមាន ៨៤០០០ ធម្មក្ខន្ធនោះ មានឬ ក៏មិនមានទេហ្ន៎ ! ។

កាលណាសង្ស័យក្នុងបដិវេធធម៌ រមែងសង្ស័យថា បណ្ឌិតទាំងឡាយ ពោលថា ការហូរចេញនៃវិបស្សនាឈ្មោះថា មគ្គ , ការហូរចេញនៃមគ្គ ឈ្មោះថា ផល , ការរលាស់ចេញនូវសង្ខារទាំងពួងឈ្មោះថា និព្វាន ដូច្នេះនុ៎ះ មានឬ មិនមានទេហ្ន៎ ! ។ បទថា **សង្ឃេ កង្ខតិ** សេចក្តីថា

រមែងសង្ស័យថា ឈ្មោះថា ព្រះសង្ឃដែលជាពួកនៃបុគ្គលប្រាំបី គឺ ដែលតាំងនៅក្នុងមគ្គ ៤ ផល ៤ អ្នកបដិបត្តិបដិបទាបែបនេះ ដោយអំណាចនៃបទទាំងឡាយមាន បទថា អ្នកបដិបត្តិល្អជាដើម មានឬ មិន មានហ្ន៎ ! ។

កាលណាសង្ស័យក្នុងសិក្ខា ក៏រមែងសង្ស័យថា បណ្ឌិតទាំងឡាយពោលថា ឈ្មោះអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ដូច្នេះ សិក្ខានោះ មានឬ មិនមានហ្ន៎ ! ។

បទថា **អយំ បញ្ចមោ** សេចក្ដីថា សភាពដែលចិត្តជាធម្មជាតិរឹងត្អឹងដូចជាគ្រោះ ដូចជាគល់ឈើ ពោលគឺ ការមានចិត្តរឹងរូសក្នុងមិត្តសព្រហ្មចារី នេះជាទី ៥ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងកិលេសជាគ្រឿងស្អិតទាំងឡាយ ។ បទថា **កាមេ** បានដល់ វត្ថុកាមខ្លះ កិលេសកាមខ្លះ ។ បទថា **កាយេ** សេចក្ដីថា ក្នុងកាយរបស់ខ្លួន ។ បទថា **រូបេ** សេចក្ដីថា ក្នុងរូបខាងក្រៅ ។ បទថា **យាវទត្ថំ** សេចក្ដីថា មានប្រមាណល្មមនឹងសេចក្ដីត្រូវការ ។ បទថា **ឧទរាវទេហកំ** បានដល់ ពេញពោះ ។ ពិតហើយ ពោះនោះហៅថា **ឧទរា-វទេហកំ** ព្រោះមិនរលាយ ។ បទថា **សេយ្យសុខំ** សេចក្ដីថា សេចក្ដីសុខលើគ្រែ លើកៅអី ឬសេចក្ដីសុខក្នុងរដូវ ។ បទថា **បស្សសុខំ** សេចក្ដីថា សេចក្ដីសុខដែលកើតឡើង ដូចជាសេចក្ដីសុខដេកផ្អៀងទៅខាងស្ដាំ និងផ្អៀងទៅខាងឆ្វេង របស់អ្នកដេកប្រែទៅមក ដូច្នោះ ។

បទថា **មិទ្ធសុខំ** បានដល់ សេចក្ដីសុខក្នុងការដេកលក់ ។ បទថា

**អនុយុត្តោ** សេចក្តីថា ជាអ្នកប្រកបដោយសេចក្តីព្យាយាម ។ បទថា **បណិធាយ** សេចក្តីថា ប្រាថ្នាហើយ ។ ពិតហើយ ចតុប្បារិសុទ្ធិសីល ឈ្មោះថា សីលក្នុងបទជាដើមថា **សីលេន** ដូច្នេះ ។ ការសមាទានវត ឈ្មោះថា **វត** ។ ការប្រព្រឹត្តសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ឈ្មោះថា **តប** ។ ការវៀរចាកមេថុន ឈ្មោះថា **ព្រហ្មចរិយ** ។ បទថា **ទេវោ វា ភវិស្សាមិ** សេចក្តីថា យើងនឹងជាស្តេចនៃទេវតាមានសក្តិធំ ។ បទថា **ទេវញ្ញតរោវា** សេចក្តីថា ឬជាទេពអង្គណាមួយក្នុងបណ្តាទេព ដែលមានសក្តិតូច ។ សមាធិដែលដល់ហើយ ព្រោះអាស្រ័យសេចក្តីពេញចិត្តក្នុងឥទ្ធិបាទទាំងឡាយ ឈ្មោះថា **ឆន្ទសមាធិ** ។ សង្ខារទាំងឡាយ ដែលជាប្រធាន ឈ្មោះថា **បធានសង្ខារ** ។ បទថា **សមន្នាគតំ** សេចក្តីថា ប្រកបដោយធម៌ទាំងនោះ ។ បាទនៃឫទ្ធិ ឬបាទដែលជាឫទ្ធិ ព្រោះដូច្នោះ ទើបឈ្មោះថា ឥទ្ធិបាទ ។ ក្នុងបទទាំងឡាយ សូម្បីដ៏សេសក៏មានន័យដូចគ្នា ។ សេចក្តីសង្ខេបក្នុងព្រះសូត្រនេះ ត្រឹមតែប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារមានមកហើយក្នុងឥទ្ធិបាទវិភង្គនោះឯង ។ ចំណែកខ្លឹមសារ នៃឥទ្ធិបាទនោះ បានសម្តែងទុកហើយក្នុងវិសុទ្ធិមគ្គ ។ បានពោលការលះបង់ដោយការគ្របសង្កត់ដោយឥទ្ធិបាទ ៤ នេះ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីព្យាយាម ដែលគប្បីធ្វើក្នុងទីទាំងពួងថា **ឧស្សោឡ្ហិ** ក្នុងបទនេះថា **ឧស្សោឡ្ហិយេវ បញ្ចាមី** ដូច្នេះ ។ បទថា ឧស្សោឡ្ហិបណ្ណរសង្គសមន្នាគតោ សេចក្តីថា អ្នកប្រកបដោយអង្គ

១៥ ប្រការ ព្រមនឹងសេចក្តីព្យាយាមយ៉ាងនេះ គឺ ការលះបង់បង្គោលរបស់ចិត្ត ៥ , ការលះបង់កិលេសជាគ្រឿងរួបរឹតចិត្ត ៥ , ឥទ្ធិបាទសេចក្តីព្យាយាម ១ ។ បទថា **កញ្ចេ** សេចក្តីថា អនុរូប គឺ សមគួរ ។ បទថា **អភិនិព្ភិទាយ** សេចក្តីថា ដើម្បីបំផ្លាញកិលេសដោយញាណ ។ បទថា **សម្ពោធាយ** សេចក្តីថា ដើម្បីត្រាស់ដឹងដ៏ប្រពៃនូវមគ្គ ៤ ។ បទថា **អនុត្តរស្ស** សេចក្តីថា ប្រសើរបំផុត ។ បទថា **យោគក្ខេមស្ស** សេចក្តីថា សេចក្តីក្សេមចាកយោគៈ ៤ គឺ ព្រះអរហត្ត ។ **អធិគមាយ** សេចក្តីថា ដើម្បីបានទទួល ។ សព្ទថា **សេយ្យថា** ជានិបាតចុះក្នុងអត្ថថា ប្រៀបធៀប ។ សព្ទថា **បិ** ជានិបាតចុះក្នុងអត្ថថា លើកតម្កើង ។ ព្រះមាន-ព្រះភាគទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ សូម្បីយ៉ាងណា ដូច្នេះ ដោយបទទាំង ២ ។ ក៏ក្នុងបទនេះថា ពងរបស់មេមាន់ មាន ៨ ពងខ្លះ មាន ១០ ពងខ្លះ មាន ១២ ពងខ្លះ ដូច្នេះ នឹងជាពងរបស់មេមាន់ សូម្បីតិចជាង ឬច្រើនជាងអំពីប្រការដែលពោលហើយក៏ដោយ ។ តែពាក្យនោះ លោកពោលដើម្បីការស្រួលស្តាប់នៃពាក្យ ។ ពិតហើយ ពាក្យដែលមានសណ្តាប់ធ្នាប់ រមែងមានក្នុងលោកយ៉ាងនេះ ។ បទថា **តានស្សុ** ញែកបទជា **តានិ អស្សុ** សេចក្តីថា ពងទាំងនោះគប្បីមាន ។ បទថា **កុក្កុដិយា សម្មា អធិសយិតានិ** សេចក្តីថា កាលណាមេមាន់នោះ យកស្លាបទាំងពីរបិទក្រាបពងទាំងនោះ ពងទាំងនោះត្រូវបានមេមាន់ ក្រាបល្អហើយ ។ បទ

ថា **សម្មា បរិសេទិតានិ** សេចក្តីថា ដែលមេមាន់បានអប់អ៊ុំនអស់កាលដ៏សមគួរ ជាការអប់អ៊ុំនដោយល្អ គឺ ដោយប្រពៃ បានដល់ ការធ្វើឲ្យមានកម្តៅក្តៅអ៊ុំន ៗ ។ បទថា **សម្មា បរិភាវិតានិ** សេចក្តីថា គឺការញ៉ាស់ដោយល្អ គឺ ដោយប្រពៃអស់កាលដ៏សមគួរ អធិប្បាយថា ឲ្យបានទទួលក្លិននៃមេមាន់ ។ បទថា **កិញ្ចាបិ តស្សា កុក្កុដិយា** សេចក្តីថា មេមាន់នោះធ្វើសេចក្តីមិនប្រមាទ ដោយការធ្វើកិរិយា ៣ យ៉ាងនេះ មិនគប្បីកើតសេចក្តីប្រាថ្នាយ៉ាងនេះ ដោយពិត ។ បទថា **អថខោ ភព្វាវ តេ** សេចក្តីថា កូនមាន់ទាំងនោះ គប្បីញាស់ចេញមកដោយស្រួល ដោយន័យដែលបានពោលហើយ ។ ពិតហើយ ព្រោះពងទាំងឡាយ ដែលមេមាន់នោះ ព្យាយាមក្រាបដោយអាការ ៣ យ៉ាងនេះ រមែងមិនស្អុយ ជរស្និតរបស់ពងទាំងនោះ ក៏នឹងដល់ការចាស់ទ្បើង សំបកពងក៏នឹងស្តើង ចុងក្រចកជើង និងចំពុះមាត់ក៏នឹងរឹងពងទាំងឡាយក៏នឹងចាស់ដោយជុំវិញ ពន្លឺភ្លឺខាងក្រៅក៏ប្រាកដខាងក្នុងព្រោះសំបកពងស្តើង ព្រោះដូច្នោះ កូនមាន់ទាំងនោះ ទើបប្រាថ្នានឹងចេញដោយគិតថា យើងអង្គុញស្លាប អង្គុញជើងនៅក្នុងទីចង្អៀតអស់វេលាយូរមកហើយទុំះ ពន្លឺភ្លឺខាងក្រៅនេះក៏ប្រាកដ ឥឡូវនេះពួកយើងនឹងនៅជាសុខក្នុងទីមានពន្លឺភ្លឺនោះ ដូច្នេះ ហើយយកជើងទម្លាយសំបកពង អើត-កចេញពីនោះ សំបកនោះ ក៏នឹងបែកចេញជាពីរចំណែកលំដាប់តមក កូនមាន់ទាំងឡាយកម្រើកស្លាប យំចេញមកតាមសមគួរដល់ខណៈនោះតែម្តង លុះចេញមកហើយ ក៏នឹងដើររកស៊ី ។ បទថា **ឯវមេវ ខោ** នេះ មានអត្ថថា ប្រៀបធៀប អ្នកប្រាជ្ញប្រៀបធៀបដោយ

អត្ថយ៉ាងនេះឯង គប្បីជ្រាប ។

ក៏គប្បីជ្រាបការដែលភិក្ខុនេះ ជាអ្នកដល់ព្រមដោយអង្គ ១៥ រួមទាំងការឧស្សាហ៍ ដូចមេមាន់ធ្វើកិរិយា ៣ យ៉ាង ក្នុងពងទាំងឡាយដូច្នោះ ។ ការមិនសាបសូន្យនៃវិបស្សនាញាណ ព្រោះការដល់ព្រមដោយអនុបស្សនា ៣ យ៉ាង របស់ភិក្ខុដែលប្រកបដោយអង្គ ១៥ ដូចការដែលពងទាំងឡាយមិនស្អុយ ព្រោះការដល់ព្រមដោយកិរិយា ៣ យ៉ាង របស់មេមាន់ដូច្នោះ ការកាន់យកជស្នេហ៍ គឺ ការប្រាថ្នាដែលប្រព្រឹត្តទៅក្នុងភព ៣ ដោយការដល់ព្រមដោយអនុបស្សនា ៣ យ៉ាង របស់ភិក្ខុនោះ ដូចការចាស់ដោយជុំវិញនៃជស្នេហ៍របស់ពងទាំងឡាយ ដោយការធ្វើកិរិយា ៣ យ៉ាង របស់មេមាន់ដូច្នោះ ការដែលសំបកពង គឺ អវិជ្ជារបស់ភិក្ខុ ជាធម្មជាតិស្រាលស្តើង ដូចសំបកពងជាធម្មជាតិស្តើង ដូច្នោះ ការដែលវិបស្សនាញាណរបស់ភិក្ខុជាធម្មជាតិ មុត រឹង ថ្លាផូរផង់ និងចាស់ក្លា ដូចចុងក្រចកជើង និងចំពុះរបស់កូនមាន់ទាំងឡាយជាធម្មជាតិរឹង ដូច្នោះ កាលផ្លាស់ប្តូរ កាលដែលចម្រើនហើយ កាលនៃការកាន់យកបន្ទប់នៃវិបស្សនាញាណរបស់ភិក្ខុ ដូចកាលប្រែប្រួលទៅនៃកូនមាន់ទាំងឡាយ ដូច្នោះ ។ កាលភិក្ខុនោះកាន់យកលំហ គឺ វិបស្សនាញាណត្រាច់ទៅ បានឧតុសប្បាយភោជនសប្បាយ បុគ្គលសប្បាយ ឬធម្មស្សវនសប្បាយ ដែលកើតអំពីវិបស្សនាញាណនោះ អង្គុយលើអាសនៈមួយ ចម្រើនវិបស្សនាទម្លាយសំបកពង គឺ អវិជ្ជា ដោយអរហត្តមគ្គ ដែលសម្រេចហើយតាមលំដាប់ កម្រើកស្លាប គឺ អភិញ្ញា ហើយសម្រេចព្រះអរហត្ត ដោយងាយ ដូច

កាលដែលកូនមាន់ទាំងឡាយ ចោះសំបកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយកម្រើកស្លាបទាំងឡាយ ចេញកដោយស្រួល ដូច្នោះ ។ ក៏ចំណែកមេមាន់ ដឹងសភាពដែលកូនមាន់ទាំងឡាយចាស់ណាស់ហើយ ទម្លាយសំបកពងយ៉ាងណា សូម្បីព្រះសាស្តា ក៏ដូច្នោះដូចគ្នា ទ្រង់ដឹងការចាស់ក្លានៃញាណរបស់ភិក្ខុបែបនោះហើយ ទ្រង់ផ្សាយឱភាស ហើយទ្រង់ទម្លាយសំបកពង គឺ អវិជ្ជាដោយព្រះគាថាមានអត្ថថា ៖

បុគ្គលគប្បីលះបង់សេចក្តីស្រឡាញ់របស់ខ្លួន ដូចក្តិចផ្កាឈូកក្រហម ក្នុងសរទកាលដោយដៃ ហើយកពូនចំពោះផ្លូវសន្តិប៉ុណ្ណោះ ភិក្ខុនោះទម្លាយសំបកពង គឺ អវិជ្ជាហើយ សម្រេចព្រះអរហត្តក្នុងវេលាចប់ព្រះគាថា ។ ចាប់ផ្តើមពីនោះ កូនមាន់ទាំងនោះ ញុំាងគាម-ខេត្តឲ្យល្អ ត្រាច់ទៅតាមគាមខេត្តនោះ យ៉ាងណា ភិក្ខុជាព្រះមហាខីណាស្រព សម្រេចផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ហើយញុំាងសង្ឃារាមឲ្យល្អស្អាតទៅ ដូច្នោះ ។ លោកសម្តែងបហានៈ ៤ យ៉ាង ក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះ ។ យ៉ាងណា ។ ក៏លោកសម្តែងបដិសង្ខារប្បហាន ដោយការលះបង្គោលរបស់ចិត្តទាំងឡាយ លះកិលេសជាគ្រឿងរួបរឹតចិត្តទាំងឡាយ , សម្តែងវិក្ខម្ភនប្បហាន ដោយឥទ្ធិបាទទាំងឡាយ , សម្តែងសមុច្ឆេទប្បហាន កាលណាមគ្គមានហើយ , សម្តែងបដិបស្សទ្ធិប្បហាន កាលណាផលមានហើយ ។

ពាក្យដ៏សេសក្នុងបទទាំងពួង មានខ្លឹមសារងាយទាំងអស់ដូច្នេះ ។

( ចប់អដ្ឋកថា ចេតោខិលសូត្រទី ៦ )

# អដ្ឋកថា

## វនបត្ថបរិយាយសូត្រ ទី ៧

វនបត្ថបរិយាយសូត្រ មានពាក្យផ្ដើមថា ខ្ញុំម្ចាស់បានស្ដាប់មក យ៉ាងនេះ ៖

បទថា **វនបត្ថបរិយាយំ** បានដល់ ហេតុនៃការនៅក្នុងព្រៃ ឬ ការសម្ដែងការនៅក្នុងព្រៃ ។ បទថា **វនបត្ថំ និស្សាយ វិហរតិ** សេចក្ដីថា ភិក្ខុអាស្រ័យសេនាសនៈក្នុងដងព្រៃ ដែលផុតពីដែនជុំវិញនៃមនុស្ស ប្រព្រឹត្តសមណធម៌ ។ ក្នុងបទថា **អនុបដ្ឋិតា** ជាដើម មានអធិប្បាយថា កាលលោកចូលទៅអាស្រ័យព្រៃនោះ សតិដែលមិនទាន់ប្រាកដក្នុងកាលមុន ក៏មិនប្រាកដ ចិត្តដែលនៅមិនតាំងមាំក្នុងកាលមុន ក៏មិនតាំងមាំ អាសវៈទាំងឡាយដែលនៅមិនទាន់អស់ទៅក្នុងកាលមុន ក៏មិនដល់ការអស់ទៅ ហើយភិក្ខុនោះ មិនបានសម្រេចអរហត្តពោលគឺ ការរួចផុតចាកយោគៈ យ៉ាងខ្ពស់ដែលនៅមិនទាន់សម្រេចក្នុងកាលមុន ។ បទថា **ជីវិតបរិក្ខារា** គឺ គ្រឿងរក្សាជីវិត ។ បទថា **សមុទានេតព្វា** បានដល់ ដែលគប្បីនាំមកស្រេចហើយ ។ បទថា **កសិរេន សមុទាគច្ឆន្តិ** គឺ ការកើតឡើងដោយលំបាក ។ បទថា **រត្តិភាគំ វា ទិវសភាគំ វា** បានដល់ ក្នុងចំណែកពេលយប់ ឬ ក្នុងចំណែកពេលថ្ងៃ ។ ក៏ក្នុងទីនោះ ភិក្ខុពិចារណានៅក្នុងចំណែកពេលយប់ ដឹងហើយ គួរចៀសចេញទៅក្នុងពេលយប់នោះឯង កាលបើផ្លូវ

ស្វាត់មានសត្វកាចសាហាវជាដើម នៅក្នុងពេលយប់គួរ វង់ចាំភ្លឺឡើង បើដឹងក្នុងចំណែកពេលថ្ងៃ គួរគេចទៅក្នុងពេលថ្ងៃតែម្តង កាលបើផ្លូវស្វាត់ក្នុងពេលថ្ងៃ ក៏គួរវង់ចាំព្រះអាទិត្យលិច ។ បទថា **សំខាបិ** សេចក្តីថា ដឹងសេចក្តីដែលសមណធម៌មិនសម្រេចយ៉ាងនេះ ។ បទថា **អនន្តរវារេ បទ សំខាបិ** សេចក្តីថា ដឹងសេចក្តីដល់សមណធម៌សម្រេចយ៉ាងនេះ ។ បទថា **យាវជីវំ** សេចក្តីថា ជីវិតនៅប្រព្រឹត្តដរាបណា គួរនៅដរាបនោះឯង ។ បទថា **សោ បុគ្គលោ** ភ្ជាប់នឹងបទនេះថា **នានុពន្ធិតព្វោ** ។ ក៏ក្នុងបទថា **អនាបុច្ឆា** មានអធិប្បាយថា ភិក្ខុនោះមិនត្រូវប្រាប់បុគ្គលនោះ គួរគេចទៅ ។

បទថា **សំខាបិ** សេចក្តីថា ភិក្ខុដឹងសភាពនៃសមណធម៌មិនសម្រេចយ៉ាងនេះ មិនគួរជាប់ជំពាក់នឹងបុគ្គលនោះ គួរប្រាប់បុគ្គលនោះហើយចៀសចេញទៅ ។ បទថា **អបិ សមុជ្ជមានេនបិ** បានដល់ សូម្បីនឹង ត្រូវបណ្តេញចេញក៏ដោយ ។ ក៏បុគ្គលបែបនេះ សូម្បីបើនឹងឲ្យនាំឈើ ១០០ បាច់ , ទឹក ១០០ ឆ្នាំង ឬ ខ្សាច់ ១០០ ធុង ឬ បណ្តេញចេញដោយ ពាក្យថា ឯងកុំនៅក្នុងទីនេះ ក៏គួរ ឲ្យបុគ្គលនោះអត់ទោសឲ្យហើយ គប្បី នៅអស់មួយជីវិតនោះចុះ ។

( ចប់អដ្ឋកថា វនបត្ថបរិយាយសូត្រទី ៧ )

# អដ្ឋកថា

## មធុបិណ្ឌិកសូត្រ ទី ៨

មធុបិណ្ឌកសូត្រមានពាក្យផ្តើមយ៉ាងនេះថា ខ្ញុំម្ចាស់បានស្តាប់មកយ៉ាងនេះ ៖

បណ្តាបទទាំងនោះ បទថា **មហាវនំ** បានដល់ ព្រៃដែលកើតឡើងឯង ដោយមិនមានអ្នកណាដាំ តជាប់ជាមួយព្រៃហិមពាន្ត មិនដូចព្រៃដែលពាក់ព័ន្ធជាមួយព្រៃដែលដាំ នឹងនៅមិនទាន់បានដាំ ក្នុងក្រុងវេសាលី ។ បទថា **ទិវាវិហារាយ** បានដល់ ដើម្បីប្រយោជន៍ទ្រង់ឈប់សម្រាកក្នុងពេលថ្ងៃ ។ បទថា **វេឡុវលដ្ឋិកាយ** បានដល់ ដើមទៀងជំទង់ ។ បទថា **ទណ្ឌបាណិ** គឺ ទ្រង់កាន់ឈើច្រត់ ព្រោះភាពជាអ្នកទុព្វលភាពដោយជរាក៏ទេ ។ ព្រោះទណ្ឌបាណិសក្យនេះ នៅក្មេងកម្លោះ ស្ថិតនៅក្នុងបឋមវ័យ តែទ្រង់កាន់ឈើច្រត់មាស ព្រោះការដែលមានចិត្តក្នុងឈើច្រត់ត្រាច់ទៅ ព្រោះដូច្នោះ ទើបហៅថា **ទណ្ឌបាណិ** ។ បទថា **ជង្ឃាវិហារំ** បានដល់ ដើរលេងដើម្បីបន្ទូរការនឿយហត់នៃស្មងជើង បទថា **អនុចង្កមមានោ** គឺ កំពុងដើរទៅមក ដើម្បីប្រយោជន៍ដល់ការទតស្ងួន ទតព្រៃភ្នំជាដើម ។ បានឮថា ទណ្ឌបាណិសក្យនោះ កាលស្តេចចេញទៅ ក៏ស្តេចចេញក្នុងពេលខ្លះប៉ុណ្ណោះ ត្រាច់ទៅ ។ បទថា **ទណ្ឌមោលុព្ភា** មានន័យថា ទ្រង់ទប់ឈើច្រត់ គឺ ដាក់ឈើច្រត់ខាងមុខ ដូចក្មេងឃ្វាលគោ ដាក់ព្រះហស្ថ

ទាំងពីរលើចុងឈើច្រត់ ទ្រង់ឯបខ្នងព្រះហស្ដដាក់និងព្រះហណុ ហើយប្រថាប់ឈរនៅនឹងកន្លែងមួយដ៏សមគួរ ។ បទថា **កឹវាទី** បានដល់ទ្រង់មានការឃើញយ៉ាងណា បទថា **កិមក្ខាយិ** គឺ ត្រាស់ប្រាប់យ៉ាងណា ។ ព្រះរាជានេះ ទ្រង់មិនសំពះព្រះមានព្រះភាគ ទ្រង់ធ្វើត្រឹមតែបដិសណ្ឋារៈប៉ុណ្ណោះ ហើយទូលសួរបញ្ហា តែក៏ទូលសួរដោយការទើសទាល់ ព្រោះការដែលមិនប្រាថ្នានឹងដឹង ។ ព្រះរាជានេះ ជាបក្សពួករបស់ទេវទត្ត ព្រោះហេតុអ្វី ។ ព្រោះទេវទត្តបែកពីតថាគត ស្ដេចមកកាន់សំណាក់របស់ព្រះអង្គ ។

បានឮថា ព្រះទេវទត្តនោះពោលយ៉ាងនេះថា ព្រះសមណគោតមមានពៀរវេរាជាមួយត្រកូលពួកយើង មិនប្រាថ្នាសេចក្ដីចម្រើនដល់ត្រកូលយើងទេ ព្រះភគនីរបស់យើង សមគួរសោយសម្បត្តិជាស្ដេចចក្រពត្តិ ព្រះនាងលះបង់សម្បត្តិនោះ ឲ្យវិនាសសាបសូន្យ ព្រោះដូច្នោះសមណគោតម ទើបស្ដេចចេញបួស ទ្រង់ដឹងថា សូម្បីព្រះភាគិនេយរបស់យើងនឹងជាលំដាប់ស្ដេចចក្រពត្តិ ក៏ទ្រង់មិនត្រេកអរ នឹងការចម្រើនរបស់ត្រកូលពួកយើង ទ្រង់គិតថា នុ៎ះរមែងសាបសូន្យទៅ ទើបទ្រង់ញុំាងឲ្យព្រះភាគិនេយនោះ ឲ្យបព្វជាក្នុងពេលនៅក្មេងនុ៎ះឯង ចំណែកយើងវៀរចាកភាគិនេយ ក៏មិនអាចនឹងប្រព្រឹត្តទៅបាន ទើបបានចេញបួសដែរ តាំងតែពីថ្ងៃបួសមក ក៏ទ្រង់មិនក្រឡេកមើលយើង សូម្បីអ្នកបួសយ៉ាងនេះ ដោយដួងព្រះនេត្រត្រង់ៗ ហើយ សូម្បីត្រាស់ក្នុងកណ្ដាលបរិស័ទ ក៏ដូចជាប្រហារដោយពាក្យមិនពិតច្រើន ដូចជាត្រាស់ថា ទេវទត្តជាសត្វអបាយ ដូច្នេះជាដើម ។ រាជានេះ ត្រូវព្រះទេវទត្តញុះ-

ញាណយ៉ាងនេះ ព្រោះដូច្នោះ ទើបទ្រង់ធ្វើដូច្នោះ ។

លំដាប់នោះ ព្រះមានព្រះភាគកាលនឹងត្រាស់ពាក្យដែលសមគួរដល់ព្រះរាជានោះ ដោយព្រះតម្រិះថា យើងនឹងត្រាស់ប្រាប់ដល់ព្រះរាជានោះ ដោយប្រការដែលព្រះរាជានេះមិនអាចដើម្បីត្រាស់ថា ព្រះសមណគោតម នឹងមិនត្រាស់ប្រាប់បញ្ហាដែលយើងទូលសួរ និងដោយប្រការដែលមិនដឹងសាច់ រឿងនៃភាសិត ទើបត្រាស់ថា **យថាវាទី ខោ** ជាដើម ។ បណ្តាបទទាំងនេះ បទថា **ន កេនចិ លោកេ វិគ្គយ្ហ តិដ្ឋតិ** មានន័យថា មិនធ្វើពាក្យជជែកតទល់ គឺ មិនឈ្លោះទាស់ទែងនិងនរណាមួយក្នុងលោក ។ ពិតហើយ ព្រះតថាគតរមែងមិនឈ្លោះទាស់ទែងនឹងសត្វលោក តែសត្វលោក កាលបើត្រាស់ថា មិនទៀង ក៏ពោលថាទៀង , កាលត្រាស់ថា ទុក្ខ , អនត្តា , មិនស្អាត ក៏ពោលថា ស្អាត , ឈ្មោះថា ឈ្លោះជាមួយតថាគត ដូច្នេះ ។ ដោយហេតុនោះឯង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនឈ្លោះជាមួយសត្វលោក តែសត្វលោកឈ្លោះជាមួយតថាគត ធម្មវាទីរមែងមិនឈ្លោះជាមួយអ្នកណា ៗ ដូចគ្នា តែអធម្មវាទីរមែងឈ្លោះ ដូច្នេះ ។ បទថា **យថា** បានដល់ ដោយហេតុណា បទថា **កាមេហិ** បានដល់ វត្ថុកាមខ្លះ កិលេសកាមខ្លះ ។ បទថា **តំ ព្រាហ្មណំ** បានដល់ ព្រាហ្មណ៍ជាខីណាស្រពនោះ ។ បទថា **អកថំកថឹ** បានដល់ ប្រាសចាកសេចក្តីសង្ស័យ ។ បទថា **ឆិន្នកុក្កុច្ចំ** គឺ ឈ្មោះថា កាត់សេចក្តីសង្ស័យបានហើយ ព្រោះកាលណាសេចក្តីសង្ស័យទាក់ទង និងសេចក្តីក្តៅក្រហាយហើយ ភាពត្តាំត្តូងដោយដៃ និងត្តាំត្តូងដោយជើង កាត់ផ្តាច់ហើយ ។

បទថា **ភវាភវេ** បានដល់ ក្នុងភព និងភពដទៃ ឬភពថោកទាប ប្រណីត ។ ពិតហើយ ភពដ៏ប្រណីតដែលដល់ហើយនូវសេចក្តីចម្រើន ហៅថា **អភព** ។ បទថា **សញ្ញា** បានដល់ កិលេសសញ្ញា ។ កិលេសទាំងឡាយនោះឯង លោកពោលហើយ ឈ្មោះថា សញ្ញាក្នុងទីនេះ ព្រោះដូច្នោះ ទើបមានអធិប្បាយក្នុងបទនេះ យ៉ាងនេះថា កិលេស-សញ្ញាទាំងឡាយ នឹងមិនគ្របសង្កត់ព្រាហ្មណ៍ដែលនៅប្រាសចាកកាមទាំងឡាយនោះ អ្នកមានប្រក្រតីពោលការរលត់ចាកលោកទាំងឡាយ ដោយហេតុណា តថាគតរមែងពោលហេតុនោះ ដូច្នេះ ។ ព្រះមាន-ព្រះភាគ ទ្រង់សម្តែងការដែលព្រះអង្គជាព្រះខីណាស្រព ដោយប្រការដូច្នេះ ។ បទថា **និល្លាឡេត្វា** គឺ លានអណ្តាតចេញ ។ បទថា **តិវិសាខំ** បានដល់ ៣ ជុំ ។ បទថា **នលាដិកំ** សេចក្តីថា ថ្ងាសជ្រួញ ទ្រង់សម្តែងស្នាមជ្រួញ ៣ ខ្សែលើថ្ងាស ធ្វើឲ្យថ្ងាសជ្រួញ ។ បទថា **ទណ្ឌមោលុព្ភ** បានដល់ ប្រត់ឈើច្រត់ បទថា **ទណ្ឌមាលុព្ភ** ដូច្នេះក៏បាន អធិប្បាយថា កាន់ហើយគេចចេញទៅ ។ បទថា **អញ្ញតរោ** បានដល់ ភិក្ខុមួយអង្គមិនប្រាកដឈ្មោះ ។

បានឮថា ភិក្ខុនោះឆ្លាតក្នុងអនុសន្ធិ កាលព្រះមានព្រះភាគទ្រង់ត្រាស់ថា **ទណ្ឌបាណិ** ទ្រង់មិនដឹងដោយប្រការណា យើងនឹងសម្តែងដោយប្រការនោះ ទើបកាន់អនុសន្ធិថា ព្រះមានព្រះភាគទ្រង់ត្រាស់បញ្ហាដែលមិនគប្បីដឹងថា ជាយ៉ាងណាហ្ន៎ ទើបទូលសូមព្រះទសពលដោយគិតថា យើងនឹងធ្វើបញ្ហានេះ ឲ្យប្រាកដដល់ព្រះភិក្ខុសង្ឃ ទើបក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ផ្គងអញ្ជលីដ៏រុងរឿង

ដោយម្រាមដៃទាំងជប់ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មានប្រក្រតីត្រាស់យ៉ាងណាជាដើម ។ បទថា **យ-តោនិទានំ** នោះ ជាការទបុំសកលិង្គ អធិប្បាយថា ព្រោះមានសការៈជាហេតុ ។ បទថា **សង្ខា** ក្នុងបទថា បបញ្ចសញ្ញាសង្ខានោះ បានដល់ចំណែក ។ បទថា **បបញ្ចសញ្ញា** បានដល់ សញ្ញាដែលប្រកបដោយគ្រឿងយឺតយូរ គឺ តណ្ហា មានះ និងទិដ្ឋិ ។ម្យ៉ាងទៀត គ្រឿងយឺតយូរនោះឯង ត្រាស់ដោយឈ្មោះថា សញ្ញា ព្រោះដូច្នោះ ក្នុងបទនេះ ទើបមានអធិប្បាយយ៉ាងនេះថា ចំណែកនៃគ្រឿងយឺតយូរ ។ បទថា **សមុទាចរន្តិ** គឺ រមែងប្រព្រឹត្តទៅ ។ បទថា **ឯត្ថ ចេ នត្ថិ អភិនន្ទិតព្វំ** សេចក្តីថា កាលបើពោល គឺ អាយតនៈ ១២ ណាមាននៅចំណែកនៃសញ្ញា គ្រឿងយឺតយូរ រមែងគ្របសង្កត់សូម្បីអាយតនៈ ១ ដែលបុគ្គលគប្បីសប្បាយ គប្បីប្រកាន់ រមែងលេបចូលបាត់មិនមានក្នុងកាលនោះ ។ បណ្តាបទទាំងនោះ បទថា **អភិនន្ទិតព្វំ** សេចក្តីថា គប្បីត្រេកអរថា ជាយើង ជារបស់យើង ។ បទថា **អភិវទិតព្វំ** បានដល់ គប្បីពោលថា យើង របស់យើង ។ បទថា **អជ្ឈោសិតព្វំ** បានដល់ ប្រកបការដែលលេបបាត់ លេបហើយ ឲ្យចប់អស់ហើយគប្បីប្រកាន់យក ។ ទ្រង់សម្តែងការមិនប្រព្រឹត្តទៅនៃតណ្ហាជាដើមនោះតែម្តងក្នុងទីនេះ ដោយបទនោះ ។ បទថា **ឯសេវន្តោ** គឺ សេចក្តីត្រេកអរជាដើម មិនមានតែម្តង ជាទីបំផុតនៃអនុស័យទាំងឡាយ មានរាគានុស័យជាដើម ។ ក្នុងបទទាំងពួងក៏មានន័យនេះដូចគ្នា ។ ក៏ក្នុងទណ្ឌាទានជាដើម បុគ្គលចាប់យកកំណាត់ឈើដោយចេតនាណា ចេតនា

នោះឈ្មោះថា **ទណ្ឌាទានំ** ប្រែថា ការចាប់កំណាត់ឈើ បុគ្គលចាប់សស្ត្រាដោយចេតនាណា ចេតនានោះឈ្មោះថា **សត្ថាទានំ** ប្រែថា ចេតនាកាន់យកសស្ត្រា ការប្រកាន់ខុស ការឈ្លោះដែលដល់ទីបំផុត ការទាស់ទែងគ្នាដែលដល់ការប្រកាន់ផ្សេង ៗ ការវិវាទដែលដល់វាទៈទាំងឡាយផ្សេង ៗ ។ បទថា **តុវំតុវំ** បានដល់ សូម្បីវាចាថា ឯង ឯង ដែលប្រព្រឹត្តទៅហើយ យ៉ាងនេះ ។ ការធ្វើសេចក្ដីស៊កសៀត ឈ្មោះថា **បេសុញ្ញំ** ប្រែថា ការស៊កសៀត ។ វាចាដែលនិយាយមិនពិតដែលមានសភាវៈមិនជាការពិតនោះ គប្បីដឹងថា មុសាវាទ ។ បទថា **ឯត្ថេតេ** មានន័យថា អកុសលដ៏លាមកទាំងនេះ ព្រោះអាយតនៈ ១២ នោះ ។ ពិតហើយ កិលេសទាំងឡាយ សូម្បីកាលនឹងកើតឡើង រមែងកើតព្រោះអាស្រ័យអាយតនៈ ១២ សូម្បីកាលនឹងរលត់ ក៏រមែងរលត់ ព្រោះអាយតនៈ ១២ ដូចគ្នា ។ កិលេសទាំងឡាយ កើតឡើងក្នុងទីណា ក៏រមែងរលត់ក្នុងទីនោះ ដោយប្រការដូច្នេះ ។ សេចក្ដីនេះ គប្បីសម្ដែងដោយ **សមុទយសច្ចបញ្ហា** ។ ពិតហើយ លោកពោលថា ក៏តណ្ហានេះ កាលកើត រមែងកើតក្នុងទីណា កាលរលត់ រលត់ក្នុងទីណា ដូច្នេះហើយទើបពោលការកើតឡើង និងការរលត់នៃតណ្ហានោះ ព្រោះអាយតនៈ ១២ ដោយន័យមានជាអាទិ៍ថា បិយរូប សាតរូប ក្នុងលោកណាតណ្ហានោះ កាលណាកើត រមែងកើតក្នុងបិយរូប សាតរូបនោះ កាលណារលត់ រមែងរលត់ក្នុងបិយរូប សាតរូបនោះ , បិយរូប សាតរូបក្នុងលោកគឺអ្វី គឺ ចក្ខុ ជាបិយរូប សាតរូប ក្នុងលោក ដូច្នេះ ។ តណ្ហាកើតឡើងក្នុងអាយតនៈ ១២ អាស្រ័យនិព្វាន ក៏រលត់ទៅ តែ

មិនមានការគ្របសង្កត់ក្នុងអាយតនៈទាំងឡាយ លោកពោលថា រលត់ហើយក្នុងអាយតនៈទាំងឡាយនោះឯង យ៉ាងណា អកុសលដ៏លាមកសូម្បីទាំងនេះ គប្បីជ្រាបថា រមែងរលត់ព្រោះអាយតនៈទាំងឡាយ ដូច្នោះ ។ ម្យ៉ាងទៀត ការមិនមានសេចក្តីក្ងើតក្ងើនជាដើមនេះ លោកពោលថា ជាទីបំផុតនៃអនុស័យទាំងឡាយ មាន **រាគានុស័យ** ជាដើម ។ អកុសលធម៌ដ៏លាមកទាំងឡាយ រមែងរលត់ដោយមិនសល់ក្នុងនិព្វាន ដែលមានវោហារពោលថា **ឯត្ថេតេ រាគានុសយាទីនំ អន្តោ** ក៏របស់ណាមិនមានក្នុងនិព្វានណា របស់នោះឈ្មោះថា រលត់ហើយក្នុងនិព្វាននោះ ។ សេចក្តីនេះ គប្បីជ្រាបដោយ **និរោធបញ្ញា** ។ សមពិតដូចពាក្យដែលលោកពោលហើយមានជាអាទិ៍ថា វិតក្កៈ វិចារៈ វចីសង្ខាររបស់ភិក្ខុនោះ ដែលចូលដល់ទុតិយជ្ឈាន រមែងស្ងប់រំងាប់ ។ បទថា **សត្ថុ ចេវ សំវណ្ណិតោ** គឺ អ្នកដែលព្រះសាស្តាទ្រង់សរសើរហើយ ។ សូម្បីពាក្យនេះថា **វិញ្ញូនំ** ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថតតិយវិភត្តិ អធិប្បាយថា អ្នកជាសព្រហ្មចារីទាំងឡាយ បណ្ឌិតសរសើរហើយ ។ បទថា **បហោតិ** គឺ រមែងអាច ។ បទថា **អតិក្កមេវ មូលំ អតិក្កម ខន្ធំ** សេចក្តីថា ធម្មតាខ្លឹមឈើគប្បីមានក្នុងដើម ឬគល់ តែកន្លងហួសនូវដើម និងគល់នោះ ។ បទថា **ឯវំ សម្បទំ** សេចក្តីថា សេចក្តីឧបមេយ្យនេះ ក៏ដូច្នោះ អធិប្បាយថា ដូច្នេះ ។ បទថា **អតិសិត្វា** បានដល់ ឈានកន្លងហើយ ។ បទថា **ជានំ ជានាតិ** បានដល់ ដឹងរបស់ដែលគប្បីដឹងនោះឯង ។ បទថា **បស្សំ បស្សតិ** បានដល់ ឃើញរបស់ដែលគួរឃើញនោះ ។ ម្យ៉ាងទៀត បុគ្គលខ្លះ ប្រកាន់យកសេចក្តី

វិបរិតសូម្បីកាលដឹងក៏ថា មិនដឹង ឃើញក៏ថា មិនឃើញ យ៉ាងណា ចំណែកព្រះមានព្រះភាគ គឺ មិនដូច្នេះ កាលណាទ្រង់ដឹង ក៏ថាដឹង កាលណាទ្រង់ឃើញ ក៏ថាឃើញ តែម្យ៉ាង ។ ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា ជាអ្នកមានព្រះចក្ខុ ព្រោះអត្ថថា ជាអ្នកនាំក្នុងទស្សនៈ , ឈ្មោះថា ជាអ្នកមានព្រះញាណ ព្រោះអត្ថថា ធ្វើរបស់ដែលទ្រង់ដឹងហើយ , ឈ្មោះថា មានធម៌ ព្រោះអត្ថថា មានសភាវៈដែលមិនវិបរិត ឬព្រោះទ្រង់មានព្រះធម៌វិន័យ ដែលទ្រង់គិតដោយព្រះហឫទ័យ ទ្រង់ថ្លែងដោយព្រះវាចាប្រព្រឹត្តទៅក្នុងព្រះបរិយត្តិធម៌ , ឈ្មោះថា ជាព្រហ្ម ព្រោះអត្ថថា ប្រសើរបំផុត ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមានព្រះចក្ខុ ព្រោះជាអ្នកមានព្រះចក្ខុ សូម្បីក្នុងបទទាំងនោះ ក៏មានសេចក្តីយ៉ាងនេះ ។ ព្រះមានព្រះភាគអង្គនោះ ជាអ្នកផ្សាយ ព្រោះទ្រង់ផ្សព្វផ្សាយព្រះធម៌ , ជាអ្នកប្រកាស ព្រោះទ្រង់ប្រកាសធម៌ , ជាអ្នកពង្រីកសេចក្តី ព្រោះព្រះអង្គទ្រង់នាំហើយ នាំទៀត នូវសេចក្តីដែលទ្រង់សម្តែង , ជាអ្នកឲ្យអមតធម៌ ព្រោះព្រះអង្គទ្រង់សម្រេចអមតធម៌ ហើយទ្រង់ឲ្យបដិបត្តិ ។ បទថា **អគរុករិត្វា** មានអធិប្បាយថា ក៏ព្រះមហាកច្ចានៈកាលបើត្រូវទទួចសុំរឿយ ៗ ឈ្មោះថា ធ្វើការធ្ងន់ចិត្ត សូម្បីស្ថិតនៅក្នុងសាវកបារមីញាណរបស់ខ្លួន សម្តែងធ្វើឲ្យដឹងបានដោយលំបាក ដូចគំនរខ្សាច់នៅជិតជើងភ្នំព្រះសិនេរុ ឈ្មោះថា ការធ្ងន់ចិត្តដូចគ្នា សូមលោកមេត្តាកុំធ្វើឲ្យពួកខ្ញុំស្រែកសូមរឿយ ៗ ហើយសម្តែងធម៌ឲ្យដឹងបានដោយងាយដល់ពួកខ្ញុំចុះ ក្នុងបទនេះថា **យំ ខោ នោ អាវុសោ** ព្រះមហាកច្ចានៈគួរពោលថា **យំ ខោ វោ** សូម្បីក៏ពិត តែដូច្នោះ កាលបើសង្គ្រោះ

ភិក្ខុទាំងនោះ ព្រមជាមួយខ្លួន ទើបពោលថា **យំ ខោ នោ** ដូច្នេះ ។ ឬព្រោះឧទ្ទេស ឲ្យសម្តែងហើយដល់ភិក្ខុទាំងនោះ តែព្រះមានព្រះភាគ ក៏ទ្រង់សម្តែងដល់ព្រះថេរខ្លះ ដល់ភិក្ខុទាំងនោះ ៗ ខ្លះ ព្រោះដូច្នោះ លោកសំដៅដល់បទនេះថា **ភគវា** ទើបពោលយ៉ាងនេះ អធិប្បាយថា ព្រះមានព្រះភាគរបស់ពួកយើង ទ្រង់សម្តែងឧទ្ទេសដោយសង្ខេបណា ដល់ពួកលោក ដូច្នេះ ។ ក្នុងបទនេះថា **ចក្ខុញ្ចាវុសោ** ជាដើម មានអធិប្បាយយ៉ាងនេះ ម្នាលអ្នកដ៏មានអាយុទាំងឡាយ ក៏ធម្មតាចក្ខុវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យចក្ខុបសាទដោយភាពជានិស្ស័យ និងរូប ដែលប្រកបដោយសមុដ្ឋាន ៤ យ៉ាង ដោយភាពជាអារម្មណ៍ ។ បទថា **តិណ្ណំ សង្គតិ ផស្សោ** សេចក្តីថា ព្រោះប្រជុំធម៌ ៣ ប្រការនោះ ទើបកើតផស្សៈ ព្រោះផស្សៈជាបច្ច័យ ដោយអំណាចកើតឡើងព្រមជាដើម ព្រោះអាស្រ័យផស្សៈនោះ ទើបកើតវេទនា និងដោយវេទនានោះ បុគ្គលសោយអារម្មណ៍ណាមួយ សញ្ញាក៏ចាំអារម្មណ៍នោះ សញ្ញាចាំអារម្មណ៍ណា វិតក្ក ក៏ត្រិះរិះដល់អារម្មណ៍នោះតែម្តង វិតក្កត្រិះរិះដល់អារម្មណ៍ណា គ្រឿងនាំឲ្យយឺតយូរ ក៏យឺតយូរដល់អារម្មណ៍នោះឯង ។ បទថា **តតោនិទានំ** បានដល់ ព្រោះការណ៍ មានចក្ខុរូបជាដើមនោះ ។ បទថា **បុរិសំ បបញ្ចសញ្ញា សង្ខា សមុទាចរន្តិ** សេចក្តីថា ចំណែកនៃគ្រឿងឲ្យយឺតយូរ រមែងគ្របសង្កត់បុរសអ្នកមិនបានកំណត់ដឹងដោយជុំវិញនៃហេតុនោះ អធិប្បាយថា រមែងប្រព្រឹត្តទៅដល់បុរសនោះ ក្នុងសេចក្តីនោះ ផស្សៈ វេទនា និងសញ្ញា ជាការដែលកើតឡើងព្រមជាមួយចក្ខុវិញ្ញាណ គប្បីឃើញវិតក្កក្នុងចិត្ត

ដែលមានវិតក្ក មានក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម ។ សួរថា ចំណែកនៃគ្រឿងនាំឲ្យយឺតយូរកើតព្រមជាមួយជវនៈ បើដូច្នោះ ព្រោះហេតុអ្វី ទើបធ្វើការកាន់យកអតីត និងអនាគតទៀត ។ ឆ្លើយថា ព្រោះកើតឡើងយ៉ាងនោះ ។ ដូចជាគ្រឿងនាំឲ្យយឺតយូរ ដែលប្រព្រឹត្តទៅតាមផ្លូវចក្ខុទ្វារ កើតឡើងហើយក្នុងឥឡូវនេះ ព្រោះអាស្រ័យចក្ខុ រូប និងសម្ផស្ស វេទនា សញ្ញា វិតក្ក យ៉ាងណា ព្រះមហាកច្ចានៈ កាលនឹងសម្ដែងការកើតឡើងនូវគ្រឿងនាំឲ្យយឺយូរនោះ ក្នុងរូបទាំងឡាយ ដែលគប្បីដឹងដោយចក្ខុ សូម្បីជាអតីត និងអនាគត ទើបពោលយ៉ាងនោះ ដូច្នោះដូចគ្នា ។ ក្នុងបទសូម្បីជាដើមថា **សោតញ្ចាវុសោ** មានបច្ច័យដូចគ្នា ។ ក៏គប្បីជ្រាបវិនិច្ឆ័យក្នុងឆដ្ឋទ្វារ ។ បទថា **មនំ** បានដល់ ភវង្គចិត្ត ។ បទថា **ធម្មេ** បានដល់ ធម្មារម្មណ៍ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **មនោវិញ្ញាណំ** បានដល់ អាវជ្ជនៈ ឬជវនៈ កាលបើអាវជ្ជនៈកាន់យកហើយ ផស្សៈ វេទនា សញ្ញា និងវិតក្ក រមែងកើតព្រមជាមួយអាវជ្ជនៈ គ្រឿងនាំឲ្យយឺតយូរក៏កើតព្រមជាមួយជវនៈ កាលបើជវនៈកាន់យកហើយ ភវង្គចិត្តដែលមានព្រមជាមួយអាវជ្ជនៈ ឈ្មោះថា **មនោ** តពីនោះទៅផស្សៈជាដើម សូម្បីទាំងអស់ក៏កើតព្រមជាមួយជវនៈ ចំណែកក្នុងមនោទ្វារ អារម្មណ៍សូម្បីទាំងអស់ ដែលផ្សេងដោយជាអតីតជាដើម ក៏រមែងមាន ព្រោះដូច្នោះ ពាក្យនេះថា ដែលជាអតីតៈ អនាគត និងបច្ចុប្បន្ន ជាការសមគួរហើយ ។ ឥឡូវនេះ ព្រះថេរៈកាលនឹងសម្ដែងពីវដ្ដៈ ទើបប្រារព្ធទេសនាថា **សោ វតាវុសោ** ដូច្នេះ ។ បទថា **ផស្សបញ្ញត្តិំ បញ្ញបេស្សតិ**

មានន័យថា នឹងបញ្ញត្តិ នឹងសម្ដែង ផស្សៈបញ្ញត្តិយ៉ាងនេះថា ធម៌ ១ ឈ្មោះថា ផស្សៈ រមែងកើតឡើង ។ ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។ ព្រះថេរៈកាលបើសម្ដែងវដ្ដៈទាំងអស់ ដោយអំណាចអាយតនៈ ១២ ថា កាលបើអាយតនៈនេះមាន អាយតនៈនោះក៏មាន ដោយប្រការដូច្នេះ ។ ឥឡូវនេះ កាលណានឹងសម្ដែងវិវដ្ដៈ ដោយអំណាចបដិសេធអាយតនៈ ១២ ទើបប្រារព្ធទេសនាថា **សោ វតាវុសោ ចក្ខុស្មឹ អសតិ** ដូច្នេះ ។ គប្បីជ្រាបអត្ថ ដោយន័យដែលបានពោលហើយក្នុងបទនេះ នោះឯង ។ ព្រះថេរៈ កាលបើវិសជ្ជនាបញ្ហាយ៉ាងនេះហើយ ឥឡូវនេះ ទើបពោលបញ្ចូនទៅថា បញ្ហាដែលសាវកពោលហើយ ព្រោះដូច្នោះ អ្នកទាំងឡាយកុំជាអ្នកសង្ស័យព្រះមានព្រះភាគអង្គនេះ ទ្រង់កាន់យកការប្រៀបធៀបដោយព្រះសព្វញ្ញុតញ្ញាណ ប្រថាប់គង់ហើយ អ្នកទាំងឡាយកាលបើប្រាថ្នា ចូរចូលទៅគាល់ព្រះមាន-ព្រះភាគអង្គនោះ ក៏នឹងអស់សេចក្ដីសង្ស័យ ដូច្នេះ ទើបពោលពាក្យថា **អាកង្ខមានា ច បន** ដូច្នេះជាដើម ។

បទថា **ឥមេហិ អាការេហិ** សេចក្ដីថា ដោយហេតុទាំងនេះ គឺដោយការណ៍ ចំពោះនៃការកើតឡើងឯង គ្រឿងនាំឲ្យយឺតយូរ និងការទាក់ទិនជាមួយវដ្ដៈ និងវិវដ្ដៈ ។ បទថា **ឥមេហិ បទេហិ** ដោយប្រមូលអក្ខរៈទាំងនេះ ។ បទថា **ព្យញ្ជនេហិ** បានដល់ ដោយអក្ខរៈយ៉ាងត្រង់ ។ បទថា **បណ្ឌិតោ** មានន័យថា ប្រកបព្រមដោយភាពជាបណ្ឌិត ឬជាបណ្ឌិតដោយហេតុ ៤ យ៉ាង គឺ ឆ្លាតក្នុងធាតុ ឆ្លាតក្នុងអាយតនៈ ឆ្លាតក្នុងបច្ចយាការ ឆ្លាតក្នុងហេតុ និងមិនមែនហេតុ ។

បទថា **មហាបញ្ញោ** មានន័យថា ដល់ព្រមដោយបញ្ញាច្រើន ដែលអាចនឹងកំណត់ធម៌ច្រើន , អត្ថច្រើន , និរុត្តិច្រើន , បដិភាណច្រើន ។ បទថា **យថា តំ មហាកច្ចានេន** មានន័យថា កច្ចានព្យាករណ៍ដោយប្រការណា ទ្រង់សម្តែងដល់ព្យាករណ៍នោះ ទើបត្រាស់ថា **តំ** សេចក្តីថា ព្យាករណ៍នោះ មហាកច្ចានៈព្យាករណ៍ហើយដោយប្រការណា សូម្បីតថាគតក៏ព្យាករណ៍យ៉ាងនោះ ដូចគ្នា ។ បទថា **មធុបិណ្ឌិកំ** បានដល់ នុំផ្អែមក្រៃលែង ឬដុំសដូវដែលផ្សំហើយ ។ បទថា **អសេ-ចនកំ** បានដល់ ដែលគប្បីរីករាយចិត្ត គឺរសដែលផ្សំល្អ ដែលមិនគួរពោលថា ក្នុងបណ្តាទឹកដោះថ្លា ទឹកអំពៅ ទឹកឃ្មុំ និងស្ករត្នោតជាដើម ឈ្មោះនេះតិច របស់នេះច្រើន ។ បទថា **ចេតសោ** បានដល់អ្នកមានជាតិជាអ្នកគិត ។ បទថា **ទព្វជាតិកោ** គឺ មានសភាពជាបណ្ឌិត ។ ព្រះថេរៈចូន់ក្នុងហេតុផលយ៉ាងក្រៃលែង ទើបគិតថា នេះជាធម្មបរិយាយ យើងនឹងទូលឲ្យទ្រង់តាំងឈ្មោះធម្មបរិយាយនោះ ដោយសព្វញ្ញុតញ្ញាណរបស់ព្រះទសពលនោះឯង ទើបទូលពាក្យនេះថា ធម្ម-បរិយាយនេះឈ្មោះអ្វី ។ បទថា **តស្មា** សេចក្តីថា ព្រោះធម្មបរិយាយដ៏ផ្អែមល្ហែមដូចនំផ្អែម ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា អ្នកចូលចងចាំធម្មបរិយាយនេះថា **មធុបិណ្ឌិកបរិយាយ** ដូច្នេះចុះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្តីងាយទាំងអស់ទេ ។

(ចប់អដ្ឋកថា មធុបិណ្ឌិកសូត្រទី ៨)

# អដ្ឋកថា

## ទ្វេធាវិតក្កសូត្រ ទី ៩

ទ្វេធាវិតក្កសូត្រមានពាក្យផ្តើមថា ខ្ញុំម្ចាស់បានស្តាប់មកយ៉ាងនេះ ៖

ក្នុងបទទាំងនោះ បទថា ទ្វេធា កត្វា ទ្វេធា កត្វា សេចក្តីថា ធ្វើឲ្យទៅជា ២ ភាគ ។ វិតក្កដែលប្រកបដោយកាម ឈ្មោះថា កាម-វិតក្ក ។ វិតក្កដែលប្រកបដោយការប្រទូសរ៉ាយ ឈ្មោះថា ព្យាបាទ-វិតក្ក ។ វិតក្កដែលប្រកបដោយការបៀតបៀន ឈ្មោះថា វិហិង្សាវិតក្ក ។ បទថា ឯកំ ភាគំ មានន័យថា វិតក្កនេះសូម្បីទាំងអស់ ទាំងខាងក្នុង ឬខាងក្រៅ គ្រោតគ្រាត ឬល្អិត ក៏ជាចំណែកនៃអកុសលទាំងអស់ ព្រោះដូច្នោះ យើងទើបធ្វើកាមវិតក្ក ព្យាបាទវិតក្ក និងវិហិង្សាវិតក្ក សូម្បីទាំង ៣ ឲ្យជាចំណែកមួយ ។ វិតក្កដែលរលាស់ចេញចាកកាមទាំងឡាយ ហើយប្រកបព្រមដោយនេក្ខម្មៈ ឈ្មោះថា នេក្ខម្មវិតក្ក ។ នេក្ខម្មវិតក្កនោះ រមែងគួរដល់បឋមជ្ឈាន ។ វិតក្កដែលប្រកបព្រម ដោយការមិនប្រទូសរ៉ាយ ឈ្មោះថា អព្យាបាទវិតក្ក ។ អព្យាបាទវិតក្កនោះ រមែងគួរផ្តើមតាំងពី មេត្តាបុព្វភាគរហូតដល់បឋមជ្ឈាន ។ វិតក្កដែលប្រកបព្រមដោយការមិនបៀតបៀន ឈ្មោះថា អវិហិង្សាវិតក្ក ។ អវិហិង្សាវិតក្កនោះ រមែងគួរតាំងពីករុណាបុព្វភាគរហូតដល់

មឋមជ្ឈាន ។

បទថា **ទុតិយភាគំ** សេចក្ដីថា លោកសម្ដែងកាលវេលាក្នុងការសង្កត់វិតក្ករបស់ព្រះពោធិសត្វ ដោយបទនេះថា វិតក្កនេះ សូម្បីទាំងអស់ជាចំណែកកុសលទាំងអស់ ព្រោះដូច្នោះ ទើបយើងធ្វើឲ្យជាចំណែកទី ២ ។

ក៏កាលណាព្រះពោធិសត្វ ទ្រង់តាំងផ្ដើមសេចក្ដីព្យាយាមរហូត ៦ ឆ្នាំ វិតក្កទាំងឡាយ មាននេក្ខម្មវិតក្កជាដើម បានប្រព្រឹត្តទៅហើយ ដូចអន្លង់ទឹកដែលពេញប្រៀបដូច្នោះ ក៏វិតក្កទាំងឡាយ មានកាមវិតក្កជាដើម កើតឡើងរហ័ស ព្រោះការវង្វេងភ្លេចសតិ កាត់ផ្ដាច់ភារៈនៃកុសល ក្លាយជាភារៈស្ទុះទៅរកអកុសលទាំងនោះ ចាប់តាំងពីនោះ ព្រះពោធិសត្វទ្រង់ត្រិះរិះថា ក៏វិតក្កទាំងឡាយ មានកាមវិតក្កជាដើមរបស់យើង បានកាត់បន្ថយភារៈនៃកុសលតាំងនៅ ណ្ហើយ យើងនឹងធ្វើវិតក្កទាំងនេះឲ្យទៅជា ២ ចំណែក ព្រោះដូច្នោះ យើងទើបធ្វើចំណែក ១ ថា វិតក្ក មានកាមវិតក្កជាដើម ជាផ្នែកអកុសល , ចំណែក ១ ទៀត មាននេក្ខម្មវិតក្កជាដើម ជាផ្នែកកុសល លំដាប់នោះ តថាគតក៏សង្កត់វិតក្ក ដែលជាផ្នែកអកុសលដោយសេចក្ដីដឹង ដូចសង្កត់ក្បាលពស់វែក ហើយចាប់ដូចជាចាប់កសត្រូវ ដូច្នោះ យើងនឹងឲ្យអកុសលវិតក្កនោះចម្រើន យើងនឹងញ៉ាំងវិតក្ក ដែលជាចំណែកកុសលឲ្យចម្រើនរហ័ស ដូចមេឃក្នុងសម័យភ្លៀង និងដូចស្រែល្អ មានដំណាំដុះល្អ ដូច្នោះ ព្រះពោធិសត្វនោះ ទ្រង់ធ្វើដូច្នោះហើយ សង្កត់អកុសលវិតក្កទាំងឡាយ ញ៉ាំងកុសលវិតក្កឲ្យចម្រើន ។

វេលាក្នុងការ សង្កត់វិតក្ករបស់ព្រះពោធិសត្វ គប្បីជ្រាបថា លោកសម្តែង ហើយដោយបទនោះ ដោយប្រការដូច្នោះ ។ វិតក្កទាំងនោះ កើតឡើងដល់ព្រះពោធិសត្វនោះ ដោយប្រការណា ហើយព្រះពោធិសត្វសង្កត់វិតក្កទាំងនោះ ដោយប្រការណា ឥឡូវនេះ ព្រះមានព្រះភាគ កាលបើទ្រង់នឹងសម្តែងប្រការនោះ ទើបទ្រង់ត្រាស់ថា **តស្ស មយ្ហំ ភិក្ខវេ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **អបមត្តស្ស** មានន័យថា ស្ថិតនៅក្នុងការមិនប្រាសចាកសតិ ។ បទថា **អាតាបិនោ** មានន័យថា មានសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។ បទថា **បហិតត្តស្ស** មានន័យថា មានចិត្តបញ្ជូនទៅហើយ ។ បទថា **ឧបជ្ជតិ កាមវិតក្កោ** មានន័យថា កាលបើព្រះពោធិសត្វទ្រង់តាំងសេចក្តីព្យាយាមរហូត ៦ ឆ្នាំ ឈ្មោះថា កាមវិតក្កដែលប្រារព្ធសេចក្តីសុខ ក្នុងការគ្រប់គ្រងរាជសម្បត្តិ ប្រាសាទ ស្រីរបាំ ស្រីស្នំ ឬប្រារព្ធសម្បត្តិយ៉ាងណាមួយ ធ្លាប់កើតឡើងហើយ ។ ក៏ព្រះពោធិសត្វនោះ ទ្រង់ដល់ការសមាទានដ៏លើសលុប ដោយទ្រង់អត់ព្រះក្រយាហារក្នុងការបំពេញទុក្ករកិរិយា ទ្រង់មានព្រះតម្រិះថា បុគ្គលអត់អាហារមិនអាចដើម្បីញ៉ាំងគុណវិសេសឲ្យកើតឡើងបាន កុំឡើយ យើងគប្បីនាំអាហារយ៉ាងគ្រោតគ្រាតមកសោយ ដូច្នោះ ។ ព្រះពោធិសត្វនោះ ស្តេចចូលទៅកាន់ឧរុវេលាដើម្បីដុំបាយ មនុស្សទាំងឡាយគិតថា ក្នុងកាលមុន មហាបុរសទ្រង់មិនទទួលអាហារ សូម្បីនាំមកថ្វាយ ឥឡូវនេះ ប្រហែលជាមនោរថរបស់ព្រះអង្គដល់ទីបំផុតហើយ ព្រោះដូច្នោះ ទើបស្តេចយាងមកខ្លួនឯង

ដូច្នោះ ទើបនាំគ្នានាំអាហារដ៏ប្រណីត ៗ មកថ្វាយ ។

អត្តភាពរបស់ព្រះពោធិសត្វ ក៏ត្រឡប់ជាធម្មតា ដោយមិនយូរប៉ុន្មាន ។ ពិតហើយ អត្តភាពដែលគ្រាំគ្រាព្រោះជរា សូម្បីនឹងបានភោជនដែលសប្បាយ ក៏មិនត្រឡប់ជាប្រក្រតីបាន ។ តែព្រះពោធិសត្វនៅក្មេង ព្រោះហេតុនោះ កាលបើព្រះពោធិសត្វ សោយក្រយាហារដោយសប្បាយ អត្តភាព ទើបជាប្រក្រតីដោយមិនយូរប៉ុន្មាន ។ ព្រះឥន្ទ្រិយ៍ទាំងឡាយក៏ផូរផង់ ព្រះឆវីវណ្ណក៏បរិសុទ្ធ ព្រះសរីរៈដែលប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ បរិបូណ៌ដូចហ្វូងតារាអណ្តែតលើផ្ទៃមេឃ ដូច្នោះ ។ ព្រះពោធិសត្វនោះ ទ្រង់មើលឃើញអត្តភាពនោះហើយ ទ្រង់គិតថា អត្តភាព ឈ្មោះថា លំបាកដល់ថ្នាក់នោះ ត្រឡប់ជាប្រក្រតីយ៉ាងនេះ ទ្រង់កាន់យកវិតក្កៈ សូម្បីបន្តិចបន្តួច ព្រោះព្រះអង្គទ្រង់មានបញ្ញាច្រើន ទើបទ្រង់ធ្វើការត្រិះរិះថា កាមវិតក្ក ។ ព្រះអង្គទ្រង់ប្រថាប់គង់ខាងមុខព្រះបណ្ណសាលា ទ្រង់ឃើញហ្វូងសត្វម្រឹគ មានក្តាន់ ឈ្លូស គោ រមាំងជាដើម ហ្វូងសត្វស្លាប មានមាន់ព្រៃជាដើម ដែលស្រែកយំពីរោះគួរចាប់ចិត្ត បឹងទាំងឡាយដេរដាសដោយឈូកខៀវ ឈូកក្រហម ឈូកសជាដើម ដងព្រៃស្ងប់ស្ងាត់ ដេរដាសដោយផ្កាឈើនានា និងស្ទឹងនេរញ្ជរាក៏ហូរនាំទឹកល្អក់ សល់តែទឹកថ្លាដូចដុំកែវមណី ។ ព្រះពោធិសត្វនោះ ទ្រង់មានព្រះតម្រិះថា ហ្វូងម្រឹគ ហ្វូងបក្សី បឹង ដងព្រៃ ស្ទឹងនេរញ្ជរាទាំងនោះ ស្រស់ល្អហ្ន៎ ដូច្នេះ ។ ព្រះអង្គ ទ្រង់មានវិតក្កបន្តិចបន្តួចយ៉ាងនេះ សូម្បីនោះ ទ្រង់ធ្វើកាមវិតក្ក

ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា កាមវិតក្ក រមែងកើតឡើង ដូច្នេះ ។ បទថា **អត្តព្យាពាធាយបិ** សេចក្តីថា ដើម្បីសេចក្តីទុក្ខដល់ខ្លួនខ្លះ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នា , សួរថា ឈ្មោះថា វិតក្កដែលប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខទាំងពីរចំណែករបស់ព្រះមហាសត្វឬ ? ឆ្លើយថា មិនមាន ។

កាលព្រះមហាសត្វស្ថិតនៅក្នុងការមិនកំណត់ដឹងវិតក្ក រមែងប្រព្រឹត្តទៅហួតដល់ការបៀតបៀនទាំង ២ ចំណែក ព្រោះដូច្នោះ ទើបមានឈ្មោះ ៣ យ៉ាង ដូច្នេះ ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ត្រាស់យ៉ាងនេះ ។ បទថា **បញ្ញានិរោធិកោ** សេចក្តីថា រមែងមិនឲ្យបញ្ញាកើតឡើងបានជាលោកិយៈ និងលោកុត្តរៈ ដែលមិនទាន់កើតឡើង ។

ក៏វិតក្កកាត់ផ្តាច់លោកិយបញ្ញា សូម្បីកើតឡើងហើយ ដោយអំណាចនៃសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យអស់ទៅ ព្រោះដូច្នោះ ទើបធ្វើឲ្យបញ្ញារលត់ ។ បទថា **វិឃាតបក្ខិកោ** មានន័យថា ជាចំណែកនៃទុក្ខ ។ ឈ្មោះថា មិនប្រព្រឹត្តទៅដើម្បីនិព្វាន ព្រោះវិតក្កនោះ ធ្វើមិនឲ្យច្បាស់នូវព្រះនិព្វានដែលមិនមានបច្ច័យតាក់តែង ។ បទថា **អព្ភត្ថំ គច្ឆតិ** សេចក្តីថា ដល់ការអស់ទៅ គឺ ការមិនមាន គឺ រលត់ទៅ ដូចពពុះទឹក ដូច្នោះ ។ បទថា **បជហមេវ** លះបង់ហើយនោះឯង ។

បទថា **វិនោទនមេវ** នាំចេញទៅហើយ ។ បទថា **ព្យន្តមេវ នំ អកាសឹ** មានន័យថា យើងធ្វើវិតក្កនោះ ឲ្យប្រាសទៅមិនមានសល់ និង

វិលត្រឡប់ បិទបាំងនោះឯង ។ បទថា **ព្យាបាទវិតក្កោ** មានន័យថា វិតក្ក ដែលឈ្មោះថា ប្រកបព្រមដោយការបៀតបៀនអ្នកដទៃ រមែងមិនកើតក្នុង ព្រះហឫទ័យរបស់ព្រះពោធិសត្វ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ សំដៅដល់ការដែលព្រះពោធិសត្វនោះ ទ្រង់បង្អោនចិត្តទៅ ព្រោះអាស្រ័យ ហេតុទាំងឡាយ មានភ្លៀងខ្លាំង ក្តៅខ្លាំង និងរងាខ្លាំងជាដើមនោះ ទើប ទ្រង់ត្រាស់ថា ព្យាបាទវិតក្ក ដូច្នោះ ។ បទថា **វិហឹសាវិតក្កោ** មានន័យថា វិតក្កដែលប្រកបព្រមដោយការញាំងទុក្ខ ឲ្យកើតឡើងដល់មនុស្សពួកដទៃ រមែងមិនកើតដល់ព្រះមហាសត្វ ។ តែអាការនៃសេចក្តីរាយមាយក្នុងព្រះ ហឫទ័យ ជាអាការនៃអារម្មណ៍ច្រើនប្រការ ព្រះពោធិសត្វទ្រង់កាន់យក អាការនោះ ធ្វើវិហិង្សាវិតក្ក ។ ព្រោះព្រះអង្គ ប្រថាប់គង់ជិតទ្វារនៃព្រះ បណ្ណសាលា ទ្រង់ឃើញសត្វសាហាវ មានសត្វ សីហៈ និងខ្លាធំជាដើម កំពុងបៀតបៀនសត្វតូច ៗ មានជ្រូកជាដើម ។ លំដាប់នោះ ព្រះពោធិសត្វ ទ្រង់ត្រិះរិះថា សត្រូវទាំងឡាយ រមែងកើតឡើងដល់សត្វតិរច្ឆានទាំងនោះ ក្នុងព្រៃដែលមិនមានភ័យ ដែលមានឈ្មោះយ៉ាងនេះ ពួកសត្វមានកម្លាំង ខ្លាំង ស៊ីសត្វមានកម្លាំងខ្សោយ , ពួកសត្វស៊ីសត្វមានកម្លាំងតិច រមែង រស់នៅបាន ដូច្នេះ ។ ទ្រង់ញាំងព្រះករុណាឲ្យកើតឡើង ទ្រង់ឃើញសត្វ សូម្បីពួកសត្វដទៃ មានខ្លា ឆ្មាជាដើម កំពុងស៊ីសត្វ មានមាន់ និងកណ្តុរ ជាដើម ។ ស្តេចទ្រង់យាងទៅកាន់ភូមិ ដើម្បីបិណ្ឌបាត ទ្រង់ញាំងព្រះ ករុណាឲ្យកើតឡើងថា មនុស្សទាំងឡាយ ត្រូវរាជការបៀតបៀន រងទុក្ខ

មានការសម្លាប់ និងការចាប់ចងជាដើម រមែងមិនមានពេលធ្វើការងារ
របស់ខ្លួន មានការធ្វើស្រែ និងការលក់ដូរចិញ្ចឹមជីវិតជាដើម ។ ទ្រង់សំដៅ
ដល់ព្រះករុណានោះ ទើបត្រាស់ថា វិហិង្សាវិតក្ក រមែងកើតឡើង ។
បទថា **តថា តថា** មានសេចក្តីថា ដោយហេតុនោះ ៗ ។ លោកអធិប្បាយ
យ៉ាងនេះថា ទ្រង់រិះគិតវិតក្កណា ៗ មានកាមវិតក្កជាដើម និងញ៉ាំងវិតក្ក
ណា ៗ ឲ្យប្រព្រឹត្តទៅ ព្រះពោធិសត្វនោះ មិនមានព្រះហឫទ័យ ដោយ
ការមានកាមវិតក្កជាដើមនោះឡើយ ដោយអាការនោះៗ ។ បទថា **បហាសិ
នេក្ខម្មវិតក្កំ** សេចក្តីថា លះនេក្ខម្មវិតក្ក ។ បទថា **ពហុលមកាសិ** មាន
ន័យថា បានធ្វើឲ្យច្រើន ។ បទថា **តស្ស តំ កាមវិតក្កាយ ចិត្តំ** មានន័យ
ថា ព្រះហឫទ័យរបស់ព្រះពោធិសត្វនោះ រមែងបង្អោនទៅដើម្បីប្រយោជន៍
ដល់កាមវិតក្ក ដោយប្រការដែលប្រកបព្រមដោយកាមវិតក្កនោះឯង ។ សូម្បី
ក្នុងបទដ៏សេស ក៏មានន័យដូចគ្នា ។ ឥឡូវនេះ កាលនឹងទ្រង់សម្តែង
ឧបមា ដែលសម្តែងដល់ខ្ចីមសារ ទើបទ្រង់ត្រាស់ថា **សេយ្យថាបិ** ដូច្នេះ
ជាដើម ។ បណ្តាបទទាំងនោះ បទថា **កិដ្ឋសម្ពាធេ** សេចក្តីថា ក្នុងទី
ចង្អៀតដោយសំណាប ។ បទថា **អាកោដ្តេយ្យ** មានន័យថា វាយត្រង់ខ្នង
គោ ។ បទថា **បដិកោដ្តេយ្យ** មានន័យថា វាយត្រង់ទទឹងឆ្អឹងជំនីរ ។
បទថា **សន្និរុន្ធេយ្យ** មានន័យថា ហាមឲ្យឈប់ហើយ ។ បទថា
**សន្និវារេយ្យ** មានន័យថា មិនគប្បីឲ្យទៅផ្លូវនោះ និងផ្លូវនេះ ។ បទថា
**តតោនិទានំ** សេចក្តីថា ដោយហេតុនោះ គឺ ដោយហេតុដែលគោទាំងឡាយ

មិនបានរក្សាយ៉ាងនេះ ស៊ីសន្ទូងរបស់អ្នកដទៃ ។ ក៏នាយគោបាលល្ងង់ កាលណាមិនរក្សាគោទាំងឡាយ យ៉ាងនេះ រមែងទទួលទុក្ខ មានការសម្លាប់ អំពីសម្នាក់នៃម្ចាស់គោ ទាំងឡាយថា អ្នកឃ្វាលគោនេះ ស៊ីបាយ និងថ្លៃឈ្នួលរបស់យើង មិនអាចរក្សាគោ ដោយត្រឡប់ឲ្យប្តូរវេនជាមួយត្រកូលទាំងឡាយខ្លះ ពីម្ចាស់សន្ទូងខ្លះ ។ តែនាយគោបាលដែលឆ្លាត កាលណាឃើញភ័យ ៤ យ៉ាងនេះ រមែងរក្សាគោទាំងឡាយឲ្យបានសុខ ។ បទនោះលោកពោលសំដៅដល់ហេតុនោះ ។ បទថា **អាទីនវំ** បានដល់ ឧបទ្ទវៈ ។ បទថា **ឱការំ** គឺ ភាពលាមក គឺ សេចក្តីថោកទាបក្នុងខន្ធទាំងឡាយ ។ បទថា **សង្កិលេសំ** បានដល់ ភាពជារបស់សៅហ្មង ។ បទថា **នេក្ខម្មេ** សេចក្តីថា ក្នុងនេក្ខម្មៈ ។ បទថា **អានិសំសំ** បានដល់ ដែលជាចំណែកនៃសេចក្តីបរិសុទ្ធិ ។

បទថា **វោទានបក្ខំ** នេះ ជាវេវចនៈរបស់អានិសង្សនេះ ។ អធិប្បាយថា ក៏យើងបានឃើញនេក្ខម្មៈ ជាចំណែកនៃសេចក្តីបរិសុទ្ធិ នៃកុសលធម៌ទាំងឡាយ ម្យ៉ាងទៀត ពាក្យថា នេក្ខម្មៈ គឺ និព្វាននោះឯង ។ កាលណាសង្គ្រោះកុសលទាំងអស់ ដែលរលាស់ចេញ ហើយអំពីកាមទាំងឡាយ ចុះក្នុងធម្មបទតែមួយ ។ ក្នុងបទនោះ មានការប្រៀបធៀបដូច្នេះ ។ ក៏អារម្មណ៍ មានរូបជាដើម ដូចទីចង្អៀតដោយសន្ទូង ចិត្តកាចដូចគោកាច ព្រះពោធិសត្វដូចនាយគោបាលដែលឆ្លាត វិតក្កដែលប្រព្រឹត្តទៅដើម្បីការបៀតបៀនខ្លួន អ្នកដទៃ និងទាំងពីរផ្នែក ប្រៀបដូចភ័យ ៤

ប្រភេទ កាលដែលព្រះពោធិសត្វ តាំងសេចក្តីព្យាយាមរហូត ៦ ឆ្នាំ ទ្រង់ឃើញភ័យនៃការបៀតបៀនខ្លួន ហើយរក្សាព្រះហឫទ័យក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ដោយប្រការដែលវិតក្កទាំងឡាយ មានកាមវិតក្កជាដើម មិនឲ្យកើតឡើង ប្រៀបដូចនាយគោបាលដែលឆ្លាត ឃើញភ័យ ៤ ប្រភេទហើយ រក្សាគោដោយសេចក្តីមិនប្រមាទ ក្នុងទីចង្អៀតដោយសន្ទូងដូច្នោះ ។ បទថា **បញ្ញានិរោធិកោ** ជាដើម ឈ្មោះថា បញ្ញានិរោធិកៈ ព្រោះប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបញ្ញា ទាំងជាលោកិយៈ និងលោកុត្តរៈដែលនៅមិនទាន់កើតឡើង និងដើម្បីការចម្រើនបញ្ញា ទាំងដែលជាលោកិយៈនិងលោកុត្តរៈ ដែលកើតឡើងហើយ ។ ឈ្មោះថា **អវិឃាតបក្ខិក** ព្រោះមិនប្រព្រឹត្តទៅដើម្បីចំណែកនៃសេចក្តីទុក្ខ ។ ឈ្មោះថា **និព្វានសំវត្តនិក** ព្រោះប្រព្រឹត្តទៅដើម្បីធ្វើឲ្យច្បាស់នូវនិព្វានធាតុ ។ បទថា **រត្តិញ្ចេបិ តំ ភិក្ខវេ អនុវិតក្កេយ្យំ** សេចក្តីថា សូម្បីបើយើង គប្បីញុំាងវិតក្កនោះឲ្យប្រព្រឹត្តទៅអស់មួយយប់ ។ បទថា **តតោនិទានំ** បានដល់ មានវិតក្កនោះជាមូល ។ បទថា **ឩហញ្ញេយ្យ** សេចក្តីថា គប្បីរវើរវាយ គឺប្រព្រឹត្តទៅដើម្បីសេចក្តីរវើរវាយ ។ បទថា **អារា** គឺ ក្នុងទីឆ្ងាយ ។ បទថា **សមាធិម្ហា** គឺ ចាកពីឧបចារសមាធិខ្លះ ពីអប្បនាសមាធិខ្លះ ។ បទថា **សោ ខោ អហំ ភិក្ខវេ អជ្ឈត្តមេវ ចិត្តំ** មានន័យថា ម្នាលភិក្ខុទាំងឡាយ តថាគតតម្កល់នូវចិត្តដែលប្រព្រឹត្តទៅក្នុងខាងក្នុងថា ចិត្តរបស់តថាគតកុំនៅក្នុងទីឆ្ងាយពីសមាធិនោះ គឺ តាំងចិត្តទុកក្នុងខាងក្នុងអារម្មណ៍ ។

បទថា **សន្និសាទេមិ** សេចក្តីថា យើងញ៉ាំងចិត្តនោះ ឲ្យស្ងប់នៅក្នុងអារម្មណ៍នោះឯង ។ បទថា **ឯកោទឹ ករោមិ** គឺ ធ្វើឲ្យមានអារម្មណ៍តែមួយ ។ បទថា **សមាទហាមិ** មានន័យថា តាំងមាំដោយប្រពៃ គឺ លើកឡើងដោយល្អ ។ បទថា **មា មេ ចិត្តំ ឧគ្ឃាដិ** មានន័យថា ចិត្តរបស់យើងកុំរាយមាយ គឺ កុំប្រព្រឹត្តទៅ ដើម្បីសេចក្តីរាយមាយ ។ ក្នុងបទថា **ឧប្បជ្ជតិ អព្យាបាទ-វិតក្កោ អវិហឹសាវិតក្កោ** នោះ វិតក្កដែលកើតឡើព្រមជាមួយតរុណ-វិបស្សនា ដែលបានពោលហើយក្នុងខាងក្រោយនោះណា លោកពោលថា ជានេក្ខម្មវិតក្ក ព្រោះអត្ថថា ជាសត្រូវដល់កាមវិតក្កនោះឯង លោកពោលថា ជាអព្យាបាទវិតក្ក ព្រោះអត្ថថា ជាសត្រូវចំពោះការប្រទូសរ៉ាយគុំគួន និងថា ជាអវិហិង្សាវិតក្ក ព្រោះអត្ថថា ជាសត្រូវដល់ការបៀតបៀន ។ លោកសម្តែងកាលនៃការតាំងវិបស្សនា អាស្រ័យសមាបត្តិរបស់ព្រះពោធិសត្វ ដោយប្រមាណប៉ុណ្ណេះ ។

ក៏ព្រះពោធិសត្វនោះ មានសមាធិខ្ចះ តរុណវិបស្សនាខ្ចះ កាលណា ព្រះពោធិសត្វតាំងវិបស្សនា ប្រថាប់អង្គុយយូរពេកទៅ ព្រះវរកាយរមែងលំបាក ដូចជា ភ្លើងដែលតាំងនៅក្នុងខាងក្នុង ព្រះសេទទាំងឡាយរមែងហូរចេញពីព្រះកច្ឆៈ ចំហាយក្តៅសាយកាយតាំងឡើង ចេញពីព្រះសីសៈព្រះហឫទ័យ រមែងក្តៅក្រហាយ សោប់សល់ មានចិត្តរាយមាយ ។ តែព្រះពោធិសត្វនោះ ទ្រង់ចូលសមាបត្តិហើយ បរិកម្មសមាបត្តិនោះ ធ្វើឲ្យទន់ ទ្រង់ស្រាលព្រះហឫទ័យ ទ្រង់តាំងវិបស្សនាទៀត ក៏កាលព្រះពោធិ-

សត្វនោះ ប្រឋាប់អន្តុយយូរពេក ព្រះវរកាយ ក៏ជាយ៉ាងនោះ ។ ក៏ព្រះពោធិសត្វនោះ កាលចូលសមាបត្តិហើយ ទ្រង់ធ្វើយ៉ាងនោះ ព្រោះសមាបត្តិមានឧបការៈច្រើនដល់វិបស្សនា ។ ប្រៀបដូច ធម្មតាខែលមានឧបការៈច្រើនដល់ទាហាន ទាហានអាស្រ័យខែលនោះ ចូលសង្គ្រាម កាលបើអាវុធទាំងឡាយ ដែលប្រើការច្បាំងរួមទាំងពួកដំរី ពួកសេះ និងក្រុមទាហាន ក្នុងសង្គ្រាមនោះអស់ទៅ គង់មានតែភាពជាអ្នកចង់នឹងបរិភោគជាដើមប៉ុណ្ណោះ ត្រឡប់ចូលទៅដល់បន្ទាយ សម្រាកហើយ ចាប់អាវុធទាំងឡាយខ្លះ សាកល្បងខ្លះ បរិភោគខ្លះ ផឹកទឹកខ្លះ ពាក់គ្រោះខ្លះ ធ្វើកិច្ចការនោះ ៗ ហើយចូលសង្គ្រាមទៀត ឬធ្វើការច្បាំងក្នុងសង្គ្រាមនោះ កើតឈឺឧច្ចារៈជាដើម ចូលទៅក្នុងបន្ទាយដោយកិច្ចដែលគួរធ្វើបែបខ្លះទៀត លុះបើធ្វើធុរៈស្រេចក្នុងបន្ទាយនោះហើយ ក៏ចូលសង្គ្រាមទៀត ។ សមាបត្តិមានឧបការៈច្រើនដល់វិបស្សនា ដូចបន្ទាយទាហាន មានឧបការៈច្រើនដល់ទាហានដូច្នោះ ។ មួយវិញទៀត វិបស្សនាមានឧបការៈច្រើនដល់សមាបត្តិ ច្រើនជាងបន្ទាយទាហានរបស់ទាហាន ដែលប្រាថ្នារំងាប់សង្គ្រាម ។ ពិតហើយ ព្រះពោធិសត្វ ទ្រង់អាស្រ័យសមាបត្តិ ចម្រើនវិបស្សនាក៏ពិត តែវិបស្សនាមានកម្លាំង រមែងរក្សានូវសមាបត្តិ ធ្វើសមាបត្តិឲ្យមានកម្លាំង ។ ក៏ជនទាំងឡាយ កាលធ្វើជំនួញតាមផ្លូវទឹក ពេលមកដល់ដីគោក ក៏ឬទំនិញឲ្យជាភារៈរបស់រទេះ នៅពេលដែលរទេះទៅដល់ផ្លូវទឹក ក៏ឬទំនិញឲ្យជាភារៈរបស់ទូក ។ ទូកកាត់ខ្សែទឹកចេញទៅដល់កំពង់ដោយសុវត្ថិភាព យ៉ាង

ណា វិបស្សនាអាស្រ័យសមាបត្តិ រមែងប្រព្រឹត្តទៅដោយពិត តែវិបស្សនាមានកម្លាំង រមែងរក្សានូវសមាបត្តិ រមែងធ្វើសមាបត្តិឲ្យមានកម្លាំងដូច្នេះដូចគ្នា ។ ក៏សមាបត្តិ ប្រៀបដូចរទេះដល់គោក វិបស្សនាប្រៀបដូចទូកដល់ទឹក ។ កាលព្រះពោធិសត្វ អាស្រ័យសមាបត្តិហើយ លោកក៏តាំងវិបស្សនា លោកសម្តែងហើយដោយប្រមាណប៉ុណ្ណេះ ដោយប្រការដូច្នេះ ។

បទថា **យញ្ចទេ** ជាដើម គប្បីជ្រាបតាមន័យដែលពោលហើយក្នុងចំណែកខាងអាក្រក់ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា **សេយ្យថាបិ** ជាដើម ដើម្បីទ្រង់សម្តែងឧបមាដែលសម្តែងខ្លឹមសារ សូម្បីក្នុងព្រះសូត្រនេះ ។ ក្នុងបទទាំងនោះ បទថា **គាមន្តសម្ភវេសុ** បានដល់ នាំមកជិតស្រុក ។ បទថា **សតិករណីយមេវ ហោតិ** សេចក្តីថា កិច្ចត្រឹមតែញាំងសតិឲ្យកើតឡើងថា គោទាំងឡាយមានប្រមាណប៉ុណ្ណេះ មិនគួរឲ្យទៅខាងណេះខាងណោះ ដោយមិនមានការវាយជាដើម ។ កិច្ចត្រឹមតែញាំងសតិឲ្យកើតឡើងថា ធម៌ទាំងឡាយនេះ គឺ សមថធម៌ និងវិបស្សនាធម៌នោះឯង ជាកិច្ចគប្បីធ្វើ ។ កាលនៃសមថៈ និងវិបស្សនារបស់ព្រះពោធិសត្វ មានកម្លាំង បានសម្តែងហើយ ដោយបទនេះ ។

បានឮថា ក្នុងកាលនោះ កាលព្រះពោធិសត្វប្រថាប់អង្គុយដើម្បីប្រយោជន៍ដល់សមាបត្តិ និងអប្បនាសមាបត្តិ ៨ ក៏មកកាន់ផ្លូវដោយការលើកតែម្យ៉ាង ។ ទ្រង់តាំងវិបស្សនា ប្រថាប់អង្គុយហើយ ទ្រង់ឡើងកាន់អនុបស្សនា ៧ ដោយខណៈជាមួយគ្នានោះឯង ។ ទ្រង់សម្តែងអ្វីដោយ

បទនេះថា **សេយ្យថាបិ** ។ អនុសន្ធិចំពោះយ៉ាងនេះ ។ ក៏ព្រះមានព្រះភាគ កាលទ្រង់សម្ដែងឧបចារៈ ដើម្បីប្រយោជន៍ដល់សត្វទាំងឡាយ និងសម្បទា គឺ សេចក្ដីដែលព្រះអង្គជាព្រះសាស្ដា ទើបទ្រង់ប្រារព្ធទេសនានេះ ។

បទថា **អរញ្ញេ** បានដល់ ដងព្រៃ ។ បទថា **បវនេ** បានដល់ ដងព្រៃ ។ ក៏បទពីរនេះ ដោយអត្ថ ក៏មានវេវចនៈដូចគ្នា ។ បទថា **អយោគក្ខេមកាមោ** សេចក្ដីថា អ្នកមិនប្រាថ្នាសេចក្ដីក្សេមចាកយោគៈ ៤ គឺ ស្ថានទីមិនមានភ័យនោះឯង ។ បទថា **សោវត្ថិកោ** បានដល់ ដែលនាំមកនូវសិរីសួស្ដី ។ បទថា **បីតិគ្គមនីយោ** គឺ គួរទៅកាន់សេចក្ដីត្រេកអរ ។ ប្រការមួយទៀត បាលីថា **បីតិគមនីយោ** ។ បទថា **បិទហេយ្យ** គឺ ពោលដោយវត្ថុទាំងឡាយ មានមែកឈើជាដើម ។ បទថា **វិវរេយ្យ** សេចក្ដីថា គប្បីធ្វើមាត់ផ្លូវឲ្យស្រួល ហើយបើកផ្លូវទុក ។ បទថា **កុម្មគ្គំ** គឺ មិនមែនផ្លូវដែលបិទការពារដោយទឹក ព្រៃ និងភ្នំជាដើម ។ បទថា **ឱទហេយ្យ ឱកចរំ** សេចក្ដីថា ចងខ្លាជំបងមួយ ក្នុងទីនៅនៃហ្វូងម្រឹគនោះក្នុងទីជាមួយគ្នា ។ បទថា **ឱកចារិកំ** សេចក្ដីថា មេម្រឹគដែលចងខ្សែវែងទុក ។ ពិតណាស់ នាយព្រានម្រឹគ ទៅកាន់ព្រៃ គឺ ស្ថានទីដែលជាទីនៅនៃម្រឹគទាំងឡាយ ធ្លាប់សង្កេតឃើញថា ហ្វូងម្រឹគនៅក្នុងទីនេះ ចេញផ្លូវនេះ ត្រាច់ទៅក្នុងទីនោះ ផឹកក្នុងទីនោះ ចូលទៅផ្លូវនេះ ដូច្នេះ ហើយបិទផ្លូវ បើកផ្លូវខុសទុក ចងម្រឹគឈ្មោល និងញី ទុកបញ្ឆោត

កាន់លំពែងឈរពួនក្នុងទីកំបាំង ។ លំដាប់នោះ ក្នុងពេលរសៀល ម្រឹគទាំងឡាយដែលដើរក្នុងព្រៃ ដែលមិនភ័យ ផឹកទឹកប្រឡែងលេងនឹងកូនម្រឹគទាំងឡាយ មកកាន់លំនៅ ដែលជាទីនៅ ឃើញម្រឹគឈ្មោល-ញីដែលចងបញ្ឆោត ក៏គិតថា សម្លាញ់របស់ពួកយើងបានមកហើយ ហើយមិនសង្ស័យ ក៏ចូលទៅ ។ ម្រឹគទាំងនោះ ឃើញផ្លូវដែលបិទ ក៏គិតថា នេះមិនមែនផ្លូវ នេះជាផ្លូវ ហើយក៏ដើរទៅខុសផ្លូវ ។ នាយព្រានម្រឹគនឹងមិនធ្វើខុសពីមុនទេ ។ តែកាលម្រឹគទាំងនោះ ចូលទៅហើយ ទើបសន្សឹម ៗ វាយម្រឹគមួយចុងក្រោយ ម្រឹគនោះក៏ភ្ញាក់ ពេលនោះ ម្រឹគទាំងអស់ក៏ភ្ញាក់ផ្អើល ក្រឡេកមើលខាងមុខថា ភ័យកើតឡើងហើយ ឃើញផ្លូវដែលបិទបាំងដោយទឹក ឬព្រៃ ឬភ្នំ ក៏មិនអាចដើម្បីនឹងចូលទៅកាន់ព្រៃដែលដុះដូចម្រាមដៃបាន ក៏វិលត្រឡប់ នឹងចេញតាមផ្លូវដែលបានចូលហើយ ។ តពីនោះ នាយព្រានដឹងថា ហ្វូងម្រឹងទាំងនេះ ត្រឡប់មកហើយ ទើបសម្លាប់ម្រឹគ ៣០ ក្បាលខ្លះ , ៤០ ក្បាលខ្លះ ។

បទនេះថា ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះឯង ដោយសម័យដទៃ ហ្វូងម្រឹគនោះ គប្បីដល់ការវិនាសដូច្នេះ ព្រះសាស្តាត្រាស់ក្នុងបទនេះថា នោះជាឈ្មោះនៃនន្ទិរាគៈ , ជាឈ្មោះនៃអវិជ្ជានោះឯង ព្រោះសត្វទាំងនេះ ជាសត្វមិនមានញាណ ព្រោះអវិជ្ជាព័ន្ធព័ន្ធ នន្ទិរាគៈនាំចូលកាន់រូបារម្មណ៍ជាដើម រមែងត្រូវសម្លាប់ ព្រោះលំពែង គឺ វដ្តទុក្ខ ព្រោះដូច្នោះ

ព្រះមានព្រះភាគ ទើបទ្រង់សម្តែងប្រៀបដល់ម្រឹគឈ្មោលបញ្ឆោត ដូចជា នន្ទិរាគៈ ប្រៀបម្រឹគញីបញ្ឆោត ដូចជាអវិជ្ជា ។ ពិតណាស់ សូម្បីក្នុងពេលមួយ នាយម្រឹគស្រោស់របងដោយមែកឈើដើម្បីមិនឲ្យម្រឹគទាំងនោះធុំក្លិនមនុស្ស ដាក់ម្រឹគឈ្មោលបញ្ឆោត ក្នុងកន្លែងមួយ ព្រលែងម្រឹគញីបញ្ឆោតព្រមទាំងខ្សែ ហើយលាក់ខ្លួនកាន់លំពែង ឈរនៅក្នុងទីជិតម្រឹគឈ្មោល ដែលទុកសម្រាប់បញ្ឆោត ។ ម្រឹគញីដែលទុកសម្រាប់បញ្ឆោតនោះ ក៏បែរមុខទៅកាន់ទីត្រាច់ទៅនៃពួកម្រឹគ ។ ម្រឹគទាំងឡាយ ឃើញម្រឹគញីដែលទុកសម្រាប់បញ្ឆោតនោះហើយ ក៏ឈរងើតក្បាល ។ ម្រឹគទាំងនោះក៏គិតថា មេម្រឹគនេះ ជាពួករបស់យើង ទើបស៊ីស្មៅ ។ ចំណែកម្រឹគញី ដែលទុកបញ្ឆោតនោះ ក៏ធ្វើដូចជាស៊ីស្មៅសន្សឹម ៗ ចូលទៅរក ។ ម្រឹគមេហ្វូងដែលនៅក្នុងព្រៃ បានធុំក្លិនម្រឹគញី ដែលទុកសម្រាប់បញ្ឆោតនោះ ក៏នឹងលះហ្វូងរបស់ខ្លួន សំដៅទៅរកមេម្រឹគដែលទុកសម្រាប់បញ្ឆោតនោះ ។ ពិតណាស់ របស់ថ្មី ៗ នោះឯង រមែងជាទីស្រឡាញ់របស់សត្វទាំងឡាយ មេម្រឹគទុកសម្រាប់បញ្ឆោត ដែលសំដៅមុខឆ្ពោះទៅរកម្រឹគព្រៃនោះ ក៏នឹងមិនឲ្យម្រឹគព្រៃចូលជិត ហើយបែរត្រឡប់ទៅកាន់លំនៅរបស់ម្រឹគឈ្មោល ដែលចងទុកសម្រាប់បញ្ឆោត និងធាយដីដោយក្រចកដែលមានខ្សែទាក់ទុក ហើយចៀសចេញទៅ ។ ម្រឹគព្រៃ ឃើញម្រឹគឈ្មោល ដែលចងទុកសម្រាប់បញ្ឆោតហើយ ព្រោះស្រវឹងរវង្វេងនឹងម្រឹគញីដែលទុកសម្រាប់បញ្ឆោតនោះ ក៏ធ្វើសេចក្តីប្រច័ណ្ឌក្នុងម្រឹគឈ្មោល ដែល

ចងទុកសម្រាប់បញ្ឆោត ចាំកោងខ្នង ឈរវេក្បាលទៅមក ។ ក្នុងខណៈនោះ សូម្បីលិទ្ធលំពែងដោយអណ្ដាត ក៏មិនដឹងថាជាអ្វី ។ ចំណែកម្រឹគឈ្មោល ដែលទុកសម្រាប់បញ្ឆោតនោះ អាចប្រហារម្រឹគព្រៃនោះបានដោយងាយ ក៏ចាំកោងខ្នង កាលបើម្រឹគព្រៃ មានបំណងដើម្បីជល់ ក៏ពើងទ្រូងឡើង ។ លំដាប់នោះ ព្រានក៏លើកលំពែងចាក់ម្រឹគព្រៃសម្លាប់ក្នុងទីនោះ ហើយកាន់យកជុំសាច់ទៅ ។ ដោយប្រការដូច្នោះ ម្រឹគនោះស្រវឹងវង្វេងនឹងមេម្រឹគដែលចងទុកសម្រាប់បញ្ឆោត សូម្បីលិទ្ធលំពែងក៏មិនដឹងថាអ្វី យ៉ាងណា សត្វទាំងនេះក៏ដូច្នោះ ជាអ្នកស្រវឹងវង្វេង ងងឹតងងល់ ព្រោះអវិជ្ជា ការមិនដឹងអ្វី អាស្រ័យសេចក្ដីត្រេកអរ ដោយសេចក្ដីភ្លើតភ្លើនក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម រមែងបានទូវការសម្លាប់ដោយលំពែង គឺ ទុក្ខក្នុងវដ្ដៈ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់សម្ដែងការប្រៀបធៀបសត្វដែលបញ្ឆោតនោះ ដូចជានន្ទិរាគៈ ទ្រង់ធ្វើម្រឹគញីដែលចងទុកសម្រាប់បញ្ឆោត ដូចជាអវិជ្ជា ។ បទថា **ឥតិ ខោ ភិក្ខវេ វិវដោ មយា ខេមោ មគ្គោ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ផ្លូវដែលប្រកបដោយអង្គ ៨ ដ៏ក្សេម គឺ ប្រសើរ ដែលតថាគតសម្រេចសម្មាសម្ពោធិញ្ញាណ ដោយការប្រព្រឹត្តដើម្បីប្រយោជន៍ ដល់សត្វទាំងនេះ មិនបានជាអ្នកអង្គុយស្ងៀម ដោយការគិតថា យើងជាព្រះពុទ្ធ សម្ដែងធម៌តាំងតែពីការញុំាងធម្មចក្ក ឲ្យប្រព្រឹត្តទៅ មគ្គអង្គ ៨ ដ៏ប្រសើរ ក្សេម តថាគតបើកហើយ ផ្លូវអាក្រក់ តថាគតបិទហើយ ម្រឹគឈ្មោល ដែលទុកសម្រាប់បញ្ឆោត គឺ នន្ទិរាគៈ

*ដែលកព្ចបុគ្គលទាំងឡាយ មានអញ្ញាកោណ្ឌញ្ញៈជាដើម បានបន្សាត់ហើយ , ម្រឹគញី ដែលទុកសម្រាប់បញ្ឆោត គឺ អវិជ្ជា ត្រូវកាត់ជាពីរចំណែកឲ្យវិនាសចាកអ្នកមានបាបទាំងអស់ ត្រូវដកអស់ហើយ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់សម្តែងឧបចារៈ ដែលឧបការៈដល់ព្រះអគ្គ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយទាំងអស់ ។*

(ចប់ អដ្ឋកថា ទ្វេធាវិតក្កសូត្រ ទី៩)

# អដ្ឋកថា

## វិតក្កសណ្ឋានសូត្រ ទី ១០

✵✵✵✵✵✵✵✵✵

*មានពាក្យផ្ដើមយ៉ាងនេះថា ខ្ញុំម្ចាស់បានស្ដាប់មកយ៉ាងនេះ ៖*

*គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ បទថា* ***អធិចិត្ត មនុយុត្តេន*** *មានន័យថា ចិត្តដែលកើតឡើងដោយកុសលកម្មបថ ១០ យ៉ាង ជាចិត្តប៉ុណ្ណោះ ។*

*ចិត្តក្នុងសមាបត្តិ ៨ មានវិបស្សនាជាបាទ ជាចិត្តក្រៃលែងជាងចិត្តនោះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ហៅចិត្តនោះថា* ***អធិចិត្ត*** *។*

*បទថា* ***អនុយុត្តេន*** *បានដល់ ព្យាយាមប្រកបដោយអធិចិត្តនោះ អធិប្បាយថា ប្រកបហើយ ខ្វល់ខ្វាយហើយ ក្នុងអធិចិត្ត ។ ក្នុងសេចក្ដីនោះ ភិក្ខុត្រាច់ទៅបិណ្ឌបាតក្នុងវេលាមុនភត្ត ត្រឡប់ពីបិណ្ឌបាតក្នុងពេលក្រោយភត្ត ហើយកាន់យកសំពត់និសីទនៈចេញទៅ ដោយគិតថា យើងនឹងធ្វើសមណធម៌ត្រង់គល់ឈើនោះ ឬត្រង់ព្រៃសណ្ឌ: ( ដងព្រៃ ) ឬត្រង់ជើងភ្នំ ឬត្រង់ញកភ្នំ ដូច្នោះ ហើយក៏យកស្មៅ ស្លឹកឈើ ចេញពីកន្លែងសម្រាប់ប្រកបអធិចិត្ត ។ លុះលោកលាងដៃ និងជើងហើយ ក៏មកអង្គុយពែនភ្នែន កាន់យកមូលនៃកម្មដ្ឋាន ប្រកបរឿយ ៗ នូវអធិចិត្តនោះឯង ។*

ពាក្យថា **និមិត្ត** បានដល់ ការណៈ ( គឺហេតុ ) ។

ពាក្យថា **តាមកាលដ៏សមគួរ** បានដល់ តាមសម័យដ៏សមគួរ ។

សួរថា ក៏ធម្មតាកម្មដ្ឋាននោះ ព្រះយោគីមិនបានបោះបង់ចោល សូម្បីមួយខ្មែត គឺ មនសិការជាប់តគ្នាទៅ មិនមែនឬ ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ពាក្យថា តាមកាលវេលាដ៏សមគួរ ដូច្នោះ ។

ឆ្លើយថា ក៏ព្រោះព្រះបាលីចែកកម្មដ្ឋានទុក ៣៨ ក្នុងកម្មដ្ឋានទាំងនោះ ភិក្ខុដែលអង្គុយបដិបត្តិកម្មដ្ឋាន តាំងពីឧបក្កិលេសណាមួយមិនទាន់បានកើតឡើង កិច្ចដែលនឹងត្រូវមនសិការដោយនិមិត្តដទៃ ៗ នៅមិនមានមុន តែកាលណាកិលេសកើតឡើង អ្នកក៏គប្បីកាន់យកនិមិត្តទាំងឡាយនាំកិលេសដែលកើតឡើងក្នុងចិត្តចេញទៅ ព្រះមានព្រះភាគទ្រង់ឃើញហេតុនោះ ទើបទ្រង់ត្រាស់យ៉ាងនេះ ។

ពោលដោយដែនខេត្ត និងអារម្មណ៍របស់អកុសលវិតក្កៈ គប្បីជ្រាបដែនខេត្ត និងអារម្មណ៍របស់វិតក្កៈទាំងនេះ គឺ ៖

វិតក្កៈ ដែលប្រកបដោយឆន្ទៈ

វិតក្កៈ ដែលសហគតដោយឆន្ទៈ

វិតក្កៈ ដែលសម្បយុត្តដោយរាគៈ

ក្នុង ៣ យ៉ាងនោះ ចិត្តដែលសហគតដោយលោភៈ ៨ ដួង ជាដែនខេត្តរបស់វិតក្កៈ ដែលប្រកបដោយឆន្ទៈ , ចិត្តដែលសហគតដោយទោសៈ ២ ដួង ជាដែនខេត្តរបស់វិតក្កៈ ដែលប្រកបដោយទោសៈ , អកុសលចិត្ត

១២ ដួង ជាដែនខេត្តរបស់វិតក្កៈ ដែលប្រកបដោយមោហៈ ប៉ុន្តែថា ចិត្ត ដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ជាដែនខេត្ត ចំពោះបុគ្គលអ្នក មានវិតក្កៈ ដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈប៉ុណ្ណោះ ។ សត្វទាំង ឡាយ និងសង្ខារទាំងឡាយ សូម្បីទាំងអស់ ក៏ជាអារម្មណ៍របស់វិតក្កៈ បានទាំងអស់ ព្រោះថា កាលណាភិក្ខុ មិនសម្លឹងមើលអារម្មណ៍ដែល ពេញចិត្ត និងមិនពេញចិត្តហើយ វិតក្កៈក្នុងសត្វ និងសង្ខារទាំងនោះ ក៏ មិនកើតឡើង ។

ពោលដោយមនសិការនិមិត្តដទៃ ៗ ពាក្យថា ភិក្ខុ

នោះគួរមនសិការនិមិត្តដទៃ ដែលប្រកបដោយកុសល

បានដល់ គួរមនសិការនិមិត្តដែលអាស្រ័យកុសលដទៃ ដោយ វៀរចាកអកុសលនិមិត្តនោះ ។ ក្នុងវគ្គនោះ ឈ្មោះថា និមិត្តដទៃ គឺ កាលណាវិតក្កៈប្រកបដោយឆន្ទៈ កើតឡើងក្នុងសត្វទាំងឡាយ ការចម្រើន អសុភៈ ( អសុភសញ្ញា ) ឈ្មោះថា និមិត្តដទៃ , កាលណា វិតក្កៈកើត ឡើងពេញចិត្តក្នុងសង្ខារទាំងឡាយ ( មានចីវរជាដើម ) មនសិការដល់ ភាពជារបស់មិនទៀង ( អនិច្ចសញ្ញា ) ឈ្មោះថា និមិត្តដទៃ ។ ក៏កាល វិតក្កៈប្រកបដោយទោសៈក្នុងសត្វទាំងឡាយ កើតឡើង ការចម្រើនមេត្តា ឈ្មោះថា និមិត្តដទៃ ៗ ។ កាលណាវិតក្កៈ ក្នុងសង្ខារទាំងឡាយកើតឡើង ការមនសិការដល់ធាតុ ឈ្មោះថា និមិត្តដទៃ ៗ , កាលណាវិតក្កៈប្រកប ដោយមោហៈ កើតឡើងក្នុងធម៌ណា ភិក្ខុអាស្រ័យធម៌ ៥ យ៉ាង ឈ្មោះថា

និមិត្តជទៃ ។

អធិប្បាយថា កាលណាលោកៈកើតឡើង ក្នុងសត្វទាំងឡាយ ដោយន័យ មានពាក្យថា ដៃ ឬជើងរបស់អ្នកនេះស្អាត ដូច្នេះជាដើម លោកនាំមកពិចារណាដោយអសុភៈ គឺ របស់ដែលមិនស្អាតថា លោកត្រេកអរស្រឡាញ់ក្នុងអ្វី ក្នុងសក់ទាំងឡាយឬ ឬថា ក្នុងរោមទាំងឡាយ ។ល។ ឬថា ក្នុងទឹកមូត្រ ធម្មតាថា អត្តភាពនេះ ការប្រកបឡើងដោយឆ្អឹង ៣០០ កំណាត់ លើកឡើងចងទុកដោយសរសៃ ៩០០ សរសៃ បូកលាបដោយសាច់ ៩០០ ដុំ ហ៊ុំខ្ចប់ដោយស្បែកស្រស់ ដែលសេចក្តីត្រេកអរពេញចិត្តក្នុងពណ៌សម្បុរបិទបាំងទុកហើយ ម្យ៉ាងទៀត របស់មិនស្អាតទាំងឡាយរមែងហូរចេញពីមុខដំបៅទាំង ៩ ( ទ្វារ ៩ ) និងពីរណ្តៅរោមប្រមាណ ៩៩.០០០ រណ្តៅ មានក្លិនស្អុយ ពេញទៅដោយសាកសព ជារបស់គួរខ្ពើម ជារបស់បដិកូល ដែលសន្សំទុកនូវរបស់បដិកូល ៣២ ប្រការ និងរករបស់ដែលជាខ្លឹមសារ ឬរបស់ដែលប្រសើរក្នុងកាយនេះមិនមាន កាលណាព្រះយោគីនាំសេចក្តីស្អាតចេញ ដោយអសុភៈយ៉ាងនេះ ដោយប្រការដូច្នេះហើយ រមែងលះលោភៈ ដែលកើតក្នុងសត្វទាំងឡាយបាន ព្រោះហេតុនោះ ការនាំភាពស្អាតចេញ បានដោយអសុភៈនេះ ទើបឈ្មោះថា និមិត្តជទៃ ។ កាលណាលោភៈកើតឡើង ក្នុងបរិក្ខារទាំងឡាយ មានបាត្រនិងចីវរជាដើម ក៏មនសិការដោយអំណាចនៃការពិចារណា ដល់ភាពជារបស់ដែលមិនមានម្ចាស់ និងជារបស់បណ្តោះអាសន្ន ដោយន័យដែលបានពោល

ទុកក្នុងសតិប្បដ្ឋានវណ្ណនាថា ភិក្ខុរមែងនៅព្រៃឈើ ក្នុងសង្ខារទាំងឡាយ មានបាត្រ និងចីវរជាដើម ដោយអាការ ២ យ៉ាង គឺ ដោយភាពជារបស់ដែលមិនមានម្ចាស់ដោយពិត និងជារបស់បណ្តោះអាសន្ន លោកក៏រមែងលះលោភៈនោះបាន ។ ព្រោះហេតុនោះ ការមនសិការដោយអាការ ២ យ៉ាង ក្នុងសង្ខារនោះ ទើបឈ្មោះថា និមិត្តដទៃ ។

កាលណាទោសៈកើតឡើងក្នុងសត្វទាំងឡាយ ព្រះយោគីគប្បីចម្រើនមេត្តា ដោយអំណាចនៃសូត្រទាំងឡាយ ដែលនាំអាឃាតចេញ មានកកចូបមសូត្រជាដើម កាលណាចម្រើនមេត្តា ក៏រមែងលះទោសៈនោះបាន ដោយហេតុនោះ ការចម្រើនមេត្តានោះ ទើបឈ្មោះថា និមិត្តដទៃ ។ កាលណាទោសៈកើតឡើង ព្រោះវត្ថុទាំងឡាយ មានការទង្គិចដង្គត់ឈើ បន្ទា ស្លឹកឈើដែលមុតស្រួចជាដើម លោកក៏គប្បីមនសិការដល់ធាតុ ដោយន័យជាដើមថា លោករមែងក្រោធនឹងអ្នកណា រមែងក្រោធនឹងបឋវីធាតុ ឬអាបោធាតុជាដើម កាលណាមនសិការធាតុយ៉ាងនេះ រមែងលះទោសៈបាន ព្រោះហេតុនោះ ការមនសិការដល់ធាតុ ទើបឈ្មោះថា និមិត្តដទៃ ។

កាលណាមោហៈកើតឡើងក្នុងធម៌ណា លោកកអាស្រ័យធម៌ ៥ ទាំង នេះ គឺ ៖

១- ការនៅរួមជាមួយគ្រូ

២- ការរៀនធម៌ ( ឧទ្ទេស )

៣- ការសាកសួរធម៌

៤- ការស្តាប់ធម៌តាមកាលដ៏គួរ

៥- ការវិនិច្ឆ័យធម៌ដែលជាឋានៈ និងអឋានៈ

ក៏រមែងលះនូវមោហៈបាន ព្រោះដូច្នោះ ភិក្ខុគួរអាស្រ័យធម៌ ទាំង ៥ នេះ ។ ព្រោះថា កាលលោកអាស្រ័យអាចារ្យ ដែលគួរដល់ការគោរព អាចារ្យរមែងដាក់ទណ្ឌកម្មដល់លោក មានការឲ្យដងទឹក ១០០ ឆ្នាំង ព្រោះមិនសួរដល់ការចូលទៅកាន់ស្រុក ឬមិនធ្វើវត្តក្នុងកាលដ៏គួរជាដើម ភិក្ខុនោះឈ្មោះថា ជាអ្នកដែលអាចារ្យព្យាយាមរៀបចំហើយ សូម្បីដូច្នេះ លោកក៏រមែងលះមោហៈក្នុងធម៌នោះបាន ។ សូម្បីកាលណារៀនធម៌ ( ឧទ្ទេស ) អាចារ្យរមែងដាក់ទណ្ឌកម្មដល់លោក លោកមិនរៀនក្នុងវេលាដ៏សមគួរ ឬស្វាធ្យាយមិនល្អ ឬមិនធ្វើការ ស្វាធ្យាយជាដើម លោករមែងជាអ្នកដែលអាចារ្យព្យាយាមរៀបចំហើយ សូម្បីដូច្នេះ លោករមែងលះមោហធម៌នោះបាន ។

ភិក្ខុចូលទៅរកភិក្ខុដែលគួរគោរពហើយ សាកសួរថា លោកម្ចាស់ចំណុចនេះយ៉ាងណា អត្ថរបស់ធម៌នេះយ៉ាងណា ជាដើម លោករមែងកម្ចាត់ការសង្ស័យបាន សូម្បីដោយអាការយ៉ាងនេះ លោកក៏រមែងលះមោហៈក្នុងធម៌នោះបាន ។ សូម្បីភិក្ខុ កាលណាទៅដល់កន្លែងដែលជាកន្លែងស្តាប់ធម៌តាមកាលវេលាដ៏សមគួរ ស្តាប់ដោយគោរពនូវអត្ថនៃធម៌ក្នុងទីនោះ ៗ រមែងភ្លឺច្បាស់ដល់លោក សូម្បីអាការយ៉ាងនេះ លោករមែង

លះមោហៈក្នុងធម៌នោះបាន ។

បុគ្គលដែលឆ្លាតក្នុងការវិនិច្ឆ័យក្នុងរបស់ដែលជាឋានៈ គឺ របស់ដែលប្រព្រឹត្តទៅបាន និងអឋានៈ គឺ របស់ដែលប្រព្រឹត្តទៅមិនបានថា នេះជាហេតុនៃរបស់នេះ នេះមិនមែនជាហេតុនៃរបស់នេះ ដូច្នេះជាដើម សូម្បីដោយអាការយ៉ាងនេះ លោកក៏រមែងលះមោហៈក្នុងធម៌នោះបាន ។ ព្រោះហេតុនោះ ការអាស្រ័យធម៌ ៥ យ៉ាងរបស់លោកនោះ ទើបឈ្មោះថា ជានិមិត្តដទៃ ។

ម្យ៉ាងទៀត កាលណាភិក្ខុចម្រើនកម្មដ្ឋានយ៉ាងណាមួយ ក្នុង ៣៨ លោករមែងលះអកុសលវិតក្កទាំងនោះបាន ព្រោះនិមិត្ត ៥ ដែលមានលក្ខណៈយ៉ាងនេះ ជាសត្រូវ និងបដិបក្ខដោយត្រង់ចំពោះកិលេសទាំងឡាយមានរាគៈជាដើម កិលេសដែលមានរាគៈជាដើម ដែលលះបានដោយនិមិត្ត ៥ ទាំងនេះហើយ រមែងជាការលះយ៉ាងល្អ ។ សេចក្តីថា បុគ្គលដែលលត់ភ្លើង ដូចជាប្រើឈើស្រស់វាយបោកខ្លះ លំអង ធូលីខ្លះ មែកឈើដទៃ ៗ ខ្លះ រមែងធ្វើភ្លើងឲ្យរលត់ ប៉ុន្តែទឹកជាសត្រូវដោយត្រង់របស់ភ្លើង កាលណាគេលត់ភ្លើងដោយទឹក ដែលជាសត្រូវដោយត្រង់ រមែងជាការរំលត់ដោយល្អហើយ យ៉ាងណា កិលេសទាំងឡាយមានរាគៈជាដើម ដែលលះបានដោយនិមិត្ត ៥ យ៉ាងនេះ ឈ្មោះថា ជាការលះដោយល្អ ដូច្នោះ ។ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបពាក្យទាំងនេះ តាមដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។

បទថា **កុសលូបសញ្ហិតំ** គឺថា អាស្រ័យកុសលជាបច្ច័យដល់កុសល ។

បទថា **អជ្ឈត្តមេវ** គឺថា ជាអារម្មណ៍ខាងក្នុងនោះឯង ។

បទថា **បលគណ្ឌោ** ប្រែថា មេជាងឈើ ។

បទថា **សុខុមាយ អាណិយា** សេចក្តីថា មេជាងឈើ ឬកូនជាងរបស់មេជាងដែលឆ្លាត ត្រូវការនាំយកកន្ទាស់ឈើណាចេញ ក៏ដំដោយកន្ទាស់ឈើដែលរឹងជាងកន្ទាស់ឈើនោះ ចូលទៅ ។

បទថា **ឱឡារិកំ អាណឹ** បានដល់ កន្ទាស់មិនស្មើគ្នាដែលមេជាងដំចូលទៅក្នុងផែនក្តារឈើច័ន្ទ ឬក្តាឈើសាច់រឹង ។

បទថា **អភិហនេយ្យ** គឺថា កាលណាដំដោយញញួរឈើហើយក៏យកចេញមក ។

បទថា **អភិនីហនេយ្យ** គឺថា កាលណារង្កៀកវាយ៉ាងនោះ ក៏គប្បីនាំយកកន្ទាស់ចេញពីសន្ទឹកក្តារបាន ។

បទថា **អភិនិវដ្ដេយ្យ** សេចក្តីថា ឥឡូវកាលមេជាងដឹងថា កន្ទាស់ឈើជាច្រើនទាំងនេះ សណ្តកចេញបាន ទើបយកដៃចាប់រង្កៀកទៅមកហើយទាញចេញ ។

បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងទីនេះថា ចិត្តដូចជាបន្ទះក្តារ ។ ឯអកុសលវិតក្ក ប្រៀបដូចកន្ទាស់ដែលធ្វើឲ្យបន្ទះក្តារមិនស្មើគ្នា ។ កុសល-និមិត្ត មានការចម្រើនអសុភៈ គឺ សេចក្តីមិនស្អាតជាដើម ប្រៀបដូច

កន្ទាស់តូច ៗ ការនាំអកុសលវិតក្កទាំងនោះចេញ ដោយកុសលនិមិត្ត ទាំងឡាយ មានការចម្រើនអសុភជាដើម ប្រៀបដូចការដំរង្កៀកដកកន្ទាស់ធំចេញបានដោយកន្ទាស់ដ៏តូចដែលរឹងជាង ដូច្នោះ ។

បទថា **អហិកុណបេន** ជាដើម ប្រែថា ខ្មោចពស់ជាដើមនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកដើម្បីសម្តែងដល់សាកសពទាំងឡាយថា សុទ្ធតែជារបស់បដិកូលគួរខ្ពើមក្រៃលែង ។ បទថា **កណ្ឋេ អាសត្តេន** គឺថា នាំយកសាកសពកន្លែងណាមួយ ដែលរកប្រយោជន៍មិនបាន មកចង គឺមកពាក់ជាក់ទុកនឹងក ។ បទថា **អដ្ដិយេយ្យ** បានដល់ សេចក្តីខ្មាស់ ៗ បទថា **ជិគុច្ឆេយ្យ** គឺថា គប្បីស្អប់ខ្ពើមកើតឡើងឯង ។ បទថា **បហីយន្តិ** សេចក្តីថា កាលណាអ្នកស្អប់ខ្ពើមដោយហេតុនេះហើយ ពិចារណាដោយកម្លាំងបញ្ញារបស់ខ្លួនថា អកុសលធម៌ទាំងនេះមានទោស មានទុក្ខជាវិបាក ក៏នឹងលះទៅបាន ប្រៀបដូចស្ត្រីក្រមុំ ឬប្រុសកម្លោះ ស្អប់ខ្ពើមសាកសពពស់ជាដើម ដូច្នោះ ។ ក៏កាលណា ភិក្ខុណាមិន អាចដើម្បីនឹងពិចារណាដោយកម្លាំងបញ្ញារបស់ខ្លួនបាន លោកគប្បីចូលទៅរកអាចារ្យ ឬឧបជ្ឈាយ៍ ឬមិត្តព្រហ្មចារីដែលគួរដល់ការគោរព ឬព្រះសង្ឃថេរៈអង្គណាមួយ ហើយវាយគោរំងឲ្យភិក្ខុមកប្រជុំគ្នា ប្រាប់ឲ្យដឹងដោយហេតុនោះ ព្រោះថា មនុស្សដែលជាបណ្ឌិតម្នាក់នឹងមានក្នុងទីប្រជុំនោះ ក៏បណ្ឌិតនេះ នឹងប្រាប់ថា លោកគប្បីឃើញទោសក្នុងអកុសលវិតក្កយ៉ាងនេះ ៗ ឬថា នឹងគ្របសង្កត់អកុសលវិតក្កទាំងនោះ ដោយកថាទាំងឡាយ មានកាយវិច្ឆិន្ទនិយកថា

ជាដើម ។ បទថា **អសតិមនសិការំ អាបជ្ជិតព្វោ** បានដល់ ភិក្ខុនោះមិនគប្បីនឹក មិនគប្បីយកចិត្តទុកដាក់ដល់អកុសលវិតក្កទាំងនោះ គប្បីជាអ្នកបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃៗ ដូចបុគ្គល ដែលមិនប្រាថ្នានឹងឃើញរូប គប្បីបិទភ្នែកទាំងពីរ យ៉ាងណា ភិក្ខុអ្នកកាន់មូលកម្មដ្ឋាន មកអង្គុយហើយ កាលណាវិតក្កកើតឡើងក្នុងចិត្ត ក៏គប្បីជាអ្នកបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃ ដូច្នោះ ។ ភិក្ខុនោះ រមែងលះអកុសលវិតក្កបាន ដោយអាការយ៉ាងនេះ កាលណាលោកប្រាថ្នានឹងលះ ក៏គប្បីកាន់យកកម្មដ្ឋានមក ហើយអង្គុយចុះទៅ ។ ក៏បើលោកលះមិនទាន់បាន ក៏គួរស្វាធ្យាយព្រះបាលីធម្មកថាដែលរៀនមកដោយសំឡេងដ៏ខ្លាំង ។ បើលោកយកចិត្តទុកដាក់ទៅក្នុងអារម្មណ៍ដទៃយ៉ាងនេះ លះមិនទាន់បាន ក៏ចូរយកសៀវភៅទទេចេញពីថង់យាម សរសេរពណ៌នាសេចក្តីល្អរបស់ព្រះពុទ្ធជាម្ចាស់ ចំនុចណាមួយលោកគប្បីជាអ្នកនាំអកុសលវិតក្កនោះចេញបាន ដោយការធ្វើចិត្តទៅក្នុងអារម្មណ៍ដទៃ យ៉ាងនេះ ។

សូម្បីធ្វើអាការយ៉ាងនោះហើយ ក៏នៅតែលះអកុសលវិតក្កនោះមិនបាន ក៏គប្បីយកឈើពួតចេញពីថង់យាម ហើយពិចារណា ឬដាក់ចិត្តទៅក្នុងអារម្មណ៍ដទៃថា នោះឈើពួតខាងលើ នេះឈើពួតក្អើងខាងក្រោម ដូច្នេះ ។ បើយ៉ាងនេះហើយ ក៏នៅតែលះអកុសលវិតក្កមិនបាន ក៏គប្បីយកកំប៉ុងតូចចេញមក រួមទាំងបរិក្ខារ ឬដាក់ចិត្តទៅក្នុងអារម្មណ៍ដទៃថា នេះឈ្មោះថា បំពង់ម្ជុល នេះកាំបិតតូច នេះឈ្មោះថា គ្រឿងកាត់ក្រចក

នេះឈ្មោះថា មូលជាដើម លោកក៏គប្បីនឹងលះអកុសលវិតក្កនោះបាន ។ បើយ៉ាងនេះហើយ ក៏នៅតែលះអកុសលវិតក្កនោះមិនបាន គប្បីយកមូលមកដេរចីវរដែលរហែក ដើម្បីដាក់ចិត្តទៅក្នុងអារម្មណ៍ដទៃ ដរាបណាដែលលោកលះអកុសលវិតក្កមិនបាន ក៏គប្បីដាក់ចិត្តទៅក្នុងអារម្មណ៍ដទៃ ដោយការធ្វើកុសលកម្មនោះ ៗ ក៏កាលណា លោកលះអកុសលវិតក្កបានហើយ ក៏គប្បីកាន់យកមូលកម្មដ្ឋានមកអង្គុយចុះ មិនគប្បីជាអ្នកផ្តើមនវកម្ម ( ការងារ ) ។

-សួរថា ព្រោះហេតុអ្វី

-ឆ្លើយថា ព្រោះថា លោកកម្ចាត់អកុសលមិនបាន ក៏មិនមានឱកាសមនសិការបាន ។ សូម្បីបណ្ឌិតក្នុងកាលមុននឹងធ្វើនវកម្ម ក៏ត្រូវកម្ចាត់អកុសលចិត្តសិន ។ ក្នុងសេចក្តីនោះ មានរឿងជាឧទាហរណ៍ដូចតទៅនេះ ។

## រឿង តិស្សសាមណេរ

បានឮថា ព្រះឧបជ្ឈាយ៍របស់សាមណេរ អាស្រ័យនៅក្នុងមហាវិហារ ព្រះតិស្សសាមណេរពោលជាមួយឧបជ្ឈាយ៍ថា លោកម្ចាស់ ខ្ញុំម្ចាស់ក្រវល់ក្រវាយ ( ចង់លាសិក្ខាបទ ) ។ ពេលនោះ ព្រះថេរៈបានពោលនឹងសាមណេរថា ក្នុងវិហារនេះ រកទឹកងូតបានដោយលំបាក អ្នកចូរនាំយើងទៅកាន់ចិត្តលតាបព៌ត សាមណេរ ក៏បានធ្វើតាមយ៉ាងនោះ ។ ព្រះថេរៈ

ពោលនឹងសាមណេរក្នុងទីនោះថា វិហារនេះជារបស់សង្ឃ អ្នកចូរធ្វើ (សាងកន្លែងនៅថ្មី) ឲ្យជាទីអាស្រ័យនៅចំពោះបុគ្គលម្នាក់ ។ សាមណេរទទួលថា ករុណាលោកម្ចាស់ ហើយសាមណេរក៏ផ្តើមរបស់ទាំងបីព្រម ៗ គ្នា គឺ ការរៀនគម្ពីរសំយុត្តនិកាយ តាំងពីដើម ការជម្រះផ្ទៃដីនៅញកភ្នំ និងការបរិកម្មតេជោកសិណ បានធ្វើកម្មដ្ឋាននោះឲ្យដល់អប្បនា ញុំាងការរៀនសំយុត្តនិកាយឲ្យចប់អស់ ហើយផ្តើមនវកម្មក្នុងល្អាង លោកបានធ្វើនវកម្មទាំងពួងសម្រេចហើយ ទើបបានជម្រាបប្រាប់ព្រះឧបជ្ឈាយ៍ឲ្យជ្រាប ។ ព្រះឧបជ្ឈាយ៍ពោលថា សាមណេរ កន្លែងនៅរបស់បុគ្គលម្នាក់ អ្នកធ្វើសម្រេចក្នុងថ្ងៃនេះ បានដោយលំបាក អ្នកចូរនៅ ដូច្នេះ ។

សាមណេរ កាលណានៅក្នុងល្អាងអស់មួយរាត្រី បាននូវឧតុជាទីសប្បាយ ទើបញុំាងវិបស្សនាឲ្យចម្រើន ហើយក៏សម្រេចព្រះអរហន្ត បរិនិព្វានក្នុងល្អាងនោះ ។ ជនទាំងឡាយ កាន់យកធាតុរបស់សាមណេរកសាងព្រះចេតិយទុក ។ ចេតិយរបស់ព្រះតិស្សត្ថេរ បានប្រាកដមកដល់សព្វថ្ងៃនេះឯង ។

បព្វ ( សេចក្តីដែលគួរកំណត់ ) នេះ ឈ្មោះថា **អសតិបព្វ** ( ប្រែថា សេចក្តីកំណត់ដោយការរលឹកមិនបាន ) ។

ពោលដោយការកម្ចាត់ឫសគល់ បំផ្លាញមូលរាគៈ ព្រះមានព្រះ-ភាគជាម្ចាស់ កាលណាសម្តែងការបំផ្លាញឫសគល់របស់អកុសលវិតក្កថា កាលណាភិក្ខុតាំងនៅក្នុងចំណុចនេះ ( គឺ អសតិបព្វ ) ហើយ នៅមិនអាច

សង្កត់អកុសលវិតក្កបាន ក៏ត្រូវតាំងនៅក្នុងការដែលបំផ្លាញឫសគល់របស់អកុសលវិតក្ក ដូច្នេះ ហើយទ្រង់ត្រាស់ពាក្យថា **តស្ស ចេ ភិក្ខវេ** ជាដើម ប្រែថា ម្នាលភិក្ខុទាំងឡាយ បើកាលណាភិក្ខុនោះ ដល់សេចក្តីមិនដឹង មិនយកចិត្តទុកដាក់ចំពោះវិតក្កទាំងនោះ ។

ក្នុងសេចក្តីនោះ គប្បីជ្រាបវិគ្រោះពាក្យថា **សង្ខារ** ក្នុងពាក្យនោះ គប្បីមនសិការសង្ខាររបស់ខ្លួននោះថា សភាវៈណារមែងតាក់តែង ហេតុនោះ សភាវៈនោះទើបឈ្មោះថា សង្ខារ ។ អធិប្បាយថា ជាបច្ច័យ ( គឺជាហេតុ ជាគ្រឿងអាស្រ័យ ) , ជាការណៈ ( គឺជាហេតុធ្វើ ) , ជាមូល ( គឺជាឫសគល់ ) ។

ឈ្មោះថា **សណ្ឋាន** ព្រោះអត្ថវិគ្រោះថា ជាទីតាំងនៅល្អ ។ សណ្ឋានរបស់វិតក្កសង្ខារ ឈ្មោះថា វិតក្កសង្ខារសណ្ឋាន ។ ភិក្ខុគប្បីមនសិការសណ្ឋាននោះ ។ ពាក្យនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អធិប្បាយទុកថា ភិក្ខុគប្បីមនសិការដល់ហេតុ និងមិនមែនហេតុ នៃវិតក្កទាំងឡាយថា វិតក្កនេះមានអ្វីជាហេតុ មានអ្វីជាបច្ច័យ ព្រោះហេតុអ្វីទើបកើតឡើង ដូច្នេះ ។

បទថា **កឹ នុ ខោ អហំ សីឃំ គច្ឆាមិ** មានន័យថា បុរសដែលដើរលឿននោះ រមែងគិតថា ប្រយោជន៍អ្វីដោយការដើរលឿន របស់យើងនេះ យើងនឹងទៅយឺត ៗ ដូច្នេះ ។

បទថា **សោ សនិកំ គច្ឆេយ្យ** គឺថា កាលបើគេគិតយ៉ាងនេះហើយ ទើបដើរយឺត ៗ ។ ក្នុងពាក្យទាំងពួងក៏មានន័យដូចគ្នា ។ បណ្ឌិត

គប្បីជ្រាបសេចក្តីក្នុងចំណុចនេះថា វេលាកើតឡើងនៃវិតក្ករបស់ភិក្ខុនេះ ប្រៀបដូចការដើរលឿនរបស់បុរស វេលាកំណត់ដឹងការត្រាច់ទៅនៃវិតក្ក របស់ភិក្ខុនេះ ប្រៀបដូចការដើរយឺត ៗ ទៅក្នុងទីនោះ ។ កាលដែលភិក្ខុនេះ កំណត់ដឹងក្នុងការត្រាច់ទៅរបស់វិតក្កបានហើយ នាំវិតក្កមកកាន់មូលរបស់កម្មដ្ឋាន ប្រៀបដូចការត្រិះរិះរបស់បុរសនោះ ។ កាលដែលភិក្ខុនេះ ញ៉ាំងវិបស្សនាឲ្យចម្រើន ហើយសម្រេចព្រះអរហត្ត ប្រៀបដូចកាលដែលបុរសនោះអង្គុយចុះហើយ ។ កាលដែលភិក្ខុនេះ ឲ្យពេលកន្លងទៅរហូតមួយថ្ងៃដោយផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ប្រៀបដូចកាលដែលបុរសនោះដេកហើយ ។

ក្នុងសេចក្តីថា វិតក្កទាំងនេះ មានអ្វីជាហេតុ មានអ្វីជាបច្ច័យ មានន័យថា ការត្រាច់ទៅរបស់វិតក្ក រមែងជារបស់ស្រាលស្តើងហើយដល់អ្នកដឹងហេតុ និងមិនមែនហេតុរបស់វិតក្កទាំងឡាយ កាលណាវិតក្កជារបស់ស្រាលស្តើងដល់ទីបំផុតហើយ ក៏រមែងរលត់ទៅ ដោយប្រការទាំងពួង ។ បណ្ឌិតគប្បីសម្តែងអត្ថបទនេះ ដោយទុទ្ទុកជាតក គឺ ៖

## រឿង ទន្សាយផ្អើលផ្លែព្នៅ

បានឮថា ទន្សាយមួយដេកលក់នៅកន្លែងជិតដើមព្នៅ ផ្លែព្នៅទុំជ្រុះចាកទង ធ្លាក់ចុះមកជិតត្រចៀករបស់ទន្សាយ ។ ទន្សាយនោះក៏ភ្ញាក់ឡើងរត់ទៅយ៉ាងលឿន ដោយនឹកគិតថា ផែនដីស្រុត ព្រោះស្នូរខ្លាំងរបស់

ផ្លែព្នៅនោះ ។ សត្វចតុបាទទាំងឡាយដ៏ទៃ ៗ ខាងមុខ ឃើញទន្សាយរត់មកយ៉ាងលឿន ក៏នាំគ្នារត់ទៅដែរ ។ គ្រានោះ ព្រះពោធិសត្វរបស់យើងកើតជារាជសីហ៍ រាជសីហ៍នោះគិតថា ធម្មតាថា ៖ ផែនដីនេះនឹងស្រុតវិនាសទៅ ក៏ព្រោះកប្បវិនាស ឈ្មោះថា កាល ដែលផែនដីនេះនឹងបែកធ្លាយទៅក្នុងចន្លោះកប្ប មិនមាន យើងនឹងត្រូវទៅស៊ើបមើលហេតុឲ្យបានដឹង ដូច្នេះ ។ រាជសីហ៍ ទើបផ្តើមសួរសត្វទាំងឡាយ តាំងពីដំរីធំរហូតទៅដល់ទន្សាយនោះថា ឯងឃើញផែនដីស្រុតឬ ទន្សាយពោលថា បពិត្រលោកជាធំ ខ្ញុំម្ចាស់ឃើញ រាជសីហ៍ ទើបពោលថា ឯងចូរនាំយើងទៅមើល ។ ទន្សាយពោលថា ខ្ញុំម្ចាស់មិនអាច ។ រាជសីហ៍ ទើបពោលថា នែ៎ទន្សាយ ចូរនាំយើងទៅ ឯងកុំខ្លាច ហើយក៏លួងចិត្តទន្សាយដោយពោលពាក្យសុភាពពកសារ ហើយក៏នាំទន្សាយទៅ ។ ទន្សាយឈរក្នុងទីមិនឆ្ងាយពីដើមព្នៅ ហើយបានពោលជាគាថា ថា ៖

បពិត្រលោកដ៏ចម្រើន ខ្ញុំម្ចាស់នៅក្នុងទីនោះបានឮសម្លេង
ស្រុតខ្ញុំម្ចាស់មិនស្គាល់សម្លេងនោះថាជាសម្លេងអ្វី ។ ព្រះ
ពោធិសត្វពោលនឹងទន្សាយថា ឯងចូរឈរក្នុងទីនេះហើយ

ហើយក៏ទៅកាន់គល់ដើមព្នៅ បានឃើញកន្លែងដែលជាទីដេករបស់ទន្សាយ និងបានឃើញផ្លែព្នៅទុំ ទើបក្រឡេកមើលខាងលើ បានឃើញទងរបស់ផ្លែព្នៅ លុះឃើញហើយក៏ដឹងថា ទន្សាយនេះកំពុងដេកលក់ក្នុងទីនេះ កាលណាផ្លែព្នៅទុំនេះធ្លាក់ចុះមកជិតត្រចៀក ទើបមានការសម្គាល់ថា

សម្រេចផែនដីស្រួត ទើបប្រញាប់រត់ទៅយ៉ាងលឿន ដូច្នេះ ហើយទើបសួរដល់ហេតុនោះ ។ ទន្សាយទទួលពាក្យថា ត្រូវហើយលោកម្ចាស់ ។ ព្រះពោធិសត្វ ទើបពោលពាក្យជាគាថា ថា ៖

**វេលុវំ បតិតំ សុត្វា ទុទ្ទុភន្តិ សសោ ជវិ**

**សសស្ស វចនំ សុត្វា សន្តត្តា មិគវាហនី**

ប្រែថា ទន្សាយស្ដាប់សម្រេងផ្លែព្នៅធ្លាក់ចុះ សម្គាល់ថាសម្រេងផែនដីស្រួត ទើបរត់ទៅយ៉ាងលឿន ពួកម្រឹគទាំងឡាយដូចកងទ័ព ជាអ្នកប្រញាប់ហើយ ព្រោះស្ដាប់ពាក្យរបស់ទន្សាយ ។

លំដាប់នោះ ព្រះពោធិសត្វ ទើបលួងលោមពួកម្រឹគទាំងឡាយថា ពួកអ្នកកុំភ័យឡើយ ដូច្នេះ ។ កាលភិក្ខុរករកដើមហេតុរបស់អកុសល-វិតក្កៈទាំងឡាយ ដោយអាការយ៉ាងនេះ ក៏រមែងលះបាន ព្រះមានព្រះភាគកាលទឹងសម្ដែងការណៈ ( ហេតុ ) យ៉ាងនេះថា ភិក្ខុដែលស្ថិតនៅក្នុងចំណុចបំផ្លាញមូលហេតុរបស់អកុសលវិតក្កនេះហើយ ក៏មិនអាចដើម្បីគ្រប សង្កត់វិតក្កនោះបាន ក៏គប្បីគ្របសង្កត់យ៉ាងនេះ ហើយទ្រង់ត្រាស់ពាក្យថា **តស្ស ចេ ភិក្ខវេ** ជាដើម ប្រែថា ម្នាលភិក្ខុទាំងឡាយ បើកាលណា ភិក្ខុនោះ មនសិការដល់សណ្ឋានរបស់វិតក្កដូច្នេះ ជាដើម ។

បទថា **ទន្តេភិ ទន្តមាធាយ** បានដល់ គប្បីសង្កត់ធ្មេញលើ ធ្មេញខាងក្រោម ។

បទថា **ចេតសា ចិត្តំ** បានដល់ គប្បីសង្កត់អកុសលចិត្ត ដោយ

កុសលចិត្ត ។

បទថា **ពលវា បុរិសោ** ជាដើម មានន័យថា ប្រៀបដូចបុរស អ្នកសម្បូរណ៍ដោយកម្លាំង មានកម្លាំងច្រើន ចាប់បុរសម្នាក់មានកម្លាំងតិច ជាង ហើយច្របាច់សង្កត់ឈ្ងួចក្បាល ឬគល់កទុកឲ្យណែន គប្បីធ្វើ បុរសនោះ ឲ្យក្តៅរោលរាល ឲ្យលំបាក ឲ្យក្រាប មានសេចក្តីស្លាប់ជា ទីបំផុត យ៉ាងណា ភិក្ខុក៏យ៉ាងដូច្នោះ ។ គប្បីជាអ្នកប្រជាល់ប្រោក ដែល ជាគូតស៊ូជាមួយអកុសលវិតក្កទាំងឡាយថា ឯងជាអ្វី យើងជាអ្វី ដូច្នេះ កាលបើគ្របសង្កត់ហើយ គប្បីផ្គងសេចក្តីព្យាយាមធំ យ៉ាងនេះថា ៖

**កាមំ តចោ នហារូ ច អដ្ឋិ ច អវសុស្សតុ**
**អវសិស្សតុ មេ សរីរេ សព្វំ មំសលោហិតំ**

ប្រែថា សាច់ និងឈាមទាំងអស់ ក្នុងរាងកាយរបស់យើងនេះនឹង ហួតហែងទៅ សល់តែស្បែក សរសៃ ឆ្អឹងក៏ដោយចុះ អ្នកគប្បីគ្របសង្កត់ អកុសលវិតក្កទាំងឡាយឲ្យបាន ។ កាលនឹងសម្តែងយ៉ាងនេះ ទើបទ្រង់ ត្រាស់ពាក្យឧបមាដែលសម្តែងអត្ថនេះថា **យតោ ច ខោ ភិក្ខវេ** ជាដើម ប្រែថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនិមិត្តណាហើយ មនសិការ និមិត្តណា ជាដើម ។ សេចក្តីនេះ ឈ្មោះថា **មរិយាទភាជនីយ** ( គឺ ពាក្យ បែកដែនខេត្ត ) ។ ពាក្យនេះ មានខ្លឹមសាររាក់ទាំងអស់ ។ គប្បីជ្រាប ឧបមាតទៅនេះ ។

ដូចយ៉ាងថា អាចារ្យ ដែលឲ្យពាក្យណែនាំប្រៀនប្រដៅព្រះរាជកុមារ

ដែលមកអំពីដែនខាងក្រៅ ឲ្យរៀនយកនូវសិល្បៈស្តីពីអាវុធប្រាំ ហើយសម្តែងរបស់ដែលគួរធ្វើ ដោយអាវុធទាំងប្រាំយ៉ាងនេះថា ព្រះអង្គចូលត្រឡប់ទៅគ្រងរាជសម្បត្តិក្នុងដែនរបស់ខ្លួន បើពួកចោរប្រាកដក្នុងរវាងផ្លូវដល់ព្រះអង្គ ព្រះអង្គត្រូវប្រើធ្នូរនេះទៅ បើធ្នូរបស់ព្រះអង្គបាក់ ឬបាក់ត្រូវប្រើលំពែង លំពែងបាក់ ត្រូវប្រើដាវ យ៉ាងនេះជាដើម ហើយឲ្យត្រឡប់ទៅ ព្រះរាជកុមារនោះ បានធ្វើដូច្នោះ កាលបើទៅដល់ដែនរបស់ខ្លួនហើយ បានគ្រងរាជសម្បត្តិ យ៉ាងណា សេចក្តីនេះក៏ដូច្នោះ ព្រះមាន-ព្រះភាគជាម្ចាស់ កាលទ្រង់បញ្ចូនភិក្ខុ ដែលព្យាយាមប្រកបដោយអធិចិត្ត ដើម្បីកាន់យកព្រះអរហត្ត ទ្រង់នឹងសម្តែងបទៈ ( ចំណុចដែលគួរកំណត់ ) ប្រាំទាំងនេះថា ៖

ប្រសិនបើអកុសលចិត្តកើតឡើងដល់អ្នកក្នុងរវាង ក៏គួរតាំងនៅក្នុងចំណុចស្តីពីនិមិត្តដទៃ ( ហៅថា អញ្ញនិមិត្តបទៈ ) កាលបើអ្នកគ្របសង្កត់វិតក្កទាំងឡាយបានហើយ ក៏នឹងញុំាងវិបស្សនាឲ្យចម្រើន ហើយនឹងសម្រេចព្រះអរហត្ត កាលណាមិនអាចក្នុងសេចក្តីនោះ ( គឺ ក្នុងអញ្ញ-និមិត្តបទៈ ) ក៏នឹងតាំងនៅក្នុងប្រការស្តីពីអាទីនវៈ បើមិនអាចក្នុងសេចក្តីនេះ ក៏នឹងតាំងនៅក្នុងប្រការស្តីអំពីអសតិបទៈ កាលណា មិនអាចក្នុងសេចក្តីនេះ ក៏គួរតាំងនៅក្នុងប្រការស្តីអំពីការបំផ្លាញមូលហេតុរបស់អកុ-សលវិតក្ក កាលណាមិនអាចក្នុងសេចក្តីនេះ ក៏នឹងតាំងនៅក្នុងប្រការស្តីអំពីការគ្របសង្កត់ បើគ្របសង្កត់វិតក្កទាំងឡាយនោះ បាននឹងញុំាងវិបស្សនា

ឲ្យចម្រើន ទឹងសម្រេចព្រះអរហត្ត ដូច្នេះ ។

បទថា **វសី វិតក្កបរិយាយបថេសុ** ប្រែថា អ្នកជំនាញក្នុងផ្លូវដើររបស់វិតក្ក បានដល់ អ្នកជំនាញតាមដែលខ្លួនបានសន្សំទុកហើយ គឺជាអ្នកជំនាញ រហ័សរហួនក្នុងផ្លូវប្រព្រឹត្តទៅនៃការត្រិះរិះ ។

បទថា **យំ វិតក្កំ អាកង្ខិស្សតិ** ប្រែថា អ្នកទឹងបំណងវិតក្កណា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ដើម្បីសម្ដែងដល់លក្ខណៈនៃភាពជាអ្នកជំនាញ ។ ព្រោះថា បុគ្គលនេះពីដើមទឹងចង់ត្រិះរិះនូវវិតក្កណា រមែងត្រិះរិះនូវវិតក្កនោះមិនបាន មិនប្រាថ្នាទឹងត្រិះរិះនូវវិតក្កណា រមែងត្រិះរិះនូវវិតក្កនោះ តែឥឡូវនេះ ព្រោះភាពជាអ្នកជំនាញ លោកជាអ្នកប្រាថ្នាដើម្បីទឹងត្រិះរិះដល់វិតក្កណា រមែងត្រិះរិះដល់វិតក្កនោះបាន មិនត្រូវការត្រិះរិះនូវវិតក្កណា ក៏មិនត្រូវត្រិះរិះនូវវិតក្កនោះ ។ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ថា អ្នកប្រាថ្នាត្រិះរិះនូវវិតក្កណា ក៏ត្រិះរិះនូវវិតក្កនោះបាន បើមិនប្រាថ្នាត្រិះរិះនូវវិតក្កណា ក៏មិនត្រិះរិះនូវវិតក្កនោះ ។

បទថា **អច្ឆេជ្ជិ តណ្ហំ** ប្រែថា កាត់ផ្ដាច់តណ្ហាបានហើយ ជាដើមនេះ បានពោលទុកក្នុងសព្វាសវសំវរសូត្រហើយ ។

" ចប់ អដ្ឋកថា វិតក្កសណ្ឋានសូត្រទី ២០ "

ការពណ៌នាសេចក្តីនៃមជ្ឈិមនិកាយ មូលបណ្ណាសកៈ
ដែលមាន ១២សូត្រ ក៏ចប់ស្រេចហើយដែរ ។
បបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ បឋមភាគ
ភាគ ២០ " ភាគ ២ "

រួមព្រះសូត្រដែលមានក្នុងវគ្គនេះគឺ
សម្មាទិដ្ឋិសូត្រទី៩ សតិប្បដ្ឋានសូត្រទី១០ ចុល្លសីហនាទសូត្រទី១
មហាសីហនាទសូត្រទី២ មហាទុក្ខក្ខន្ធសូត្រទី ៣ ចុល្លទុក្ខក្ខន្ធសូត្រទី៤ អនុមានសូត្រទី៥
ចេតោខិលសូត្រទី៦ វនបត្ថបរិយាយសូត្រទី៧
មធុបិណ្ឌិកសូត្រទី ៨ ទ្វេធាវិតក្កសូត្រទី ៩ វិតក្កសណ្ឋានសូត្រទី ១០
រួមជា ១២ សូត្រ។

